# សេចក្តីពន្យល់ អំពី ក្រមនីតិវិធីរដ្ឋប្បវេណី
## ភាគ ២ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ
## (គន្ថីទី ៦ គន្ថីទី ៧, គន្ថីទី ៨ និង ទី ៩)


**ជំពូកទី ១ ការអនុវត្តដោយបង្ខំ និង ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ** · · · · · ១

**ផ្នែកទី ១ អត្ថន័យនៃការអនុវត្តដោយបង្ខំ** · · · · · ១

**ផ្នែកទី ២ ប្រភេទនៃការអនុវត្ត** · · · · · ៧

**ផ្នែកទី ៣ ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ** · · · · · ១០

**ជំពូកទី ២ សេចក្តីពន្យល់ទូទៅ** · · · · · ១៣

**ផ្នែកទី ១ ស្ថាប័នអនុវត្ត** · · · · · ១៣

កថាភាគទី ១ ប្រភេទនៃស្ថាប័នអនុវត្ត · · · · · ១៣

កថាភាគទី ២ តុលាការអនុវត្ត · · · · · ១៣

១. គោលគំនិត · · · · · ១៣

២. សមត្ថកិច្ច · · · · · ១៣

៣. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត · · · · · ១៤

កថាភាគទី ៣ អាជ្ញាសាលា · · · · · ១៥

១. គោលគំនិត · · · · · ១៥

២. តួនាទីរបស់អាជ្ញាសាលា · · · · · ១៥

៣. ឋានៈរបស់អាជ្ញាសាលា នៅក្នុងការអនុវត្តដោយបង្ខំ · · · · · ១៦

៤. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយអាជ្ញាសាលា · · · · · ១៧

កថាភាគទី ៤ វិធីឧបាស្រ័យចំពោះការអនុវត្តខុសច្បាប់ · · · · · ១៩

១. អត្ថន័យ · · · · · ១៩

២. បណ្តឹងជំទាស់ · · · · · ១៩

៣. ការតវ៉ាចំពោះការអនុវត្ត · · · · · ២២

**ផ្នែកទី ២ ភាគីនៃការអនុវត្ត និង អ្នកតំណាងដោយអាណត្តិ** · · · · · ២៤

១. ភាគីនៃការអនុវត្ត · · · · · ២៤

២. អ្នកតំណាងដោយអាណត្តិ · · · · · ២៥

**ផ្នែកទី ៣ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ** · · · · · ២៦

កថាភាគទី ១ ទ្រព្យសម្បត្តិទទួលខុសត្រូវ · · · · · ២៦

១. គោលគំនិត · · · · · ២៦

២. វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ · · · · · ២៧

៣. ការទទួលខុសត្រូវដោយមានកម្រិត ២៨
កថាភាគទី ២ បណ្តឹងតវ៉ារបស់តតិយជន ២៩
១. គោលគំនិត ២៩
២. ទំហំនៃការអនុវត្ត ៣០
៣. មូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ៣១
៤. លក្ខណៈជាភាគី ៣២
៥. អំឡុងពេលនៃការដាក់ពាក្យបណ្តឹង ៣២
៦. នីតិវិធីនៃបណ្តឹង ៣៣

**ផ្នែកទី ៤ ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ ៣៤**

កថាភាគទី ១ សេចក្តីផ្តើម ៣៤
១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ៣៤
២. លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ៣៥
កថាភាគទី ២ លិខិតអនុវត្ត ៣៧
១. គោលគំនិត និង តួនាទីនៃលិខិតអនុវត្ត ៣៧
២. ប្រភេទផ្សេងៗនៃលិខិតអនុវត្ត ៣៨
៣. បណ្តឹងតវ៉ាចំពោះការទាមទារ ៤៥
កថាភាគទី ៣ រូបមន្តអនុវត្ត ៥៣
ចំណុចទី ១ អត្ថន័យនៃរូបមន្តអនុវត្ត ៥៣
១. គោលគំនិតនៃរូបមន្តអនុវត្ត ៥៣
២. ភាពចាំបាច់នៃរូបមន្តអនុវត្ត ៥៤
ចំណុចទី ២ នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត ៥៥
១. ស្ថាប័នផ្តល់រូបមន្តអនុវត្ត ៥៥
២. ចំណុចដែលត្រូវធ្វើការស្រាវជ្រាវ ៥៥
៣. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ៥៩
៤. វិញ្ញត្តិនៃរូបមន្តអនុវត្ត ៥៩
ចំណុចទី ៣ ការសង្គ្រោះពាក់ព័ន្ធនឹងការផ្តល់រូបមន្តអនុវត្ត ៦០
១. ការសង្គ្រោះសម្រាប់ម្ចាស់បំណុល ៦០
២. ការសង្គ្រោះសម្រាប់កូនបំណុល ៦១

**ផ្នែកទី ៥ ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមការអនុវត្តដោយបង្ខំ ៦៥**

១. ការបញ្ជាក់អំពីភាគីនៃការអនុវត្ត ៦៥
២. ការបញ្ជូនលិខិតអនុវត្ត ៦៥

៣. ការបញ្ជូនរូបមន្តអនុវត្ត និង លិខិតបញ្ជាក់ . . . . . . . . . . . . . . . . ៦៦
៤. ការមកដល់នៃពេលដែលត្រូវផ្តល់តាវកាលិក . . . . . . . . . . . . . . . ៦៦
៥. ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ . . . . . . . . . . . . . . ៦៧
៦. ការផ្តល់តាវកាលិកតប . . . . . . . . . . . . . . . . . . . ៦៧
៧. ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . . ៦៨
**ផ្នែកទី ៦ ដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . ៦៨**
កថាភាគទី ១ ពេលនៃការចាប់ផ្តើម និង ការបញ្ចប់ការអនុវត្តដោយបង្ខំ . . . . . . . . . ៦៩
១. ការចាប់ផ្តើមការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . . ៦៩
២. ការបញ្ចប់ការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . . ៦៩
កថាភាគទី ២ ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ . . . . . . . . . . . ៧០
១. ការផ្អាកការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . . . ៧០
២. ការលុបចោលការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . . ៧០
៣. មូលហេតុនៃការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ . . . . . . . . . ៧១
៤. មូលហេតុនៃការផ្អាកការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . ៧៤
៥. ការចាត់ចែងផ្អាកការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . ៧៥
៦. ការចាត់ចែងលុបចោលការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . ៧៦
៧. អានុភាពនៃការលុបចោលការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . ៧៧
**ផ្នែកទី ៧ សោហ៊ុយសម្រាប់ការអនុវត្ត ការដាក់ប្រាតិភោគ និង ការផ្ញើ . . . . . . . . . . ៧៧**
កថាភាគទី ១ សោហ៊ុយសម្រាប់ការអនុវត្ត . . . . . . . . . . . . . . . . ៧៧
កថាភាគទី ២ ការដាក់ប្រាតិភោគ និង ការផ្ញើ . . . . . . . . . . . . . . . ៧៩
**ជំពូកទី ៣ ប្រភេទផ្សេងៗនៃការអនុវត្តដោយបង្ខំ . . . . . . . . . . . . . . . . ៨០**
**ផ្នែកទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ . . . . . . ៨០**
កថាភាគទី ១ សេចក្តីពន្យល់ទូទៅ . . . . . . . . . . . . . . . . . . . ៨០
១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ . . ៨០
២. ភាពជាន់គ្នានៃការអនុវត្តដោយបង្ខំឱ្យសងជាប្រាក់ . . . . . . . . . . . . . ៨១
៣. លំហូរនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ៨២
៤. អានុភាពនៃការរឹបអូស . . . . . . . . . . . . . . . . . . . . ៨៣
៥. ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន និង ទ្រព្យសម្បត្តិដែលមិនអាចរឹបអូសបាន . . . . ៨៤
កថាភាគទី ២ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ . . . . . . . . . . . . . . . ៨៥
១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ . . . . . . . . . . . . . . . ៨៥
២. វិធីរឹបអូស . . . . . . . . . . . . . . . . . . . . . . . . ៨៥

៣. ការថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស . . . . . . . . . . . . . ៨៦
៤. អានុភាពនៃការរឹបអូស . . . . . . . . . . . . . . . . . . . . . ៨៧
៥. ការដាក់កម្រិតទៅលើការរឹបអូស . . . . . . . . . . . . . . . . . . ៨៨
៦. ការប្តូរជាប្រាក់ នូវទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស . . . . . . . . . . . . . ៨៨
៧. ករណីមានម្ចាស់បំណុលច្រើន - ការរួមបញ្ចូលរឿងក្តី . . . . . . . . . . . . . ៨៩
៨. ករណីមានម្ចាស់បំណុលច្រើន - ការទាមទារឱ្យចែកចំណែក . . . . . . . . . . . . ៩០
៩. ការចែកចំណែក . . . . . . . . . . . . . . . . . . . . . . . ៩១
កថាភាគទី ៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល . . . . . . . . . . . . ៩១
១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល . . . . . . . . . . . . ៩១
២. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស . . . . . . . . . . . . . . . . ៩២
៣. នីតិវិធីនៃការចេញដីកាសម្រេចរឹបអូស . . . . . . . . . . . . . . . . ៩៣
៤. អានុភាពនៃដីកាសម្រេចរឹបអូស . . . . . . . . . . . . . . . . . . ៩៤
៥. ការដាស់តឿនឱ្យកូនបំណុលទី ៣ ធ្វើសេចក្តីថ្លែងការណ៍ . . . . . . . . . . . . ៩៥
៦. ករណីមានម្ចាស់បំណុលច្រើន . . . . . . . . . . . . . . . . . . . ៩៦
៧. ការប្តូរជាប្រាក់ - ការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស . . . . . . . . ៩៧
៨. ការប្តូរជាប្រាក់ - ការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស . . . . . . . . . ៩៨
៩. ការផ្ញើប្រាក់ទុក ដោយកូនបំណុលទី ៣ . . . . . . . . . . . . . . . . ៩៨
១០. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ . . . . . . . . . . ៩៩
១១. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត . . . . . . . . . . ១០០
កថាភាគទី ៤ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ . . . . . . . . . . . . . ១០១
ចំណុចទី ១ កំណត់សំគាល់ទូទៅ . . . . . . . . . . . . . . . . . . ១០១
ចំណុចទី ២ ការលក់ដោយបង្ខំ . . . . . . . . . . . . . . . . . . . ១០៣
១. គោលគំនិត . . . . . . . . . . . . . . . . . . . . . . . . ១០៣
២. ការចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ . . . . . . . . . . . . . . . . . ១០៤
៣. ល័ក្ខខ័ណ្ឌនៃការលក់ . . . . . . . . . . . . . . . . . . . . . ១០៩
៤. ការអនុវត្តកាលបរិច្ឆេទនៃការលក់ . . . . . . . . . . . . . . . . . ១១៥
៥. នីតិវិធីនៃការអនុញ្ញាតឱ្យលក់ . . . . . . . . . . . . . . . . . . ១១៨
៦. ករណីមានការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការទាមទារឱ្យចែកចំណែកច្រើន . . ១២៨
កថាភាគទី ៥ ការអនុវត្តដោយបង្ខំចំពោះនាវា . . . . . . . . . . . . . . ១៣៣
កថាភាគទី ៦ នីតិវិធីចែកចំណែក . . . . . . . . . . . . . . . . . . ១៣៩
១. ស្ថាប័នដែលទទួលបន្ទុកធ្វើការចែកចំណែក . . . . . . . . . . . . . . . ១៣៩

២. នីតិវិធីចែកចំណែកដោយអាជ្ញាសាលា ១៤០
៣. នីតិវិធីចែកចំណែកដោយតុលាការ ១៤១
៤. បណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ១៥០
**ផ្នែកទី ២ បទប្បញ្ញត្តិពិសេសស្ដីពីការអនុវត្តសិទ្ធិប្រាតិភោគ ១៥៣**
កថាភាគទី ១ កំណត់សំគាល់ទូទៅ ១៥៣
១. អត្ថន័យនៃនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ១៥៣
២. បញ្ញត្តិពិសេសស្ដីពីលិខិតអនុវត្ត ១៥៣
៣. សមត្ថកិច្ចលើបណ្ដឹងពាក់ព័ន្ធនឹងការអនុវត្ត ១៥៤
៤. បញ្ញត្តិពិសេសពាក់ព័ន្ធនឹងការផ្អាក និង ការលុបចោលការអនុវត្ត ១៥៤
៥. ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់ ១៥៤
កថាភាគទី ២ ការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះចលនវត្ថុ ១៥៥
១. កំណត់សំគាល់ទូទៅ ១៥៥
២. ការចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ១៥៥
៣. ការធ្វើឧបាស្រ័យ ១៥៦
៤. នីតិវិធី ១៥៧
៥. នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ១៥៧
កថាភាគទី ៣ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ១៥៨
១. កំណត់សំគាល់ទូទៅ ១៥៨
២. ការចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ១៥៩
៣. នីតិវិធី ១៦០
កថាភាគទី ៤ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ១៦១
១. កំណត់សំគាល់ទូទៅ ១៦១
២. ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ១៦១
៣. នីតិវិធីនៃការលក់ដោយបង្ខំ ១៦២
៤. ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ ១៧២
៥. វិសាលភាពនៃម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក ១៧៥
កថាភាគទី ៥ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ១៧៦
១. កំណត់សំគាល់ទូទៅ ១៧៦
២. ការចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ១៧៦
៣. នីតិវិធី ១៧៧
**ផ្នែកទី ៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ១៧៨**

កថាភាគទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុបរិ . . . . . . . . . ១៧៨
១. កំណត់សំគាល់ទូទៅ . . . . . . . . . . . . . . . . . . . . . . ១៧៨
២. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍ ១៧៨
៣. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុជាក់លាក់ . ១៨១
៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យផ្តល់តាវកាលិកនូវចំនួនជាកំណត់នៃវត្ថុជំនួស . . . . . . . . . . . . . . . . . . . . . . . . . ១៨២
កថាភាគទី ២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពអ្វីមួយ . . . . ១៨៣
ចំណុចទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ . . . . . . . ១៨៣
១. កំណត់សំគាល់ទូទៅ . . . . . . . . . . . . . . . . . . . . . . ១៨៣
២. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន . . . ១៨៤
៣. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាព ដែលមិនអាចអនុវត្តជំនួសបាន . . ១៨៦
៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ . . . . . . . . . . . . ១៨៨
ចំណុចទី ២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ . . . . . . . ១៩០
១. ប្រភេទនៃសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ . . . . . . . . . . . . ១៩០
២. វិធីអនុវត្ត . . . . . . . . . . . . . . . . . . . . . . . . ១៩១
**ជំពូកទី ៤ នីតិវិធីនៃការចាត់ចែងរក្សាការពារ . . . . . . . . . . . . . ១៩៣**
**ផ្នែកទី ១ គោលគំនិត . . . . . . . . . . . . . . . . . . . . . . ១៩៣**
១. គោលបំណង និង ប្រភេទនៃការចាត់ចែងរក្សាការពារ . . . . . . . . . . . ១៩៣
២. រចនាសម្ព័ន្ធនៃនីតិវិធីចាត់ចែងរក្សាការពារ . . . . . . . . . . . . . ១៩៤
**ផ្នែកទី ២ ការរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . . . . . . ១៩៥**
កថាភាគទី ១ លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . ១៩៥
១. លក្ខខណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ . . . . . . . . . . . . . . . ១៩៥
២. ភាពចាំបាច់នៃការរក្សាការពារ . . . . . . . . . . . . . . . . . . ១៩៦
កថាភាគទី ២ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . . ១៩៧
១. តុលាការនៃការរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . . . . ១៩៧
២. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . ១៩៨
៣. វិធីនៃការវិនិច្ឆ័យ . . . . . . . . . . . . . . . . . . . . . . ១៩៨
៤. ដីកាសម្រេច . . . . . . . . . . . . . . . . . . . . . . . . ១៩៩
កថាភាគទី ៣ ឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន . . . . . . . . ២០០
១. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . ២០០
២. ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . . ២០២

៣. បណ្តឹងជំទាស់ . . . . . . . . . . . . . . . . . . . . . ២០៤
កថាភាគទី ៤ ការអនុវត្តរីបអូសជាបណ្តោះអាសន្ន . . . . . . . . . . . . . ២០៥
១. ល័ក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . . ២០៥
២. ប្រភេទផ្សេងៗនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន . . . . . . . . . ២០៦
៣. ការផ្អាក និង ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន . . . . . . . ២០៨
៤. ការបំលែងពីការរឹបអូសជាបណ្តោះអាសន្ន ទៅជាការអនុវត្តដោយបង្ខំ . . . . . ២០៩

**ផ្នែកទី ៣ ការចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . . . . . . ២០៩**

កថាភាគទី ១ ប្រភេទ ល័ក្ខខ័ណ្ឌ និង វិធីនៃការចាត់ចែងជាបណ្តោះអាសន្ន . . . . . . ២០៩
១. ប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . . . . ២០៩
២. ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ . . . . ២០៩
៣. ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន . . . . ២១០
៤. វិធីនៃការចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . . . . . ២១២
កថាភាគទី ២ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . . ២១៤
១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្តោះអាសន្ន . . . . . . . ២១៤
២. តុលាការមានសមត្ថកិច្ច . . . . . . . . . . . . . . . . . . . ២១៤
៣. វិធីនៃការវិនិច្ឆ័យ . . . . . . . . . . . . . . . . . . . . ២១៤
៤. ដីកាសម្រេច . . . . . . . . . . . . . . . . . . . . . . ២១៥
កថាភាគទី ៣ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន . . . . . . . ២១៥
១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្តោះអាសន្ន . . . . . . . ២១៥
២. អានុភាពនៃការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន . . . . . . . ២១៥
៣. ការលុបចោលការចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស . . . . . ២១៦
កថាភាគទី ៤ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . . . ២១៧
១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្តោះអាសន្ន . . . . . . . ២១៧
២. វិធីនៃការអនុវត្ត . . . . . . . . . . . . . . . . . . . . ២១៧
៣. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន . . . . . . . . . . . ២១៨

**ជំពូកទី ៥ អន្តរប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ . . . . . . . . . . . . . ២២១**

១. និយមន័យនៃអន្តរប្បញ្ញត្តិ . . . . . . . . . . . . . . . . . ២២១
២. វិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ . . . . . . . . . . . . ២២២
៣. វិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ . . . . . . . . . . . ២២៣
៤. អវសានប្បញ្ញត្តិ . . . . . . . . . . . . . . . . . . . . ២២៤

## សមាសភាពនៃក្រុមអ្នកនិពន្ធ ៖

| | |
|---|---|
| លោក Takeshita Morio | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Surugadai ( ប្រធាន) |
| លោកស្រី Homma Yoshiko | មេធាវី, ការិយាល័យមេធាវី Homma Yoshiko |
| លោក Kitamura Haruki | នាយកដ្ឋានរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក Ikeda Tatsuo | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Osaka, មេធាវី |
| លោក Matsushita Jun'ichi | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo |
| លោក Miki Koichi | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Keio |
| លោក Omura Hasahiko | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Chuo |
| លោក Takada Masahiro | សាស្ត្រាចារ្យ, សកលវិទ្យាល័យទីក្រុង Osaka |
| លោក Uehara Toshio | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក Yamamoto Kazuhiko | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក Yanagida Kozo | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

## សមាសភាពនៃក្រុមអ្នកបកប្រែ ៖

| | |
|---|---|
| លោក **សាកាណុ អ៊ីសេស** | ជំនាញការ , កម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ, អង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ( ភាសាខ្មែរ, ជប៉ុន) |
| លោកស្រី **គក បូរ៉េន** | អតីតជំនួយការជាន់ខ្ពស់, កម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ, អង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ( ភាសាខ្មែរ, អង់គ្លេស) |
| លោក **ស៊ឹម ទីរៈ** | អ្នកបកប្រែជាប់កិច្ចសន្យា ( ភាសាខ្មែរ, ជប៉ុន) |
| កញ្ញា **ម៉ាណាបេ ការណា** | មេធាវី, អតីតជំនាញការ , កម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ, អង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ( ភាសាជប៉ុន, អង់គ្លេស) |

# ជំពូកទី ១ ការអនុវត្តដោយបង្ខំ និង ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ

## ផ្នែកទី ១ អត្ថន័យនៃការអនុវត្តដោយបង្ខំ

### (i) **គោលគំនិតនៃការអនុវត្តដោយបង្ខំ**

(១) តើអ្វីទៅគឺជាការអនុវត្តដោយបង្ខំ ? : ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជន ដោយប្រើអំណាចរបស់រដ្ឋ ។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី មានគោលបំណងផ្តល់ទៅឱ្យភាគីឯកជនដែលមានសិទ្ធិដែលបានកំណត់ដោយច្បាប់ នូវការការពារសិទ្ធិទាំងនោះ (មាត្រា ២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ ចាប់ពីត្រឹមនេះតទៅ បទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបានយោងដោយចង្អុលតែទៅលើលេខនៃមាត្រាតែប៉ុណ្ណោះ ។ ចំពោះគោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី សូមមើលទំព័រទី ៤ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង" ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា) ។ ដើម្បីការពារដល់សិទ្ធិទាមទារ និង សិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះ ត្រឹមតែការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម ឬ សាលដីកា នៅមិនទាន់គ្រប់គ្រាន់ទេ ។ បន្ថែមពីលើនេះ ត្រូវមានការផ្តល់តាវកាលិកជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ (ឧទាហរណ៍ដូចជាការបង់ប្រាក់តាមចំនួនកំណត់ណាមួយ ការប្រគល់ចលនវត្ថុណាមួយជាក់លាក់ ជាដើម) ឬ ការផ្តល់តាវកាលិកជាប្រាក់ ដែលជាគោលបំណងនៃសិទ្ធិទាមទារឱ្យសងជាប្រាក់ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ យ៉ាងជាក់ស្តែង ផងដែរ ។ ឧទាហរណ៍ ក្នុងករណីដែល A មានសិទ្ធិទាមទារចំពោះ B ឱ្យ B ប្រគល់រថយន្តដែលជាកម្មវត្ថុនៃការលក់ទិញមកឱ្យខ្លួន នោះទោះបីជាតុលាការបានចេញសាលក្រម ឬ សាលដីកាកំណត់អំពីអត្ថិភាពនៃសិទ្ធិនោះហើយក៏ដោយ ក៏សិទ្ធិទាមទារនោះនៅមិនទាន់បានទទួលការការពារយ៉ាងពេញលេញនៅឡើយ រហូតទាល់តែរថយន្តត្រូវបានប្រគល់ដោយជាក់ស្តែងទៅឱ្យ A ។ ស្រដៀងគ្នានេះដែរ ឧទាហរណ៍ថា នៅពេល C មានហ៊ីប៉ូតែកលើអចលនវត្ថុរបស់ D ដែល D បានដាក់ដើម្បីធានាបំណុលរបស់ខ្លួនលើទឹកប្រាក់ចំនួន ១០ លានរៀល ចំពោះ C នោះបើទោះណាជាតុលាការបានចេញសាលក្រម ឬ សាលដីកាកំណត់អំពីអត្ថិភាពនៃហ៊ីប៉ូតែកនោះហើយក៏ដោយ ក៏ការការពារចំពោះសិទ្ធិប្រាតិភោគនោះ នៅមិនទាន់គ្រប់គ្រាន់ដែរ រហូតទាល់តែមានការសងប្រាក់ចំនួន ១០ លានរៀលនោះ ។ ហេតុនេះហើយ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬ កូនបំណុល មិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬ

សិទ្ធិប្រាតិភោគ តាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ជារបស់រដ្ឋ ។ អ្វីដែលត្រូវបានរៀបចំឡើងដើម្បីបំពេញភាពចាំបាច់នេះ គឺការអនុវត្តដោយបង្ខំ ។

(២) ការបែងចែករវាង ការអនុវត្តដោយបង្ខំ និង ការអនុវត្តក្នុងន័យទូលាយ : គោលបំណងដោយចំពោះនៃការអនុវត្តដោយបង្ខំ គឺដើម្បីសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជនដោយអំណាចរបស់រដ្ឋ (មាត្រា ៣៣៤) ។ ប្រសិនបើនីតិវិធីណាមួយ ពុំមានគោលបំណងធ្វើឱ្យសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគទេ ទោះបីជាខ្លឹមសារនៃសាលក្រម ឬ សាលដីកា ត្រូវបានសម្រេចដោយនីតិវិធីនោះក៏ដោយ ក៏នីតិវិធីនោះពុំមែនជានីតិវិធីនៃការអនុវត្តដោយបង្ខំដែរ ។ ឧទាហរណ៍ ការកែប្រែព័ត៌មានដែលបានចុះនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន បញ្ជីអចលនវត្ថុ ឬ បញ្ជីផ្សេងៗ ដោយផ្អែកលើសាលក្រម ឬ សាលដីកា ពុំមែនជានីតិវិធីនៃការអនុវត្តដោយបង្ខំទេ ។ ទោះជាយ៉ាងនេះក្តី ដោយសារតែការកែប្រែនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងការអនុវត្តដោយបង្ខំ នៅត្រង់ថា ទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលសាលក្រម ឬ សាលដីកាបានទទួលស្គាល់ ត្រូវបានសម្រេចជាក់ស្តែងនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន បញ្ជីអចលនវត្ថុ ឬ បញ្ជីផ្សេងៗយ៉ាងនេះ ទើបគេហៅ នីតិវិធីនេះថាជាការអនុវត្តក្នុងន័យទូលាយ ។

(៣) ការអនុវត្តដោយបង្ខំ ជាផ្នែកដ៏សំខាន់ នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី : ការអនុវត្តដោយបង្ខំ គឺជាផ្នែកដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។ ក៏ប៉ុន្តែ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីឯករាជ្យមួយ ដែលអនុវត្តដោយអាជ្ញាធររដ្ឋផ្សេងពីអាជ្ញាធរដែលអនុវត្តនីតិវិធីបណ្តឹង ដែលហៅក្នុងន័យចង្អៀតថា នីតិវិធីរដ្ឋប្បវេណី (នីតិវិធីដែលមានចែងចាប់ពីគន្ថីទី ១ ដល់គន្ថីទី ៤) ។ ការអនុវត្តដោយបង្ខំ មិនមែនជានីតិវិធីបន្ទាប់ ឬ បន្តពីនីតិវិធីបណ្តឹងទេ តែគឺជានីតិវិធីឯករាជ្យមួយ ដែលចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលដែលត្រូវការឱ្យមានការសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគរបស់ខ្លួន ។

(ក) ការអនុវត្តដោយបង្ខំ មានលក្ខណៈស្រដៀងគ្នាទៅនឹងនីតិវិធីបណ្តឹង នៅត្រង់ថា នីតិវិធីនេះ ក៏ត្រូវបានអនុវត្តក្នុងលក្ខណៈជានីតិវិធីនៃការតទល់ ដែលមានភាគីពីរដែលមានផលប្រយោជន៍ប្រឆាំងគ្នា បន្ថែមពីលើស្ថាប័នរដ្ឋដែលទទួលបន្ទុកក្នុងការផ្តល់យុត្តិធម៌ ។ ស្ថាប័នរដ្ឋដែលមានតួនាទីធ្វើការអនុវត្តដោយបង្ខំ ហៅថា "ស្ថាប័នអនុវត្ត" ។ ចំពោះភាគីទំនាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំវិញ ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំហៅថា "ម្ចាស់បំណុលនៃការអនុវត្ត" (ចាប់ពីត្រង់នេះតទៅ ហៅដោយសាមញ្ញថា "ម្ចាស់បំណុល") ចំណែកភាគីម្ខាងទៀត ហៅថា "កូនបំណុលនៃការអនុវត្ត" (ចាប់ពីត្រង់នេះតទៅ ហៅដោយសាមញ្ញថា "កូនបំណុល") ។ ប្រធាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំ រួមមាន ស្ថាប័នអនុវត្ត ម្ចាស់បំណុល និង កូនបំណុល ។ ក៏ប៉ុន្តែ ដោយសារថា នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលដាក់បន្ទុកនៃការអនុវត្តទៅលើកូនបំណុលដើម្បីឱ្យសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ឋានៈរបស់ភាគីទាំងពីរនៅក្នុងនីតិវិធីនេះ មិនស្មើគ្នាទេ គឺ ខុសពីឋានៈរបស់ភាគីទាំងសងខាងនៅក្នុងនីតិវិធីបណ្តឹង ។ ដោយព្រោះតែ

នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបានរៀបចំឡើង ដោយផ្អែកលើការសន្មតថា ម្ចាស់បំណុលគឺជាបុគ្គលដែលមានសិទ្ធិ ហើយកូនបំណុលគឺជាបុគ្គលដែលមានកាតព្វកិច្ច តែមិនបានអនុវត្តកាតព្វកិច្ច ដូច្នេះ គោលការណ៍នៃសិទ្ធិស្មើគ្នារវាងភាគីមិនត្រូវបានយកមកអនុវត្តនៅក្នុងនីតិវិធីនេះទេ ។ ជាងនេះទៅទៀត តតិយជនផ្សេងពីបុគ្គលដែលបានរៀបរាប់ខាងលើ អាចចូលរួមនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ក្នុងឋានៈជាជនដែលមានផលប្រយោជន៍ពាក់ព័ន្ធបាន ប៉ុន្តែ តតិយជននេះ មិនមែនជាប្រធាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំទាំងមូលទេ ។

(ខ) ការអនុវត្តដោយបង្ខំ ក៏ជានីតិវិធីនៃច្បាប់ដែរ ។ល័ក្ខខ័ណ្ឌទាមទារ ព្រមទាំងបែបបទនៃការអនុវត្តដោយបង្ខំ ត្រូវបានចែងនៅក្នុងច្បាប់ ហើយជាគោលការណ៍ ស្ថាប័នអនុវត្ត និង ភាគី មិនអាចធ្វើការកែប្រែល័ក្ខខ័ណ្ឌ ក៏ដូចជាបែបបទទាំងនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានឡើយ ។ ពិសេសជាងនេះទៅទៀត បទប្បញ្ញត្តិដែលចែងអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំ បានកំណត់នូវបែបបទក្នុងកម្រិតអតិបរមា ដែលអាចបានជាផលប្រយោជន៍ដល់ម្ចាស់បំណុល និង បែបបទក្នុងកម្រិតអប្បបរមា ដែលចាំបាច់សម្រាប់ការការពារសិទ្ធិរបស់កូនបំណុល ។ អាស្រ័យហេតុនេះហើយ គួរកត់សំគាល់ថា ការធ្វើសកម្មភាពបែបណាមួយដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុល ហួសអំពីទំហំដែលបានកម្រិតទុកនេះ មិនត្រូវបានអនុញ្ញាតឡើយ ។ ក៏ប៉ុន្តែ នេះមិនមែនបានន័យថា រាល់បទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ សុទ្ធតែជាបញ្ញត្តិអធិបញ្ញា (បញ្ញត្តិដែលត្រូវអនុវត្តជាដាច់ខាត) នោះទេ ។ បទប្បញ្ញត្តិមួយចំនួននៃការអនុវត្តដោយបង្ខំ គ្រាន់តែជាគោលការណ៍ណែនាំតែប៉ុណ្ណោះ ឯមួយចំនួនទៀត គ្រាន់តែមានអានុភាពក្នុងទំហំដែលថា សកម្មភាពនៃការអនុវត្តដោយបង្ខំដែលផ្ទុយនឹងបញ្ញត្តិនោះ មិនបាត់បង់សុពលភាពដោយស្វ័យប្រវត្តិឡើយ រហូតទាល់តែមានការលុបចោល ហើយម្យ៉ាងទៀត វិការៈនៃសកម្មភាពទាំងនោះ អាចជួសជុលឡើងវិញបាន ដោយការបោះបង់ ឬ ការបាត់បង់សិទ្ធិតវ៉ារបស់ភាគី (មាត្រា ៥៨) ។

(គ) នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជាដំណើរការនៃការសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជន ។ រចនាសម្ព័ន្ធនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (ចាប់ពីមាត្រា ៣៧៩ តទៅ) មានលក្ខណៈស្មុគស្មាញជាពិសេស ។ នីតិវិធីនៃការអនុវត្តដោយបង្ខំប្រភេទនេះ មានគោលដៅបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុមួយថ្មី រវាងភាគីទាំងពីរ ឬ ក្នុងករណីខ្លះ រវាងភាគី និង តតិយជន ក្នុងខណៈដែលនីតិវិធីចេះតែដើរទៅមុខ ហើយចុងក្រោយនឹងសម្រេចនូវសិទ្ធិទាមទារ ដោយការរួមបញ្ចូលនូវនីតិវិធីទាំងនោះ ។ ឧទាហរណ៍ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ចាប់ពីមាត្រា ៣៨៤ តទៅ) ដែលជាប្រភេទមួយនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ មានដំណាក់កាលជាច្រើន ដូចជា ការបាត់បង់សិទ្ធិចាត់ចែងរបស់កូនបំណុល ទៅលើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសដោយស្ថាប័នអនុវត្ត (មាត្រា ៣៨៥ និង ៣៨៦)

ការលក់វត្ថុដែលត្រូវបានរឹបអូសដោយស្ថាប័នអនុវត្ត (មាត្រា ៣៩៥) ការសងកាតព្វកិច្ចដោយការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ (មាត្រា ៣៩៩ និង មាត្រា ៤៨៧ តទៅ) ។ សកម្មភាពនានានៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនមានន័យត្រឹមតែជាដំណាក់កាលនៃនីតិវិធីប៉ុណ្ណោះទេ តែវាក៏មានអានុភាពក្នុងការបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុបែបនេះផងដែរ ។

(៤) ទំនាក់ទំនងរវាងនីតិវិធីបណ្តឹង និង នីតិវិធីនៃការអនុវត្តដោយបង្ខំ :

(ក) ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនតាមរយៈនីតិវិធីនៃការអនុវត្តដោយបង្ខំ ជាដំបូង ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងសុំឱ្យចេញសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិកសិន រួចមកបន្ទាប់ពីសាលក្រម ឬ សាលដីកានោះចូលជាស្ថាពរហើយ ត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរនោះ ។ ក៏ប៉ុន្តែ មិនមែនគ្រប់សាលក្រម ឬ សាលដីកា សុទ្ធតែអាចយកទៅធ្វើជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ បានទាំងអស់នោះទេ ។ ដោយសារថា សាលក្រម ឬ សាលដីកាដែលបញ្ជាក់ទំនាក់ទំនងគតិយុត្ត (រួមទាំងសាលក្រម ឬ សាលដីកាដែលច្រានចោលការទាមទារផង) និង សាលក្រមដែលបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ពុំមានអានុភាពអនុវត្តទេ (សូមមើលទំព័រ ១៤៤ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង" ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា) ដូច្នេះហើយ នីតិវិធីនៃការអនុវត្តដោយបង្ខំ មិនអាចធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាទាំងនោះបានឡើយ ។ ប៉ុន្តែ យ៉ាងណាក្តី សេចក្តីសម្រេចទៅលើប្រាក់ប្រដាប់ក្តីដែលមាននៅក្នុងសាលក្រម ឬ សាលដីកាទាំងនោះ មានលក្ខណៈជាសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិក ហើយដោយហេតុនេះ អាចយកទៅធ្វើជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំបាន ។

(ខ) ការអនុវត្តដោយបង្ខំ ក៏អាចធ្វើទៅបាន ក្នុងខណៈពេលដែលនីតិវិធីបណ្តឹង កំពុងមានដំណើរការដែរ ។ ការអនុវត្តដោយបង្ខំប្រភេទនេះ ត្រូវធ្វើឡើង ដោយផ្អែកលើសាលក្រម ឬ សាលដីកាចុងក្រោយដែលបង្គាប់ឱ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ១៩៦ និង មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច (ខ)) ឬ ដោយផ្អែកលើដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ៣២៨ និង មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច (ឃ)) នៅមុនពេលដែលសាលក្រមឬសាលដីកា ឬ ដីកាសម្រេចនោះ ចូលជាស្ថាពរ។

(គ) ការអនុវត្តដោយបង្ខំ ក៏អាចធ្វើទៅបាន ដោយពុំចាំបាច់មាននីតិវិធីបណ្តឹង នាំមុខដែរ ។ ការអនុវត្តដោយបង្ខំបែបនេះ ត្រូវធ្វើឡើង ដោយផ្អែកលើលិខិតយថាភូត ដែលធ្វើដោយសារការី (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច (ច)) ឬ ផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច (ជ)) ។

### (ii) សិទ្ធិទាមទារ សិទ្ធិប្រាតិភោគ និង លិខិតអនុវត្ត

(១) គោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបាន

កំណត់នៅក្នុងនីតិឯកជន ។ ក៏ប៉ុន្តែ នេះមិនមែនបានន័យថា ស្ថាប័នអនុវត្ត ត្រូវធ្វើការពិនិត្យឡើងវិញនូវអត្ថិភាពនៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគទាំងនោះ នៅពេលចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំនោះទេ ។ ដោយសារថា អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ត្រូវបានវិនិច្ឆ័យតាមនីតិវិធីបណ្តឹងរួចហើយ ដូច្នេះ ឧទាហរណ៍ថា បើមានសាលក្រម ឬ សាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្តល់តាវកាលិក នោះម្ចាស់បំណុលត្រូវមានលទ្ធភាពធ្វើការទាមទារឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រម ឬ សាលដីកានោះបាន ។ ប្រសិនបើស្ថាប័នអនុវត្តត្រូវធ្វើការពិនិត្យឡើងវិញនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ នៅពេលទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះ វាគ្មានប្រយោជន៍អ្វីដែលត្រូវទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិកនោះទេ ហើយវាក៏នឹងហុចឱកាសដោយមិនចាំបាច់ ទៅឱ្យកូនបំណុល ក្នុងការពន្យារពេលនៃការអនុវត្តកាតព្វកិច្ចរបស់ខ្លួនផងដែរ ដែលការណ៍នេះ វាផ្ទុយទៅនឹងគោលការណ៍សមភាពរវាងភាគីទាំងពីរ ហើយក៏មិនស្របទៅនឹងគោលបំណងនៃការអនុវត្តដោយបង្ខំដែរ ។

អាស្រ័យហេតុនេះ បើកាលណាមានសាលក្រម ឬ សាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្តល់តាវកាលិកហើយ នោះមិនគួរនឹងអនុញ្ញាតឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យឡើងវិញអំពីសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគទេ គឺស្ថាប័នអនុវត្ត ត្រូវចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំភ្លាម ដើម្បីសម្រេចនូវសិទ្ធិរបស់ម្ចាស់បំណុល ។ នៅក្នុងន័យនេះ ម្ចាស់បំណុល អាចនឹងទាមទារឱ្យអនុវត្តដោយបង្ខំបាន បើកាលណាខ្លួនបានទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិករួចហើយ ។ មានសំណួរចោទឡើងថា តើជានិច្ចកាល គេត្រូវតែបានទទួលសាលក្រម ឬ សាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្តល់តាវកាលិកសិន មុននឹងអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ យ៉ាងណា ។ សំណួរនេះអាចសួរម្យ៉ាងទៀតបានថា តើមានតែម្ចាស់បំណុលដែលបានទទួលសាលក្រម ឬ សាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្តល់តាវកាលិកតែប៉ុណ្ណោះទេ ដែលមានសិទ្ធិទាមទារឱ្យអនុវត្តដោយបង្ខំបាន ។ នេះគឺជាបញ្ហាមួយដែលពាក់ព័ន្ធទៅនឹងគោលនយោបាយវិស័យយុត្តិធម៌ ហើយចម្លើយតបទៅនឹងសំណួរនេះ អាចនឹងខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ក្រៅពីសាលក្រម ឬ សាលដីកាស្ថាពរ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់នូវអានុភាពដូចជាសាលក្រម ឬ សាលដីកាស្ថាពរ (អានុភាពអនុវត្ត) ទៅលើលិខិតផ្លូវការមួយចំនួន ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ប្រកបដោយកម្រិតនៃការជឿជាក់ខ្ពស់ និង ដែលត្រូវបានចាត់ទុកថា នឹងផ្តល់ភាពយុត្តិធម៌ ក៏ដូចជានឹងបម្រើឱ្យគោលបំណងនៃការអនុវត្តដោយបង្ខំ ប្រសិនបើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុល ត្រូវបានអនុញ្ញាតនោះ ដោយមានលិខិតផ្លូវការនោះ ។

ដូចបានរៀបរាប់ខាងលើ លិខិតផ្លូវការណាមួយ ដែលច្បាប់អនុញ្ញាតឱ្យមានអានុភាពនៃការអនុវត្តដោយបង្ខំ (អានុភាពអនុវត្ត) នោះហៅថា លិខិតអនុវត្ត ។ បន្ថែមពីលើសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលបានចូលជាស្ថាពរ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច (ក)) ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏ទទួលស្គាល់ផងដែរ នូវសាលក្រម ឬ សាលដីកាចុងក្រោយដែលបង្គាប់ឱ្យផ្តល់តាវកាលិក ហើយ

ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រាដដែល កថាខណ្ឌដដែល ចំណុច(ខ)), ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រាដដែល កថាខណ្ឌដដែល ចំណុច (ឃ)), លិខិតយថាភូតដែលធ្វើសារការីដែលត្រូវនឹងល័ក្ខខ័ណ្ឌទាមទារមួយចំនួន (មាត្រាដដែល កថាខណ្ឌដដែល ចំណុច (ច)), កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ដូចជាកំណត់ហេតុស្តីពីការសះជា ឬ កំណត់ហេតុស្តីពីការទទួលស្គាល់ការទាមទារ ជាអាទិ៍ (មាត្រាដដែល កថាខណ្ឌដដែល ចំណុច (ឈ)) ជាដើម ថាជាលិខិតអនុវត្ត ។ ជាងនេះទៅទៀត នៅក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ សាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ, កំណត់ហេតុស្តីពីការសះជាដែលបានទទួលស្គាល់អត្ថិភាពនៃសិទ្ធិប្រាតិភោគ (មាត្រា ៤៩៦ ចំណុច (ក)) ក៏ដូចជាលិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (មាត្រា ៤៩៦ ចំណុច (ខ)) ក៏ត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្តដែរ ។

(២) លិខិតអនុវត្តដែលបានរៀបរាប់ខាងលើ គឺជាលិខិតដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ប្រកបដោយកម្រិតនៃការជឿជាក់ខ្ពស់ ហើយកាលានុវត្តភាពដែលកូនបំណុលអាចធ្វើការការពារខ្លួន ត្រូវបានធានានៅក្នុងដំណើរការនៃការបង្កើតលិខិតទាំងនោះ ។ ចំណុចនេះ អាចនិយាយម៉្យាងទៀតបានថា ប្រសិនបើសិទ្ធិទាំងនោះពុំមានអត្ថិភាពទេ កូនបំណុលត្រូវបានផ្តល់ឱកាសក្នុងការរារាំងមិនឱ្យមានការរៀបចំ ឬ ការបង្កើតលិខិតនោះបាន ដោយធ្វើការអះអាងអំពីនត្ថិភាពនៃសិទ្ធិនោះ ។ ហេតុដូច្នេះហើយ ប្រសិនបើម្ចាស់បំណុលមានលិខិតទាំងនោះនៅក្នុងដៃ ដាច់ខាតត្រូវចាត់ទុកថាសិទ្ធិដែលបានរៀបរាប់នៅក្នុងលិខិតទាំងនោះ មានអត្ថិភាព និង ថាសិទ្ធិក្នុងការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតទាំងនោះ ត្រូវបានទទួលស្គាល់ ហើយស្ថាប័នអនុវត្តមិនត្រូវវិនិច្ឆ័យឡើងវិញអំពីអត្ថិភាពនៃសិទ្ធិទាំងនោះឡើយ ដែលការណ៍នេះគឺស្របទៅនឹងគោលការណ៍នៃសមភាពរវាងម្ចាស់បំណុល និង កូនបំណុល ។ ក៏ប៉ុន្តែ គេមិនអាចបដិសេធបានឡើយ ចំពោះការណ៍ដែលថា បើទោះបីជាមានសាលក្រម ឬ សាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយ ក៏សាលក្រម ឬ សាលដីកានោះ អាចនឹងត្រូវបានលុបចោល តាមរយៈនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ឬ បើមិនដូច្នោះទេ សិទ្ធិទាមទារដែលបានចូលជាស្ថាពរនោះ អាចនឹងត្រូវបានកែប្រែ ឬ រលត់ ដោយសារហេតុណាមួយដែលបានកើតឡើងនៅក្រោយពេលដែលសាលក្រម ឬ សាលដីកានោះចូលជាស្ថាពរ ។ ជាងនេះទៅទៀត នៅក្នុងករណីនៃលិខិតអនុវត្តក្រៅពីសាលក្រម ឬ សាលដីកា សិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងលិខិតទាំងនោះ អាចនឹងពុំមានអត្ថិភាពតាំងពីដំបូង ឬ អាចនឹងបានរលត់ដោយសារហេតុការណ៍ថ្មីណាមួយដែលបានកើតឡើងនៅក្រោយពេលធ្វើលិខិតទាំងនោះ ។ នៅក្នុងករណីបែបនេះ បើអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តទាំងនោះ ដោយពុំមានការកែប្រែសោះនោះ គឺវានឹងបញ្ច្រាសពីគោលបំណងដើមនៃការអនុវត្តដោយបង្ខំទៅវិញហើយ ។ ហេតុនេះហើយបានជាកូនបំណុលត្រូវបានអនុញ្ញាត

ឱ្យដាក់ពាក្យបណ្ដឹងតវ៉ា ដោយអះអាងអំពីនត្ថិភាពនៃសិទ្ធិ និង សុំកុំឱ្យមានការអនុវត្តដោយបង្ខំបាន (មាត្រា ៣៦៣) ។ នៅក្នុងន័យដដែលនេះ វាជាការពិតហើយដែលថាលិខិតអនុវត្ត ពុំធានាយ៉ាងដាច់ខាតអំពីអត្ថិភាពនៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគទេ ក៏ប៉ុន្តែ ដោយសារតែលិខិតទាំងនោះ មានលក្ខណៈជាលិខិតអនុវត្តដូចបានរៀបរាប់ខាងលើ គេអាចនិយាយបានថា លិខិតអនុវត្ត អាចមានអានុភាពស្មើគ្នានឹងសិទ្ធិតែម្ដង នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែក្នុងករណីដែលកូនបំណុលបានធ្វើសកម្មភាព ហើយបានទទួលសាលក្រម ឬ សាលដីកាដែលមិនអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះ ។ អានុភាពអនុវត្តនៃលិខិតអនុវត្ត មានន័យថាជាអានុភាពបែបនេះឯង ។

## ផ្នែកទី ២ ប្រភេទនៃការអនុវត្ត

### (i) ការអនុវត្តបែបបុគ្គលភាព និង ការអនុវត្តបែបសម្ភារៈ

នេះគឺជាការបែងចែកដោយឈរលើទស្សនវិស័យនៃកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ។ កម្មវត្ថុនៃការអនុវត្តបែបបុគ្គលភាព គឺមិនត្រឹមតែជាវត្ថុ ឬ ទ្រព្យសម្បត្តិដែលកូនបំណុលគ្រប់គ្រងប៉ុណ្ណោះទេ តែរួមទាំងរាងកាយ និង កំលាំងពលកម្មរបស់កូនបំណុល ដែលអាចយកទៅសម្រេចសិទ្ធិទាមទារផងដែរ ។ នៅក្នុងទ្វីបអឺរ៉ុប កាលពីសម័យដើម មានការអនុញ្ញាតឱ្យលក់កូនបំណុលឱ្យទៅធ្វើជាទាសករ ឬ ឱ្យបង្ខាំងកូនបំណុលឱ្យធ្វើការ ដើម្បីដោះបំណុលទៀតផង ។ ក៏ប៉ុន្តែ ប្រព័ន្ធច្បាប់ទំនើប ដែលគោរពបុគ្គលភាពឯកជន បានធ្វើការហាមឃាត់ជាគោលការណ៍ មិនឱ្យមានការអនុវត្តតាមវិធីណាមួយដែលរារាំងសេរីភាពរូបកាយរបស់បុគ្គលណាម្នាក់ ដើម្បីអនុវត្តកាតព្វកិច្ចដែលបានកំណត់នៅក្នុងនីតិឯកជនឡើយ ។ ក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានកម្រិតកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ត្រឹមតែជាវត្ថុ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុល (ការអនុវត្តបែបសម្ភារៈ) ហើយបានហាមដាច់ខាតនូវការអនុវត្តបែបបុគ្គលភាព ។

### (ii) ការអនុវត្តដើម និង ការអនុវត្តសងជំនួស

ការបែងចែកនេះ គឺផ្អែកទៅលើទម្រង់នៃការអនុវត្តកាតព្វកិច្ច តាមរយៈការអនុវត្ត ។ ការអនុវត្តដើមមានន័យថាជាវិធីសម្រេចនូវខ្លឹមសារដើមនៃកាតព្វកិច្ចផ្ដល់តាវកាលិក (ការប្រគល់វត្ថុ កាតព្វកិច្ចធ្វើសកម្មភាព កាតព្វកិច្ចមិនធ្វើសកម្មភាព) ចំពោះសិទ្ធិទាមទារគ្រប់ប្រភេទ ។ ចំណែកការអនុវត្តសងជំនួស មានន័យថា ក្នុងករណីដែលកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តទេ នោះតាវកាលិកទាំងអស់នឹងត្រូវប្ដូរទៅជាការបង់ជាទឹកប្រាក់វិញ ។ នៅក្នុងការសម្រេចសិទ្ធិទាមទារ មិនមែនមានករណីតិចតួចទេដែលទោះជាកូនបំណុលមិនផ្ដល់តាវកាលិកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិបានទទួលលទ្ធផលដូចគ្នាទៅនឹងការផ្ដល់តាវកាលិកនោះ ក៏ជាការគ្រប់គ្រាន់ហើយ ។ លើសពីនេះទៅទៀត នៅក្នុងករណីជាច្រើននៃការអនុវត្តតាមវិធីសងជាប្រាក់ ម្ចាស់សិទ្ធិមិនមានការពេញចិត្តទាំងស្រុងនោះទេ ។ ហេតុនេះហើយ ការអនុវត្តដើមគួរតែ

ចាត់ទុកថាជាគោលការណ៍ ។ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាត់ទុកការអនុវត្តដើមជាគោលការណ៍ដែរ (ចាប់ពីមាត្រា ៥២៤ តទៅ) ។ គួរកត់សំគាល់ថា ដោយឈរលើទស្សនវិស័យនៃច្បាប់សារធាតុ បណ្តឹងទាមទារឱ្យសងការខូចខាត ជំនួសឱ្យការផ្តល់តាវកាលិកដើម ដោយសារតែតាវកាលិកនោះបានក្លាយជាតាវកាលិកដែលមិនអាចអនុវត្តបាន ក៏អាចនឹងកើតមានឡើងបានដែរ ។ ក៏ប៉ុន្តែ នោះគឺជាបញ្ហាផ្សេងពីការអនុវត្តសងជំនួសដែលជាទម្រង់មួយនៃការអនុវត្ត នៅក្នុងការពិភាក្សាទីនេះ ។

(iii) **ការអនុវត្តដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និង ការអនុវត្តជំនួស**

នេះគឺជាការបែងចែកប្រភេទនៃការអនុវត្តដោយបង្ខំ ដោយឈរលើទស្សនវិស័យនៃវិធីដែលយកទៅប្រើប្រាស់សម្រាប់ការអនុវត្ត ។

(១) ការអនុវត្តដោយផ្ទាល់ គឺជាវិធីសម្រេចគោលបំណងនៃតាវកាលិកដោយផ្ទាល់ ដោយស្ថាប័នអនុវត្តដែលជាវិធីសមស្របសម្រាប់ការអនុវត្តកាតព្វកិច្ចដូចជាការសងប្រាក់ និង ការប្រគល់វត្ថុ ។ ដោយសារថា វិធីនៃការអនុវត្តបែបនេះ មិនទាមទារជាចាំបាច់នូវការសហការរបស់កូនបំណុលទេនោះ គេមិនចាំបាច់ដាក់ការគាបសង្កត់ទៅលើរូបកាយ ក៏ដូចជាឆន្ទៈសេរីរបស់កូនបំណុលឡើយ ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (គន្ថីទី ៦ ជំពូកទី ២) និង ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ អចលនវត្ថុ ជាអាទិ៍ (មាត្រា ៥២៤, មាត្រា ៥២៥ និង មាត្រា ៥២៦) ក្នុងចំណោមការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ គឺសុទ្ធតែត្រូវធ្វើឡើងតាមរយៈការអនុវត្តដោយផ្ទាល់នេះ ។ ការអនុវត្តសិទ្ធិប្រាតិភោគ ក៏ជាប្រភេទមួយនៃការអនុវត្តដោយផ្ទាល់ ដែលធ្វើឡើងដើម្បីសម្រេចសិទ្ធិទាមទារប្រាក់ ដែលត្រូវបានធានាដែរ ។

(២) ការអនុវត្តជំនួស គឺជាវិធីដែលអនុញ្ញាតឱ្យម្ចាស់បំណុល ឬ តតិយជន សម្រេចនូវខ្លឹមសារនៃតាវកាលិក ជំនួសកូនបំណុល ហើយប្រមូលសោហ៊ុយនោះជាប្រាក់ពីកូនបំណុលវិញ (មាត្រា ៥២៧) ។ វិធីនេះស័ក្តិសមសម្រាប់ការអនុវត្តកាតព្វកិច្ចដែលមិនសមស្របនឹងឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយផ្ទាល់បាន ប៉ុន្តែកាតព្វកិច្ចនោះមានលក្ខណៈមួយដែលថា បើទោះបីជាកូនបំណុលមិនសម្រេចនូវខ្លឹមសារនៃតាវកាលិកនោះដោយខ្លួនឯងក៏ដោយ ក៏ការសម្រេចឱ្យបាននូវលទ្ធផលដូចគ្នានោះជាការគ្រប់គ្រាន់ដែរសម្រាប់ម្ចាស់បំណុល ។ កាតព្វកិច្ចបែបនេះ មានដូចជាកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើសកម្មភាពណាមួយដែលអាចជំនួសបានជាអាទិ៍ ។

(៣) វិធានបង្ខំដោយប្រយោល គឺជាវិធីមួយដែលដាក់ការគាបសង្កត់ផ្នែកផ្លូវចិត្ត ទៅលើកូនបំណុលដើម្បីបង្ខំឱ្យកូនបំណុលនោះ អនុវត្តកាតព្វកិច្ចរបស់ខ្លួន (មាត្រា ៥២៨) ។ វិធានការណ៍នៃការគាបសង្កត់នោះមានដូចជា ការបង្គាប់ឱ្យបង់ប្រាក់ជាសំណងសងការខូចខាត ការដាក់ទោសដោយអាជ្ញាធររដ្ឋ ការដាក់ទណ្ឌកម្ម ឬ ការដាក់ពន្ធនាគារជាដើម ។ ដោយសារថាការបង្ខិតបង្ខំទៅលើរូបកាយ និង ឆន្ទៈសេរីរបស់កូនបំណុល មាន

លក្ខណៈខ្លាំងក្លាជាងការអនុវត្តដោយផ្ទាល់នោះ វិធីនេះ ត្រូវបានយកទៅប្រើប្រាស់សម្រាប់ការអនុវត្តកាតព្វកិច្ច ដែលមានលក្ខណៈមួយថា មានតែកូនបំណុលតែប៉ុណ្ណោះដែលអាចធ្វើសកម្មភាពសម្រេចនូវកម្មវត្ថុនៃតាវកាលិកបាន ។ កាតព្វកិច្ចបែបនេះ មានដូចជាកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយ ដែលមិនអាចជំនួសបាន ជាអាទិ៍ ។ ក៏ប៉ុន្តែ ដោយសារថា កាតព្វកិច្ចធ្វើសកម្មភាពដែលអាចជំនួសបាន ក៏អាចអនុវត្តតាមរយៈវិធានបង្ខំដោយប្រយោលដែរនោះ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏ទទួលស្គាល់ការអនុវត្តតាមវិធានបង្ខំប្រយោល ថាជាវិធីអនុវត្តចំពោះកាតព្វកិច្ចធ្វើសកម្មភាពដែលអាចជំនួសបានផងដែរ ។

### (iv) **ការអនុវត្តជាចម្បង និង ការអនុវត្តជាបណ្ដោះអាសន្ន**

ការអនុវត្តជាបណ្ដោះអាសន្ន គឺជាការអនុវត្តមួយបែបដែលធ្វើឡើងដើម្បីរក្សាស្ថានភាពបច្ចុប្បន្នឱ្យនៅដដែល ក្នុងគោលបំណងបង្ការមិនឱ្យមានឧបសគ្គណាមួយកើតឡើងចំពោះការអនុវត្ត នៅមុនពេលធ្វើការអនុវត្តដើម្បីសម្រេចសិទ្ធិទាមទារ ជាអាទិ៍ ដែលជាការអនុវត្តជាចម្បង ។ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានចែងអំពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន និង ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន (ចាប់ពីមាត្រា ៥៦២ តទៅ) ដែលជាប្រភេទនៃការអនុវត្តជាបណ្ដោះអាសន្ន ។ ដើម្បីធ្វើការអនុវត្តបែបនេះបាន ចាំបាច់ត្រូវតែបានទទួលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៤៥) ឬ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (មាត្រា៥៤៨) សិន ដែលទាំងនេះ គឺជាលិខិតអនុវត្តពិសេស ។ នីតិវិធីតុលាការសម្រាប់ការចេញសេចក្ដីបង្គាប់ទាំងនេះ (រឿងក្ដីរក្សាការពារ) និង សម្រាប់ការអនុវត្តបន្ទាប់នោះ ហៅជារួមថា ការចាត់ចែងរក្សាការពារ (គន្ថីទី ៧) ។

### (v) **ការអនុវត្តដោយឡែក និង ការអនុវត្តជាទូទៅ**

ការអនុវត្តដោយឡែក គឺជាការអនុវត្តដែលធ្វើឡើងចំពោះទ្រព្យសម្បត្តិដោយឡែកណាមួយរបស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគជាក់លាក់ណាមួយ ។ ចំណែកឯការអនុវត្តជាទូទៅ សំដៅទៅលើការអនុវត្តដែលធ្វើឡើងជារួម ចំពោះទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិនៃម្ចាស់បំណុលទាំងអស់របស់កូនបំណុល ។ នៅក្នុងច្បាប់សម័យដើម ការអនុវត្តជាទូទៅ ត្រូវបានធ្វើឡើងលើសពីភាពចាំបាច់ ដោយសារគេគិតថា ចរិតលក្ខណៈប្រកបដោយសីលធម៌ និង ឋានៈគតិយុត្តទាំងមូល ដែលមានលក្ខណៈឯកភាព បម្រើឱ្យគោលបំណងនៃការអនុវត្ត ។ ក៏ប៉ុន្តែ នៅក្នុងច្បាប់ទំនើបវិញ ការអនុវត្តជាទូទៅត្រូវបានធ្វើឡើងជាលក្ខណៈនៃនីតិវិធីក្ស័យធន នៅក្នុងករណីដែលទ្រព្យសម្បត្តិរបស់កូនបំណុល មិនគ្រប់គ្រាន់នឹងសងទៅម្ចាស់បំណុលទាំងអស់ តែប៉ុណ្ណោះ ។ ការអនុវត្តដោយបង្ខំដែលមានចែងនៅក្នុងគន្ថីទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សុទ្ធសឹងតែជាការអនុវត្តដោយឡែកទាំងអស់ ។

## ផ្នែកទី ៣ ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ

(i) **អត្ថន័យជាទម្រង់ និង អត្ថន័យជាសារធាតុនៃច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ**

ដូចបានរៀបរាប់ពីខាងដើម ប្រព័ន្ធនៃការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធមួយដែលធ្វើការសម្រេចដោយ បង្ខំនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ របស់បុគ្គលឯកជន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីផ្តល់ការការពារដល់បុគ្គលឯកជនដែលជាម្ចាស់សិទ្ធិទាំងនោះ ហើយនីតិវិធីនេះ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។ ហេតុនេះហើយបានជាបទប្បញ្ញត្តិជាច្រើន ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏ដូចជាពាក់ព័ន្ធទៅនឹងស្ថាប័នអនុវត្ត ត្រូវបានចងក្រងជាផ្នែកមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺនៅក្នុងគន្ថីទី ៦ ស្តីពីការអនុវត្តដោយបង្ខំ និង គន្ថីទី ៧ ស្តីពីការចាត់ចែងរក្សាការពារ ។ នៅក្នុងអត្ថន័យជាទម្រង់ ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ត្រូវសំដៅទៅលើគន្ថីទី ៦ និង គន្ថីទី ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ។

ក៏ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានបទប្បញ្ញត្តិទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃប្រព័ន្ធនៃការអនុវត្ត ដែលមានចែងនៅក្នុងផ្នែកផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី (ឧទាហរណ៍ដូចជាមាត្រា ១៩៦, មាត្រា ១៩៧, មាត្រា ២៧១, និង មាត្រា ២៨២ ពាក់ព័ន្ធទៅនឹងសាលក្រម ឬ សាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង មាត្រា ៣២៨ ពាក់ព័ន្ធទៅនឹងដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) និង មានចែងនៅក្នុងច្បាប់ដទៃទៀតក្រៅពីក្រមនីតិវិធីរដ្ឋប្បវេណី (ឧទាហរណ៍ដូចជាច្បាប់ស្តីពីអាជ្ញាសាលា) ផងដែរ ។ នៅក្នុងអត្ថន័យជាសារធាតុ ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំត្រូវសំដៅទៅលើបទប្បញ្ញត្តិដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធ និង នីតិវិធីនៃប្រព័ន្ធនៃការអនុវត្តទាំងអស់នេះ ។

(ii) **កិច្ចសន្យានៃការអនុវត្ត**

(១) អត្ថន័យ : ដូចបានរៀបរាប់ពីខាងដើម ការអនុវត្តដោយបង្ខំ គឺជានីតិវិធីមួយ ដែលល័ក្ខខ័ណ្ឌទាមទារក៏ដូចជា បែបបទរបស់វា មានចែងនៅក្នុងច្បាប់ ហើយជាគោលការណ៍ ស្ថាប័នអនុវត្ត និង ភាគី មិនត្រូវបានអនុញ្ញាត ឱ្យធ្វើការកែប្រែល័ក្ខខ័ណ្ឌ និង បែបបទទាំងនោះ ដោយសេរីបានទេ ។ ក៏ប៉ុន្តែ ដោយសារថាបទប្បញ្ញត្តិទាំងអស់ដែលពាក់ព័ន្ធនឹងការអនុវត្ត ពុំមែនជាបទប្បញ្ញត្តិអធិបញ្ញាទេនោះ ភាគីទាំងសងខាងមិនត្រូវបានហាមឃាត់ជានិច្ចកាល មិនឱ្យកំណត់បែបបទ និង របៀបនៃការអនុវត្តដោយបង្ខំ ផ្សេងអំពីច្បាប់ឡើយ ។ ដូចទើបនឹងបានរៀបរាប់មកនេះ ការព្រមព្រៀងរវាងភាគីពាក់ព័ន្ធនៃការអនុវត្តដោយបង្ខំ នៅក្នុងការកំណត់អំពីបែបបទ និង របៀបនៃការអនុវត្តដោយបង្ខំ ដែលមានលក្ខណៈបែបណាមួយផ្សេងអំពីបទប្បញ្ញត្តិនៃច្បាប់ ហៅថា "កិច្ចសន្យានៃការអនុវត្ត" ។ កិច្ចសន្យាបែបនេះរួមមាន (i) កិច្ចសន្យាពង្រីកទំហំនៃការអនុវត្តដែលបន្ធូរបន្ថយ ល័ក្ខខ័ណ្ឌទាមទារនៃការអនុវត្ត ឬ សកម្មភាពនៃការអនុវត្តដោយឡែក ឬ ដែលពង្រីកវិសាលភាពនៃបែបបទ និង កម្មវត្ថុនៃការអនុវត្ត ដើម្បីឱ្យបានជាប្រយោជន៍ដល់ម្ចាស់បំណុល

នៃការអនុវត្ត និង (ii) កិច្ចសន្យាបង្រួមទំហំនៃការអនុវត្តដែលបន្ថែមល័ក្ខខ័ណ្ឌទាមទារនៃការអនុវត្ត រឹតបន្តឹងលទ្ធភាពក្នុងការអនុវត្ត ដាក់កម្រិតទៅលើកម្មវត្ថុ ឬ បទបញ្ជានៃការអនុវត្ត ព្រមទាំងកំណត់ជាក់លាក់នូវបែបបទនៃការអនុវត្ត ដើម្បីឱ្យបានជាប្រយោជន៍ដល់កូនបំណុល ។ កិច្ចសន្យាប្រភេទទីមួយ ពន្លាតនូវសិទ្ធិអំណាចខាងផ្លូវច្បាប់របស់ស្ថាប័នអនុវត្ត និង នាំឱ្យមានការគម្រាមកំហែងទៅលើផលប្រយោជន៍ដ៏តិចតួចដែលច្បាប់ធានាដល់កូនបំណុល ។ ហេតុដូច្នេះហើយ ជាគោលការណ៍ មិនគួរឱ្យមានកិច្ចសន្យាប្រភេទទីមួយនេះទេ ។

(២) ប្រភេទ និង អានុភាព : កិច្ចសន្យានៃការអនុវត្ត រួមមានការព្រមព្រៀងនៅក្រោមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ និង កិច្ចសន្យានៅក្រោមនីតិឯកជន ។

(ក) ការព្រមព្រៀងដែលមានការទទួលស្គាល់យ៉ាងច្បាស់លាស់ ពីសំណាក់ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ (ឧទាហរណ៍ មាត្រា ៤៣១ កថាខណ្ឌទី ៤) មានអានុភាពដោយចំពោះ តាមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ។ ការព្រមព្រៀងនៅក្នុងករណីបែបនេះ គឺជាការព្រមព្រៀងនៅក្រោមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ។ ហេតុដូច្នេះហើយបានជាការព្រមព្រៀងបែបនេះ មានអានុភាពចងចំពោះស្ថាប័នអនុវត្ត ។ ចំពោះនីតិវិធីនៃការអនុវត្ត ឬ ការចាត់ចែងនៅក្នុងការអនុវត្ត ដែលសម្រាប់តទល់នឹងការព្រមព្រៀងបែបនេះ គឺថា ភាគីដែលមានការពាក់ព័ន្ធ អាចនឹងទាមទារឱ្យលុបចោលការព្រមព្រៀងនោះ ដោយអះអាងអំពីភាពមិនស្របច្បាប់របស់វា តាមរយៈការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤) ឬ តាមរយៈបណ្តឹងជំទាស់ (មាត្រា ៣៨៣) ។

(ខ) កិច្ចសន្យាបង្រួមទំហំនៃការអនុវត្ត ដូចជាការព្រមព្រៀងថានឹងមិនធ្វើការអនុវត្ត (ការព្រមព្រៀងលើការមិនអនុវត្តដោយបង្ខំ) ការព្រមព្រៀងលើការកម្រិតទ្រព្យសម្បត្តិដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្ត ជាអាទិ៍ ពុំមានអានុភាពចងដោយផ្ទាល់ ចំពោះស្ថាប័នអនុវត្តទេ ហើយក៏ពុំមានអានុភាពធ្វើឱ្យការអនុវត្តប្រឆាំងនឹងកិច្ចសន្យានោះ មិនស្របច្បាប់នោះដែរ ។ ការព្រមព្រៀងប្រភេទនេះ គួរចាត់ទុកថា ជាការព្រមព្រៀងដែលមានអានុភាពធ្វើការផ្លាស់ប្តូរនូវចំណែកនៃការទាមទារ នៅក្រោមច្បាប់សារធាតុ ឬ ជាកិច្ចសន្យានៅក្រោមនីតិឯកជន ដែលបង្កើតកាតព្វកិច្ចធ្វើ ឬ មិនធ្វើសកម្មភាព ទៅលើម្ចាស់បំណុលដែលស្វែងរកការអនុវត្តដោយបង្ខំ ។ ដោយសារថាការព្រមព្រៀងទាំងនេះ ពុំមានលក្ខណៈផ្ទុយទៅនឹងគោលនយោបាយសាធារណៈ យ៉ាងជាក់ស្តែងទេនោះ ទើបបានជាការព្រមព្រៀងទាំងនេះ មានអានុភាពជាកិច្ចសន្យានៅក្រោមនីតិឯកជន ។

ក៏ប៉ុន្តែ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្ទុយទៅនឹងការព្រមព្រៀងទាំងនេះ នោះនឹងមានបញ្ហាចោទឡើងថាតើការសង្គ្រោះបែបណាដែលត្រូវផ្តល់ទៅឱ្យកូនបំណុល ។ ខុសពីករណីនៃការព្រមព្រៀងនៅក្រោមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ នីតិវិធីនៃការអនុវត្ត ឬ សកម្មភាពនៃការអនុវត្ត

ដែលធ្វើឡើងដោយស្ថាប័នអនុវត្ត មិនផ្ទុយនឹងច្បាប់ទេ ហើយការតវ៉ាចំពោះការអនុវត្ត ក៏ដូចជាបណ្ដឹងជំទាស់ក៏មិនត្រូវបានអនុញ្ញាតដែរ ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើគ្រាន់តែអនុញ្ញាតឱ្យមានការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើការបំពានកិច្ចសន្យានោះ ការសង្គ្រោះបែបនេះ នឹងមានលក្ខណៈកាន់តែវែងឆ្ងាយហើយ ។ ហេតុនេះហើយ គេអាចនឹងពិចារណាអំពីវិធីមួយជំនួសវិញ គឺការធ្វើបណ្ដឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣) ដែលជាការសង្គ្រោះចំពោះករណីដែលការអនុវត្ត ពុំមានភាពសមស្របតាមច្បាប់សារធាតុ ។ ដូច្នេះ ប្រសិនបើម្ចាស់បំណុលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទោះបីជាមានការព្រមព្រៀងលើការមិនអនុវត្តដោយបង្ខំក៏ដោយ ហើយការអនុវត្តដែលបានសុំនោះ បានចាប់ផ្ដើមហើយ កូនបំណុលអាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីទទួលការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ហើយផ្អាកការអនុវត្តនោះ (មាត្រា ៣៦៧ កថាខណ្ឌទី ១ និង មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច(ក)) រួចអាចនឹងទទួលសេចក្ដីសម្រេចដែលកំណត់ថាមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ហើយផាត់ចោលការអនុវត្តដោយបង្ខំនោះតែម្ដង (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច (ខ)) ។

# ជំពូកទី ២ សេចក្តីពន្យល់ទូទៅ

## ផ្នែកទី ១ ស្ថាប័នអនុវត្ត

### កថាភាគទី ១ ប្រភេទនៃស្ថាប័នអនុវត្ត

សមត្ថភាព និង អំណាចធ្វើការអនុវត្តដោយបង្ខំ ធ្លាក់ទៅលើស្ថាប័នជាតិ ។ ស្ថាប័នដែលទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំ ដែលជាអំណាចរបស់រដ្ឋ ហៅថា "ស្ថាប័នអនុវត្ត" ( មាត្រា ៣៣៦ កថាខណ្ឌទី ១) ។ ដោយសារថា នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និង ឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះវាមិនចាំបាច់ដែលតុលាការដែលទទួលពាក្យបណ្តឹង ត្រូវតែជាស្ថាប័នអនុវត្តទេ ។ ផ្ទុយទៅវិញ ដោយគិតអំពីតម្រូវការនៃភាពងាយស្រួល និង ភាពឆាប់រហ័ស ការដាក់ការទទួលបន្ទុកទៅឱ្យស្ថាប័នមួយផ្សេងទៀត គឺជាការសមស្រប ។ ហេតុដូច្នេះហើយបានជាច្បាប់ចែងឱ្យតុលាការអនុវត្ត និង អាជ្ញាសាលា ធ្វើជាស្ថាប័នអនុវត្ត ( មាត្រា ៣៣៦ កថាខណ្ឌទី ២) ។

តុលាការអនុវត្ត និង អាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ ។ ស្ថាប័នទាំងពីរនេះ មានចរិតលក្ខណៈផ្សេងពីគ្នា ហេតុនេះហើយបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង ទៅតាមប្រភេទបែបបទនៃការអនុវត្ត ជាអាទិ៍ ។ ឧទាហរណ៍ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលតម្រូវឱ្យមានសកម្មភាពជាក់ស្តែងដោយប្រើប្រាស់កម្លាំង ត្រូវបានដាក់ជាបន្ទុកទៅឱ្យអាជ្ញាសាលា ចំណែកឯការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលជាទង្វើបញ្ញាមានលក្ខណៈអរូបី និង ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលត្រូវធ្វើឡើងតាមនីតិវិធីដ៏មធ្យ័ត ត្រូវបានទម្លាក់ជាបន្ទុកទៅឱ្យតុលាការអនុវត្ត ។

### កថាភាគទី ២ តុលាការអនុវត្ត

#### ១. គោលគំនិត

តុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬ ដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ (តុលាការតាមនិយមន័យចង្អៀត) ហៅថា តុលាការអនុវត្ត ។ មាត្រា ៣៣៦ កថាខណ្ឌទី ៣ ចែងថា "សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត" ។ យោងតាមបញ្ញត្តិនេះ ស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមនៃសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជាតុលាការអនុវត្ត ។

#### ២. សមត្ថកិច្ច

(១) ក្នុងករណីដែលតុលាការអនុវត្តដើរតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះ រួមមាន ការអនុវត្តដោយបង្ខំ និង ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ( មាត្រា ៤០២), ការអនុវត្តដោយបង្ខំ និង

ការអនុវត្តសិទ្ធិលើប្រាតិភោគ ចំពោះអចលនវត្ថុ (មាត្រា ៤១៨), ការអនុវត្តដោយបង្ខំ និង ការអនុវត្តសិទ្ធិលើប្រាតិភោគ ចំពោះនាវា (មាត្រា ៤៥៦), ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុ ក្នុងករណីវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជន (មាត្រា ៥២៦), និង ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ (មាត្រា ៥២៧ និង មាត្រា ៥២៨) ។ សូមកត់សំគាល់ថា សមត្ថកិច្ចតាមដែនដីនៅក្នុងករណីនីមួយៗ ក៏ត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិទាំងនេះដែរ (សូមមើលមាត្រា ៣៣៦ កថាខណ្ឌទី ៣) ។

(២) នៅពេលដើរតួជាស្ថាប័នសម្រាប់ផ្តល់កិច្ចសហការ និង មើលខុសត្រូវលើនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាសាលា តុលាការអនុវត្តមានសិទ្ធិអំណាចនៅក្នុងការអនុញ្ញាតឱ្យអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់ (មាត្រា ៣៨០), ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨១) ជាអាទិ៍ ។

(៣) ចំពោះហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការអនុវត្ត តុលាការអនុវត្តក៏មានសមត្ថកិច្ចលើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត (មាត្រា ៣៨៤ កថាខណ្ឌទី ១) ជាអាទិ៍ ដែរ (សូមកត់សំគាល់ថា ការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។ នៅក្នុងករណីនេះ ដោយសារថាសាលាដំបូងនោះមិនដើរតួនាទីជាស្ថាប័នអនុវត្ត គេមិនហៅតុលាការនោះថាជាតុលាការអនុវត្តទេ ។ សូមមើលមាត្រា ៣៣៦ កថាខណ្ឌទី ៤ និង មាត្រា ៣៨៤ កថាខណ្ឌទី ២) ។

សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ (មាត្រា ៣៤៦) ។

## ៣. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត

(១) ទម្រង់នៃសេចក្តីសម្រេច : ជាទូទៅ ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្តី (សកម្មភាពធ្វើការសម្រេចសេចក្តី) ហើយទម្រង់នៃសេចក្តីសម្រេចនេះគឺជាដីកាសម្រេច (មាត្រា ៣៣៧ កថាខណ្ឌទី ១) ។ បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬ ជនផ្សេងទៀតដែលពាក់ព័ន្ធបាន (មាត្រា ៣៣៧ កថាខណ្ឌទី ២) ។ វិធានការនៃការអនុវត្តដែលកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៣៧ ឆ្លុះបញ្ចាំងនូវទស្សនទានដ៏ទូលំទូលាយ ដែលមិនត្រឹមតែរួមបញ្ចូលនូវសកម្មភាពរបស់តុលាការអនុវត្តដែលធ្វើឡើងនៅក្នុងនីតិវិធីនៃការអនុវត្ត ដូចជាការរឹបអូស ការប្តូរជាប្រាក់ ការចែកចំណែក ជាអាទិ៍ ប៉ុណ្ណោះទេ គឺថែមទាំងរួមបញ្ចូលនូវការចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្ត និង សកម្មភាពជាក់ស្តែងផ្សេងទៀតដែលមិនមែនជាការសម្រេចសេចក្តី ផងដែរ ។ ជាគោលការណ៍ ក្នុងករណីដែលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រោមទម្រង់ជាការចេញដីកាសម្រេច តុលាការនោះមានឆន្ទានុសិទ្ធិនៅក្នុងការកំណត់ថា

ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ (មាត្រា ៣៣៥ និង មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ហើយប្រសិនបើតុលាការមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចសួរភាគីបាន (មាត្រា ៣៣៥ និង មាត្រា ១១៤ កថាខណ្ឌទី ២) ។ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ វិសាលភាពនៃអ្នកដែលតុលាការអាចសួរបាន ត្រូវបានពង្រីក គឺថាតុលាការអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ថែមទៀត បន្ថែមពីលើការសួរភាគី ។ ជាងនេះទៅទៀត នៅពេលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រៅពីការចាត់ចែងក្រោមទម្រង់ជាការចេញដីកាសម្រេច (ឧទាហរណ៍ដូចជាការរៀបចំឯកសារលំអិតអំពីវត្ថុដូចមានចែងនៅក្នុងមាត្រា ៤៣៤ ជាដើម) តុលាការអាចសួរជនទាំងនេះបាន ប្រសិនបើចាំបាច់ ។

(២) វិធីឧបាស្រ័យ : វិធីឧបាស្រ័យចំពោះសេចក្តីសម្រេចរបស់តុលាការអនុវត្ត រួមមានបណ្តឹងជំទាស់ និងការតវ៉ាចំពោះការអនុវត្ត (សូមមើលកថាភាគទី ៤) ។

## កថាភាគទី ៣ អាជ្ញាសាលា

### ១. គោលគំនិត

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ (មាត្រា ២៤៦ កថាខណ្ឌទី ៣) និង ធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់ ។ ស្ថាប័នយុត្តាធិការនេះ ស្ថិតនៅក្រោមក្រសួងយុត្តិធម៌ និង មានសមាសភាពជាមន្ត្រីរាជការដែលមានឈ្មោះថាជាអាជ្ញាសាលាដែលបំពេញការងារ នៅសាលាដំបូងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ (មាត្រា ២ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។

អាជ្ញាសាលា ជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ចេញពីក្នុងចំណោមបុគ្គលដែលបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារមួយចំនួន (មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។ ក៏ប៉ុន្តែ ខុសពីមន្ត្រីរាជការទូទៅ អាជ្ញាសាលាមិនទទួលប្រាក់ខែពីរដ្ឋទេ គឺទទួលចំណូលជាប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំ ចំពោះការអនុវត្តមុខងាររបស់ខ្លួនវិញ ដែលនេះគឺជាចរិតលក្ខណៈពិសេសមួយរបស់អាជ្ញាសាលា (មាត្រា ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។

### ២. តួនាទីរបស់អាជ្ញាសាលា

(១) អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួន នៅតំបន់សមត្ថកិច្ចរបស់សាលាដំបូងដែលខ្លួនបំពេញការងារ (មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។ ការកម្រិតទៅលើតំបន់នៃការបំពេញមុខនាទីនេះ មានឥទ្ធិពលដោយប្រយោលទៅលើការកំណត់ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា ។

(២) នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យ ក្នុងនាមជា

ស្ថាប័នអនុវត្ត រួមមាន ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ចាប់ពីមាត្រា ៣៨៤ តទៅ), ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ (ចាប់ពីមាត្រា ៥០០ តទៅ), ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ (មាត្រា ៥២៤) និង ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ (មាត្រា ៥២៥) ។

(៣) ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំដែលតុលាការអនុវត្តជាអ្នកទទួលបន្ទុកក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំណុចដូចតទៅ : ការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា ៤២៥), ការអនុវត្តការលក់ (មាត្រា ៤៣៦ កថាខណ្ឌទី ៣), ការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា (មាត្រា ៤៥៥) ជាដើម ។ លើសពីនេះ នៅក្នុងនីតិវិធីនៃការអនុវត្តរក្សាការពារ អាជ្ញាសាលាមានសិទ្ធិអំណាចនៅក្នុងការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ថែមទៀត (មាត្រា ៥៧១) ។

### ៣. ឋានៈរបស់អាជ្ញាសាលា នៅក្នុងការអនុវត្តដោយបង្ខំ

(១) ទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល : អាជ្ញាសាលា ត្រូវធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំ ដោយផ្អែកលើពាក្យសុំត្រឹមត្រូវតាមច្បាប់ របស់ម្ចាស់បំណុល និង ដោយអនុលោមទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់ ។ ទំនាក់ទំនងនេះ គឺជាទំនាក់ទំនងរវាងបុគ្គលឯកជន និង អាជ្ញាធររដ្ឋ នៅក្រោមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី មិនមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេ ។ គេអាចនិយាយម្យ៉ាងទៀតបានថា អាជ្ញាសាលាគឺជាស្ថាប័នយុត្តាធិការឯករាជ្យ ហើយបើទោះបីជាប្រព័ន្ធនៃការបង់ប្រាក់កម្រៃត្រូវបានអនុវត្តដូចបានរៀបរាប់ខាងលើក៏ដោយ ក៏អាជ្ញាសាលាពុំមែនជាអ្នកតំណាងរបស់ម្ចាស់បំណុលឡើយ ។ អាជ្ញាសាលា ត្រូវធ្វើការអនុវត្តដោយបង្ខំ នៅក្នុងឆន្ទានុសិទ្ធិ និង ការទទួលខុសត្រូវរបស់ខ្លួន ។ ទោះបីជាអាជ្ញាសាលាធ្វើតាមការណែនាំរបស់ម្ចាស់បំណុលក៏ដោយ ប្រសិនបើសកម្មភាពនៃការអនុវត្តដោយបង្ខំនោះខុសច្បាប់ នោះអាជ្ញាសាលាមិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសកម្មភាពនោះបានទេ ។ អាជ្ញាសាលាអាចគោរពតាមឆន្ទៈរបស់ម្ចាស់បំណុលបាន ចំពោះទំហំ និង កម្រិតនៃការអនុវត្តដោយបង្ខំ ប៉ុន្តែ ប្រសិនបើការណែនាំ ឬ សំណូមពរនោះ ខុសច្បាប់ អាជ្ញាសាលា មិនត្រូវធ្វើតាមឡើយ ។

ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា គឺជាការប្រើអំណាចអនុវត្តរបស់រដ្ឋ នោះមន្ត្រីដែលទទួលបន្ទុកការអនុវត្ត ពុំមែនជានិយោជិតរបស់ម្ចាស់បំណុលឡើយ ។ ហេតុនេះហើយ ប្រសិនបើអាជ្ញាសាលាបង្កឱ្យមានការខូចខាតដល់កូនបំណុល ឬ តតិយជន ដោយសារការធ្វើសកម្មភាពអនុវត្តដោយបង្ខំ នោះម្ចាស់បំណុលមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក្នុងនាមជានិយោជកឡើយ ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលឱ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវ ដោយចេតនា ឬ ដោយការធ្វេសប្រហែស ហើយបង្កឱ្យមានការខូចខាតដល់អ្នកដទៃ នោះម្ចាស់បំណុលអាចនឹងមានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល

ដោយផ្ទាល់ខ្លួន (ឧទាហរណ៍ដូចជាករណីដែលម្ចាស់បំណុលកុហកថាអចលនវត្ថុណាមួយជាកម្មសិទ្ធិរបស់កូនបំណុល ហើយឱ្យអាជ្ញាសាលារឹបអូសអចលនវត្ថុនោះ ទាំងដែលខ្លួនដឹងថាវាជាកម្មសិទ្ធិរបស់តតិយជនសោះ) ។

(២) ទំនាក់ទំនងជាមួយនឹងកូនបំណុល និង តតិយជន : អាជ្ញាសាលា មានសិទ្ធិប្រើប្រាស់អំណាចបង្ខំទៅលើកូនបំណុល និង តតិយជន នៅក្នុងទំហំដែលចាំបាច់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ហើយត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពនេះ ដោយស្របច្បាប់ ។

ម្យ៉ាងទៀត ដូចបានរៀបរាប់ខាងលើ ដោយសារថាទំនាក់ទំនងរវាងម្ចាស់បំណុល និង អាជ្ញាសាលា ពុំមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេនោះ ម្ចាស់បំណុលមិនអាចប្រគល់ទៅឱ្យអាជ្ញាសាលា នូវសិទ្ធិតំណាងតាមច្បាប់ឯកជន ដូចជាការទទួលការសង ការផ្សះផ្សា ជាអាទិ៍ បានឡើយ ។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និង ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ អាជ្ញាសាលាមានសិទ្ធិទទួលការសងដោយស្ម័គ្រចិត្ត ទៅតាមច្បាប់បាន (មាត្រា ៣៨៤ កថាខណ្ឌទី ៦ និង មាត្រា ៥២៥ កថាខណ្ឌទី ៤) ។ គោលបំណងនៃបញ្ញត្តិនេះ គឺដើម្បីកុំឱ្យមានការខាតបង់នៅក្នុងការអនុវត្ត ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមានឆន្ទៈធ្វើការសងដោយស្ម័គ្រចិត្ត ។

(៣) ទំនាក់ទំនងជាមួយនឹងតុលាការអនុវត្ត : តុលាការអនុវត្ត និង អាជ្ញាសាលា សុទ្ធតែជាស្ថាប័នឯករាជ្យរបស់រដ្ឋ រៀង១ខ្លួន ហើយអាជ្ញាសាលា ពុំមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ ។ ច្បាប់អនុញ្ញាតឱ្យតុលាការអនុវត្តផ្តល់ការណែនាំ ប្រគល់សិទ្ធិ និង បង្គាប់អាជ្ញាសាលា នៅក្នុងករណីជាក់លាក់មួយចំនួន ប៉ុន្តែ បទប្បញ្ញត្តិទាំងនេះ ត្រូវបានរៀបចំឡើង ដោយយកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន និង ដោយគិតពិចារណាទៅលើចរិតលក្ខណៈរបស់ស្ថាប័ននីមួយ១ផងដែរ ។ ដោយឡែកចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យ ពីសាលាដំបូងដែលខ្លួនស្ថិតនៅ ចំពោះមុខងាររបស់ខ្លួន (មាត្រា ៦ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ។ ក៏ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាអ្នកតែងតាំង មានសិទ្ធិអំណាចដាក់ទណ្ឌកម្មខាងផ្នែកវិន័យ ចំពោះការបំពានលើមុខងារ ជាអាទិ៍ របស់អាជ្ញាសាលា) ។

(៤) ការដកហូត : ក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាតិ ឬ មានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងទៀត ជាមួយនឹងភាគី អាជ្ញាសាលានោះ ត្រូវដកហូតចេញពីការអនុវត្តមុខការរបស់ខ្លួន ដើម្បីជៀសវាងភាពមន្ទិលសង្ស័យអំពីភាពត្រឹមត្រូវនៅក្នុងការបំពេញមុខនាទីនោះ (មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។

## ៤. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយអាជ្ញាសាលា

(១) ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ : អាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍

បើជននោះទាមទារ ( មាត្រា ៣៤១) ។

(២) ការអនុវត្តសិទ្ធិឆែកឆេរ : អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូស នៅក្នុងទំហំចាំបាច់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ។ នៅក្នុងករណីនេះ ប្រសិនបើមានភាពចាំបាច់ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្ត បើកទ្វារដែលចាក់សោរ ទូដែក និង ប្រអប់ផ្សេងទៀតបាន ហើយប្រសិនបើកូនបំណុលនៃការអនុវត្ត បដិសេធមិនព្រមធ្វើតាមទេ អាជ្ញាសាលាអាចចាត់វិធានការណ៍ចាំបាច់ដើម្បីបើករបស់ទាំងនោះ ដោយប្រើកម្លាំង ( មាត្រា ៣៨៥ កថាខណ្ឌទី ២) ។

(៣) ការបំបាត់នូវការប្រឆាំង : ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះ អាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ ស្ថាប័នរដ្ឋផ្សេងទៀតដែលទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំបាត់នូវការប្រឆាំងនោះបាន ( មាត្រា ៣៣៨ កថាខណ្ឌទី ១) ។

(៤) អ្នកសង្កេតការណ៍ : នៅពេលចូលទៅទីកន្លែងរស់នៅរបស់ជនណាម្នាក់ ដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងម្ចាស់នៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយ ឬ អ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ត្រូវហៅរកអ្នកសង្កេតការណ៍ដែលអាចជាមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលយល់ឃើញថាសមរម្យអាចធ្វើជាអ្នកសង្កេតការណ៍បាន ។ ក្នុងករណីដែលអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំ ដោយប្រើកម្លាំង ឬ ដោយមានជំនួយពីនគរបាល ជាអាទិ៍ តាមបញ្ញត្តិនៃមាត្រា ៣៣៨ កថាខណ្ឌទី ១ នោះបើទោះបីជាមិនចូលទៅក្នុងទីកន្លែងរស់នៅក៏ដោយ ក៏ចាំបាច់ត្រូវមានអ្នកសង្កេតការណ៍ដែរ ( មាត្រា ៣៣៩) ។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីសង្កេតទៅលើភាពត្រឹមត្រូវនៅក្នុងការអនុវត្ត និង ដើម្បីបង្កើតភស្តុតាងសម្រាប់ពេលអនាគតផង ។

(៥) ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់ : ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅរបស់ជនណាម្នាក់ នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់បានកំណត់ ឬ នៅក្នុងចន្លោះពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងប្រាំមួយព្រឹក អាជ្ញាសាលាត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញដីកាបង្គាប់ ។ បន្ថែមពីលើនេះ នៅពេលបំពេញមុខនាទី អាជ្ញាសាលាត្រូវបង្ហាញលិខិតដែលបញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតនោះផងដែរ ( មាត្រា ៣៤០) ។ ការកំណត់បែបនេះ គឺដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កូនបំណុល ដោយពុំមានភាពចាំបាច់ ។

(៦) ការធ្វើកំណត់ហេតុ : អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន ( មាត្រា ២០ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។ អាជ្ញាសាលា ត្រូវរក្សាទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំ

ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងរឿងក្ដីដែលមានការអនុវត្តដោយបង្ខំ ដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ (សូមមើលមាត្រា ៣៧៨ កថាខណ្ឌទី ២ អំពីការមើលសំណុំរឿងដែលរក្សាទុកដោយអាជ្ញាសាលា) ។

(៧) វិធីឧបាស្រ័យ : វិធីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយអាជ្ញាសាលា ត្រូវធ្វើឡើងតាមរយៈការតវ៉ាចំពោះការអនុវត្ត (សូមមើលកថាភាគទី ៤) ។

## កថាភាគទី ៤ វិធីឧបាស្រ័យចំពោះការអនុវត្តខុសច្បាប់

### ១. អត្ថន័យ

នៅពេលអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តត្រូវអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិនានា ហើយត្រូវធ្វើការអនុវត្តនោះឱ្យស្របទៅតាមច្បាប់ ។ ប៉ុន្តែយ៉ាងណាក៏ដោយ ភាពត្រឹមត្រូវតាមច្បាប់មិនមែនសុទ្ធតែត្រូវបានធានារហូតនោះទេ ។ នៅក្នុងករណីដែលមានការអនុវត្តដោយបង្ខំ ផ្ទុយនឹងច្បាប់ ដូចជាក្នុងករណីដែលសកម្មភាពណាមួយរបស់ស្ថាប័នអនុវត្ត បំពានទៅលើក្រមនីតិវិធី ជាដើម យើងមានវិធីឧបាស្រ័យចំពោះការអនុវត្ត ដែលរួមមានបណ្ដឹងជំទាស់ និង ការតវ៉ាចំពោះការអនុវត្ត ។ បណ្ដឹងជំទាស់ គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្ដី រីឯការតវ៉ាចំពោះការអនុវត្តវិញ គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមិនអាចប្ដឹងជំទាស់បាន និង ចំពោះការចាត់ចែងការអនុវត្តដោយអាជ្ញាសាលា (មាត្រា ៣៤៣ និង មាត្រា ៣៤៤) ។

ការអនុវត្តដោយបង្ខំដែលខុសច្បាប់ សំដៅលើមានន័យថាជាសកម្មភាពនៃការអនុវត្តដែលធ្វើឡើងដោយបំពានទៅលើច្បាប់ និង បទប្បញ្ញត្តិផ្សេងៗដែលចែងអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំ ហើយវាមិនមែនមានន័យថាជាការអនុវត្តមិនត្រឹមត្រូវដែលមិនស្របទៅតាមទំនាក់ទំនងគតិយុត្តសារធាតុ ។ នៅក្នុងន័យនេះ ត្រូវតែមានការបែងចែកឱ្យច្បាស់លាស់រវាងការអនុវត្តខុសច្បាប់ និង ការអនុវត្តមិនត្រឹមត្រូវ ។ សូមមើលផ្នែកទី ៤ កថាភាគទី ១ នៃជំពូកនេះ អំពីការបែងចែករវាងការអនុវត្តខុសច្បាប់ និង ការអនុវត្តមិនត្រឹមត្រូវ ព្រមទាំងភាពខុសគ្នានៃការសង្គ្រោះចំពោះការអនុវត្តទាំងពីរនេះ ។

### ២. បណ្ដឹងជំទាស់

(១) អត្ថន័យ និង វិសាលភាពនៃការអនុវត្ត : ដូចបានរៀបរាប់ខាងលើ ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ជាទូទៅ ត្រូវបានធ្វើឡើង ក្រោមទម្រង់ជាការសម្រេចសេចក្ដី ពោលគឺការចេញដីកាសម្រេច ។ នៅក្នុងការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ប្រសិនបើការចេញដីកាសម្រេច បំពានទៅលើក្រមនីតិវិធី និង ផ្ទុយនឹងច្បាប់ នោះវិធីឧបាស្រ័យ ចំពោះដីកាសម្រេចនោះ គឺតាមរយៈបណ្ដឹងជំទាស់ ដែលនេះគឺជាគោលការណ៍ (មាត្រា ៣៣៥ និង មាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច គ) ។ ក៏ប៉ុន្តែ មានបញ្ញត្តិចែងជាទូទៅ

ថា បណ្តឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ (មាត្រា ២៥៩ កថាខណ្ឌទី ២) ។ ហេតុនេះហើយ បណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏អាចធ្វើឡើងបាន តែក្នុងករណីដែលមានបញ្ញត្តិជាក់លាក់នៅក្នុងមាត្រានីមួយៗនៃគន្ថីទី ៦ ដែរ (ឧទាហរណ៍ មាត្រា ៤០៣ កថាខណ្ឌទី ១១, មាត្រា ៤១៩ កថាខណ្ឌទី ៣, មាត្រា ៤៤៤ កថាខណ្ឌទី ១, មាត្រា ៤៥៧ កថាខណ្ឌទី ៧, មាត្រា ៤៧៥ កថាខណ្ឌទី ១ ជាអាទិ៍) ។ អនុលោមតាមមាត្រា ៣៣៥ ដោយផ្អែកទៅលើការយកមកអនុវត្តដូចគ្នា នូវបញ្ញត្តិដែលមានចែងចាប់ពីគន្ថីទី ២ ដល់គន្ថីទី ៤ នោះបញ្ញត្តិនៃមាត្រា ២៥៩ កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នា ចំពោះបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ប្រសិនបើបណ្តឹងជំទាស់មិនអាចធ្វើបានទេ នោះការតវ៉ាចំពោះការអនុវត្ត ត្រូវបានអនុញ្ញាត ដូចនឹងរៀបរាប់ខាងក្រោម ។

(២) បុគ្គលដែលមានសិទ្ធិដាក់ពាក្យបណ្តឹងជំទាស់បាន : បុគ្គលដែលអាចដាក់ពាក្យបណ្តឹងជំទាស់បាន គឺបុគ្គលដែលទទួលរងការប៉ះពាល់ដោយសារដីកាសម្រេច ដែលរួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និង អាចជាតតិយជនផងដែរ (ឧទាហរណ៍ដូចជាកូនបំណុលទី ៣ ដែលត្រូវបានហាមឃាត់មិនឱ្យសងបំណុល ដោយដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល (មាត្រា ៤០៣ កថាខណ្ឌទី ១១)) ។

(៣) នីតិវិធីនៃបណ្តឹងជំទាស់ : ដើម្បីប្តឹងជំទាស់ ចាំបាច់ត្រូវដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរ ទៅតុលាការដើម នៅក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច (មាត្រា ៣៣៥, មាត្រា ៣០១ និង មាត្រា ៣០៣ ។ ចាប់ពីត្រឹមនេះតទៅ នឹងមិនសរសេរអំពីការយោងទៅមាត្រា ៣៣៥ ទៀតទេ) ។ នីតិវិធីនៃការសម្រេចសេចក្តីលើបណ្តឹងជំទាស់ គឺជានីតិវិធីនៃការចេញដីកាសម្រេច ដែលមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ (មាត្រា ៣០៦) ។

ក៏ប៉ុន្តែ ខុសពីករណីទូទៅ បើទោះជាមានបញ្ញត្តិនៃមាត្រា ៣០៥ កថាខណ្ឌទី ១ ក៏ដោយ បណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនផ្អាកអានុភាពនៃដីកាសម្រេចដើមទេ (មាត្រា ៣៤៣ កថាខណ្ឌទី ១) ។ នេះក៏ព្រោះថា ប្រសិនបើអានុភាពនៃដីកាសម្រេចដើម ត្រូវបានផ្អាកដោយសារតែពាក្យបណ្តឹងជំទាស់ នឹងអាចធ្វើឱ្យមានការប្រើសិទ្ធិប្តឹងជំទាស់ដោយបំពាន ដើម្បីពន្យារពេលនៃការអនុវត្តដោយបង្ខំ ដោយមិនសមហេតុផល ។

ផ្ទុយទៅវិញ ប្រសិនបើការអនុវត្តមិនត្រូវបានផ្អាកទាល់តែសោះ បើទោះជាមានការដាក់ពាក្យបណ្តឹងជំទាស់ក៏ដោយនោះ នឹងអាចធ្វើឱ្យបាត់បង់នូវប្រសិទ្ធិភាពនៃការសង្គ្រោះដោយបណ្តឹងជំទាស់បាន ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីចែងថា តុលាការនៃបណ្តឹងជំទាស់ ត្រូវកំណត់ថាតើបណ្តឹងជំទាស់អាច ឬមិនអាចនឹងត្រូវបានទទួលស្គាល់ថាសមហេតុផល ដោយយោងទៅតាមកាលៈទេសៈជាក់ស្តែង នៅក្នុងករណីដោយឡែកនីមួយៗ ហើយដោយផ្អែកលើការកំណត់នោះ អាចចេញដីកាសម្រេចដែលមានលក្ខណៈជាបណ្តោះអាសន្ន ដូចជាផ្អាកការអនុវត្តដោយបង្ខំ ជាអាទិ៍ រហូតដល់សេចក្តីសម្រេចអំពីបណ្តឹងជំទាស់មាន

អានុភាព (មាត្រា ៣៨៣ កថាខណ្ឌទី ២) ។ ដីកាសម្រេចដែលមានលក្ខណៈជាបណ្តោះអាសន្នទាំងនេះ រួមមាន ដីកាសម្រេចបង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ និង ដីកាសម្រេចបង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងមូល ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ (មាត្រា ៣៨៣ កថាខណ្ឌទី ២ ចំណុច ក និង ចំណុច ខ) ។ ករណីទីមួយគឺការផ្អាកអានុភាពនៃដីកាសម្រេចដើម រួមមាន ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំដែលផ្អែកលើដីកាសម្រេចដើម និង ដីកាសម្រេចផ្អាកការបង្កើតអានុភាពនៃដីកាសម្រេចដើម ។ ឧទាហរណ៍នៃដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំដែលផ្អែកលើដីកាសម្រេចដើម មានដូចជាដីកាសម្រេចដែលបង្គាប់ឱ្យផ្អាកការអនុវត្តចាត់ចែងរក្សាការពារ ដោយផ្អែកលើដីកាសម្រេចចាត់ចែងរក្សាការពារ (ដីកាសម្រេចដើម) នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំនូវអចលនវត្ថុ (មាត្រា ៤២៩ កថាខណ្ឌទី ១) ក្នុងករណីដែលមានបណ្តឹងជំទាស់ចំពោះដីកាសម្រេចដើមនោះ (មាត្រា ៤២៩ កថាខណ្ឌទី ៤) ជាអាទិ៍ (ការដាក់ឯកសារចម្លងយថាភូតនៃដីកាសម្រេចបង្គាប់ឱ្យផ្អាកនេះ ទៅអាជ្ញាសាលា បង្កលទ្ធភាពឱ្យមានការផ្អាកដោយជាក់ស្តែង នូវការអនុវត្តការចាត់ចែងរក្សាការពារនោះ ។ សូមមើលមាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ក) ។ ដីកាសម្រេចផ្អាកការបង្កើតអានុភាពនៃដីកាសម្រេចដើម គឺជាដីកាសម្រេចដែលរារាំងអានុភាពនៃដីកាសម្រេចដែលមិនបានលើកឡើងនូវការអនុវត្តដោយស្ថាប័នអនុវត្តដើម មិនឱ្យកើតឡើងបាន ។ ឧទាហរណ៍នៃដីកាសម្រេចផ្អាកការបង្កើតអានុភាពនៃដីកាសម្រេចដើមនេះ មានដូចជា ដីកាសម្រេចដែលបង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចអំពីប្រាក់បំណាច់ក្នុងករណីដែលមានបណ្តឹងជំទាស់ (មាត្រា ៤៦០ កថាខណ្ឌទី ៤) ចំពោះដីកាសម្រេចអំពីប្រាក់បំណាច់សម្រាប់អ្នកថែរក្សាគ្រប់គ្រង នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា (មាត្រា ៤៦០ កថាខណ្ឌទី ៣) ។ ចំពោះគោលបំណងនៃការផ្អាកការអនុវត្តដោយបង្ខំ ក្នុងករណីដែលមានបណ្តឹងជំទាស់ ជាទូទៅ គោលបំណងនេះត្រូវបានសម្រេចដោយដីកាសម្រេចប្រភេទទីមួយខាងលើ ពោលគឺដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំដែលផ្អែកលើដីកាសម្រេចដើម (ដីកាសម្រេចផ្អាកការបង្កើតអានុភាពនៃដីកាសម្រេចដើម ត្រូវបានទាមទារតែនៅក្នុងករណីពិសេសតែប៉ុណ្ណោះ) ។ ទោះបីជាយ៉ាងនេះក៏ដោយ ដីកាសម្រេចប្រភេទទីពីរនេះ (ដីកាសម្រេចបង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្ត) នៅតែអាចចេញបាន ដោយសារថាដីកាសម្រេចប្រភេទនេះ អាចនឹងមានភាពចាំបាច់ នៅក្នុងករណីមួយចំនួន ។ ឧទាហរណ៍ ប្រសិនបើម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែកដាក់ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក (មាត្រា ៤២៦ កថាខណ្ឌទី ៤) នីតិវិធីនៃការអនុវត្តដោយបង្ខំទាំងមូល មិនត្រូវបានផ្អាកដោយសារតែការផ្អាកអានុភាពនៃដីកាសម្រេចនេះដោយតុលាការ ដោយប្រើវិធីចេញដីកាសម្រេចប្រភេទទីមួយទេ ដែលការណ៍នេះអាចនឹងនាំឱ្យឈានទៅដល់ការបញ្ចប់ដំណើរការនីតិវិធីទាំងមូល និង ការចែកចំណែកផងដែរ ហើយវានឹងធ្វើឱ្យបណ្តឹងជំទាស់ត្រូវបាត់បង់អត្ថន័យរបស់វា ។ អាស្រ័យហេតុនេះហើយបានជានៅក្នុងករណីបែបនេះ ចាំបាច់ត្រូវប្រើវិធីទីពីរ ដើម្បីផ្អាក

នីតិវិធីនៃការអនុវត្តដោយបង្ខំទាំងស្រុង (ឬ នីតិវិធីនៃការចែកចំណែក) តែម្តង ។

## ៣. ការតវ៉ាចំពោះការអនុវត្ត

(១) អត្ថន័យ និង វិសាលភាពនៃការអនុវត្ត : ការតវ៉ាចំពោះការអនុវត្តគឺជាវិធីឧបាស្រ័យដែលមានភាពងាយស្រួល និង ឆាប់រហ័សជាងការដាក់ពាក្យបណ្តឹងជំទាស់ ។ ការតវ៉ាចំពោះការអនុវត្ត អាចធ្វើឡើងចំពោះ (i) ការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្តឹងជំទាស់បាន និង (ii) ការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និង ការយឺតយ៉ាវ ឬ ការធ្វេសប្រហែស ក្នុងការចាត់ចែងការអនុវត្តនោះ (មាត្រា ៣៨៤ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២) ។ ឧទាហរណ៍ ចំពោះដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនូវអចលនវត្ថុ ដោយតុលាការអនុវត្ត មិនអាចប្តឹងជំទាស់បានទេ (សូមមើលមាត្រា ៤១៩ កថាខណ្ឌទី ៣) ក៏ប៉ុន្តែ ការតវ៉ាចំពោះការអនុវត្ត អាចធ្វើឡើងបាន ។ ដោយសារថា ដីកាសម្រេចលើកចោលពាក្យសុំឱ្យលក់ដោយបង្ខំ គឺជាការចាត់ចែងចុងក្រោយ ហើយមានភាពចាំបាច់ត្រូវតែអនុញ្ញាតឱ្យអាចប្តឹងជំទាស់បាន នៅក្នុងដំណាក់កាលនោះ ។ ផ្ទុយទៅវិញ ដោយសារថា ដីកាសម្រេចចាប់ផ្តើម មិនមែនជាការចាត់ចែងចុងក្រោយទេនោះ ទើបបានជាអនុញ្ញាតឱ្យត្រឹមតែការតវ៉ាចំពោះការអនុវត្តប៉ុណ្ណោះ ដែលជាវិធីងាយស្រួល ជាងបណ្តឹងជំទាស់ ។ ការតវ៉ាចំពោះការអនុវត្ត ក៏អាចធ្វើឡើងបានដែរ ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលពុំមានចរិតលក្ខណៈជាដីកាសម្រេច ។

ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា ពុំមែនជាការសម្រេចសេចក្តីទេនោះ ទើបបានជាបណ្តឹងជំទាស់មិនអាចធ្វើឡើងបានឡើយចំពោះសកម្មភាពទាំងនោះ តែអាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ។

(២) មូលហេតុនៃការតវ៉ាចំពោះការអនុវត្ត : មូលហេតុនៃការតវ៉ាចំពោះការអនុវត្ត ត្រូវបានកម្រិតត្រឹមមូលហេតុដែលថា ស្ថាប័នអនុវត្តបានបំពានទៅលើបញ្ញត្តិនៃនីតិវិធី ដែលខ្លួនត្រូវពិនិត្យ និង គោរពតាម ។ ដូច្នេះហើយ ជាឧទាហរណ៍ ដោយសារថា នត្ថិភាពនៃសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្តមិនមែនជាបញ្ហាដែលអាជ្ញាសាលា ត្រូវធ្វើការពិនិត្យទេនោះ មូលហេតុនេះ មិនអាចអះអាងបានតាមរយៈការតវ៉ាចំពោះការអនុវត្តឡើយ (ក្នុងករណីនេះ ភាគីត្រូវធ្វើការអះអាងតាមរយៈបណ្តឹងតវ៉ាចំពោះការទាមទារដែលបានកំណត់នៅក្នុងមាត្រា ៣៦៣) ។ ប្រសិនបើអាជ្ញាសាលាត្រូវធ្វើការចាត់ចែងការអនុវត្តណាមួយតែមានភាពយឺតយ៉ាវនៅក្នុងការចាត់ចែងនោះ ការណ៍នេះ គឺជាការបំពានទៅលើបញ្ញត្តិនៃនីតិវិធីហើយ ។ នៅក្នុងករណីបែបនេះ ម្ចាស់បំណុលអាចធ្វើការតវ៉ាចំពោះការអនុវត្ត ហើយទាមទារឱ្យធ្វើការចាត់ចែងការអនុវត្តនោះបាន (សាលាដំបូង នឹងចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាធ្វើការចាត់ចែងការអនុវត្តនោះ) ។

(៣) បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្ត : បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្ត គឺអ្នកដែលទទួលរងការប៉ះពាល់ ដោយសារតែការចាត់ចែងការអនុវត្តខុសច្បាប់ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្ត ។ ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត តតិយជនក៏អាច

ធ្វើការតវ៉ាចំពោះការអនុវត្តបានដែរ ។

ឧទាហរណ៍ ម្ចាស់បំណុល អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ប្រសិនបើអាជ្ញាសាលាលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលធ្វើឡើងដោយត្រឹមត្រូវតាមច្បាប់ ឬ ធ្វេសប្រហែសមិនធ្វើការចាប់ផ្តើមការអនុវត្តដោយបង្ខំ ។ កូនបំណុល អាចធ្វើការតវ៉ាចំពោះការអនុវត្តដោយបង្ខំបាន ប្រសិនបើល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្តើមការអនុវត្តដោយបង្ខំ (ឧទាហរណ៍ ការបញ្ជូនលិខិតអនុវត្ត, ការមកដល់នូវពេលកំណត់ពិតប្រាកដជាអាទិ៍) មិនត្រូវបានបំពេញ ឬ ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលានោះខុសច្បាប់ (ឧទាហរណ៍ ការអនុវត្តដោយបង្ខំនៅពេលយប់ដោយពុំមានការអនុញ្ញាត, ការរឹបអូសចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) ។ តតិយជន អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ប្រសិនបើខ្លួនបានទទួលរងការប៉ះពាល់ដោយសារការអនុវត្តខុសច្បាប់ ដូចជាករណីនៃការរឹបអូសទ្រព្យ ដោយយល់ច្រឡំថា ទ្រព្យនោះ ជាកម្មសិទ្ធិរបស់កូនបំណុល បើទោះបីជាមានភាពច្បាស់លាស់ថា ទ្រព្យនោះ ជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ ។

(៤) នីតិវិធីនៃការតវ៉ាចំពោះការអនុវត្ត : ជាទូទៅ ការតវ៉ាចំពោះការអនុវត្ត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (ការតវ៉ាដោយផ្ទាល់មាត់ អាចធ្វើទៅបាន នៅកាលបរិច្ឆេទតុលាការ) (i) ទៅតុលាការអនុវត្តដែលពាក់ព័ន្ធ ប្រសិនបើការតវ៉ានោះ ធ្វើឡើង ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ឬ (ii) ទៅសាលាដំបូងដែលអាជ្ញាសាលាពាក់ព័ន្ធស្ថិតនៅ ប្រសិនបើការតវ៉ានោះធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ឬ ចំពោះការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្តនោះ (មាត្រា ៣៤៤ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២) ។

ពុំមានការកម្រិតអំពីអំឡុងពេលដែលអាចធ្វើការតវ៉ាចំពោះការអនុវត្តទេ គឺថា ការតវ៉ាអាចធ្វើទៅបានឱ្យតែមានផលប្រយោជន៍ក្នុងការតវ៉ានោះ (ផលប្រយោជន៍ជាក់ស្តែងនៅក្នុងការកែតម្រូវការអនុវត្ត) ។ នៅក្នុងការអនុវត្តទូទៅ ផលប្រយោជន៍នៃការតវ៉ា នឹងរលត់ ប្រសិនបើមិនបានធ្វើការតវ៉ា នៅក្រោយការចាប់ផ្តើមការចាត់ចែងការអនុវត្ត និង នៅមុនពេលបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលរួមបញ្ចូលនូវការចាត់ចែងនោះ ។

តុលាការអនុវត្ត ឬ សាលាដំបូង ធ្វើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្ត ដោយចេញដីកាសម្រេច (មាត្រា ៣៣៧ កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣) ។ តុលាការមានឆន្ទានុសិទ្ធិនៅក្នុងការកំណត់ថាតើត្រូវធ្វើ ឬ មិនត្រូវធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញដីកាសម្រេច ។ ប្រសិនបើមិនធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចសួរភាគី និង អ្នកដែលពាក់ព័ន្ធដទៃទៀតបាន ។ ប្រសិនបើតុលាការអនុវត្ត ឬ សាលាដំបូង យល់ឃើញថា ការតវ៉ាចំពោះការអនុវត្ត ផ្ទុយនឹងច្បាប់ ឬ មិនមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះ ។ ប្រសិនបើយល់ឃើញថា ការតវ៉ាចំពោះការអនុវត្តដែលធ្វើឡើងចំពោះការចាត់ចែងការអនុវត្ត

របស់តុលាការអនុវត្ត មានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តនោះ ។ ប្រសិនបើយល់ឃើញថាការតវ៉ាចំពោះការអនុវត្តដែលធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា មានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលុបចោលការចាត់ចែងការអនុវត្ត ឬ ហាមឃាត់ការអនុវត្ត ។

ទោះបីជាមានការតវ៉ាចំពោះការអនុវត្តក៏ដោយ ក៏ដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនផ្អាកដោយឯកឯងដែរ ។ ក៏ប៉ុន្តែ ដូចក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងជំទាស់ដែរ តុលាការអនុវត្ត ឬ សាលាដំបូង អាចបង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ឬ ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំបាន (មាត្រា ៣៨៤ កថាខណ្ឌទី ៣) ។

ជាគោលការណ៍ ការសម្រេចសេចក្តី (ដីកាសម្រេច) អំពីការតវ៉ាចំពោះការអនុវត្ត ត្រូវបានកម្រិតត្រឹមការសម្រេចសេចក្តីម្តងតែប៉ុណ្ណោះ ។ មានន័យថា ឧបាស្រ័យផ្សេងទៀត (បណ្តឹងជំទាស់) ចំពោះការសម្រេចសេចក្តីនេះ មិនអាចធ្វើឡើងបានទេ ។ ក៏ប៉ុន្តែ ដោយសារថា ដីកាសម្រេចដូចខាងក្រោមនេះ សុទ្ធតែជាដីកាសម្រេចសំខាន់ៗដែលបញ្ចប់ដោយផ្ទាល់ ឬ ដោយប្រយោល នូវនីតិវិធីនៃការអនុវត្តដោយបង្ខំ នោះដើម្បីជាការប្រុងប្រយ័ត្ន ទើបបានជាមានការអនុញ្ញាតជាពិសេស ឱ្យអាចប្តឹងជំទាស់បាន ចំពោះដីកាសម្រេចទាំងនោះ (មាត្រា ៣៨៥ កថាខណ្ឌទី ១ ចំណុច ក ដល់ចំណុច គ) ។

(ក) ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (ដោយទទួលការតវ៉ាចំពោះការអនុវត្ត)

(ខ) ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (ដោយទទួលការតវ៉ាចំពោះការអនុវត្ត ដែលធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា)

(គ) ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលើកចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

## ផ្នែកទី ២ ភាគីនៃការអនុវត្ត និង អ្នកតំណាងដោយអាណត្តិ

### ១. ភាគីនៃការអនុវត្ត

(១) នៅក្នុងការអនុវត្តដោយបង្ខំ បុគ្គលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ សម្រាប់ផលប្រយោជន៍របស់ខ្លួន ហៅថា "ម្ចាស់បំណុលនៃការអនុវត្ត" (ឬ ហៅដោយសាមញ្ញថា "ម្ចាស់បំណុល") ហើយភាគីម្ខាងទៀតនៃការអនុវត្តនោះ ហៅថា "កូនបំណុលនៃការអនុវត្ត" (ឬ ហៅដោយសាមញ្ញថា "កូនបំណុល") (មាត្រា ៣៨៧) ។ នេះមិនមែនជានិយមន័យតាមច្បាប់សារធាតុទេ គឺគ្រាន់តែជាឈ្មោះហៅរបស់ភាគីនៅក្នុងច្បាប់នីតិវិធីនៃការអនុវត្តដោយបង្ខំ តែប៉ុណ្ណោះ ។ ទោះជានៅក្នុងការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬ សាលដីកា ក៏ដោយ ដើមចោទនៅក្នុងរឿងក្តី មិនសុទ្ធតែក្លាយទៅជាម្ចាស់បំណុលនៃការអនុវត្ត

ជានិច្ចនោះទេ ។ មានករណីខ្លះ ដើមចោទនៅក្នុងរឿងក្ដី អាចនឹងក្លាយទៅជាកូនបំណុលនៃការអនុវត្តទៅវិញ នៅក្នុងការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យបង់ប្រាក់ប្រដាប់ក្ដី ។ ម៉្យាងទៀត ក៏អាចមានករណីដែលបុគ្គលណាម្នាក់ផ្សេងពីភាគីនៃបណ្ដឹង ក្លាយទៅជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តដែរ (មាត្រា ៣៥១) ។

(២) ត្រង់ចំណុចដែលថាតើនរណាជាម្ចាស់បំណុលនៃការអនុវត្ត ហើយនរណាជាកូនបំណុលនៃការអនុវត្ត នៅក្នុងរឿងក្ដីនៃការអនុវត្តដោយបង្ខំ ត្រូវកំណត់តាមការរៀបរាប់នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ៣៨៩ កថាខណ្ឌទី ១) ពោលគឺថាតើនរណាជាអ្នកដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ សម្រាប់ផលប្រយោជន៍របស់ខ្លួន ហើយសុំឱ្យអនុវត្តចំពោះនរណា ។ បុគ្គលផ្សេងពីនេះ គ្រាន់តែជាតតិយជនប៉ុណ្ណោះ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ បើទោះបីជាពួកគេគឺជាម្ចាស់បំណុល ឬ កូនបំណុលពិតប្រាកដនៅក្នុងច្បាប់សារធាតុក៏ដោយ ។ នៅពេលធ្វើការអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តត្រូវពិនិត្យមើល និង កំណត់ថាតើម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ត្រូវបានបញ្ជាក់ថាជា "បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន និង ភាគីម្ខាងទៀត" (មាត្រា ៣៥៧ កថាខណ្ឌទី ១ ចំណុច ក) នៅក្នុងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (មាត្រា ៣៨៩ កថាខណ្ឌទី ២) ដែលភ្ជាប់ជាមួយនឹងពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលធ្វើជាលាយលក្ខណ៍អក្សរដែរឬទេ (នៅក្នុងករណីនៃលិខិតអនុវត្តដែលមិនចាំបាច់ទទួលការផ្ដល់នូវរូបមន្តអនុវត្ត ដូចបានកំណត់នៅក្នុងមាត្រា ៣៥៤ កថាខណ្ឌទី ១ ចាប់ពីចំណុច ក ដល់ចំណុច គ ត្រឹមតែការបញ្ជាក់អំពីដើមចោទនិងចុងចម្លើយ ម្ចាស់បំណុលនិងកូនបំណុល នៅក្នុងលិខិតអនុវត្តដែលមានអានុភាពអនុវត្តនោះ ជាការគ្រប់គ្រាន់ហើយ) ។

**២. អ្នកតំណាងដោយអាណត្តិ**

ជាគោលការណ៍ បទប្បញ្ញត្តិស្ដីពីអ្នកតំណាងដែលច្បាប់បានកំណត់ នៅក្នុងនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាចំពោះការអនុវត្តដោយបង្ខំ ។ ក៏ប៉ុន្តែ ចំពោះលក្ខណសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិវិញ មានបញ្ញត្តិពិសេសដូចនឹងរៀបរាប់ខាងក្រោម (មាត្រា ៣៤៨) ។ គោលបំណងនៃបញ្ញត្តិពិសេសនេះ គឺដើម្បីសម្រួលដល់ការបំពេញលក្ខណសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិ ដោយយល់ឃើញថា នៅក្នុងការអនុវត្តដោយបង្ខំ ជាទូទៅ ស្ថាប័នអនុវត្តធ្វើនូវនីតិវិធីដែលបានចែងទុក ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន ហើយសកម្មភាពរបស់ភាគី ក៏មិនមានលក្ខណៈស្មុគស្មាញនោះទេ ។

(១) នីតិវិធីនៃបណ្ដឹង ឬ បណ្ដឹងជំទាស់ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃមាត្រា ៥៣ កថាខណ្ឌទី ១ (មាត្រា ៣៤៨ កថាខណ្ឌទី ១ ចំណុច ក) ។ មូលហេតុនៃការចែងបែបនេះ ព្រោះថា នីតិវិធីទាំងនេះ ជាមូលដ្ឋាន គឺជានីតិវិធីបណ្ដឹង ឬ នីតិវិធីដែលស្រដៀងទៅនឹងនីតិវិធីបណ្ដឹង ។ ហេតុនេះហើយបានជានៅក្នុងនីតិវិធីទាំងនេះ ជាគោលការណ៍ មានតែមេធាវីប៉ុណ្ណោះ ដែល

អាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន ។ ឧទាហរណ៍ ពាក្យបណ្ដឹងតវ៉ារបស់តតិយជន បើជាការតវ៉ាចំពោះការរឹបអូសដោយតុលាការអនុវត្ត ត្រូវដាក់ទៅតុលាការអនុវត្តនោះ តែបើជាការតវ៉ាចំពោះការរឹបអូសដោយអាជ្ញាសាលា ត្រូវដាក់ទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ( សូមមើលមាត្រា ៣៦៥ កថាខណ្ឌទី ២) ។ នៅក្នុងបែបនេះ ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិ ត្រូវតែជាមេធាវី ។

(២) លើកលែងតែករណីដែលបានកំណត់នៅក្នុងខទី (១) ខាងលើ នៅក្នុងនីតិវិធីដែលតុលាការអនុវត្ត ឬ សាលាដំបូងធ្វើឡើងចំពោះការអនុវត្តដោយបង្ខំ អ្នកក្រៅពីអ្នកដែលអាចធ្វើជាអ្នកតំណាងដោយអាណត្តិ តាមបញ្ញត្តិនៃមាត្រា ៥៣ កថាខណ្ឌទី ១ អាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការអនុវត្ត ឬ សាលាដំបូង ( មាត្រា ៣៤៨ កថាខណ្ឌទី ១ ចំណុច ខ) ។ តុលាការអនុវត្ត ឬ សាលាដំបូងអាចលុបចោលការអនុញ្ញាតនេះ នៅពេលណាក៏បាន (មាត្រា ៣៤៨ កថាខណ្ឌទី ២) ។ សូមកត់ចំណាំថា "នីតិវិធីដែលសាលាដំបូងធ្វើឡើងចំពោះការអនុវត្តដោយបង្ខំ" មានឧទាហរណ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដូចជា ការសម្រេចសេចក្ដីអំពីពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៤៤ កថាខណ្ឌទី ២), ការសម្រេចសេចក្ដីប្ដូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨១), ការអនុវត្តការចែកចំណែក នៅពេលម្ចាស់បំណុលពិភាក្សាគ្នា មិនបានដាច់ស្រេច ( មាត្រា ៤០១) ជាអាទិ៍ ។

(៣) នៅក្នុងនីតិវិធីដែលធ្វើឡើងដោយអាជ្ញាសាលា អ្នកណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ ( មាត្រា ៣៤៨ កថាខណ្ឌទី ១ ចំណុច គ) ។

## ផ្នែកទី ៣ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ

## កថាភាគទី ១ ទ្រព្យសម្បត្តិទទួលខុសត្រូវ

### ១. គោលគំនិត

ការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធនៃការសម្រេចដោយបង្ខំ នូវសិទ្ធិទាមទារ និង សិទ្ធិប្រាតិភោគ ។ គេអាចនិយាយម៉្យាងទៀតបានថា គោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីផ្ដល់ទៅឱ្យម្ចាស់បំណុល នូវភាពស្កប់ចិត្ត ដោយអំណាចរដ្ឋ ដូចគ្នានឹងករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរ ។ ទ្រព្យសម្បត្តិដែលអាចធ្វើឱ្យសម្រេចនូវគោលបំណងនេះបាន ក្នុងករណីនៃការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារ គឺទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុល ។ ដោយឡែក នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគវិញ ទ្រព្យសម្បត្តិនោះ គឺជាទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដែលពាក់ព័ន្ធនោះ ។ ដូចបានរៀបរាប់មកនេះ ទ្រព្យសម្បត្តិដែលអាចធ្វើឱ្យសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ តាមរយៈការអនុវត្តដោយបង្ខំ ហៅថា "ទ្រព្យសម្បត្តិទទួលខុសត្រូវ" នៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគនោះ ។ ក្នុងនោះ ចំណុចដែលបង្កបញ្ហាស្មុគស្មាញ

បំផុតនោះគឺ សិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ។

## ២. វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ

(១) វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ : ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុល នៅពេលចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំ ។

នៅក្នុងករណីនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់កូនបំណុល នៅពេលចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំ (ទ្រព្យសម្បត្តិទូទៅ) គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ (មាត្រា ៣៧៩) ។ ក៏ប៉ុន្តែ ដោយមានហេតុផលពិសេស វត្ថុ ឬ សិទ្ធិមួយចំនួន ត្រូវបានដកចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវ បើទោះបីជាវត្ថុ ឬ សិទ្ធិទាំងនោះជាវត្ថុ ឬ សិទ្ធិរបស់កូនបំណុលក៏ដោយ (ឧទាហរណ៍ វត្ថុដែលមិនអាចប្តូរជាប្រាក់បាន តាមចក្ខុវិស័យរបស់ច្បាប់ដូចជារូបិយវត្ថុក្លែងក្លាយ, ទ្រព្យសម្បត្តិដែលច្បាប់ហាមឃាត់មិនឱ្យរឹបអូស ជាអាទិ៍) ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិ និង សិទ្ធិរបស់តតិយជន មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវទេ ។ អាស្រ័យហេតុនេះ ទ្រព្យសម្បត្តិទាំងឡាយណាដែលកូនបំណុលបានធ្វើអនុប្បទានដោយស្របច្បាប់ ហើយដែលអនុប្បទានិកបានបំពេញគ្រប់ល័ក្ខខ័ណ្ឌតតាំងរួចរាល់នៅមុនពេលចាប់ផ្តើមការអនុវត្តដោយបង្ខំនោះ មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលទៀតទេ ។ ក៏ប៉ុន្តែ ប្រសិនបើកូនបំណុលធ្វើអនុប្បទាននូវទ្រព្យសម្បត្តិរបស់ខ្លួនទាំងដឹងថា អនុប្បទាននោះ នឹងនាំឱ្យមានការខូចខាតដល់ម្ចាស់បំណុល នោះម្ចាស់បំណុលអាចលុបចោលអនុប្បទាននោះបាន ដើម្បីធ្វើបដិទាននូវទ្រព្យសម្បត្តិទទួលខុសត្រូវ និង ដាក់ទ្រព្យសម្បត្តិនោះ ជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយប្រើសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍របស់ម្ចាស់បំណុល (មាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី) ។

នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុវិញ កម្មវត្ថុនៃការអនុវត្តដោយបង្ខំគឺជាវត្ថុដែលកូនបំណុលកាន់កាប់ (មាត្រា ៥២៤ និង មាត្រា ៥២៥) ឬ សិទ្ធិទាមទារឱ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជន (មាត្រា ៥២៦) ។

ដោយឡែក ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ទ្រព្យសម្បត្តិទទួលខុសត្រូវ គឺកម្មវត្ថុនៃសិទ្ធិប្រាតិភោគដែលពាក់ព័ន្ធនោះ ។

(២) ការស្រាវជ្រាវអំពីទ្រព្យសម្បត្តិទទួលខុសត្រូវ : ការកំណត់ថាតើទ្រព្យសម្បត្តិណាមួយ គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ ឬទេនោះ ជាទូទៅ គឺ ជាការកំណត់នៅក្រោមច្បាប់សារធាតុ ។ ក៏ប៉ុន្តែ ការដែលឱ្យស្ថាប័នអនុវត្ត (ជាពិសេស អាជ្ញាសាលា) ធ្វើការកំណត់លើបញ្ហានេះទៅតាមច្បាប់សារធាតុនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំនោះ មិនមែនជារឿងសមរម្យទេ ហើយម្យ៉ាងទៀត ប្រសិនបើឱ្យ

ស្ថាប័នអនុវត្តទទួលបន្ទុកលើការកំណត់នេះ វាអាចនឹងធ្វើឱ្យស្ថាប័នអនុវត្តមានការរារែកនៅក្នុងការអនុវត្តដោយបង្ខំ ហើយនឹងមានការលំបាកនៅក្នុងការចាប់ផ្ដើមការអនុវត្តដោយបង្ខំឱ្យបានឆាប់រហ័ស ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីកំណត់ថា ស្ថាប័នអនុវត្តអាចធ្វើសកម្មភាពដោយគ្រាន់តែផ្អែកទៅលើស្ថានភាពដែលសមល្មមឱ្យគិតថាទ្រព្យសម្បត្តិណាមួយ គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវនោះ ។ ឧទាហរណ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការណ៍ដែលកូនបំណុលធ្វើការកាន់កាប់ជាក់ស្ដែងនូវវត្ថុនោះ គឺជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់សម្រាប់ការកំណត់ថា វត្ថុនោះគឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ (មាត្រា ៣៨៥ កថាខណ្ឌទី ១) ។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ លិខិតបញ្ជាក់ ដូចជាលិខិតចម្លងយថាភូតនៃការចុះបញ្ជីអចលនវត្ថុដោយដាក់ឈ្មោះកូនបំណុល ជាអាទិ៍ គឺជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់ (មាត្រា ៤១៧ កថាខណ្ឌទី ៣ ចំណុច ក) ។ ដោយឡែកនៅក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតវិញ ស្ថាប័នអនុវត្តអាចកំណត់អត្ថិភាពនៃសិទ្ធិ ឬ ម្ចាស់សិទ្ធិនោះ ដោយផ្អែកលើការរៀបរាប់នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំជាលាយលក្ខណ៍អក្សរ ដែលម្ចាស់បំណុលបានដាក់ (មាត្រា ៤០៣ កថាខណ្ឌទី ២ ជាអាទិ៍) ។ នេះមានន័យថា ស្ថាប័នអនុវត្តអាចចាប់ផ្ដើមការអនុវត្តដោយបង្ខំ ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវថាតើទ្រព្យសម្បត្តិនោះ ពិតជាទ្រព្យសម្បត្តិរបស់កូនបំណុល តាមច្បាប់សារធាតុ ឬ យ៉ាងណានោះទេ ។ ប្រសិនបើមានវិវាទអំពីម្ចាស់សិទ្ធិនៅក្រោមច្បាប់សារធាតុ វិវាទនោះត្រូវដោះស្រាយតាមរយៈបណ្ដឹងតវ៉ារបស់តតិយជន (មាត្រា ៣៦៥) (ដែលនឹងរៀបរាប់បន្ទាប់ពីនេះ) ។

## ៣. ការទទួលខុសត្រូវដោយមានកម្រិត

(១) នៅក្នុងការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ជាគោលការណ៍ ម្ចាស់បំណុលមានសិទ្ធិធ្វើការជ្រើសរើសទ្រព្យសម្បត្តិដើម្បីរឹបអូស ពីក្នុងចំណោមទ្រព្យសម្បត្តិទទួលខុសត្រូវ (ទ្រព្យសម្បត្តិទូទៅ) របស់កូនបំណុល (ប៉ុន្តែ លើកលែងត្រង់ថា គោលការណ៍នេះ មិនអាចអនុវត្តបានទេ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ) ក៏ប៉ុន្តែ ចំពោះប្រភេទសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មួយចំនួន ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវបានកម្រិតត្រឹមវត្ថុ ឬ ទ្រព្យជាក់លាក់ណាមួយ នៅក្នុងទំហំមួយជាក់លាក់ ហើយការអនុវត្តដោយបង្ខំ មិនអាចធ្វើទៅបានចំពោះទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុលទេ ។

ឧទាហរណ៍ ក្នុងករណីដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត ទំហំនៃទ្រព្យសម្បត្តិទទួលខុសត្រូវដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃមតកជន ត្រូវកម្រិតត្រឹមទំហំនៃមតិក ហើយម្ចាស់បំណុលនៃមតកជន អាចធ្វើការអនុវត្តដោយបង្ខំចំពោះសន្តតិជន ត្រឹមតែក្នុងទំហំនៃមតិកតែប៉ុណ្ណោះ (សូមមើលមាត្រា ១២៥៦ និង មាត្រា ១២៥៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិទទួលខុសត្រូវ ក៏អាចត្រូវបានកម្រិតដោយច្បាប់ ឬ ដោយការព្រមព្រៀងពិសេសរបស់ភាគី

ផងដែរ ។

(២) ការទទួលខុសត្រូវដោយមានកម្រិត មិនមែនជាការផាត់ចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវ ដោយផ្អែកលើមូលហេតុដែលកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ដូចជាទ្រព្យសម្បត្តិដែលហាមឃាត់មិនឱ្យរឹបអូសទេ ប៉ុន្តែ គឺជាការដាក់កម្រិតទៅលើទ្រព្យសម្បត្តិទទួលខុសត្រូវ ដោយទាញចេញពីលក្ខណៈរបស់សិទ្ធិទាមទារ នៅក្រោមច្បាប់សារធាតុ ។ អាស្រ័យហេតុនេះហើយ បញ្ហានេះ មិនមែនជារឿងដែលស្ថាប័នអនុវត្តត្រូវធ្វើការពិនិត្យស្រាវជ្រាវនៅពេលធ្វើការអនុវត្តដោយបង្ខំទេ ។ ដូចនេះ ក្នុងករណីដែលឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត មិនបញ្ជាក់អំពីចំណុចនេះទេ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងចំពោះទ្រព្យសម្បត្តិក្រៅពីទ្រព្យសម្បត្តិទទួលខុសត្រូវ ការអនុវត្តដោយបង្ខំនោះ មិនខុសច្បាប់ទេ ។ ក៏ប៉ុន្តែ ដោយសារថាច្បាប់សារធាតុមិនអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិក្រៅពីទ្រព្យសម្បត្តិទទួលខុសត្រូវទេនោះ តតិយជនដែលអះអាងថា មានសិទ្ធិលើទ្រព្យសម្បត្តិនោះ អាចទាមទារឱ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈបណ្ដឹងតវ៉ារបស់តតិយជន ( មាត្រា ៣៦៥) ។

ជាងនេះទៅទៀត ប្រសិនបើនៅក្នុងដំណើរការនៃនីតិវិធីចេញសាលក្រម ឬ សាលដីកា (នីតិវិធីបណ្ដឹង) មានភាពច្បាស់លាស់ថា ទ្រព្យសម្បត្តិទទួលខុសត្រូវដើម្បីសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ របស់ម្ចាស់បំណុល ត្រូវបានកម្រិតត្រឹមវត្ថុ ឬ ទ្រព្យជាក់លាក់ណាមួយ នៅក្នុងទំហំមួយជាក់លាក់ នោះកូនបំណុលអាចដាក់មធ្យោបាយការពារខ្លួន (អះអាងអង្គហេតុតវ៉ា) ដោយបង្ហាញអំពីការទទួលខុសត្រូវដោយមានកម្រិត នៅក្នុងអំឡុងពេលនៃនីតិវិធីនោះ បាន ។ ក្នុងករណីនេះ ប្រសិនបើតុលាការយល់ឃើញថា អង្គហេតុតវ៉ានោះ មានភាពត្រឹមត្រូវ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាបញ្ជាក់អំពីការកម្រិតនោះ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកា (ឧទាហរណ៍ដូចជា សរសេរនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមថា "ត្រូវសងត្រឹមទំហំនៃមត៌ក") ។ម៉្យាងវិញទៀត ប្រសិនបើមានមូលហេតុណាមួយដែលនាំឱ្យការទទួលខុសត្រូវដោយមានកម្រិត កើតឡើងនៅក្រោយពេលដែលបណ្ដឹងត្រូវបានបញ្ចប់ (ឧទាហរណ៍ ប្រសិនបើសន្តតិកម្មចាប់ផ្ដើមនៅក្រោយពេលដែលបណ្ដឹងត្រូវបានបញ្ចប់ ហើយការយល់ព្រមដោយមានកម្រិតត្រូវបានធ្វើឡើង) នោះកូនបំណុលអាចទទួលសាលក្រម តាមរយៈបណ្ដឹងតវ៉ាចំពោះការទាមទារ ( មាត្រា ៣៦៣) ដែលកំណត់ថា ការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនេះ ត្រូវបានអនុញ្ញាតតែក្នុងទំហំនៃការទទួលខុសត្រូវដោយមានកម្រិតតែប៉ុណ្ណោះ ។

## កថាភាគទី ២ បណ្ដឹងតវ៉ារបស់តតិយជន

### ១. គោលគំនិត

បណ្ដឹងតវ៉ារបស់តតិយជន គឺជាបណ្ដឹងដែលតតិយជនប្ដឹងប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ដោយ

អះអាងថាកម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវនៅក្រោមច្បាប់សារធាតុ ហើយទាមទារឱ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិនោះ (សូមមើលមាត្រា ៣៦៥ កថាខណ្ឌទី ១) ។

ការពិនិត្យស្រាវជ្រាវអំពីទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវធ្វើឡើងដោយផ្អែកលើចរិតលក្ខណៈខាងក្រៅប៉ុណ្ណោះ ហើយទំនាក់ទំនងគតិយុត្តជាសារធាតុនៃកម្មវត្ថុនៃការអនុវត្ត មិនត្រូវបានពិនិត្យស្រាវជ្រាវឱ្យល្អិតល្អន់ទេ ។ ហេតុនេះហើយទើបអាចកើតមាននូវករណីដែលថាការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើង ចំពោះទ្រព្យសម្បត្តិដែលមិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។ ឧទាហរណ៍ជាទូទៅនៃរឿងហេតុបែបនេះ គឺករណីដែលការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើង មិនមែនចំពោះទ្រព្យសម្បត្តិរបស់កូនបំណុលទេ តែចំពោះទ្រព្យសម្បត្តិរបស់តតិយជនទៅវិញ ។ ដូចបានពោលខាងលើរួចមកហើយ ទោះបីជាក្នុងករណីបែបនេះក៏ដោយ ប្រសិនបើមើលពីខាងក្រៅវត្ថុនោះទំនងជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុល ការអនុវត្តនោះមិនខុសច្បាប់ តាមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ។ ហេតុនេះហើយ តតិយជនមិនអាចទាមទារឱ្យដកចេញនូវការអនុវត្ត តាមវិធីនៃការតវ៉ាចំពោះការអនុវត្តដោយបង្ខំ ឬ បណ្តឹងជំទាស់បានឡើយ ។ ក៏ប៉ុន្តែ ដោយសារថាការអនុវត្តនោះត្រូវបានធ្វើឡើងចំពោះទ្រព្យសម្បត្តិដែលជារបស់តតិយជន ហើយដែលមិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវដើម្បីសម្រេចសិទ្ធិលើបំណុលដែលពាក់ព័ន្ធនោះ ការអនុវត្តនោះ គឺជាការអនុវត្តដែលមិនមានយុត្តិធម៌ នៅក្នុងន័យដែលថា វាមិនគួរត្រូវបានអនុញ្ញាតទេ បើឈរលើទស្សនទាននៃទំនាក់ទំនងគតិយុត្តជាសារធាតុរវាងម្ចាស់បំណុលនៃការអនុវត្ត និង តតិយជននោះ ។ ហេតុដូច្នេះ ហើយបានជានៅក្នុងករណីបែបនេះ ច្បាប់បានចែងអំពីវិធីដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន, ដែលធ្វើឱ្យតតិយជនអាចទាមទារឱ្យមានការសង្គ្រោះនូវសិទ្ធិរបស់ខ្លួន តាមច្បាប់សារធាតុបាន ។ ខុសពីបណ្តឹងតវ៉ាចំពោះការទាមទារដែលនឹងពន្យល់ខាងក្រោម (មាត្រា ៣៦៣) បណ្តឹងតវ៉ារបស់តតិយជន មិនមែនជាវិធីធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារដែលម្ចាស់បំណុលចង់ឱ្យសម្រេចតាមរយៈការអនុវត្តដោយបង្ខំនោះទេ ប៉ុន្តែ វាគឺជាវិធីសង្គ្រោះនៅក្នុងករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំ មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។

## ២. ទំហំនៃការអនុវត្ត

បណ្តឹងតវ៉ារបស់តតិយជននេះ អាចយកទៅអនុវត្តបាន ចំពោះការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ។ បណ្តឹងនេះត្រូវបានទទួលស្គាល់ថាជាវិធីសង្គ្រោះ មិនចំពោះតែការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះទេ តែក៏ចំពោះការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុ, ការអនុវត្តដោយបង្ខំឱ្យចាកចេញពីផ្ទះណាមួយ ជាអាទិ៍ ផងដែរ ។

បណ្តឹងនេះ អាចយកទៅអនុវត្តបាន មិនចំពោះតែករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺជាវត្ថុរូបីដូចជាចលនវត្ថុ និង អចលនវត្ថុ ប៉ុណ្ណោះទេ តែក៏ចំពោះករណីដែលកម្មវត្ថុនៃការអនុវត្ត គឺជាសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ផងដែរ ។

ដោយមិនគិតអំពីប្រភេទនៃស្ថាប័នអនុវត្ត បណ្តឹងនេះ អាចធ្វើបានមិនចំពោះតែការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្តប៉ុណ្ណោះទេ តែក៏អាចធ្វើបានចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ផងដែរ ។ ជាងនេះទៅទៀត បណ្តឹងនេះក៏អាចធ្វើបានដែរ នៅក្នុងករណីដែលការអនុវត្តដោយបង្ខំ ខុសច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំតាំងពីដំបូង ហើយដែលការតវ៉ាចំពោះការអនុវត្ត និង បណ្តឹងជំទាស់ ក៏អាចធ្វើទៅបាន ។

## ៣. មូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន

បញ្ញត្តិដែលចែងនៅក្នុងមាត្រា ៣៦៥ បញ្ជាក់ថា បុគ្គលអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនបាន គឺ "តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ" (មាត្រា ៣៦៥ កថាខណ្ឌទី ១) ។ ទោះជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាឧទាហរណ៍មួយតែប៉ុណ្ណោះ ។ និយាយឱ្យខ្លីទៅ ការចែងបែបនេះ មានន័យថា ក្នុងករណីដែលតតិយជនអះអាងថា កម្មវត្ថុនៃការអនុវត្តដោយបង្ខំ មិនត្រឹមត្រូវដើម្បីសម្រេចនូវសិទ្ធិរបស់ម្ចាស់បំណុលបាន នៅក្នុងទំនាក់ទំនងទៅនឹងខ្លួន នោះបណ្តឹងតវ៉ារបស់តតិយជន អាចធ្វើទៅបាន ។ ស្ថានភាពដែលបណ្តឹងនេះ អាចធ្វើទៅបាន ឬ មិនបាន គឺកំណត់ដោយគិតពិចារណាទៅលើប្រភេទនៃសិទ្ធិដែលតតិយជន មានចំពោះកម្មវត្ថុនៃការអនុវត្ត គឺថាតើសិទ្ធិនោះ នឹងត្រូវខូចខាតដោយសារការអនុវត្តដោយបង្ខំដែរឬទេ ហើយមានភាពចាំបាច់ និងផលប្រយោជន៍ដែរឬទេ នៅក្នុងការដកចេញនូវការអនុវត្តនោះ ។

(១) ឧទាហរណ៍សំខាន់នៃ "សិទ្ធិរាំងការអនុវត្តដោយបង្ខំ " ដែលអាចអះអាងថាជាមូលហេតុមួយសម្រាប់ការប្តឹងតវ៉ារបស់តតិយជន គឺកម្មសិទ្ធិ ។ ជាក់ស្តែង កម្មសិទ្ធិត្រូវបានលើកមកអះអាងនៅក្នុងករណីច្រើនបំផុតនៃបណ្តឹងតវ៉ារបស់តតិយជន ។ ប៉ុន្តែ យ៉ាងណាក៏ដោយ កម្មសិទ្ធិរបស់តតិយជន ត្រូវបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលតម្រូវដោយច្បាប់សារធាតុ ដើម្បីអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តបាន (មាត្រា ១៣៤ នៃក្រមរដ្ឋប្បវេណី) នៅពេលដែលមានការរឹបអូស ។ ល័ក្ខខ័ណ្ឌតតាំងទាំងនោះ មានដូចជាការផ្ទេរការកាន់កាប់លើចលនវត្ថុ, ការចុះបញ្ជីអំពីការផ្ទេរអចលនវត្ថុ ជាអាទិ៍ ។

សិទ្ធិកាន់កាប់ ត្រូវទទួលការការពារដោយឯករាជ្យពីសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់ ហើយក៏អាចជាមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជនដែរ ។ ឧទាហរណ៍ ប្រសិនបើតតិយជនកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត នោះចាំបាច់ត្រូវមានការយល់ព្រមពីតតិយជននោះសិន ទើបអាជ្ញាសាលាអាចធ្វើការរឹបអូសបាន តាមនីតិវិធីនៃការអនុវត្តចំពោះចលនវត្ថុ (មាត្រា ៣៨៦) ។ ប្រសិនបើអាជ្ញាសាលាធ្វើការរឹបអូសចលនវត្ថុ ដោយពុំទទួលការយល់ព្រមនេះទេ តតិយជននោះមិនត្រឹមតែអាចទាមទារឱ្យមានការសង្គ្រោះតាមវិធីនៃការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្តបាន ដោយផ្អែកលើការបំពានច្បាប់នៃនីតិវិធីនៃការអនុវត្តដោយបង្ខំប៉ុណ្ណោះទេ គឺអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ដោយផ្អែកលើមូលហេតុនៃការបំពានសិទ្ធិកាន់កាប់ផងដែរ ។

(២) ក្នុងករណីនៃការរឹបអូសទ្រព្យសម្បត្តិដែលតតិយជនមានហ៊ីប៉ូតែកនៅលើនោះ ជាធម្មតា ការណ៍ដែលមានហ៊ីប៉ូតែកនោះ មិនអាចយកទៅធ្វើជាមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជនបានទេ ។ ប្រសិនបើហ៊ីប៉ូតែកនោះ អាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបាន សិទ្ធិនោះនឹងបន្តមានអត្ថិភាពនៅក្រោយការលក់ដោយបង្ខំ ពោលគឺហ៊ីប៉ូតែកនោះ មិនខូចខាតដោយសារការអនុវត្តដោយបង្ខំទេ (មាត្រា ៤៣១ កថាខណ្ឌទី ១) ។ ជាការពិត ហ៊ីប៉ូតែក គឺជាសិទ្ធិប្រាតិភោគ ដែលពុំមានអំណាចកាន់កាប់ និង ប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនោះ ។ ដោយសារថាគោលបំណងនៃហ៊ីប៉ូតែកនេះ អាចសម្រេចបានដោយគ្រាន់តែមានការធានាអំពីការទទួលការសងដោយមានអាទិភាពនាពេលអនាគតនោះ មិនមានភាពចាំបាច់ឱ្យដកចេញនូវការអនុវត្តដោយបង្ខំទេ ។

## ៤. លក្ខណៈជាភាគី

(១) បុគ្គលដែលមានលក្ខណៈជាដើមចោទដែលអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនបាន គឺតតិយជនដែលអះអាងថាការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុណាមួយ បំពានលើសិទ្ធិរបស់ខ្លួន (កម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត) ។

កូនបំណុលនៃការអនុវត្ត ពុំមានលក្ខណៈជាដើមចោទដែលអាចដាក់ពាក្យបណ្តឹងនេះបានទេ បើទោះបីជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ មិនមែនជាទ្រព្យសម្បត្តិរបស់ខ្លួនក៏ដោយ ។ ក៏ប៉ុន្តែ បើក្នុងករណីដែលមានការរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន បើទោះជានៅក្នុងលិខិតអនុវត្ត មានការសរសេរថា "ត្រូវសងត្រឹមទំហំនៃទ្រព្យសម្បត្តិដែលបានទទួលតាមរយៈសន្តតិកម្ម" ក៏ដោយនោះ សន្តតិជនអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនបាន ព្រោះថានៅក្នុងករណីនេះ ឋានៈរបស់សន្តតិជននោះនៅក្នុងទំនាក់ទំនងទៅនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួន មានលក្ខណៈប្រហាក់ប្រហែលទៅនឹងតតិយជនដែរ ។

(២) បុគ្គលដែលមានលក្ខណៈជាចុងចម្លើយ គឺម្ចាស់បំណុលនៃការអនុវត្ត មិនមែនអាជ្ញាសាលា ឬស្ថាប័នអនុវត្តផ្សេងទៀតទេ ។ ពុំមានភាពចាំបាច់ដែលត្រូវឱ្យកូនបំណុលនៃការអនុវត្ត ធ្វើជាចុងចម្លើយនៅក្នុងករណីនេះទេ ។

## ៥. អំឡុងពេលនៃការដាក់ពាក្យបណ្តឹង

(១) ជាគោលការណ៍ ផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្តឹង កើតឡើងនៅក្រោយការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុដែលពាក់ព័ន្ធ ។ ក៏ប៉ុន្តែ ក្នុងករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំត្រូវបានបញ្ជាក់ ដូចជា ការប្រគល់វត្ថុជាក់លាក់ណាមួយនោះ ប្រសិនបើមានការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៩៧) នោះនឹងមានការទទួលស្គាល់ថា ភយន្តរាយនៃការអនុវត្តដោយបង្ខំ លេចចេញយ៉ាងជាក់ស្តែង ហើយពេលនោះ ផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្តឹងក៏នឹងត្រូវបានទទួលស្គាល់ដែរ ។

(២) ដោយសារថា បណ្តឹងតវ៉ារបស់តតិយជន ត្រូវបានទទួលស្គាល់ថាជាវិធីសម្រាប់ឱ្យតតិយជនអាច

ទាមទារឱ្យដកចេញនូវការអនុវត្តដោយបង្ខំបាន នៅក្នុងករណីដែលការអនុវត្តដោយបង្ខំនោះត្រូវបានធ្វើឡើងយ៉ាងជាក់ស្តែង ហើយដែលសិទ្ធិរបស់តតិយជននោះ ទទួលរងនូវការខូចខាត ដូចនេះហើយ នៅពេលណាដែលការអនុវត្តដោយបង្ខំចំពោះវត្ថុដែលពាក់ព័ន្ធនោះ បានបញ្ចប់ទៅហើយ ផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនក៏ត្រូវរលត់ដែរ ហើយបើតតិយជននៅតែដាក់ពាក្យបណ្តឹងទៀត បណ្តឹងនោះនឹងត្រូវលើកចោល ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងទាំងខុស ចំពោះទ្រព្យសម្បត្តិរបស់តតិយជន ដែលមិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ ដើម្បីសម្រេចនូវសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយប្រសិនបើតតិយជនបានទទួលរងនូវការខូចខាតដោយសារតែការអនុវត្តដោយបង្ខំនោះ តតិយជននោះអាចទាមទារឱ្យសងនូវសេចក្តីចម្រើនដោយឥតហេតុ និង អាចទាមទារសំណងនៃការខូចខាត ពីម្ចាស់បំណុលនៃការអនុវត្តបាន ។

## ៦. នីតិវិធីនៃបណ្តឹង

(១) សមត្ថកិច្ច : តុលាការអនុវត្ត មានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជនចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើង ដោយតុលាការអនុវត្តក្នុងនាមជាស្ថាប័នអនុវត្ត ហើយសាលាដំបូង មានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជន ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលា ( មាត្រា ៣៦៥ កថាខណ្ឌទី ២) ។

(២) ការដាក់ពាក្យបណ្តឹង : ការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើឡើងដោយអនុលោមទៅតាមវិធីទូទៅសម្រាប់ការដាក់ពាក្យបណ្តឹង ( មាត្រា ៧៥) ។ ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គប្បីរៀបរាប់អំពីការសុំឱ្យចេញសាលក្រមដែលមានខ្លឹមសារថា "ការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនេះ ត្រូវហាមឃាត់" ។ លើសពីនេះទៅទៀត ក៏អាចទាមទារឱ្យធ្វើការបញ្ជាក់អំពីសិទ្ធិរបស់បុគ្គលណាម្នាក់ផងដែរ ។ ចំពោះមូលហេតុនៃការទាមទារ គប្បីរៀបរាប់អំពីទំនាក់ទំនងគតិយុត្តជាសារធាតុ ដែលជាមូលហេតុនាំឱ្យការអនុវត្តដោយបង្ខំនោះត្រូវហាមឃាត់ ( មូលហេតុនៃការតវ៉ា ឬ និយាយម៉្យាងទៀត សិទ្ធិដែលបុគ្គលណាម្នាក់មាន និង អង្គហេតុដែលថាសិទ្ធិនោះ ទទួលរងនូវការខូចខាតដោយសារការអនុវត្តដោយបង្ខំ) ។

(៣) ការផ្អាកមួយរយៈនូវការអនុវត្តដោយបង្ខំ ជាអាទិ៍ : ការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន មិនផ្អាកដោយស្វ័យប្រវត្តិ នូវការអនុវត្តដោយបង្ខំទេ ហើយក៏មិនរារាំងបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដែលកំពុងដើរទៅមុខដែរ ។ ក៏ប៉ុន្តែ ប្រសិនបើតតិយជនដែលជាដើមចោទនៃបណ្តឹងនោះ ធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការតវ៉ា នោះតុលាការអាចបង្គាប់ឱ្យធ្វើការចាត់ចែងមួយរយៈ ដូចជាការផ្អាកមួយរយៈនូវការអនុវត្តដោយបង្ខំ ឬ លុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ (ចាប់ពីត្រឹមនេះតទៅ ហៅថា "ការចាត់ចែងមួយរយៈដោយផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ") ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ រហូតដល់ចេញសាលក្រម ឬ សាលដីកាចុងក្រោយ ( មាត្រា ៣៦៧) ។

ចំពោះថាតើត្រូវផ្អាក ឬ លុបចោល ឬ បន្ត នូវការអនុវត្តដោយបង្ខំ ត្រូវកំណត់ជាចុងក្រោយ ដោយគិតពិចារណាថាតើការទាមទាររបស់តតិយជនដែលជាដើមចោទនៃបណ្តឹងតវ៉ារបស់តតិយជន អាចទទួលស្គាល់ថាសមស្របដែរឬទេ ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា នៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយអំពីបណ្តឹងតវ៉ារបស់តតិយជន តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីចំណុចនេះឡើងវិញ បង្គាប់សាជាថ្មីឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ ឬ ត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវការចាត់ចែងមួយរយៈដោយការផ្អាក ឬ ការលុបចោលនូវការអនុវត្តដោយបង្ខំ ដែលបានធ្វើរួចហើយ (មាត្រា ៣៦៨ វាក្យខណ្ឌទី ១) ។ បញ្ញត្តិចែងបន្តទៀតថា ការសម្រេចសេចក្តីនេះ ត្រូវមានអានុភាព ចាប់ពីពេលប្រកាសសាលក្រម ឬ សាលដីកាចុងក្រោយ (មាត្រា ៣៦៨ វាក្យខណ្ឌទី ២) ។ គោលបំណងនៃការបង្កើតអនុភាពនៃសេចក្តីសម្រេចនេះ ព្រមទាំងទំនាក់ទំនងរបស់វាជាមួយនឹងការផ្អាក ឬ ការលុបចោលនូវនីតិវិធីជាក់ស្តែងនៃការអនុវត្តដោយបង្ខំ នឹងមានរៀបរាប់យ៉ាងលំអិត នៅក្នុងផ្នែកដែលនិយាយអំពីបណ្តឹងតវ៉ាចំពោះការទាមទារ (ផ្នែកទី ៤ កថាភាគទី ២. ៣. (iv)) ។

(៤) សាលក្រម ឬ សាលដីកា : ប្រសិនបើតុលាការយល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ នោះតុលាការត្រូវចេញសាលក្រម ឬ សាលដីកាដែលប្រកាសថា "ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនេះ ត្រូវហាមឃាត់" ។ នៅពេលសាលក្រម ឬ សាលដីកានេះចូលជាស្ថាពរ តតិយជនដែលជាដើមចោទនៃបណ្តឹងតវ៉ារបស់តតិយជននោះ អាចទទួលបាននូវការផ្អាកការអនុវត្តដោយបង្ខំ ឬ ការលុបចោលនូវការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ដោយដាក់ឯកសារចម្លងយថាភូតនៃសាលក្រម ឬ សាលដីកានោះ ទៅស្ថាប័នអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ) ។ ប្រសិនបើការតវ៉ារបស់តតិយជន ពុំមានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលការទាមទារនោះ ។

## ផ្នែកទី ៤ លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

## កថាភាគទី ១ សេចក្តីផ្តើម

### ១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច (តុលាការអនុវត្ត ឬ អាជ្ញាសាលា (មាត្រា ៣៣៦ កថាខណ្ឌទី ២)) (មាត្រា ៣៤៩ កថាខណ្ឌទី ១) ។ នៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ ត្រូវមានបញ្ជាក់អំពីប្រភេទនៃការអនុវត្តដោយបង្ខំដែលសុំឱ្យធ្វើ (ការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬ ការបង្ខំដោយប្រយោល) ។ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ត្រូវបញ្ជាក់ផងដែរលើលិខិតនោះនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ (ចលនវត្ថុ

អចលនវត្ថុ ឬ សិទ្ធិលើបំណុល ជាអាទិ៍) ហើយក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬ ការបង្ខំដោយប្រយោល ត្រូវបញ្ជាក់នូវខ្លឹមសារនៃសេចក្តីសម្រេចដែលទាមទារឱ្យមានការអនុវត្តនោះ ព្រមទាំងភ្ជាប់មកជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ផងដែរ (មាត្រា ៣៨៩ កថាខណ្ឌទី ២) ។

បន្ថែមពីលើនេះ អាស្រ័យទៅតាមប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំដែលសុំឱ្យធ្វើ នៅក្នុងករណីមួយចំនួន មានការតម្រូវឱ្យសរសេររៀបរាប់ក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ អំពីចំណុចដើម្បីកំណត់ដោយជាក់លាក់នូវកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ក៏ដូចជាការតម្រូវឱ្យដាក់ឯកសារបញ្ជាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងកម្មវត្ថុនោះ ផងដែរ (មាត្រា ៤០៣, មាត្រា ៤១៧ កថាខណ្ឌទី ៣ និង មាត្រា ៤៥៥ កថាខណ្ឌទី ៣) ។ នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ម្ចាស់បំណុលត្រូវបង់ពន្ធដាក់ពាក្យសុំទៅស្ថាប័នអនុវត្ត (មាត្រា ៣៧២) ឬ ត្រូវបង់ប្រាក់កម្រៃជាមុន (មាត្រា ២១ និង មាត្រា ២៨ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ហើយលើសពីនេះ ក៏ត្រូវបង់ជាមុន នូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ផងដែរ (សូមមើលជំពូកទី ២ ផ្នែកទី ៧ ខាងក្រោម) (មាត្រា ៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ២៤, មាត្រា ២៥ និង មាត្រា ២៨ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ។

## ២. លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត

### (i) **អត្ថន័យ :**

លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ជាគោលការណ៍ គឺជាលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត (មាត្រា ៣៥០) ដែលភាគី (ម្ចាស់បំណុលនៃការអនុវត្ត) មាន ហើយដែលបានទទួលនូវការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៥៧) នៅផ្នែកខាងក្រោមនៃលិខិតនោះ ។ ប៉ុន្តែ ចំពោះសាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ, សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នវិញ ពុំចាំបាច់មានរូបមន្តអនុវត្តទេ ឱ្យតែការអនុវត្តដោយបង្ខំនោះ ធ្វើឡើងរវាងភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្តនោះ ពោលគឺថា លិខិតចម្លងយថាភូតទាំងនោះ ត្រូវចាត់ទុកជាលិខិតចម្លងយថាភូតដែលមានអានុភាពអនុវត្តតែម្តង (មាត្រា ៣៥៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

### (ii) **តួនាទី**

ម្ចាស់បំណុលនៃការអនុវត្ត ធ្វើការបញ្ជាក់អំពីអត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ (អត្ថន័យនៃសិទ្ធិទាមទារ, ម្ចាស់សិទ្ធិ, និង កូនបំណុល) និង ដែលត្រូវសម្រេច

ដោយការអនុវត្តដោយបង្ខំ តាមវិធីនៃការដាក់លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តដែលខ្លួនមាន ទៅឱ្យស្ថាប័នអនុវត្ត ។ សិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ ត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ហើយអានុភាពអនុវត្តនៃលិខិតអនុវត្តនោះ ត្រូវបានបញ្ជាក់តាមទម្រង់យថាភូតដោយការផ្តល់រូបមន្តអនុវត្តដែលជាសេចក្តីសរសេរបន្ថែមនៅក្នុងលិខិតនោះ ។ តាមរយៈវិធីនេះ វាធ្វើឱ្យមានភាពប្រាកដថា ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិទាមទារចំពោះអាជ្ញាធររដ្ឋ ឱ្យធ្វើការអនុវត្តដោយបង្ខំ (សិទ្ធិនេះ ហៅថា "សិទ្ធិទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំ") និង ថាម្ចាស់បំណុលនោះ មានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីប្រើសិទ្ធិនោះ ។

ក្នុងន័យនេះ សិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ ត្រូវបានបញ្ជាក់នៅក្នុងឯកសារមួយដែលហៅថា លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយឯកសារនេះនឹងក្លាយទៅជាមូលដ្ឋាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីមួយដែលធ្វើឡើងដើម្បីសម្រេចនូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ ។ ប៉ុន្តែ ស្ថាប័នអនុវត្ត ពុំធ្វើការសម្រេចសេចក្តីដោយផ្ទាល់ ទៅលើអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុទេ គឺគ្រាន់តែទទួលស្គាល់ដោយប្រយោល និង ជាទម្រង់ នូវអត្ថិភាពនៃសិទ្ធិនោះ តាមរយៈលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តប៉ុណ្ណោះ ដែលការទទួលស្គាល់នេះ គឺជាការបើកផ្លូវសម្រាប់នីតិវិធីជាបន្តទៀត ។

### (iii) ការអនុវត្តមិនត្រឹមត្រូវ និង ការអនុវត្តខុសច្បាប់

(១) ដោយសារថា ម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យអនុវត្ត ដោយផ្អែកលើលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដូច្នេះ ស្ថាប័នអនុវត្ត អាចនឹងអនុវត្តនូវនីតិវិធីនៃការអនុវត្តដោយបង្ខំដោយស្របតាមច្បាប់ ព្រមទាំងមានកាតព្វកិច្ចធ្វើបែបនេះ ដោយមិនបាច់គិតពិចារណាអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ និង អំពីអានុភាពនៃលិខិតអនុវត្តទេ ។ ក៏ប៉ុន្តែ ដោយសារថា គោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីសម្រេចនូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុនោះ ការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយពុំមានអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក និង ការអនុវត្តដោយបង្ខំដែលធ្វើឡើងចំពោះទ្រព្យសម្បត្តិក្រៅពីទ្រព្យសម្បត្តិដែលអាចយកដើម្បីសម្រេចសិទ្ធិទាមទារ (ទ្រព្យសម្បត្តិទទួលខុសត្រូវ) មិនត្រូវបានទទួលស្គាល់តាមវិធាននៃច្បាប់សារធាតុទេ ព្រោះវាគឺជាការអនុវត្តមិនត្រឹមត្រូវ ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីបញ្ចៀសនូវការអនុវត្តមិនត្រឹមត្រូវ ចាំបាច់ត្រូវមាននីតិវិធីនៃបណ្តឹងដូចជាបណ្តឹងតវ៉ាចំពោះការទាមទារ, បណ្តឹងតវ៉ារបស់តតិយជន ជាអាទិ៍ ។ ម្យ៉ាងទៀត ដោយសារថា ការអនុវត្តដោយបង្ខំបែបនេះ ជានីតិវិធីនៃការអនុវត្តដែលស្របច្បាប់ នោះស្ថាប័នរដ្ឋមិនត្រូវទទួលខុសត្រូវចំពោះ

រឿងនេះទេ ។ ដោយហេតុនេះហើយ បដិទាន ឬ វិធីសង្គ្រោះ ចំពោះការខូចខាតដែលទទួលរងដោយកូនបំណុលនៃការអនុវត្ត ឬ ដោយតតិយជន ដោយសារការអនុវត្តបែបនេះ ត្រូវសម្រេចដោយការទាមទារពីម្ចាស់បំណុលនៃការអនុវត្ត តាមការទាមទារឱ្យសងនូវសេចក្តីចម្រើនដោយឥតហេតុ ឬ ឱ្យសងសំណងនៃការខូចខាត ។ ដោយសារថា សំណងនៃការខូចខាតដោយផ្អែកលើការអនុវត្តមិនត្រឹមត្រូវ គឺជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ដូច្នេះ ជាទូទៅ វាអាចទាមទារបានតែក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មានកំហុសចេតនា ឬ អចេតនា តែប៉ុណ្ណោះ ( មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី) ។ ក៏ប៉ុន្តែ ចំពោះការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬ សាលដីកាចុងក្រោយដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ខ និង ចំណុច ឃ) ប្រសិនបើលិខិតអនុវត្តត្រូវបានលុបចោលនៅក្នុងនីតិវិធីនៃបណ្តឹងនាពេលក្រោយ នោះត្រូវបកស្រាយថា ម្ចាស់បំណុលត្រូវទទួលខុសត្រូវដោយពុំចាំបាច់មានកំហុស (មាត្រា ១៩៧ កថាខណ្ឌទី ២) ។ ចំណុចនេះ ក៏ត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការរឹបអូសជាបណ្តោះអាសន្នដែលមិនត្រឹមត្រូវ និង ចំពោះការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលមិនត្រឹមត្រូវ ។

(២) ដោយឡែក ចំពោះការអនុវត្តដោយបង្ខំ ដែលស្ថាប័នអនុវត្តធ្វើឡើងដោយបំពានច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំដែលខ្លួនត្រូវគោរពតាម ហៅថា ការអនុវត្តខុសច្បាប់ ។ ការសង្គ្រោះចំពោះការអនុវត្តខុសច្បាប់ ត្រូវធ្វើនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ តាមរយៈនីតិវិធីសាមញ្ញដូចជា បណ្តឹងជំទាស់ (មាត្រា ៣៨៣) ឬ ការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤) ។

ការទទួលខុសត្រូវចំពោះការអនុវត្តខុសច្បាប់ ត្រូវធ្លាក់ទៅលើស្ថាប័នអនុវត្ត ហើយបុគ្គលណាម្នាក់ដែលទទួលរងការខូចខាតដោយសារការអនុវត្តខុសច្បាប់នោះ អាចទាមទារសំណងនៃការខូចខាតពីសំណាក់អាជ្ញាធររដ្ឋបាន ទៅតាមករណីជាក់ស្តែង ។ ដោយឡែក ម្ចាស់បំណុលនៃការអនុវត្ត ពុំមានការទទួលខុសត្រូវដោយស្វ័យប្រវត្តិ ចំពោះការអនុវត្តខុសច្បាប់ទេ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បំណុលបានបណ្តាលឱ្យមានសកម្មភាពរបស់ស្ថាប័នអនុវត្ត ដោយកំហុសចេតនា ឬ អចេតនារបស់ខ្លួននោះ ម្ចាស់បំណុលអាចនឹងត្រូវទទួលខុសត្រូវចំពោះទង្វើនោះ ដោយអំពើអនីត្យានុកូល ។

## កថាភាគទី ២ លិខិតអនុវត្ត

### ១. គោលគំនិត និង តួនាទីនៃលិខិតអនុវត្ត

(១) លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកលើឯកសារនេះ ច្បាប់ផ្តល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះ តាមរយៈការអនុវត្តដោយបង្ខំ ។ អ្វីដែលជាលិខិតអនុវត្ត រួមមានជាចម្បង

សេចក្ដីសម្រេចរបស់តុលាការ និង កំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាពដូចសេចក្ដីសម្រេចរបស់តុលាការ ។ ក្រៅពីនេះ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ដោយផ្អែកលើសេចក្ដីថ្លែងការណ៍របស់ភាគី ក៏អាចជាលិខិតអនុវត្តដែរ ប្រសិនបើបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារមួយចំនួន (នេះហៅថា "លិខិតបញ្ជាក់អនុវត្ត") ។

(២) លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់ជាផ្លូវការ (តាមទម្រង់យថាភូត) អំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិក ដែលកំណត់នៅក្រោមនីតិឯកជន ។ តាមរយៈការបង្កើតលិខិតអនុវត្ត ទំនាក់ទំនងដែលថា ម្ចាស់សិទ្ធិមានសិទ្ធិទាមទារឱ្យអាជ្ញាធររដ្ឋ (ស្ថាប័នអនុវត្ត) ធ្វើការអនុវត្តដោយបង្ខំ និង ដែលថាកូនបំណុលត្រូវព្រមទទួលយកសកម្មភាពរបស់អាជ្ញាធររដ្ឋ (ស្ថាប័នអនុវត្ត) កើតចេញមកពីទំនាក់ទំនងនៃសិទ្ធិ និង កាតព្វកិច្ចរវាងភាគី នៅក្រោមនីតិឯកជន ។ អានុភាពអនុវត្តនៃលិខិតអនុវត្ត មិនបាត់បង់ដោយសារតែការណ៍ដែលថាសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកដែលកំណត់នៅក្រោមនីតិឯកជន ដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ពុំមានអត្ថិភាពដូចការបញ្ជាក់នោះទេ ។ ក៏ប៉ុន្តែ ប្រសិនបើស្ថានភាពនេះ ត្រូវបានកំណត់ជាស្ថាពរតាមរយៈបណ្ដឹង នោះអានុភាពអនុវត្តនោះ ត្រូវរលត់ ។ ការកំណត់អំពីភាពមិនស្របគ្នារវាងសេចក្ដីបញ្ជាក់នៅក្នុងលិខិតអនុវត្ត និង ភាពជាក់ស្ដែង ដែលទាក់ទងទៅនឹងសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិក និង ការបំភ្លឺអំពីហេតុដែលថាការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនេះ មិនត្រូវបានអនុញ្ញាតទេ នោះគឺជាតួនាទីនៃបណ្ដឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣) ។

(៣) ខ្លឹមសារ និង វិធីនៃការអនុវត្តដោយបង្ខំ ត្រូវកំណត់ដោយផ្អែកទៅលើលិខិតអនុវត្ត ។ អាស្រ័យទៅតាមស្ថានភាពផ្សេងៗ ខ្លឹមសារ និង វិធីនៃការអនុវត្តដោយបង្ខំ អាចត្រូវបានកម្រិត ឬ បន្ថែម ដោយរូបមន្តអនុវត្ត ។ ខ្លឹមសារនៃលិខិតអនុវត្ត ត្រូវបកស្រាយដោយស្ថាប័នអនុវត្ត នៅពេលធ្វើការអនុវត្ត ។ ភាគីណាមួយដែលមិនពេញចិត្តនឹងការបកស្រាយរបស់ស្ថាប័នអនុវត្ត នៅក្នុងករណីនេះ អាចធ្វើវិវាទ តាមរយៈបណ្ដឹងជំទាស់ ឬ តាមរយៈការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៣ និង មាត្រា ៣៨៤) អាស្រ័យទៅតាមប្រភេទនៃការចាត់ចែងការអនុវត្តដែលពាក់ព័ន្ធ ។ ក៏ប៉ុន្តែ ប្រសិនបើខ្លឹមសារ ឬ វិធីនៃការអនុវត្តដោយបង្ខំ មិនអាចធ្វើការកំណត់ដោយមិនឱ្យមានភាពស្រពេចស្រពិលបាន ដោយសារតែមានភាពមិនច្បាស់លាស់ នោះការអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើទៅបានទេ ហើយម្ចាស់បំណុល ត្រូវទទួលលិខិតអនុវត្តម្ដងទៀត សម្រាប់សិទ្ធិទាមទារនោះ ។

## ២. ប្រភេទផ្សេងៗនៃលិខិតអនុវត្ត

### (i) សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិក ដែលបានចូលជាស្ថាពរ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក)

សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិក ដែលចេញដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលបានចូលជាស្ថាពរ ត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត (ចំពោះសាលក្រម ឬ សាលដីកាដែលចេញ

ដោយតុលាការបរទេស សូមមើល (vii) ខាងក្រោម) ។ ចំពោះការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកា សូមមើលគន្លឹះទី ៣ ជំពូកទី ៤ ផ្នែកទី ១ កថាភាគទី ៣. **២.** នៃ "សេចក្តីពន្យល់ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង" ។

ក្នុងចំណោមសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ មានតែសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិកតែប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត ។ ទោះបីជាក្នុងករណីដែលសាលក្រម ឬ សាលដីកា ដែលពាក់ព័ន្ធ គឺជាសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយ ប្រសិនបើការអនុវត្តដោយបង្ខំ មិនអាចធ្វើទៅបាន អាស្រ័យដោយចរិតលក្ខណៈនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក នោះសាលក្រម ឬ សាលដីកានោះ ពុំមានអានុភាពអនុវត្តទេ ។ ឧទាហរណ៍ថាកាតព្វកិច្ចដែលត្រូវបំពេញ គឺជាកាតព្វកិច្ចគូរគំនូររបស់ជាងគំនូរណាម្នាក់ ។ ក្នុងករណីដែលបុគ្គលនោះ មិនព្រមបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តទេនោះ គេមិនអាចទទួលបានការផ្តល់តាវកាលិកដែលស្របទៅតាមគោលបំណងនៃកាតព្វកិច្ចនោះឡើយ ។ ជាងនេះទៅទៀត ក្នុងករណីដែលការបង្ខំកូនបំណុលដោយមិនគិតអំពីឆន្ទៈរបស់កូនបំណុលនោះ មានលក្ខណៈមិនអាចទទួលយកបានយោងតាមទស្សនទានសង្គម ព្រោះមានការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិបុគ្គល និង ភាពថ្លៃថ្នូររបស់កូនបំណុល នោះអានុភាពអនុវត្ត ក៏មិនត្រូវបានទទួលស្គាល់ដែរ ។ មានឧទាហរណ៍មួយចំនួនសម្រាប់ករណីបែបនេះ ដូចជាសិទ្ធិរបស់សហព័ទ្ធណាម្នាក់ដែលទាមទារឱ្យសហព័ទ្ធម្នាក់ទៀតមករស់នៅជាមួយគ្នា, សិទ្ធិឱ្យបុគ្គលណាម្នាក់មកធ្វើជាអ្នកបម្រើ, សិទ្ធិឱ្យបុគ្គលណាម្នាក់បញ្ចូលឈាម ជាអាទិ៍ ។

### (ii) សាលក្រម ឬ សាលដីកាចុងក្រោយ ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ខ)

ចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន សូមមើលគន្លឹះទី ៣ ជំពូកទី ៤ ផ្នែកទី ១ កថាភាគទី ៥. **១.** នៃ "សេចក្តីពន្យល់ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង" ។ ស្រដៀងគ្នាទៅនឹងករណីនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរដែរ ដោយសារថាការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបង្ខំ នឹងធ្វើឱ្យមានការវិវត្ត ទៅដល់ការសម្រេចនូវសិទ្ធិទាមទារជាស្ថាពរ ដូច្នេះ ការសម្រេចសិទ្ធិនេះ មិនមានលក្ខណៈបណ្តោះអាសន្នទេ ។

### (iii) ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ)

ជាគោលការណ៍ ដីកាសម្រេចមានអានុភាពភ្លាមបន្ទាប់ពីបានធ្វើការជូនដំណឹង ។ ប្រសិនបើដីកាសម្រេចនោះ គឺជាដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ដីកាសម្រេចនោះត្រូវមានអានុភាពអនុវត្ត ។ ឧទាហរណ៍នៃដីកាសម្រេចបែបនេះ មានដូចជា ដីកាសម្រេចបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តជំនួស (មាត្រា ៥២៧ កថាខណ្ឌទី ៤) ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ដើម្បីធានាការអនុវត្តកាតព្វកិច្ច នៅក្នុង

វិធានការបង្ខំដោយប្រយោល ( មាត្រា ៥២៨ កថាខណ្ឌទី ១) ជាអាទិ៍ ។ ក៏ប៉ុន្តែ ដីកាសម្រេចដែលត្រូវបាន កំណត់ថាមិនមានអានុភាពបើមិនទាន់ចូលជាស្ថាពរ មិនអាចក្លាយជាលិខិតអនុវត្តបានទេ រហូតដល់ពេលចូលជាស្ថាពរ ។ ឧទាហរណ៍នៃដីកាសម្រេចបែបនេះ គឺដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ ឬ នាវា ( មាត្រា ៤៥០ និង មាត្រា ៤៨៣) ។

### (iv) **ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ( មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឃ)**

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេលពីរសប្តាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬ ប្រសិនបើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន បានចូលជាស្ថាពរ នោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នឹងត្រូវបានភ្ជាប់ទៅនឹងដីកាសម្រេចដាស់តឿន ( មាត្រា ៣២៨, សូមមើលគន្លឹះទី ៦ ជំពូកទី ៣ នៃ "សេចក្តីពន្យល់ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង") ហើយដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបណ្តោះអាសន្ននោះ នឹងក្លាយទៅជាលិខិតអនុវត្ត ។

### (v) **ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលកំណត់អំពីចំនួនប្រាក់ប្រដាប់ក្តី ( មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ង)**

បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគ និង បន្ទុកនៃប្រាក់ប្រដាប់ក្តីហើយ ចំនួនទឹកប្រាក់លំអិត ត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូង តាមពាក្យសុំរបស់ភាគី ( មាត្រា ៦៦ កថាខណ្ឌទី ១) ។ ភាគីម្ខាងអាចធ្វើការអនុវត្តដោយបង្ខំ ឱ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្តី ដោយយកការចាត់ចែងរបស់ក្រឡាបញ្ជីនេះធ្វើជាលិខិតអនុវត្ត ។

### (vi) **លិខិតបញ្ជាក់អនុវត្ត ( មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច)**

( ១) លិខិតយថាភូតដែលធ្វើដោយសារការី និង ដែលបានបំពេញតាមល័ក្ខខ័ណ្ឌទាមទារមួយចំនួន ត្រូវបានទទួលស្គាល់ថាមានអានុភាពអនុវត្ត ក្នុងលក្ខណៈជាលិខិតអនុវត្ត ។ លិខិតយថាភូតធ្វើឡើងដោយសារការីដែលបានបំពេញតាមល័ក្ខខ័ណ្ឌទាមទារមួយចំនួននេះ ហៅថា លិខិតបញ្ជាក់អនុវត្ត ។ ដោយសារថាការអនុវត្តដោយបង្ខំ អាចធ្វើឡើងបានភ្លាមដោយពុំចាំបាច់ឆ្លងកាត់តាមបណ្តឹង ដូច្នេះ លិខិតបញ្ជាក់អនុវត្តត្រូវបានប្រើប្រាស់នៅក្នុងករណីជាច្រើន ដូចជាការខ្ចីបរិភោគ ក្នុងករណីដែលការខ្ចីដោយពុំមានដាក់ប្រាតិភោគ គឺជារឿងសាមញ្ញធម្មតា ។ ម៉្យាងវិញទៀត ទោះបីជាលិខិតយថាភូតដែលធ្វើដោយសារការី ត្រូវបានធ្វើឡើង ដោយយកសុពលភាពនៃកិច្ចសន្យានៅក្រោមច្បាប់សារធាតុមកជាបុរេល័ក្ខខ័ណ្ឌក៏ដោយ លិខិតនេះមិនកំណត់ជាស្ថាពរនូវសុពលភាពនៃកិច្ចសន្យាទេ ពោលគឺមិនដូចគ្នាទៅនឹងសាលក្រម ឬ សាលដីកាស្ថាពរឡើយ ។ នេះគឺព្រោះតែ

សិទ្ធិអំណាចនៅក្នុងការត្រួតពិនិត្យរបស់សារការី ត្រូវបានកម្រិត ហើយលិខិតយថាភូតធ្វើដោយសារការី ត្រូវបានធ្វើឡើង ដោយមិនផ្អែកទៅលើការពិនិត្យ និង ទទួលស្គាល់អង្គហេតុ និង ការសម្រេចសេចក្តី តាមផ្លូវច្បាប់របស់ចៅក្រមទេ ។ អាស្រ័យហេតុនេះហើយ ដោយសារថាលទ្ធភាពដែលនាំឱ្យមានការអនុវត្ត មិនត្រឹមត្រូវ មានទ្រង់ទ្រាយធំ ដូច្នេះ ទើបអានុភាពអនុវត្ត ត្រូវបានទទួលស្គាល់តែចំពោះលិខិតយថាភូតធ្វើ ដោយសារការី ដែលមានកម្មវត្ថុជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ ព្រោះវាមានភាព ងាយស្រួលក្នុងការធ្វើបដិទាននូវផលប្រយោជន៍ ដែលបានទទួលដោយសារការអនុវត្តដោយបង្ខំ ឬ ក្នុងការ សងសំណងនៃការខូចខាត ប្រសិនបើការអនុវត្តដោយបង្ខំនោះ ធ្វើឡើងដោយមិនត្រឹមត្រូវ ។

(២) ល័ក្ខខ័ណ្ឌទាមទារនៃលិខិតបញ្ជាក់អនុវត្ត មានដូចតទៅ :

(ក) គប្បីជាលិខិតយថាភូតធ្វើឡើងដោយសារការី ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន និង តាមវិធីដែល ត្រឹមត្រូវ ។ បើគ្រាន់តែឱ្យសារការី ធ្វើការបញ្ជាក់នៅលើលិខិតឯកជននោះ មិនគ្រប់គ្រាន់ទេ ។

(ខ) គប្បីបញ្ជាក់អំពីសិទ្ធិទាមទារដែលមានកម្មវត្ថុជាការសងប្រាក់មួយចំនួនជាក់លាក់ ។ អានុភាពអនុវត្ត មិនត្រូវបានទទួលស្គាល់ចំពោះលិខិតយថាភូតធ្វើដោយសារការី ដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យចាកចេញពី លំនៅឋាន ជាអាទិ៍ ឡើយ ។ ចំនួនទឹកប្រាក់ ត្រូវមានភាពច្បាស់លាស់ ដើម្បីងាយស្រួលគណនា ក៏ប៉ុន្តែ គេក៏អាចភ្ជាប់នូវពេលកំណត់ និង ល័ក្ខខ័ណ្ឌនានា បានដែរ ។ ចំពោះការរៀបរាប់នៅក្នុងលិខិតយថាភូត ធ្វើដោយសារការី គប្បីបញ្ជាក់ថា សិទ្ធិទាមទារ គឺជាសិទ្ធិដែលបានកំណត់ជាក់លាក់ ហើយប៉ុណ្ណោះ គឺជាការ គ្រប់គ្រាន់ហើយ ។ ភាពពិត ឬ មិនពិតនៃហេតុដែលបានរៀបរាប់នៅក្នុងលិខិត មិនទាក់ទងទៅនឹងអានុភាព នៃលិខិតនោះទេ ។

(គ) គប្បីរៀបរាប់អំពីការបង្ហាញឆន្ទៈរបស់កូនបំណុលថា នឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។ ពាក្យថា ភ្លាមៗ នៅទីនេះ មានន័យថា ដោយពុំឆ្លងកាត់តាមនីតិវិធីនៃបណ្តឹង ។ ការបង្ហាញឆន្ទៈទទួលយកការអនុវត្ត ដោយបង្ខំនេះ គប្បីធ្វើឡើងដោយមានអានុភាព ហើយបើគ្រាន់តែធ្វើជាទម្រង់នោះ គឺមិនគ្រប់គ្រាន់ទេ ។ ប្រសិនបើមានវិការៈផ្សេងៗទាក់ទងទៅនឹងសមត្ថភាព សិទ្ធិតំណាង ជាអាទិ៍នោះ អានុភាពអនុវត្ត មិនត្រូវ កើតឡើងទេ ។

### (vii) **សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឆ)**

(១) សាលក្រមអនុវត្ត មានន័យថាជាសាលក្រមដែលផ្តល់អានុភាពស្ថាពរ ទៅឱ្យសាលក្រម ឬ សាល ដីការបស់តុលាការបរទេស (ពីត្រឹមនេះទៅ ហៅថា សាលក្រម ឬ សាលដីកាបរទេស) ។ ប្រសិនបើសាលក្រម ឬ សាលដីកាបរទេស បានបំពេញគ្រប់ល័ក្ខខ័ណ្ឌមួយចំនួន សាលក្រម ឬ សាលដីកាបរទេសនោះ នឹងត្រូវបាន ទទួលស្គាល់នូវអានុភាព ដូចជាសាលក្រម ឬ សាលដីកាស្ថាពររបស់តុលាការកម្ពុជាដែរ (មាត្រា ១៩៩) ។ ក្នុង

ករណីដែលអានុភាពនៃសាលក្រម ឬ សាលដីកាបរទេស (ជាពិសេស អាជ្ញាអស់ជំនុំ) ក្លាយទៅជាបញ្ហាវិវាទនៅក្នុងនីតិវិធីបណ្តឹងនាតុលាការកម្ពុជា នោះតុលាការដែលទទួលបន្ទុកនូវបណ្តឹងនេះ គ្រាន់តែធ្វើការវិនិច្ឆ័យថា តើល័ក្ខខ័ណ្ឌទាមទារនៃមាត្រា ១៩៩ ត្រូវបានបំពេញគ្រប់ដែរឬទេ នោះគឺជាការគ្រប់គ្រាន់ហើយ ។ នៅក្នុងករណីបែបនេះ ពុំចាំបាច់មាននីតិវិធីពិសេសសម្រាប់ការទទួលស្គាល់ទេ (ការទទួលស្គាល់ដោយស្វ័យប្រវត្តិ) ។

ម៉្យាងវិញទៀត ប្រសិនបើការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាបរទេស នោះការវិនិច្ឆ័យអំពីល័ក្ខខ័ណ្ឌទាមទារសម្រាប់ការទទួលស្គាល់សាលក្រម ឬ សាលដីកាបរទេស នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ពុំមែនជាទង្វើត្រឹមត្រូវឡើយ ព្រោះថា ស្ថាប័នដែលផ្តល់រូបមន្តអនុវត្ត និង ស្ថាប័នអនុវត្ត ត្រូវបានបង្កើតឡើងដោយផ្តោតភាពសំខាន់ទៅលើការសម្រេចនូវសិទ្ធិ ដែលមានលក្ខណៈឆាប់រហ័ស និង មានប្រសិទ្ធភាព ។ ម៉្យាងទៀត បើមើលពីទស្សនវិស័យផ្នែករចនាសម្ព័ន្ធនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ នីតិវិធីនេះ ពុំប្រើរចនាសម្ព័ន្ធពេញលេញដែលឱ្យភាគីទាំងសងខាងប្រឈមមុខដាក់គ្នាដោយឈរលើគោលការណ៍ស្មើភាពនោះទេ គឺខុសគ្នាពីនីតិវិធីបណ្តឹង ។ អាស្រ័យហេតុនេះហើយ ទើបមានការតម្រូវឱ្យធ្វើការវិនិច្ឆ័យជាមុន ថាតើល័ក្ខខ័ណ្ឌទាមទារត្រូវបានបំពេញគ្រប់គ្រាន់ដែរឬទេ តាមរយៈនីតិវិធីបណ្តឹង (បណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត) ពោលគឺនៅក្រៅនីតិវិធីនៃការអនុវត្តដោយបង្ខំ ហើយស្ថាប័នអនុវត្ត ត្រូវធ្វើការអនុវត្តដោយបង្ខំ នូវសាលក្រម ឬ សាលដីកាបរទេសនោះ ដោយយកសាលក្រមអនុវត្តនោះមកធ្វើជាបុរេល័ក្ខខ័ណ្ឌ ។ ហេតុនេះហើយ គេអាចនិយាយបានថា សាលក្រម ឬ សាលដីកាបរទេសដែលពាក់ព័ន្ធ រួមគ្នាជាមួយនឹងសាលក្រមអនុវត្ត បង្កើតបានជាលិខិតអនុវត្ត ។

(២) ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត ត្រូវកំណត់ទៅតាមលំនៅឋាន ជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត (ចុងចម្លើយ) (មាត្រា ៨) ។ ប្រសិនបើកូនបំណុលពុំមានលំនៅឋាន ជាអាទិ៍ ទេ តុលាការមានសមត្ថកិច្ច គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងស្ថិតនៅនៃកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យដែលអាចធ្វើការរឹបអូសបានរបស់កូនបំណុលនៃការអនុវត្ត (ចុងចម្លើយ) (មាត្រា ៣៥២ កថាខណ្ឌទី ២) ។ គេគប្បីយល់ថា ចរិតលក្ខណៈនៃបណ្តឹងនេះ គឺជាបណ្តឹងទាមទារឱ្យបញ្ជាក់នៅក្រោមច្បាប់នីតិវិធី ដែលសុំឱ្យតុលាការបញ្ជាក់អំពីការចូលជាស្ថាពរនូវអានុភាពនៃសាលក្រម ឬ សាលដីកាបរទេស ជាពិសេស អានុភាពអនុវត្តនៃសាលក្រម ឬ សាលដីកាបរទេសនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គួរចាត់ទុកថា ការទទួលស្គាល់សាលក្រម ឬ សាលដីកាបរទេស មានន័យមិនត្រឹមតែការទទួលស្គាល់នូវអាជ្ញាអស់ជំនុំនៃសាលក្រម ឬ សាលដីកានោះប៉ុណ្ណោះទេ គឺមានន័យជាការទទួលស្គាល់នូវអានុភាពអនុវត្ត ព្រមទាំងអានុភាពបង្កើតទំនាក់ទំនងគតិយុត្តរបស់វាផងដែរ ហើយរបបនៃសាលក្រមអនុវត្ត ត្រូវបានបង្កើតឡើង ក្នុងគោលបំណងធ្វើឱ្យតុលាការនៃព្រះរាជាណាចក្រកម្ពុជា ពិនិត្យទៅលើអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌទាមទារ សម្រាប់ការអនុវត្តដោយបង្ខំ នៅមុនពេលធ្វើការ

អនុវត្តដោយបង្ខំ ដូចបានរៀបរាប់ខាងលើ ។ម្យ៉ាងទៀត វិសាលភាពនៃអានុភាពអនុវត្តរបស់សាលក្រម ឬ សាលដីកាបរទេស ត្រូវកំណត់ដោយផ្អែកទៅតាមច្បាប់នៃប្រទេសដែលពាក់ព័ន្ធនោះ ។

នៅក្នុងបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត តុលាការធ្វើការវិនិច្ឆ័យតែទៅលើចំណុចថាតើសាលក្រម ឬ សាលដីកាបរទេសដែលបានចូលជាស្ថាពរនោះ បានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារនៃមាត្រា ១៩៩ ដែរឬទេ ហើយចំណែកឯចំណុចថាតើខ្លឹមសារនៃសាលក្រម ឬ សាលដីកាបរទេសនោះ ត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ពោល គឺចំណុចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារ ដែលសាលក្រម ឬ សាលដីកាបរទេសនោះបានទទួលស្គាល់វិញ តុលាការមិនធ្វើការស្រាវជ្រាវទេ (មាត្រា ៣៥២ កថាខណ្ឌទី ៤) ។ហេតុនេះហើយ ចុងចម្លើយ មិនអាចធ្វើវិវាទទៅលើអត្ថិភាពនៃសិទ្ធិដែលបានទទួលស្គាល់ដោយសាលក្រម ឬ សាលដីកាបរទេសទេ ។ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ គប្បីយល់ថា ហេតុដែលបានកើតឡើងនៅក្រោយពេលដែលសាលក្រម ឬ សាលដីកាបរទេសនេះ មានអាជ្ញាអស់ជំនុំ អាចលើកមកអះអាងនៅពេលមានបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្តនេះបាន ។

ក្រោយពីធ្វើការវិនិច្ឆ័យ ប្រសិនបើតុលាការយល់ឃើញថា ល័ក្ខខ័ណ្ឌទាមទារសម្រាប់ការទទួលស្គាល់សាលក្រម ឬ សាលដីកាបរទេស (មាត្រា ១៩៩) ត្រូវបានបំពេញគ្រប់ហើយ នោះតុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសាលក្រម ឬ សាលដីកាបរទេសនោះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម (មាត្រា ៣៥២ កថាខណ្ឌទី ៥) ។សាលក្រមនេះ ហៅថា សាលក្រមអនុវត្ត ។ប្រសិនបើសាលក្រមអនុវត្តនេះ ចូលជាស្ថាពរ ឬ មានភ្ជាប់ជាមួយនូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នៅពេលនោះ អានុភាពអនុវត្តនឹងកើតមានឡើង ។ប៉ុន្តែ យ៉ាងណាក៏ដោយ រូបមន្តអនុវត្ត ត្រូវមានភ្ជាប់ជាមួយនឹងសាលក្រមនោះផងដែរ ។ក្នុងករណីផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថាល័ក្ខខ័ណ្ឌទាមទារនៃមាត្រា ១៩៩ មិនបានបំពេញគ្រប់ទេនោះ តុលាការត្រូវលើកចោលបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត (មាត្រា ៣៥២ កថាខណ្ឌទី ៣) ។ នៅក្នុងករណីដែលមិនអាចបញ្ជាក់ថាសាលក្រម ឬ សាលដីកាបរទេសនោះ បានចូលជាស្ថាពរ ក៏តុលាការត្រូវលើកចោលបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្តនោះដែរ ។

### (viii) សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្ត ដែលបានចូលជាស្ថាពរ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ជ)

(១) នីតិវិធីមជ្ឈត្តកម្ម គឺជានីតិវិធីនៃការដោះស្រាយវិវាទជំនួសនីតិវិធីបណ្តឹង ហើយសេចក្តីសម្រេចមជ្ឈត្តករ ដែលជាលទ្ធផលនៃនីតិវិធីនេះ មានអានុភាពចងចំពោះភាគី ដូចជាសាលក្រម ឬ សាលដីកាស្ថាពរដែរ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ប្រសិនបើមានវិការៈនៅក្នុងនីតិវិធីមជ្ឈត្តកម្ម ភាគីអាចសុំឱ្យតុលាការលុបចោលសេចក្តីសម្រេចមជ្ឈត្តករនោះបាន (មាត្រា ៣៤ នៃច្បាប់គំរូស្តីពីមជ្ឈត្តកម្មនៃ UNCITRAL) ។អាស្រ័យហេតុនេះហើយ មានតែក្នុងករណីដែលពុំមានមូលហេតុនៃការលុបចោលសេចក្តីសម្រេចមជ្ឈត្តករតែប៉ុណ្ណោះ ដែល

គប្បីអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្តីសម្រេចនោះ ។ ដោយសារថាការបញ្ជាក់អំពីនត្ថិភាពនៃមូលហេតុនៃការលុបចោល ត្រូវធ្វើឡើងតាមការពិនិត្យស្រាវជ្រាវយ៉ាងហ្មត់ចត់ ដូច្នេះការណ៍នេះមិនគប្បីនឹងឱ្យស្ថាប័នអនុវត្ត ឬ ស្ថាប័នដែលផ្តល់រូបមន្តអនុវត្តជាអ្នកធ្វើនោះទេ គឺត្រូវឱ្យតុលាការជាអ្នកធ្វើការបញ្ជាក់វិញ ។

ដូចបានរៀបរាប់ខាងលើ ភាពចាំបាច់នៃការទទួលស្គាល់ដោយតុលាការកម្ពុជា នូវអានុភាពនៃសេចក្តីសម្រេចមជ្ឈត្តករ ដោយចាត់ទុកថានេះគឺជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្តីសម្រេចនេះ គឺដូចគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំតាមសាលក្រម ឬ សាលដីកាបរទេសដែរ ។ ក៏ប៉ុន្តែចរិតលក្ខណៈ និង គុណសម្បត្តិនៃនីតិវិធីមជ្ឈត្តកម្ម គឺការដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងឆាប់រហ័សតាមរយៈនីតិវិធីដែលមានលក្ខណៈបត់បែន ដោយមជ្ឈត្តករដែលជាបុគ្គលឯកជន ។ ដោយសារហេតុផលនេះហើយបានជាខុសគ្នាពីការអនុវត្តដោយបង្ខំនូវសាលក្រម ឬ សាលដីកាបរទេស នីតិវិធីនៃការបញ្ជាក់អំពីអានុភាពនៃសេចក្តីសម្រេចមជ្ឈត្តករ ដែលជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តដោយបង្ខំ មិនទាមទារឱ្យមានការវិនិច្ឆ័យដោយឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ គឺត្រូវធ្វើឡើងតាមរយៈនីតិវិធីនៃការចេញដីកាសម្រេចវិញ (ដីកាសម្រេចអនុវត្ត, មាត្រា ៣៥៣ កថាខណ្ឌទី ១) ។ សេចក្តីសម្រេចមជ្ឈត្តករ និងដីកាសម្រេចអនុវត្ត រួមគ្នា បានជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ជ) ។

(២) ជាគោលការណ៍ ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត (ភាគីម្ខាងទៀត) (មាត្រា ៨) ។ ក៏ប៉ុន្តែ ក្នុងករណីដែលពុំមានលំនៅឋាន ជាអាទិ៍ នោះតុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបានស្ថិតនៅ (មាត្រា ៣៥៣ កថាខណ្ឌទី ៥) ។ ពាក្យសុំនេះ គឺសុំឱ្យបញ្ជាក់ថាពុំមានវិការៈណាមួយនៅក្នុងការសម្រេចសេចក្តីរបស់មជ្ឈត្តករ (មាត្រា ៣៥៣ កថាខណ្ឌទី ៣) ក៏ដូចជាពុំមានមូលហេតុណាមួយនៃការបដិសេធការអនុវត្តដោយបង្ខំទេ (មាត្រា ៣៥៣ កថាខណ្ឌទី ៤) ។ ជាងនេះទៅទៀត នៅពេលដែលព្រះរាជាណាចក្រកម្ពុជាបង្កើតច្បាប់ស្តីពីមជ្ឈត្តកម្ម នាពេលអនាគតនោះ ចំណុចដែលបានកំណត់នៅក្នុងមាត្រា ៣៥៣ កថាខណ្ឌទី ៣ ក៏នឹងត្រូវបានចែងជាមូលហេតុនៃការលុបចោលសេចក្តីសម្រេចមជ្ឈត្តករដែរ ។

ការសម្រេចសេចក្តីរបស់តុលាការ ទៅលើពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករត្រូវធ្វើឡើងទៅលើចំណុចថាតើមូលហេតុដែលមានចែងនៅក្នុងមាត្រា ៣៥៣ កថាខណ្ឌទី ៣ និង ទី ៤ មានអត្ថិភាពដែរឬទេ ហើយការសម្រេចសេចក្តីនេះ មិនធ្វើទៅលើចំណុចថាតើខ្លឹមសារនៃសេចក្តីសម្រេចមជ្ឈត្តករនោះ មានភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនោះទេ (មាត្រា ៣៥៣ កថាខណ្ឌទី ៧) ។ ប្រសិនបើមាន

មូលហេតុទាំងនោះ តុលាការត្រូវលើកចោលពាក្យសុំ ដោយដីកាសម្រេច ។ ប្រសិនបើពុំមានមូលហេតុទាំងនោះទេ តុលាការត្រូវចេញដីកាសម្រេចប្រកាសអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្ដីសម្រេចមជ្ឈត្តករនោះ (ដីកាសម្រេចអនុវត្ត) ។ ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្ត អាចប្ដឹងជំទាស់បាន (មាត្រា ៣៩៣ កថាខណ្ឌទី ៩) ។ ជាងនេះទៅទៀត ដោយសារថាដីកាសម្រេចអនុវត្តចូលជាស្ថាពរ សុពលភាពនៃសេចក្ដីសម្រេចមជ្ឈត្តករក៏ចូលជាស្ថាពរដែរ ដូច្នេះ គួរបកស្រាយថា បន្ទាប់ពីនោះ គេមិនអាចសុំឱ្យលុបចោលសេចក្ដីសម្រេចនោះបានទៀតទេ ។

(៣) សេចក្ដីសម្រេចមជ្ឈត្តករដែលផ្អែកលើកិច្ចសន្យាមជ្ឈត្តកម្មដែលធ្វើឡើងតាមច្បាប់បរទេស និង សេចក្ដីសម្រេចមជ្ឈត្តករដែលបានធ្វើឡើងនៅបរទេស ហៅថា "សេចក្ដីសម្រេចមជ្ឈត្តករបរទេស" ។ ជាគោលការណ៍ ការអនុវត្តដោយបង្ខំនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេស ត្រូវធ្វើឡើងតាមវិធីដូចបានរៀបរាប់ខាងលើដែរ លើកលែងតែថា តុលាការដែលមានសមត្ថកិច្ចលើពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករបរទេស គឺសាលាឧទ្ធរណ៍ (មាត្រា ៣៩៣ កថាខណ្ឌទី ៦) ។ម្យ៉ាងទៀត ព្រះរាជាណាចក្រកម្ពុជា ជាសមាជិកនៃអនុសញ្ញាញូវយ៉ក ហេតុដូច្នេះ ការអនុវត្តដោយបង្ខំនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេស ដែលជាកម្មវត្ថុនៃអនុសញ្ញាញូវយ៉កនេះ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃអនុសញ្ញានេះ ។

### (ix) កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឈ)

កំណត់ហេតុនៃការទទួលស្គាល់ការទាមទារ និង កំណត់ហេតុនៃការសះជាតាមផ្លូវតុលាការ (មាត្រា ២២២) សុទ្ធតែត្រូវបានរាប់ចូលជាកំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរ ។ លើសពីនេះទៅទៀត នៅពេលដែលរបបសន្ទានកម្ម និង របបក្ស័យធន ត្រូវបានបង្កើតឡើងនោះ ទៅតាមករណីនីមួយៗ កំណត់ហេតុដែលរៀបរាប់អំពីខ្លឹមសារនៃសន្ទានកម្មដែលបានធ្វើឡើងនៅតុលាការ (កំណត់ហេតុនៃសន្ទានកម្ម) និង បញ្ជីឈ្មោះម្ចាស់បំណុលដែលមានអានុភាពស្ថាពរ នឹងក្លាយជាលិខិតអនុវត្តដែលស្ថិតនៅក្រោមការអនុវត្តនៃមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឈ នេះដែរ ។

### (x) លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ (មាត្រា ៤៩៦)

សូមមើលជំពូកទី ៣ ផ្នែកទី ២ កថាភាគទី ១. ២. ខាងក្រោម ។

## ៣. បណ្ដឹងតវ៉ាចំពោះការទាមទារ

### (i) គោលគំនិត

(១) គោលបំណងនៃបណ្ដឹងតវ៉ាចំពោះការទាមទារ គឺដើម្បីឱ្យមានការវិនិច្ឆ័យតាមនីតិវិធីបណ្ដឹង អំពីអត្ថិភាព/នត្ថិភាព និង អត្ថន័យ នៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់នៅក្រោមច្បាប់សារធាតុ

ដែលលិខិតអនុវត្តបានបញ្ជាក់ថាមានអត្ថិភាព ហើយប្រសិនបើក្រោយការវិនិច្ឆ័យនេះ តុលាការរកឃើញថា សិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគនោះពុំមានអត្ថិភាពទេ បណ្តឹងនេះមានគោលបំណងឱ្យតុលាការធ្វើការប្រកាសនៅក្នុងសាលក្រមថា ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះ មិនត្រូវបានអនុញ្ញាតទេ និង ឱ្យដកចេញនូវនីតិវិធីនៃការអនុវត្តដោយបង្ខំផងដែរ (មាត្រា ៣៦៣ កថាខណ្ឌទី ១) ។

ដូចបានពោលខាងដើម គោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់នៅក្រោមច្បាប់សារធាតុ ។ ប៉ុន្តែ ក៏មានការកំណត់ដែរថា ស្ថាប័នអនុវត្ត ត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយមិនបាច់ស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តទេ ។ អាស្រ័យហេតុនេះហើយ អំណាចនៃសេចក្តីសម្រេចដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តចំពោះស្ថាប័នអនុវត្តដែលនោះ គឺជាអានុភាពអនុវត្ត មិនអាចត្រូវបានរំលាយដោយសារតែហេតុដែលថាសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគនោះ មិនត្រូវបានបង្កើតឡើង ឬ បានរលត់ទៅវិញ ឬ ដោយសារការអះអាងអំពីហេតុនោះដោយអត្តនោម័តិរបស់កូនបំណុលនៃការអនុវត្តឡើយ ។ ដើម្បីបដិសេធនូវអានុភាពអនុវត្ត ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរ តាមរយៈនីតិវិធីបណ្តឹង ថាអត្ថិភាព/នត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ មានលក្ខណៈខុសគ្នាពីការបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។ ចាប់ពីត្រឹមនេះទៅ គឺជាការពន្យល់អំពីករណីនៃការអនុវត្តដោយបង្ខំ ដើម្បីសម្រេចនូវសិទ្ធិទាមទារ ។ ដោយឡែក ចំពោះវិធានពិសេសទាក់ទងទៅនឹងបណ្តឹងតវ៉ាចំពោះការទាមទារ ដែលធ្វើឡើងចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ សូមមើលជំពូកទី ៣ ផ្នែកទី ២ កថាភាគទី ១. ៣. ខាងក្រោម ។

(២) មានទស្សនៈមិនស្របគ្នាអំពីចរិតលក្ខណៈនៃបណ្តឹងតវ៉ាចំពោះការទាមទារ ។ ក៏ប៉ុន្តែ វាសមហេតុផលនឹងគិតថា បណ្តឹងនេះ គឺជាបណ្តឹងពិសេស ដែលមានគោលបំណងសុំឱ្យធ្វើការកំណត់អំពីអត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត និង ឱ្យឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការកំណត់នោះ ទៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ កម្មវត្ថុនៃបណ្តឹង គឺការបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលបានបង្ហាញនៅក្នុងលិខិតអនុវត្ត និង ការសុំឱ្យតុលាការចេញបង្គាប់ទៅស្ថាប័នអនុវត្តដើម្បីហាមឃាត់ ឬ លុបចោលការអនុវត្តដោយបង្ខំ ដោយផ្អែកលើការបញ្ជាក់នេះ ។ គួរយល់ថាសាលក្រមសម្រេចអង្គសេចក្តីនៃបណ្តឹងនេះ មានអាជ្ញាអស់ជំនុំ ចំពោះអត្ថិភាព ឬ នត្ថភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ។

(៣) បណ្តឹងតវ៉ាចំពោះការទាមទារ ធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃអត្ថិភាពរបស់លិខិតអនុវត្តដែលមានអានុភាព ។ ក៏ប៉ុន្តែ គោលបំណងនៃបណ្តឹងនេះ ពុំមែនសុំឱ្យលុបចោលនូវលិខិតអនុវត្តនោះទេ ។ ត្រង់ចំណុចនេះ បណ្តឹងតវ៉ាចំពោះការទាមទារ មានលក្ខណៈខុសគ្នាពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលផ្អែកលើមូលហេតុថាសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរហើយ មានវិការៈមិនធម្មតា ។ ជាងនេះទៅទៀត

ដើម្បីបញ្ឈប់ការអនុវត្តដោយបង្ខំ ដោយមូលហេតុនត្ថិភាពនៃលិខិតអនុវត្តដែលមានអានុភាព នោះត្រូវដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦២) ឬ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦៤) ។

(ii) **មូលហេតុនៃបណ្តឹងតវ៉ាចំពោះការទាមទារ**

(១) មូលហេតុដែលដើមចោទអាចលើកឡើងធ្វើជាមូលដ្ឋាននៃការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ គឺការតវ៉ាទាក់ទងនឹងអត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារ ដូចជាករណីដែលសិទ្ធិទាមទារមិនបានកើតមានឡើង (ការមិនបានបង្កើតកិច្ចសន្យា, មោឃភាពនៃកិច្ចសន្យាដោយសារមានវិការៈនៅក្នុងការបង្ហាញឆន្ទៈ, ពុំមានហេតុកើតឡើងដែលត្រូវនឹងខសន្យាសងការខូចខាត ជាអាទិ៍), ករណីដែលសិទ្ធិទាមទារបានរលត់ (ការសង, ការទូទាត់, នវកម្ម, ការលើកលែង, ការរលត់សិទ្ធិដោយអាជ្ញាយុកាល, ការរំលាយកិច្ចសន្យា, ការលុបចោល, ការបានបំពេញល័ក្ខខ័ណ្ឌរំលាយ ជាអាទិ៍), ករណីដែលមានការផ្លាស់ប្តូរនូវទម្រង់នៃសិទ្ធិទាមទារ ឬ ការទទួលខុសត្រូវ (ការពន្យារពេលកំណត់, ការផ្លាស់ប្តូរល័ក្ខខ័ណ្ឌនៃការអនុវត្តកាតព្វកិច្ច , ហេតុនៃការកម្រិតការទទួលខុសត្រូវដែលមិនបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ជាអាទិ៍) ។

(២) ប្រសិនបើលិខិតអនុវត្តគឺជាសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ សាលក្រម ឬ សាលដីកានេះ មានអាជ្ញាអស់ជំនុំទៅលើសិទ្ធិទាមទារ ។ ហេតុនេះហើយ មូលហេតុនៃការតវ៉ាដែលអាចលើកឡើងបានត្រូវកម្រិតត្រឹមហេតុដែលកើតឡើង នៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះអង្គហេតុនៅក្នុងនីតិវិធីបណ្តឹងមុន តែប៉ុណ្ណោះ (មាត្រា ៣៦៣ កថាខណ្ឌទី ២) ។ ដោយសារថា លិខិតអនុវត្តផ្សេងទៀត ពុំមានអាជ្ញាអស់ជំនុំ ទើបពុំមានការកម្រិតទៅលើមូលហេតុសម្រាប់ការតវ៉ា ។ ឧទាហរណ៍ គេអាចលើកឡើងអំពីហេតុដែលថាសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ពុំបានកើតឡើង បាន ។

(៣) ទោះបីជាមូលហេតុសម្រាប់ការតវ៉ាដែលបានលើកឡើងចំពោះសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត មានច្រើនក៏ដោយ ក៏មិនមែនមានន័យថាជាការបញ្ចូលរឿងក្តីទេ ។ ដោយសារថាកម្មវត្ថុនៃបណ្តឹងបែបនេះ ត្រូវបានបែងចែកទៅតាមសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដូច្នេះ ឱ្យតែមានកម្មវត្ថុដូចគ្នា ភាពខុសគ្នានៃមូលហេតុសម្រាប់ការតវ៉ា មិននាំឱ្យមានបណ្តឹងមួយផ្សេងទៀតទេ ។

(iii) **ល័ក្ខខ័ណ្ឌនៃបណ្តឹងតវ៉ាចំពោះការទាមទារ**

(១) បុគ្គលដែលក្លាយជាដើមចោទនៃបណ្តឹងតវ៉ាចំពោះការទាមទារ គឺបុគ្គលដែលទទួលនូវអានុភាពអនុវត្តនៃលិខិតអនុវត្ត (កូនបំណុលដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត និង ប្រតិសិទ្ធិនៃកូនបំណុលនោះ ជាអាទិ៍) ហើយបុគ្គលដែលក្លាយជាចុងចម្លើយ គឺបុគ្គលដែលទទួលផលពីអានុភាពអនុវត្តនៃលិខិតអនុវត្ត (ម្ចាស់បំណុលដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត និង ប្រតិសិទ្ធិនៃម្ចាស់បំណុលនោះ ជាអាទិ៍) ។ បុគ្គលទាំងពីរនេះ គ្រប់គ្រាន់ហើយដើម្បីធ្វើជាបុគ្គលដែលទទួលអានុភាពពីលិខិតអនុវត្ត (មាត្រា ៣៥១) និង

អាចធ្វើជាភាគីនៃបណ្តឹងតវ៉ាចំពោះការទាមទារ ទោះបីជានៅក្នុងដំណាក់កាលដែលលិខិតអនុវត្ត ឬ រូបមន្តអនុវត្ត ពុំទាន់ត្រូវបានបញ្ជាក់បុគ្គលនោះក៏ដោយ ។ ដូចបានពោលខាងលើ គោលបំណងនៃបណ្តឹងតវ៉ាចំពោះការទាមទារ គឺដើម្បីផាត់ចេញនូវនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ក៏ប៉ុន្តែ បណ្តឹងនេះ គឺជាបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងរវាងបុគ្គលឯកជន ហើយស្ថាប័នអនុវត្ត មិនក្លាយទៅជាចុងចម្លើយទេ ។

(២) បណ្តឹងតវ៉ាចំពោះការទាមទារ អាចធ្វើឡើងបាន នៅក្នុងករណីដែលមានវិវាទអំពីអត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។ ក៏ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង នៅក្នុងដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នវិញ បណ្តឹងនេះ មិនអាចធ្វើឡើងបានទេ ប្រសិនបើលិខិតអនុវត្តទាំងនេះ មិនទាន់ចូលជាស្ថាពរ (មាត្រា ៣៦៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ នេះក៏ព្រោះថា នៅមុនពេលដែលលិខិតអនុវត្តទាំងនេះចូលជាស្ថាពរ វិវាទអំពីសិទ្ធិទាមទារទាំងនេះ ត្រូវធ្វើឡើងតាមរយៈនីតិវិធីនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (មាត្រា ២៦០ និង មាត្រា ២៨៣) ឬ តាមរយៈនីតិវិធីនៃពាក្យសុំតវ៉ា (មាត្រា ៣២៩) ។ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ បណ្តឹងតវ៉ាចំពោះការទាមទារអាចធ្វើឡើងបាន ដើម្បីធ្វើវិវាទទៅនឹងអត្ថិភាពនៃសិទ្ធិប្រាតិភោគ ក៏ដូចជាអត្ថិភាព និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ។

(៣) ឱ្យតែមានលិខិតអនុវត្តដែលមានអានុភាព បណ្តឹងតវ៉ាចំពោះការទាមទារ អាចធ្វើទៅបាន ទោះបីនៅមុនពេលចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬ នៅមុនពេលផ្តល់រូបមន្តអនុវត្ត ក៏ដោយ ។ នៅពេលណាដែលការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនោះ បានចប់សព្វគ្រប់ទៅហើយ ហើយសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងលិខិតនោះ ក៏ត្រូវបានសម្រេចដែរហើយនោះ បណ្តឹងតវ៉ាចំពោះការទាមទារ លែងធ្វើទៅបានទៀតហើយ ព្រោះពុំមានផលប្រយោជន៍អ្វីដែលត្រូវដកចេញនូវការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនោះទៀតទេ ។ ក៏ប៉ុន្តែ ទោះបីជាក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានបញ្ចប់ទៅហើយក៏ដោយ ប្រសិនបើសិទ្ធិទាមទារពុំមានអត្ថិភាពទេនោះ គេអាចទាមទារឱ្យធ្វើការសងផលប្រយោជន៍ដែលបានទទួលតាមរយៈការអនុវត្តដោយបង្ខំ ក្នុងលក្ខណៈជាសេចក្តីចម្រើនដោយឥតហេតុ និង អាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការអនុវត្តដោយបង្ខំនោះផងដែរ ។ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានបញ្ចប់ក្នុងខណៈដែលបណ្តឹងតវ៉ាចំពោះការទាមទារកំពុងត្រូវបានចាត់ការ នោះដើមចោទអាចផ្លាស់ប្តូរបណ្តឹងនោះ ទៅជាការទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុ ឬ ទាមទារសំណងនៃការខូចខាតបាន (មាត្រា ៨៤) ។

(៤) តុលាការដែលមានសមត្ថកិច្ចទៅលើបណ្តឹងតវ៉ាចំពោះការទាមទារ ត្រូវបានកំណត់ទៅតាមប្រភេទ

នៃលិខិតអនុវត្តដែលពាក់ព័ន្ធ (មាត្រា ៣៦៣ កថាខណ្ឌទី ៣. ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ មានបញ្ញត្តិពិសេសចែងនៅក្នុងមាត្រា ៤៩៧) ។ ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រម ឬ សាលដីការបស់តុលាការ, ដីកាសម្រេចផ្សេងៗ ឬ កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរ តុលាការមានសមត្ថកិច្ច គឺសាលាដំបូងដែលបានទទួលបន្ទុកនីតិវិធីនៃការសម្រេចសេចក្តីនោះ ។ ក្នុងករណីដែលលិខិតអនុវត្ត គឺជាការចាត់ចែងរបស់ក្រឡាបញ្ជី តុលាការមានសមត្ថកិច្ច គឺតុលាការដែលក្រឡាបញ្ជីដែលបានធ្វើការចាត់ចែងនោះស្ថិតនៅ ។ ក្នុងករណីដែលលិខិតអនុវត្ត គឺជាលិខិតបញ្ជាក់អនុវត្តវិញ តុលាការមានសមត្ថកិច្ច ត្រូវកំណត់ទៅតាមលំនៅឋាន ជាអាទិ៍ របស់ចុងចម្លើយនៃបណ្តឹងនេះ (ម្ចាស់បំណុលនៃការអនុវត្ត) ។

## (iv) ឥទ្ធិពលនៃបណ្តឹងតវ៉ាចំពោះការទាមទារទៅលើការអនុវត្តដោយបង្ខំ

(១) ការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ មិនរារាំងដល់ការចាប់ផ្តើម ឬ ការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះទេ ។ ដោយសារថា អានុភាពអនុវត្តនៃលិខិតអនុវត្តនោះ ត្រូវរលត់តែនៅក្រោយពេលដែលសាលក្រមទទួលស្គាល់បណ្តឹងតវ៉ាចំពោះការទាមទារ បានចូលជាស្ថាពរតែប៉ុណ្ណោះ ដូច្នេះ រហូតដល់ពេលនោះ ស្ថាប័នអនុវត្តអាចធ្វើការអនុវត្តដោយបង្ខំ ដោយស្របច្បាប់បាន ។ ក៏ប៉ុន្តែ ប្រសិនបើកូនបំណុល មានបង្កាន់ដៃទទួលការសង ឬ លិខិតពន្យារពេលសង ដែលម្ចាស់បំណុលបានធ្វើឡើងនៅក្រោយពេលបង្កើតលិខិតអនុវត្ត នោះកូនបំណុលអាចនឹងទាមទារឱ្យផ្អាកការអនុវត្តដោយបង្ខំដោយដាក់ឯកសារទាំងនោះ ទៅស្ថាប័នអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ខ) ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ការដាក់ឯកសារទាំងនេះ ពុំមានទំនាក់ទំនងទៅនឹងការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារទេ ។

(២) ក៏ប៉ុន្តែ ប្រសិនបើការអនុវត្តដោយបង្ខំ នៅតែត្រូវបានបន្ត ហើយបញ្ចប់នៅក្នុងអំឡុងពេលនៃការសម្រេចសេចក្តីអំពីបណ្តឹងតវ៉ាចំពោះការទាមទារ បណ្តឹងនោះ នឹងពុំមានន័យអ្វីឡើយ ។ ហេតុនេះហើយទើបមានបញ្ញត្តិចែងថា ប្រសិនបើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាង តុលាការដែលធ្វើការសម្រេចសេចក្តីអំពីបណ្តឹងតវ៉ាចំពោះការទាមទារ (តុលាការដែលបានទទួលពាក្យបណ្តឹង) អាចបង្គាប់ឱ្យធ្វើការចាត់ចែងមួយរយៈ ដូចជាការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬ ព្រមជាមួយគ្នានេះការលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ តាមពាក្យសុំ ដោយចេញដីកាសម្រេចបានរហូតដល់ពេលចេញសាលក្រមចុងក្រោយអំពីបណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៧ កថាខណ្ឌទី ១) ។ កូនបំណុល អាចទទួលបានការផ្អាក ឬ ការលុបចោល ជាអាទិ៍ នូវនីតិវិធីនៃការអនុវត្តដោយបង្ខំ ដោយដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចនេះ ទៅស្ថាប័នអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ឆ និង កថាខណ្ឌ ទី ២ ចំណុច ក) ។

ការចាត់ចែងមួយរយៈ ដូចបានពោលខាងលើ មានដូចជា : (ក) ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយ

បង្ខំមួយរយៈ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ (មាត្រា ៣៦៧ កថាខណ្ឌទី ១) និង អាស្រ័យទៅតាមករណីជាក់ស្តែង (ខ) ការបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយឱ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ (មាត្រា ៣៦៧ កថាខណ្ឌទី ២) ។ នៅក្នុងករណីដែលមានស្ថានភាពបន្ទាន់ ហើយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ និង ពាក្យសុំឱ្យធ្វើការចាត់ចែងមួយរយៈ ត្រូវប្រើពេលយូរ នោះកូនបំណុលអាចដាក់ពាក្យសុំឱ្យធ្វើការចាត់ចែងមួយរយៈបែបនេះ ទៅតុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅបាន (មាត្រា ៣៦៧ កថាខណ្ឌទី ៣) ។ ការចាត់ចែងមួយរយៈដោយតុលាការអនុវត្ត ឬ សាលាដំបូង គឺជាវិធានការណ៍ចម្លង រហូតដល់ពេលដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារទៅតុលាការដែលមានសមត្ថកិច្ច និង ពេលបានទទួលដីកាសម្រេចឱ្យផ្អាកការអនុវត្តដោយបង្ខំ ជាអាទិ៍ ដែលចេញដោយតុលាការមានសមត្ថកិច្ចនោះ ។ អាស្រ័យហេតុនេះហើយ នៅក្នុងករណីដែលតុលាការអនុវត្ត ឬ សាលាដំបូងបង្គាប់ឱ្យធ្វើការចាត់ចែងមួយរយៈ តុលាការនោះត្រូវកំណត់អំឡុងពេលមួយដើម្បីឱ្យកូនបំណុលដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ទទួលសេចក្តីសម្រេចដែលបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ ជាអាទិ៍ ពីតុលាការដែលទទួលពាក្យបណ្តឹង និង ដាក់ឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។ នៅពេលផុតអំឡុងពេលនោះ ការចាត់ចែងមួយរយៈរបស់តុលាការអនុវត្ត ឬ សាលាដំបូងនឹងត្រូវបាត់បង់អានុភាព (មាត្រា ៣៦៧ កថាខណ្ឌទី ៤) ។ ក៏ប៉ុន្តែ ប្រសិនបើឯកសារចម្លងយថាភូតនៃដីកាសម្រេចរបស់តុលាការដែលទទួលពាក្យបណ្តឹង ត្រូវបានដាក់នៅក្នុងអំឡុងពេលនោះ ការផ្អាកការអនុវត្តដោយបង្ខំ នៅតែផ្អាកដដែល ដោយអានុភាពនៃដីកាសម្រេចនោះ ។ ផ្ទុយទៅវិញ ប្រសិនបើឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចរបស់តុលាការដែលទទួលពាក្យបណ្តឹង មិនត្រូវបានដាក់នៅក្នុងអំឡុងពេលនោះទេ ស្ថាប័នអនុវត្ត ត្រូវបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំតទៅមុខទៀត ។ ប្រសិនបើស្ថាប័នអនុវត្ត មិនបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំទេ ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យបន្តបាន ។

ការចាត់ចែងមួយរយៈ ដូចបានរៀបរាប់ខាងលើ មិនអាចប្តឹងឧបាស្រ័យបានទេ (មាត្រា ២៩៩ កថាខណ្ឌទី ២) ។

(៣) សាលក្រមចុងក្រោយនៃបណ្តឹងតវ៉ាចំពោះការទាមទារ នឹងបញ្ចប់តួនាទីនៃការចាត់ចែងមួយរយៈដែលបានរៀបរាប់ខាងលើ ។ ហេតុនេះហើយ តុលាការដែលបានទទួលពាក្យបណ្តឹង ត្រូវធ្វើការកំណត់សាជាថ្មីថាតើត្រូវផ្អាក ឬ លុបចោលនូវការអនុវត្តដោយបង្ខំ ដោយយោងទៅតាមខ្លឹមសារនៃសាលក្រមចុងក្រោយ ។

(ក) ក្នុងករណីដែលសាលក្រមចុងក្រោយ ទទួលស្គាល់បណ្តឹងតវ៉ាចំពោះការទាមទារ និង ហាមឃាត់ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធ (សូមមើលផ្នែកដែលនឹងរៀបរាប់នៅខាងក្រោម) តុលាការដែលបានទទួលពាក្យបណ្តឹង ត្រូវធ្វើការបង្គាប់សាជាថ្មី ឱ្យលុបចោលការអនុវត្តដោយបង្ខំ ឬ ត្រូវសម្រេចអនុម័តយល់ព្រមលើការចាត់ចែងមួយរយៈដែលបានផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំដែល

បានធ្វើរួចហើយ ។ ផ្ទុយទៅវិញ ក្នុងករណីដែលតុលាការចេញសាលក្រមចុងក្រោយ លើកចោលបណ្ដឹង ឬ ច្រានចោលការទាមទារ នោះមានន័យថាការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះ ត្រូវបានអនុញ្ញាត ។ ក្នុងករណីនេះ ប្រសិនបើបានធ្វើការចាត់ចែងមួយរយៈដោយផ្អាក ឬ លុបចោលការអនុវត្ត ដោយបង្ខំរួចហើយ នោះវាជារឿងធម្មតាដែលត្រូវលុបចោលការចាត់ចែងនោះ ។ លើសពីនេះទៅទៀត ប្រសិន បើការចាត់ចែងមួយរយៈ បានបង្គាប់ឱ្យលុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ នោះបើទោះបីជាសាលក្រមចុងក្រោយបង្គាប់ឱ្យលុបចោលការចាត់ចែងមួយរយៈ ដែលបង្គាប់ឱ្យលុបចោលនូវ ការចាត់ចែងការអនុវត្តដោយបង្ខំនោះក៏ដោយ ក៏ការចាត់ចែងការអនុវត្តដែលបានលុបចោលទៅហើយនោះ មិនអាចស្ដារឡើងវិញដែរ ។ ហេតុនេះហើយ នៅក្នុងករណីបែបនេះ ម្ចាស់បំណុលចាំបាច់ត្រូវតែដាក់ពាក្យសុំឱ្យ អនុវត្តដោយបង្ខំ ម្ដងទៀត ។ ផ្ទុយទៅវិញ ប្រសិនបើការចាត់ចែងមួយរយៈ បានបង្គាប់ឱ្យផ្អាកនីតិវិធីនៃ ការអនុវត្តដោយបង្ខំ នោះនៅពេលដែលសាលក្រមចុងក្រោយបង្គាប់ឱ្យលុបចោលការចាត់ចែងនោះវិញ ម្ចាស់ បំណុលអាចដាក់ពាក្យសុំឱ្យបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដែលបានផ្អាកនោះ ឡើងវិញបាន ។

(ខ) ដោយសារថា សេចក្ដីសម្រេចដែលបង្គាប់សាជាថ្មីឱ្យលុបចោលការអនុវត្តដោយបង្ខំ, សេចក្ដីសម្រេច ដែលអនុម័តយល់ព្រមលើការចាត់ចែងមួយរយៈដោយផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំដែលបានធ្វើ រួចហើយ ឬ សេចក្ដីសម្រេចដែលបង្គាប់ឱ្យលុបចោលការចាត់ចែងមួយរយៈនោះ សុទ្ធតែត្រូវបានសរសេរ នៅក្នុងសេចក្ដីសំម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកាចុងក្រោយ ដូច្នេះ ជាគោលការណ៍ទូទៅ សេចក្ដី សម្រេចទាំងនោះ នឹងមានអានុភាពលុះត្រាតែសាលក្រម ឬ សាលដីកានោះចូលជាស្ថាពរសិន (សូមមើលទំព័រ ១៣៤ នៃ "សេចក្ដីពន្យល់ស្ដីពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្ដឹង") ។ ប៉ុន្តែ ទោះជាយ៉ាងនេះ ក៏ដោយ មានបញ្ញត្តិពិសេសចែងថា សេចក្ដីសម្រេចនេះ ត្រូវមានអានុភាពភ្លាម ចាប់ពីពេលប្រកាសសាលក្រម ឬ សាលដីកាចុងក្រោយ (មាត្រា ៣៦៨) ។ មូលហេតុនៃការលើកលែងនេះ គឺថា ប្រសិនបើមិនចែង បែបនេះទេ នោះបើទោះជាមានការទទួលស្គាល់របស់សាលាដំបូង នូវបណ្ដឹងតវ៉ាចំពោះការទាមទារ និង ទោះជា មានសេចក្ដីសម្រេចដែលបង្គាប់សាជាថ្មី ឱ្យលុបចោលការអនុវត្តដោយបង្ខំ ឬ សេចក្ដីសម្រេចដែលអនុម័តយល់ ព្រមលើការចាត់ចែងមួយរយៈ ដោយផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ក៏ដោយ ក៏ការអនុវត្តដោយបង្ខំ នៅតែត្រូវបានធ្វើឡើង រហូតដល់សាលក្រមចុងក្រោយនោះ ចូលជាស្ថាពរ ។ ហេតុនេះហើយទើបមានការកំណត់ថា សេចក្ដីសម្រេចទាំងនេះ ត្រូវមានអានុភាពចាប់ពីពេលប្រកាសសាលក្រម ឬ សាលដីកាចុងក្រោយ ហើយការដាក់ពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (បណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ) ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយនោះ ពុំមានឥទ្ធិពលអ្វីទៅលើអានុភាពនៃសេចក្ដី សម្រេចទាំងនោះទេ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ តុលាការដែលធ្វើការសម្រេចសេចក្ដីទៅលើបណ្ដឹងឧបាស្រ័យ អាចបង្គាប់សាជាថ្មី ឱ្យធ្វើការចាត់ចែងមួយរយៈតាមមាត្រា ៣៦៧ បាន (មាត្រា ២៧៣ និង មាត្រា ៣០៤) ។

(v) **ការវិនិច្ឆ័យ និង ការចេញសាលក្រម**

(១) ការវិនិច្ឆ័យទៅលើបណ្តឹងតវ៉ាចំពោះការទាមទារ ត្រូវធ្វើឡើងទៅតាមនីតិវិធីទូទៅនៃការចេញសាលក្រម ។ អត្ថិភាពនៃលិខិតអនុវត្ត ពុំបង្វែរបន្ទុកនៃភស្តុតាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកទេ ។ ក៏ប៉ុន្តែ ដូចបានពោលពីខាងដើម ក្នុងករណីដែលលិខិតអនុវត្តមានអាជ្ញាអស់ជំនុំ នោះកូនបំណុលមិនអាចលើកអង្គហេតុដែលកើតឡើងនៅមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ មកអះអាងបានទេ ។ ដូច្នេះ អាចនឹងមានការដាក់កម្រិតថា កូនបំណុលមានជម្រើសតែមួយគត់ គឺត្រូវអះអាង និង ផ្តល់ភស្តុតាងអំពីការរលត់នូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក នៅក្រោយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីយកការកើតឡើងនូវសិទ្ធិទាមទារនោះជាមូលដ្ឋាន ។

(២) ប្រសិនបើការទាមទារមានហេតុផលត្រឹមត្រូវ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាចុងក្រោយ ដោយធ្វើការប្រកាសនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកានោះ មិនអនុញ្ញាតឱ្យមានការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលដើមចោទបានចង្អុលបង្ហាញ ( មាត្រា ៣៦៣ កថាខណ្ឌទី ១) ។ សេចក្តីសម្រេចនេះ ត្រូវកំណត់ថាតើនាពេលបច្ចុប្បន្ន សិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត មានអត្ថិភាព ឬ មិនមាន ។ ប្រសិនបើបានកំណត់ថាសិទ្ធិទាមទារនោះពុំមានអត្ថិភាពទេ សេចក្តីសម្រេចនោះ មានអានុភាពរំលត់អានុភាពអនុវត្តនៃលិខិតអនុវត្ត (អំណាចដែលធ្វើឱ្យស្ថាប័នអនុវត្តទទួលស្គាល់នូវអត្ថិភាព និង អត្ថន័យនៃសិទ្ធិទាមទារ) ។ នៅពេលសាលក្រម ឬ សាលដីកានេះចូលជាស្ថាពរ នោះសេចក្តីសម្រេចអំពីនត្ថិភាពនៃសិទ្ធិទាមទារទាំងមូល ឬ មួយផ្នែក ដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត នឹងមានអានុភាពនៃអាជ្ញាអស់ជំនុំ (មាត្រា ១៩៤) ហើយពេលនោះអានុភាពអនុវត្តនៃលិខិតអនុវត្ត នឹងត្រូវបាត់បង់ នៅក្នុងទំហំដែលបានកំណត់នោះ ។ នៅពេលសាលក្រម ឬ សាលដីកានេះ ចូលជាស្ថាពរ កូនបំណុលអាចធ្វើការទាមទារឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ ដោយដាក់អនុសារសាលក្រម ឬ អនុសារសាលដីកានោះ ទៅស្ថាប័នអនុវត្ត ( មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ) ។

(៣) ប្រសិនបើការទាមទារពុំមានហេតុផលត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលការទាមទារ ។ នៅពេលសាលក្រម ឬ សាលដីកាច្រានចោលការទាមទារចូលជាស្ថាពរ នោះអត្ថិភាពនៃសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តដែលពាក់ព័ន្ធ នឹងមានអានុភាពនៃអាជ្ញាអស់ជំនុំ ។ បន្ទាប់ពីនោះ កូនបំណុលមិនអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ សាជាថ្មីម្តងទៀត ចំពោះលិខិតអនុវត្តដដែល ដោយឈរលើមូលហេតុដែលបានកើតឡើងរួចហើយ នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃនីតិវិធីនៃបណ្តឹងតវ៉ាចំពោះការទាមទារនេះ បានទេ ។ មូលហេតុដែលបានកើតឡើងរួចហើយនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ បើទោះជាមូលហេតុនោះមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងតវ៉ាមុនក៏ដោយ ក៏មិនអាចលើកមកអះអាងនៅក្នុងបណ្តឹងតវ៉ាថ្មីបានដែរ ។

# កថាភាគទី ៣ រូបមន្តអនុវត្ត

## ចំណុចទី ១ អត្ថន័យនៃរូបមន្តអនុវត្ត

### ១. គោលគំនិតនៃរូបមន្តអនុវត្ត

(១) រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬ សារការី សរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និង ដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និង អត្ថន័យនៃអំណាចបង្ខំឱ្យអនុវត្ត នៃលិខិតអនុវត្តនោះ ។ ជាគោលការណ៍ទូទៅ ស្ថាប័នអនុវត្ត ត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ( មាត្រា ៣៥៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។

(២) ហេតុផលនៃការតម្រូវឱ្យភ្ជាប់បន្ថែមនូវរូបមន្តអនុវត្ត ទៅនឹងលិខិតអនុវត្ត មានដូចតទៅ ។ ទីមួយ ដោយសារថា ស្ថាប័នអនុវត្ត មិនមែនជាតុលាការនៃបណ្តឹងទេ ដូច្នេះ វាមិនមែនជាការសមស្របទេ បើឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើអានុភាពអនុវត្តនៃលិខិតអនុវត្ត នៅពេលណាមានពាក្យសុំឱ្យអនុវត្តដោយបង្ខំម្តងៗ ដែលការណ៍នេះ នឹងនាំឱ្យមានការយឺតយ៉ាវនៅក្នុងការអនុវត្តដោយបង្ខំ ។ ទីពីរ នៅក្នុងករណីដែលការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត នោះចាំបាច់ត្រូវធ្វើការពិនិត្យស្រាវជ្រាវថាតើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្ត ដែរឬទេ (តើបុគ្គលនោះមានលក្ខណៈក្នុងការធ្វើជាភាគីនៃការអនុវត្តដោយបង្ខំ ដែរឬទេ) ហើយប្រសិនបើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តមែន នោះត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្ត ដោយរៀបរាប់អំពីចំណុចនោះ ក្រោមទម្រង់ជារូបមន្តអនុវត្ត ។ អត្ថិភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ ។ ម៉្យាងទៀត ប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តហើយ នោះស្ថាប័នអនុវត្ត ត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយមិនបាច់ពិនិត្យពិចារណាលើខ្លឹមសារនៃលិខិតអនុវត្តនោះទេ ។ ហេតុនេះហើយ ទោះបីជាឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ខុសគ្នាពីលិខិតអនុវត្តច្បាប់ដើម ឬ ប្រសិនបើរូបមន្តអនុវត្តនោះត្រូវបានផ្តល់ដើម្បីជាផលប្រយោជន៍ ឬ ទៅឱ្យបុគ្គលណាម្នាក់ដែលពុំមានលក្ខណៈជាភាគីនៃការអនុវត្តដោយបង្ខំក៏ដោយ ឬ ទោះបីជាលិខិតអនុវត្តនោះបានបាត់បង់អានុភាពក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះ នៅតែជាការអនុវត្តស្របតាមច្បាប់ស្តីពីការអនុវត្តដោយបង្ខំដែរ ។

(៣) ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត មានអានុភាពនៅគ្រប់ទីកន្លែងទាំងអស់ដែលស្ថិតនៅក្រោមសិទ្ធិជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់បំណុល អាចធ្វើការអនុវត្តដោយបង្ខំ នៅទីកន្លែងណាមួយក៏បាន ដោយផ្អែកលើឯកសារចម្លងយថាភូតនោះ ។ ជាងនេះទៅទៀត អានុភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនេះ ពុំមានការកម្រិតអំឡុងពេលដែលមានអានុភាពនោះទេ ។

## ២. ភាពចាំបាច់នៃរូបមន្តអនុវត្ត

(១) ជាគោលការណ៍ ទោះបីជាមានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ដើម្បីអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគបាន ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលបាននូវការផ្តល់រូបមន្តអនុវត្តសិនជានិច្ច ។ ទោះបីជាលិខិតអនុវត្តដែលម្ចាស់បំណុលមានសេចក្តីប្រកាសថាការអនុវត្តដោយបង្ខំអាចធ្វើទៅបាន ដោយផ្អែកលើលិខិតនោះ ដូចជាករណីនៃសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ខ) ឬ លិខិតបញ្ជាក់អនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច) ជាអាទិ៍ ក៏ដោយ ក៏ចាំបាច់ត្រូវតែបានទទួលការផ្តល់រូបមន្តអនុវត្ត សិនដែរ ។

(២) ជាករណីលើកលែង ប្រសិនបើលិខិតអនុវត្ត គឺជាសាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នោះពុំចាំបាច់មានរូបមន្តអនុវត្តទេ (មាត្រា ៣៥៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ និង ចំណុច ក ដល់ គ) ។ ដោយសារថា គោលបំណងនៃនីតិវិធីដែលនាំទៅដល់ការចេញលិខិតអនុវត្តទាំងនេះ គឺដើម្បីផ្តល់នូវលិខិតអនុវត្តដោយងាយស្រួល និងឆាប់រហ័ស ដូច្នេះ ប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតទាំងនេះហើយ ចាំបាច់ម្ចាស់បំណុលត្រូវតែអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតទាំងនោះ បានភ្លាម ។

ក៏ប៉ុន្តែ ទោះបីជាក្នុងករណីនៃការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តទាំងនេះក៏ដោយ ប្រសិនបើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ចំពោះបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាកូនបំណុលនៃការអនុវត្ត នោះចាំបាច់ត្រូវទទួលបាននូវរូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ កថាខណ្ឌទី ២) ។ សរុបសេចក្តីទៅ គេអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តមួយចំនួន ដូចបានរៀបរាប់ខាងលើ ដោយពុំចាំបាច់មានរូបមន្តអនុវត្តបាន តែក្នុងករណីដែលភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តនោះ គឺជាម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ។

## ចំណុចទី ២ នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត

### ១. ស្ថាប័នផ្តល់រូបមន្តអនុវត្ត

(១) ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រម ឬ សាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្ត (ស្ថាប័នផ្តល់រូបមន្តអនុវត្ត) គឺក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនៃបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬ សាលដីកានោះ (មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ មូលហេតុនៃការយកទីកន្លែងដែលទុកសំណុំរឿង ធ្វើជាល័ក្ខខ័ណ្ឌដើម្បីកំណត់ថាតើក្រឡាបញ្ជីនៃតុលាការណាមួយត្រូវដើរតួនាទីជាស្ថាប័នផ្តល់រូបមន្តអនុវត្តនោះ គឺព្រោះថា ឯកសារចាំបាច់បំផុតសម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃសាលក្រម ឬ សាលដីកាដែលជាលិខិតអនុវត្ត (អត្ថិភាព ឬ នត្ថិភាពនៃអានុភាពអនុវត្ត) ជាអាទិ៍ គឺជាសំណុំរឿងនៃបណ្តឹងនោះ ។ ដោយហេតុនេះ វាជាការសមស្របបំផុតដែលឱ្យក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះ ធ្វើជាស្ថាប័នផ្តល់រូបមន្តអនុវត្ត ។ ដូចគ្នានេះដែរ ចំពោះករណីដែលលិខិតអនុវត្តគឺជាសេចក្តីសម្រេចផ្សេងទៀត កំណត់ហេតុរបស់តុលាការ ឬ ការចាត់ចែងរបស់ក្រឡាបញ្ជី ស្ថាប័នផ្តល់រូបមន្តអនុវត្ត គឺក្រឡាបញ្ជីដែលរក្សាទុកសំណុំរឿង ដែលជាឯកសារចាំបាច់សម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃលិខិតអនុវត្តនោះ (មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។

(២) ក្នុងករណីដែលលិខិតអនុវត្ត គឺជាលិខិតបញ្ជាក់អនុវត្ត សារការីដែលរក្សាទុកនូវច្បាប់ដើមនៃលិខិតបញ្ជាក់នោះ គឺជាស្ថាប័នផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

### ២. ចំណុចដែលត្រូវធ្វើការស្រាវជ្រាវ

(១) ចំណុចដែលស្ថាប័នផ្តល់រូបមន្តអនុវត្តត្រូវធ្វើការស្រាវជ្រាវ នៅពេលផ្តល់រូបមន្តអនុវត្ត គឺចំណុចដែលនឹងរៀបរាប់ពីចំណុច (ក) ដល់ចំណុច (ច) ខាងក្រោម ។ ដោយឡែក ចំពោះអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារវិញ ស្ថាប័នផ្តល់រូបមន្តអនុវត្ត មិនបាច់ធ្វើការស្រាវជ្រាវទេ ព្រោះថា រូបមន្តអនុវត្ត គ្រាន់តែបញ្ជាក់ជាផ្លូវការ នូវអានុភាពអនុវត្តនៃលិខិតអនុវត្តតែប៉ុណ្ណោះ គឺមិនបញ្ជាក់ជាផ្លូវការ អំពីអត្ថិភាពនៃសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតនោះទេ ។ ម៉្យាងទៀត ស្ថាប័នផ្តល់រូបមន្តអនុវត្ត មិនបាច់ធ្វើការស្រាវជ្រាវអំពីចំណុចដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ នៅពេលធ្វើការអនុវត្តដោយបង្ខំ (មាត្រា ៣៦១) នោះទេ ។

(ក) សុពលភាពនៃឯកសារដែលជាលិខិតអនុវត្ត ។

ឧទាហរណ៍ បើជាសាលក្រម ឬ សាលដីកា ត្រូវតែ ជាសាលក្រម ឬ សាលដីកាដែលត្រូវបានប្រកាស និងដែលមិនបាត់បង់អានុភាពដោយសារការលុបចោល នៅក្នុងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ ឬ ការជំនុំជម្រះសាជាថ្មី ។

(ខ) ភាពសមស្របទៅនឹងស្ថានភាពជាក់ស្តែង នៃខ្លឹមសារនៃលិខិតអនុវត្ត ។

ឧទាហរណ៍ បើជាសាលក្រម ឬ សាលដីកា ត្រូវតែជាសាលក្រម ឬ សាលដីកាដែលកំណត់ជាស្ថាពរ

នូវករណីយកិច្ចផ្តល់តាវកាលិកដែលអាចអនុវត្តបាន ។ បើជាលិខិតបញ្ជាក់អនុវត្តវិញ ត្រូវបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារ ដើម្បីក្លាយជាលិខិតអនុវត្ត ( មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច) ។

(គ) ការកើតឡើង និង មានអត្ថិភាពនៃអានុភាពអនុវត្តរបស់លិខិតអនុវត្ត ។

ឧទាហរណ៍ បើជាសាលក្រម ឬ សាលដីកា ត្រូវតែជាសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (មាត្រា ១៩៣) ហើយដែលអានុភាពអនុវត្ត មិនបាត់បង់ ដោយសាលក្រម ឬ សាលដីកាដែលទទួលស្គាល់ការទាមទារនៃបណ្តឹងតវ៉ាចំពោះការទាមទារទេ (សូមមើលទំព័រ ៥២ ខាងលើ) ជាដើម ។ បើជាសាលក្រម ឬ សាលដីកា ដែលមិនទាន់ចូលជាស្ថាពរ ត្រូវមានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ហើយអានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ មិនបានរលត់នាពេលក្រោយមក ដោយសារការលុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ( មាត្រា ១៩៧ កថាខណ្ឌទី ១) ជាដើម ទេ ។

(ឃ) ការបានបំពេញគ្រប់ល័ក្ខខ័ណ្ឌបង្អង់ ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់ក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ និង ការមកដល់នូវពេលកំណត់ ក្នុងករណីដែលសិទ្ធិទាមទារនោះ មានពេលកំណត់មិនពិតប្រាកដ ( មាត្រា ៣៥៦ កថាខណ្ឌទី ១) ។

ល័ក្ខខ័ណ្ឌបង្អង់ ត្រូវតែជាល័ក្ខខ័ណ្ឌដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត ហើយដែលម្ចាស់បំណុលត្រូវបញ្ជាក់អំពីការបានបំពេញល័ក្ខខ័ណ្ឌនោះ ។ នៅក្នុងករណីបែបនេះ រូបមន្តអនុវត្តដែលបានផ្តល់ក្រោយពេលដែលការបានបំពេញល័ក្ខខ័ណ្ឌបង្អង់ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដនោះ ត្រូវបានទទួលស្គាល់ត្រូវហៅថា រូបមន្តអនុវត្តពិសេស ឬ រូបមន្តអនុវត្តបន្ថែម ។ ក្នុងករណីដែលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តពិសេស ក្រឡាបញ្ជីនោះ ត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន ( មាត្រា ៣៥៦ កថាខណ្ឌទី ៤) ។ ដោយឡែក ចំពោះហេតុដែលថាសិទ្ធិទាមទារមានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ តែល័ក្ខខ័ណ្ឌនោះមិនបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ឬ ចំពោះករណីដែលកូនបំណុលត្រូវបញ្ជាក់អំពីល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងលិខិតអនុវត្ត (ឧទាហរណ៍ ល័ក្ខខ័ណ្ឌរំលាយ) ហេតុដែលថាសិទ្ធិទាមទារនោះ មានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ ថាសិទ្ធិទាមទារនោះ បានរលត់ដោយសារការបានបំពេញល័ក្ខខ័ណ្ឌរួចទៅហើយ ទាំងនោះគឺជាចំណុចដែលកូនបំណុលត្រូវលើកមកអះអាងដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ពោលគឺវាមិនមែនជាចំណុចដែលត្រូវធ្វើការស្រាវជ្រាវនៅពេលផ្តល់រូបមន្តអនុវត្តទេ ។ មួយវិញទៀត ក្នុងករណីដែលមានដាក់ល័ក្ខខ័ណ្ឌដែលតម្រូវឱ្យដាក់ប្រាតិភោគ ឬ តម្រូវឱ្យផ្តល់តាវកាលិកតប ដើម្បីអាចអនុវត្តដោយបង្ខំបាន ស្ថានភាពទាំងនោះត្រូវស្រាវជ្រាវដោយស្ថាប័នអនុវត្ត ( មាត្រា ៣៦១ កថាខណ្ឌទី ២ និង ទី ៣) ពោលគឺវាមិនមែនជាចំណុចដែលត្រូវធ្វើការស្រាវជ្រាវនៅពេលផ្តល់រូបមន្តអនុវត្តទេ ។

(ង) ក្នុងករណីដែលបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ជាអ្នកសុំឱ្យផ្តល់រូបមន្តអនុវត្ត ដើម្បីយកទៅដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយតាំងខ្លួនជាម្ចាស់បំណុលនៃការអនុវត្ត ឬ ក្នុង

ករណីដែលមានការសុំឱ្យផ្តល់រូបមន្តអនុវត្ត ដើម្បីយកទៅដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ដោយចាត់ទុកបុគ្គលនោះជាកូនបំណុលនៃការអនុវត្ត នោះអានុភាពអនុវត្តនៃលិខិតអនុវត្តដែលពាក់ព័ន្ធនោះ ត្រូវមានឥទ្ធិពលលើបុគ្គលទាំងនោះ ( មាត្រា ៣៥៦ កថាខណ្ឌទី ២) ។

វិសាលភាពនៃបុគ្គលដែលត្រូវទទួលអានុភាពអនុវត្តនៃលិខិតអនុវត្ត មានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៥១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រាដដែលនេះ ។ រូបមន្តអនុវត្ត ដែលត្រូវបានផ្តល់ដោយយកបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ហៅថា រូបមន្តអនុវត្តពិសេស ឬ រូបមន្តអនុវត្តបន្ត ។ ក្នុងករណីដែលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តពិសេសបែបនេះ ក្រឡាបញ្ជីនោះ ក៏ត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិនដែរ ( មាត្រា ៣៥៦ កថាខណ្ឌទី ៤) ។

(ច) ភាពចាំបាច់ ឬ មិនចាំបាច់ ក្នុងការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ នៅក្នុងករណីដែលមានការសុំឱ្យផ្តល់រូបមន្តអនុវត្តច្រើន សម្រាប់លិខិតអនុវត្តតែមួយ (ការផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតច្រើនច្បាប់) ( មាត្រា ៣៥៨) ។

នៅក្នុងករណីដែលគោលបំណងនៃការអនុវត្តដោយបង្ខំ អាចសម្រេចបានពេញលេញ លុះត្រាតែការអនុវត្តនោះ ត្រូវបានធ្វើឡើងតាមវិធីជាច្រើន ដូចជាករណីដែលការអនុវត្តដោយបង្ខំត្រូវធ្វើឡើងនៅកន្លែងជាច្រើន ឬ ត្រូវធ្វើឡើងចំពោះអចលនវត្ថុផង និង ចលនវត្ថុផង ដោយផ្អែកលើលិខិតអនុវត្តតែមួយ ជាអាទិ៍ នោះម្ចាស់បំណុលនៃការអនុវត្ត មានភាពចាំបាច់ត្រូវតែសុំឱ្យផ្តល់រូបមន្តអនុវត្ត លើឯកសារចម្លងយថាភូតជាច្រើនច្បាប់ នៃលិខិតអនុវត្ត ។ ម្យ៉ាងទៀត ក្នុងករណីដែលបាត់លិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះចាំបាច់ត្រូវសុំលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តមួយទៀត ។ ក៏ប៉ុន្តែ ប្រសិនបើផ្តល់រូបមន្តអនុវត្ត នៅលើឯកសារចម្លងយថាភូតជាច្រើនច្បាប់ ដោយហួសពីភាពចាំបាច់ នោះកូនបំណុលនៃការអនុវត្តអាចនឹងទទួលការអនុវត្តដោយបង្ខំម្តងហើយម្តងទៀត ដែលការណ៍នេះ នឹងនាំឱ្យមានហានិភ័យ ដែលថា ការផ្តល់តាវកាលិកដោយបង្ខំ នឹងសម្រេចបានច្រើនជាងចំនួនដែលត្រូវផ្តល់ពីដំបូង ។ អាស្រ័យហេតុនេះហើយ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ នោះត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត អំពីហេតុការណ៍និងមូលហេតុនោះ និង ចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត ( មាត្រា ៣៥៨ កថាខណ្ឌទី ២) ។

(២) ការស្រាវជ្រាវអំពីចំណុចខាងលើទាំងនេះ ត្រូវធ្វើឡើងដោយស្ថាប័នផ្តល់រូបមន្តអនុវត្ត ដោយផ្អែកលើសំណុំរឿងនៃបណ្តឹង និង លិខិតបញ្ជាក់ដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ ជាអាទិ៍ (ជាពិសេសអំពីការផ្តល់រូបមន្តអនុវត្តពិសេស សូមមើលមាត្រា ៣៥៦ កថាខណ្ឌទី ៣) ។

(៣) បញ្ហាដែលស្ថិតនៅក្នុងការពិភាក្សាទៅលើចំណុចថា តើការស្រាវជ្រាវត្រូវធ្វើឡើងនៅពេលផ្តល់

រូបមន្តអនុវត្តដែរឬទេនោះ គឺមូលហេតុនៃការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ក្នុងករណីដែលមានខសន្យាអំពីការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ។ ខសន្យាអំពីការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល គឺជាខសន្យាដែលត្រូវបានចុះជាល័ក្ខខ័ណ្ឌមួយនៃកិច្ចសន្យា នៅក្នុងការលក់ទិញដោយបង់បណ្តាក់ ការខ្ចីបរិភោគ ជាអាទិ៍ ។ នៅក្នុងកិច្ចសន្យាទាំងនេះ នៅពេលចុះកិច្ចសន្យាលក់ទិញដោយបង់បណ្តាក់ ឬ កិច្ចសន្យាខ្ចីបរិភោគ អ្នកទិញ ឬ អ្នកខ្ចី ត្រូវបានផ្តល់ឱ្យនូវការពន្យារពេលសម្រាប់ការបង់ប្រាក់ ដោយមានការព្រមព្រៀងដែលតម្រូវឱ្យអ្នកទាំងនោះ បង់ប្រាក់ថ្លៃលក់ ឬ ប្រាក់កម្ចីម្តងបន្តិច១ក្នុងអំឡុងពេលពីរ ឬ បីខែម្តង ។ នៅក្នុងករណីបែបនេះ មានការព្រមព្រៀងថា ប្រសិនបើមានការខកខានមិនបានបង់ប្រាក់តែមួយដងនោះ ផលប្រយោជន៍នៃការកំណត់ពេល នឹងត្រូវរលត់សម្រាប់ចំនួនទឹកប្រាក់ទាំងអស់ដែលមិនទាន់បង់តែម្តង ។ ក្នុងករណីដែលមានកំណត់ហេតុស្តីពីការសះជា ឬ លិខិតបញ្ជាក់អនុវត្ត ធ្វើឡើងសម្រាប់សិទ្ធិទាមទារឱ្យបង់ប្រាក់ថ្លៃលក់ ឬ សិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយភ្ជាប់ជាមួយនឹងខសន្យាអំពីការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលបែបនេះ នៅពេលម្ចាស់បំណុល (អ្នកលក់ ឬ អ្នកឱ្យខ្ចី) ចង់ធ្វើការអនុវត្តដោយបង្ខំចំពោះទឹកប្រាក់សេសសល់ទាំងអស់ ដោយយកឯកសារនោះធ្វើជាលិខិតអនុវត្ត នោះនឹងកើតមានបញ្ហាថា តើដើម្បីទទួលបានរូបមន្តអនុវត្ត ម្ចាស់បំណុលត្រូវធ្វើការបញ្ជាក់អំពីការយឺតយ៉ាវក្នុងការបង់ប្រាក់ តាមមាត្រា ៣៥៦ កថាខណ្ឌទី ១ ដែរឬទេ ? ក៏ប៉ុន្តែ ជាគោលការណ៍ទូទៅនៃការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ (សូមមើលទំព័រ ១០១ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង") ការបានសងបំណុលគឺជាអង្គហេតុដែលកូនបំណុលត្រូវធ្វើការបញ្ជាក់ ហើយខសន្យាអំពីការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលខាងលើ គឺជាផលប្រយោជន៍របស់កូនបំណុល ព្រោះថា បើស្ថិតក្នុងកាលៈទេសៈធម្មតា បំណុលត្រូវសងភ្លាម១ ក៏ប៉ុន្តែ កូនបំណុលត្រូវបញ្ជាក់ថាខ្លួនបានទទួលការពន្យារពេល ។ ហេតុដូចនេះហើយទើបគេអាចគិតថា ម្ចាស់បំណុលនៃការអនុវត្ត អាចទទួលបានការផ្តល់រូបមន្តអនុវត្ត ដោយមិនចាំបាច់ធ្វើការបញ្ជាក់អំពីការយឺតយ៉ាវក្នុងការបង់ប្រាក់ ប្រសិនបើពេលកំណត់ផ្តល់តាវកាលិកលើកទីមួយបានកន្លងផុតទៅ បន្ទាប់ពីពេលធ្វើលិខិតអនុវត្ត ។ ផ្ទុយទៅវិញ ការកំណត់នេះ មិនអាចយកទៅអនុវត្តដូចគ្នាបានទេ ក្នុងករណីដែលការមិនបំពេញករណីយកិច្ចក្នុងអំឡុងពេលជាក់លាក់ណាមួយ គឺមិនមែនគ្រាន់តែនាំឱ្យបាត់បង់នូវផលប្រយោជន៍នៃការកំណត់ពេលប៉ុណ្ណោះទេ គឺជាការបំពេញល័ក្ខខ័ណ្ឌរំលាយកិច្ចសន្យាទាំងមូលតែម្តង ។ ឧទាហរណ៍ ដូចជាករណីនៃភតិសន្យាលើអាគារណាមួយ ប្រសិនបើភតិកៈខកខានមិនបានបង់ប្រាក់ថ្លៃឈ្នួលសម្រាប់រយៈពេល ២ ខែ នោះភតិសន្យាទាំងមូលត្រូវបានរំលាយដោយស្វ័យប្រវត្តិ ហើយភតិកៈត្រូវចាកចេញពីអាគាររបស់ភតិបតីជាដើម ។ នៅក្នុងករណីបែបនេះ ដោយសារថា ការមិនបង់ប្រាក់ថ្លៃឈ្នួល គឺជាល័ក្ខខ័ណ្ឌបង្អង់ដើម្បីឱ្យសិទ្ធិទាមទារឱ្យចាកចេញពីអាគារកើតឡើង ដូច្នេះ វាជាការសមស្របដែលត្រូវកំណត់ថា នៅពេលទទួលការផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញហើយ ។

## ៣. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត

(១) ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ នៅក្នុងពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវរៀបរាប់ពីឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត លិខិតអនុវត្ត ព្រមទាំងខ្លឹមសារនៃរូបមន្តអនុវត្តដែលសុំឱ្យផ្តល់ (មាត្រា ៣៥៥ កថាខណ្ឌទី ១) ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបញ្ជាក់អំពីចំណុចនានាដែលស្ថាប័នផ្តល់រូបមន្តអនុវត្តត្រូវស្រាវជ្រាវ ប្រសិនបើមានការចាំបាច់ ។ ឧទាហរណ៍ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកា ប្រសិនបើពុំមានភាពច្បាស់លាស់នៅក្នុងសំណុំរឿងថា តើសាលក្រម ឬ សាលដីកានោះបានចូលជាស្ថាពរហើយឬនៅ (មាត្រា ៣៥៥ កថាខណ្ឌទី ២) ឬ ត្រូវបញ្ជាក់អំពីការផ្ទេរសមត្ថភាពធ្វើជាភាគីនៃការអនុវត្តដោយបង្ខំ ដោយដាក់លិខិតបញ្ជាក់នៃអនុប្បទានសិទ្ធិលើបំណុល ជាអាទិ៍ (មាត្រា ៣៥៦ កថាខណ្ឌទី ២ និង ទី ៣) ។

(២) ក្រឡាបញ្ជី ឬ សារការី ត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាពនៃល័ក្ខខ័ណ្ឌទាមទារនានា សម្រាប់ការផ្តល់រូបមន្តអនុវត្ត និង ធ្វើការសម្រេចដោយឯករាជ្យ និង ដោយឆន្ទានុសិទ្ធិ ថាតើគួរផ្តល់រូបមន្តអនុវត្ត តាមពាក្យសុំ ឬ មិនផ្តល់ ។ ក៏ប៉ុន្តែ ដើម្បីផ្តល់រូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ កថាខណ្ឌទី ១ និង ទី ២) ក្រឡាបញ្ជី ត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន (មាត្រា ៣៥៦ កថាខណ្ឌទី ៣) ។ នៅពេលសរសេរបន្ថែមនូវរូបមន្តអនុវត្ត នៅក្នុងឯកសាចម្លងយថាភូតនៃលិខិតអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរអំពីហេតុការណ៍នៃការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ នៅក្នុងច្បាប់ដើមនៃលិខិតអនុវត្តនោះ (មាត្រា ៣៥៩ កថាខណ្ឌទី ១ ចំណុច ក ដល់ គ) ។ ជាគោលការណ៍ ការផ្តល់រូបមន្តអនុវត្ត មិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត នៅក្នុងលិខិតចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ត្រូវជូនដំណឹងអំពីហេតុនោះ ទៅកូនបំណុលនៃការអនុវត្តឱ្យបានដឹង (មាត្រា ៣៥៨ កថាខណ្ឌទី ២) ។

## ៤. វិញ្ញត្តិនៃរូបមន្តអនុវត្ត

(១) រូបមន្តអនុវត្ត ត្រូវសរសេរភ្ជាប់បន្ថែម នៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (មាត្រា ៣៥៧ កថាខណ្ឌទី ១) ។ នៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីបុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត ។ ឧទាហរណ៍ ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដែលមាន A ជាដើមបណ្តឹង និង B ជាចុងចម្លើយ នោះនៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្ត ត្រូវសរសេរថា "ដើមចោទ A អាចធ្វើការអនុវត្តដោយបង្ខំ ចំពោះចុងចម្លើយ B ដោយផ្អែកលើសាលក្រមនេះ" ។ នៅក្នុងរូបមន្តអនុវត្តដែលផ្តល់ឱ្យជាផលប្រយោជន៍សម្រាប់បុគ្គលផ្សេងពីភាគី ឬ ទល់នឹងបុគ្គលផ្សេងពីភាគី ត្រូវរៀបរាប់អំពីឈ្មោះ ឬ នាមករណ៍របស់បុគ្គលនោះ

ព្រមទាំងលក្ខណៈដែលអាចឱ្យបុគ្គលនោះ ក្លាយជាម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត (មាត្រា ៣៥៧ កថាខណ្ឌទី ១ ចំណុច ខ) ។ ឧទាហរណ៍ នៅក្នុងករណីខាងលើ ប្រសិនបើរូបមន្តអនុវត្ត ត្រូវបានផ្តល់ឱ្យជាផល ប្រយោជន៍សម្រាប់ C ដែលជាសន្តតិជនរបស់ដើមចោទ A និង ទល់នឹង D ដែលជាអ្នកកាន់កាប់ វត្ថុដែលជាកម្មវត្ថុ នោះនៅក្នុងរូបមន្តអនុវត្ត ត្រូវសរសេរថា "C ដែលជាសន្តតិជន (ឬ ប្រតិសិទ្ធិ) របស់ ដើមចោទ A អាចធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមនេះ ចំពោះ D ដែលជាអ្នកកាន់កាប់វត្ថុ ដែលជាកម្មវត្ថុ សម្រាប់ចុងចម្លើយ B" (មាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច គ និង កថាខណ្ឌទី ២) ។ ប្រសិនបើរូបមន្តអនុវត្ត ត្រូវបានផ្តល់ សម្រាប់តែសិទ្ធិទាមទារណាមួយជាក់លាក់ ក្នុងចំណោមសិទ្ធិទាមទារច្រើន ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ឬ ចំពោះតែភាគីណាមួយជាក់លាក់ ក្នុងចំណោមភាគីដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត នោះត្រូវរៀបរាប់ចំណុចនោះ ឱ្យបានច្បាស់លាស់ នៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្ត (មាត្រា ៣៥៧ កថាខណ្ឌទី ១ ចំណុច គ) ។ មួយវិញទៀត ប្រសិនបើផ្តល់រូបមន្តអនុវត្ត នៅក្នុងឯកសារចម្លងយថាភូត ច្រើនច្បាប់ ឬ ក៏នៅក្នុងលិខិតចម្លងយថាភូតដែលបានចេញសាជាថ្មី ក៏ត្រូវរៀបរាប់ចំណុចនោះឱ្យបាន ច្បាស់លាស់ដែរ (មាត្រា ៣៥៧ កថាខណ្ឌទី ១ ចំណុច ឃ) ។

## ចំណុចទី ៣ ការសង្គ្រោះពាក់ព័ន្ធនឹងការផ្តល់រូបមន្តអនុវត្ត

### ១. ការសង្គ្រោះសម្រាប់ម្ចាស់បំណុល

#### (i) ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍

(១) ក្នុងករណីដែលក្រឡាបញ្ជីបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យ សុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ ដើម្បីធ្វើឧបាស្រ័យទៅនឹងការចាត់ចែងនេះ (មាត្រា ៣៦២ កថាខណ្ឌទី ១) ។ ក្នុងករណីដែលសារការីបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ ពាក្យសុំតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះបាន ។ ប្រសិនបើ មានការដាក់ពាក្យសុំតវ៉ាបែបនេះ តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវនៃការតវ៉ានោះ ដោយ ដីកាសម្រេច (មាត្រា ៣៦២ កថាខណ្ឌទី ២) ។ ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ានោះ មិនមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ានោះ ។ ម្ចាស់បំណុល នៃការអនុវត្ត មិនអាចដាក់ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចនេះបានឡើយ ។ ប្រសិនបើតុលាការយល់ ឃើញថា ពាក្យសុំតវ៉ាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យស្ថាប័នផ្តល់រូបមន្តអនុវត្ត ផ្តល់នូវរូបមន្តអនុវត្តនោះ ។ ប្រសិនបើមានដីកាសម្រេចបង្គាប់ដូចនេះ ក្រឡាបញ្ជី ឬ សារការី ត្រូវផ្តល់ រូបមន្តអនុវត្តនោះ ។

#### (ii) ការដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់នាវការលិក

ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ប្រសិនបើស្ថាប័នផ្តល់រូបមន្តអនុវត្ត បដិសេធមិនផ្តល់រូបមន្តអនុវត្តពិសេស ដោយមូលហេតុថាល័ក្ខខ័ណ្ឌនោះមិនទាន់បានបំពេញ ឬ ពេលកំណត់នោះមិនទាន់មកដល់ (មាត្រា ៣៥៦ កថាខណ្ឌទី ១) នោះបើទោះបីជាម្ចាស់បំណុលនៃការអនុវត្ត មិនពេញចិត្តនឹងការចាត់ចែងនេះក៏ដោយ ក៏ម្ចាស់បំណុលនោះមិនត្រូវបានអនុញ្ញាតឱ្យប្រើវិធីពិសេសនៃឧបាស្រ័យណាផ្សេង ក្រៅពីវិធីនៃការដាក់ពាក្យសុំតវ៉ាដែលបានរៀបរាប់ខាងលើដែរ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា នៅក្នុងករណីបែបនេះ ម្ចាស់បំណុលនៃការអនុវត្ត អាចសម្រេចគោលបំណងរបស់ខ្លួន ដោយដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក តាមវិធីធម្មតា ដោយធ្វើការអះអាង និង បញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដនោះ ហើយទទួលសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដោយគ្មានល័ក្ខខ័ណ្ឌបាន ។ ស្រដៀងគ្នានេះដែរ ក្នុងករណីដែលបុគ្គលណាម្នាក់ផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត សុំឱ្យផ្តល់រូបមន្តអនុវត្ត ឬ ករណីដែលមានការសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះបុគ្គលណាផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត តែស្ថាប័នផ្តល់រូបមន្តអនុវត្ត បដិសេធមិនផ្តល់តាមការសុំនោះ ដោយមូលហេតុថា ពុំមានភាពច្បាស់លាស់ថាការអនុវត្តដោយបង្ខំអាចធ្វើទៅបានដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ហើយពុំមានការបញ្ជាក់ការអះអាងអំពីចំណុចនេះទេ (មាត្រា ៣៥៦ កថាខណ្ឌទី ២ និង ទី ៣) នោះបុគ្គលដែលមានបំណងធ្វើការអនុវត្តដោយបង្ខំដោយតាំងខ្លួនជាម្ចាស់បំណុល ត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក តាមវិធីធម្មតា ដោយយកបុគ្គលដែលខ្លួនគិតថាជាកូនបំណុល ធ្វើជាចុងចម្លើយ និង ដោយអះអាងអំពីហេតុនៃការស្នងឋានៈជាភាគី ដូចជាអនុប្បទានសិទ្ធិទាមទារ សន្តតិកម្ម ជាអាទិ៍ រួចទាមទារឱ្យចេញសាលក្រមថ្មីដែលបង្គាប់ឱ្យផ្តល់តាវកាលិក ។ ក្នុងករណីធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានទទួលថ្មីនេះ គេគ្រាន់តែចាំបាច់ត្រូវទទួលការផ្តល់រូបមន្តអនុវត្តធម្មតា ជាការគ្រប់គ្រាន់ ។

## ២. ការសង្គ្រោះសម្រាប់កូនបំណុល

### (i) **ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍**

(១) មូលហេតុនៃការតវ៉ា : ការតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ ដែលបានរៀបរាប់ខាងលើនេះ ក៏ត្រូវបានអនុញ្ញាតចំពោះកូនបំណុលនៃការអនុវត្តផងដែរ ដើម្បីធ្វើឧបាស្រ័យទៅនឹងការផ្តល់រូបមន្តអនុវត្តក្នុងករណីដែលស្ថាប័នផ្តល់រូបមន្តអនុវត្ត បានផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦២ កថាខណ្ឌទី ១) ។ ប្រសិនបើរូបមន្តអនុវត្ត ត្រូវបានផ្តល់ឱ្យដើម្បីធ្វើការអនុវត្តចំពោះកូនបំណុលនៃការអនុវត្តណាម្នាក់ កូនបំណុលនោះអាចដាក់ពាក្យសុំតវ៉ាទៅតុលាការ ដើម្បីសុំការសង្គ្រោះបាន ។ ចំណុចដែលអាចលើកមកអះអាងធ្វើជាមូលហេតុនៃការតវ៉ាបាន គឺហេតុដែលធ្វើឱ្យការផ្តល់រូបមន្តអនុវត្តនោះ ខុសច្បាប់ ពោលគឺហេតុនៃការខ្វះក្នុងការ

ស្រាវជ្រាវចំណុចណាមួយដែលស្ថាប័នផ្ដល់រូបមន្តអនុវត្តត្រូវធ្វើការស្រាវជ្រាវ ។ ក្នុងករណីដែលការផ្ដល់រូបមន្តអនុវត្ត មានភាពស្របច្បាប់នៅពេលផ្ដល់ ប៉ុន្តែ ក្រោយមកក្លាយជាខុសច្បាប់ទៅវិញ (ឧទាហរណ៍ដូចជាករណីដែលសាលក្រម ឬ សាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បានបាត់បង់អានុភាពដោយសារការដកពាក្យបណ្ដឹង នៅក្រោយពេលផ្ដល់រូបមន្តអនុវត្ត) នោះក៏អាចដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្តបានដែរ ។ នៅក្នុងករណីផ្ទុយទៅវិញ ទោះបីជាការផ្ដល់រូបមន្តអនុវត្ត មិនស្របច្បាប់នាពេលផ្ដល់ តែបើបច្ចុប្បន្ន វាបានក្លាយជាស្របច្បាប់វិញ (ឧទាហរណ៍ ដូចជាករណីដែលល័ក្ខខ័ណ្ឌទាមទារនានាត្រូវបានបំពេញនាពេលក្រោយមក) នោះការតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត នឹងត្រូវបានលើកចោល ។ ម្យ៉ាងវិញទៀត ចំណុចសារធាតុពាក់ព័ន្ធនឹងសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត (ឧទាហរណ៍ ការរលត់សិទ្ធិទាមទារដោយសារការសង ជាអាទិ៍) ត្រូវលើកមកអះអាងជាមូលហេតុនៃការតវ៉ានៅក្នុងបណ្ដឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣) ពោលគឺមិនត្រូវលើកជាមូលហេតុនៃការតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តទេ ។

ទោះបីជាក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់តាមរយៈដីកាសម្រេចរបស់តុលាការ ដោយផ្អែកលើពាក្យសុំតវ៉ារបស់ម្ចាស់បំណុលនៃការអនុវត្ត ចំពោះការមិនផ្ដល់រូបមន្តអនុវត្ត (របស់ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) ក៏ដោយ ក៏កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តនោះបានដែរ ឱ្យតែមានមូលហេតុដែលនាំឱ្យការផ្ដល់នោះ ខុសច្បាប់ ។

(២) ពេលនៃការដាក់ពាក្យសុំតវ៉ា : ពាក្យសុំតវ៉ា អាចដាក់បាន បន្ទាប់ពីរូបមន្តអនុវត្តត្រូវបានផ្ដល់ទោះជាពេលនោះ ការអនុវត្តដោយបង្ខំ មិនទាន់ត្រូវបានចាប់ផ្ដើមក៏ដោយ ។ ប៉ុន្តែ នៅក្រោយពេលបញ្ចប់ការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តដែលពាក់ព័ន្ធ ពេលនោះផលប្រយោជន៍ក្នុងការដាក់ពាក្យសុំតវ៉ា ត្រូវរលត់ហើយ ។

(៣) នីតិវិធី : (ក) ប្រសិនបើក្រឡាបញ្ជីជាអ្នកផ្ដល់រូបមន្តអនុវត្ត តុលាការដែលមានសមត្ថកិច្ចគឺតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ រីឯប្រសិនបើសារការីជាអ្នកផ្ដល់រូបមន្តអនុវត្តវិញ តុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលការិយាល័យរបស់សារការីនោះស្ថិតនៅ (មាត្រា ៣៦២ កថាខណ្ឌទី ១) ។

(ខ) តុលាការ ធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ដោយចេញដីកាសម្រេច (មាត្រា ៣៦២ កថាខណ្ឌទី ២) ។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំតវ៉ា ដោយពុំមានមូលហេតុត្រឹមត្រូវ កូនបំណុលនៃការអនុវត្ត មិនអាចធ្វើឧបាស្រ័យទៀតបានឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលរូបមន្តអនុវត្តពិសេសត្រូវបានផ្ដល់តាមបញ្ញត្តិនៃមាត្រា ៣៥៦ នោះកូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ដោយឡែកបាន (មាត្រា ៣៦៤) ។ ប្រសិនបើការដាក់ពាក្យបណ្ដឹងតវ៉ានេះ ត្រូវបានទទួលស្គាល់ថាមានមូលហេតុត្រឹមត្រូវ នោះនឹងមានដីកាសម្រេចប្រកាសថាលុបចោលរូបមន្តអនុវត្ត និង

ថាការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្ត អនុវត្តនោះ មិនត្រូវបានអនុញ្ញាតទេ ។ ម្ចាស់បំណុលនៃការអនុវត្ត មិនអាចធ្វើឧបាស្រ័យចំពោះដីកាសម្រេច នេះបានទេ ។ កូនបំណុលនៃការអនុវត្ត អាចទាមទារឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ ដោយ ដាក់ដីកាសម្រេចដែលហាមឃាត់ការអនុវត្តដោយបង្ខំនេះ ជូនទៅស្ថាប័នអនុវត្ត ( មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ) ។

(គ) ការចាត់ចែងមួយរយៈចំពោះការអនុវត្តដោយបង្ខំ : ទោះបីជាកូនបំណុលនៃការអនុវត្ត ដាក់ពាក្យសុំ តវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលមានភ្ជាប់ជា មួយនឹងរូបមន្តអនុវត្តនោះ មិនត្រូវបានផ្អាកដោយឯកឯងដែរ ។ ហេតុដូចនេះហើយ ដូចជាការពន្យល់ដែលបាន រៀបរាប់ពីខាងដើម អំពីករណីដែលមានការដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន និង ការដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការទាមទារដែរ នៅក្នុងករណីបែបនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចធ្វើការចាត់ចែង មួយរយៈ ដោយបង្គាប់ឱ្យផ្អាកការអនុវត្តសិន តាមពាក្យសុំរបស់កូនបំណុល ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ រហូតដល់ពេលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ារបស់កូនបំណុលនោះ ( មាត្រា ៣៦៩) ។ នៅក្នុងករណីបែបនេះ តុលាការមិនអាចបង្គាប់ឱ្យលុបចោលការអនុវត្តដោយបង្ខំ នៅក្នុងការចាត់ចែងមួយរយៈ នោះទេ ។

### (ii) បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត

(១) គោលគំនិត : បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ( មាត្រា ៣៦៤) គឺជាបណ្ដឹងពិសេសដែល អាចធ្វើទៅបាន នៅក្នុងករណីដែលមានការផ្ដល់រូបមន្តអនុវត្តពិសេសតាមបញ្ញត្តិនៃមាត្រា ៣៥៦ ដើម្បីឱ្យ កូនបំណុលនៃការអនុវត្ត អាចផាត់ចេញនូវការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិត អនុវត្តនោះ ដោយឈរលើមូលហេតុថា ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការផ្ដល់រូបមន្តអនុវត្តពិសេសនោះ មិនត្រូវបាន បំពេញ ។ រូបមន្តអនុវត្តពិសេស ត្រូវបានផ្ដល់ឱ្យ (ក) ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុង លិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ប្រសិនបើម្ចាស់បំណុលនៃការ អនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នៃពេលវេលាមិនពិតប្រាកដនោះ ឬ (ខ) ក្នុង ករណីដែលការអនុវត្តដោយបង្ខំ ប្រុងនឹងធ្វើឡើង ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់ នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ប្រសិនបើមានភាព ច្បាស់លាស់ថា បុគ្គលនោះ ស្ថិតនៅក្នុងវិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា ៣៥១ (ឬ អាចហៅម៉្យាងទៀតបានថា បុគ្គលដែលទទួលអានុភាពនៃលិខិតអនុវត្ត) ហើយដោយហេតុនេះ មានភាពច្បាស់លាស់ថា ការអនុវត្តដោយបង្ខំ អាចធ្វើទៅបាន ដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃ ការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត បានធ្វើការបញ្ជាក់អំពី

ហេតុនោះ ។ បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត គឺជាបណ្ដឹងដែលកូនបំណុលនៃការអនុវត្តទាមទារឱ្យផាត់ចេញនូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តពិសេស (ក) ដោយលើកវិវាទអំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នៃពេលវេលាមិនពិតប្រាកដ ឬ (ខ) ដោយផ្អែកលើមូលហេតុថា បុគ្គលដែលត្រូវបានកំណត់នៅក្នុងរូបមន្តអនុវត្ត ថាជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តនោះ មិនមែនជាបុគ្គលដែលស្ថិតនៅក្នុងវិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា ៣៥១ ទេ (ឧទាហរណ៍ បុគ្គលនោះ មិនមែនជាអ្នកទទួលបន្តសិទ្ធិ ឬ ករណីយកិច្ច ដូចមានចែងក្នុងមាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច គ ទេ) ហើយដោយហេតុនេះ ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនោះ មិនអាចធ្វើទៅបានដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តឡើយ ។

(២) ទំនាក់ទំនងជាមួយនឹងពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត : បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត អាចធ្វើទៅបានតែក្នុងករណីដែលកូនបំណុលនៃការអនុវត្ត លើកការអះអាងប្រឆាំងនឹងការផ្ដល់រូបមន្តអនុវត្តពិសេស ថាការផ្ដល់រូបមន្តអនុវត្តនោះ ខុសច្បាប់ ដោយសារការមិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៥៦ កថាខណ្ឌទី ១ ឬ ទី ៣ ប៉ុណ្ណោះ ។ ដោយឡែក ដើម្បីលើកការអះអាងអំពីភាពខុសច្បាប់នៃការផ្ដល់រូបមន្តអនុវត្តផ្សេងទៀត មានតែធ្វើតាមវិធីនៃការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត (មាត្រា ៣៦២) ដែលបានរៀបរាប់ពីមុន តែប៉ុណ្ណោះ ។ មូលហេតុដែលបណ្ដឹងនេះ អាចធ្វើទៅបាន តែដោយផ្អែកលើការមិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៥៦ កថាខណ្ឌទី ១ ឬ ទី ៣ ប៉ុណ្ណោះ ព្រោះថា ល័ក្ខខ័ណ្ឌទាំងនេះ ពាក់ព័ន្ធទៅនឹងចំណុចដែលស្ថិតនៅក្នុងច្បាប់សារធាតុ ហើយដោយហេតុនេះ ចាំបាច់ត្រូវវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពរបស់វា ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ និង ត្រូវសម្រេចសេចក្ដីដោយចេញសាលក្រម (សូមមើលមាត្រា ១១៤ កថាខណ្ឌទី ១) ។ ប៉ុន្តែ ក្នុងករណីដែលបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ត្រូវបានដាក់ដើម្បីលើកវិវាទអំពីការបំពេញល័ក្ខខ័ណ្ឌ ឬ អំពីលក្ខណសម្បត្តិជាប្រតិសិទ្ធិ ជាអាទិ៍ នោះក្នុងពេលជាមួយគ្នា ក៏អាចលើកការអះអាងអំពីភាពខុសច្បាប់នៃការផ្ដល់រូបមន្តអនុវត្តដោយផ្អែកលើមូលហេតុផ្សេងទៀត បានដែរ (ដោយដាក់ពាក្យសុំតវ៉ា) ។ ម្យ៉ាងទៀត បញ្ហាពាក់ព័ន្ធនឹងការមិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារ ឬ ភាពមិនគ្រប់លក្ខណសម្បត្តិធ្វើជាប្រតិសិទ្ធិ អាចលើកមកអះអាងនៅក្នុងការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត (មាត្រា ៣៦២ កថាខណ្ឌទី ១) បាន ហើយបើទោះជានៅក្រោយពេលដែលចំណុចទាំងនេះត្រូវបានបដិសេធដោយដីកាសម្រេចលើកចោលពាក្យសុំតវ៉ាក៏ដោយ ក៏ពុំមានការហាមឃាត់មិនឱ្យលើកបញ្ហាទាំងនេះមកអះអាងឡើងវិញ នៅក្នុងបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តដែរ ព្រោះថា ដីកាសម្រេចអំពីពាក្យសុំតវ៉ា មិនមានអាជ្ញាអស់ជំនុំទេ ។

(៣) ចំពោះនីតិវិធីនៅក្នុងបណ្ដឹងតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត គឺដូចគ្នាទៅនឹងនីតិវិធីនៅក្នុងបណ្ដឹងតវ៉ា

ចំពោះការទាមទារដែរ ។ ម្ចាស់បំណុល ត្រូវទទួលខុសត្រូវក្នុងការលើកឡើងនូវចំណុចនានាដែលត្រូវធ្វើការបញ្ជាក់ ពាក់ព័ន្ធនឹងការផ្តល់រូបមន្តអនុវត្ត ។ ការផ្អាកការអនុវត្តដោយបង្ខំ ដែលអាចធ្វើបាន នៅពេលមានការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ត្រូវបានចែងដូចគ្នាជាមួយនឹងបណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៧) ។

(៤) ប្រសិនបើទទួលស្គាល់ការទាមទាររបស់កូនបំណុលនៃការអនុវត្ត តុលាការត្រូវប្រកាសនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមចុងក្រោយថា មិនអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះទេ (មាត្រា ៣៦៤ កថាខណ្ឌទី ១) ។ នៅពេលសាលក្រមនេះចូលជាស្ថាពរ រូបមន្តអនុវត្តនោះ នឹងបាត់បង់អានុភាព ។ នៅពេលសាលក្រមនេះចូលជាស្ថាពរ កូនបំណុលនៃការអនុវត្តអាចសុំឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំបាន ដោយដាក់ឯកសារចម្លងយថាភូតនៃសាលក្រមនេះ ជូនទៅស្ថាប័នអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ) ។ ប៉ុន្តែ អ្វីដែលត្រូវហាមឃាត់ គឺការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេសដែលពាក់ព័ន្ធនោះ តែប៉ុណ្ណោះ ។ អាចនិយាយម៉្យាងទៀតបានថា មានតែការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានរូបមន្តអនុវត្តភ្ជាប់ជាមួយ ដោយសារការបានបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬ ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ដែលកំណត់យកបុគ្គលផ្សេងពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះ ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត តែប៉ុណ្ណោះ ដែលត្រូវបានហាមឃាត់ ។ មានន័យថា ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនោះ មិនត្រូវបានហាមឃាត់ទាំងស្រុងនោះឡើយ ។ ឧទាហរណ៍ ម្ចាស់បំណុលនៃការអនុវត្ត អាចនឹងសុំឱ្យផ្តល់រូបមន្តអនុវត្តម្តងទៀត ហើយធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើរូបមន្តអនុវត្តនោះ ប្រសិនបើល័ក្ខខ័ណ្ឌទាមទារត្រូវបានបំពេញនាពេលក្រោយមក ដោយធ្វើការបញ្ជាក់អំពីហេតុនោះ ឬ ដោយធ្វើការបញ្ជាក់ថា បុគ្គលផ្សេងម្នាក់ទៀត អាចធ្វើជាកូនបំណុលនៃការអនុវត្ត និង ទទួលអានុភាពនៃលិខិតអនុវត្តនោះ ។

## ផ្នែកទី ៥ ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមការអនុវត្តដោយបង្ខំ

### ១. ការបញ្ជាក់អំពីភាគីនៃការអនុវត្ត

ឈ្មោះ ឬ នាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ត្រូវបញ្ជាក់ដោយរូបមន្តអនុវត្ត នៅក្នុងឯកសាចម្លងយថាភូតនៃលិខិតអនុវត្ត ថាជាបុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន និង ភាគីម្ខាងទៀត (មាត្រា ៣៥៧ កថាខណ្ឌទី ១ ចំណុច ក) ។

### ២. ការបញ្ជូនលិខិតអនុវត្ត

លិខិតអនុវត្ត ដែលជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត នៅមុនពេលចាប់ផ្តើមការអនុវត្ត ឬ យ៉ាងយូរបំផុត ស្របពេលជាមួយនឹងការចាប់ផ្តើមការអនុវត្ត (មាត្រា ៣៦០ វាក្យខណ្ឌទី ១) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះវាមានភាពចាំបាច់ក្នុងការជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត អំពីសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលនឹងអនុវត្តដោយបង្ខំ ។ ក៏ប៉ុន្តែ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន អាចធ្វើទៅបាន ដោយមិនចាំបាច់មានការបញ្ជូនទេ (មាត្រា ៥៦២ កថាខណ្ឌទី ៣) ព្រោះថា ការអនុវត្តប្រភេទនេះ ទាមទារនូវភាពឆាប់រហ័ស ហើយការជូនដំណឹងជាមុនទៅកូនបំណុលនៃការអនុវត្ត អាចនឹងបណ្តាលឱ្យមានការរំខានដល់ការអនុវត្តផង ។ ដោយសារថា សាលក្រមឬសាលដីកា ត្រូវបានបញ្ជូនទៅភាគី ដោយឆន្ទានុសិទ្ធិ ក្រោយពេលត្រូវបានប្រកាស (មាត្រា ១៩០ កថាខណ្ឌទី ១) ដូច្នេះ មិនចាំបាច់ត្រូវបញ្ជូនម្តងទៀតទេ ជាពិសេសក្នុងគោលបំណងធ្វើការអនុវត្តដោយបង្ខំ ។ ក៏ប៉ុន្តែ ដោយសារថា ការបញ្ជូនត្រូវធ្វើចំពោះកូនបំណុលពិតប្រាកដនៃការអនុវត្ត ដូច្នេះ នៅក្នុងការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេងពីភាគីដែលបានកំណត់នៅក្នុងសាលក្រមឬសាលដីកា ធ្វើជាកូនបំណុលនៃការអនុវត្ត នោះត្រូវតែបញ្ជូនលិខិតអនុវត្ត ទៅបុគ្គលនោះ ។ សកម្មភាពនៃការអនុវត្តដោយបង្ខំ ដែលធ្វើឡើងដោយគ្មានការបញ្ជូន គឺជាសកម្មភាពខុសច្បាប់ ប៉ុន្តែ ប្រសិនបើមានការបញ្ជូនធ្វើឡើងនៅមុនពេលសកម្មភាពនោះត្រូវបានលុបចោល ភាពខុសច្បាប់នោះ នឹងត្រូវបានស្រោចស្រង់ឡើងវិញ ។

### ៣. ការបញ្ជូនរូបមន្តអនុវត្ត និង លិខិតបញ្ជាក់

ជាគោលការណ៍ ការបញ្ជូនរូបមន្តអនុវត្ត មិនមានភាពចាំបាច់ទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការអនុវត្តដោយបង្ខំ ជាប់ពាក់ព័ន្ធនឹងការបំពេញល័ក្ខខ័ណ្ឌបង្អង់ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ (មាត្រា ៣៥៦ កថាខណ្ឌទី ១) និង ករណីដែលរូបមន្តអនុវត្ត ត្រូវបានផ្តល់ដោយយកបុគ្គលផ្សេងពីភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត (មាត្រា ៣៥៦ កថាខណ្ឌទី ២) មានការទាមទារជាពិសេសឱ្យធ្វើការបញ្ជូនរូបមន្តអនុវត្តនោះ នៅមុនពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ (មាត្រា ៣៦០ វាក្យខណ្ឌទី ២) ដោយសារថា រូបមន្តអនុវត្តប្រភេទនេះ គឺជាការបន្ថែមខ្លឹមសារទៅលើលិខិតអនុវត្ត ។ ម្យ៉ាងវិញទៀត ប្រសិនបើរូបមន្តអនុវត្ត ត្រូវបានផ្តល់ឱ្យ ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ នោះក៏ត្រូវបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារនោះផងដែរ (មាត្រា ៣៦០ វាក្យខណ្ឌទី ២) ។

### ៤. ការមកដល់នៃពេលដែលត្រូវផ្តល់ដាវកាលិក

ប្រសិនបើសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ ស្ថាប័នអនុវត្ត អាចចាប់ផ្តើមអនុវត្តដោយបង្ខំបាន លុះត្រាតែពេលកំណត់នោះបានមកដល់ហើយ (មាត្រា ៣៦១ កថាខណ្ឌទី ១) ។ ចំពោះបញ្ហាថាតើពេលកំណត់បានមកដល់ហើយឬនៅ នោះគឺជាចំណុចសារធាតុ ប៉ុន្តែ

វាងាយស្រួលនឹងដឹងថាតើពេលកំណត់មកដល់ ឬនៅ ក្នុងករណីនៃពេលកំណត់ពិតប្រាកដនោះ ហេតុដូច្នេះ ការស្រាវជ្រាវអំពីចំណុចនេះ ត្រូវទុកឱ្យស្ថាប័នអនុវត្តជាអ្នកធ្វើ ពោលគឺមិនបាច់ធ្វើការស្រាវជ្រាវនៅពេលផ្តល់រូបមន្តអនុវត្តទេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់មិនពិតប្រាកដ ដូចគ្នាទៅនឹងករណីដែលសិទ្ធិនោះមានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ដែរ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការបញ្ជាក់អំពីការមកដល់នៃពេលកំណត់នោះជាមុនសិន ទើបទទួលការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៥៦ កថាខណ្ឌទី ១) ។ ប្រសិនបើស្ថាប័នអនុវត្ត ចាប់ផ្តើមការអនុវត្តនៅមុនការមកដល់នៃពេលកំណត់ពិតប្រាកដ សកម្មភាពនៃការអនុវត្តនោះ គឺជាសកម្មភាពខុសច្បាប់ ។ ក៏ប៉ុន្តែ ប្រសិនបើពេលកំណត់ពិតប្រាកដ មកដល់មុនពេលដែលសកម្មភាពនោះត្រូវបានលុបចោល វិការៈនោះ នឹងត្រូវបានស្រោចស្រង់ឡើងវិញ ។

## ៥. ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ

ក្នុងករណីដែលលិខិតអនុវត្ត ដាក់ល័ក្ខខ័ណ្ឌដែលតម្រូវឱ្យដាក់ប្រាតិភោគ ស្ថាប័នអនុវត្ត អាចចាប់ផ្តើមការអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត បានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ (មាត្រា ៣៦១ កថាខណ្ឌទី ២) ។ ដោយសារថា ការបានដាក់ប្រាតិភោគ ឬមិនបានដាក់ប្រាតិភោគ មានភាពច្បាស់លាស់ និង ងាយស្រួលបញ្ជាក់ដោយឯកសារផ្លូវការ ដូច្នេះ ខុសគ្នាពីល័ក្ខខ័ណ្ឌដទៃទៀត (សូមមើលមាត្រា ៣៥៦ កថាខណ្ឌទី ១) បញ្ហានេះមិនត្រូវបានចាត់ជាបញ្ហាដែលត្រូវស្រាវជ្រាវនៅពេលផ្តល់រូបមន្តអនុវត្តទេ ពោលគឺវាជាបញ្ហាដែលត្រូវស្រាវជ្រាវដោយស្ថាប័នអនុវត្ត នៅពេលចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំវិញ ។ ការអនុវត្តដោយបង្ខំ ដោយពុំមានការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ គឺជាការអនុវត្តខុសច្បាប់ ។ ក៏ប៉ុន្តែ ប្រសិនបើលិខិតនោះ ត្រូវបានដាក់នាពេលក្រោយមក ការអនុវត្តនោះ នឹងក្លាយទៅជាស្របច្បាប់វិញ ចាប់ពីពេលដាក់នោះ ។

## ៦. ការផ្តល់តាវកាលិកតប

ក្នុងករណីដែលលិខិតអនុវត្តកំណត់ថា តាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្តល់ ដោយប្តូរនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត ស្ថាប័នអនុវត្តអាចចាប់ផ្តើមការអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត បញ្ជាក់ថា ខ្លួនបានផ្តល់តាវកាលិកតបនោះរួចហើយ (មាត្រា ៣៦១ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រមស្ថាពរបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ ដោយប្តូរនឹងការបង់ថ្លៃលក់ នោះអាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត អាចចាប់ផ្តើមការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុនោះបាន លុះណាតែអ្នកទិញ ដែលជាម្ចាស់បំណុលនៃការអនុវត្ត បានបញ្ជាក់ចំពោះអាជ្ញាសាលាថា ខ្លួនបានបង់ ឬ ធ្វើសំណើផ្តល់ការសងនូវថ្លៃលក់នោះសិន ។ មានន័យថា ម្ចាស់បំណុលមិនចាំបាច់បញ្ជាក់អំពីការផ្តល់ ឬ ការធ្វើសំណើផ្តល់សងចំពោះតាវកាលិកតប នៅពេលខ្លួនសុំឱ្យផ្តល់រូបមន្ត

អនុវត្តទេ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា : ប្រសិនបើកំណត់ថា ការផ្តល់តាវកាលិកតប គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការផ្តល់រូបមន្តអនុវត្ត ហើយដោយហេតុនេះ ស្ថាប័នផ្តល់រូបមន្តអនុវត្តត្រូវស្រាវជ្រាវអំពីចំណុចនេះ នៅពេលផ្តល់រូបមន្តអនុវត្ត នោះនៅក្នុងឧទាហរណ៍ខាងលើ អ្នកទិញត្រូវបង់ថ្លៃលក់ ឬ ធ្វើសំណើផ្តល់ការសង នៅពេលសុំឱ្យផ្តល់រូបមន្តអនុវត្ត គឺនៅមុនពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តដោយបង្ខំ ។ នេះ មានន័យថា អ្នកទិញត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុន ដែលការណ៍នេះ នាំទៅដល់ការមិនអាចធានាបាន នូវទំនាក់ទំនងនៃការផ្តល់តាវកាលិកក្នុងពេលជាមួយគ្នា តាមច្បាប់សារធាតុ ។

## ៧. ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ

(១) ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ សំដៅទៅលើហេតុដែលរារាំងក្នុងការចាប់ផ្តើម ឬ ការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ពោលគឺល័ក្ខខ័ណ្ឌអវិជ្ជមានសម្រាប់ការអនុវត្ត ។ ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ គឺជាហេតុដែលនឹងក្លាយជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំទាំងស្រុង ចំពោះសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគណាមួយ ហើយខុសគ្នាពីហេតុដែលជាឧបសគ្គពិសេសក្នុងការធ្វើសកម្មភាពណាមួយក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ (ឧទាហរណ៍ដូចជា ការហាមឃាត់ការរឹបអូស) ។

(២) ខាងក្រោមនេះ គឺជាឧទាហរណ៍នៃហេតុនានាដែលជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ

(ក) ការចាប់ផ្តើមនីតិវិធីក្ស័យធនចំពោះកូនបំណុលនៃការអនុវត្ត : នៅពេលណាដែលនីតិវិធីក្ស័យធនដូចជានីតិវិធីក្ស័យធនបុគ្គល ឬ នីតិវិធីនៃការរៀបចំសហគ្រាសឡើងវិញ ជាអាទិ៍ ត្រូវបានចាប់ផ្តើមឡើង នោះការអនុវត្តដោយបង្ខំមួយៗដែលផ្អែកលើសិទ្ធិលើបំណុលចំពោះកូនបំណុលនៃការអនុវត្ត ត្រូវហាមឃាត់ ហើយអាស្រ័យលើលក្ខណៈនៃនីតិវិធី ការអនុវត្តសិទ្ធិប្រាតិភោគ ក៏ត្រូវហាមឃាត់ដែរ ។

(ខ) ការរឹបអូសសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត : ប្រសិនបើសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ត្រូវបានរឹបអូសដោយម្ចាស់បំណុលរបស់ខ្លួន ម្ចាស់បំណុលនៃការអនុវត្តនោះ ត្រូវបានហាមឃាត់មិនឱ្យធ្វើការប្រមូលសិទ្ធិទាមទារនោះទេ (មាត្រា ៤០៣ កថាខណ្ឌទី ៥) ។ អាស្រ័យហេតុនេះហើយ នៅពេលណាដែលមានការបង្គាញនូវដីកាសម្រេចរឹបអូសចំពោះស្ថាប័នអនុវត្ត នោះស្ថាប័នអនុវត្តនោះ មិនអាចចាប់ផ្តើម ឬ បន្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលត្រូវបានរឹបអូសនោះទៀតទេ ។ សិទ្ធិប្រាតិភោគ មិនអាចត្រូវបានរឹបអូសដោយឯករាជ្យឡើយ ប៉ុន្តែ ប្រសិនបើមានការរឹបអូសនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ នោះភាគីដែលត្រូវបានធានា មិនអាចចាប់ផ្តើម ឬ បន្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ដើម្បីសម្រេចនូវសិទ្ធិប្រាតិភោគនោះបានទេ ព្រោះថា ការរឹបអូសនោះ បង្កើតអានុភាពចំពោះសិទ្ធិប្រាតិភោគផងដែរ (មាត្រា ៤០៣ កថាខណ្ឌទី ១០) ។

## ផ្នែកទី ៦ ដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ

## កថាភាគទី ១ ពេលនៃការចាប់ផ្ដើម និង ការបញ្ចប់ការអនុវត្តដោយបង្ខំ

### ១. ការចាប់ផ្ដើមការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ ចាប់ផ្ដើមនៅពេលដែលស្ថាប័នអនុវត្តធ្វើសកម្មភាពបង្ខំលើកដំបូង ចំពោះកូនបំណុលនៃការអនុវត្ត ដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ គ្រាន់តែហេតុដែលម្ចាស់បំណុលបានទទួលការផ្ដល់រូបមន្តអនុវត្ត នៅលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ ពុំមែនជាការចាប់ផ្ដើមការអនុវត្តដោយបង្ខំទេ ។ នៅក្នុងករណីដែលស្ថាប័នអនុវត្ត គឺជាអាជ្ញាសាលា នៅពេលដែលអាជ្ញាសាលានោះ ធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូស ដោយចូលទៅក្នុងផ្ទះរបស់កូនបំណុលនៃការអនុវត្ត ដើម្បីធ្វើការរឹបអូស (មាត្រា ៣៨៥ កថាខណ្ឌទី ២) ឬ ដោយបង្គាប់ឱ្យអ្នកស្នាក់នៅ រើចេញពីដី ឬ អាគារណាមួយ និង យកគ្រឿងសង្ហារិមចេញ ជាអាទិ៍ (មាត្រា ៥២៤ កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤) នោះត្រូវចាត់ទុកថា ការអនុវត្តដោយបង្ខំ ត្រូវបានចាប់ផ្ដើមនៅពេលនោះ ។ ការដាស់តឿនឱ្យកូនបំណុលនៃការអនុវត្ត សងបំណុលដោយស្ម័គ្រចិត្ត (មាត្រា ៣៨៤ កថាខណ្ឌទី ៥) មិនមែនជាការចាប់ផ្ដើមការអនុវត្តដោយបង្ខំទេ ។ ក្នុងករណីដែលស្ថាប័នអនុវត្ត គឺជាតុលាការអនុវត្តវិញ ពេលនៃការចាប់ផ្ដើមការអនុវត្តដោយបង្ខំ គឺពេលចេញសេចក្ដីសម្រេចដែលផ្ដុកនូវនីតិវិធីនៃការអនុវត្តនាដំណាក់កាលដំបូង ឧទាហរណ៍ដូចជា ដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល (មាត្រា ៤០៣ កថាខណ្ឌទី ៤) ដីកាសម្រេចចាប់ផ្ដើមការលក់អចលនវត្ថុដោយបង្ខំ (មាត្រា ៤១៩ កថាខណ្ឌទី ១) ជាដើម ។

### ២. ការបញ្ចប់ការអនុវត្តដោយបង្ខំ

(១) ទាក់ទងទៅនឹងការបញ្ចប់ការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវធ្វើការបែងចែករវាងការបញ្ចប់ការអនុវត្តដោយបង្ខំទាំងស្រុង ដែលបានសម្រេចយ៉ាងពេញលេញនូវសិទ្ធិទាមទារជាក់លាក់ណាមួយ និង ការបញ្ចប់នូវនីតិវិធីនៃការអនុវត្តដោយបង្ខំ ចំពោះកម្មវត្ថុជាក់លាក់ណាមួយ ឬ ដោយវិធីជាក់លាក់ណាមួយនៃការអនុវត្ត ព្រោះថា ការសម្រេចយ៉ាងពេញលេញនូវសិទ្ធិទាមទារណាមួយ អាចធ្វើឡើង ដោយរួមបញ្ចូលនូវនីតិវិធីនៃការអនុវត្តដោយបង្ខំជាច្រើនប្រភេទ ។ ចំណុចនេះ នឹងក្លាយទៅជាបញ្ហា នៅក្នុងករណីនៃការផ្អាក ឬ ការលុបចោលការអនុវត្ត ដូចនឹងពន្យល់ខាងក្រោម ។ ក្នុងករណីនៃការអនុវត្តដោយបង្ខំដើម្បីសម្រេចសិទ្ធិប្រាតិភោគ ប្រសិនបើកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ មានច្រើន ដូចជាករណីនៃហ៊ីប៉ូតែករួម (មាត្រា ៨៥៧ នៃក្រមរដ្ឋប្បវេណី) នោះគេអាចនឹងធ្វើការបែងចែកបាន រវាងការបញ្ចប់ការអនុវត្តដោយបង្ខំទាំងស្រុង និង ការបញ្ចប់នីតិវិធីមួយៗនៃការអនុវត្តដោយបង្ខំ តាមវិធីដូចគ្នាដែរ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងចំពោះកម្មវត្ថុទាំងមូលនៃសិទ្ធិប្រាតិភោគនោះ ការអនុវត្តដោយបង្ខំនោះត្រូវបញ្ចប់ទាំងស្រុង បើទោះបីជាសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគនោះ មិនទាន់បានសម្រេចយ៉ាងពេញលេញក៏ដោយ ។

(២) ការអនុវត្តដោយបង្ខំទាំងមូល បញ្ចប់នៅពេលដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ឬ នៅក្នុងឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ព្រមទាំងសោហ៊ុយទាំងអស់នៃការអនុវត្ត ត្រូវបានសម្រេចយ៉ាងពេញលេញ ។ មុននឹងដល់ការសម្រេចនេះ គឺគេនៅតែទទួលស្គាល់ថា មានផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ និង ការតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍ ។

នីតិវិធីនៃការអនុវត្តដោយបង្ខំមួយៗ បញ្ចប់នៅពេលដែលសកម្មភាពចុងក្រោយដែលត្រូវបានកំណត់សម្រាប់នីតិវិធីនីមួយៗនោះ ត្រូវបានបញ្ចប់ ។ ជាងនេះទៅទៀត ទោះបីជាមិនបានទៅដល់ដំណាក់កាលចុងក្រោយក៏ដោយ ប្រសិនបើស្ថាប័នអនុវត្ត ផ្អាកនីតិវិធីនៃការអនុវត្ត និង លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយសារម្ចាស់បំណុលបានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ ដោយសារកូនបំណុលនៃការអនុវត្ត ឬ តតិយជនបានដាក់ឯកសារដែលនាំឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ នោះនីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបញ្ចប់ ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏ត្រូវបញ្ចប់ផងដែរ នៅពេលដែលស្ថាប័នអនុវត្ត លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយសារការកើតឡើងនូវហេតុដែលជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ ។

## កថាភាគទី ២ ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

### ១. ការផ្អាកការអនុវត្តដោយបង្ខំ

(១) ការផ្អាកការអនុវត្តដោយបង្ខំ សំដៅទៅលើស្ថានភាពដែលស្ថាប័នអនុវត្ត មិនអាចចាប់ផ្ដើម ឬ បន្តការអនុវត្តដោយបង្ខំ តាមច្បាប់បាន ។ ទំហំនៃអានុភាពនៃការផ្អាក ប្រែប្រួលទៅតាមមូលហេតុនៃការផ្អាក ។ ឧទាហរណ៍ ប្រសិនបើមានការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ការផ្អាកដែលត្រូវបានបង្គាប់ជាការចាត់ចែងមួយរយៈរហូតដល់ពេលចេញសាលក្រមចុងក្រោយ (មាត្រា ៣៦៧ កថាខណ្ឌទី ១) មានអានុភាពទៅលើការអនុវត្តដោយបង្ខំទាំងមូល ដែលផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះ ។ ផ្ទុយទៅវិញ ការផ្អាកដែលជាការចាត់ចែងមួយរយៈ ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤ កថាខណ្ឌទី ៣ និង មាត្រា ៣៨៣ កថាខណ្ឌទី ២) ត្រូវបានកម្រិតត្រឹមតែការផ្អាកនូវសកម្មភាពនៃការអនុវត្តដោយបង្ខំដែលជាកម្មវត្ថុនៃការតវ៉ានោះប៉ុណ្ណោះ ។

(២) ករណីដែលការអនុវត្តដោយបង្ខំ ត្រូវបានផ្អាកតែចំពោះផ្នែកខ្លះនៃសិទ្ធិទាមទារ ឬ ចំពោះតែបុគ្គលណាម្នាក់នៃម្ចាស់បំណុលរួម ឬ ចំពោះតែផ្នែកខ្លះនៃកម្មវត្ថុនៃការអនុវត្តប៉ុណ្ណោះ ហៅថា ការកម្រិតនៃការអនុវត្តដោយបង្ខំ ។

### ២. ការលុបចោលការអនុវត្តដោយបង្ខំ

(១) ការលុបចោលការអនុវត្តដោយបង្ខំ មានន័យថាជាការជម្រះចេញនូវការចាត់ចែងការអនុវត្តទាំង

មូល ឬ មួយផ្នែក ដែលបានធ្វើរួចហើយដោយស្ថាប័នអនុវត្ត នៅក្នុងដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ហេតុនេះហើយ ការលុបចោលការអនុវត្តដោយបង្ខំ ពុំអាចគិតបាន នៅមុនពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ ហើយនៅក្រោយការបញ្ចប់នីតិវិធីមួយៗនៃការអនុវត្តដោយបង្ខំ ការលុបចោលនូវការចាត់ចែងការអនុវត្តដែលធ្វើឡើងនៅក្នុងនីតិវិធីនោះ មិនត្រូវបានអនុញ្ញាតទេ ។ បើទោះបីជាការចាត់ចែងការអនុវត្តពុំមានសុពលភាពតាមផ្លូវច្បាប់តាំងពីដំបូងក៏ដោយ ប្រសិនបើវាមានអត្ថិភាពពីខាងក្រៅ វាអាចនឹងត្រូវបានលុបចោល ដើម្បីជម្រះចោលនូវឧបសគ្គដែលអាចនឹងកើតចេញពីការចាត់ចែងនោះ ។

(២) ក្រៅពីករណីដែលមានមូលហេតុសម្រាប់ការលុបចោល ដូចនឹងរៀបរាប់ខាងក្រោមនេះ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ដកពាក្យសុំឱ្យចាប់ផ្ដើមការអនុវត្តដោយបង្ខំ ឬ លះបង់សិទ្ធិដែលបានទទួលពីការចាត់ចែងការអនុវត្តនោះ (ឧទាហរណ៍ សិទ្ធិប្រមូលបំណុល ដែលបានទទួលពីដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលនៃមាត្រា ៤១០ កថាខណ្ឌទី ១) នៅមុនពេលបញ្ចប់ការអនុវត្តដោយបង្ខំ នោះការអនុវត្តដោយបង្ខំ ក៏ត្រូវលុបចោលដែរ ។ ដោយសារថា ការលះបង់នេះ ពុំមែនជាការលះបង់សិទ្ធិទាមទារតាមច្បាប់សារធាតុ ដូច្នេះ ការលះបង់នេះ មិនរារាំងម្ចាស់បំណុលនៃការអនុវត្តមិនឱ្យធ្វើការអនុវត្តដោយបង្ខំម្ដងទៀត នាពេលក្រោយមកដោយផ្អែកលើឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្តនៃលិខិតអនុវត្តដដែល តាមវិធីដដែល ឬ តាមវិធីផ្សេង ឡើយ ។

## ៣. មូលហេតុនៃការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

ទាញចេញពីទស្សនវិស័យច្បាប់ ការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ មានន័យថា ស្ថាប័នអនុវត្ត មិនអាចចាប់ផ្ដើម ឬ បន្តការអនុវត្តដោយបង្ខំបានទេ ហើយប្រសិនបើបានធ្វើការចាត់ចែងការអនុវត្តខ្លះហើយ ការចាត់ចែងនោះត្រូវលុបចេញវិញ ។ ជាគោលការណ៍ ការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំកើតឡើងនៅពេលដែលកូនបំណុលនៃការអនុវត្ត ឬ តតិយជន ដាក់ឯកសារជាលាយលក្ខណ៍អក្សរដែលជាមូលហេតុនៃការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ ដូចមានរៀបរាប់ចាប់ពីចំណុចទី (១) ដល់ទី (៨) ខាងក្រោមនេះ ។ ក៏ដូចគ្នាផងដែរ ប្រសិនបើស្ថាប័នអនុវត្ត រកឃើញថា មានការខ្វះល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ ដែលធ្វើឱ្យការអនុវត្តនោះ ក្លាយជាមោឃៈដោយឯកឯង ឬ ថាមានហេតុដែលជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ នោះស្ថាប័នអនុវត្ត ត្រូវផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំនោះ ។ ឧទាហរណ៍នៃករណីទាំងនេះ មានដូចជាករណីដែលមានវិការៈនៅក្នុងឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្តនៃលិខិតអនុវត្ត ឬ ករណីដែលរកឃើញថាមាននីតិវិធីធនក្ស័យរបស់កូនបំណុលនៃការអនុវត្តបានចាប់ផ្ដើម ជាអាទិ៍ ។

(១) ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្ត ក្រៅពីលិខិតបញ្ជាក់អនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ក វាក្យខណ្ឌទី ១) : ប្រសិនបើលិខិតអនុវត្តគឺជា

សាលក្រម ឬ សាលដីកា ឯកសារនេះគឺជាសាលដីកាទទួលស្គាល់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ក្នុងករណីនៃសាលក្រម ឬ សាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) និង សាលក្រម ឬ សាលដីកាទទួលស្គាល់បណ្តឹងសុំជំនុំជម្រះសាជាថ្មី (ក្នុងករណីនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ) ដែលលុបចោលសាលក្រម ឬ សាលដីកាដែលជាលិខិតអនុវត្តនោះ ។ ក្នុងករណីដែលលិខិតអនុវត្តគឺជាដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឯកសារនេះ គឺជាសាលក្រម ឬ សាលដីកាដែលលុបចោលដីកាសម្រេចនោះ នៅក្នុងនីតិវិធីនៃបណ្តឹងក្រោយពីមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន (មាត្រា ៣៣២ កថាខណ្ឌទី ២) ។ នៅក្នុងករណីទាំងពីរនេះ ដើម្បីទទួលបានការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ កូនបំណុលនៃការអនុវត្ត ចាំបាច់ត្រូវតែដាក់ឯកសារចម្លងយថាភូតនៃសាលក្រម ឬ សាលដីកាលុបចោលទាំងនេះ ដែលបានចូលជាស្ថាពរហើយ ជូនទៅស្ថាប័នអនុវត្ត ព្រោះថា អានុភាពនៃការលុបចោល កើតឡើងនៅពេលដែលសេចក្តីសម្រេចទាំងនេះ ចូលជាស្ថាពរ ។ មិនមានភាពចាំបាច់ដែលត្រូវឱ្យមានរូបមន្តអនុវត្ត ភ្ជាប់ជាមួយនឹងឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលចូលជាស្ថាពរនេះទេ ។

(២) ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលនូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ក វាក្យខណ្ឌទី ២) : ឯកសារនេះ គឺជាឯកសារចម្លងយថាភូតនៃសាលដីកាលុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ផ្លាស់ប្តូរសេចក្តីសម្រេចអង្គសេចក្តីនៅក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រម ឬ សាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ហើយតុលាការនៃបណ្តឹងឧបាស្រ័យ សម្រេចលុបចោលតែការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ផ្លាស់ប្តូរសាលក្រម ឬ សាលដីកាសម្រេចអង្គសេចក្តី (មាត្រា ១៩៧ កថាខណ្ឌទី ១) ។ ដោយសារថា ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នឹងបាត់បង់អានុភាពដោយការប្រកាសសាលដីកាទាំងនេះ ដូច្នេះ នៅក្នុងករណីបែបនេះ គ្រាន់តែដាក់អនុសារសាលដីកាដែលត្រូវបានប្រកាសប៉ុណ្ណោះ ជាការគ្រប់គ្រាន់ហើយ ពោលគឺមិនចាំបាច់ត្រូវដាក់អនុសារសាលដីកាដែលបានចូលជាស្ថាពរទេ ។

(៣) ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ) : ឧទាហរណ៍គំរូនៃឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលជាមូលហេតុនៃការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំនេះ គឺអនុសារសាលក្រមស្ថាពរដែលទទួលស្គាល់បណ្តឹងតវ៉ាចំពោះការទាមទារ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ បណ្តឹងតវ៉ារបស់តតិយជន ហើយដែលប្រកាសថាមិនអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំ ។ ដោយសារថា សាលក្រម ឬ សាលដីកា នឹងមានអានុភាពនៅពេលចូលជាស្ថាពរ (មាត្រា ១៩៣ និង មាត្រា ១៩៤) ដូច្នេះ ឯកសារដែលត្រូវដាក់ ត្រូវតែជា

អនុសារសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរហើយ ។ បន្ថែមពីលើនេះ ឯកសារចម្លងយថាភូតនៃដីកាសម្រេចទទួលស្គាល់ការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤) និង ដីកាសម្រេចទទួលស្គាល់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ (មាត្រា ៣៦២) ដែលប្រកាសថាមិនអនុញ្ញាតឱ្យធ្វើការអនុវត្តដោយបង្ខំក៏អាចចាត់ទុកជាឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ថាមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំនេះបានដែរ ។ ដោយសារថា នេះគឺជាដីកាសម្រេច ដូច្នេះ ដីកាសម្រេចទាំងនេះនឹងមានអានុភាពស្របពេលជាមួយគ្នានឹងការជូនដំណឹង (មាត្រា ២១៣ កថាខណ្ឌទី ១) ។

(៤) អនុសារសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរ ដែលប្រកាសថា ការផ្សះផ្សា ឬ ការទទួលស្គាល់ការទាមទារ ដែលទាក់ទងនឹងលិខិតអនុវត្ត គ្មានអានុភាព (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច គ) : ឯកសារនេះ គឺជាអនុសារសាលក្រម ឬ សាលដីកាស្ថាពរ ដែលទទួលស្គាល់បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃការផ្សះផ្សា ឬ ការទទួលស្គាល់ការទាមទារ នៅក្នុងករណីដែលលិខិតអនុវត្ត គឺជាកំណត់ហេតុស្តីពីការសះជា ឬ ការទទួលស្គាល់ (មាត្រា ២២២) ។

(៥) ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬ ឯកសារផ្សេងទៀតដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថា លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ៣៥០ បាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង ឬ មូលហេតុផ្សេងទៀត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ឃ) : លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ៣៥០ គឺជាសេចក្តីសម្រេច ឬ ការចាត់ចែង ដែលធ្វើឡើងនៅក្នុងខណៈពេលដែលនីតិវិធីបណ្តឹង ឬ នីតិវិធីដាស់តឿនកំពុងត្រូវបានចាត់ការ ។ ប្រសិនបើនីតិវិធីចម្បង ត្រូវបានបញ្ចប់នៅពាក់កណ្តាលទី មុនពេលដែលសាលក្រមចុងក្រោយ ឬ ដីកាសម្រេចដាស់តឿន ចូលជាស្ថាពរ ដោយសារការដកពាក្យបណ្តឹង ឬ ដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ជាដើម លិខិតអនុវត្តទាំងនោះ នឹងបាត់បង់អានុភាព ។ ឯកសារដែលរៀបរាប់នៅក្នុងចំណុចនេះ គឺឯកសារចម្លងយថាភូតនៃកំណត់ហេតុដែលក្រឡាបញ្ជីបានធ្វើដើម្បីបញ្ជាក់អំពីហេតុទាំងអស់នេះឯង ។ ឧទាហរណ៍ ចំពោះករណីដែលមានការដកពាក្យបណ្តឹងនៅក្រោយពេលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលមានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឯកសារចម្លងយថាភូតនៃកំណត់ហេតុដែលក្រឡាបញ្ជីធ្វើឡើងដើម្បីរៀបរាប់អំពីការដកពាក្យបណ្តឹងនេះ (មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក និង មាត្រា ២៧៣) គឺជាឯកសារដែលកំពុងនិយាយនេះហើយ ។

(៦) ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលកំណត់ថា មិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ង) : ប្រសិនបើមានការព្រមព្រៀងអំពីការមិនអនុវត្តដោយបង្ខំ ឬ អំពីការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ នៅក្នុងការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី នោះឯកសារដែលកំពុងនិយាយក្នុងចំណុចនេះ គឺឯកសារចម្លង

យថាភូតនៃកំណត់ហេតុដែលរៀបរាប់អំពីហេតុនេះឯង ( មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក) ។ ការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ ត្រូវបានអនុញ្ញាត ដោយមិនចាំបាច់មានការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដោយផ្អែកលើការព្រមព្រៀងអំពីការមិនអនុវត្តដោយបង្ខំ (សូមមើលជំពូកទី ១ ផ្នែកទី ៣ (កិច្ចសន្យានៃការអនុវត្ត) (ii) (ខ) ខាងលើ) ឬ ដោយមិនចាំបាច់មានការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

(៧) ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ ( មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ច) : ក្នុងករណីដែលមានការប្រកាសភ្ជាប់ទៅនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ថាភាគីអាចរួចផុតពីការអនុវត្តជាបណ្ដោះអាសន្នបាន ប្រសិនបើដាក់ប្រាតិភោគ តាមបញ្ញត្តិនៃមាត្រា ១៩៦ កថាខណ្ឌទី ២ នោះឯកសារដែលកំពុងនិយាយក្នុងចំណុចនេះ គឺឯកសារដែលបញ្ជាក់អំពីការបានដាក់ប្រាតិភោគនោះឯង ។ សូមមើលមាត្រា ៧១ និង មាត្រា ៣៧៧ អំពីវិធីដាក់ប្រាតិភោគ ។

(៨) ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និង លុបចោលការចាត់ចែងការអនុវត្ត ( មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ឆ) : ឯកសារនេះ គឺឯកសារចម្លងយថាភូតនៃដីកាសម្រេច (ការចាត់ចែងមួយរយៈ) ដែលបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និង លុបចោលការចាត់ចែងការអនុវត្ត ដែលបានបញ្ញត្តនៅក្នុងមាត្រា ៣៨៣ កថាខណ្ឌទី ២ ចំណុច ខ, មាត្រា ៣៨៤ កថាខណ្ឌទី ៣, មាត្រា ៣៦៦ កថាខណ្ឌទី ២ និង ទី ៣ និង មាត្រា ៣៦៧ កថាខណ្ឌទី ២ និង ទី ៣ ។ ជាងនេះទៅទៀត ឯកសារដែលកំពុងនិយាយក្នុងចំណុចនេះ ក៏រួមបញ្ចូលផងដែរ នូវអនុសារសាលក្រម ឬ សាលដីកាចុងក្រោយ ដែលសម្រេចសេចក្ដីផ្អាក និង លុបចោលការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា ៣៦៨ ។ ការសម្រេចសេចក្ដីនេះ ត្រូវបានធ្វើឡើងនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ក៏ប៉ុន្តែ វាមានអានុភាពចាប់ពីពេលប្រកាសសាលក្រម ឬ សាលដីកានោះ ។ ហេតុនេះហើយ គេមិនចាំបាច់រង់ចាំរហូតដល់ពេលសាលក្រម ឬ សាលដីកានោះចូលជាស្ថាពរទេ (សូមមើលជំពូកទី ២ ផ្នែកទី ៤ កថាភាគទី ២ **៣.** (បណ្ដឹងតវ៉ាចំពោះការទាមទារ) (iv) (៣) ខាងលើ) ។

## ៤. មូលហេតុនៃការផ្អាកការអនុវត្តដោយបង្ខំ

ការគ្រាន់តែនិយាយថា "ផ្អាកការអនុវត្តដោយបង្ខំ" សំដៅទៅលើស្ថានភាពដែលស្ថាប័នអនុវត្ត មិនអាចចាប់ផ្ដើម ឬ បន្តការអនុវត្តដោយបង្ខំ តាមច្បាប់បាន ដោយមិនមានការលុបចោលនូវការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយទេ ។ គេក៏អាចហៅថា ជាការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ផងដែរ ។ ការផ្អាកការអនុវត្តដោយបង្ខំ កើតឡើងនៅពេលដែលកូនបំណុលនៃការអនុវត្ត ឬ តតិយជន ដាក់ឯកសារជាលាយលក្ខណ៍អក្សរដែលកំណត់ក្នុងចំណុចទី (១) ឬ ទី (២) ខាងក្រោម ជូនទៅស្ថាប័នអនុវត្ត ( មាត្រា ៣៧០ កថាខណ្ឌទី ២) ។

(១) ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយ

រយៈ ( មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ក) ៖ ឯកសារដែលស្ថិតក្នុងប្រភេទនេះ រួមមាន ឯកសារចម្លងយថាភូតនៃដីកាសម្រេចដែលបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ដែលបានចែងក្នុងមាត្រា ៣៤៣ កថាខណ្ឌទី ២ ចំណុច ក, មាត្រា ៣៤៤ កថាខណ្ឌទី ៣, មាត្រា ៣៦៦ កថាខណ្ឌទី ១, មាត្រា ៣៦៧ កថាខណ្ឌទី ១ និង មាត្រា ៣៦៩ ។ បន្ថែមពីលើនេះ អនុសារសាលក្រម ឬ សាលដីកាចុងក្រោយដែលមានសេចក្តីសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ ឬ ទទួលស្គាល់ការចាត់ចែងមួយរយៈដែលបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ ដែលបានធ្វើឡើងហើយ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៦៨ ក៏ត្រូវចាត់ទុកជាឯកសារដែលកំពុងនិយាយនេះដែរ ។ ដោយសារថា សេចក្តីសម្រេចទាំងនេះ នឹងមានអានុភាពនៅពេលប្រកាស ដូច្នេះ កូនបំណុលនៃការអនុវត្ត ជាអាទិ៍ អាចទទួលបានការផ្អាកការអនុវត្តដោយបង្ខំ នៅមុនពេលសាលក្រម ឬ សាលដីកាចុងក្រោយនោះចូលជាស្ថាពរ ដោយគ្រាន់តែដាក់អនុសារសាលក្រម ឬ សាលដីកាចុងក្រោយដែលត្រូវបានប្រកាសនោះ ជូនទៅស្ថាប័នអនុវត្ត ប៉ុណ្ណោះ (សូមមើលផ្នែកទី ៤ កថាភាគទី ២ **៣.** (បណ្តឹងតវ៉ាចំពោះការទាមទារ) (iv) (៣) ខាងលើ) ។

(២) ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត ( មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ខ) ៖ នៅក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មិនព្រមដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ បើទោះបីជាខ្លួនបានទទួលការសង ឬ បានយល់ព្រមពន្យារពេលត្រូវសងក៏ដោយ នោះជាវិធីមូលដ្ឋានដើម្បីគេចផុតពីការអនុវត្តដោយបង្ខំ កូនបំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដោយអះអាងអំពីការបានសងប្រាក់ ឬ ការពន្យារពេលត្រូវសង និង សុំឱ្យផ្អាកនិងលុបចោលការអនុវត្តដោយបង្ខំ ( មាត្រា ៣៦៣ និង មាត្រា ៣៦៧ កថាខណ្ឌទី ១ និង ទី ២) ។ ក៏ប៉ុន្តែ ដោយសារថាវិធីនេះ ត្រូវប្រើពេលយូរ ដូច្នេះ ដើម្បីផ្តល់ការការពារដោយងាយស្រួល និងឆាប់រហ័សឱ្យដល់កូនបំណុលនៃការអនុវត្ត ទើបមានការកំណត់ថា ប្រសិនបើមានបង្កាន់ដៃបង់ប្រាក់ជាលាយលក្ខណ៍អក្សរ ឬ លិខិតយល់ព្រមពន្យារពេលត្រូវសងជាលាយលក្ខណ៍អក្សរ ដែលត្រូវបានធ្វើដោយម្ចាស់បំណុលនៃការអនុវត្ត នោះកូនបំណុលនៃការអនុវត្ត អាចទទួលបានការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ដោយដាក់ឯកសារនោះបាន ។ ប៉ុន្តែ វាជាការសមរម្យហើយ ដែលការផ្អាកដោយផ្អែកលើឯកសារទាំងនេះ មានលក្ខណៈបណ្តោះអាសន្ន រហូតដល់ពេលដែលពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ត្រូវបានដាក់ ហើយបើក្នុងករណីនៃការពន្យារពេលត្រូវសងវិញ ចាំបាច់ត្រូវទទួលស្គាល់លទ្ធភាពនៃដំណើរការនៃការអនុវត្តដោយបង្ខំ នៅក្រោយពេលដែលការពន្យារពេលនោះ កន្លងផុតទៅ ហេតុនេះហើយបានជាអានុភាពនៃការផ្អាក ត្រូវបានកម្រិតត្រឹមតែពីរខែ ប៉ុណ្ណោះ ( មាត្រា ៣៧០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

### ៥. ការចាត់ចែងផ្អាកការអនុវត្តដោយបង្ខំ

(១) ការផ្អាកការអនុវត្តដោយបង្ខំ ត្រូវសម្រេចដោយសកម្មភាពរបស់ស្ថាប័នអនុវត្ត ។ ការផ្អាក មិនមែន

អាចទទួលបានដោយគ្រាន់តែមានសេចក្តីសម្រេច ជាអាទិ៍ ដែលជាមូលហេតុនៃការផ្អាកនោះទេ ។ ដើម្បីអាចទទួលបានស្ថានភាពពិតនៃការផ្អាកការអនុវត្តដោយបង្ខំ កូនបំណុលនៃការអនុវត្ត ឬ តតិយជន ចាំបាច់ត្រូវដាក់ឯកសារដូចបានរៀបរាប់ខាងលើ ជូនទៅស្ថាប័នអនុវត្ត ។ ក្នុងករណីដែលស្ថាប័នអនុវត្ត មិនព្រមផ្អាកការអនុវត្តដោយបង្ខំ បើទោះបីជាឯកសារនោះត្រូវបានដាក់ ហើយល័ក្ខខ័ណ្ឌទាមទារសម្រាប់ការផ្អាកក៏ត្រូវបានបំពេញហើយក៏ដោយនោះ បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចធ្វើឧបាស្រ័យទៅនឹងការចាត់ចែងនោះតាមរយៈការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤ កថាខណ្ឌទី ១ និង ទី ២) បាន ។

(២) អ្វីដែលស្ថាប័នអនុវត្តត្រូវធ្វើដើម្បីផ្អាកការអនុវត្តដោយបង្ខំ ប្រែប្រួលទៅតាមកាលៈទេសៈនីមួយៗ ។ នៅក្នុងករណីខ្លះ ជាការអនុវត្តជាក់ស្តែង មិនចាំបាច់មាននីតិវិធីអ្វីវែងឆ្ងាយទៀតទេ ។ ក៏ប៉ុន្តែ ក្នុងករណីខ្លះទៀត ជាពិសេសក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំរបស់តុលាការអនុវត្ត ពេលខ្លះចាំបាច់ត្រូវមានសេចក្តីសម្រេចបង្អាក់ដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលកំពុងដើរទៅមុខ ។ ឧទាហរណ៍ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ប្រសិនបើឯកសារពាក់ព័ន្ធនឹងការផ្អាកការអនុវត្ត ត្រូវបានដាក់ នៅក្រោយពេលដែលតុលាការបានកំណត់កាលបរិច្ឆេទនៃការលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់រួចហើយ (មាត្រា ៤៣៦ កថាខណ្ឌទី ១ និង ទី ៣) នោះចាំបាច់ត្រូវចេញដីកាសម្រេចលុបចោលការកំណត់កាលបរិច្ឆេទនោះវិញ ។ ប៉ុន្តែ ការជម្រះចោលនូវការចាត់ចែងការអនុវត្តណាមួយដែលធ្លាប់មានអានុភាពម្តងរួចហើយនោះ គឺជាការលុបចោលការអនុវត្តដោយបង្ខំ ពោលគឺមិនមែនជាការផ្អាកទេ ។

(៣) ប្រសិនបើមានមូលហេតុនៃការផ្អាកការអនុវត្តដោយបង្ខំ នៅមុនពេលចាប់ផ្តើមការអនុវត្ត ស្ថាប័នអនុវត្តមិនអាចចាប់ផ្តើមការអនុវត្តនោះបានទេ ។ នៅក្រោយពេលបញ្ចប់ការអនុវត្តដោយបង្ខំ ពុំមានការផ្អាកការអនុវត្តទៀតទេ ។

## ៦. ការចាត់ចែងលុបចោលការអនុវត្តដោយបង្ខំ

(១) ជាធម្មតា ការលុបចោលការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងតាមវិធីដែលស្ថាប័នអនុវត្ត រំលត់នូវអត្ថិភាពនៃការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ។ ឧទាហរណ៍ ប្រសិនបើអាជ្ញាសាលាលុបចោលការរឹបអូស នោះមានន័យថា អាជ្ញាសាលាប្រគល់វត្ថុដែលត្រូវបានរឹបអូស ទៅកូនបំណុលនៃការអនុវត្តវិញ ឬដកស្លាកសញ្ញានៃការរឹបអូសចេញពីវត្ថុនោះ (សូមមើលមាត្រា ៣៨៥ កថាខណ្ឌទី ១ និង ទី ៤) ។ ក្នុងករណីដែលតុលាការអនុវត្តគឺជាស្ថាប័នអនុវត្ត នោះត្រូវចេញសេចក្តីសម្រេចលុបចោលសេចក្តីសម្រេចដែលបានធ្វើរួចហើយ ។ ឧទាហរណ៍ ដើម្បីលុបចោលនីតិវិធីនៃការលក់ដោយបង្ខំនូវអចលនវត្ថុ ត្រូវមានដីកាសម្រេចលុបចោលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ (មាត្រា ៤១៩) ។

(២) ចំពោះដីកាសម្រេចលុបចោលការអនុវត្តដោយបង្ខំ ដោយផ្អែកលើការដាក់ឯកសារដែលលុបចោលការអនុវត្ត មិនអាចប្តឹងជំទាស់បានទេ (សូមមើលមាត្រា ៣៧០ កថាខណ្ឌទី ៣ និង មាត្រា ៣៨៥ កថាខណ្ឌទី

១ ចំណុច ក) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះវាពុំមានភាពចាំបាច់អ្វីដែលគួរអនុញ្ញាតឱ្យភាគី ធ្វើឧបាស្រ័យទេ ដោយសារថាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចេញដីកាសម្រេចលុបចោល មានភាពច្បាស់លាស់ទៅហើយ ។

## ៧. អានុភាពនៃការលុបចោលការអនុវត្តដោយបង្ខំ

ការចាត់ចែងលុបចោលការអនុវត្តដោយបង្ខំ រំលត់នូវអានុភាពនៃការចាត់ចែងការអនុវត្ត ឬ នៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ប៉ុន្តែ អានុភាពដែលបានកើតឡើងហើយដោយផ្អែកលើការចាត់ចែងការអនុវត្ត នាពេលដែលការចាត់ចែងនោះមានសុពលភាព ពុំរលត់ដោយប្រតិសកម្មដោយសារការលុបចោលទេ ។ ឧទាហរណ៍ ទោះបីជាដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានលុបចោល នៅក្រោយពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរក៏ដោយ ក៏ហេតុនេះមិនមានឥទ្ធិពលទៅលើអានុភាពនៃការលក់ដែរ ។ នីតិវិធីនៃការអនុវត្ត ឬ ការចាត់ចែងការអនុវត្ត នឹងត្រូវបញ្ចប់ដោយសារការលុបចោល ។ ចំណុចនេះ ក៏ដូចគ្នាផងដែរនៅក្នុងករណីដែលការលុបចោលត្រូវបានបង្គាប់តាមរយៈការចាត់ចែងមួយរយៈ ។ ហេតុនេះហើយ ក្នុងករណីដែលមូលហេតុនៃការផ្អាក ឬ ការលុបចោល បានបាត់បង់ទៅ ចាំបាច់ត្រូវចាប់ផ្តើមការអនុវត្តដោយបង្ខំសាជាថ្មីម្តងទៀត ។

# ផ្នែកទី ៧ សោហ៊ុយសម្រាប់ការអនុវត្ត ការដាក់ធ្មានាគារ និង ការផ្ញើ

## កថាភាគទី ១ សោហ៊ុយសម្រាប់ការអនុវត្ត

(១) គោលគំនិត : សោហ៊ុយសម្រាប់ការអនុវត្ត មានន័យថាជាការចំណាយរបស់ស្ថាប័នអនុវត្ត និង ភាគីដែលជាសេចក្តីត្រូវការ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ។ ការចំណាយនេះ ខុសគ្នាពីប្រាក់ប្រដាប់ក្តីក្នុងន័យចង្អៀត ពោលគឺការចំណាយលើនីតិវិធីបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬ សាលដីកាដែលជាលិខិតអនុវត្ត ចំពោះខ្លឹមសារ អ្នកទទួលបន្ទុក វិធីប្រមូល ជាដើម ។ សូមកត់សំគាល់ថា ចំណាយទៅលើការបញ្ជូនលិខិតអនុវត្ត ជាអាទិ៍ ដែលជាការត្រៀមរៀបចំការចាប់ផ្តើមការអនុវត្តដោយបង្ខំ គឺជាសោហ៊ុយសម្រាប់ការអនុវត្ត (មាត្រា ៣៧៣) ។ ចំណាយចាំបាច់សម្រាប់ធ្វើការអនុវត្តដោយបង្ខំ រួមមាន ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (មាត្រា ៣៧២), ប្រាក់កម្រៃសម្រាប់អាជ្ញាសាលា (មាត្រា ២១ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា), ចំណាយដែលស្ថាប័នអនុវត្តត្រូវបង់ ដូចជាថ្លៃសម្រាប់ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស, ចំណាយសម្រាប់ការជូនដំណឹង និង ការប្រកាសជាសាធារណៈ, ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង ប្រាក់កម្រៃសម្រាប់អ្នកវាយតម្លៃអចលនវត្ថុ ជាអាទិ៍ ក៏ដូចជាថ្លៃធ្វើឯកសារនានារបស់ភាគី និង ចំណាយសម្រាប់អ្នកសង្កេតការណ៍ចំពោះការអនុវត្ត (មាត្រា ៣៧៤) ។ ចំពោះការចំណាយលើការតវ៉ា បណ្តឹងជំទាស់បណ្តឹងផ្សេងៗ ជាអាទិ៍ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តដោយបង្ខំវិញ ចំណែកនៃការចំណាយទាំងនេះ ត្រូវ

កំណត់ដោយសាលក្រម ឬ ដីកាសម្រេចចុងក្រោយ ថាជាចំណាយសម្រាប់នីតិវិធីឯករាជ្យ ។ ហេតុនេះហើយ ចំណាយទាំងនេះ មិនត្រូវបានរាប់ជាសោហ៊ុយសម្រាប់ការអនុវត្តទេ ។

(២) ការបង់សោហ៊ុយ ការទទួលបន្ទុក និង ការប្រមូល : (ក) ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់សោហ៊ុយសម្រាប់ការអនុវត្តជាមុន ពោលគឺត្រូវបង់ជាមុន នូវចំណាយដែលត្រូវចាយដោយស្ថាប័នអនុវត្ត ។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត មិនបង់សោហ៊ុយជាមុនទេ នោះមិនអាចសុំឱ្យធ្វើការអនុវត្តដោយបង្ខំបានឡើយ (មាត្រា ៣៧៥) ។

(ខ) ក៏ប៉ុន្តែ ចំណាយដែលម្ចាស់បំណុលនៃការអនុវត្តបានបង់ ឱ្យតែវាជាចំណាយចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ នៅទីបញ្ចប់ វានឹងក្លាយជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត (មាត្រា ៣៧៦ កថាខណ្ឌ ទី ១) ។ ហេតុនេះហើយ ម្ចាស់បំណុលនៃការអនុវត្ត នឹងទទួលបានសំណងត្រឹមកម្រិតនៃចំណាយចាំបាច់នោះវិញ ។

(គ) ដើម្បីទទួលការសងសោហ៊ុយសម្រាប់ការអនុវត្ត ក្នុងករណីនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ឬ សិទ្ធិប្រាតិភោគ នោះគេអាចអនុវត្តដោយបង្ខំចំពោះសោហ៊ុយនោះ ព្រមគ្នាក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិនោះបាន ដោយពុំចាំបាច់មានលិខិតអនុវត្តទេ (មាត្រា ៣៧៦ កថាខណ្ឌទី ២) ។ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ដោយយកមាត្រា ៦៦ មកអនុវត្តដូចគ្នា ក្រឡាបញ្ជីនៃតុលាការអនុវត្ត ឬ នៃសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវធ្វើការកំណត់ចំនួនសោហ៊ុយសម្រាប់ការអនុវត្ត ហើយការចាត់ចែងរបស់ក្រឡាបញ្ជីនោះ ក្លាយទៅជាលិខិតអនុវត្ត ។

(៣) ការសងវិញ នូវប្រាក់ចំណាយដែលបានប្រមូល : ក្នុងករណីដែលសាលក្រម ជាអាទិ៍ ដែលជាលិខិតអនុវត្ត ត្រូវបានលុបចោល ឬ បដិសេធចោល ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសងទៅកូនបំណុលនៃការអនុវត្តវិញ នូវសោហ៊ុយដែលបានប្រមូលរួចហើយ ដោយផ្អែកលើសេចក្ដីសម្រេចនោះ ។ ឧទាហរណ៍ដូចជាករណីដែលសាលក្រមដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវបានលុបចោល ដោយការជំនុំជម្រះលើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង ករណីដែលសាលក្រមស្ថាពរ ត្រូវបានលុបចោលដោយការជំនុំជម្រះសាជាថ្មី ។ ដោយសារថា ការដកចេញនូវការអនុវត្តដោយបង្ខំ តាមរយៈបណ្ដឹងតវ៉ាចំពោះការទាមទារ មិនមែនជាការលុបចោលដោយប្រតិសកម្មនូវលិខិតអនុវត្តទេនោះ ការណ៍នេះ មិនស្ថិតនៅក្នុងករណីដូចបានរៀបរាប់ខាងលើឡើយ ។ សោហ៊ុយសម្រាប់ការអនុវត្តដែលត្រូវសងវិញ រួមមានការចំណាយដែលកូនបំណុលនៃការអនុវត្តបានបង់ (ឧទាហរណ៍ ការចំណាយលើអ្នកសង្កេតការណ៍ ការចំណាយលើការដាក់ពាក្យសុំឱ្យផ្អាកការអនុវត្តដោយបង្ខំ ជាអាទិ៍) ។ ចំពោះវិធីនៃការទាមទារឱ្យសងវិញ កូនបំណុលនៃការអនុវត្ត អាចទាមទារឱ្យក្រឡាបញ្ជីនៃតុលាការអនុវត្ត ឬ នៃសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅធ្វើការកំណត់ជាស្ថាពរនូវចំនួនទឹកប្រាក់នៃសោហ៊ុយនោះ ដោយផ្អែកលើសេចក្ដីសម្រេចលុបចោលលិខិតអនុវត្ត

(យកមាត្រា ៦៦ មកអនុវត្តដូចគ្នា) ហើយទើបយកការចាត់ចែងរបស់ក្រឡាបញ្ជីនោះ ទៅអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ង) ។

## កថាភាគទី ២ ការដាក់ប្រាតិភោគ និង ការផ្ញើ

(១) ការដាក់ប្រាតិភោគ : នៅក្នុងករណីខ្លះ ការដាក់ប្រាតិភោគដោយកូនបំណុលនៃការអនុវត្ត គឺជាល័ក្ខខ័ណ្ឌសម្រាប់ការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ (មាត្រា ៣៤៣ កថាខណ្ឌទី ២ ចំណុច ខ, មាត្រា ៣៦៦ កថាខណ្ឌទី ១ និង ទី ២, មាត្រា ៣៦៧ កថាខណ្ឌទី ១ និង ទី ២, មាត្រា ៣៦៨ និង មាត្រា ៣៦៩) ។ នៅក្នុងករណីខ្លះទៀត ការដាក់ប្រាតិភោគដោយម្ចាស់បំណុលនៃការអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្ដើមការអនុវត្តដោយបង្ខំ (មាត្រា ៣៦១ កថាខណ្ឌទី ២) ។

ប្រាតិភោគនៅទីនេះ ត្រូវដាក់ដោយភាគី ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្ត តាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ (មាត្រា ៣៧៧) ។

(២) ការផ្ញើ : នីតិវិធីនៃការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ទៅតុលាការ ដែលជាវិធីដាក់ប្រាតិភោគត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីនៃការផ្ញើតាមផ្លូវតុលាការ ។ នៅក្នុងជំពូកទី ១ (បទប្បញ្ញត្តិទូទៅ) នៃប្រកាស មានការចែងថា កិច្ចការទាក់ទងទៅនឹងការផ្ញើ ត្រូវបំពេញដោយក្រឡាបញ្ជីដែលត្រូវបានត្រូវចាត់តាំងដោយប្រធានតុលាការដែលត្រូវទទួលការផ្ញើនេះ (មាត្រា ២) ។ ក្នុងជំពូកនេះក៏មានចែងអំពីពេលដែលការចាត់ចែងរបស់ក្រឡាបញ្ជីពាក់ព័ន្ធទៅនឹងការផ្ញើ បង្កើតអានុភាព ព្រមទាំងវិធីឧបាស្រ័យ (មាត្រា ៣), សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្ដឹង (មាត្រា ៤) ផងដែរ ។ ក្រៅពីនេះ ក៏មានការចែងអំពីនីតិវិធីនៃការផ្ញើវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ នៅក្នុងជំពូកទី ២ និង នីតិវិធីនៃការប្រគល់នូវវត្ថុផ្ញើ នៅក្នុងជំពូកទី ៣ ផងដែរ ។

## ជំពូកទី ៣ ប្រភេទផ្សេងៗនៃការអនុវត្តដោយបង្ខំ

## ផ្នែកទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់

### កថាភាគទី ១ សេចក្តីពន្យល់ទូទៅ

**១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់**

(១) ក្នុងចំណោមការអនុវត្តដោយបង្ខំជាច្រើនប្រភេទ ការអនុវត្តដើម្បីប្រមូលប្រាក់ដោយបង្ខំ ពីទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហៅថា ការអនុវត្តចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ។ ដោយសារថា សិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ គឺជាសិទ្ធិដ៏សំខាន់នៅក្នុងជីវភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ក៏ជាករណីនៃការអនុវត្តដោយបង្ខំដែលមានចំនួនច្រើនជាងគេដែរ ។ ទ្រព្យសម្បត្តិដែលអាចក្លាយទៅជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហៅថា ទ្រព្យសម្បត្តិទទួលខុសត្រូវ ។ ទ្រព្យសម្បត្តិទទួលខុសត្រូវ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត ។ ក៏ប៉ុន្តែ ដូចនឹងរៀបរាប់ខាងក្រោម មានចលនវត្ថុ និង សិទ្ធិលើបំណុលមួយចំនួន ត្រូវបានផាត់ចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវ ។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ មានលក្ខណៈខុសគ្នាពីមួយទៅមួយ អាស្រ័យទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តនោះ ឧទាហរណ៍ វិធីនៃការរឹបអូស ខុសគ្នាពីមួយទៅមួយ អាស្រ័យទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលត្រូវរឹបអូស ។ អាស្រ័យហេតុនេះហើយទើបនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានបញ្ញត្តិដាច់ដោយឡែកពីគ្នា អាស្រ័យទៅតាមប្រភេទនៃទ្រព្យសម្បត្តិ រវាងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តដោយបង្ខំចំពោះនាវា ។

(២) ម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច ដោយកំណត់ទៅតាមប្រភេទនៃទ្រព្យសម្បត្តិ ។ ហេតុនេះហើយ ម្ចាស់បំណុល ចាំបាច់ត្រូវជ្រើសរើសទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត និង ត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅស្ថាប័នអនុវត្តដែលសមស្របទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលបានជ្រើសរើសនោះ ។ នេះមានន័យថា ស្ថាប័នអនុវត្ត មិនធ្វើការជ្រើសរើសទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីធ្វើការអនុវត្ត ដោយឆន្ទានុសិទ្ធិរបស់ខ្លួនទេ ។ ស្ថាប័នអនុវត្តជាក់លាក់ដែលម្ចាស់បំណុលត្រូវដាក់ពាក្យសុំ គឺអាជ្ញាសាលា ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (មាត្រា ៣៨៤ កថាខណ្ឌទី ១) ឬ តុលាការអនុវត្ត ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល (មាត្រា ៤០៣ កថាខណ្ឌទី ១) ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា ៤១៨) និង ការអនុវត្ត

ដោយបង្ខំចំពោះនាវា (មាត្រា ៨៥៥ កថាខណ្ឌទី ១) ។ ក្នុងចំណោមទ្រព្យសម្បត្តិរបស់កូនបំណុល ដោយសារពុំមានបញ្ញត្តិច្បាប់បញ្ជាក់លំដាប់លំដោយថា តើទ្រព្យសម្បត្តិប្រភេទណាត្រូវទទួលការអនុវត្តមុន នោះ ដូច្នេះ ម្ចាស់បំណុលនៃការអនុវត្ត អាចធ្វើការជ្រើសរើសយកទ្រព្យសម្បត្តិណាមកអនុវត្តដោយសេរីបាន ។

## ២. ភាពជាន់គ្នានៃការអនុវត្តដោយបង្ខំឱ្យសងជាប្រាក់

(១) ក្នុងករណីដែលអ្នកមានសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ទៅលើកូនបំណុលតែមួយ មានច្រើននាក់ នោះវាអាចនឹងកើតហេតុដែលថាការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណង ឱ្យសងជាប្រាក់នោះ ត្រូវបានធ្វើឡើងដោយជាន់គ្នា ទៅលើទ្រព្យសម្បត្តិដូចគ្នា ។ នៅក្នុងករណីបែបនេះ ប្រសិនបើប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិនោះ មិនគ្រប់គ្រាន់ដើម្បីសងបំណុលទាំងអស់ទេ នោះនឹង ធ្វើឱ្យបុគ្គលម្នាក់ ឬ ច្រើននាក់ មិនអាចទទួលការសម្រេចសិទ្ធិយ៉ាងពេញលេញបាន ។ ហេតុនេះហើយ អ្វីដែលជាបញ្ហានៅក្នុងករណីបែបនេះ គឺវិធីបែងចែកប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិនោះ ។ ក៏ប៉ុន្តែ ពុំមានកត្តាប្រាកដប្រជាណាមួយ សម្រាប់បង្កើតវិធីបែងចែកនេះទេ ។ ដូច្នេះ បញ្ហានេះ ជាបញ្ហាដែល ត្រូវឆ្លើយតបតាមគោលនយោបាយនីតិកម្មនៃប្រទេសនីមួយៗ ដែលមានច្បាប់ខុសៗគ្នា ។

(២) ជំហានទីមួយ គឺការផ្តល់អាទិភាពទៅឱ្យម្ចាស់បំណុលដែលផ្តួចផ្តើមការអនុវត្តដោយបង្ខំ មុនគេ ។ គោលការណ៍នេះ ហៅថា គោលការណ៍សិទ្ធិអាទិភាព ។ គោលការណ៍សិទ្ធិអាទិភាពនេះ ត្រូវបានទទួលយក ដោយច្បាប់អាល្លឺម៉ង់ ច្បាប់អូទ្រីស ច្បាប់អាមេរិក និង ច្បាប់អង់គ្លេស ជាអាទិ៍ ។ ជំហានទីពីរ គឺការផ្តល់ភាព ស្មើគ្នា ឱ្យដល់ម្ចាស់បំណុលទាំងអស់ដែលបានចូលរួមរហូតដល់ដំណាក់កាលចុងក្រោយនៃការអនុវត្តដោយបង្ខំ ហើយបែងចែកប្រាក់ដែលបានពីការលក់ ទៅតាមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗ ។ គោលការណ៍នេះ ហៅថា គោលការណ៍សមភាព ។ គោលការណ៍សមភាពនេះ ត្រូវបានទទួលយកដោយច្បាប់បារាំង និង ច្បាប់ ជប៉ុន ជាអាទិ៍ ។ ជំហានទីបី គឺការចាត់ម្ចាស់បំណុលនានាដែលបានចូលរួមក្នុងការអនុវត្តដោយបង្ខំ នាដំណាក់ កាលណាមួយដែលច្បាប់បានកំណត់ ចូលជាក្រុមមួយ ហើយម្ចាស់បំណុលនីមួយៗនៅក្នុងក្រុមនេះ នឹងត្រូវបាន ផ្តល់ឱ្យនូវភាពស្មើគ្នា ។ ម៉្យាងទៀត ម្ចាស់បំណុលនៃក្រុមនេះ មានអាទិភាពលើម្ចាស់បំណុលនៃក្រុមដទៃទៀត ដែលចូលរួមក្នុងការអនុវត្តដោយបង្ខំ នាពេលក្រោយមក ហើយម្ចាស់បំណុលនៃក្រុមក្រោយនេះ ក៏ទទួលបាន នូវសិទ្ធិស្មើគ្នាដែរ ។ នេះមានន័យថា សិទ្ធិអាទិភាព ត្រូវបានទទួលស្គាល់ជាក្រុម ។ គោលការណ៍នេះ ហៅថា គោលការណ៍សិទ្ធិអាទិភាពជាក្រុម ។ គោលការណ៍សិទ្ធិអាទិភាពជាក្រុមនេះ ត្រូវបានទទួលយកដោយច្បាប់ ស្វីស ជាអាទិ៍ ។

(៣) គុណសម្បត្តិនៃគោលការណ៍សិទ្ធិអាទិភាព មានដូចតទៅ : (ក) ការផ្តល់ផលប្រយោជន៍ទៅឱ្យ ម្ចាស់បំណុលដែលឧស្សាហ៍ព្យាយាម គឺជាភាពយុត្តិធម៌, (ខ) គោលការណ៍សិទ្ធិអាទិភាព មានរចនាសម្ព័ន្ធនៃ នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលងាយស្រួល និង ធ្វើឱ្យគេអាចដោះស្រាយបញ្ហាបានឆាប់រហ័ស, (គ)

គោលការណ៍សិទ្ធិអាទិភាព ធ្វើឱ្យគេអាចទប់ស្កាត់ការរឹបអូសបហួសប្រមាណ ដែលនេះគឺជាការការពារកូនបំណុលនៃការអនុវត្ត ជាអាទិ៍ ។ ដោយឡែក គុណសម្បត្តិនៃគោលការណ៍សមភាព មានដូចតទៅ : (ក) គោលការណ៍នេះ មានភាពស្របគ្នាទៅនឹងគោលការណ៍សមភាពរវាងម្ចាស់បំណុល នៅក្នុងច្បាប់សារធាតុ, (ខ) គោលការណ៍នេះ មានលក្ខណៈល្អប្រសើរសម្រាប់កូនបំណុល ព្រោះថា ម្ចាស់បំណុល ពុំចាំបាច់ត្រូវប្រញាប់ប្រញាល់ក្នុងការផ្តួចផ្តើមការអនុវត្តដោយបង្ខំនោះទេ, (គ) ប្រសិនបើជ្រើសយកគោលការណ៍សិទ្ធិអាទិភាព នោះស្ថាប័នហិរញ្ញវត្ថុ ជាអាទិ៍ នឹងមិនប៉ានផ្តល់ឥណទានរយៈពេលវែងទេ ព្រោះពួកគេខ្លាចថាម្ចាស់បំណុលដទៃទៀត ធ្វើសកម្មភាពបានមុន នៅពេលដែលស្ថានភាពរបស់កូនបំណុលមានភាពយ៉ាប់យ៉ឺន ជាអាទិ៍ ។ ដូចបានពន្យល់មកនេះ ទាំងគោលការណ៍សិទ្ធិអាទិភាព និង គោលការណ៍សមភាព សុទ្ធតែមានគុណសម្បត្តិ និង គុណវិបត្តិដូចគ្នា ។ មួយវិញទៀត គោលការណ៍សិទ្ធិអាទិភាពជាក្រុម ក៏ត្រូវបានគេរិះគន់ផងដែរ ថាធ្វើឱ្យការអនុវត្តដោយបង្ខំ មានភាពយឺតយ៉ាវ ។

(៤) ជាចុងក្រោយ ច្បាប់កម្ពុជា ជ្រើសរើសយកគោលការណ៍សមភាព ដូចច្បាប់បារាំង និង ច្បាប់ជប៉ុនដែរ សម្រាប់ករណីដែលមានភាពជាន់គ្នានៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ។

## ៣. លំហូរនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

(១) ការរឹបអូស : ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ចាប់ផ្តើមចេញពីការរឹបអូសទ្រព្យដែលជាកម្មវត្ថុនៃការអនុវត្តនោះ ។ ការរឹបអូស គឺជាសកម្មភាពនៃការប្រើអំណាចទុកដាក់ទ្រព្យសម្បត្តិជាក់លាក់ណាមួយ ទៅក្នុងស្ថានភាពដែលមានចំណង ដើម្បីធានាទ្រព្យនោះ ទុកជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ។ និយាយម្យ៉ាងទៀត ការរឹបអូស គឺជាការហាមឃាត់ដោយស្ថាប័នអនុវត្តនូវការចាត់ចែងជាក់ស្តែង និង តាមផ្លូវច្បាប់ របស់កូនបំណុល ទៅលើទ្រព្យសម្បត្តិជាក់លាក់ណាមួយ ។ វិធានការនៃការរឹបអូស ប្រែប្រួលទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលត្រូវរឹបអូស ។ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការរឹបអូស ត្រូវធ្វើឡើងដោយការកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលា ដែលនេះគឺជាការចាត់ចែងដែលមានលក្ខណៈជាក់ស្តែង (មាត្រា ៣៨៤ កថាខណ្ឌទី ៣) ។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តដោយបង្ខំចំពោះនាវា ការរឹបអូស ត្រូវធ្វើឡើងដោយការចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ របស់តុលាការអនុវត្ត ដែលនេះគឺជាការចាត់ចែងដែលមានលក្ខណៈជាទស្សនទាន (មាត្រា ៤១៩ កថាខណ្ឌទី ១ និង មាត្រា ៤៥៧ កថាខណ្ឌទី ១) ។ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលវិញ ការរឹបអូស ត្រូវធ្វើឡើងដោយការចេញដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត ដែលនេះ ក៏ជាការចាត់ចែងដែលមានលក្ខណៈជាទស្សនទានដែរ (មាត្រា ៤០៣ កថាខណ្ឌទី ៤) ។

(២) ការប្តូរជាប្រាក់ : លើកលែងតែករណីដែលវត្ថុដែលត្រូវបានរឹបអូសគឺជាប្រាក់ វត្ថុក្រៅពីនោះ ចាំបាច់ត្រូវតែប្តូរទៅជាប្រាក់ ។ ជាទូទៅ វិធីប្តូរជាប្រាក់ គឺការលក់ ។ ក៏ប៉ុន្តែ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល វិធីប្តូរជាប្រាក់ គឺការប្រមូលបំណុលដោយម្ចាស់បំណុល ។

(៣) ការចែកចំណែក : ដំណាក់កាលចុងក្រោយនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ គឺការចែកចំណែកទៅឱ្យម្ចាស់បំណុល ដែលតាមរយៈការចែកចំណែកនេះ សិទ្ធិទាមទាររបស់ម្ចាស់បំណុល ត្រូវបានសម្រេច ។ ប្រាក់ដែលយកមកចែកចំណែក គឺប្រាក់ដែលបានមកពីការលក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលបានរឹបអូស នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តដោយបង្ខំចំពោះនាវា ។ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលវិញ ប្រាក់ដែលយកមកចែកចំណែក គឺប្រាក់ដែលម្ចាស់បំណុលប្រមូលបានពីកូនបំណុលទី ៣ ។

## ៤. អានុភាពនៃការរឹបអូស

(១) នៅពេលធ្វើការរឹបអូស កូនបំណុលនឹងបាត់បង់សិទ្ធិចាត់ចែងលើទ្រព្យដែលត្រូវបានរឹបអូស ហើយអាជ្ញាធររដ្ឋទទួលបានសិទ្ធិចាត់ចែងនោះ ។ ការចាត់ចែងរបស់កូនបំណុលទៅលើទ្រព្យដែលត្រូវបានរឹបអូសនោះពុំមានសុពលភាពទេ ។ ប៉ុន្តែ អានុភាពនៃការរឹបអូសនេះ កើតឡើងតែនៅក្នុងទំនាក់ទំនងទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ ហើយការចាត់ចែងលើទ្រព្យសម្បត្តិនៃការរឹបអូសនោះ មិនមែនមោឃៈដោយដាច់ខាតទេ ដែលនេះហៅថា អានុភាពមិនដាច់ខាតនៃការរឹបអូស ។

(២) ជាដំបូង ដោយសារថាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ គឺជានីតិវិធីនៃការសម្រេចសិទ្ធិលើបំណុល ដោយស្ថាប័នអនុវត្ត តាមរយៈការប្តូរជាប្រាក់នូវទ្រព្យសម្បត្តិរបស់កូនបំណុល និង តាមរយៈការប្រើប្រាស់ប្រាក់នោះ ដូច្នេះ នៅដំណាក់កាលដំបូងនៃការអនុវត្តដោយបង្ខំចាំបាច់ត្រូវធានាឱ្យបាននូវទ្រព្យដែលជាកម្មវត្ថុនោះ ។ ដើម្បីធានាឱ្យបានដូច្នេះ ចាំបាច់ត្រូវកម្រិតសិទ្ធិចាត់ចែងរបស់កូនបំណុល ទៅលើទ្រព្យនោះ តាមរយៈការរឹបអូស ។ ហេតុដូច្នេះ ការដាក់កម្រិតទៅលើសិទ្ធិចាត់ចែងរបស់កូនបំណុល តែត្រឹមទំហំចាំបាច់ដើម្បីធានានូវតម្លៃនៃការប្តូរជាប្រាក់នូវវត្ថុដែលបានរឹបអូសនោះ ដើម្បីសម្រេចនូវគោលបំណងនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់នោះជាការគ្រប់គ្រាន់ហើយ ។ នេះមានន័យថា គេអាចទទួលស្គាល់នូវអានុភាពនៃការចាត់ចែងទៅលើទ្រព្យដែលបានរឹបអូស ដែលមានភាពផ្ទុយនឹងការរឹបអូស នៅក្នុងទំហំដែលវាមិនប៉ះពាល់ទៅដល់គោលបំណងនៃការរឹបអូសនោះ បាន ។

(៣) ជាក់ស្តែងជាងនេះ ឧទាហរណ៍ នៅក្នុងករណីដែលកូនបំណុល ធ្វើអនុប្បទាននូវទ្រព្យសម្បត្តិរបស់ខ្លួនដែលត្រូវបានរឹបអូស ទៅឱ្យតតិយជន នោះនីតិវិធីនៃការអនុវត្តដោយបង្ខំ នៅតែអាចធ្វើទៅបានដោយមិនខ្វល់

ពីអនុប្បទាននោះឡើយ ព្រោះថា អនុប្បទាននោះ មិនអាចយកទៅតតាំងជាមួយនឹងម្ចាស់បំណុលដែលធ្វើការរឹបអូសបានទេ ។ ក៏ប៉ុន្តែ អនុប្បទាននោះ មានសុពលភាពរវាងភាគីនៃអនុប្បទាន ហើយបើទ្រព្យដែលត្រូវបានធ្វើអនុប្បទាននោះគឺជាអចលនវត្ថុ គេអាចនឹងចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើទ្រព្យនោះ នៅក្រោយការចុះបញ្ជីអំពីការរឹបអូសបានទៀត ។ ជាការពិត ប្រសិនបើការប្តូរជាប្រាក់ ត្រូវបានបញ្ចប់ដោយពុំមានបញ្ហាអ្វី អនុប្បទានដែលប្រព្រឹត្តទៅផ្ទុយនឹងការរឹបអូសនោះ នឹងក្លាយជាមោឃៈ ។ តែផ្ទុយទៅវិញ ប្រសិនបើអានុភាពនៃការរឹបអូស បានរលត់ ដោយសារការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ ការលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ នោះនៅចុងបញ្ចប់ ការចាត់ចែងដែលប្រព្រឹត្តទៅផ្ទុយនឹងការរឹបអូសនោះ នឹងត្រូវចាត់ទុកថាមានសុពលភាពយ៉ាងពេញលេញ ។

## ៥. ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន និង ទ្រព្យសម្បត្តិដែលមិនអាចរឹបអូសបាន

(១) ជាគោលការណ៍ ទ្រព្យសម្បត្តិដែលអាចក្លាយជាកម្មវត្ថុនៃការរឹបអូស នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ គឺទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល លើកលែងតែមានបញ្ញត្តិចែងផ្សេងពីនេះ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ ។ ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល រួមមានទាំងរូបទ្រព្យ ដូចជាចលនវត្ថុ អចលនវត្ថុ នាវា ជាអាទិ៍ និង អរូបទ្រព្យ ដូចជាសិទ្ធិលើបំណុល សិទ្ធិលើកម្មសិទ្ធិបញ្ញា ជាអាទិ៍ ដែលទាំងអស់នេះ ហៅថា "ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន" (មាត្រា ៣៧៩) ។ ដោយសារថា សិទ្ធិដែលពាក់ព័ន្ធនឹងឋានៈបុគ្គលរបស់កូនបំណុល ឬ សិទ្ធិដែលជាសិទ្ធិផ្តាច់មុខរបស់កូនបំណុល មិនអាចប្តូរទៅជាប្រាក់បាន ដូច្នេះ សិទ្ធិទាំងអស់នេះ មិនមែនជាទ្រព្យសម្បត្តិដែលអាចរឹបអូសបានទេ ។

(២) មានទ្រព្យសម្បត្តិខ្លះ ទោះបីវាជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលក៏ដោយ ក៏វាត្រូវបានហាមឃាត់មិនឱ្យរឹបអូស ដោយហេតុផលគោលនយោបាយដែរ ពោលគឺវាធ្លាក់នៅក្នុងករណី "លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង" នៃមាត្រា ៣៧៩ ។ ក្រមនីតិវិធីរដ្ឋប្បវេណី មានចែងអំពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨០) និង សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨២) ។ ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស មានរាយបញ្ជីចាប់ពីចំណុច ក ដល់ចំណុច ឈ នៃមាត្រា ៣៨០ ដែលទាំងអស់នេះ អាចត្រូវបានចាត់ថ្នាក់ជា ទ្រព្យសម្បត្តិសម្រាប់ធានាការចិញ្ចឹមជីវិតក្នុងកម្រិតអប្បបរមារបស់កូនបំណុល (ចំណុច ក ដល់ចំណុច ឃ), ទ្រព្យសម្បត្តិសម្រាប់ធានាការបន្តការងាររបស់កូនបំណុល (ចំណុច ង ដល់ចំណុច ឆ), ទ្រព្យសម្បត្តិដែលត្រូវបានយកចិត្តទុកដាក់តាមគោលនយោបាយផ្នែកវប្បធម៌ (ចំណុច ជ ដល់ចំណុច ឋ) និង ទ្រព្យសម្បត្តិដែលត្រូវបានយកចិត្តទុកដាក់តាមគោលនយោបាយផ្នែកសង្គម (ចំណុច ឌ និង ចំណុច ឈ) ។

(៣) សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស មានរាយបញ្ជីចាប់ពីចំណុច ក ដល់ចំណុច ច កថាខណ្ឌ

ទី ១ នៃមាត្រា ៣៨២ និង កថាខណ្ឌទី ២ នៃមាត្រាដដែលនេះ ។ បញ្ញត្តិនេះ ចែងឡើងដើម្បីបុព្វហេតុសង្គម និង សុខមាលភាព ពោលគឺដើម្បីធានានូវការចិញ្ចឹមជីវិតរបស់កូនបំណុល ដូចគ្នានឹងចំណុច ក ដល់ចំណុច ឃ នៃមាត្រា ៣៨០ ស្តីអំពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសដែរ ។

(៤) ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស និង សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស ត្រូវបានកំណត់រួចជាស្រេច ក្នុងលក្ខណៈជាទម្រង់ ។ ក៏ប៉ុន្តែ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់កូនបំណុល ឬ របស់ម្ចាស់បំណុល ពេលខ្លះ ចាំបាច់ត្រូវបង្រួម ឬ ពង្រីកទំហំនៃទ្រព្យដែលហាមឃាត់មិនឱ្យរឹបអូសនេះដែរ ។ ដូច្នេះហើយបានជានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានចែងបញ្ញត្តិស្តីអំពីការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨១) និង ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨៣) ដើម្បីអាចដោះស្រាយបញ្ហានៅក្នុងករណីបែបនោះប្រកបដោយភាពបត់បែនបាន ។

## កថាភាគទី ២ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### ១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

(១) ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាការអនុវត្តដោយបង្ខំដែលត្រូវបានធ្វើឡើង តាមវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចលនវត្ថុនៅទីនេះ រួមមានចលនវត្ថុតាមក្រមរដ្ឋប្បវេណី និង ផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយដែលអាចនឹងទទួលផលយ៉ាងច្បាស់ នៅក្នុងអំឡុងពេលមួយខែ (មាត្រា ៣៨៤ កថាខណ្ឌទី ៤) ។ ម្យ៉ាងទៀត ចលនវត្ថុនៅទីនេះ ក៏រួមបញ្ចូលផងដែរនូវរូបិយវត្ថុដូចជាក្រដាសប្រាក់ និង កាក់ប្រាក់ ដែលមិនទាមទារឱ្យមាននីតិវិធីនៃការប្តូរជាប្រាក់នោះទេ ។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ចាប់ផ្តើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុល (មាត្រា ៣៨៤ កថាខណ្ឌទី ៣) ។

(២) នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះ ស្ថិតនៅ (មាត្រា ៣៨៤ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ គេមិនចាំបាច់ចង្អុលបង្ហាញចំៗអំពីទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសទេ ។ នៅទីតាំងនីមួយៗ ដែលបានរៀបរាប់នៅក្នុងពាក្យសុំ ចលនវត្ថុនៅទីនោះ នឹងក្លាយជាកម្មវត្ថុនៃការរឹបអូស ។ មូលហេតុនៃការកំណត់បែបនេះ គឺព្រោះតែវាមានការលំបាក នៅក្នុងការដៅចង្អុលចំៗនូវចលនវត្ថុតូចៗ ដែលខុសពីអចលនវត្ថុ និង សិទ្ធិលើបំណុល ។ ការកំណត់ចលនវត្ថុនីមួយៗដែលត្រូវរឹបអូស គឺជាការងាររបស់អាជ្ញាសាលា ដែលនឹងមានវត្តមាននៅកន្លែងអនុវត្តដោយបង្ខំ ។ ការរឹបអូសចលនវត្ថុត្រូវធ្វើឡើងដោយអាជ្ញាសាលា ដែលនឹងទទួលការកាន់កាប់ចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល ម្ចាស់បំណុល ឬ តតិយជន (មាត្រា ៣៨៥ និង មាត្រា ៣៨៦) ។

### ២. វិធីរឹបអូស

(១) ការរឹបអូសចលនវត្ថុដែលកូនបំណុលកាន់កាប់ ៖ ក្នុងករណីរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល អាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះ ដោយគ្រាន់តែផ្អែកទៅលើរូបភាពខាងក្រៅនៃការកាន់កាប់របស់កូនបំណុលប៉ុណ្ណោះ ដោយមិនបាច់ស្រាវជ្រាវអំពីរឿងរ៉ាវពាក់ព័ន្ធនឹងកម្មសិទ្ធិអ្វីទេ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមើលពីរូបភាពខាងក្រៅនៃការកាន់កាប់ គេអាចដឹងយ៉ាងច្បាស់ថា ទ្រព្យនោះជារបស់អ្នកដទៃ ការរឹបអូសវត្ថុនោះ មិនត្រូវធ្វើឡើងទេ ។ ឧទាហរណ៍នៃករណីនេះ គឺសៀវភៅដែលមានបិទស្លាកសញ្ញាខ្ចីពីបណ្ណាល័យ ជាអាទិ៍ ។ នៅពេលធ្វើការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល អាជ្ញាសាលាអាចទទួលការកាន់កាប់វត្ថុនោះ ដោយប្រើកម្លាំងបង្ខំបាន ។ និយាយម្យ៉ាងទៀត អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀត ហើយអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក ជាអាទិ៍ បាន (មាត្រា ៣៨៥ កថាខណ្ឌទី ២) ។ ប៉ុន្តែ នៅពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងល័ក្ខខ័ណ្ឌដែលពុំធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៣៨៥ កថាខណ្ឌទី ៣) ។

(២) ការរឹបអូសចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់ ៖ ក្នុងករណីដែលម្ចាស់បំណុលខ្លួនឯងជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុល ម្ចាស់បំណុលនោះ អាចប្រគល់វត្ថុនោះ ដោយស្ម័គ្រចិត្ត ឱ្យដល់អាជ្ញាសាលាដើម្បីធ្វើការរឹបអូស (មាត្រា ៣៨៦) ។ ឧទាហរណ៍នៃស្ថានភាពបែបនេះ គឺករណីដែលម្ចាស់បំណុលកាន់កាប់ទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាកម្មវត្ថុនៃបញ្ចាំ ឬ ដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ។

(៣) ការរឹបអូសចលនវត្ថុដែលតតិយជនកាន់កាប់ ៖ ក្នុងករណីដែលតតិយជនជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុលវិញ អាជ្ញាសាលាអាចរឹបអូសវត្ថុនោះបាន លុះត្រាតែតតិយជននោះ មិនបដិសេធអំពីការប្រគល់ចលនវត្ថុនោះ (មាត្រា ៣៨៦) ព្រោះថា អាជ្ញាសាលាមិនអាចធ្វើការរឹបអូសដោយបង្ខំនូវចលនវត្ថុដែលកាន់កាប់ដោយអ្នកផ្សេងក្រៅពីកូនបំណុល ដោយផ្អែកលើលិខិតអនុវត្តដែលកំណត់ឈ្មោះកូនបំណុលនោះបានទេ ។ ប្រសិនបើតតិយជនបដិសេធមិនព្រមប្រគល់ទេនោះ ម្ចាស់បំណុលពុំមានជម្រើសអ្វីផ្សេងឡើយ ក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យសង ឬ សិទ្ធិទាមទារឱ្យប្រគល់វត្ថុ ដែលកូនបំណុលមានចំពោះតតិយជននោះតាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ហើយប្រមូល និង ប្រគល់វត្ថុនោះ ទៅឱ្យអាជ្ញាសាលា ។ ក្រៅពីចំណុចនេះ នីតិវិធីផ្សេងទៀត មានលក្ខណៈដូចគ្នាទៅនឹងករណីនៃការរឹបអូសចលនវត្ថុដែលកូនបំណុលកាន់កាប់ដែរ ។

## ៣. ការថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស

ជាគោលការណ៍ ចលនវត្ថុដែលត្រូវបានរឹបអូស នឹងស្ថិតនៅក្រោមការថែរក្សាគ្រប់គ្រងរបស់អាជ្ញាសាលា ។ ឧទាហរណ៍ ចំពោះចលនវត្ថុដែលមានតម្លៃ តែងាយស្រួលក្នុងការដឹកជញ្ជូន និង ថែរក្សាគ្រប់គ្រង គេតែងតែ

ប្រើវិធីនេះ ។ ក៏ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្ត ថែរក្សាគ្រប់គ្រងចលនវត្ថុដែលបានរឹបអូសនោះបាន ។ ឧទាហរណ៍ ចំពោះវត្ថុដែលអាចនឹងមានបញ្ហាច្រើន ឬ ដែលត្រូវការចំណាយច្រើន នៅក្នុងការដឹកជញ្ជូន និង ថែរក្សាគ្រប់គ្រង ការទុកឱ្យកូនបំណុលដែលធ្លាប់កាន់កាប់វត្ថុនោះកន្លងមក ថែរក្សាគ្រប់គ្រង ជាការងាយស្រួលជាង ។ នៅក្នុងករណីនេះ ការរឹបអូសនោះមានអានុភាព លុះត្រាតែចលនវត្ថុដែលបានរឹបអូសនោះ ត្រូវបានបិទស្លាក ឬ ដាក់សញ្ញារឹបអូសដោយវិធីផ្សេងទៀត (មាត្រា ៣៨៥ កថាខណ្ឌទី ៤) ។

## ៤. អានុភាពនៃការរឹបអូស

(១) ដោយសារការរឹបអូស កូនបំណុលត្រូវបានហាមឃាត់មិនឱ្យធ្វើការចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូសនោះឡើយ ។ ដូចបានពន្យល់ខាងលើរួចមកហើយ អានុភាពនៃការហាមឃាត់លើការចាត់ចែង គឺជាអានុភាពមិនដាច់ខាត ដែលមានត្រឹមតែកម្រិតចាំបាច់ដើម្បីសម្រេចនូវគោលបំណងនៃការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ ។ ការរឹបអូស មានអានុភាពទៅលើផលធម្មជាតិដែលកើតចេញពីចលនវត្ថុដែលត្រូវបានរឹបអូសនោះ ផងដែរ (មាត្រា ៣៨៥) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ការហាមឃាត់ទៅលើការចាត់ចែង មានអានុភាពលើចលនវត្ថុដើមដែលត្រូវបានរឹបអូសទៅហើយ ហេតុដូច្នេះ មិនចាំបាច់អ្វីត្រូវដើរនីតិវិធីរឹបអូសថ្មីទៀត ចំពោះផលនៃទ្រព្យនោះទេ ។ ឧទាហរណ៍នៃផលដែលកើតចេញពីចលនវត្ថុ មានដូចជាកូនសត្វក្នុងករណីនៃការរឹបអូសសត្វចិញ្ចឹម, ស៊ុត ក្នុងករណីនៃការរឹបអូសមេមាន់ ជាអាទិ៍ ។ ប្រសិនបើទ្រព្យសម្បត្តិដែលបានរឹបអូស ត្រូវបានទុកឱ្យកូនបំណុលថែរក្សាគ្រប់គ្រង កូនបំណុលនោះ អាចប្រើប្រាស់ទ្រព្យនោះបានដោយទទួលការអនុញ្ញាតពីអាជ្ញាសាលា (មាត្រា ៣៨៥ កថាខណ្ឌទី ៥) ។ ក៏ប៉ុន្តែ ដោយសារថា ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិដែលកើតចេញពីចលនវត្ថុដែលបានរឹបអូសនោះដែរ កូនបំណុលពុំមានសិទ្ធិទទួលផ្លែ កូនសត្វចិញ្ចឹម ស៊ុត ជាអាទិ៍ ឡើយ ។ ចំពោះការរឹបអូសរថយន្តដែលបានចុះបញ្ជី ជាអាទិ៍ ការរឹបអូសនឹងមានអានុភាព នៅពេលដែលបានសរសេរនូវហេតុការណ៍នៃការរឹបអូសនោះ ចូលទៅក្នុងសៀវភៅចុះបញ្ជី (មាត្រា ៣៨៧ កថាខណ្ឌទី ២ និង ទី ៣) ។

(២) ប្រសិនបើចលនវត្ថុដែលត្រូវបានរឹបអូស បែរជាធ្លាក់ទៅនៅក្រោមការកាន់កាប់របស់តតិយជន មិនមែនដោយផ្អែកលើការចាត់ចែងរបស់អាជ្ញាសាលា (ឧទាហរណ៍ដូចជាករណីដែលកូនបំណុលដែលមានបន្ទុកថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលបានរឹបអូស បានផ្ទេរការកាន់កាប់ទ្រព្យនោះ ទៅឱ្យតតិយជន ដោយពុំមានការអនុញ្ញាត) សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះ ប្រគល់ចលនវត្ថុនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន (មាត្រា ៣៩០ កថាខណ្ឌទី ១) ។ ដីកាសម្រេចនេះ អាចចេញបាន បើទោះបីជាតតិយជនលើកយកសិទ្ធិកាន់កាប់វត្ថុនោះមកអះអាងក៏ដោយ ព្រោះថា ប្រព័ន្ធនេះ រៀបចំឡើង ដើម្បីធ្វើបដិទានស្ថានភាពដើមឱ្យបានងាយស្រួល និង

ឆាប់រហ័ស ។ ដើម្បីអាចលើកយកសិទ្ធិកាន់កាប់មកអះអាងបាន តតិយជនត្រូវដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ( មាត្រា ៣៦៥) ។ ពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូសត្រូវធ្វើក្នុងអំឡុងពេលមួយសប្តាហ៍ គិតពីថ្ងៃដែលម្ចាស់បំណុលបានដឹងថា ចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន ។ បើអំឡុងពេលមួយសប្តាហ៍ នេះកន្លងផុតទៅ ម្ចាស់បំណុលមិនអាចដាក់ពាក្យសុំនេះបានទេ ( មាត្រា ៣៩០ កថាខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា បើទុករយៈពេលវែងពេកសម្រាប់ការដាក់ពាក្យសុំ នោះនឹងប៉ះពាល់ទៅដល់ស្ថិរភាពនៃទំនាក់ទំនងគតិយុត្ត ។

## ៥. ការដាក់កម្រិតទៅលើការរឹបអូស

( ១) ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ : ដោយសារថា គោលបំណងនៃការអនុវត្តដោយបង្ខំគឺដើម្បីសម្រេចនូវសិទ្ធិទាមទារដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត ដូច្នេះ មិនគួរអនុញ្ញាតឱ្យមានការដាក់ការគាបសង្កត់ទៅលើកូនបំណុលនៃការអនុវត្ត លើសពីការចាំបាច់ ដោយការរឹបអូសហួសពីទំហំដែលចាំបាច់ ( ការរឹបអូសហួសប្រមាណ) នោះទេ ។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ លទ្ធភាពដែលអាចកើតមានការរឹបអូសហួសប្រមាណនោះ មានខ្ពស់ ព្រោះថា ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ពុំត្រូវបានកំណត់ជាក់លាក់ នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំទេ ។ ហេតុនេះហើយបានជាច្បាប់ហាមមិនឱ្យអាជ្ញាសាលាធ្វើការរឹបអូសចលនវត្ថុ ហួសពីកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តទេ ( មាត្រា ៣៩១) ។

( ២) ការហាមឃាត់មិនឱ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់ : នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ប្រសិនបើប៉ាន់ប្រមាណឃើញ ថាចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូស គ្មានចំនួនសេសសល់ទេ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ ការអនុវត្តនោះ ពុំមានផលប្រយោជន៍ទេ ហើយថែមទាំងជាការធ្វើបាបដោយគ្មានន័យចំពោះកូនបំណុលនៃការអនុវត្ត និង ប៉ះពាល់ទៅដល់សេដ្ឋកិច្ចសាធារណៈថែមទៀតផង ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ហាមឃាត់ការរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់បែបនេះ ( មាត្រា ៣៩២) ។

## ៦. ការប្តូរជាប្រាក់ នូវទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស

( ១) ការប្តូរជាប្រាក់ នូវទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ត្រូវធ្វើឡើងតាមរយៈការលក់ ។ ជាទូទៅវិធីលក់ មានការលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ( មាត្រា ៣៩៥ កថាខណ្ឌទី ១) ។ ការលក់ឡាយឡុងដោយផ្ទាល់មាត់ ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ ហើយអាជ្ញាសាលានឹងប្រកាសអំពីការអនុញ្ញាតឱ្យទិញ ចំពោះអ្នកស្នើដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ។ ការលក់ឡាយឡុងដោយដាក់ស្រោមសំបុត្រ ធ្វើឡើងតាមវិធីដែលអ្នកសុំទិញ ដាក់ពាក្យសុំទិញជាលាយលក្ខណ៍អក្សរ ហើយអាជ្ញាសាលានឹងបើក

ស្រោមសំបុត្រភ្លាមបន្ទាប់ពីបិទការដេញថ្លៃ រួចប្រកាសឈ្មោះ និង ថ្លៃដេញ របស់បុគ្គលដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ព្រមទាំងការអនុញ្ញាតឱ្យបុគ្គលនោះទិញ ។

(២) អាជ្ញាសាលា មានសិទ្ធិអំណាច និង ការទទួលខុសត្រូវ នៅក្នុងការរៀបចំ និង រក្សាសណ្ដាប់ធ្នាប់នៃការលក់ឡាយឡុងដោយផ្ទាល់មាត់ និង ដោយដាក់ស្រោមសំបុត្រ ។ និយាយម្យ៉ាងទៀត ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យមានការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះថ្លៃលក់ដោយមិនត្រឹមត្រូវ ឬ ចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះ ចូលកន្លែងលក់ ឬ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនឱ្យស្នើសុំទិញបាន ( មាត្រា ៣៩៦) ។

(៣) ក្នុងករណីដែលការលក់មិនអាចធ្វើទៅបាន បើទោះបីជាបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយហើយប៉ានប្រមាណឃើញថា មិនអាចលក់បាននាពេលអនាគត អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន ( មាត្រា ៣៩៣) ។

## ៧. ករណីមានម្ចាស់បំណុលច្រើន - ការរួមបញ្ចូលរឿងក្ដី

(១) ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការរឹបអូសរួចមកហើយ នៅទីកន្លែងនៃការរឹបអូសដដែលនោះ (ឬ និយាយម្យ៉ាងទៀត ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រួតគ្នា ចំពោះទីកន្លែងរឹបអូសដូចគ្នា) បើមានចលនវត្ថុដែលមិនទាន់បានរឹបអូសនៅឡើយ អាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុនោះ តែប្រសិនបើគ្មានចលនវត្ថុដែលអាចរឹបអូសបានទៀតទេនោះ (អាជ្ញាសាលាត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុ ហើយត្រូវរួមបញ្ចូលរឿងក្ដីអនុវត្តចំពោះចលនវត្ថុថ្មីនេះ និង រឿងក្ដីអនុវត្តចំពោះចលនវត្ថុមុន ជាមួយគ្នា ( មាត្រា ៣៨៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ អាជ្ញាសាលាក៏ត្រូវធ្វើការបញ្ចូលរឿងក្ដីតាមវិធីដូចគ្នានេះដែរ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ទៅលើកូនបំណុលដែលបានទទួលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន នៅទីកន្លែងនៃការអនុវត្តដដែលនោះ ( មាត្រា ៣៨៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

(២) ប្រសិនបើរឿងក្ដីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នា នោះចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្ដីក្រោយ ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្ដីមុននៅពេលរួមបញ្ចូលរឿងក្ដី ហើយពាក្យសុំនៃរឿងក្ដីដែលធ្វើពេលក្រោយនេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ( មាត្រា ៣៨៨ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្ដើមដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្ដីមុននេះ ត្រូវចាត់ទុកថា បានរឹបអូសដើម្បីរឿងក្ដីក្រោយ នៅពេលរួមបញ្ចូលរឿងក្ដី ( មាត្រា

៣៨៨ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

(៣) ប្រសិនបើរឿងក្តីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន និង រឿងក្តីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នា ចលនវត្ថុដែលត្រូវបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា បានរឹបអូស ក្នុងរឿងក្តីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក (មាត្រា ៣៨៨ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត បានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្តើមដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬ លុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ត្រូវចាត់ទុកថា បានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ក្នុងរឿងក្តីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន នៅពេលរួមបញ្ចូលរឿងក្តី (មាត្រា ៣៨៨ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

## ៨. ករណីមានម្ចាស់បំណុលច្រើន - ការទាមទារឱ្យចែកចំណែក

(១) បុគ្គលដែលមានឯកសិទ្ធិ ឬ មានសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យចែកចំណែក នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន ដោយដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ (មាត្រា ៣៩៤) ។ គោលបំណងនៃបញ្ញត្តិនេះ គឺថាខុសពីការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (សូមមើលមាត្រា ៤២៦ កថាខណ្ឌទី ១) នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ បុគ្គលដែលមានសិទ្ធិអាចទាមទារឱ្យចែកចំណែកបាន គឺមានតែបុគ្គលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ប៉ុណ្ណោះ មានន័យថា ម្ចាស់បំណុលដែលមានលិខិតអនុវត្ត ឬ បុគ្គលដែលមានសិទ្ធិរឹបអូសជាបណ្តោះអាសន្ន មិនអាចមកទាមទារឱ្យចែកចំណែកបានទេ ។ ម្ចាស់បំណុលដែលមានលិខិតអនុវត្ត ឬ បុគ្គលដែលមានសិទ្ធិរឹបអូសជាបណ្តោះអាសន្ន អាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំបន្ថែមទៀត ដើម្បីទទួលបានការចែកចំណែក តាមនីតិវិធីនៃការរួមបញ្ចូលរឿងក្តី ។ ដោយសារថា នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានគោលការណ៍ហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ ដូច្នេះ ការរឹបអូសត្រូវធ្វើឡើងត្រឹមតែទំហំដែលអាចសម្រេចនូវសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលធ្វើការរឹបអូស ប៉ុណ្ណោះ ។ ហេតុនេះហើយ ប្រសិនបើចេះតែអនុញ្ញាតឱ្យម្ចាស់បំណុលទូទៅដទៃទៀត អាចធ្វើការទាមទារឱ្យចែកចំណែកបានដែរនោះ ម្ចាស់បំណុលដែលបានរឹបអូសចលនវត្ថុ នឹងមិនបានទទួលការសងពេញលេញសម្រាប់សិទ្ធិទាមទាររបស់ខ្លួនទេ ។ ដូច្នេះហើយទើបពុំមានការអនុញ្ញាតឱ្យធ្វើការទាមទារឱ្យចែកចំណែក យ៉ាងសាមញ្ញបែបនេះ ហើយមានតែក្នុងករណីដែលម្ចាស់បំណុលដទៃទៀត ធ្វើការរឹបអូស ដោយខ្លួនឯងតែប៉ុណ្ណោះ ទើបអានុភាពនៃការទាមទារឱ្យចែកចំណែក ត្រូវបានទទួលស្គាល់តាមរយៈការរួមបញ្ចូលរឿងក្តី ។ ប៉ុន្តែ ក្នុងចំណោមម្ចាស់បំណុលទាំងអស់ ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ដែលមានសិទ្ធិអាទិភាពចំពោះប្រាក់ដែលប្តូរបានពីចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវបានអនុញ្ញាតជាពិសេសឱ្យធ្វើការទាមទារឱ្យចែកចំណែកបាន ព្រោះ

បើហាមឃាត់ម្ចាស់បំណុលបែបនេះមិនឱ្យទាមទារឱ្យចែកចំណែកទេនោះ វាស្មើនឹងការបិទផ្លូវសម្រាប់ពួកគេក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្លួនដូច្នោះឯង ។

## ៩. ការចែកចំណែក

(១) ម្ចាស់បំណុលដែលត្រូវទទួលចំណែក : ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលត្រូវបានទទួលស្គាល់អានុភាពនៃការទាមទារឱ្យចែកចំណែក តាមរយៈការរួមបញ្ចូលរឿងក្តី និង ម្ចាស់បំណុលដែលបានធ្វើការទាមទារឱ្យចែកចំណែក (មាត្រា ៣៩៨) ។ ការចែកចំណែកត្រូវធ្វើឡើងដោយអាជ្ញាសាលា ឬ ដោយសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ។

(២) ការចែកចំណែកដោយអាជ្ញាសាលា : ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែក ចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់នៅសេសសល់ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ (មាត្រា ៣៩៩ កថាខណ្ឌទី ១) ព្រោះថា ប្រសិនបើម្ចាស់បំណុលមានតែម្នាក់ ឬ បើទោះជាម្ចាស់បំណុលមានច្រើននាក់ក៏ដោយ បើទឹកប្រាក់ដែលបានមកពីការលក់ អាចសងបំណុលគ្រប់នោះ នេះជាការគ្រប់គ្រាន់ហើយ ដែលត្រូវសងបំណុលទៅម្ចាស់បំណុលនីមួយៗ និង ប្រគល់ប្រាក់ដែលនៅសេសសល់ ទៅឱ្យកូនបំណុលវិញ ។ នៅក្នុងករណីផ្សេងទៀត ប្រសិនបើម្ចាស់បំណុលទាំងអស់បានព្រមព្រៀងគ្នាលើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ ជាអាទិ៍ នោះអាជ្ញាសាលាត្រូវធ្វើការបែងចែកទៅតាមការព្រមព្រៀងនោះ (មាត្រា ៣៩៩ កថាខណ្ឌទី ២) ។ ទោះបីជាម្ចាស់បំណុលមានច្រើន ហើយទឹកប្រាក់ដែលបានមកពីការលក់មិនអាចសងបំណុលគ្រប់ក៏ដោយ ប្រសិនបើម្ចាស់បំណុលទាំងអស់បានព្រមព្រៀងគ្នាលើការចែកចំណែកហើយនោះពុំមានភាពចាំបាច់អ្វីដែលត្រូវធ្វើការសម្រេចជាពិសេសទៀតនោះទេ ហេតុដូច្នេះ បញ្ញត្តិនេះតម្រូវឱ្យអាជ្ញាសាលា ធ្វើការចែកចំណែកទៅតាមនោះ ។

(៣) ការចែកចំណែកដោយសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ : ប្រសិនបើម្ចាស់បំណុល មិនអាចព្រមព្រៀងគ្នាលើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ ជាអាទិ៍ ទេនោះ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះ ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៤០១) ។ នៅពេលទទួលការរាយការណ៍អំពីហេតុការណ៍នោះ ដោយអាជ្ញាសាលាហើយ សាលាដំបូងត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការចែកចំណែករួចធ្វើការចែកចំណែក ។

# កថាភាគទី ៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

## ១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំ ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ របស់ម្ចាស់បំណុល តាមរយៈការរឹបអូសសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ ឬ ជាការប្រគល់ចលនវត្ថុដែលជារបស់កូនបំណុល ហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ (មាត្រា ៤០២ កថាខណ្ឌទី ១) ។ សិទ្ធិលើបំណុលដែលអាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល រួមមានសិទ្ធិទាមទារឱ្យសងប្រាក់ និង សិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ។ ក្នុងចំណោមសិទ្ធិទាំងពីរប្រភេទនេះ សិទ្ធិដែលត្រូវបានអនុវត្តច្រើនជាងគេ នៅក្នុងករណីជាក់ស្តែង គឺសិទ្ធិទាមទារឱ្យសងប្រាក់ ។ ឧទាហរណ៍គំរូនៃករណីនេះ គឺការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការទាមទារឱ្យសងប្រាក់បញ្ញើពីធនាគារ ។ ការអនុវត្តមួយប្រភេទមួយទៀត ពោលគឺការអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការប្រគល់ចលនវត្ថុ ត្រូវបានគេយកទៅប្រើប្រាស់ នៅក្នុងករណីដែលតតិយជនកាន់កាប់ចលនវត្ថុរបស់កូនបំណុល ហើយបានបដិសេធមិនព្រមប្រគល់ចលនវត្ថុនោះ ។ ដូចបានពន្យល់រួចមកហើយថា ប្រសិនបើតតិយជនបដិសេធមិនព្រមប្រគល់ចលនវត្ថុទេ នោះគេមិនអាចធ្វើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះបានឡើយ (សូមមើលមាត្រា ៣៨៦) ហេតុនេះហើយ គេពុំមានជម្រើសអ្វីផ្សេងឡើយក្រៅពីធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដោយរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុរបស់កូនបំណុលនោះ ។ លើសពីនេះទៅទៀត ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល (មាត្រា ៤១៦) ។ លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះ ការពន្យល់ចាប់ពីត្រឹមនេះទៅ គឺស្ថិតនៅក្នុងប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

## ២. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស

ពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្ត (មាត្រា ៤០៣ កថាខណ្ឌទី ១) ។ តុលាការអនុវត្តនៅទីនេះ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅឋាន ឬ ការិយាល័យជាអាទិ៍ របស់កូនបំណុល ស្ថិតនៅ ហើយប្រសិនបើគ្មានកន្លែងបែបនេះទេ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅឋាន ឬ ការិយាល័យ ជាអាទិ៍ របស់កូនបំណុលទី ៣ ស្ថិតនៅ (មាត្រា ៤០២ កថាខណ្ឌទី ៣) ។ នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៣៤៩ ត្រូវបញ្ជាក់អំពីកូនបំណុលទី ៣ ផងដែរ (មាត្រា ៤០៣ កថាខណ្ឌទី ២) ។ ដោយសារថា ចំណុច ឃ នៃកថាខណ្ឌទី ២ មាត្រា ៣៤៩ ទាមទារឱ្យមានការបញ្ជាក់អំពីសញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដូច្នេះ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ចាំបាច់ត្រូវចង្អុលបង្ហាញ និង បញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូសផងដែរ ។ ក៏ប៉ុន្តែ កម្រិតនៃការបញ្ជាក់នៅក្នុងករណីបែបនេះ នឹងក្លាយជាបញ្ហា ព្រោះថា នៅក្នុងករណីភាគច្រើន ស្ថាប័នហិរញ្ញវត្ថុ ជាអាទិ៍

មិនព្រមបង្ហាញព័ត៌មានទេ ដោយយកករណីយកិច្ចត្រូវរក្សាការសំងាត់ធ្វើជាមូលហេតុ ។ ហេតុនេះហើយ ជាទូទៅ វាមានការលំបាក ក្នុងការបញ្ជាក់ឱ្យច្បាស់អំពីសិទ្ធិលើបំណុល ។ នៅប្រទេសជប៉ុន យើងបកស្រាយថា ការចង្អុលបញ្ជាក់អំពីសិទ្ធិលើបំណុល ត្រឹមតែកម្រិតដែលធ្វើឱ្យកូនបំណុល ឬ កូនបំណុលទី ៣ អាចស្គាល់អំពី សញ្ញាណនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូស នៅពេលបានមើលដីកាសម្រេចរឹបអូស នោះជាការគ្រប់គ្រាន់ ហើយ ហើយគេមិនចាំបាច់ទាមទារឱ្យបញ្ជាក់អំពីមូលហេតុនៃការបង្កើតសិទ្ធិលើបំណុល និង ចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុលនោះទេ ។

### ៣. នីតិវិធីនៃការចេញដីកាសម្រេចរឹបអូស

(១) តុលាការអនុវត្តដែលបានទទួលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស ត្រូវពិនិត្យមើលថាតើវិធីនៃ ការដាក់ពាក្យសុំ មានភាពត្រឹមត្រូវដែរឬទេ ថាតើសិទ្ធិទាមទារនោះ ត្រូវបានហាមឃាត់មិនឱ្យរឹបអូសដែរឬទេ និង ថាតើមានការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ (មាត្រា ៤០៤ កថាខណ្ឌទី ២) ដែរឬទេ ។ តុលាការអនុវត្ត មិនពិនិត្យទៅលើអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសនោះទេ ។ ម្យ៉ាងទៀត នៅមុនពេលចេញដីកាសម្រេចរឹបអូស តុលាការអនុវត្ត មិនសួរកូនបំណុល និង កូនបំណុលទី ៣ ទេ (មាត្រា ៤០៣ កថាខណ្ឌទី ៦) ព្រោះថា បើសួរកូនបំណុល ឬ កូនបំណុលទី ៣ នៅមុនពេលចេញ ដីកាសម្រេចរឹបអូស កូនបំណុលនោះ នឹងអាចមើលដឹងអំពីការរឹបអូស នៅមុនពេលចេញដីកាសម្រេចរឹបអូស ហើយអាចនឹងបញ្ចៀសការអនុវត្តដោយបង្ខំ ដោយប្រមូលសិទ្ធិលើបំណុលដែលត្រូវរឹបអូស ឬ ធ្វើការចាត់ចែង សិទ្ធិលើបំណុលនោះ ដូចជាការធ្វើអនុប្បទាន ជាអាទិ៍ ។ ដីកាសម្រេចរឹបអូសដែលមានកម្មវត្ថុជាសិទ្ធិលើបំណុល ដែលពុំមានអត្ថិភាព នៅតែមានអានុភាពជាដីកាសម្រេចរឹបអូស ហើយការកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃ សិទ្ធិលើបំណុល ត្រូវធ្វើតាមរយៈបណ្តឹងទាមទារប្រមូលបំណុល (មាត្រា ៤១២) ជាអាទិ៍ ។

(២) ចំពោះសិទ្ធិលើបំណុលណាមួយ បើទោះបីជាវាមានតម្លៃលើសពីចំនួនទឹកប្រាក់នៃសិទ្ធិទាមទារឱ្យ សងជាប្រាក់ ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត ក៏ដោយ តុលាការអនុវត្ត អាចរឹបអូសសិទ្ធិនោះទាំងអស់បាន (មាត្រា ៤០៤ កថាខណ្ឌទី ១) ដើម្បីសងបំណុលរបស់ម្ចាស់បំណុលឱ្យបាន គ្រប់ ប្រសិនបើមានម្ចាស់បំណុលដទៃទៀត ទាមទារឱ្យចែកចំណែកដែរ ។ ផ្ទុយទៅវិញ ប្រសិនបើតម្លៃនៃសិទ្ធិ លើបំណុលដែលបានរឹបអូស មានលើសពីចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិត អនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្ត មិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ (មាត្រា ៤០៤ កថាខណ្ឌទី ២) ។ នេះគឺជាការហាមឃាត់មិនឱ្យធ្វើការរឹបអូសហួសប្រមាណ ដែលមានហេតុ ផលដូចគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (មាត្រា ៣៩១) ដែរ ។

(៣) ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន (មាត្រា ៤០៣ កថាខណ្ឌទី ១១) ។ ចំពោះដីកាសម្រេចរឹបអូសដែលបានទទួលស្គាល់ពាក្យសុំ ក៏អាចប្តឹងជំទាស់បាន

ហើយចំពោះដីកាសម្រេចដែលបានលើកចោលពាក្យសុំ ដោយមូលហេតុថាពាក្យសុំនោះ ខុសច្បាប់ ឬ ពុំមានហេតុផលត្រឹមត្រូវ ក៏អាចប្តឹងជំទាស់បានដែរ ។ ក្នុងករណីដែលមានបណ្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំ ហើយដីកាសម្រេចនោះត្រូវបានលុបចោលដោយតុលាការនៃបណ្តឹងជំទាស់ តុលាការនៃបណ្តឹងជំទាស់នោះ មិនត្រូវចេញដីកាសម្រេចរឹបអូសទេ តែត្រូវបង្វិលរឿងក្តីនោះ ទៅតុលាការដើម ដើម្បីឱ្យតុលាការអនុវត្តនោះ ចេញដីកាសម្រេចរឹបអូស ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា កូនបំណុល និង កូនបំណុលទី ៣ មិនត្រូវបានសួរទេ នៅមុនពេលចេញដីកាសម្រេចរឹបអូស ។ ហេតុនេះហើយ ប្រសិនបើតុលាការអនុវត្តលើកចោលពាក្យសុំដោយមិនបានសួរកូនបំណុល កូនបំណុលនោះ នឹងពុំមានឱកាសអាចលើកឡើងអំពីមតិយោបល់របស់ខ្លួនទេ ។

## ៤. អានុភាពនៃដីកាសម្រេចរឹបអូស

(១) នៅក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្ត ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូស ត្រូវហាមមិនឱ្យកូនបំណុលនៃការអនុវត្ត ធ្វើការប្រមូលសិទ្ធិលើបំណុល ឬ ការចាត់ចែងផ្សេងទៀត និង ត្រូវហាមមិនឱ្យកូនបំណុលទី ៣ សងបំណុលឱ្យកូនបំណុលនៃការអនុវត្តនោះ (មាត្រា ៤០៣ កថាខណ្ឌទី ៥) ។ ដីកាសម្រេចរឹបអូស ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ (មាត្រា ៤០៣ កថាខណ្ឌទី ៧) ។ ការរឹបអូស នឹងមានអានុភាព នៅពេលដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅដល់កូនបំណុលទី ៣ (មាត្រា ៤០៣ កថាខណ្ឌទី ៨) ។ នៅពេលដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ក្រឡាបញ្ជី ត្រូវជូនដំណឹងអំពីការណ៍នោះ និង ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជូននោះ ទៅម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៤០៣ កថាខណ្ឌទី ៩) ។ ក្នុងករណីដែលដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជីបានបង្កើតអានុភាព ក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីបញ្ជាក់ថាសិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៤០៣ កថាខណ្ឌទី ១០) ។

(២) ដីកាសម្រេចរឹបអូស មានអានុភាពទៅលើសិទ្ធិលើបំណុលទាំងមូលដែលត្រូវបានរឹបអូស ដោយមិនគិតអំពីចំនួនទឹកប្រាក់នៃសិទ្ធិទាមទារឱ្យសងប្រាក់ ដែលបានកំណត់នៅក្នុងលិខិតអនុវត្តទេ លើកលែងតែមានការដាក់កម្រិតពិសេស នៅក្នុងដីកាសម្រេចរឹបអូសនោះ (មាត្រា ៤០៤ កថាខណ្ឌទី ១) និង មានអានុភាពទៅលើសិទ្ធិប្រាតិភោគ ដែលជាសិទ្ធិបន្ទាប់បន្សំ ផងដែរ ។ អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្ស ឬ តាវកាលិកផ្សេងទៀតដែលទទួលបន្តបន្ទាប់ មានលើតាវកាលិកដែលនឹងទទួលក្រោយពីការរឹបអូសនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត (មាត្រា ៤០៧) ។ ចំពោះតាវកាលិកដែលទទួលបន្តបន្ទាប់ ដើម្បីផ្តល់ភាពងាយស្រួលឱ្យដល់ម្ចាស់បំណុលនៃការអនុវត្ត ច្បាប់កំណត់ថា នៅពេលបានទទួលដីកាសម្រេចរឹបអូសហើយ នោះមិនចាំបាច់

ទទួលដីកាសម្រេចរឹបអូសផ្សេងទៀត សម្រាប់កាលបរិច្ឆេទនៃការផ្តល់តាវកាលិកនីមួយៗនោះទេ ។ សិទ្ធិលើបំណុលដែលទាក់ទងនឹងតាវកាលិកដែលទទួលបន្តបន្ទាប់ សំដៅទៅលើករណីដែលសិទ្ធិលើបំណុលនោះ នឹងកើតមានយ៉ាងពិតប្រាកដ ឬ ពេលកំណត់សងនីមួយៗ នឹងមកដល់យ៉ាងពិតប្រាកដ ដោយផ្អែកលើទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ ។ ឧទាហរណ៍នៃសិទ្ធិលើបំណុលប្រភេទនេះ មានដូចជា សិទ្ធិលើប្រាក់បៀវត្សសិទ្ធិលើប្រាក់សោធននិវត្តន៍ សិទ្ធិលើថ្លៃឈ្នួលដី សិទ្ធិលើថ្លៃឈ្នួល សិទ្ធិលើការប្រាក់ ជាអាទិ៍ ។

(៣) អានុភាពនៃដីកាសម្រេចរឹបអូស ដែលមានទៅលើកូនបំណុល ធ្វើឱ្យកូនបំណុលនោះ លែងមានសិទ្ធិប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូស ទទួលការសង ឬ ធ្វើការចាត់ចែងផ្សេងទៀតដូចជាការធ្វើអនុប្បទានការលើកលែង ការទូទាត់ ជាអាទិ៍ នូវសិទ្ធិលើបំណុលដែលបានរឹបអូសនោះ ដោយសារមានការរឹបអូស ។ ក៏ប៉ុន្តែ ដូចបានពន្យល់ពីខាងដើម អានុភាពនេះ គឺជាអានុភាពមិនដាច់ខាតទេ ព្រោះថា មោឃភាពនៃការចាត់ចែងដោយកូនបំណុល មានតែនៅក្នុងទំនាក់ទំនងទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការរឹបអូស មិនហាមឃាត់ដល់ការចាត់ចែងទំនាក់ទំនងគតិយុត្តដែលនាំឱ្យកើតមានសិទ្ធិលើបំណុលដែលបានរឹបអូសនោះទេ ។ ឧទាហរណ៍ នៅក្រោយពេលមានការរឹបអូសសិទ្ធិលើប្រាក់បៀវត្ស កូនបំណុលដែលជានិយោជិត នៅតែអាចលាឈប់ពីការងារ, នៅក្រោយពេលមានការរឹបអូសសិទ្ធិលើប្រាក់ថ្លៃឈ្នួល កូនបំណុលដែលជាភតិបតី នៅតែអាចរំលាយភតិសន្យា បានដដែល ។

(៤) អានុភាពនៃដីកាសម្រេចរឹបអូស ដែលមានទៅលើកូនបំណុលទី ៣ គឺការហាមឃាត់មិនឱ្យកូនបំណុលទី ៣ នោះ សងបំណុលទៅកូនបំណុលនៃការអនុវត្ត ដោយសារមានការរឹបអូស ។ ក្នុងករណីដែលកូនបំណុលទី ៣ នៅតែសងបំណុលទៅឱ្យកូនបំណុលនៃការអនុវត្ត ដោយមិនខ្វល់អំពីអានុភាពនេះ កូនបំណុលនោះនឹងត្រូវសងបំណុលម្តងទៀត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តធ្វើការទាមទារនៅពេលក្រោយ ដើម្បីប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូសនោះ ។

## ៥. ការដាស់តឿនឱ្យកូនបំណុលទី ៣ ធ្វើសេចក្តីថ្លែងការណ៍

(១) ប្រសិនបើមានពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្ត នៅពេលបញ្ជូនដីកាសម្រេចរឹបអូស តុលាការអនុវត្ត ត្រូវដាស់តឿនឱ្យកូនបំណុលទី ៣ ធ្វើសេចក្តីថ្លែងការណ៍អំពីចំណុចដូចខាងក្រោម ក្នុងអំឡុងពេលពីរសប្តាហ៍ គិតចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស (មាត្រា ៤០៥ កថាខណ្ឌទី ១) ។ ចំណុចដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ទាំងនោះ រួមមាន : (i) អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ព្រមទាំងប្រភេទ ចំនួនទឹកប្រាក់ និង ខ្លឹមសារនៃសិទ្ធិលើបំណុល បើមានសិទ្ធិនោះ, (ii) អត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈសង និង ទំហំនៃការសង ឬ មូលហេតុដែលមិនសង, (iii) បើមានសញ្ញាណនៃជនដែលមានសិទ្ធិអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ព្រមទាំងប្រភេទនៃសិទ្ធិអាទិភាពរបស់ជននោះ និង ទំហំនៃអាទិភាពនោះ, (iv) អត្ថិភាព ឬ នត្ថិភាពនៃការរឹបអូស ឬ ការអនុវត្ត

ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ដោយម្ចាស់បំណុលផ្សេង ។ ប្រសិនបើកូនបំណុលទី ៣ មិនបានធ្វើសេចក្ដីថ្លែងការណ៍តាមការដាស់តឿននេះ ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន ឬ បានធ្វើសេចក្ដីថ្លែងការណ៍ខុសពីការពិត កូនបំណុលទី ៣ នោះ ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលកើតឡើងដោយសារអំពើនេះ ( មាត្រា ៤០៥ កថាខណ្ឌទី ២) ។

(២) គោលបំណងនៃការបង្កើតឱ្យមានរបបនៃការដាស់តឿនឱ្យកូនបំណុលទី ៣ ធ្វើសេចក្ដីថ្លែងការណ៍មានដូចតទៅ ។ ដោយសារថា ដីកាសម្រេចរឹបអូស ត្រូវចេញដោយផ្អែកតែទៅលើពាក្យសុំរបស់ម្ចាស់បំណុលដែលពុំមានព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ដូច្នេះ របបនេះត្រូវបានបង្កើតឡើង ដើម្បីទម្លាក់ករណីយកិច្ចធ្វើការសហការនៅក្នុងនីតិវិធី ទៅលើកូនបំណុលទី ៣ ដែលដឹងព័ត៌មានច្រើនជាងគេ អំពីអត្ថិភាព ឬ នត្ថិភាព ចំនួនទឹកប្រាក់ ជាអាទិ៍ នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ហើយឱ្យកូនបំណុលទី ៣ នោះ ផ្ដល់ព័ត៌មានចាំបាច់សម្រាប់នីតិវិធីដែលបានផ្ដួចផ្ដើមដោយម្ចាស់បំណុលនោះ នៅពេលបន្ទាប់មក ។ នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន តុលាការរៀបចំបោះពុម្ព នូវឯកសារដែលត្រូវសរសេរបញ្ចូលអំពីចំណុចទាំងនេះ ហើយក្រឡាបញ្ជីផ្ញើឯកសារនោះទៅកូនបំណុលទី ៣ ឱ្យបំពេញលើឯកសារនោះ និង ឱ្យផ្ញើត្រឡប់មកវិញ ។

## ៦. ករណីមានម្ចាស់បំណុលច្រើន

(១) ការរឹបអូសជាន់គ្នា ក៏ត្រូវបានអនុញ្ញាតដែរ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ។ ប្រសិនបើម្ចាស់បំណុលដទៃទៀត ដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសរួចទៅហើយនោះ តុលាការអនុវត្ត នឹងចេញដីកាសម្រេចរឹបអូស បន្ថែមទៀត ( មាត្រា ៤០២ កថាខណ្ឌទី ៤, មាត្រា ៤០៤ កថាខណ្ឌទី ៣, មាត្រា ៤១១ កថាខណ្ឌទី ២ ចំណុច ក, និង មាត្រា ៤១៥) ។ ក្នុងករណីដែលការរឹបអូសសិទ្ធិលើបំណុល និង ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុល ត្រូវបានធ្វើឡើងដោយជាន់គ្នា ទៅលើសិទ្ធិលើបំណុលតែមួយ នោះដើម្បីធ្វើការចែកចំណែកឱ្យបានស្មើភាពរវាងម្ចាស់បំណុលទាំងអស់ ការរឹបអូស និង ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ននោះ ត្រូវមានអានុភាពទៅលើសិទ្ធិលើបំណុលទាំងមូលតែម្ដង ( មាត្រា ៤០៤ កថាខណ្ឌទី ៣) ។ ក្នុងករណីដែលមានការរឹបអូសជាន់គ្នា កូនបំណុលទី ៣ មិនអាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួនឡើយ លុះត្រាតែបានផ្ញើទុកប្រាក់ ស្មើនឹងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុល នៅនឹងតុលាការអនុវត្ត ( មាត្រា ៤១១ កថាខណ្ឌទី ២ ចំណុច ក) ។ ពេលកំណត់ចុងក្រោយសម្រាប់ការរឹបអូសជាន់គ្នា គឺដូចគ្នានឹងពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យ ចែកចំណែកដែរ ( មាត្រា ៤១៥) ។

(២) ម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែកបាន នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត និង

ម្ចាស់បំណុលដែលបញ្ជាក់ដោយឯកសារថា ខ្លួនមានឯកសិទ្ធិ (មាត្រា ៤០៩ កថាខណ្ឌទី ១) ។ ដោយសារថា ម្ចាស់សិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុល អាចប្រមូលសិទ្ធិលើបំណុល ដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំដោយផ្ទាល់បាន (មាត្រា ៨៤២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ម្ចាស់សិទ្ធិលើការបញ្ចាំនេះ មិនអាចទាមទារឱ្យចែកចំណែកបានទេ ។ ប្រសិនបើមានការទាមទារឱ្យចែកចំណែក តុលាការអនុវត្ត ត្រូវបញ្ជូនឯកសារដែលបញ្ជាក់អំពីការទាមទារនោះ ទៅឱ្យកូនបំណុលទី ៣ (មាត្រា ៤០៩ កថាខណ្ឌទី ២) ។ ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក គឺពេលដែលកូនបំណុលទី ៣ បានធ្វើការធ្វើ តាមបញ្ញត្តិនៃមាត្រា ៤១១ (មាត្រា ៤១៥ ចំណុច ក), ពេលដែលពាក្យបណ្តឹងទាមទារប្រមូលបំណុល (មាត្រា ៤១២) ត្រូវបានបញ្ជូនទៅកូនបំណុលទី ៣ (មាត្រា ៤១៥ ចំណុច ខ), និង ពេលដែលអាជ្ញាសាលាបានទទួលប្រាក់ពីការលក់ តាមដីកាសម្រេចបង្គាប់ឱ្យលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស (មាត្រា ៤១៣) (មាត្រា ៤១៥ ចំណុច គ) ។ ប្រសិនបើមានពេលបែបនេះច្រើននៅក្នុងនីតិវិធីតែមួយ ពេលកំណត់ដែលត្រូវយកមកគិត គឺពេលដែលមកដល់មុនគេ ។ ដោយសារមានការទាមទារឱ្យចែកចំណែក កូនបំណុលទី ៣ មានករណីយកិច្ចត្រូវធ្វើទុកប្រាក់ (មាត្រា ៤១១ កថាខណ្ឌទី ២ ចំណុច ខ) ហើយម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក អាចទទួលបានចំណែក ពីប្រាក់ដែលបានធ្វើទុកនោះ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក មិនអាចធ្វើការប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូសដោយខ្លួនឯងបានទេ ។ ម៉្យាងទៀត ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក មិនអាចទទួលចំណែកបានទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត បានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ឬ ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវបានលុបចោល ។

## ៧. ការប្តូរជាប្រាក់ - ការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

(១) វិធីទូទៅនៃការប្តូរជាប្រាក់ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ គឺការប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូស ដោយម្ចាស់បំណុលនៃការអនុវត្ត ដែលបានធ្វើការរឹបអូស (មាត្រា ៤១០ កថាខណ្ឌទី ១) ។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជាអាទិ៍ ការប្តូរជាប្រាក់ ត្រូវបានធ្វើឡើងតាមរយៈនីតិវិធីនៃការលក់ទ្រព្យសម្បត្តិដែលបានរឹបអូស ។ ប៉ុន្តែ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលវិញ ការលក់សិទ្ធិលើបំណុល ទៅឱ្យតតិយជនដើម្បីប្តូរសិទ្ធិនោះជាប្រាក់ វាមានលក្ខណៈកាច់កុងច្រើនពេក ហើយដោយសារតែហេតុផលថា បើគ្រាន់តែប្រមូលសិទ្ធិនោះពីកូនបំណុលទី ៣ នោះវាជាការគ្រប់គ្រាន់ទៅហើយ ទើបច្បាប់ប្រគល់សិទ្ធិទៅឱ្យម្ចាស់បំណុល ក្នុងការប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូស ។ ប៉ុន្តែ ដើម្បីធានាឱ្យកូនបំណុលអាចមានឱកាសធ្វើឧបាស្រ័យបាន ការអនុវត្តសិទ្ធិប្រមូល ត្រូវធ្វើបន្ទាប់ពីរយៈពេលមួយសប្តាហ៍បានកន្លងផុត គិតចាប់ពីពេលដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤១០ កថាខណ្ឌទី ១) ។

(២) ដើម្បីប្រមូលសិទ្ធិលើបំណុល ម្ចាស់បំណុលដែលបានធ្វើការរឹបអូស អាចធ្វើសកម្មភាពទាំងអស់ តាមផ្លូវតុលាការ ឬ ក្រៅផ្លូវតុលាការ បាន ។ មានន័យថា ប្រសិនបើកូនបំណុលទី ៣ មិនព្រមសងដោយស្ម័គ្រចិត្តទេនោះ ម្ចាស់បំណុលអាចដាក់ពាក្យបណ្ដឹងទាមទារប្រមូលបំណុលបាន ហើយបើសិទ្ធិលើបំណុលនោះត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ម្ចាស់បំណុលក៏អាចអនុវត្តសិទ្ធិប្រាតិភោគនោះបានដែរ ។ នៅក្នុងករណីនៃបណ្ដឹងទាមទារប្រមូលបំណុល ប្រសិនបើមានពាក្យសុំរបស់កូនបំណុលទី ៣ ដែលជាចុងចម្លើយ តុលាការដែលទទួលពាក្យបណ្ដឹង អាចបង្គាប់ម្ចាស់បំណុលផ្សេងទៀតដែលបានរឹបអូសសិទ្ធិលើបំណុលនោះ មុនពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូន ឱ្យចូលរួមក្នុងនាមជាសហដើមចោទបាន (ការបង្គាប់ឱ្យចូលរួម) ដោយដីកាសម្រេច (មាត្រា ៤១២ កថាខណ្ឌទី ១) ។ អានុភាពនៃសាលក្រមលើបណ្ដឹងទាមទារប្រមូលបំណុល មិនត្រឹមតែមានចំពោះភាគីប៉ុណ្ណោះទេ គឺមានចំពោះម្ចាស់បំណុលផ្សេងដែលបានរឹបអូសសិទ្ធិលើបំណុលនោះ ដែលបានទទួលការបង្គាប់ឱ្យចូលរួម តែមិនបានចូលរួមក្នុងបណ្ដឹងទាមទារប្រមូលបំណុលនោះ ផងដែរ (មាត្រា ៤១២ កថាខណ្ឌទី ២) ។

## ៨. ការប្ដូរជាប្រាក់ - ការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានល័ក្ខខ័ណ្ឌ ឬ មានកំណត់ពេល ឬ មានការលំបាកក្នុងការប្រមូល ដោយសារភ្ជាប់នឹងតាវកាលិកតប ឬ មានហេតុផ្សេងទៀត តុលាការអនុវត្ត អាចចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយឱ្យយកប្រាក់ដែលបានមកពីការលក់នោះ ទៅឱ្យតុលាការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៤១៣ កថាខណ្ឌទី ១) ។ ដីកាសម្រេចនេះ ហៅថា ដីកាសម្រេចបង្គាប់ឱ្យលក់ ។ ដោយសារនីតិវិធីនេះ គឺជានីតិវិធីពិសេស តុលាការអនុវត្ត ចាំបាច់ត្រូវសួរកូនបំណុលនៃការអនុវត្តសិន មុននឹងជ្រើសដើរតាមនីតិវិធីនេះ (មាត្រា ៤១៣ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ដីកាសម្រេចនេះ មិនបង្កើតអានុភាពទេ បើមិនទាន់ចូលជាស្ថាពរ (មាត្រា ៤១៣ កថាខណ្ឌទី ៥) ។ នីតិវិធីនៃការចេញដីកាសម្រេចបង្គាប់ឱ្យលក់ ត្រូវអនុលោមទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ។ នៅក្នុងករណីនេះ ក៏មានការហាមឃាត់ការលក់ដែលពុំមានប្រាក់សេសសល់ (មាត្រា ៤១៣ កថាខណ្ឌទី ៣ និង ទី ៧) និង ការហាមឃាត់ការស្នើទិញដោយកូនបំណុលនៃការអនុវត្ត (មាត្រា ៤១៣ កថាខណ្ឌទី ៨) ដែរ ។ ទោះជាយ៉ាងណាក្ដី ជាវិធានពិសេសសម្រាប់សិទ្ធិលើបំណុល នៅក្រោយការលក់ ត្រូវមានវិធានការផ្សេងៗ ដូចជាការបំពេញល័ក្ខខ័ណ្ឌតតាំងសម្រាប់អនុប្បទាននៃសិទ្ធិលើបំណុល ដោយអាជ្ញាសាលា (មាត្រា ៤១៣ កថាខណ្ឌទី ៩) និង ការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ដោយអាជ្ញាសាលា (មាត្រា ៤១៤ កថាខណ្ឌទី ១០) ជាអាទិ៍ ។

## ៩. ការផ្ញើប្រាក់ទុក ដោយកូនបំណុលទី ៣

(១) ទោះបីជាម្ចាស់បំណុលដែលធ្វើការរឹបអូស មានតែម្នាក់ក៏ដោយ កូនបំណុលទី ៣ អាចរួចផុតពីបំណុលរបស់ខ្លួន ដោយធ្វើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុលនោះ ឬប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនោះទាំងអស់ នៅតុលាការអនុវត្តបាន (មាត្រា ៤១១ កថាខណ្ឌទី ១) ។ នេះគឺជាការធ្វើប្រាក់ ដែលចេញពីសិទ្ធិរបស់កូនបំណុល ។ ការធ្វើប្រាក់នេះ ហៅថា ការធ្វើដោយមានសិទ្ធិ ។

(២) ប្រសិនបើមានម្ចាស់បំណុលច្រើន ចំពោះសិទ្ធិលើបំណុលតែមួយ កូនបំណុលទី ៣ ត្រូវមានកាតព្វកិច្ចធ្វើប្រាក់ ។ និយាយម៉្យាងទៀត កូនបំណុលទី ៣ ត្រូវធ្វើទុកប្រាក់នៅតុលាការអនុវត្ត (i) ស្មើនឹងចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលនោះ ប្រសិនបើបានចេញដីកាសម្រេចរឹបអូស ឬ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយលើសភាគសំណល់ពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ហើយបានទទួលការបញ្ជូននូវដីកាសម្រេចនោះ មុនពេលដែលកូនបំណុលទី ៣ បានទទួលការបញ្ជូននូវពាក្យបណ្តឹងទាមទារប្រមូលបំណុល, ឬ (ii) ស្មើនឹងភាគនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ប្រសិនបើបានទទួលការបញ្ជូននូវឯកសារដែលបញ្ជាក់ថា មានការទាមទារឱ្យចែកចំណែក (មាត្រា ៤១១ កថាខណ្ឌទី ២) ។ នេះគឺជាការធ្វើប្រាក់ដែលកើតចេញពីករណីយកិច្ចរបស់កូនបំណុល ហេតុដូច្នេះ ការធ្វើនេះ ហៅថា ការធ្វើដោយមានករណីយកិច្ច ។

(៣) ទោះបីជាការធ្វើដោយមានសិទ្ធិក៏ដោយ ឬ ការធ្វើដោយមានករណីយកិច្ចក៏ដោយ កូនបំណុលទី ៣ ដែលបានធ្វើប្រាក់ទុកនោះ ត្រូវជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត (មាត្រា ៤១១ កថាខណ្ឌទី ៣) ។

## ១០. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ

(១) ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ក៏ជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដូចជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ដែរ ។ ក៏ប៉ុន្តែដោយសារថាសិទ្ធិទាមទារឱ្យប្រគល់វត្ថុ មានចរិតលក្ខណៈខុសគ្នាពីសិទ្ធិទាមទារឱ្យសងប្រាក់ នោះវាក៏នាំឱ្យមានភាពខុសគ្នាជាច្រើន នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាំងពីរប្រភេទនេះ ។ ឧទាហរណ៍ បញ្ញត្តិមួយចំនួនទាក់ទងនឹងសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស, ការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ដោយម្ចាស់បំណុលនៃការអនុវត្ត, ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣ ជាអាទិ៍ មិនអាចយកទៅអនុវត្តបានទេ ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ដោយសារតែចរិតលក្ខណៈរបស់វា ។

(២) ម្ចាស់បំណុលដែលរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ អាចទាមទារឱ្យកូនបំណុលទី ៣ ប្រគល់ចលនវត្ថុនោះ ទៅអាជ្ញាសាលាដែលទទួលពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើអំឡុងពេល មួយសប្តាហ៍បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត (មាត្រា ៤១៤ កថាខណ្ឌទី ១) ។ ប្រសិនបើកូនបំណុលទី ៣ បដិសេធមិនព្រមប្រគល់ ម្ចាស់បំណុលនៃការអនុវត្ត

ត្រូវដាក់ពាក្យបណ្ដឹងទាមទារប្រមូលបំណុល ដើម្បីទទួលសាលក្រមបង្គាប់ឱ្យកូនបំណុលទី ៣ ដែលជាចុងចម្លើយ ប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ទៅអាជ្ញាសាលា រួចហើយធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់ ។ ពេលដែលទទួលការប្រគល់ចលនវត្ថុ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីនៃការលក់ចលនវត្ថុនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានមកពីការលក់នោះ ទៅតុលាការអនុវត្ត (មាត្រា ៤១៤ កថាខណ្ឌទី ២) ។ នៅក្នុងករណីបែបនេះ អាជ្ញាសាលាគ្រាន់តែដឹកនាំនីតិវិធីនៃការប្ដូរចលនវត្ថុជាប្រាក់ប៉ុណ្ណោះ ហើយស្ថាប័នអនុវត្ត នៅតែជាតុលាការអនុវត្តដដែល ។ ហេតុនេះហើយ នីតិវិធីនៃការចែកចំណែក ក៏ត្រូវធ្វើឡើងដោយតុលាការអនុវត្តដែរ ។

### ១១. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

(១) ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេសអំពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ៤១៦) ។ ឧទាហរណ៍នៃសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត នៅក្នុងច្បាប់ជប៉ុន រួមមាន សិទ្ធិជួល សិទ្ធិអ្នកនិពន្ធ សិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិជាសមាជិកសហគ្រាស សិទ្ធិទាមទារឱ្យប្រគល់នាវា និង អចលនវត្ថុ ជាអាទិ៍ ។ ហេតុផលនៃការចែងបញ្ញត្តិនេះ គឺដើម្បីឱ្យមានបញ្ញត្តិសម្រាប់អនុវត្តទៅលើសិទ្ធិលើទ្រព្យសម្បត្តិទាំងអស់ ដើម្បីចៀសវាងនូវស្ថានភាពមួយដែលពុំមានបញ្ញត្តិសម្រាប់ការអនុវត្តដោយបង្ខំ ចំពោះទ្រព្យសម្បត្តិដែលជាទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល និង ដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់បាន ។

(២) លើកលែងតែមានបញ្ញត្តិពិសេស ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវអនុវត្តទៅតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល ។ ក៏ប៉ុន្តែ មានករណីជាច្រើន ដែលការអនុវត្តបែបនេះ មិនត្រូវបានធ្វើទៅតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល។ ឧទាហរណ៍ នៅក្នុងករណីជាច្រើន វិធីនៃការប្ដូរជាប្រាក់ត្រូវបានធ្វើឡើងដោយផ្អែកលើការបង្គាប់ឱ្យលក់ ព្រោះគេមិនអាចធ្វើតាមការប្រមូល ដែលជាវិធីទូទៅសម្រាប់ការប្ដូរជាប្រាក់ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់បាន ។ ម្យ៉ាងវិញទៀត នីតិវិធីដែលសមស្រប ប្រែប្រួលទៅតាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗ ។ ឧទាហរណ៍ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលមិនអាចមានកូនបំណុលទី ៣ ដូចជាសិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម ជាអាទិ៍ ការរឹបអូស នឹងមានអានុភាពនៅពេលដែលកូនបំណុលបានទទួលការបញ្ជូន មិនមែនពេលដែលកូនបំណុលទី ៣ បានទទួលការបញ្ជូននោះទេ ។ ម្យ៉ាងទៀត ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចុះបញ្ជី នោះចាំបាច់ត្រូវមានការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ដូចក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ជាអាទិ៍ ។ ចំណាត់ការលំអិតលើករណីទាំងនេះ ជាបន្ទុកការងារប្រតិបត្តិរបស់តុលាការ ដោយយោងទៅ

តាមបញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង ដោយអាស្រ័យទៅតាមប្រភេទជាក់លាក់នៃសិទ្ធិលើទ្រព្យសម្បត្តិដែលពាក់ព័ន្ធ ។

## កថាភាគទី ៤ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

### ចំណុចទី ១ កំណត់សំគាល់ទូទៅ

(i) **អត្ថន័យនៃអចលនវត្ថុ**

អចលនវត្ថុ ដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ រួមមាន ដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគនោះដែលជាសិទ្ធិរួម (សិទ្ធិអវិភាគ) (មាត្រា ៤១៧ កថាខណ្ឌទី ១) ។ ការចាត់ទុកថា អាគារ គឺជាអចលនវត្ថុឯករាជ្យអំពីដី ឬ យ៉ាងណានោះ វាអាស្រ័យទៅលើគោលនយោបាយនីតិកម្មរបស់ប្រទេសនីមួយៗ ។ ដោយសារក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ជាគោលការណ៍ អាគារគឺជាសមាសភាគនៃដី (មាត្រា ១២២ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ជាគោលការណ៍ទូទៅ អាគារមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក្នុងលក្ខណៈជាអចលនវត្ថុឯករាជ្យបានទេ ។ ក៏ប៉ុន្តែ នៅក្នុងពេលបច្ចុប្បន្ននេះ យើងបានដឹងថា មានករណីដែលអាចចុះបញ្ជីអាគារជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យបាន តាមច្បាប់រដ្ឋប្បវេណី ដោយសារមានកាលៈទេសៈពិសេសដែលថា ដីមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិតាមច្បាប់រដ្ឋប្បវេណីទេ នៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា ជាពិសេសទីក្រុងភ្នំពេញ ។ ហេតុនេះហើយ នៅក្នុងករណីបែបនេះ អាគារដែលត្រូវបានចុះបញ្ជីក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបានដែរ ។ ចំពោះអាគារដែលមិនបានចុះបញ្ជី វាគឺជាសមាសភាគនៃកម្មសិទ្ធិលើដី ឬ សមាសភាគនៃសិទ្ធិប្រត្យក្សប្រើប្រាស់ដី (សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ) ដែលមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដោយឯករាជ្យបានទេ ។ នៅក្នុងករណីបែបនេះ ដោយសារថា អានុភាពនៃការអនុវត្តដោយបង្ខំចំពោះកម្មសិទ្ធិលើដី ឬ ចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ដី មានទៅលើអាគារដែលជាសមាសភាគនៃសិទ្ធិនោះដែរ (មាត្រា ៤២១ កថាខណ្ឌទី ១) អាគារទាំងនោះ នឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងកម្មសិទ្ធិលើដី ឬ សិទ្ធិប្រត្យក្សប្រើប្រាស់ដីនោះ ។

(ii) **ប្រភេទផ្សេងៗនៃវិធីអនុវត្តដោយបង្ខំ**

(១) ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ (មាត្រា ៤១៧ កថាខណ្ឌទី ២) ។ មានច្បាប់បរទេសមួយចំនួន ចែងអំពីវិធីគ្រប់គ្រងដោយបង្ខំ ។ ការគ្រប់គ្រងដោយបង្ខំ គឺជាវិធីនៃការអនុវត្តដោយបង្ខំ ដែលតាមរយៈនោះ តុលាការអនុវត្ត ជ្រើសរើសអ្នកគ្រប់គ្រង និង ឱ្យអ្នកនោះ គ្រប់គ្រងលើអចលនវត្ថុ ទៅតាមវិធីប្រើប្រាស់របស់វា រួចហើយយកផលចំណេញដែលបានមកពីការគ្រប់គ្រងនោះ

ទៅសងចំពោះសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ឧទាហរណ៍គំរូ គឺករណីដែលអ្នកគ្រប់គ្រងជួលអចលនវត្ថុដែលជាកម្មវត្ថុនោះ ទៅឱ្យតតិយជន រួចប្រមូលថ្លៃឈ្នួល ហើយយកថ្លៃឈ្នួលនោះ ទៅសងឱ្យម្ចាស់បំណុល ។ ក៏ប៉ុន្តែ ប្រទេសកម្ពុជា មិនទទួលយកវិធីនេះទេ ព្រោះវាពុំមានភាពច្បាស់លាស់ថាតើវិធីបែបនេះ មានភាពចាំបាច់ត្រឹមកម្រិតណា ។ ដូច្នេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនទទួលស្គាល់វិធីអនុវត្តបែបនេះឡើយ ។

(២) ការលក់ដោយបង្ខំ ដែលជាវិធីអនុវត្តចំពោះអចលនវត្ថុ គឺជាវិធីអនុវត្តដែលតាមរយៈនោះ តុលាការអនុវត្ត រឹបអូសអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយទើបយកប្រាក់ដែលបានមកពីការលក់នោះ ទៅសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ របស់ម្ចាស់បំណុល ។ ការលក់ដោយបង្ខំ ចាប់ផ្ដើមដោយដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ដែលតុលាការអនុវត្តចេញ តាមពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ របស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៤១៩ កថាខណ្ឌទី ១) ។

(iii) **ស្ថាប័នអនុវត្ត**

(១) នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ស្ថាប័នអនុវត្ត គឺជាតុលាការអនុវត្ត (មាត្រា ៤១៨) ។ ជាធម្មតា អចលនវត្ថុ មានតម្លៃខ្ពស់ជាងចលនវត្ថុ ហើយអាចនឹងមានម្ចាស់សិទ្ធិជាច្រើនមកពាក់ព័ន្ធ ចំណែកឯនីតិវិធីក៏មានលក្ខណៈស្មុគស្មាញដែរ ដែលទាមទារឱ្យមានចំណាត់ការដោយហ្មត់ចត់ ។ ហេតុនេះហើយបានជាច្បាប់កំណត់ថា ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្ត ។ អាជ្ញាសាលា ចូលពាក់ព័ន្ធនៅក្នុងនីតិវិធីនេះ នៅពេលធ្វើការលក់ដោយបង្ខំ ។ ក៏ប៉ុន្តែ ការចូលពាក់ព័ន្ធនេះ គឺកម្រិតត្រឹមតែកិច្ចការបន្ទាប់បន្សំប៉ុណ្ណោះ ដូចជាការគ្រប់គ្រងថែរក្សាដែលជាការចាត់ចែងរក្សាការពារ ដើម្បីជៀសវាងការធ្វើឱ្យចុះថយនូវតម្លៃនៃអចលនវត្ថុ (មាត្រា ៤២៩ កថាខណ្ឌទី ១) ការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្នដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ (មាត្រា ៤៣៤ កថាខណ្ឌទី ២ និង ទី ៣) ការផ្ដល់ជំនួយដល់អ្នកវាយតម្លៃ នៅក្នុងការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន (មាត្រា ៤៣០ កថាខណ្ឌទី ២ និង ទី ៤) ការអនុវត្តការលក់ (មាត្រា ៤៣៦ កថាខណ្ឌទី ៣ និង មាត្រា ៤៣៩ ជាអាទិ៍) ជាអាទិ៍ ។ នេះមានន័យថា តុលាការអនុវត្ត មានសមត្ថកិច្ចផ្ដាច់មុខ លើការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ។

(២) តុលាការអនុវត្តដែលមានសមត្ថកិច្ច ត្រូវបានកំណត់ដូចតទៅ : (i) បើយកដី ឬ អាគារដែលបានចុះបញ្ជី ធ្វើជាកម្មវត្ថុនៃការអនុវត្ត គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ (មាត្រា ៤១៨ ចំណុច ក) និង (ii) បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងពីរនេះដែលជាសិទ្ធិរួមធ្វើជាកម្មវត្ថុនៃការអនុវត្ត គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី (មាត្រា ៤១៨

ចំណុច ខ) ។ សមត្ថកិច្ចទាំងនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ( មាត្រា ៣៤៦) ។

## ចំណុចទី ២ ការលក់ដោយបង្ខំ

### ១. គោលគំនិត

#### (i) រចនាសម្ព័ន្ធនៃនីតិវិធី

នីតិវិធីនៃការលក់ដោយបង្ខំ មានដំណើរតាមលំដាប់លំដោយដូចតទៅ : តាមពាក្យសុំរបស់ម្ចាស់បំណុល តុលាការអនុវត្ត ដាក់កម្រិតទៅលើសិទ្ធិចាត់ចែងរបស់កូនបំណុល ចំពោះអចលនវត្ថុដែលជាកម្មវត្ថុ ដោយធ្វើការរឹបអូសអចលនវត្ថុនោះ ហើយលក់អចលនវត្ថុនោះ រួចទើបធ្វើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់នោះ ។ លំហូរនៃនីតិវិធីដែលមានការរឹបអូស ការលក់ ( ការប្តូរជាប្រាក់) និង ការចែកចំណែក គឺដូចគ្នាទៅនឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ ខុសតែត្រង់ថា សកម្មភាពនៃការអនុវត្តទាំងអស់នេះ ត្រូវធ្វើឡើងតាមលំដាប់លំដោយ ដោយតុលាការអនុវត្ត ។ មានន័យថា ជាដំបូង តុលាការអនុវត្ត រឹបអូសអចលនវត្ថុដោយចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ( មាត្រា ៤១៩ កថាខណ្ឌទី ១) ។ បន្ទាប់មក តុលាការអនុវត្ត កំណត់វិធីលក់ ( មាត្រា ៤៣៦), កំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ( មាត្រា ៤៣៦ កថាខណ្ឌទី ៣) និង កំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ( មាត្រា ៤៣៩) ។ ក្រៅពីនេះ តុលាការអនុវត្ត ស្តាប់ការថ្លែងយោបល់របស់បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ( មាត្រា ៤៤១) រួចហើយប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ( មាត្រា ៤៤០) ។ ជាចុងក្រោយ នៅពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរហើយ តុលាការអនុវត្ត នឹងកំណត់ពេលដែលអ្នកទិញត្រូវបង់ប្រាក់ថ្លៃទិញ ( មាត្រា ៤៤៧) ។ បន្ទាប់ពីបានទទួលការបង់ប្រាក់ថ្លៃទិញហើយ តុលាការអនុវត្ត នឹងកំណត់កាលបរិច្ឆេទនៃការចែកចំណែក និង ធ្វើការចែកចំណែកនៅកាលបរិច្ឆេទនោះ ( សូមមើលគន្លឹទី ៦ ជំពូកទី ២ ផ្នែកទី ៦) ។ តុលាការអនុវត្តត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ នៅកាលបរិច្ឆេទនីមួយៗនៃតុលាការអនុវត្ត ( មាត្រា ៣៣៥, មាត្រា ២១៦ និង មាត្រា ១១៧) ។

#### (ii) វិធីលក់ដោយបង្ខំ – ការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

ការលក់អចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលា តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ( មាត្រា ៤៣៦ កថាខណ្ឌទី ១ និង ទី ៣) ។ មានតែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ទេ ដែលតុលាការអនុវត្តអាចកំណត់វិធីលក់ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ( មាត្រា ៤៣៦ កថាខណ្ឌទី ២) ។

( ១) វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ : វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីលក់ដែល

តាមរយៈនោះ អ្នកស្នើសុំទិញ មកជួបជុំគ្នា នៅថ្ងៃលក់ឡាយឡុង ហើយធ្វើសំណើទិញដោយដាក់ឯកសារដេញថ្លៃដែលមានបញ្ជាក់ពីថ្លៃសុំទិញនៅក្នុងនោះ ។ បន្ទាប់មក គេនឹងបើកឯកសារដេញថ្លៃទាំងនោះ ហើយប្រកាសអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា នៅលើឆាក ។ វិធីលក់នេះ នឹងមិនធ្វើឱ្យបុគ្គលដែលចង់ទិញ ដឹងអំពីកម្មវត្ថុ និង ថ្លៃដែលបុគ្គលផ្សេងទៀតហ៊ានឱ្យទេ ព្រោះថា អ្នកស្នើសុំទិញម្នាក់ៗ ដាក់សំណើអំពីថ្លៃទិញដែលគេហ៊ានឱ្យ នៅក្នុងឯកសារបិទជិត ។ ហេតុនេះ នាំឱ្យគេអាចទប់ស្កាត់ការប្រើល្បិចកល និង ការឃុបឃិតដើម្បីបញ្ចុះថ្លៃលក់បាន ។ ម្យ៉ាងទៀត ការប្រើវិធីនេះ នាំឱ្យគេមិនសូវមានក្តីបារម្ភថាអ្នកស្នើសុំទិញ អាចទទួលរងការគាបសង្កត់ដោយសារបរិយាកាសនាកន្លែងលក់ ឬ ដោយសារអ្នកប្រកួតប្រជែងដែលមិនស្មោះត្រង់ ។ ហេតុនេះហើយបានជាគេកំណត់យកវិធីនេះជាវិធីទូទៅ សម្រាប់ការលក់អចលនវត្ថុ ។

នៅកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រនោះ ពេលដែលការដេញថ្លៃបានបញ្ចប់ហើយ អាជ្ញាសាលាត្រូវបើកស្រោមសំបុត្រនៅចំពោះមុខអ្នកស្នើសុំទិញទាំងអស់ដែលមានវត្តមាន ហើយកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា រួចទើបប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកនោះ និង ថ្លៃលក់ឡាយឡុងនោះ (មាត្រា ៤៣៩ កថាខណ្ឌទី ១) ។ ប្រសិនបើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត (មាត្រា ៤៣៩ កថាខណ្ឌទី ២) ។ ក្នុងករណីដែលអ្នកដេញថ្លៃទាំងនោះមិនព្រមដេញថ្លៃម្តងទៀត ឬ ករណីដែលនៅតែមានអ្នកហ៊ានឱ្យថ្លៃស្មើគ្នាទៀត នោះត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយការចាប់ឆ្នោត (មាត្រា ៤៣៩ កថាខណ្ឌទី ៣) ។

(២) ការលក់ឡាយឡុងដោយផ្ទាល់មាត់ ៖ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីលក់ដែលតាមរយៈនោះ អ្នកស្នើសុំទិញ ធ្វើសំណើទិញ ដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការលក់ ហើយពួកគេដេញថ្លៃឡើង រហូតដល់ពេលគេអាចកំណត់អ្នកដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេបាន ។ ចរិតលក្ខណៈនៃការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺថា អ្នកស្នើសុំទិញ ដឹងអំពីចំនួនទឹកប្រាក់ដែលដៃគូប្រកួតប្រជែងរបស់ខ្លួនដាក់ស្នើ ហើយដេញថ្លៃឡើងឱ្យខ្ពស់ជាងថ្លៃដែលគេបានស្នើនោះ ។ វិធីនេះ បង្កភាពងាយស្រួលដល់ការស្នើសុំទិញ ហើយការប្រកួតប្រជែងត្រូវបានធ្វើឡើងដោយចំពោះ ។ គុណសម្បត្តិនៃវិធីនេះ គឺគេអាចលក់វត្ថុបានថ្លៃ ។ ដោយឡែក គុណវិបត្តិនៃវិធីនេះ គឺវាទាមទារនូវភាពប៉ិនប្រសប់ បច្ចេកទេស និង បទពិសោធន៍ ។ មានន័យថា វិធីនេះ ល្អសម្រាប់តែអ្នកជំនួញដែលមានបទពិសោធន៍ប៉ុណ្ណោះ ហើយគេពិបាកនឹងទាក់ទាញឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់សាធារណជនទូទៅណាស់ ។

## ២. ការចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ

### (i) ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

(១) វិធីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ៖ ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះ

អចលនវត្ថុ ក៏ត្រូវធ្វើជាលាយលក្ខណ៍អក្សរដែរ (មាត្រា ៣៨៩ កថាខណ្ឌទី ១) ។ ពាក្យសុំជាលាយលក្ខណ៍អក្សរនេះ ត្រូវសរសេររៀបរាប់អំពីចំណុចនានាដែលមានចែងក្នុងចំណុចនីមួយៗនៃមាត្រា ៣៨៩ កថាខណ្ឌទី ២ ជាពិសេសត្រូវកំណត់ឱ្យបានច្បាស់លាស់ អំពីសញ្ញាណនៃអចលនវត្ថុ ដែលនឹងក្លាយជាកម្មវត្ថុនៃការលក់ដោយបង្ខំ (មាត្រា ៣៨៩ កថាខណ្ឌទី ២ ចំណុច ឃ) ។ ដើម្បីដាក់ពាក្យសុំនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់ពន្ធចំនួន មួយម៉ឺនរៀល ទៅតុលាការ (មាត្រា ៣៧២ កថាខណ្ឌទី ១) ។

(២) ឯកសារភ្ជាប់ : ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនឹងឯកសារដូចតទៅ : ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្តត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថាអចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត (មាត្រា ៤១៧ កថាខណ្ឌទី ៣) ។

(៣) ការសម្រេចសេចក្តីអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ : តុលាការអនុវត្ត ត្រូវសម្រេចសេចក្តីអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដោយចេញដីកាសម្រេច (មាត្រា ៣៣៧ កថាខណ្ឌទី ១) ។ បើយល់ឃើញថាពាក្យសុំមានទម្រង់ត្រឹមត្រូវ ហើយល័ក្ខខ័ណ្ឌដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំត្រូវបានបំពេញ តុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ (មាត្រា ៤១៩ កថាខណ្ឌទី ១) ។ ផ្ទុយទៅវិញ ប្រសិនបើយល់ឃើញថា ពាក្យសុំពុំមានទម្រង់ត្រឹមត្រូវ ឬ បើល័ក្ខខ័ណ្ឌដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំ មិនត្រូវបានបំពេញទេ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំនោះ (មាត្រា ៤១៩ កថាខណ្ឌទី ៣) ។ អ្នកដាក់ពាក្យសុំ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន (មាត្រា ៤១៩ កថាខណ្ឌទី ៣) ។ រីឯកូនបំណុល មិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំបានទេ តែអាចប្តឹងតវ៉ាចំពោះការអនុវត្តដោយបង្ខំ ទៅតុលាការអនុវត្តបានប៉ុណ្ណោះ ។ ការដែលមិនអាចប្តឹងជំទាស់បាន ព្រោះថា បើអនុញ្ញាតឱ្យប្តឹងជំទាស់នៅដំណាក់កាលនេះបាន នោះនឹងបណ្តាលឱ្យមានករណីនៃការប្តឹងជំទាស់ដើម្បីតែពន្យារពេលនៃការអនុវត្តដោយបង្ខំច្រើន ។

### (ii) ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

(១) ការប្រកាសរឹបអូសអចលនវត្ថុ : នៅក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចង្អុលបញ្ជាក់អំពីម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និង អចលនវត្ថុ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុនោះ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៤១៩ កថាខណ្ឌទី ១) ។ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤១៩ កថាខណ្ឌទី ២) ។ ជាគោលការណ៍ អានុភាពនៃការរឹបអូស នឹងកើតឡើង នៅពេលដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត (មាត្រា ៤២១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។

(២) ការចុះបញ្ជីអំពីការរឹបអូស : នៅពេលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ដុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ជាបន្ទាន់ (មាត្រា ៤២០ កថាខណ្ឌទី ១) (ប្រសិនបើប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិលើដីធ្លីត្រូវបានរៀបចំដោយមានលក្ខណៈទូលំទូលាយ ហើយនឹងមានស្ថានភាពដែលមានដីខ្លះមិនទាន់ត្រូវបានចុះបញ្ជីកម្មសិទ្ធិ នៅក្នុងតំបន់នៃទីតាំងធ្វើការវិនិច្ឆ័យដែលការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ត្រូវបានធ្វើឡើងរួចហើយ នោះនឹងមានភាពចាំបាច់ថា ក្នុងករណីដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញ ចំពោះដីដែលមិនទាន់ត្រូវបានចុះបញ្ជី ស្ថាប័នដែលមានសមត្ថកិច្ច ត្រូវចុះបញ្ជីកម្មសិទ្ធិលើដីនោះសិន រួចទើបចុះបញ្ជីអំពីការរឹបអូសនោះ) ។ ក្នុងករណីដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញចំពោះចំណែកនៃកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ការចុះបញ្ជីអំពីការរឹបអូស ត្រូវចុះចំពោះចំណែករបស់កូនបំណុលនៃការអនុវត្ត ។ បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ដុកផ្ដាក់នេះ ស្ថាប័នដែលមានសមត្ថកិច្ច ត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ នៃសៀវភៅចុះបញ្ជីនោះ ទៅក្រឡាបញ្ជី (មាត្រា ៤២០ កថាខណ្ឌទី ២) ។

(iii) **អានុភាពនៃការរឹបអូស**

(១) ពេលដែលអានុភាពនៃការរឹបអូស កើតឡើង : ជាគោលការណ៍ អានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ កើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមនោះ ត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤២១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ក៏ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើឡើងនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមនោះ អានុភាពនោះ នឹងកើតឡើងនៅពេលបានចុះបញ្ជី (មាត្រា ៤២១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។ នៅក្នុងការអនុវត្តជាក់ស្ដែង គេគួរតែធ្វើការចុះបញ្ជីជាមុន ។ ប្រសិនបើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត មុនពេលចុះបញ្ជីអំពីការរឹបអូសនោះ វាដូចជាទុកឱកាសឱ្យកូនបំណុល អាចធ្វើអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុនោះ ទៅឱ្យតតិយជន ហើយការចុះបញ្ជីអំពីកម្មសិទ្ធិរបស់តតិយជននោះ អាចនឹងធ្វើបានមុនការចុះបញ្ជីអំពីការរឹបអូសផង ។

(២) ការហាមឃាត់មិនឱ្យធ្វើការចាត់ចែង : ដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អានុភាពចម្បងនៃការរឹបអូស គឺការហាមឃាត់មិនឱ្យធ្វើការចាត់ចែង ។ នៅខណៈពេលដែលការរឹបអូសបង្កើតអានុភាពដោយការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ ដោយការចុះបញ្ជីអំពីការរឹបអូស នោះកូនបំណុលនឹងបាត់បង់សិទ្ធិចាត់ចែងនូវអចលនវត្ថុដែលជាកម្មវត្ថុ ហើយអាជ្ញាធររដ្ឋទទួលបាននូវសិទ្ធិចាត់ចែងនោះវិញ ។ ហេតុនេះហើយ ដូចបានពន្យល់នៅក្នុងផ្នែកទូទៅស្ដីពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (ផ្នែកទី ១ កថាភាគទី ១ ៤.) រួចមកហើយ

ប្រសិនបើកូនបំណុលនៃការអនុវត្ត ធ្វើអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុ ទៅឱ្យតតិយជន នៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាព អនុប្បទាននោះ ត្រូវទុកជាមោឃៈ ។ ក៏ប៉ុន្តែ មោឃភាពនេះ គ្រាន់តែមានន័យថា អនុប្បទាននោះ មិនអាចយកទៅតតាំងបានជាមួយនឹងម្ចាស់បំណុលដែលបានធ្វើការរឹបអូសតែប៉ុណ្ណោះ ពោលគឺវាជាមោឃភាពមិនដាច់ខាត ។ ហេតុនេះហើយ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តធ្វើអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុ ទៅឱ្យតតិយជន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស នោះគេអាចនឹងចុះបញ្ជីអំពីលទ្ធកម្មនៃកម្មសិទ្ធិដោយតតិយជនដែលជាអនុប្បទានិកនោះបាន ។ ក៏ប៉ុន្តែ ការចុះបញ្ជីនេះពុំមានសុពលភាព និង ពុំមានន័យអ្វីទេ ចំពោះនីតិវិធីនៃការលក់ដោយបង្ខំ ដែលបានចាប់ផ្តើមឡើងដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយនីតិវិធីនៃការលក់ដោយបង្ខំនោះ នៅតែបន្តដំណើរការដដែល ។ អនុប្បទានិក មិនអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ដោយអះអាងចំពោះម្ចាស់បំណុលនៃការអនុវត្ត ថាអចលនវត្ថុដែលជាកម្មវត្ថុនោះ គឺជាកម្មសិទ្ធិរបស់ខ្លួនទេ ។ ជាងនេះទៅទៀត ប្រសិនបើអចលនវត្ថុដែលពាក់ព័ន្ធនោះ ត្រូវបានលក់ទៅឱ្យអ្នកទិញ តាមនីតិវិធីនៃការលក់ដោយបង្ខំ នោះអនុប្បទានពីមុនដោយប្រឆាំងនឹងការរឹបអូស ត្រូវបាត់បង់អានុភាព ហើយការចុះបញ្ជីអំពីលទ្ធកម្មកម្មសិទ្ធិដោយអនុប្បទានិក ក៏ត្រូវលុបចោលដែរ (មាត្រា ៤៤៨ កថាខណ្ឌទី ១ ចំណុច ខ) ។ ក៏ប៉ុន្តែ ប្រសិនបើអានុភាពនៃការរឹបអូសត្រូវរលត់ទៅវិញដោយសារការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ ដោយសារការលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ នោះការចាត់ចែងដែលបានធ្វើនៅក្រោយការរឹបអូសក៏ដោយ នឹងមានអានុភាព ។

អានុភាពនៃការរឹបអូស មានទៅលើអចលនវត្ថុដែលជាកម្មវត្ថុនោះ ព្រមទាំងលើវត្ថុដែលភ្ជាប់នឹង និងក្លាយទៅជាផ្នែកមួយនៃអចលនវត្ថុនោះ និង លើវត្ថុចំណុះ និង សិទ្ធិចំណុះនៃអចលនវត្ថុនោះ ផងដែរ (មាត្រា ៤២១ កថាខណ្ឌទី ១) ។ ឧទាហរណ៍នៃវត្ថុភ្ជាប់ មានដូចជាអាគារ និង ដើមឈើនៅលើដីដែលជាកម្មវត្ថុនៃការរឹបអូស ។ វត្ថុចំណុះ មានដូចជាគ្រឿងសាងសង់ ក្នុងករណីនៃការរឹបអូសអាគារដែលបានចុះបញ្ជី ។ ចំណែកសិទ្ធិចំណុះ មានដូចជាសេវភាពនៃដីដែលនៅជាប់គ្នា ដែលជាសិទ្ធិរបស់កូនបំណុលក្នុងនាមជាកម្មសិទ្ធិករនៃដីនោះ ។

(៣) ការប្រើប្រាស់ដោយកូនបំណុលនៃការអនុវត្ត នៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាព : ការរឹបអូសអចលនវត្ថុ គ្រាន់តែរារាំងកូនបំណុលមិនឱ្យធ្វើការចាត់ចែងតែប៉ុណ្ណោះ ពោលគឺមិនរារាំងសិទ្ធិកាន់កាប់របស់កូនបំណុលនោះទេ ។ ទោះជានៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាពក៏ដោយ កូនបំណុល នៅតែអាចប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើប្រាស់ធម្មតាបាន (មាត្រា ៤២១ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ កូនបំណុលនៅតែអាចបន្តស្នាក់នៅក្នុងផ្ទះ ដែលស្ថិតនៅលើដីដែលបានរឹបអូស ឬ នៅតែអាចបន្តបង្កបង្កើនផលលើដីកសិកម្មដែលបានរឹបអូស ។ ម្យ៉ាងទៀត ប្រសិនបើដី ឬ អាគារនៅលើដីនោះ កំពុងជួលឱ្យអ្នកដទៃ កូនបំណុល នៅតែអាចទទួលយកប្រាក់ឈ្នួលដដែល (ក៏ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវ

យកមកអនុវត្តឡើយ ចំពោះករណីដែលបានចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណង ឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ តាមនីតិវិធីនៃការអនុវត្តសិទ្ធិលើប្រាតិភោគ នៅពេលដែលនីតិវិធីនៃការលក់ដោយបង្ខំដែលបានប្រព្រឹត្តទៅក្នុងនាមជាការអនុវត្តសិទ្ធិលើប្រាតិភោគ ត្រូវបានចាប់ផ្តើមត្រួតគ្នា ទៅលើអចលនវត្ថុតែមួយនោះ (មាត្រា ៤២១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) សូមមើលទំព័រ ១៧២ ខាងក្រោម) ។ ផ្ទុយទៅវិញ គួរកត់សំគាល់ថា ការបង្កើតសិទ្ធិប្រើប្រាស់ថ្មី ដែលនឹងធ្វើឱ្យថ្លៃលក់អចលនវត្ថុនោះ ធ្លាក់ចុះ ត្រូវបានចាត់ទុកថាជាការចាត់ចែង ហើយត្រូវបានហាមឃាត់ ។

(iv) **ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក**

(១) ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក : ក្នុងករណីដែលការរឹបអូសបានបង្កើតអានុភាពដោយសារការចុះបញ្ជីអំពីការរឹបអូស ឬ ដោយសារការបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ទៅឱ្យកូនបំណុលនៃការអនុវត្ត តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ ដែលនឹងពន្យល់ខាងក្រោម (មាត្រា ៤២២ កថាខណ្ឌទី ១) ។ ច្បាប់នេះ បានទទួលយកគោលការណ៍សមភាព សម្រាប់ករណីដែលមានម្ចាស់បំណុលច្រើន នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (សូមមើលផ្នែកទី ១ កថាភាគទី ១ **២.**) ។ ប៉ុន្តែ ដើម្បីជៀសវាងផលប៉ះពាល់អាក្រក់នៃគោលការណ៍នេះ ដែលចេះតែអនុញ្ញាតជារៀងរហូតឱ្យមានការទាមទារឱ្យចែកចំណែក ទើបបញ្ញត្តិនេះ បង្កើតឱ្យមានការដាក់កម្រិតលើពេលវេលាដែលអាចធ្វើការទាមទារឱ្យចែកចំណែកបាន ។ នៅពេលដែលបានកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកហើយ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះ (មាត្រា ៤២២ កថាខណ្ឌទី ២) ។

(២) ការដាស់តឿនឱ្យរាយការណ៍អំពីសិទ្ធិ ជាអាទិ៍ : នៅពេលបានកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកហើយ តុលាការអនុវត្តត្រូវដាស់តឿនឱ្យជនដែលបានកំណត់ក្នុងមាត្រា ៤២២ កថាខណ្ឌទី ២ ចាប់ពីចំណុច ក ដល់ចំណុច គ រាយការណ៍ទៅតុលាការអនុវត្ត អំពីសិទ្ធិរបស់ខ្លួន ឱ្យបានមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដើម្បីផ្តល់ឱកាសឱ្យពួកគេអាចទទួលបានចំណែកពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុនោះ ។ ក្នុងចំណោមបុគ្គលទាំងនេះ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស (មាត្រា ៤២២ កថាខណ្ឌទី ២ ចំណុច ខ) មិនបានទទួលឥទ្ធិពលពីការលក់ដោយបង្ខំទេ ពោលគឺមិនបានទទួលចំណែកពីប្រាក់ដែលបានមកពីការលក់នោះ ហើយសិទ្ធិប្រាតិភោគរបស់បុគ្គលនោះ បន្តមានអត្ថិភាពនៅក្រោយការលក់ (មាត្រា ៤៣១ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ បុគ្គលទាំងនេះ អាចនឹងត្រូវការអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួន ហើយទទួលការសងនូវសិទ្ធិលើបំណុលដែល

ត្រូវបានធានានោះ នៅពេលមានការលក់ដោយបង្ខំដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលដទៃ ។ ហេតុដូច្នេះ ការដាស់តឿននេះ ធ្វើឡើងដើម្បីឱ្យពួកគេបញ្ជាក់អំពីឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួននោះ ( មាត្រា ៤២២ កថាខណ្ឌទី ៣) ។

(៣) ការផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក : ប្រសិនបើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេលបីខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្ត អាចផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន ( មាត្រា ៤២២ កថាខណ្ឌទី ៤) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ក្នុងករណីបែបនេះ ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះ លឿនពេក បើគិតអំពីដំណើរទៅមុខរបស់នីតិវិធី ។ បើបានផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្ត ត្រូវប្រកាសជាសាធារណៈ អំពីការផ្លាស់ប្តូរនេះ ( មាត្រា ៤២២ កថាខណ្ឌទី ៥) ។

### (v) ការដកពាក្យសុំឱ្យលក់ដោយបង្ខំ

ម្ចាស់បំណុលនៃការអនុវត្ត អាចដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពោលគឺអាចដកពាក្យសុំឱ្យលក់ដោយបង្ខំ នៅតុលាការអនុវត្តបាន ។ នៅពេលដកពាក្យសុំ ម្ចាស់បំណុល មិនចាំបាច់ទទួលការយល់ព្រមពីកូនបំណុលនៃការអនុវត្ត ពីម្ចាស់សិទ្ធិប្រាតិភោគដែលអាចទទួលចំណែកពីប្រាក់ដែលបានពីការលក់ ឬ ពីម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក ជាអាទិ៍ ឡើយ ។ ម្ចាស់បំណុលអាចដកពាក្យសុំ នៅក្រោយពេលមានការផ្តល់សំណើទិញ នៅកាលបរិច្ឆេទនៃការលក់បាន ។ ក៏ប៉ុន្តែ ដើម្បីដកពាក្យសុំ នៅក្រោយពេលដែលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាហើយ ត្រូវទទួលការយល់ព្រមពីបុគ្គលនោះ ឬ ពីអ្នកទិញសិន ( មាត្រា ៤៤៦) ។ ហេតុផលនៃការកំណត់បែបនេះ ព្រោះថា អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ បានទទួលនូវឋានៈដែលធ្វើឱ្យពួកគេអាចរំពឹងថានឹងបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុនោះបាន ។ ដូច្នេះហើយ បើអនុញ្ញាតឱ្យមានការក្រឡាស់ក្តីរំពឹងនេះ ដោយសារតែឆន្ទៈតែម្ខាងរបស់ម្ចាស់បំណុលនៃការអនុវត្ត នោះវាស្មើនឹងការមិនផ្តល់ការការពារដល់បុគ្គលទាំងនោះ ហើយថែមទាំងធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់សាធារណៈទៅលើប្រព័ន្ធនៃការលក់ដោយបង្ខំនូវអចលនវត្ថុ ទៀតផង ។ ប្រសិនបើមានការដកពាក្យសុំ ដោយស្របច្បាប់ តុលាការអនុវត្ត ត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ។ ពេលនោះ អានុភាពនៃការរឹបអូស នឹងត្រូវរលត់ ។

## ៣. លក្ខខណ្ឌនៃការលក់

### (i) គោលគំនិត

ការលក់ដោយបង្ខំ គឺជាប្រភេទនៃការលក់ ដែលធ្វើឡើងដោយអាជ្ញាធររដ្ឋ អនុវត្តនូវសិទ្ធិចាត់ចែង

ដែលខ្លួនបានទទួលតាមរយៈការរឹបអូស ។ គេអាចនិយាយបានថា ការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ គឺជានីតិវិធីមួយដែលប្រកាសឱ្យអ្នកស្នើសុំទិញ មកទិញវត្ថុ ហើយកំណត់យកបុគ្គលម្នាក់ពីក្នុងចំណោមអ្នកទាំងនោះ ឱ្យធ្វើជាអ្នកទិញ ។ ចំណែកដីកាសម្រេចអនុញ្ញាតឱ្យទិញ មានតម្លៃស្មើនឹងការបង្ហាញឆន្ទៈស្តីការរបស់អាជ្ញាធររដ្ឋដែលជាអ្នកលក់ ចំពោះអ្នកទិញ ។ នៅក្នុងការលក់ធម្មតា បញ្ហាថាតើគួរធ្វើកិច្ចសន្យាលក់ដោយមានល័ក្ខខ័ណ្ឌអ្វីខ្លះ និង ថាតើការលក់នោះ ត្រូវបង្កើតអានុភាពប្រភេទណាខ្លះ នោះត្រូវកំណត់ដោយការព្រមព្រៀងរបស់ភាគីទាំងសងខាង ។ ប៉ុន្តែ នៅក្នុងការលក់ដោយបង្ខំវិញ ប្រសិនបើដាក់ល័ក្ខខ័ណ្ឌផ្សេងៗគ្នា អាស្រ័យទៅតាមអ្នកស្នើសុំទិញ នោះនឹងមានការលំបាកក្នុងការកំណត់ថាតើអ្នកស្នើសុំទិញណាមួយដែលគួរជ្រើសរើស ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្ត ។ ហេតុនេះហើយ ចាំបាច់ត្រូវបង្កើតរបបមួយ ដែលកំណត់ថា ល័ក្ខខ័ណ្ឌផ្សេងៗក្រៅពីថ្លៃលក់ ត្រូវកំណត់ដោយច្បាប់ ដោយគ្មានការលើកលែង ហើយមានតែថ្លៃលក់តែប៉ុណ្ណោះ ដែលភាគីអាចស្នើបាន ។ ដូចបានពោលមកនេះ ល័ក្ខខ័ណ្ឌគ្របដណ្តប់ ដែលច្បាប់បានកំណត់ ទាក់ទងទៅនឹងការបង្កើត និង អានុភាពនៃការលក់ ហៅថា ល័ក្ខខ័ណ្ឌនៃការលក់ដែលច្បាប់បានកំណត់ ។ នេះមានន័យថា ប្រសិនបើទ្រព្យសម្បត្តិណាមួយត្រូវបានស្នើលក់ ដោយពុំមានដាក់ល័ក្ខខ័ណ្ឌពិសេសបន្ថែមទេនោះ ការលក់នោះ ត្រូវធ្វើឡើងទៅតាមល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ ។ ក៏ប៉ុន្តែ ចំពោះល័ក្ខខ័ណ្ឌនៃការលក់ ដែលពាក់ព័ន្ធនឹងការទទួល ឬ ការរំលត់នូវសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ឬ សិទ្ធិជួលដែលមានលើអចលនវត្ថុ (សូមមើល (ii) (២) ខាងក្រោម) ប្រសិនបើបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មានការព្រមព្រៀងគ្នាផ្សេងពីបញ្ញត្តិនៃច្បាប់ ហើយបានរាយការណ៍អំពីការព្រមព្រៀងនោះ ទៅតុលាការអនុវត្ត នៅមុនពេលដែលចេញ ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា នោះល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ នឹងត្រូវផ្លាស់ប្តូរទៅតាមការព្រមព្រៀងនោះ (មាត្រា ៤៣១ កថាខណ្ឌទី ៤) ។ ក្នុងករណីនេះ ល័ក្ខខ័ណ្ឌនៃការលក់ផ្សេងពីល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ ដែលត្រូវបានកំណត់ដោយការព្រមព្រៀងរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ដូច្នេះ ហៅថា ល័ក្ខខ័ណ្ឌពិសេសនៃការលក់ ។

(ii) **ល័ក្ខខ័ណ្ឌនៃការលក់ ដែលច្បាប់បានកំណត់**

(១) ការលក់ នៅក្នុងតម្លៃថោកជាងតម្លៃលក់អប្បបរមា មិនអាចធ្វើបានទេ ព្រោះថា ការលក់អចលនវត្ថុ ក្នុងតម្លៃទាបពេក នឹងធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្ត ហើយថែមទាំងធ្វើឱ្យប៉ះពាល់ដល់តម្លៃជីវិតខាងទៀតផង ។

(២) ការទទួល ឬ ការរំលត់នូវបន្ទុកលើអចលនវត្ថុ : (ក) ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុមានភ្ជាប់ជាមួយនឹងបន្ទុក (សិទ្ធិដែលមានលក្ខណៈជាសិទ្ធិប្រត្យក្សដែលអាចតតាំងនឹងតតិយជនបាន រួមទាំងការរឹបអូស ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន) ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិ

ប្រត្យក្សប្រើប្រាស់និងអាស្រ័យផល (រួមទាំងសិទ្ធិជួលដែលមានល័ក្ខខ័ណ្ឌតតាំងផង) ជាអាទិ៍ នោះវានឹងកើតមានបញ្ហាថាតើទ្រព្យនោះត្រូវលក់ដោយមានល័ក្ខខ័ណ្ឌថាសិទ្ធិនោះត្រូវរលត់ ឬ ថាសិទ្ធិនោះមិនបាច់រលត់ទេ ហើយអ្នកទិញត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ ដែលភ្ជាប់ជាមួយនឹងបន្ទុកទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ វាជាការពិតដែលថា សិទ្ធិដែលបំពេញល័ក្ខខ័ណ្ឌតតាំង ដូចជាការចុះបញ្ជី ជាអាទិ៍ នៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាព ហើយដោយហេតុនេះ វាត្រូវបានចាត់ទុកថាមោឃៈ ចំពោះម្ចាស់បំណុលនៃការអនុវត្ត នឹងត្រូវរលត់ដោយការលក់ ហើយអ្នកទិញ អាចធ្វើលទ្ធកម្មកម្មសិទ្ធិ ដោយមិនទទួលយកបន្ទុកនៃសិទ្ធិទាំងនោះបាន ។ បើមិនដូច្នោះទេ អចលនវត្ថុនោះ នឹងត្រូវលក់ក្នុងតម្លៃទាបជាងតម្លៃពេលរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត ។ បើដូច្នេះមែន ការរឹបអូសយកសិទ្ធិចាត់ចែងរបស់កូនបំណុលនៃការអនុវត្ត ដោយផ្អែកលើការរឹបអូស នឹងគ្មានន័យខ្លឹមសារអ្វីឡើយ ។

(ខ) ដូច្នេះ បញ្ហាចម្បង គឺបញ្ហាថាតើគួរកំណត់ល័ក្ខខ័ណ្ឌនៃការលក់បែបណា ចំពោះសិទ្ធិប្រាតិភោគប្រត្យក្ស និង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ដែលបានចុះបញ្ជីនៅមុនពេលដែលការរឹបអូសបង្កើតអានុភាព ។ នេះគឺជាបញ្ហាដែលត្រូវកំណត់ដោយសេចក្តីសម្រេចផ្អែកគោលនយោបាយ ដោយគិតពិចារណាទៅលើស្ថានភាពជាក់ស្តែងនៃប្រតិបត្តិការហិរញ្ញវត្ថុ និង ការជួញដូរអចលនវត្ថុ ការការពារសិទ្ធិប្រើប្រាស់ដីនិងអាគារ ជាអាទិ៍ របស់ប្រទេសនីមួយៗ ។ បើមើលទៅច្បាប់បរទេស គេឃើញមានគោលការណ៍ពីរប្រឆាំងគ្នា ទាក់ទងទៅនឹងការកំណត់ល័ក្ខខ័ណ្ឌនៃការលក់ ចំពោះបញ្ហាដែលលើកឡើងនេះ ។ គោលការណ៍ទាំងពីរនោះ គឺគោលការណ៍លុបចេញ និង គោលការណ៍ទទួលបន្ត ។ គោលការណ៍លុបចេញ គឺជាគោលការណ៍ដែលតាមរយៈនោះ ទោះបីជាសិទ្ធិដែលមានលើអចលនវត្ថុ មានអាទិភាពទៅលើការរឹបអូសក៏ដោយ ក៏សិទ្ធិនោះត្រូវរលត់ដោយការលក់ដោយបង្ខំ ក្នុងនាមជាសិទ្ធិលើអចលនវត្ថុនោះដែរ ហើយអ្នកទិញនឹងធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុនោះ ដោយពុំមានបន្ទុក ។ ផ្ទុយទៅវិញ គោលការណ៍ទទួលបន្ត គឺជាគោលការណ៍ដែលតាមរយៈនោះ សិទ្ធិលើអចលនវត្ថុដែលមានអាទិភាពទៅលើការរឹបអូស មិនត្រូវរលត់ដោយការលក់ដោយបង្ខំទេ គឺនៅតែបន្តមានអត្ថិភាព ហើយអ្នកទិញ នឹងធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុនោះ ដែលមានភ្ជាប់ជាមួយនឹងសិទ្ធិទាំងនោះ ។ អ្វីដែលគួរកត់សំគាល់នៅទីនេះ គឺថា ការរលត់សិទ្ធិប្រាតិភោគប្រត្យក្សដែលអាចតតាំងចំពោះការរឹបអូស តាមគោលការណ៍លុបចេញ មានន័យគ្រាន់តែជាការរលត់សិទ្ធិលើអចលនវត្ថុ ប៉ុណ្ណោះ ហើយសិទ្ធិប្រាតិភោគប្រត្យក្សទាំងនេះ បែរទៅមានអត្ថិភាពលើប្រាក់ដែលបានមកពីការលក់ និង អ្នកដែលមានសិទ្ធិប្រាតិភោគទាំងនេះ អាចទទួលចំណែក (ការសង) ពីប្រាក់ដែលបានមកពីការលក់ ទៅតាមលំដាប់ដើមដដែល ។ តាមគោលការណ៍លុបចេញនៅក្នុងន័យនេះ ឋានៈរបស់អ្នកទិញមានស្ថិរភាព ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ អ្នកមានសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្ខំឱ្យប្រមូលប្រាក់ដែលខ្លួនបានវិនិយោគ នៅពេលមួយដែលគេមិនទាន់ចង់ប្រមូល ហើយប្រាក់ថ្លៃលក់ដែលអ្នកទិញត្រូវបង់ ក៏ឡើងថ្លៃ

ដើម្បីរំលត់បន្ទុកលើអចលនវត្ថុនោះ ។ ម្យ៉ាងទៀត ចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ដោយសារពុំមានហេតុផលអ្វីដែលត្រូវឱ្យសិទ្ធិនេះរលត់បាន ប្រសិនបើវាបានបំពេញល័ក្ខខ័ណ្ឌតតាំងនៅមុនពេលរឹបអូស ដូច្នេះ គោលការណ៍លុបចេញ ពិបាកនឹងទទួលយកណាស់ ។ ផ្ទុយទៅវិញ តាមគោលការណ៍ទទួលបន្ត ឋានៈរបស់បុគ្គលដែលមានសិទ្ធិអាទិភាព មិនត្រូវបានប្រែប្រួលទេ ហើយបុគ្គលនោះ ក៏មិនត្រូវបានបង្ខំឱ្យប្រមូលប្រាក់ដែលខ្លួនបានវិនិយោគ ដោយគ្មានការស្ម័គ្រចិត្តដែរ ។ ចំណែកឯអ្នកទិញ ក៏អាចនឹងជៀសវាងបង់ប្រាក់ច្រើននៅពេលតែម្តង ។ ក៏ប៉ុន្តែ វាអាចនឹងមានការអនុវត្តសិទ្ធិប្រាតិភោគនេះ នាពេលអនាគត ។ មានន័យថា ឋានៈរបស់អ្នកទិញ មិនមានស្ថិរភាពទេ ត្រង់ចំណុចនេះ ។

(គ) ដោយគិតពិចារណាអំពីស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ដែលបន្ទុកលើអចលនវត្ថុ មិនតែងតែត្រូវបានទទួលស្គាល់យ៉ាងពិតប្រាកដ ដោយការចុះបញ្ជីនោះ ទើបក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ផ្តោតការសំខាន់ទៅលើគុណសម្បត្តិនៃគោលការណ៍ទទួលបន្ត ហើយបានអនុម័តយកគោលការណ៍នេះធ្វើជាវិធានទូទៅ ដោយចែងនូវបញ្ញត្តិដូចតទៅ ( មាត្រា ៤៣១ កថាខណ្ឌទី ១):

① ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមានលើអចលនវត្ថុ ចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ( មាត្រា ៤៣១ កថាខណ្ឌទី ១) ។

② សិទ្ធិលើអចលនវត្ថុ ក្រៅពីសិទ្ធិដែលបានកំណត់ក្នុងចំណុច ① ខាងលើនេះ បានសេចក្តីថា សិទ្ធិដែលពុំអាចតតាំងជាមួយនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវរលត់ ដោយសារការលក់ ( មាត្រា ៤៣១ កថាខណ្ឌទី ២) ។

③ ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនឹងអចលនវត្ថុ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលពុំអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្តោះអាសន្ន ត្រូវបាត់បង់អានុភាពដោយសារការលក់ ( មាត្រា ៤៣១ កថាខណ្ឌទី ៣) ។

ដោយសារថា គោលបំណងចុងក្រោយនៃការរឹបអូស និង ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ( ការរឹបអូស និង ការរឹបអូសជាបណ្តោះអាសន្នដែលបានចុះបញ្ជី) ដែលបានធ្វើឡើងដោយម្ចាស់បំណុលផ្សេងក្រៅពីម្ចាស់បំណុលនៃការអនុវត្ត គឺដើម្បីធ្វើការលក់ដោយបង្ខំនូវអចលនវត្ថុដែលពាក់ព័ន្ធនោះ ដូច្នេះ ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំ បានដើរទៅដល់ការលក់អចលនវត្ថុហើយ ទោះបីជាការលក់នោះធ្វើឡើងដោយផ្អែកលើការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តក៏ដោយ ក៏គោលបំណងចុងក្រោយនេះ ត្រូវបានសម្រេចដែរ ។ ហេតុនេះហើយបានជាច្បាប់កំណត់ថា ការរឹបអូស និង ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នទាំងនេះ ត្រូវរលត់ទាំងស្រុង ។ ផ្ទុយទៅវិញ ដោយសារថា ជាគោលការណ៍ ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ពុំមានគោលបំណងរក្សាការពារនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ទេនោះ អាស្រ័យទៅលើ

ពេលវេលានៃការចុះបញ្ជីអំពីការរឹបអូសដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ច្បាប់កំណត់ថា ការអនុវត្តណាដែលអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ហើយ ការអនុវត្តណាដែលមិនអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបាត់បង់អានុភាពដោយសារការលក់ នោះ ។ ប៉ុន្តែ ទោះបីជាការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នណាមួយអាចតតាំងជាមួយនឹងម្ចាស់ បំណុលនៃការអនុវត្តបានក៏ដោយ ប្រសិនបើការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះមិនអាចតតាំងនឹង ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ហើយបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នោះមុនពេលចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះក៏ត្រូវ បាត់បង់អានុភាពដោយសារការលក់ដែរ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ប្រសិនបើការអនុវត្ត ការចាត់ចែងជាបណ្ដោះអាសន្ននេះ បន្តអត្ថិភាពនៅក្រោយការលក់ដោយបង្ខំ នោះវានឹងនាំឱ្យមានការខូចខាត ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្ដោះអាសន្ន ។ ដោយសារថា ការចាត់ចែង ជាបណ្ដោះអាសន្ននៅទីនេះ គឺជាការចាត់ចែងជាបណ្ដោះអាសន្នដែលទាក់ទងទៅនឹងល័ក្ខខ័ណ្ឌនៃការលក់ បន្ទុកដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ ដូច្នេះ វាមិនសំដៅលើការចាត់ចែងជាបណ្ដោះអាសន្នទាំងអស់ទេ ពោលគឺវាសំដៅទៅលើតែការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់មិនឱ្យធ្វើការចាត់ចែង ដែលរារាំងមិនឱ្យអ្នកទិញអាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន ឬ ដែលរក្សាការពារសិទ្ធិដែលជាបន្ទុកលើកម្មសិទ្ធិ ដែលអ្នកទិញនឹងធ្វើលទ្ធកម្ម ។ ឧទាហរណ៍នៃករណីនេះ គឺការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់មិនឱ្យ ធ្វើការចាត់ចែង ដែលអ្នកទិញអចលនវត្ថុបានទទួល ចំពោះកូនបំណុលនៃការអនុវត្តដែលជាអ្នកលក់ ដើម្បីធ្វើ ការចុះបញ្ជីអំពីលទ្ធកម្មកម្មសិទ្ធិនោះ ។

(ឃ) ដោយសារថា ការដែលបន្ទុកលើអចលនវត្ថុ នឹងរលត់ ឬ មិនរលត់ នៅក្រោយការលក់នោះ មាន ឥទ្ធិពលទៅលើថ្លៃលក់នៃអចលនវត្ថុ ដូច្នេះ តុលាការអនុវត្ត ត្រូវកំណត់ថ្លៃលក់អប្បបរមា ដោយគិតពិចារណា ទៅលើចំណុចថាតើសិទ្ធិណាខ្លះនឹងបន្តអត្ថិភាព ហើយសិទ្ធិណាខ្លះនឹងត្រូវរលត់ (មាត្រា ៤៣២ កថាខណ្ឌទី ១) ។ តុលាការអនុវត្ត ក៏ត្រូវប្រាប់អ្នកវាយតម្លៃឱ្យគិតពិចារណាអំពីចំណុចនេះ នៅពេលបង្គាប់អ្នកវាយតម្លៃឱ្យវាយ តម្លៃអចលនវត្ថុ (មាត្រា ៤៣០ កថាខណ្ឌទី ១) ។ ចំពោះអ្នកស្នើសុំទិញ ក៏ចាំបាច់ត្រូវស្នើថ្លៃទិញដោយគិត ពិចារណាអំពីចំណុចនេះដែរ ។ អ្វីដែលគួរតែកត់សំគាល់ជាពិសេសនៅទីនេះ គឺថា ចំពោះសិទ្ធិប្រាតិភោគ ប្រត្យក្សដែលនឹងបន្តអត្ថិភាពក្រោយការលក់ បើកូនបំណុលនៃការអនុវត្ត គឺជាកូនបំណុលនៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគនេះ នោះអ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលនោះ (មាត្រា ៤៤៩ កថាខណ្ឌទី ១) ។ ហេតុដូច្នេះហើយ នៅពេលធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្ត ត្រូវសរសេររៀបរាប់អំពីសិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពនៅក្រោយការលក់ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ លាស់ ចំពោះអ្នកស្នើទិញ (មាត្រា ៤៣៤ កថាខណ្ឌទី ១ ចំណុច ខ វាក្យខណ្ឌទី ១) ។ ចំពោះការ

អនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលមិនបាត់បង់អានុភាពដោយការលក់ ក៏ត្រូវធ្វើដូចគ្នានេះដែរ (មាត្រា ៤៣៤ កថាខណ្ឌទី ១ ចំណុច ខ វាក្យខណ្ឌទី ២) ។

(៣) ការលក់សរុប : ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើឡើងចំពោះអចលនវត្ថុមួយៗដាច់ដោយឡែកពីគ្នា ។ ក៏ប៉ុន្តែ ជួនកាលមានករណីដែលសមរម្យនឹងឱ្យបុគ្គលម្នាក់ ទិញសរុបតែម្ដងនូវអចលនវត្ថុជាច្រើនដែលបានរឹបអូស ដោយសារវាមានទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ ឧទាហរណ៍ ដូចជា សិទ្ធិផលុបភោគដែលបានចុះបញ្ជី ហើយដែលមានអាគារលើសិទ្ធិនោះ និង ដីដែលផលុបភោគនោះត្រូវបានបង្កើតលើនោះ, ឬ ដីជាច្រើនក្បាលដែលនៅជាប់គ្នា ។ ជាទូទៅ ការលក់សរុបនូវអចលនវត្ថុច្រើនរួមគ្នាដូចក្នុងករណីនេះ បង្កភាពងាយស្រួលដល់អ្នកទិញ ហើយថែមទាំងលក់បានថ្លៃជាងការលក់ដោយឡែកៗពីគ្នាទៀតផង ដែលការណ៍នេះ នឹងនាំឱ្យចំណេញដល់ម្ចាស់បំណុលនៃការអនុវត្ត ក៏ដូចជាកូនបំណុលនៃការអនុវត្ត ។ ហេតុនេះហើយ ប្រសិនបើយល់ឃើញថាជាការសមរម្យក្នុងការឱ្យអ្នកទិញណាមួយ ទិញសរុបតែម្ដងនូវអចលនវត្ថុ ជាមួយនឹងអចលនវត្ថុផ្សេងទៀត ដោយយោងតាមទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ តុលាការអនុវត្ត អាចចេញដីកាសម្រេចលក់អចលនវត្ថុទាំងនោះសរុបតែម្ដងបានដែរ (មាត្រា ៤៣៣ វាក្យខណ្ឌទី ១) ។ ទោះបីជាអចលនវត្ថុនីមួយៗនោះ មានម្ចាស់បំណុលនៃការអនុវត្តផ្សេងគ្នា ឬ កូនបំណុលនៃការអនុវត្តផ្សេងគ្នា ក៏ដោយ ក៏ពុំចោទជាបញ្ហាអ្វីដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានលទ្ធភាពអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ដោយការលក់អចលនវត្ថុណាមួយ ក្នុងតម្លៃអប្បបរមា ក្នុងចំណោមអចលនវត្ថុច្រើនដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានសម្រេចតាមពាក្យសុំតែមួយនោះ តុលាការអនុវត្ត អាចកំណត់ការលក់សរុបតែម្ដងបាន លុះត្រាតែមានការយល់ព្រមពីកូនបំណុលនៃការអនុវត្ត (មាត្រា ៤៣៣ វាក្យខណ្ឌទី ២) ។ ហេតុដូច្នេះ ចាំបាច់ត្រូវកំណត់ថ្លៃលក់អប្បបរមានៃអចលនវត្ថុនីមួយៗ ទៅតាមនោះ ។

(៤) ករណីយកិច្ចរបស់អ្នកស្នើសុំទិញ : ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងមួយភាគដប់នៃតម្លៃលក់អប្បបរមា (មាត្រា ៤៣៧ កថាខណ្ឌទី ១) ទៅកាន់តុលាការអនុវត្ត ។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីត្រៀមប្រឈមនឹងករណីដែលអ្នកស្នើសុំទិញ មិនព្រមបង់ថ្លៃលក់ បើទោះជាខ្លួនបានទទួលដីកាសម្រេចអនុញ្ញាតឱ្យទិញ និង បានក្លាយជាអ្នកទិញ ក៏ដោយនោះ ។ បើអ្នកទិញមិនបានបង់ថ្លៃលក់ នៅមុនពេលកំណត់ទេ នោះតុលាការអនុវត្តនឹងមិនប្រគល់ប្រាក់ធានាឱ្យវិញឡើយ (មាត្រា ៤៥១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ក្នុងករណីនេះ តុលាការអនុវត្ត នឹងបញ្ចូលប្រាក់នេះជាផ្នែកមួយនៃថ្លៃលក់ ដើម្បីយកទៅធ្វើការចែកចំណែក (មាត្រា ៤៥២ កថាខណ្ឌទី ១ ចំណុច ខ) ។ អានុភាពនៃការមិនបង់ថ្លៃលក់ មានទៅលើអ្នកទិញតែត្រឹមកម្រិតនេះឯង ។ ក្នុងករណីដែលអ្នកទិញ មិនបង់ថ្លៃលក់ ដីកាសម្រេចអនុញ្ញាតឱ្យលក់ នឹងបាត់បង់អានុភាព ហើយតុលាការអនុវត្ត ត្រូវធ្វើការលក់ដោយ

បង្គំសាជាថ្មីម្តងទៀត ( មាត្រា ៤៥១ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ទោះបីជាថ្លៃលក់ដែលបានទទួលនៅពេលលក់លើកទីពីរ បូករួមជាមួយនឹងប្រាក់ធានា មិនបានស្មើនឹងថ្លៃលក់នៅពេលលក់លើកទីមួយក៏ដោយ ក៏អ្នកទិញទីមួយ ពុំមានករណីយកិច្ចត្រូវបំពេញភាពចន្លោះនោះឡើយ ។

(៥) ការបង់ថ្លៃលក់ និង ពេលនៃការផ្ទេរកម្មសិទ្ធិ នឹងមានពន្យល់នៅខាងក្រោម ។

(iii) **វិធានការ ក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់**

ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ( មាត្រា ៤៣៥ កថាខណ្ឌទី ១) ។

ដោយសារថា តម្លៃលក់អប្បបរមា ត្រូវបានកំណត់ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃរបស់អ្នកវាយតម្លៃ ( មាត្រា ៤៣២) ដូច្នេះ មានលទ្ធភាពតិចតួចណាស់ដែលអ្នកស្នើសុំទិញ ស្នើតម្លៃខ្ពស់ឆ្ងាយពីតម្លៃលក់អប្បបរមានោះ ។ ហេតុនេះហើយ ប្រសិនបើមើលទៅមិនអាចបង់សោហ៊ុយសម្រាប់នីតិវិធីគ្រប់ទេជាគោលការណ៍ទូទៅ តុលាការអនុវត្ត ត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្គំ ដោយមិនចាំបាច់រង់ចាំកាលបរិច្ឆេទនៃការលក់ដោយបង្គំ ( មាត្រា ៤៣៥ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក្នុងករណីដែលក្នុងអំឡុងពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងនេះ ម្ចាស់បំណុលនៃការអនុវត្ត ដាក់សំណើថា ខ្លួននឹងទិញអចលនវត្ថុ ក្នុងតម្លៃស្នើសុំមួយ ដែលលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ប្រសិនបើគ្មានសំណើទិញណាផ្សេងក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនេះទេ ហើយដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំនេះនោះនីតិវិធីនៃការលក់ដោយបង្គំ នៅតែបន្តទៅមុខដដែល ។ ក្នុងករណីនេះ នីតិវិធីមិននឹងក្លាយទៅជាគ្មានន័យទេ គឺនៅតែបន្តដដែល ។

## ៤. ការអនុវត្តកាលបរិច្ឆេទនៃការលក់

### (i) ការត្រៀមរៀបចំសម្រាប់កាលបរិច្ឆេទនៃការលក់

(១) ការកំណត់តម្លៃលក់អប្បបរមា : តុលាការអនុវត្ត ត្រូវឱ្យអ្នកវាយតម្លៃ ធ្វើការវាយតម្លៃអចលនវត្ថុ ( មាត្រា ៤៣០) ហើយត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃនោះ ( មាត្រា ៤៣២) ។ វិធានការដែលតុលាការអនុវត្តត្រូវចាត់ ក្នុងករណីមានការបារម្ភថា តម្លៃលក់អប្បបរមា នៅក្រោយពេលសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ បានពន្យល់នៅខាងលើរួចហើយ ។

(២) ការរៀបចំឯកសារលំអិតអំពីវត្ថុ : បន្ទាប់ពីបានកំណត់តម្លៃលក់អប្បបរមាហើយ តុលាការអនុវត្តត្រូវរៀបចំឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្តជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ឱ្យសាធារណជនមើល ។ ឯកសារលំអិតអំពីវត្ថុ

ត្រូវសរសេររៀបរាប់អំពីសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុ ក៏ដូចជាសិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ និង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលមិនបាត់បង់អានុភាពដោយការលក់ តាមល័ក្ខខ័ណ្ឌនៃការលក់ (មាត្រា ៤៣៤ កថាខណ្ឌទី ១) ។ គោលបំណងនៃការរៀបចំឯកសារលំអិតអំពីវត្ថុ គឺដើម្បីជូនដំណឹងជាមុន ទៅដល់អ្នកស្នើសុំទិញ អំពីស្ថានភាពនៃបន្ទុកដែលអាចមានភ្ជាប់ជាមួយនឹងអចលនវត្ថុដែលខ្លួនចង់ធ្វើលទ្ធកម្មកម្មសិទ្ធិ (ចំពោះល័ក្ខខ័ណ្ឌនៃការលក់ ដែលទាក់ទងទៅនឹងបន្ទុក សូមមើល **៣.** (ii) ខាងលើ) ។

(៣) ការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ : បើយល់ឃើញថាចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្ត អាចបង្គាប់ឱ្យអាជ្ញាសាលា ស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដូចជាសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ រចនាសម្ព័ន្ធនៃអាគារ បើមានអាគារ ឬ បើកម្មវត្ថុនៃការអនុវត្តគឺជាអាគារ ជាអាទិ៍ ហើយរាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវនោះ ជាលាយលក្ខណ៍អក្សរ (មាត្រា ៤៣៤ កថាខណ្ឌទី ២) ។ នៅពេលធ្វើការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ តាមការបង្គាប់របស់តុលាការអនុវត្ត អាជ្ញាសាលាអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។ ម្យ៉ាងទៀត បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ ដើម្បីបើកទ្វារដែលបិទទៀតផង (មាត្រា ៤៣៤ កថាខណ្ឌទី ៣ និង មាត្រា ៤៣០ កថាខណ្ឌទី ៣) ។ តុលាការអនុវត្ត អាចយករបាយការណ៍នៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ របស់អាជ្ញាសាលា ទៅប្រើប្រាស់ដើម្បីកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍ ។

(៤) ការកំណត់វិធីលក់ កាលបរិច្ឆេទ និង ទីកន្លែងលក់ : ប្រសិនបើគ្មានកាលៈទេសៈពិសេសដែលតម្រូវឱ្យលុបចោលនីតិវិធីនៃការលក់ដោយបង្ខំទេ តុលាការអនុវត្ត ត្រូវកំណត់ដោយឆន្ទានុសិទ្ធិ នូវវិធីលក់ (វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់) កាលបរិច្ឆេទនៃការលក់ និង ទីកន្លែងនៃការលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ (មាត្រា ៤៣៦ កថាខណ្ឌទី ១ ដល់ទី ៣) ។

(៥) ការផ្សាយជាសាធារណៈ : នៅពេលដែលកាលបរិច្ឆេទ និង ទីកន្លែងលក់ត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈ នូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ផង (មាត្រា ៤៣៦ កថាខណ្ឌទី ៤) ។

### (ii) ការកន្លងផុតនៃកាលបរិច្ឆេទនៃការលក់

(១) កាលបរិច្ឆេទនៃការលក់ ត្រូវប្រារព្ធដោយអាជ្ញាសាលា នៅកាលបរិច្ឆេទ និង ទីកន្លែងដែលបានកំណត់នៅក្នុងការផ្សាយជាសាធារណៈ (មាត្រា ៤៣៦ កថាខណ្ឌទី ៣) ។ គោលបំណងនៃកាលបរិច្ឆេទនៃការលក់ គឺដើម្បីកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តាមរយៈវិធីលក់ដែលបានកំណត់ដោយតុលាការអនុវត្ត ។

(២) នៅកាលបរិច្ឆេទនៃការលក់ អាជ្ញាសាលាត្រូវឱ្យបុគ្គលដែលមានវត្តមាន មើលសំណុំរឿងនៃការ

អនុវត្តដោយបង្ខំ ហើយលើកទឹកចិត្តឱ្យពួកគេស្នើសុំទិញ ។ ពុំមានការរឹតបន្តឹងជាពិសេស ទៅលើការស្នើសុំទិញទេ។ ប៉ុន្តែ កូនបំណុលនៃការអនុវត្ត មិនអាចធ្វើសំណើទិញបានឡើយ (មាត្រា ៤៣៨) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា បើកូនបំណុលនៃការអនុវត្ត មានថវិកាគ្រប់គ្រាន់ដើម្បីស្នើទិញអចលនវត្ថុ កូនបំណុលនោះ គួរតែសងប្រាក់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដោយស្ម័គ្រចិត្ត ដោយប្រើថវិកានោះ ។ ពាក្យស្នើសុំទិញអាចដាក់រួមគ្នាដោយបុគ្គលច្រើននាក់បាន ។

(៣) ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងដប់ភាគរយនៃតម្លៃលក់អប្បបរមា (ប្រសិនបើតុលាការអនុវត្ត កំណត់ចំនួនច្រើនជាងនេះ ត្រូវដាក់ប្រាក់ធានាស្មើនឹងចំនួនដែលបានកំណត់នោះ) (មាត្រា ៤៣៧ កថាខណ្ឌទី ១) ។ ចំនួនទឹកប្រាក់ដែលដាក់ស្នើ ត្រូវស្មើ ឬ ច្រើនជាងតម្លៃលក់អប្បបរមា ។ ក្នុងករណីនៃការលក់ឡាយឡុងដោយផ្ទាល់មាត់ អ្នកស្នើសុំទិញត្រូវបានចងដោយពាក្យស្នើសុំទិញ រហូតដល់ពេលដែលមានពាក្យស្នើសុំទិញថ្មីដែលឱ្យតម្លៃលក់ខ្ពស់ជាងមុន ហើយពាក្យស្នើសុំទិញនោះត្រូវបានទទួលស្គាល់ថាស្របច្បាប់ ។ នៅពេលដែលអាជ្ញាសាលាបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង បានប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ហើយ អ្នកស្នើសុំទិញដទៃទៀត អាចទាមទារឱ្យតុលាការអនុវត្តប្រគល់ប្រាក់ធានាមកឱ្យខ្លួនវិញបាន (មាត្រា ៤៣៧ កថាខណ្ឌទី ២) ។ បុគ្គលដែលត្រូវបានកំណត់ថាជាអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានចងដោយសំណើសុំទិញរបស់ខ្លួន ហើយមិនអាចដកពាក្យស្នើសុំទិញវិញបានទេ លើកលែងតែករណីដែលការលក់នោះ មិនត្រូវអនុញ្ញាត ហើយដីកាសម្រេចមិនអនុញ្ញាតឱ្យទិញនោះ បានចូលជាស្ថាពរ ។ នៅពេលដែលដីកាសម្រេចមិនអនុញ្ញាតឱ្យទិញ បានចូលជាស្ថាពរហើយ ប្រាក់ធានារបស់បុគ្គលនោះ ត្រូវប្រគល់ឱ្យបុគ្គលនោះវិញ នៅក្រោយពេលបញ្ចប់កាលបរិច្ឆេទនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

(៤) នៅពេលបញ្ចប់ការលក់ឡាយឡុង ដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពីក្នុងចំណោមអ្នកស្នើសុំទិញដោយស្របច្បាប់ទាំងអស់ ហើយត្រូវប្រកាសនាម ឬ នាមករណ៍របស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានោះ ហើយបើធ្វើការលក់ឡាយឡុងដោយស្រោមសំបុត្រ ត្រូវប្រកាសផងដែរនូវថ្លៃលក់ឡាយឡុងរបស់អ្នកនោះ រួចទើបប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ (មាត្រា ៤៣៩ កថាខណ្ឌទី ១, ចំពោះករណីដែលមានអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ចាប់ពីពីរនាក់ ឡើងទៅ សូមមើលមាត្រា ៤៣៩ កថាខណ្ឌទី ២ និង ទី ៣) ។ នៅពេលបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដោយសរសេរចូលនូវចំណុចផ្សេងៗជាកំណត់ទាក់ទងនឹងដំណើរការនៃការលក់នោះ ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម (មាត្រា ៤៣៩ កថាខណ្ឌទី ៤) ។ នៅក្នុងករណីនេះ អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនោះ (មាត្រា ៤៣៩ កថាខណ្ឌទី ៥) ។

(៥) ក្នុងករណីគ្មានការស្នើសុំទិញដោយស្របច្បាប់ នៅក្នុងកាលបរិច្ឆេទនៃការលក់ទេ អាជ្ញាសាលាត្រូវបញ្ចប់កាលបរិច្ឆេទនៃការលក់នោះ ដោយពុំកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។ ក្នុងករណីបែបនេះ តុលាការអនុវត្ត ត្រូវកំណត់វិធីលក់ កាលបរិច្ឆេទ និង ទីកន្លែងនៃការលក់សាជាថ្មី ហើយឱ្យអាជ្ញាសាលាអនុវត្តការលក់ម្ដងទៀត។ តុលាការអនុវត្ត អាចប្ដូរវិធីលក់ពីការលក់ឡាយឡុងដោយស្រោមសំបុត្រ ទៅជាការលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ពីការលក់ឡាយឡុងដោយផ្ទាល់មាត់ ទៅជាការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ អាចកំណត់វិធីលក់ដទៃផេលបាន ។ ម៉្យាងទៀត តុលាការអនុវត្ត អាចបន្ថយតម្លៃលក់អប្បបរមា ដោយយោងទៅតាមកាលៈទេសៈជាក់ស្ដែង ។ ប្រសិនបើនៅតែពុំមានការស្នើសុំទិញទៀត បើទោះជាបានលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ និង តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ហើយក៏ដោយនោះ តុលាការអនុវត្ត អាចកំណត់វិធីលក់ផ្សេង ហើយលក់អចលនវត្ថុតាមវិធីផ្សេងដែលបានកំណត់នោះបាន (មាត្រា ៤៣៦ កថាខណ្ឌទី ២) ។ ឧទាហរណ៍ តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាធ្វើការចរចាដោយផ្ទាល់ និង លក់វត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត អ្នកមានសិទ្ធិប្រាតិភោគ ភតិកៈជាអាទិ៍ ។ នៅក្នុងករណីនេះ អចលនវត្ថុ ក៏ត្រូវលក់ក្នុងតម្លៃខ្ពស់ជាងតម្លៃលក់អប្បបរមាដែរ ។

## ៥. នីតិវិធីនៃការអនុញ្ញាតឱ្យលក់

### (i) កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការអនុវត្ត ត្រូវសម្រេចអនុញ្ញាតឱ្យលក់ ឬ មិនអនុញ្ញាតឱ្យលក់ទៅឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាដែលអាជ្ញាសាលាបានកំណត់នៅក្នុងកាលបរិច្ឆេទនៃការលក់ ដោយបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ និង ស្ដាប់សេចក្ដីថ្លែងការណ៍របស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ (មាត្រា ៤៤០ កថាខណ្ឌទី ១) ។ យើងដឹងហើយថា ស្ថាប័នអនុវត្តនៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺតុលាការអនុវត្ត ហើយម៉្យាងទៀត ដោយសារថាជាទូទៅអចលនវត្ថុ មានតម្លៃខ្ពស់ឆ្ងាយជាងចលនវត្ថុ ដូច្នេះ ការលក់អចលនវត្ថុ ទាមទារឱ្យមាននូវចំណាត់ការដោយប្រុងប្រយ័ត្ន ។ ហេតុនេះហើយបានជានៅពេលដែលនីតិវិធីនៃការលក់ដោយអាជ្ញាសាលាបានបញ្ចប់ទៅតុលាការអនុវត្តត្រូវស្ដាប់ការថ្លែងយោបល់របស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវពិនិត្យឡើងវិញនូវនីតិវិធីទាំងមូល ចាប់តាំងពីពេលចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ រហូតដល់ពេលកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង ត្រូវសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។ នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ (មាត្រា ៤៤០ កថាខណ្ឌទី ២) ។ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍នៅទីនេះ សំដៅទៅលើបុគ្គលទាំងឡាយ ដែលមានផលប្រយោជន៍ពាក់ព័ន្ធ នៅក្នុងការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុទៅឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ក្នុងតម្លៃដែលជននេះបានស្នើ ។ បុគ្គល

ទាំងនោះ រួមមាន ម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ព្រមទាំងបុគ្គលដែលមានសិទ្ធិទទួលចំណែកពីថ្លៃលក់ (មាត្រា ៤៩៣) និង បុគ្គលដែលមានសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ ជាអាទិ៍ ។ លើសពីនេះ បុគ្គលដែលអះអាងថា ខ្លួនគួរតែត្រូវបានកំណត់ថាជាអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ក៏ជាជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ដែរ ។ កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវធ្វើឡើងនៅតុលាការអនុវត្ត (មាត្រា ៤៤០ កថាខណ្ឌទី ១) ហើយក្រឡាបញ្ជីត្រូវមានវត្តមាននៅពេលនោះ និង ត្រូវធ្វើកំណត់ហេតុ (មាត្រា ៣៣៥, មាត្រា ២១៦ និង មាត្រា ១១៧) ។

### (ii) **ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់**

នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលបង្ហាញខ្លួន អាចថ្លែងយោបល់ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុ ដោយផ្អែកលើហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៤២ ដែលបណ្តាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួនបាន (មាត្រា ៤៤១) ។ មូលហេតុនីមួយៗនៃការមិនអនុញ្ញាតឱ្យលក់ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៤២ គឺជាចំណុចដែលទាក់ទងនឹងវិការៈធ្ងន់ធ្ងរនៃនីតិវិធីទាំងមូលនៃការលក់ដោយបង្ខំ ឬ នីតិវិធីនៃការលក់ ។ ហេតុនេះហើយ តុលាការ គួរតែពិចារណាអំពីចំណុចទាំងនេះដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ ក៏ប៉ុន្តែ ប្រសិនបើវិការៈទាំងនេះ មានឥទ្ធិពលប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ក៏អាចថ្លែងយោបល់អំពីបញ្ហាទាំងនោះបានដែរ ។

### (iii) **ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់**

(១) ដីកាសម្រេចអនុញ្ញាតឱ្យលក់ : ប្រសិនបើពុំមានមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ដែលរៀបរាប់ខាងក្រោមនេះទេ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ (មាត្រា ៤៤២ កថាខណ្ឌទី ១) ។ ដីកាសម្រេចអនុញ្ញាតការលក់ ត្រូវជូនដំណឹង ដោយប្រកាសនៅកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ (មាត្រា ៤៤០ កថាខណ្ឌទី ១) ។ ដីកាសម្រេចអនុញ្ញាតឱ្យលក់ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ (មាត្រា ៤៤៤ កថាខណ្ឌទី ៤) ។

(២) ដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ : (ក) បើយល់ឃើញថាមានមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ដោយឆន្ទានុសិទ្ធិ ឬ តាមការថ្លែងយោបល់របស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ (មាត្រា ៤៤២ កថាខណ្ឌទី ២) ។ នៅក្នុងដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ចាំបាច់ត្រូវសរសេរអំពីមូលហេតុដែលនាំឱ្យតុលាការមិនអនុញ្ញាតឱ្យលក់ផង ។ ដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ ក៏ត្រូវជូនដំណឹង ដោយប្រកាសនៅកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ដែរ ហើយដីកាសម្រេចនេះ ពុំមានអានុភាពឡើយបើមិនទាន់ចូលជាស្ថាពរ (មាត្រា ៤៤០ កថាខណ្ឌទី ១ និង មាត្រា ៤៤៤ កថាខណ្ឌទី ៤) ។

(ខ) មូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ : មូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ ត្រូវបានកម្រិតត្រឹមមូលហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៤២ ។

①ករណីដែលនីតិវិធីនៃការលក់ដោយបង្ខំ មិនគួរបានចាប់ផ្ដើម ឬ បន្ត (ចំណុច ក) : ករណីនេះ រួមមានករណីដែលនីតិវិធីនៃការលក់ដោយបង្ខំ មិនគួរបានចាប់ផ្ដើម តាំងពីដំបូង ដោយសារខ្វះល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្ដើមការលក់ដោយបង្ខំ (ជំពូកទី ២ ផ្នែកទី ៥), ករណីដែលមានមូលហេតុនៃការផ្អាក ឬលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬ មូលហេតុនៃការផ្អាកមួយរយៈ (មាត្រា ៣៧០ កថាខណ្ឌទី ១ និងទី ២) ឬ មានការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ប៉ុន្តែ ហេតុទាំងនោះ ត្រូវបានគេមើលរំលងជាអាទិ៍ ។ ផ្ទុយទៅវិញ ឱ្យតែមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តចំណុចផ្សេងៗដូចជានត្ថិភាព ឬ ការរលត់សិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តនោះ ត្រូវលើកទៅអះអាងនៅក្នុងបណ្ដឹងតវ៉ាចំពោះការទាមទារ ហើយដោយឡែក ចំពោះហេតុដែលថាអចលនវត្ថុដែលជាកម្មវត្ថុនោះ គឺជាកម្មសិទ្ធិរបស់តតិយជន (ករណីដែលកូនបំណុលនៃការអនុវត្ត ត្រូវបានចុះបញ្ជីថាជាកម្មសិទ្ធិករ) នោះត្រូវលើកទៅអះអាងនៅក្នុងបណ្ដឹងតវ៉ារបស់តតិយជន ។ និយាយឱ្យចំទៅ ចំណុចទាំងនេះ មិនមែនជាមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ទេ ។

②ករណីដែលអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញអចលនវត្ថុ ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ (ចំណុច ខ) : ករណីនេះ មានដូចជាករណីដែលអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា គឺជាកូនបំណុលនៃការអនុវត្ត ឬ ជាបុគ្គលដែលធ្លាប់បានក្លាយជាអ្នកទិញ ប៉ុន្តែមិនបានបង់ថ្លៃទិញ ហើយដោយហេតុនេះ បានបាត់បង់លក្ខណសម្បត្តិធ្វើជាអ្នកទិញ (មាត្រា ៤៣៨ និង មាត្រា ៤៥១ កថាខណ្ឌទី ៣), ករណីដែលអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា គឺជាបុគ្គលដែលពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាព, និង ករណីដែលពាក្យស្នើសុំទិញ ត្រូវបានដាក់ដោយអ្នកតំណាងដែលពុំមានសិទ្ធិតំណាង ជាអាទិ៍ ។ ក៏ប៉ុន្តែ ប្រសិនបើសកម្មភាពរបស់បុគ្គលដែលពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាព ឬ របស់អ្នកតំណាងដែលពុំមានសិទ្ធិតំណាង ត្រូវបានផ្ដល់សច្ចានុមតិ សកម្មភាពទាំងនោះនឹងមិនត្រូវក្លាយទៅជាមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ទេ ។

③ ករណីដែលមានសេចក្ដីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ (ចំណុច គ) : តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ នៅក្រោយពេលធ្វើសំណើទិញ ដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ អាចស្នើសុំទៅតុលាការអនុវត្ត កុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ អាចដាក់ពាក្យសុំទៅតុលាការអនុវត្ត ឱ្យលុបចោលដីកាសម្រេចនោះ នៅមុនពេលបង់ប្រាក់បាន ប្រសិនបើនៅក្រោយពេលចេញដីកាសម្រេច

អនុញ្ញាតការលក់ហើយ ( មាត្រា ៤៤៥ កថាខណ្ឌទី ១) ។ ប្រសិនបើអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដាក់សំណើសុំកុំឱ្យអនុញ្ញាតការលក់ ដោយយោងតាមបញ្ញត្តិនេះ ហេតុនោះនឹងក្លាយទៅជាមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ ។ ប្រសិនបើការខូចខាត មានតែបន្តិចបន្តួច សំណើសុំកុំឱ្យអនុញ្ញាតការលក់ មិនអាចដាក់បានទេ ។

④ករណីដែលមានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា (ចំណុច ឃ) : ករណីនេះ មានដូចជា ករណីដែលតម្លៃលក់អប្បបរមា ត្រូវបានកំណត់ដោយមិនផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ, ករណីដែលអ្នកវាយតម្លៃ បានធ្វើការវាយតម្លៃដោយផ្អែកលើការយល់ច្រលំអំពីល័ក្ខខ័ណ្ឌនៃការលក់ ដែលទាក់ទងទៅនឹងការរលត់ ឬ ការបន្តអត្ថិភាពនៃបន្ទុកលើអចលនវត្ថុ ហើយតម្លៃលក់អប្បបរមាត្រូវបានកំណត់ដោយផ្អែកលើការវាយតម្លៃដោយយល់ច្រឡំនេះ ជាអាទិ៍ ។

⑤ ករណីដែលមានកំហុសធ្ងន់ធ្ងរ នៅក្នុងនីតិវិធីនៃការលក់ (ចំណុច ង) : ក្រៅពីមូលហេតុដែលបានរៀបរាប់ចាប់ពីចំណុចទី ①ដល់ទី ④ខាងលើ កំហុសធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងនីតិវិធីនៃការលក់ ក៏ជាមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ដែរ ។ ឧទាហរណ៍ កំហុសអំពីកាលបរិច្ឆេទនៃការលក់ កំហុសទាក់ទងនឹងការកំណត់ទីកន្លែងលក់ កំហុសទាក់ទងនឹងការផ្សាយជាសាធារណៈ កំហុសនៅក្នុងការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍ ។

(៣) ការបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់ : ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើន ក្នុងចំណោមអចលនវត្ថុទាំងអស់នោះ ត្រូវបានប៉ាន់ប្រមាណឃើញថាអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ដើម្បីជៀសវាងការលក់ហួសប្រមាណ តុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុផ្សេងទៀត ( មាត្រា ៤៤៣ កថាខណ្ឌទី ១) ។ នៅក្នុងករណីបែបនេះ តុលាការអនុវត្តត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុនសិន អំពីអចលនវត្ថុដែលត្រូវអនុញ្ញាតឱ្យលក់ ( មាត្រា ៤៤៣ កថាខណ្ឌទី ២) ។ លើសពីនេះ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវបានបម្រុងទុក អាចលុបចោលសំណើទិញនោះ ដោយជូនដំណឹងទៅតុលាការអនុវត្តបាន ( មាត្រា ៤៤៣ កថាខណ្ឌទី ៣) ។ បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុដែលមានដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងអចលនវត្ថុ ដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ( មាត្រា ៤៤៣ កថាខណ្ឌទី ៤) ។

### (iv) **នីតិវិធីនៃបណ្ដឹងជំទាស់**

(១) បុគ្គលដែលមានសិទ្ធិប្ដឹងជំទាស់ : ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ អាចប្ដឹងជំទាស់បាន ។ បុគ្គលដែលត្រូវបានទទួលស្គាល់នូវផលប្រយោជន៍ក្នុងការប្ដឹងជំទាស់ ពោលគឺបុគ្គលដែលមាន

សិទ្ធិប្ដឹងជំទាស់ គឺមានតែបុគ្គលដែលអះអាងថាសិទ្ធិរបស់ខ្លួនទទួលរងការខូចខាតដោយដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ មិនអនុញ្ញាតឱ្យលក់ តែប៉ុណ្ណោះ (មាត្រា ៤៤៤ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត អះអាងថា ប្រសិនបើនីតិវិធីនៃការលក់ដោយបង្ខំ ត្រូវបានធ្វើឡើង ដោយត្រឹមត្រូវនោះអចលនវត្ថុអាចនឹងលក់បានថ្លៃជាងនេះ ម្ចាស់បំណុលនោះអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់បាន ។ ក៏ប៉ុន្តែ ម្ចាស់បំណុលមិនអាចប្ដឹងជំទាស់ដោយគ្រាន់តែលើកហេតុផលថា សិទ្ធិរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរងនូវការខូចខាតនោះទេ ។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលនៃការអនុវត្ត អាចប្ដឹងជំទាស់ជាទូទៅ ចំពោះដីកាសម្រេចមិនអនុញ្ញាតឱ្យលក់បាន ។ ចំពោះកូនបំណុលនៃការអនុវត្តវិញ ជាទូទៅ ផលប្រយោជន៍ក្នុងការប្ដឹងជំទាស់របស់បុគ្គលនេះ ត្រូវបានទទួលស្គាល់ ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ដោយផ្អែកលើរាល់មូលហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៤២ ។ បុគ្គលដែលអាចប្ដឹងជំទាស់បាន មិនកម្រិតត្រឹមតែបុគ្គលដែលមានវត្តមាននៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ហើយដែលបានថ្លែងយោបល់របស់ខ្លួននោះទេ ។

(២) មូលហេតុនៃបណ្ដឹងជំទាស់ : ហេតុដែលអាចយកមកធ្វើជាមូលហេតុនៃបណ្ដឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់បាន មានតែហេតុដែលមានមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ ឬ ហេតុដែលមានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ តែប៉ុណ្ណោះ (មាត្រា ៤៤៤ កថាខណ្ឌទី ២) ។ ផ្ទុយទៅវិញ ហេតុដែលអាចយកមកធ្វើជាមូលហេតុនៃបណ្ដឹងជំទាស់ចំពោះដីកាសម្រេចមិនអនុញ្ញាតឱ្យលក់បាន គឺហេតុដែលពុំមានមូលហេតុនៃការមិនអនុញ្ញាតឱ្យលក់ ដែលត្រូវបានយកធ្វើជាមូលហេតុដើម្បីចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់នោះ ។ មូលហេតុនៃការជំនុំជម្រះសាជាថ្មី អាចយកមកធ្វើជាមូលហេតុនៃបណ្ដឹងជំទាស់បានជានិច្ច ។

(៣) ការសម្រេចសេចក្ដីអំពីបណ្ដឹងជំទាស់ : ដោយសារគេអាចប្ដឹងជំទាស់ដោយពុំចាំបាច់កំណត់ភាគីម្ខាងទៀតបាន តុលាការនៃបណ្ដឹងជំទាស់ អាចកំណត់យកបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ណាម្នាក់ ដែលទំនងជាមានផលប្រយោជន៍ខ្លាំងនៅក្នុងការរក្សាទុកនូវដីកាសម្រេចដើមឱ្យនៅដដែល មកធ្វើជាភាគីម្ខាងទៀត និងឱ្យបុគ្គលនោះ ចូលរួមក្នុងនីតិវិធីនៃការសម្រេចសេចក្ដីអំពីបណ្ដឹងជំទាស់បាន (មាត្រា ៤៤៤ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលនៃការអនុវត្ត ប្ដឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ដោយទាមទារឱ្យលុបចោលដីកាសម្រេចនោះ តុលាការនៃបណ្ដឹងជំទាស់ នឹងកំណត់យកអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាដែលបានទទួលការអនុញ្ញាតឱ្យទិញ មកធ្វើជាភាគីម្ខាងទៀត ជាអាទិ៍ ។ ក្នុងករណីដែលមានបណ្ដឹងជំទាស់ច្រើនចំពោះដីកាសម្រេចតែមួយ រឿងក្ដីទាំងនោះគប្បីរួមបញ្ចូលគ្នា ។ ដីកាសម្រេចទទួលស្គាល់បណ្ដឹងជំទាស់ដែលលុបចោល ឬ ផ្លាស់ប្ដូរដីកាសម្រេចដើម ត្រូវជូនដំណឹងទៅបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ (សូមមើលមាត្រា ៤៤០ និង មាត្រា ៤៤៤) ។

(v) **អានុភាពនៃការលក់ដោយបង្ខំ**

(១) ការបង្កើតទំនាក់ទំនងនៃការលក់ទិញ : នៅពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរហើយ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា នឹងក្លាយទៅជាអ្នកទិញ ហើយទំនាក់ទំនងគតិយុត្ត នឹងកើតមានឡើង រវាងអ្នកទិញ និង កូនបំណុលនៃការអនុវត្ត ដូចគ្នាទៅនឹងការលក់ទិញធម្មតាដែរ ដោយយោងទៅតាមល័ក្ខខ័ណ្ឌនៃការលក់នោះ ។

(ក) ការបង់ថ្លៃលក់ : ដោយមានទំនាក់ទំនងគតិយុត្តដូចខាងលើនេះ អ្នកទិញ មានករណីយកិច្ចត្រូវបង់ថ្លៃលក់ទៅឱ្យតុលាការអនុវត្ត ។ នៅពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរហើយ តុលាការអនុវត្តត្រូវកំណត់ពេលដែលអ្នកទិញត្រូវបង់ប្រាក់ថ្លៃលក់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ (មាត្រា ៤៨៧ កថាខណ្ឌទី ១) ។ ជាគោលការណ៍ ថ្លៃលក់ ត្រូវបង់ជាសាច់ប្រាក់សុទ្ធទាំងអស់ ។ ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ (មាត្រា ៤៨៧ កថាខណ្ឌទី ២) ។ ក្នុងករណីដែលអ្នកទិញ គឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ វិធីដែលហៅថា ការបង់បង្គ្រប់ ត្រូវបានទទួលស្គាល់ថាជាវិធីសាមញ្ញនៃការបង់ថ្លៃលក់ (មាត្រា ៤៨៧ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ប្រសិនបើម្ចាស់បំណុល ដែលមានសិទ្ធិទាមទារចំនួន មួយលានរៀល បានទិញអចលនវត្ថុក្នុងតម្លៃបីលានរៀល នោះជំនួសឱ្យការបង់ប្រាក់បីលានរៀលសិន ហើយទើបទទួលចំណែកមួយលានរៀលមកវិញ ម្ចាស់បំណុលដែលជាអ្នកទិញ អាចបង់តែពីរលានរៀលបាន ដើម្បីបង្គ្រប់ភាពចន្លោះរវាងថ្លៃលក់ និង ចំនួនទឹកប្រាក់ដែលខ្លួនបានទទួលពីការចែកចំណែក ។ ដើម្បីអាចបង់ថ្លៃលក់តាមវិធីសាមញ្ញដូច្នេះបាន អ្នកទិញត្រូវស្នើសុំទៅតុលាការអនុវត្ត ឱ្យបានមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយនៅកាលបរិច្ឆេទនៃការចែកចំណែក ត្រូវបង់បង្គ្រប់ចំនួនទឹកប្រាក់ដែលបានដកទឹកប្រាក់នៃចំណែករបស់ខ្លួនដែលមានចុះទៅក្នុងតារាងចែកចំណែក (មាត្រា ៤៩០ កថាខណ្ឌទី ៤) ។ ម៉្យាងទៀត ដោយសារថាចំនួនទឹកប្រាក់នៃការចែកចំណែកចុងក្រោយ មិនត្រូវបានកំណត់ជាស្ថាពរលុះណាតែបានបញ្ចប់នីតិវិធីនៅកាលបរិច្ឆេទនៃការចែកចំណែកសិន ដូច្នេះ ប្រសិនបើម្ចាស់បំណុលដទៃទៀតថ្លែងតវ៉ា ចំពោះចំនួនទឹកប្រាក់នៃចំណែករបស់អ្នកទិញ (មាត្រា ៤៩១) នោះអ្នកទិញត្រូវបង់ចំនួនទឹកប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់ (មាត្រា ៤៨៧ កថាខណ្ឌទី ៣) ។ នៅក្នុងឧទាហរណ៍ដដែលខាងលើ ឧបមាថាមានម្ចាស់បំណុលណាផ្សេងម្នាក់ ថ្លែងតវ៉ាចំពោះការសរសេរនៅលើតារាងចែកចំណែកថាសិទ្ធិលើបំណុលរបស់អ្នកទិញនោះ មិនមែនមួយលានរៀលទេ គឺតែបីសែនរៀលតែប៉ុណ្ណោះ ហេតុដូច្នេះចំនួនទឹកប្រាក់ នៃចំណែកដែលអ្នកទិញនោះត្រូវបាន ក៏មិនមែនមួយលានរៀលដែរ គឺតែបីសែនរៀលប៉ុណ្ណោះ ។ បើមានការថ្លែងតវ៉ាដូច្នេះ អ្នកទិញ ត្រូវបង់ប្រាក់ចំនួនប្រាំពីរសែនរៀលដែលមានការថ្លែងតវ៉ានោះភ្លាម ទោះបីជាការតវ៉ានោះ មានមូលហេតុត្រឹមត្រូវ ឬ មិនត្រឹមត្រូវក៏ដោយ ។

នៅពេលដែលថ្លៃលក់ត្រូវបានបង់រួចហើយ តុលាការអនុវត្ត ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយជូនដំណឹងទៅម្ចាស់បំណុលដែលនឹងត្រូវទទួលចំណែក ព្រមទាំងកូនបំណុលនៃការអនុវត្ត អំពីកាលបរិច្ឆេទ និង ទីកន្លែងដែលបានកំណត់សម្រាប់ការចែកចំណែកនោះ (មាត្រា ៤៨៨ កថាខណ្ឌទី ១) ។

(ខ) ការមិនបង់ថ្លៃលក់ : ប្រសិនបើអ្នកទិញមិនបង់ថ្លៃលក់ទៅតាមពេលកំណត់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់ នឹងបាត់បង់អានុភាព (មាត្រា ៤៩១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក្នុងករណីនេះ ដូចដែលបានរៀបរាប់ខាងលើនេះរួចហើយ អ្នកទិញមិនអាចទាមទារឱ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជាការធានាលើសំណើទិញបានទេ (មាត្រា ៤៩១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ពេលនោះ តុលាការអនុវត្ត ត្រូវលក់ដោយបង្ខំសាជាថ្មី (មាត្រា ៤៩១ កថាខណ្ឌទី ២) ។ នៅក្នុងការលក់ដោយបង្ខំលើកទីពីរនេះ អ្នកទិញមុនដែលមិនបានបង់ថ្លៃលក់ មិនអាចស្នើសុំទិញ ម្តងទៀតបានទេ (មាត្រា ៤៩១ កថាខណ្ឌទី ៣) ។

(គ) ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ : នៅពេលអ្នកទិញបង់ថ្លៃលក់ កម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរពីកូនបំណុលនៃការអនុវត្ត ទៅឱ្យអ្នកទិញនោះ ។ ពេលនៃការផ្ទេរកម្មសិទ្ធិ គឺពេលបង់ថ្លៃលក់ (មាត្រា ៤៨៧ កថាខណ្ឌទី ៤) ។ ក្រៅពីអចលនវត្ថុ កម្មសិទ្ធិលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ ហើយក្លាយទៅជាផ្នែកមួយនៃអចលនវត្ថុនោះ កម្មសិទ្ធិលើវត្ថុចំណុះ និង សិទ្ធិចំណុះនៃអចលនវត្ថុ ដែលបានទទួលអានុភាពនៃការរឹបអូស ក៏ត្រូវផ្ទេរជាមួយគ្នាដែរ (មាត្រា ៤២១ កថាខណ្ឌទី ១) ។ ប្រសិនបើនៅក្រោយពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ ហើយថ្លៃលក់ក៏ត្រូវបានបង់រួច ស្រាប់តែរកឃើញថា សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ពុំមានអត្ថិភាពទេនោះ ក៏លទ្ធកម្មកម្មសិទ្ធិដោយអ្នកទិញ ពុំទទួលរងការប៉ះពាល់អ្វីដែរ ។ ផ្ទុយទៅវិញ ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនោះ មិនមែនជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តតាំងពីដំបូង នោះអ្នកទិញមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិបានទេ ។ បើទោះបីជានៅក្នុងបញ្ជី បានចុះថាកូនបំណុលនៃការអនុវត្តគឺជាកម្មសិទ្ធិករនៃអចលនវត្ថុនោះ ហើយអ្នកទិញបានជឿលើខ្លឹមសារនោះក៏ដោយ ក៏អ្នកទិញមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិបានដែរ ។ ខុសពីករណីនៃចលនវត្ថុ (មាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណី) ចំពោះអចលនវត្ថុ របបនៃលទ្ធកម្មដោយសុចរិត ពុំត្រូវបានទទួលស្គាល់ទេ ។ ប៉ុន្តែ អ្នកទិញអាចទាមទារឱ្យកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទទួលចំណែក ទទួលខុសត្រូវក្នុងការធានានៅក្នុងការលក់ដោយបង្ខំ ដែលនឹងមានពន្យល់ដូចខាងក្រោមនេះបាន ។

(ឃ) ស្ថានភាពនៃបន្ទុកលើអចលនវត្ថុ : ស្ថានភាពនៃកម្មសិទ្ធិដែលត្រូវធ្វើលទ្ធកម្មដោយអ្នកទិញ ត្រូវកំណត់ទៅតាមល័ក្ខខ័ណ្ឌនៃការលក់ ។ ល័ក្ខខ័ណ្ឌតាមច្បាប់នៃការលក់ ទាក់ទងនឹងការទទួលបន្ត ឬ ការរលត់នូវបន្ទុក គឺដូចអ្វីដែលបានពន្យល់នៅក្នុងចំណុចទី ២ ៣. (ii) (២) ខាងលើ ។ ជាពិសេស ក្នុងករណីដែលតតិយជនណាម្នាក់ មានផលុបភោគដែលបានចុះបញ្ជី ឬ សិទ្ធិអាស្រ័យនៅដោយបានអាស្រ័យនៅជាក់ស្តែងចំពោះអចលនវត្ថុ តាំងពីមុនពេលរឹបអូសសិទ្ធិទាំងនោះ អាចលើកមកតតាំងចំពោះអ្នកទិញអចលនវត្ថុបាន

( មាត្រា ២៥៩ កថាខណ្ឌទី ២ និង មាត្រា ២៧៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី) ។ នៅក្នុងករណីបែបនេះ អ្នកទិញ ទទួលបន្តនូវទំនាក់ទំនងនៃផលុបភោគ និង ទំនាក់ទំនងនៃសិទ្ធិអាស្រ័យនៅ រវាងតតិយជននោះ និង កូនបំណុលនៃការអនុវត្ត ។ អាស្រ័យហេតុនេះហើយ ប្រសិនបើកូនបំណុលនៃការអនុវត្ត មានករណីយកិច្ចត្រូវសងប្រាក់ធានាដើម្បីបង្កើតសិទ្ធិនោះ ទៅឱ្យម្ចាស់ផលុបភោគ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅវិញ នោះអ្នកទិញត្រូវទទួលស្នងនូវករណីយកិច្ចនោះ ។ ម្យ៉ាងទៀត ប្រសិនបើប្រាក់ថ្លៃឈ្នួលត្រូវបានបង់ជាមុនរួចហើយនោះ អ្នកទិញ មិនអាចទាមទារឱ្យម្ចាស់ផលុបភោគ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ បង់ថ្លៃឈ្នួលនោះជាថ្មីបានឡើយ ។ ជាងនេះទៅទៀត ប្រសិនបើកូនបំណុលនៃការអនុវត្ត គឺជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគដែលបន្តមានអត្ថិភាពនៅក្រោយការលក់ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ( មាត្រា ៤៤៥) ។

(២) ម្ចាស់នៃផល និង ផលប្រយោជន៍ដទៃទៀត : ផលធម្មជាតិ និង ផលស៊ីវិលដូចជាថ្លៃឈ្នួល ជាអាទិ៍ នៃអចលនវត្ថុ ត្រូវក្លាយជារបស់អ្នកទិញ ចាប់ពីពេលបង់ប្រាក់ថ្លៃលក់ ។

(៣) ការទទួលខុសត្រូវក្នុងការធានា នៅក្នុងការលក់ដោយបង្ខំ : នៅក្នុងករណីដែលអ្នកទិញមិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិទាំងអស់ ឬ មួយផ្នែកនៃអចលនវត្ថុដែលជាកម្មវត្ថុ ដោយសារមានវិការៈនៃសិទ្ធិនោះ ជាអាទិ៍ អ្នកទិញអាចទាមទាររំលាយការលក់ ឬ ឱ្យបន្ថយថ្លៃលក់ ចំពោះកូនបំណុលនៃការអនុវត្ត និង ទាមទារឱ្យសងចំនួនទឹកប្រាក់ថ្លៃលក់ទាំងអស់ ឬ ចំនួនទឹកប្រាក់ដែលស្មើនឹងភាគដែលបានបន្ថយនោះមកវិញបាន (មាត្រា ៥៣៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ។ ប្រសិនបើកូនបំណុលនៃការអនុវត្ត មិនអាចសងប្រាក់នេះវិញបាន ដោយសារអសាធនភាព នោះអ្នកទិញអាចទាមទារឱ្យម្ចាស់បំណុលដែលបានទទួលចំណែកនៃថ្លៃលក់ សងចំណែកនោះមកវិញបាន ( មាត្រា ៥៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី) ។ ម្យ៉ាងទៀត ប្រសិនបើកូនបំណុលបានដឹងអំពីអត្ថិភាពនៃវិការៈនៃសិទ្ធិនោះ តែមិនបានជូនដំណឹងទៅស្ថាប័នអនុវត្ត ឬ ប្រសិនបើម្ចាស់បំណុលបានដឹងរឿងនោះដែរ តែនៅតែទាមទារឱ្យលក់ដោយបង្ខំទៀត អ្នកទិញអាចទាមទារនូវសំណងនៃការខូចខាតពីអ្នកទាំងនោះបាន ( មាត្រា ៥៣៦ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ។ ផ្ទុយទៅវិញ ប្រសិនបើមានវិការៈកំបាំង នោះពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណីដែលចែងអំពីករណីនេះទេ ។ ហេតុដូច្នេះ គេអាចបកស្រាយបានថា នៅក្នុងករណីនេះ អ្នកទិញមិនអាចទាមទាររំលាយការលក់ ឬ ឱ្យបន្ថយថ្លៃលក់បានទេ ( សូមមើលមាត្រា ៥៣៦ និង មាត្រា ៥៤០ នៃក្រមរដ្ឋប្បវេណី) ។

(៤) ការទទួលបន្ទុកហានិភ័យ នៅក្នុងការលក់ដោយបង្ខំ : ហានិភ័យនៃការបាត់បង់ ឬ ខូចខាត អចលនវត្ថុដែលជាកម្មវត្ថុ ដោយសារហេតុដែលមិនមែនជាកំហុសរបស់អ្នកទិញ និង កូនបំណុលនៃការអនុវត្ត ទាំងសងខាង ត្រូវផ្ទេរជាបន្ទុករបស់អ្នកទិញ ចាប់ពីត្រឹមពេលបង់ប្រាក់ថ្លៃលក់ (ចំពោះគោលការណ៍នៅក្នុងក្រមរដ្ឋប្បវេណី សូមមើលមាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណី) ។

(ក) នៅក្នុងករណីដែលការផ្ទេរអចលនវត្ថុ មិនអាចធ្វើទៅបានដោយសារការវិនាស ឬ ការបាត់បង់អចលនវត្ថុ (ឬ ដោយសារស្ថានភាពផ្សេងទៀត) តុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយឆន្ទានុសិទ្ធិរបស់ខ្លួន (មាត្រា ៤២៧) ។ បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ទោះជាក្នុងករណីដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរហើយក៏ដោយ ។ នៅក្នុងករណីនេះ តុលាការអនុវត្ត ត្រូវលុបចោលដោយឆន្ទានុសិទ្ធិ នូវដីកាសម្រេចអនុញ្ញាតឱ្យលក់ដែលបានចូលជាស្ថាពរ ក៏ដូចជាដីកាសម្រេចចាប់ផ្តើមការលក់ ហើយដោយសារការលុបចោលនេះ ករណីយកិច្ចរបស់អ្នកទិញ នៅក្នុងការបង់ប្រាក់ថ្លៃលក់នឹងត្រូវរលត់ ។

(ខ) ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ ដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកទិញអាចទាមទារឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមវិធីប្តឹងជំទាស់បាន ប្រសិនបើដីកាសម្រេចនោះមិនទាន់ចូលជាស្ថាពរទេ ។ ទោះបីជាដីកាសម្រេចនេះ បានចូលជាស្ថាពរហើយ ក៏អ្នកទិញនៅតែអាចស្នើសុំឱ្យលុបចោលដីកាសម្រេចស្ថាពរនោះបានដែរ បើមិនទាន់បានបង់ប្រាក់ថ្លៃលក់ទេនោះ (មាត្រា ៤៤៥ កថាខណ្ឌទី ១) ។ ការលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់នឹងរំលត់ករណីយកិច្ចបង់ប្រាក់របស់អ្នកទិញ ។ ក៏ប៉ុន្តែ ប្រសិនបើបានបង់ប្រាក់ថ្លៃលក់រួចហើយ អ្នកទិញមិនអាចស្នើសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់បានទេ ។

(៥) ការផ្តុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់ដោយអ្នកទិញ : នៅពេលអ្នកទិញបានបង់ប្រាក់ថ្លៃលក់ហើយ នោះកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុ ត្រូវបានផ្ទេរទៅឱ្យអ្នកទិញនោះ ។ ហេតុនេះហើយក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ពីកូនបំណុលនៃការអនុវត្តទៅឱ្យអ្នកទិញ ។ បន្ថែមពីនេះ ក្រឡាបញ្ជីក៏ត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច លុបចោលការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិផ្សេងៗដែលបានរលត់ដោយសារការលក់ (ការចុះបញ្ជីអំពីសិទ្ធិប្រាតិភោគ ផលុបភោគជាអាទិ៍ ដែលបានរលត់ដោយសារការលក់) ក៏ដូចជាការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ការរឹបអូសនិង ការរឹបអូសជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយសារការលក់ (មាត្រា ៤៤៨ កថាខណ្ឌទី ១) ។ ដើម្បីផ្តុកផ្តាក់ឱ្យចុះបញ្ជីបែបនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្តុកផ្តាក់នោះ (មាត្រា ៤៤៨ កថាខណ្ឌទី ២) ។ សោហ៊ុយចាំបាច់ដើម្បីផ្តុកផ្តាក់ឱ្យចុះបញ្ជី គឺជាបន្ទុករបស់អ្នកទិញ (មាត្រា ៤៤៨ កថាខណ្ឌទី ៣) ។

(៦) ការប្រគល់អចលនវត្ថុ : នៅពេលអ្នកទិញបានបង់ប្រាក់ថ្លៃលក់ និង បានធ្វើលទ្ធកម្មកម្មសិទ្ធិហើយអ្នកទិញនោះ អាចធ្វើការទាមទារឱ្យប្រគល់អចលនវត្ថុ ចំពោះកូនបំណុលនៃការអនុវត្ត ឬ ចំពោះអ្នកកាន់កាប់ដែលពុំមានសិទ្ធិតតាំងចំពោះអ្នកទិញ តាមច្បាប់សារធាតុបាន ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីចែងថា អ្នកទិញដែលបានបង់ថ្លៃលក់គ្រប់ចំនួនហើយ អាចដាក់ពាក្យសុំឱ្យតុលាការអនុវត្ត ចេញដីកាសម្រេច

បង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកកាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះ ទៅឱ្យខ្លួនបាន (ដីកាសម្រេចនេះ ហៅថា ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ) (មាត្រា ៤៥០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ តុលាការអនុវត្ត មិនអាចចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយនឹងអ្នកទិញបាន ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ បានទេ (មាត្រា ៤៥០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ដោយផ្អែកលើដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ ដែលជាលិខិតអនុវត្តមួយដែរ (មាត្រា ៣៥០ កថាខណ្ឌទី ១ ចំណុច គ) អ្នកទិញអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ចំពោះជនដែលត្រូវប្រគល់នោះបាន (មាត្រា ៥២៤) ។ បើហួសអំឡុងពេល ៦ ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញនោះ មិនអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុបានទេ (មាត្រា ៤៥០ កថាខណ្ឌទី ២) ។ ដោយសារថា នេះគឺជាការចាត់ចែងបន្ទាប់បន្សំ នៃនីតិវិធីនៃការលក់ដោយបង្ខំ ទើបបានជាមានការកម្រិតអំឡុងពេលដូច្នេះ ។ នៅពេលដែលអំឡុងពេលប្រាំមួយខែនេះបានកន្លងផុតទៅ អ្នកទិញអាចដាក់ពាក្យបណ្តឹងធម្មតា ដើម្បីទាមទារឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកកាន់កាប់ដែលពុំមានសិទ្ធិតតាំងនឹងអ្នកទិញនេះ ប្រគល់អចលនវត្ថុបាន ព្រោះថា អ្នកទិញនៅតែមានសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុ ចំពោះបុគ្គលទាំងនេះដដែល តាមច្បាប់សារធាតុ ។

របបនៃដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ ត្រូវបានបង្កើតឡើង ដើម្បីបង្កភាពងាយស្រួលដល់អ្នកទិញ ក្នុងការទទួលយកអចលនវត្ថុ នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ។ អ្នកទិញក៏អាចទទួលបាននូវលទ្ធផលបែបនេះដូចគ្នា ដោយការអនុវត្តនូវសិទ្ធិរបស់ខ្លួន តាមច្បាប់សារធាតុ ដើម្បីទាមទារឱ្យប្រគល់ដោយផ្អែកលើកម្មសិទ្ធិ ពោលគឺដោយការដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់ ចំពោះបុគ្គលដែលកំពុងកាន់កាប់អចលនវត្ថុ ហើយទទួលសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដោយការប្រគល់ ។ ក៏ប៉ុន្តែ ដោយសារនីតិវិធីនៃបណ្តឹងទាមទារនូវពេលវេលា និង ការចំណាយច្រើន ទើបបានជាគេគិតថា ការបង្កភាពងាយស្រួលក្នុងការទទួលបាននូវការប្រគល់អចលនវត្ថុ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ នឹងនាំឱ្យមានអ្នកស្នើសុំទិញច្រើន ហើយការលក់ក៏បានថ្លៃទៅតាមនោះផងដែរ ។

អ្នកដែលត្រូវបានបង្គាប់តាមដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ គឺកូនបំណុលនៃការអនុវត្ត និង អ្នកកាន់កាប់ដែលមិនត្រូវបានតុលាការទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយនឹងអ្នកទិញ ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ (មាត្រា ៤៥០ កថាខណ្ឌទី ១) ។ ដើម្បីកំណត់ថា អ្នកកាន់កាប់ មានសិទ្ធិដែលអាចតតាំងនឹងអ្នកទិញ ឬ ពុំមាន ការវិនិច្ឆ័យដោយយោងតែទៅតាមសំណុំរឿង ដូចជារបាយការណ៍ស្តីពីការស្រាវជ្រាវស្ថានភាពបច្ចុប្បន្ន ដែលបានធ្វើដោយអាជ្ញាសាលា ជាអាទិ៍ ជាការគ្រប់គ្រាន់ហើយ ។ តុលាការ មិនចាំបាច់ធ្វើការកំណត់អំពីបញ្ហានេះ ដោយផ្អែកលើ

ភស្តុតាងផ្សេងពីសំណុំរឿងក្ដីនោះទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលបានចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុចំពោះអ្នកកាន់កាប់ក្រៅពីកូនបំណុលនៃការអនុវត្ត តុលាការអនុវត្ត ត្រូវសួរជននោះ (មាត្រា ៤៥០ កថាខណ្ឌទី ៣) ។ ភាគីណាមួយដែលមិនពេញចិត្តនឹងដីកាសម្រេចអំពីពាក្យសុំឱ្យតុលាការបង្គាប់ឱ្យប្រគល់អចលនវត្ថុ អាចដាក់ពាក្យបណ្ដឹងជំទាស់បាន (មាត្រា ៤៥០ កថាខណ្ឌទី ៤) ។ ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ (មាត្រា ៤៥០ កថាខណ្ឌទី ៥) ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលតុលាការមិនបានទទួលស្គាល់តាមសំណុំរឿងថា កាន់កាប់អចលនវត្ថុដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយនឹងអ្នកទិញ ហើយត្រូវបានបង្គាប់ឱ្យប្រគល់អចលនវត្ថុនោះ តែតាមការពិតបុគ្គលនោះមានសិទ្ធិនោះមែន អាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីតទល់នឹងដីកាសម្រេចបង្គាប់ឱ្យប្រគល់នោះបាន ដោយលើកអត្ថិភាពនៃសិទ្ធិនោះ មកអះអាងជាមូលហេតុនៃការតវ៉ានោះ ។

## ៦. ករណីមានការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការទាមទារឱ្យចែកចំណែកច្រើន

### (i) កំណត់សំគាល់ទូទៅ

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក៏មានករណីមួយចំនួនដែរ ដែលអ្នកមានសិទ្ធិទាមទារដែលមានបំណងឱ្យសងជាប្រាក់ មានចំនួនច្រើន ហើយចូលរួមក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំរួមគ្នា ដើម្បីទទួលសំណងពីកម្មវត្ថុនៃការអនុវត្តដោយបង្ខំតែមួយដូចគ្នា ។ ករណីទីមួយ ហៅថា ការអនុវត្តរួម ដែលនៅក្នុងនោះ អ្នកមានសិទ្ធិទាមទារច្រើនគ្នា បានដាក់ពាក្យសុំរួមគ្នា ឱ្យអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុតែមួយ ។ នៅក្នុងករណីនេះ ប្រសិនបើយល់ឃើញថាពាក្យសុំនោះត្រឹមត្រូវ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំតែមួយ ។ ពេលនោះ អ្នកដាក់ពាក្យសុំដែលមានគ្នាច្រើននោះ នឹងក្លាយជាម្ចាស់បំណុលនៃការអនុវត្ត ហើយការអនុវត្តដោយបង្ខំ នឹងត្រូវធ្វើឡើងដូចករណីដែលមានម្ចាស់បំណុលនៃការអនុវត្តតែមួយដែរ ។ ករណីទីពីរ គឺករណីដែលមានអ្នកមានសិទ្ធិទាមទារផ្សេងទៀត បានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុ ដែលមានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បានចេញតាមពាក្យសុំរបស់ម្ចាស់បំណុលមុនទៅហើយ ។ នៅក្នុងករណីនេះ តុលាការអនុវត្ត នឹងចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា ។ ក៏ប៉ុន្តែ តុលាការអនុវត្ត នៅតែត្រូវដឹកនាំនីតិវិធីនៃការលក់ដោយបង្ខំទីមួយ លើកលែងតែមានមូលហេតុនៃការផ្អាក ឬ ការលុបចោលនីតិវិធីនោះ ជាអាទិ៍ ។ ម្ចាស់បំណុលនៅក្នុងនីតិវិធីដែលបានចាប់ផ្ដើមក្រោយ អាចទទួលបានចំណែក នៅក្នុងនីតិវិធីនៃការចែកចំណែកដែរ ។ ករណីទីបី គឺករណីដែលមានអ្នកទាមទារផ្សេងទៀត បានធ្វើការទាមទារឱ្យចែកចំណែក នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ដែលបានចាប់ផ្ដើមតាមពាក្យសុំរបស់អ្នកមានសិទ្ធិទាមទារណាម្នាក់ ។ ករណីទីមួយ បើប្រៀបធៀបទៅនឹងករណីដែលមានម្ចាស់បំណុលតែម្នាក់ គឺសឹងតែដូចគ្នាទាំងស្រុង ដោយខុសតែម៉្យាងថាមួយមានម្ចាស់បំណុលតែម្នាក់ និង មួយទៀតមានម្ចាស់បំណុលច្រើននាក់ តែប៉ុណ្ណោះ ។ ដូច្នេះ ករណីនេះ ពុំមានភាពខុសគ្នាជាពិសេសនោះទេ ។ ហេតុនេះហើយ នៅផ្នែក

ខាងក្រោមនេះ នឹងមានការពន្យល់តែអំពីករណីទីពីរ និង ករណីទីបី ប៉ុណ្ណោះ ។

(ii) **ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា**

(១) ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា : បើមានពាក្យសុំឱ្យអនុវត្តដោយបង្ខំថ្មីទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញរួចហើយ ហើយបើទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីទៀត (មាត្រា ៤២៤ កថាខណ្ឌទី ១) ។ ដីកាសម្រេចចាប់ផ្ដើមទីពីរ ត្រូវប្រកាសអំពីការរឹបអូស ដូចដែលត្រូវធ្វើចំពោះដីកាសម្រេចចាប់ផ្ដើមទូទៅ ហើយត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង ត្រូវឱ្យក្រឡាបញ្ជីផ្ញើផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ។ ក្នុងករណីដែលបានចេញដីកាសម្រេចចាប់ផ្ដើមថ្មីមួយទៀត តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីករណីដែលបានចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានេះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុន (មាត្រា ៤២៤ កថាខណ្ឌទី ១) ។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្ដល់ឱកាសឱ្យម្ចាស់បំណុលដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុន អាចចាត់វិធានការផ្សេងៗ ដូចជាដាក់ពាក្យសុំឱ្យធ្វើការអនុវត្ត ចំពោះទ្រព្យសម្បត្តិផ្សេងទៀត ជាអាទិ៍ ព្រោះថា ចំនួនទឹកប្រាក់នៃចំណែកដែលម្ចាស់បំណុលនេះត្រូវទទួល នឹងទទួលរងការប៉ះពាល់ដោយសារដីកាសម្រេចថ្មីនោះ ។

(២) ដំណើរការនៃនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន និង ការលុបចោលនូវនីតិវិធីនៃការអនុវត្តដោយបង្ខំ ជាអាទិ៍ : ទោះបីជាមានការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នាក៏ដោយក៏តុលាការអនុវត្ត មិនដឹកនាំនីតិវិធីនៃការលក់ដោយបង្ខំ មួយៗដាច់ដោយឡែកពីគ្នាដែរ ពោលគឺតុលាការអនុវត្ត ដំណើរការតែនីតិវិធីដែលផ្អែកលើដីកាសម្រេចចាប់ផ្ដើមទីមួយតែប៉ុណ្ណោះ ។ ប្រសិនបើនីតិវិធីនេះធ្វើដំណើរទៅមុខដោយពុំមានបញ្ហាអ្វី រហូតដល់ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ហើយអ្នកទិញក៏បានបង់ប្រាក់ថ្លៃលក់រួចនោះ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ នឹងបានទទួលចំណែកពីថ្លៃលក់ ប្រសិនបើម្ចាស់បំណុលនោះ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក (មាត្រា ៤៤៣ ចំណុច ក) ។ ក៏ប៉ុន្តែ ប្រសិនបើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានលុបចោល (មាត្រា ៣៧០ កថាខណ្ឌទី ១) នៅពេលដែលនីតិវិធីនៃការអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន មានដំណើរការ តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ (មាត្រា ៤២៤ កថាខណ្ឌទី ២) ។ ក្នុងករណីនេះ ប្រសិនបើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយនោះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដែលត្រូវបានកំណត់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន តុលាការអនុវត្ត ត្រូវកំណត់ពេលចុងក្រោយសម្រាប់

ការទាមទារឱ្យចែកចំណែក សាជាថ្មី ( មាត្រា ៤២៤ កថាខណ្ឌទី ៣) ។

(៣) ការផ្អាកនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន និង ការបន្ដនីតិវិធីនៃការអនុវត្តដោយបង្ខំ : ប្រសិនបើនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានផ្អាក (មាត្រា ៣៧០ កថាខណ្ឌទី ២) តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ (មាត្រា ៤២៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ ប្រសិនបើម្ចាស់បំណុលដែលទទួលបានការជូនដំណឹងនោះ ដាក់ពាក្យសុំឱ្យបន្ដនីតិវិធី តុលាការអនុវត្ត អាចចេញដីកាសម្រេចបន្ដនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមក្រោយ ដែលម្ចាស់បំណុលនោះបានទទួល ហើយនីតិវិធីនៃការលក់ នឹងបន្ដទៅ តាមដីកាសម្រេចបន្ដនោះ (មាត្រា ៤២៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២) ។ ក៏ប៉ុន្តែ បុគ្គលដែលអាចដាក់ពាក្យសុំឱ្យបន្ដនីតិវិធីបាន មានតែម្ចាស់បំណុលដែលបានដាក់ពាក្យសុំនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនៅក្នុងនីតិវិធីមុន តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលការលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានលុបចោល ហើយប្រសិនបើការផ្លាស់ប្ដូរនឹងកើតមានឡើងនៅក្នុងល័ក្ខខ័ណ្ឌនៃការលក់ដែលទាក់ទងទៅនឹងបន្ទុកលើអចលនវត្ថុ នោះដីកាសម្រេចបន្ដនីតិវិធី មិនអាចចេញបានទេ ( មាត្រា ៤២៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ៣) ។ ឧទាហរណ៍ ប្រសិនបើមានផលុបភោគមួយត្រូវបានបង្កើតឡើង នៅក្រោយការចុះបញ្ជីអំពីការរឹបអូសទីមួយ និង នៅមុនការចុះបញ្ជីអំពីការរឹបអូសទីពីរ ផលុបភោគនោះ មិនអាចតតាំងជាមួយនឹងការរឹបអូសតាមដីកាសម្រេចចាប់ផ្ដើមទីមួយបានទេ តែអាចតតាំងជាមួយនឹងការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមទីពីរបាន ។ ហេតុនេះហើយ ប្រសិនបើអចលនវត្ថុ ត្រូវបានលក់ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមទីមួយ ផលុបភោគនោះ នឹងត្រូវរលត់ ។ ក៏ប៉ុន្តែ ប្រសិនបើអចលនវត្ថុ ត្រូវបានលក់ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមទីពីរ ផលុបភោគនោះ នឹងបន្ដអត្ថិភាព ហើយនឹងត្រូវបានទទួលយកដោយអ្នកទិញ ។ ដោយសារថា នីតិវិធីដែលផ្អែកលើដីកាសម្រេចចាប់ផ្ដើមទីមួយ គ្រាន់តែត្រូវបានផ្អាកប៉ុណ្ណោះ ប្រសិនបើនីតិវិធីនេះបន្ដឡើងវិញ ការលក់នឹងត្រូវធ្វើឡើងជាមួយនឹងល័ក្ខខ័ណ្ឌដែលថា ផលុបភោគនោះ ត្រូវរលត់ ។ ក៏ប៉ុន្តែ ប្រសិនបើនីតិវិធីទីមួយនោះ ត្រូវបានលុបចោលនាពេលក្រោយមក គេអាចនិយាយបានថា ការលក់នេះ ត្រូវបានធ្វើឡើងដោយខុសនឹងល័ក្ខខ័ណ្ឌ ។

(៤) ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ : ក្នុងករណីដែលមានពាក្យសុំឱ្យលក់ដោយបង្ខំ ដែលជាការអនុវត្តដែលមានគោលបំណងឱ្យសងជាប្រាក់ ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញរួចហើយ តុលាការអនុវត្ត នឹងចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នាដែរ (មាត្រា ៤២៤ កថាខណ្ឌទី ១ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយមាត្រា ៤២៥) ។ ចំពោះការបន្ដនីតិវិធីនៅក្រោយពេលមានដីកាសម្រេច

ចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា និង ចំពោះការបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ ក្នុងករណីដែលនីតិវិធីមុន ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ បានបាត់បង់សុពលភាពដោយសារការដកពាក្យសុំមុន ឬ ត្រូវបានលុបចោល ហើយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ត្រូវកំណត់សាជាថ្មីដែរ នោះការកំណត់ដែលមានពន្យល់ក្នុងចំណុចទី (២) ខាងលើ ត្រូវយកមកអនុវត្តដូចគ្នា (មាត្រា ៤២៤ កថាខណ្ឌទី ២ និង ទី ៣ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយមាត្រា ៤២៥) ។ ក៏ប៉ុន្តែ ដោយសារមាត្រា ៤២៤ កថាខណ្ឌទី ៤ មិនត្រូវបានយកមកអនុវត្តដូចគ្នានោះ ប្រសិនបើនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគត្រូវបានផ្អាក តុលាការអនុវត្តមិនអាចបន្តនីតិវិធីនៃការលក់ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមក្រោយបានទេ ។ ហេតុនេះហើយ គេពុំមានជម្រើសអ្វីផ្សេងក្រៅពីត្រូវរង់ចាំឱ្យនីតិវិធីមុន ត្រូវបានលុបចោលសិន ឬ ឱ្យការផ្អាកត្រូវបានលុបចោល ហើយនីតិវិធីត្រូវបានបន្តឡើងវិញសិន ។

### (iii) **ការទាមទារឱ្យចែកចំណែក**

(១) វិសាលភាពនៃម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែក : នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក៏ច្បាប់អនុញ្ញាតឱ្យម្ចាស់បំណុលដទៃ អាចធ្វើការទាមទារឱ្យចែកចំណែកបានដែរ ។ ក៏ប៉ុន្តែម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែកបាន ត្រូវបានកម្រិតត្រឹមតែម្ចាស់បំណុលដូចតទៅនេះប៉ុណ្ណោះ ដើម្បីជៀសវាងការមិនគោរពតាមគោលការណ៍សមភាព :

①ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត (មាត្រា ៤២៦ កថាខណ្ឌទី ១ ចំណុច ក) : មូលហេតុនៃការទទួលស្គាល់ចំពោះម្ចាស់បំណុលទាំងនេះ នូវលក្ខណសម្បត្តិដែលអាចធ្វើការទាមទារឱ្យចែកចំណែកបាន គឺដោយសារម្ចាស់បំណុលទាំងនេះ ជាបុគ្គលដែលបានព្យាយាមប្រឹងប្រែងដើម្បីទទួលបានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយម្ចាស់បំណុលទាំងនោះ អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីទទួលបានដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា និង ដើម្បីទទួលបានចំណែក នៅពេលណាក៏បាន ។ ហេតុនេះហើយ វាជារឿងធម្មតាដែលពួកគេអាចទាមទារឱ្យចែកចំណែកបានដោយពុំចាំបាច់ដាក់ពាក្យសុំឱ្យលក់ដោយបង្ខំត្រួតគ្នា ។ ក៏ប៉ុន្តែ ម្ចាស់បំណុល ដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលនៅតែបន្តអត្ថិភាព នៅក្រោយការលក់អចលនវត្ថុ ដោយយោងទៅតាមល័ក្ខខ័ណ្ឌនៃការលក់ មិនអាចទាមទារឱ្យចែកចំណែកបានទេ បើទោះបីជាម្ចាស់បំណុលទាំងនោះ មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ក៏ដោយ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា បើឱ្យម្ចាស់បំណុលទាំងនេះទទួលបានចំណែក ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាផង ហើយម្យ៉ាងទៀត អាចបន្តអត្ថិភាពនៃសិទ្ធិប្រាតិភោគផងនោះ វានឹងធ្វើឱ្យការប្រព្រឹត្តចំពោះម្ចាស់បំណុលនីមួយៗ មានភាពមិនស្មើគ្នា ហើយវាក៏នឹងនាំឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្តផងដែរ ។ ប្រសិនបើម្ចាស់បំណុលទាំងនេះចង់បានទទួលការចែកចំណែក ពួកគេត្រូវដាក់ពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិប្រាតិភោគ ដោយខ្លួនឯង (សូមមើល

មាត្រា ៤២២ កថាខណ្ឌទី ២ ចំណុច ខ និង កថាខណ្ឌទី ៣) ។

② ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ (មាត្រា ៤២៦ កថាខណ្ឌទី ១ ចំណុច ខ) : មូលហេតុនៃការទទួលស្គាល់ចំពោះម្ចាស់បំណុលទាំងនេះ នូវលក្ខណសម្បត្តិដែលអាចធ្វើការទាមទារឱ្យចែកចំណែកបាន គឺដោយសារម្ចាស់បំណុលទាំងនេះ ជាបុគ្គលដែលបានព្យាយាមប្រឹងប្រែងដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បើទោះបីជាពួកគេពុំមានលិខិតអនុវត្តក៏ដោយ និង បានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីអត្ថិភាពនៃសិទ្ធិទាមទារដែលជាសិទ្ធិដែលត្រូវបានរក្សាការពាររបស់ខ្លួន ដែលជាបុរេល័ក្ខខ័ណ្ឌដើម្បីទទួលនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយសិទ្ធិនោះ ត្រូវបានទទួលស្គាល់ដោយតុលាការ (មាត្រា ៥៤១ កថាខណ្ឌទី ៣) ។ មូលហេតុដែលម្ចាស់បំណុលទាំងនេះ ត្រូវបានកម្រិតត្រឹមតែម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ព្រោះថា ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនពេលចុះបញ្ជីអំពីការរឹបអូស អាចទទួលបានចំណែក ដោយមិនចាំបាច់ធ្វើការទាមទារឱ្យចែកចំណែក (សូមមើលមាត្រា ៤២២ កថាខណ្ឌទី ២ ចំណុច ក និង មាត្រា ៤៥៣ ចំណុច គ) ។

③ ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ (មាត្រា ៤២៦ កថាខណ្ឌទី ១ ចំណុច គ) : ដោយសារម្ចាស់បំណុលទាំងនេះ មានសិទ្ធិអាទិភាពលើម្ចាស់បំណុលទូទៅ តាមច្បាប់សារធាតុ ដូច្នេះទើបច្បាប់ទទួលស្គាល់នូវលក្ខណសម្បត្តិដែលអាចទាមទារឱ្យចែកចំណែកបាន ដើម្បីផ្ដល់ឱកាសឱ្យម្ចាស់បំណុលទាំងនោះ អាចអនុវត្តនូវឯកសិទ្ធិរបស់ខ្លួន នៅក្នុងការលក់ដោយបង្ខំនូវអចលនវត្ថុ ដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលដទៃទៀត ។

(២) អំឡុងពេលដែលអាចធ្វើការទាមទារឱ្យចែកចំណែកបាន : តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ (មាត្រា ៤២២ កថាខណ្ឌទី ១) ។ បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេលបីខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្ដូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន (មាត្រា ៤២២ កថាខណ្ឌទី ៤) ។

(៣) នីតិវិធី : ម្ចាស់បំណុល ត្រូវដាក់ការទាមទារឱ្យចែកចំណែកជាលាយលក្ខណ៍អក្សរ ដែលមានសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល (ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត) (មាត្រា ៤២៦ កថាខណ្ឌទី ២) ។ បើមានការទាមទារឱ្យចែកចំណែកដូច្នេះ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត (មាត្រា ៤២៦ កថាខណ្ឌទី ៣) ។ បុគ្គលដែលទាមទារឱ្យចែកចំណែក អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែកបាន (មាត្រា ៤២៦ កថាខណ្ឌទី ៤) ។

## កថាភាគទី ៥ ការអនុវត្តដោយបង្ខំចំពោះនាវា

### (i) អត្ថន័យនៃនាវា

នៅក្នុងគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) និង គន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នាវា សំដៅទៅលើ ជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ តោន និង ជលយានដែលមានចំណុះសរុប ជាតោន ក្រោម ២០ តោន ហើយដែលបានចុះបញ្ជីទៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៤៥៤ កថាខណ្ឌទី ១) ។ ចំពោះជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ តោន នោះទោះបីជាមិនត្រូវបាន ចុះបញ្ជីក៏ដោយ ក៏ចាត់ទុកថាជានាវាក្នុងន័យក្រមនីតិវិធីរដ្ឋប្បវេណីដែរ ។ ចំណុះសរុបជាតោន ដែលអក្សរកាត់ជា ភាសាអង់គ្លេស ហៅថា GT (Gross Tonnage) គឺជារង្វាស់ទំហំនៃនាវា ដែលគេប្រើច្រើនបំផុត នាពេល បច្ចុប្បន្ននេះ ។ គេអាចរកឃើញចំណុះសរុបជាតោន តាមរូបមន្តនៃការគណនាជាក់លាក់មួយ ដោយយករង្វាស់ សរុបនៃផ្ទៃក្នុងទាំងអស់របស់នាវាមកគិត ។ រង្វាស់មួយតោន មានទំហំប្រហែលជា មួយរយហ្វ៊ីតគូប ។ ម៉្យាងទៀត ជលយាន ដែលជាទូក "ចែវ" ឬ "អុំ" មិនត្រូវបានរាប់ជានាវាតាមន័យច្បាប់នេះទេ គឺត្រូវរាប់ជា ចលនវត្ថុ ដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ (បញ្ញត្តិចាប់ពីមាត្រា ៣៨៤) ។ ចំពោះនាវាដែលកំពុងស្ថិតក្នុងការសាងសង់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ។ ប្រដាប់ឧបករណ៍ទាំងឡាយដែលមានភ្ជាប់ជាមួយនឹងនាវា ត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូស តែក្នុងករណីដែល ឧបករណ៍ទាំងនោះត្រូវបានរឹបអូសជាមួយគ្នានឹងនាវាដែរ ។

តាមក្រមរដ្ឋប្បវេណី នាវាគឺជាចលនវត្ថុ ។ ក៏ប៉ុន្តែ ដោយសារវាមានតម្លៃប្រហាក់ប្រហែលនឹងអចលនវត្ថុ ដែរ ហើយម៉្យាងទៀត លទ្ធកម្ម ការបាត់បង់ ឬ ការផ្លាស់ប្តូរនូវកម្មសិទ្ធិលើនាវា ដែលធ្វើឡើងតាមការចុះបញ្ជី ត្រូវតែប្រកាសជាសាធារណៈ ដូច្នេះ ចំពោះបច្ចេកទេសនៅក្នុងការអនុវត្តដោយបង្ខំ គេចាំបាច់ត្រូវយកវិធាន ទូទៅសម្រាប់ការអនុវត្តចំពោះអចលនវត្ថុ មកអនុវត្តឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ហេតុនេះហើយ បានជានៅក្នុងបញ្ញត្តិច្បាប់ស្តីពីការអនុវត្តដោយបង្ខំ នាវាមិនត្រូវបានចាត់ទុកថាជាចលនវត្ថុទេ តែជាអ្វីដែល មានលក្ខណៈដូចអចលនវត្ថុទៅវិញ ។

នាវាដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះនាវា នៅទីនេះ សំដៅទៅលើនាវាដែលមានរចនាសម្ព័ន្ធ ជាក់លាក់មួយ និង ដែលមានសមត្ថភាពអាចធ្វើដំណើរតាមផ្លូវទឹក ដើម្បីដឹកអ្នកដំណើរ ឬ វត្ថុផ្សេងៗ បាន ។ នៅក្នុងករណីនេះ ពាក្យថា ទឹក រួមបញ្ចូលទាំង លើទឹក និង ក្នុងទឹក ។ កប៉ាល់ hovercraft (ប្រើក្តោង) និង hydrofoil គឺសុទ្ធតែជានាវា ។ ដោយឡែក ក្បូន មិនមែនជានាវាទេ ព្រោះគោលបំណងរបស់វា គឺគ្រាន់តែ ដើម្បីដឹកឈើដែលចងជាក្បូននោះតែប៉ុណ្ណោះ ។ ថ្វីត្បិតថាវាមានរូបរាងដូចជានាវាក៏ដោយ ក៏គេមិនអាច និយាយថា នាវាពន្លឺ ឃ្លាំងទំនិញនៅលើទឹក ផ្ទះបណ្តែតទឹក ជាអាទិ៍ គឺជានាវាដែរ ព្រោះវត្ថុទាំងនេះ មិនត្រូវបាន ធ្វើឡើងដើម្បីធ្វើដំណើរទៅណាឆ្ងាយនោះទេ ។ ចំពោះកប៉ាល់ទេសចរណ៍ដែលធ្វើចលនានៅលើផ្លូវដែកដែលគេ

ក្រោលនៅបាតបឹង ក៏មិនមែនជានាវាដែរ ។

សញ្ជាតិរបស់នាវា ពុំចោទជាបញ្ហាអ្វីនោះទេ ។ ចំពោះនាវាដែលដាក់ទង់ជាតិដើម្បីបង្កភាពងាយស្រួល (flag-of-convenience vessels) ពោលគឺនាវាដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ម្ចាស់នាវានោះ (ដូចជា ប៉ាណាម៉ា លីបេរី ជាដើម) (ដើម្បីឱ្យមានភាពងាយស្រួលក្នុងការបង់ពន្ធ) ឱ្យតែនាវានោះ មានទីតាំងនៅក្នុងវង្វង់អធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា ការអនុវត្តដោយបង្ខំ អាចធ្វើឡើងចំពោះនាវានោះបាន ។ ទោះជាយ៉ាងណាក៏ដោយ ល័ក្ខខ័ណ្ឌដើម្បីក្លាយជានាវារបស់កម្ពុជា ត្រូវកំណត់តាមច្បាប់ដោយឡែក ។ ចំពោះល័ក្ខខ័ណ្ឌដើម្បីទទួលបាននូវសញ្ជាតិរបស់នាវា ប្រទេសនីមួយៗ មានការកំណត់ផ្សេងៗពីគ្នា ដោយបូកផ្សំនូវលក្ខណៈមួយចំនួនដូចជា កម្មសិទ្ធិរបស់ពលរដ្ឋនៃប្រទេសខ្លួន ការផលិតដោយពលរដ្ឋនៃប្រទេសខ្លួន និង យានិកជាពលរដ្ឋនៃប្រទេសខ្លួន ជាអាទិ៍ ។ ប្រទេសជប៉ុន តម្រូវឱ្យមានលក្ខណសម្បត្តិតែមួយប៉ុណ្ណោះ គឺកម្មសិទ្ធិរបស់ពលរដ្ឋនៃប្រទេសខ្លួន (មាត្រា ១ នៃច្បាប់នាវាជប៉ុន) ។ ម្យ៉ាងទៀត នៅក្រោយពេលដែលម្ចាស់នាវាជប៉ុន បានកំណត់កំពង់ផែលំនៅរបស់ខ្លួន (មាត្រា ៤ នៃច្បាប់នាវាជប៉ុន) បានចុះបញ្ជី (មាត្រា ៦៨៦ នៃក្រមពាណិជ្ជកម្មជប៉ុន) និង បានចុះឈ្មោះ (មាត្រា ៥ កថាខណ្ឌទី ១ នៃច្បាប់នាវាជប៉ុន) រួចហើយ ម្ចាស់នាវាទាំងនោះ នឹងទទួលបានលិខិតបញ្ជាក់អំពីសញ្ជាតិនៃនាវារបស់ពួកគេ (មាត្រា ៥ កថាខណ្ឌទី ២ នៃច្បាប់នាវាជប៉ុន និង មាត្រា ៣០ នៃបទប្បញ្ញត្តិលម្អិតស្តីពីការអនុវត្តច្បាប់នាវាជប៉ុន) ។ ការកំណត់អំពីការទទួលសញ្ជាតិនាវារបស់កម្ពុជា នឹងធ្វើឱ្យគេអាចបែងចែករវាងនាវាកម្ពុជា និង នាវាបរទេសបាន ។

### (ii) វិធីអនុវត្ត

ការអនុវត្តដោយបង្ខំចំពោះនាវា ជាមូលដ្ឋាន ត្រូវធ្វើឡើងតាមវិធីដែលស្របទៅតាមវិធីលក់ដោយបង្ខំនៃអចលនវត្ថុ ពោលគឺធ្វើឡើងតាមរយៈការលក់ដោយបង្ខំនូវនាវាដែលជាកម្មវត្ថុ (មាត្រា ៤៥៥ កថាខណ្ឌទី ១) ។ ការគ្រប់គ្រងដោយបង្ខំ មិនអាចធ្វើឡើងបានឡើយ ហើយតាមច្បាប់របស់ប្រទេសជប៉ុន ការគ្រប់គ្រងដោយបង្ខំនៅពេលធ្វើការអនុវត្តចំពោះនាវា ក៏មិនត្រូវបានអនុញ្ញាតដែរ ។ នេះគឺដើម្បីធានាដល់ផលប្រយោជន៍នៃការដឹកជញ្ជូន ។ នៅក្នុងច្បាប់បរទេសមួយចំនួន (ដូចជាតាមមាត្រា ១៦៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការគ្រប់គ្រងដោយបង្ខំនៅក្នុងការលក់ដោយបង្ខំរបស់ប្រទេសអាល្លឺម៉ង់) ការគ្រប់គ្រងដោយបង្ខំ អាចធ្វើទៅបានតាមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួន ។

### (iii) ស្ថាប័នអនុវត្ត

ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ។ ចំពោះការអនុវត្តដោយបង្ខំចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត (មាត្រា ៤៥៦) ។

(iv) **នីតិវិធីនៃការអនុវត្ត**

ជាទូទៅ នីតិវិធីនៃការលក់ដោយបង្ខំនៃនាវា ត្រូវធ្វើឡើង ដោយអនុលោមទៅតាមនីតិវិធីប្រហាក់ប្រហែលគ្នានឹងនីតិវិធីលក់ដោយបង្ខំនៃអចលនវត្ថុ ។ ខាងក្រោមនេះ យើងសូមធ្វើការពន្យល់តែអំពីចំណុចពិសេសនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវាប៉ុណ្ណោះ ។

(១) ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង ឯកសារភ្ជាប់ (មាត្រា ៤៥៥) : នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្រៅពីសរសេរចំណុចនីមួយៗដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរអំពីទីកន្លែងដែលនាវានោះស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវានោះ និងទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនោះ នៅនាពេលបច្ចុប្បន្ន (មាត្រា ៤៥៥ កថាខណ្ឌទី ២) ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជាមួយនឹងពាក្យសុំ នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តរួមនឹងឯកសារដែលបានកំណត់មួយចំនួនទៀត ។ ឯកសារដែលបានកំណត់នោះ គឺ ឯកសារចម្លងនៃសៀវភៅចុះបញ្ជីដែលមានសេចក្តីបញ្ជាក់ ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជី និង ឯកសារដែលបញ្ជាក់ថា នាវានោះជានាវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤៥៤ (អត្ថន័យនៃនាវា ជាអាទិ៍) និង ឯកសារបញ្ជាក់ថានាវានោះស្ថិតនៅជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ចំពោះនាវាកម្ពុជាដែលមិនបានចុះបញ្ជី ឬ នាវាផ្សេងទៀតក្រៅពីនាវាកម្ពុជា ។

(២) ការរឹបអូស : (ក) ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ : ដើម្បីចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតដែលចាំបាច់សម្រាប់ការធ្វើចរាចរណ៍ដោយស្របច្បាប់ ដូចជា លិខិតបញ្ជាក់សញ្ជាតិនាវានោះជាអាទិ៍ (ឧទាហរណ៍ លិខិតបញ្ជាក់សញ្ជាតិនាវា លិខិតអនុញ្ញាតឱ្យធ្វើចរាចរណ៍ សៀវភៅកំណត់ហេតុរបស់បរិបាលនាវា លិខិតបញ្ជាក់អំពីការត្រួតពិនិត្យនាវា បញ្ជីឈ្មោះយានិក ជាអាទិ៍) មកប្រគល់ជូនតុលាការអនុវត្ត (មាត្រា ៤៥៧ កថាខណ្ឌទី ១) ។ នៅក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវប្រកាសអំពីការរឹបអូសនាវានោះជាផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ចំពោះការចេញដំណើរនៃនាវានោះ (មាត្រា ៤៥៧ កថាខណ្ឌទី ២) ។ ដីកាសម្រេចចាប់ផ្តើមនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤៥៧ កថាខណ្ឌទី ៣) ។ បើបានចេញដីកាសម្រេចចាប់ផ្តើម ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជីហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះ ជាបន្ទាន់ (មាត្រា ៤៥៧ កថាខណ្ឌទី ៤) ។

(ខ) ការដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ : ដូចបានពោលខាងលើ ដើម្បីចាប់ផ្តើម

ការអនុវត្តដោយបង្ខំចំពោះនាវា តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ មកប្រគល់ជូនតុលាការអនុវត្ត ។ ការដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា គឺជាវិធីដែលអាចរក្សាទុកយ៉ាងជាក់ស្ដែងនូវនាវា នៅនឹងកន្លែងរឹបអូស ។ ប្រសិនបើអាជ្ញាសាលា ពុំអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅក្នុងអំឡុងពេលពីរសប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំបានទេ តុលាការអនុវត្ត ត្រូវលុបចោលនូវនីតិវិធីលក់ដោយបង្ខំនោះ ( មាត្រា ៤៦៤) ។ ក្នុងគោលបំណងប្ដូរជាប្រាក់ នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ការឃាត់ទុកនូវនាវានោះ គឺជាការចាំបាច់ ។ ដូច្នេះ បើមិនអាចបញ្ចប់វិធានការខាងលើ នៅក្នុងអំឡុងពេលពីរសប្ដាហ៍បានទេ នោះត្រូវលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវា ។

( គ) ពេលដែលការរឹបអូសបង្កើតអានុភាព : ជាគោលការណ៍ អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលបានធ្វើការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ទៅឱ្យកូនបំណុលនៃការអនុវត្ត ( មាត្រា ៤៥៧ កថាខណ្ឌទី ៥ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើមុនការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ អានុភាពនោះ នឹងកើតឡើងនៅពេលបានចុះបញ្ជី ( មាត្រា ៤៥៧ កថាខណ្ឌទី ៥ វាក្យខណ្ឌទី ២) ។ ម៉្យាងទៀត បើអាជ្ញាសាលាបានដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ឬ នៅមុនពេលចុះបញ្ជីអំពីការរឹបអូស អានុភាពនៃការរឹបអូសនេះ កើតឡើងនៅពេលដកហូត ( មាត្រា ៤៥៧ កថាខណ្ឌទី ៦) ។

( ឃ) ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ : ក្នុងករណីដែលមានការបារម្ភថា នឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំចំពោះនាវា បើមិនដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទិ៍ នៅមុនការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវាទេ សាលាដំបូង អាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ តាមពាក្យសុំបាន ( មាត្រា ៤៥៩ កថាខណ្ឌទី ១) ។ ដើម្បីដាក់ពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង្ហាញឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង អំពីមូលហេតុដែលធ្វើឱ្យដីកាសម្រេចបង្គាប់ឱ្យប្រគល់នេះ មានភាពចាំបាច់ នៅមុនពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ( មាត្រា ៤៥៩ កថាខណ្ឌទី ២) ។ នៅក្នុងអំឡុងពេលពីរសប្ដាហ៍ គិតចាប់ពីពេលបានទទួលការជូនដំណឹងអំពីដីកាសម្រេចបង្គាប់ឱ្យប្រគល់ ម្ចាស់បំណុលនៃការអនុវត្ត អាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ( មាត្រា ៥២៥) ចំពោះកូនបំណុលនៃការអនុវត្ត ដោយយកដីកាសម្រេចបង្គាប់ឱ្យប្រគល់នោះ ធ្វើជាលិខិតអនុវត្ត ( មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ) ( មាត្រា ៤៥៩ កថាខណ្ឌទី ៦) ។ អាជ្ញាសាលា ជាអ្នករក្សាទុកនូវលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។ ក៏ប៉ុន្តែ ប្រសិនបើ

ម្ចាស់បំណុលនៃការអនុវត្ត មិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុងពេលប្រាំថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍នោះទេ អាជ្ញាសាលាត្រូវប្រគល់វិញនូវលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤៥៩ កថាខណ្ឌទី ៧) ។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុងពេលប្រាំថ្ងៃនេះ ហើយតុលាការបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ អាជ្ញាសាលានឹងដាក់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នោះ ជូនទៅតុលាការអនុវត្ត ហើយនីតិវិធីនៃការលក់ដោយបង្ខំ នឹងចាប់ផ្តើមឡើង ។

(ង) ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍ : នៅពេលបានដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នាវាដែលបានរឹបអូសនោះ មិនអាចធ្វើចរាចរណ៍បានទេ ហើយគេនឹងអាចរក្សាទុកនាវានោះ នៅក្នុងការថែរក្សាគ្រប់គ្រងមួយដើម្បីជាផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។ ក៏ប៉ុន្តែ ប្រសិនបើមានភាពចាំបាច់ក្នុងការដកការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ដើម្បីថែរក្សាគ្រប់គ្រងនាវានោះឱ្យបានត្រឹមត្រូវ តុលាការអនុវត្ត អាចជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងនាវានោះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន (មាត្រា ៤៦០ កថាខណ្ឌទី ១) ។ អ្នកថែរក្សាគ្រប់គ្រង ត្រូវទទួលខុសត្រូវក្នុងការបំពេញមុខនាទីរបស់ខ្លួនដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ហើយអាចទទួលជាមុន នូវសោហ៊ុយចាំបាច់ក្នុងការថែរក្សាគ្រប់គ្រង និង ប្រាក់បំណាច់ដែលកំណត់ដោយដីកាសម្រេចរបស់តុលាការអនុវត្តបាន ។ សោហ៊ុយសម្រាប់ការថែរក្សាគ្រប់គ្រងនាវា និង ប្រាក់បំណាចសម្រាប់អ្នកថែរក្សាគ្រប់គ្រង ត្រូវចាត់ជាសោហ៊ុយសម្រាប់នីតិវិធី (មាត្រា ៤៦០ កថាខណ្ឌទី ២ និង ទី ៣) ។

(ច) ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា : ក្នុងករណីដែលលិខិតផ្អាកការអនុវត្តដោយបង្ខំ (ចំណុចទីមួយ១ក្នុងមាត្រា ៣៧០ កថាខណ្ឌទី ២) ចំពោះសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបានដាក់មក ប្រសិនបើនាវាត្រូវបានដាក់ក្នុងការរក្សាគ្រប់គ្រងដោយគ្មានកំណត់នោះ អាចមានការបារម្ភថា កូនបំណុលនៃការអនុវត្ត នឹងត្រូវទទួលខុសត្រូវ ក្នុងការសងសំណងនៃការខូចខាតដែលកើតចេញពីការមិនអនុវត្តកិច្ចសន្យាដឹកជញ្ជូន ដែលនឹងនាំឱ្យកូនបំណុលនោះ ទទួលរងនូវការខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដោយសារតែនាវាមិនអាចធ្វើចរាចរណ៍បាន ។ ហេតុនេះហើយ ក្នុងករណីបែបនេះ ប្រសិនបើកូនបំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានាដែលស្មើនឹងចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្ត ត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ លើកលែងតែនីតិវិធីនៃការចែកចំណែកចេញ (មាត្រា ៤៦១ កថាខណ្ឌទី ១) ។ នេះគឺជាបញ្ញត្តិដែលទទួលស្គាល់ឱ្យមានការប្តូរកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ពីនាវា មកជាប្រាក់ធានាវិញ

ក៏ដូចជាការលើកលែងនាវានោះ ចេញពីការរឹបអូសផងដែរ ។ ក៏ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើកាលបរិច្ឆេទនៃការលក់ត្រូវបានធ្វើរួច ព្រមទាំងមានសំណើសុំទិញដែរហើយនោះ ។ ម្យ៉ាងទៀត ទោះបីជានីតិវិធីនៃការលក់ដោយបង្ខំ ត្រូវបានលុបចោលក៏ដោយ ក៏នីតិវិធីនៃការចែកចំណែក នៅតែបន្តដែរ ហើយប្រសិនបើការផ្អាកការអនុវត្តដោយបង្ខំ បាត់បង់អានុភាព ចំពោះសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្ត នោះនីតិវិធីនៃការចែកចំណែក នឹងត្រូវធ្វើឡើង (មាត្រា ៤៦១ កថាខណ្ឌទី ២) ។ កូនបំណុលនៃការអនុវត្ត អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំនេះបាន (មាត្រា ៤៦១ កថាខណ្ឌ ទី ៣) ។

(ឆ) ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ : ដូចបានពន្យល់នៅចំណុច (ច) ខាងលើ ប្រសិនបើនាវាត្រូវបានរឹបអូស វាអាចនឹងមានការបារម្ភថា កូនបំណុលនៃការអនុវត្ត នឹងមិនអាចអនុវត្តកិច្ចសន្យាដឹកជញ្ជូនបាន ហើយនឹងទទួលរងនូវការខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរផ្សេងទៀត ដូចជាការខាតបង់នៅក្នុងអាជីវកម្ម ជាអាទិ៍ ។ ហេតុនេះហើយបានជាច្បាប់ចែងថា តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត តុលាការអនុវត្ត អាចអនុញ្ញាតឱ្យនាវាធ្វើដំណើរបាន បើមានការយល់ព្រមពីម្ចាស់បំណុលនីមួយៗ ដូចជាម្ចាស់បំណុលនៃការអនុវត្ត និង ម្ចាស់បំណុលដែលអាចនឹងទទួលបានចំណែកពីថ្លៃលក់ និង អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ (មាត្រា ៤៦២) ។ ក៏ប៉ុន្តែ ករណីនេះ ទាមទារឱ្យមានភាពចាំបាច់សម្រាប់អាជីវកម្ម ឬ មូលហេតុសមរម្យផ្សេងទៀត ។

(ជ) ការផ្ទេររឿងក្តី : ប្រសិនបើនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បែរជាស្ថិតនៅទីកន្លែងផ្សេងក្រៅពីតំបន់ដែលមានសមត្ថកិច្ច តុលាការអនុវត្ត អាចផ្ទេររឿងក្តីនោះ ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅបាន (មាត្រា ៤៦៣) ។ ដីកាសម្រេចផ្ទេររឿងក្តីអាចចេញបាន នៅក្នុងករណីដែលនាវាធ្វើបំលាស់ទីដើម្បីជៀសចេញពីការគ្រប់គ្រងថែរក្សា ក៏ដូចជាករណីដែលនាវាបានធ្វើដំណើរដោយខុសច្បាប់ បន្ទាប់ពីមានការដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។ សូមកត់ចំណាំថា ការផ្ទេររឿងក្តី អាចធ្វើទៅបាន នៅក្នុងករណីដែលនាវាត្រូវបានគេឃើញថាស្ថិតនៅទីកន្លែងផ្សេងក្រៅពីវង្វង់សមត្ថកិច្ចនៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

(ឈ) ម្ចាស់បំណុលដែលមានសិទ្ធិអាចទាមទារឱ្យចែកចំណែកបាន : វិសាលភាពនៃម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែកបាន ជាមូលដ្ឋាន ត្រូវបានកំណត់ ដោយស្របទៅតាមករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ (មាត្រា ៤៨៥ កថាខណ្ឌទី ១ ចំណុច ក ដល់ចំណុច ឃ) ។ ក៏ប៉ុន្តែ ចំណុចដែលប្លែកនៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា គឺម្ចាស់បំណុលដែលមានឯកសារបញ្ជាក់អំពីឯកសិទ្ធិលើនាវា ក៏ជាម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែកបានដែរ (មាត្រា ៤៨៥ កថាខណ្ឌទី ១ ចំណុច ឃ) ។ ឯកសិទ្ធិលើនាវា សំដៅទៅលើឯកសិទ្ធិពិសេសដែលត្រូវបានទទួលស្គាល់លើនាវា គ្រឿងប្រដាប់ដែលមានភ្ជាប់នឹងនាវានោះ ជាអាទិ៍ សម្រាប់ម្ចាស់បំណុលជាក់លាក់មួយចំនួន ។ ច្បាប់ក្នុងស្រុករបស់ប្រទេសនីមួយៗ

មានបទប្បញ្ញត្តិផ្សេងៗពីគ្នា ទាក់ទងទៅនឹងទំហំនៃសិទ្ធិលើបំណុលដែលឯកសិទ្ធិលើនាវាត្រូវបានទទួលស្គាល់ ។ ច្បាប់អាមេរិក ទទួលស្គាល់ឯកសិទ្ធិលើនាវា ចំពោះសិទ្ធិលើបំណុលតាមច្បាប់សមុទ្រ ជាច្រើន ។ ដោយឡែក នៅក្នុងច្បាប់អង់គ្លេសវិញ ឯកសិទ្ធិលើនាវា ត្រូវបានកម្រិតត្រឹមចំពោះតែសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ដោយសារនាវាប៉ះទង្គិចគ្នា ថ្លៃជួយសង្គ្រោះនៅពេលមានគ្រោះថ្នាក់នៅសមុទ្រ និង សិទ្ធិទាមទារប្រាក់បៀវត្សរបស់នាវិក តែប៉ុណ្ណោះ ។ នៅក្នុងច្បាប់ជប៉ុន ឯកសិទ្ធិត្រូវបានទទួលស្គាល់ចំពោះសិទ្ធិលើបំណុលដែលមានចែងនៅក្នុងក្រមពាណិជ្ជកម្មជប៉ុន ( មាត្រា ៨៤២ នៃក្រមពាណិជ្ជកម្មជប៉ុន) មានដូចជាសិទ្ធិលើបំណុលដែលបានកើតឡើងជាផលប្រយោជន៍រួមរបស់ម្ចាស់បំណុលទាំងអស់ សិទ្ធិលើបំណុលរបស់យានិកដែលបានកើតឡើងតាមកិច្ចសន្យាការងារ សិទ្ធិលើបំណុលដែលជាផលប្រយោជន៍សាធារណៈដូចជាពន្ធដែលពាក់ព័ន្ធនឹងការធ្វើចរាចរណ៍របស់នាវា (ដូចជាពន្ធកំពង់ផែ ជាអាទិ៍) ដែលមានអាទិភាពលើឯកសិទ្ធិដទៃទៀត និង ហ៊ីប៉ូតែកលើនាវា ( មាត្រា ៨៤៥ និង មាត្រា ៨៤៩ នៃក្រមពាណិជ្ជកម្មជប៉ុន) ។

មានអនុសញ្ញាអន្តរជាតិមួយដែលទាក់ទងទៅនឹងសិទ្ធិប្រាតិភោគ និង ការរឹបអូសនាវា គឺ "អនុសញ្ញាអន្តរជាតិស្ដីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនដែលពាក់ព័ន្ធទៅនឹងឯកសិទ្ធិ និង ហ៊ីប៉ូតែកលើនាវា" (International Convention for the Unification of Certain Rules relating to Maritime Liens and Mortgages) ឆ្នាំ ១៩៦៧ និង ឆ្នាំ ១៩៩៣ ។

(v) **ការអនុវត្តដោយបង្ខំ ចំពោះចំណែកនៃកម្មសិទ្ធិអវិភាគលើនាវា**

ការអនុវត្តដោយបង្ខំចំពោះចំណែកនៃកម្មសិទ្ធិអវិភាគលើនាវា ត្រូវធ្វើទៅតាមវិធីនៃការអនុវត្តចំពោះសិទ្ធិ ( សិទ្ធិលើបំណុល) ( មាត្រា ៤១៦) ។

## កថាភាគទី ៦ នីតិវិធីចែកចំណែក

### ១. ស្ថាប័នដែលទទួលបន្ទុកធ្វើការចែកចំណែក

នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ជាទូទៅ អាជ្ញាសាលាគឺជាអ្នកដែលត្រូវធ្វើការចែកចំណែក ( មាត្រា ៣៩៩) ។ នៅក្នុងករណីផ្សេងទៀត តុលាការអនុវត្ត ជាស្ថាប័នដែលត្រូវធ្វើការចែកចំណែក ( មាត្រា ៤៨៧) ។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ប្រសិនបើម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស មិនគ្រប់គ្រាន់សម្រាប់សងចំពោះសិទ្ធិទាមទាររបស់ម្ចាស់បំណុលនីមួយៗ (ទាក់ទងនឹងនីតិវិធីចែកចំណែក តទៅហៅថា "សិទ្ធិលើបំណុល") និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បានទេ ហើយប្រសិនបើម្ចាស់បំណុលទាំងអស់ មិនអាចពិភាក្សាគ្នាបានដាច់ស្រេចទេ ហើយពេលនោះ អាជ្ញាសាលាបានរាយការណ៍អំពីហេតុការណ៍នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ( មាត្រា ៤០១) សាលាដំបូងនោះ នឹងត្រូវធ្វើការចែកចំណែក ( មាត្រា ៤៨៧) ។

## ២. នីតិវិធីចែកចំណែកដោយអាជ្ញាសាលា

### (i) ការបែងចែកចំនួនទឹកប្រាក់ទាំងអស់

នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ប្រសិនបើម្ចាស់បំណុលមានតែម្នាក់ ឬ ប្រសិនបើម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែកចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់សេសសល់ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ (មាត្រា ៣៩៩ កថាខណ្ឌទី ១) ។ នៅក្នុងករណីបែបនេះ អាជ្ញាសាលាមិនចាំបាច់កំណត់កាលបរិច្ឆេទនៃការចែកចំណែកទេ ហើយអាចអនុវត្តការចែកចំណែក តាមវិធីដែលខ្លួនយល់ថាសមរម្យបាន ។

### (ii) ការពិភាក្សាគ្នារវាងម្ចាស់បំណុល

នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ប្រសិនបើម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស មិនគ្រប់គ្រាន់សម្រាប់សងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បានទេ អាជ្ញាសាលាត្រូវកំណត់ថ្ងៃ ក្នុងអំឡុងពេល ២ សប្តាហ៍ ជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស ហើយត្រូវជូនដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលនីមួយៗ (មាត្រា ៣៩៩ កថាខណ្ឌទី ២) ។

ប្រសិនបើម្ចាស់បំណុលនីមួយៗ បានពិភាក្សាគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវចែកចំណែកតាមការពិភាក្សានោះ (មាត្រា ៣៩៩ កថាខណ្ឌទី ២) ។

ប្រសិនបើការពិភាក្សាគ្នារវាងម្ចាស់បំណុល ធ្វើមិនបានដាច់ស្រេចទេ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះ រួចផ្ញើប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៤០១) ។ នៅក្នុងករណីនេះ នីតិវិធីចែកចំណែក នឹងត្រូវធ្វើឡើងដោយសាលាដំបូងនោះ ។

### (iii) ករណីនៃការលុបចោលការអនុវត្តដោយបង្ខំ

ប្រសិនបើឯកសារពាក់ព័ន្ធនឹងការផ្អាក ឬ ការលុបចោលការអនុវត្តដោយបង្ខំ (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ក ដល់ចំណុច ឆ) ត្រូវបានដាក់ទៅអាជ្ញាសាលា នៅក្រោយពេលដែលអ្នកទិញបានបង់ថ្លៃលក់រួចទៅហើយនោះ នីតិវិធីនៃការអនុវត្តដោយបង្ខំ មិនអាចលុបចោលបានទៀតទេ ព្រោះថាកម្មសិទ្ធិលើចលនវត្ថុត្រូវបានផ្ទេរទៅឱ្យអ្នកទិញ នៅពេលបង់ថ្លៃលក់រួចទៅហើយ ហើយស្ថានភាពនេះ មិនអាចស្តារឡើងវិញបានទេ ។ នៅក្នុងករណីបែបនេះ អាជ្ញាសាលា មិនអាចចែកចំណែកទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលមានមូលហេតុសម្រាប់ការលុបចោលការអនុវត្តដោយបង្ខំទេ ។ ក៏ប៉ុន្តែ ប្រសិនបើមានម្ចាស់បំណុលដទៃទៀតដែល

មានសិទ្ធិទាមទារឱ្យចែកចំណែក ក្រៅពីម្ចាស់បំណុលនៃការអនុវត្តនោះ អាជ្ញាសាលាត្រូវចែកចំណែកទៅឱ្យម្ចាស់បំណុលទាំងនោះ (មាត្រា ៣៩៩ កថាខណ្ឌទី ៣) ។

(iv) **ករណីនៃការផ្អាកការអនុវត្តដោយបង្ខំ**

ប្រសិនបើឯកសារពាក់ព័ន្ធនឹងការផ្អាកមួយរយៈនូវការអនុវត្តដោយបង្ខំ (មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ក និង ចំណុច ខ) ត្រូវបានដាក់ទៅអាជ្ញាសាលា នៅក្រោយពេលដែលអ្នកទិញបានបង់ថ្លៃលក់រួចទៅហើយនោះ ការដាក់ឯកសារនោះ មិនអាចរារាំងការអនុវត្តការចែកចំណែកបានទេ គឺអាជ្ញាសាលានៅតែត្រូវធ្វើការចែកចំណែក (មាត្រា ៣៩៩ កថាខណ្ឌទី ៤) ។ ក៏ប៉ុន្តែ អាជ្ញាសាលា ត្រូវធ្វើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃចំណែករបស់ម្ចាស់បំណុលនៃសិទ្ធិលើបំណុលដែលឯកសារពាក់ព័ន្ធនឹងការផ្អាកមួយរយៈដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៣៧០ ត្រូវបានដាក់ ទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ហើយប្រាក់នេះ មិនអាចប្រគល់បាន រហូតដល់ពេលដែលការផ្អាកនោះបានបាត់បង់អានុភាព (មាត្រា ៤០០ កថាខណ្ឌទី ១ ចំណុច គ, មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ក និង មាត្រា ៤៨៩ កថាខណ្ឌទី ១) ។

(v) **ការសងបំណុលដែលមានកំណត់ពេលពិតប្រាកដ**

ចំពោះការចែកចំណែក សិទ្ធិលើបំណុលដែលភ្ជាប់នឹងពេលកំណត់ពិតប្រាកដ ហើយដែលពេលកំណត់ពិតប្រាកដនោះពុំទាន់មកដល់ ត្រូវចាត់ទុកថា កំណត់ពេលសងនោះបានចូលមកដល់ហើយ (មាត្រា ៣៩៩ កថាខណ្ឌទី ៥) ។ ហេតុនេះហើយ ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលបែបនេះ អាចទទួលបានចំណែកភ្លាមៗ នៅមុនពេលដែលកំណត់ពេលពិតប្រាកដ បានមកដល់ ។ ប្រសិនបើសិទ្ធិលើបំណុលនោះ ពុំមានការប្រាក់ទេ នោះនឹងមានសំណួរចោទឡើងថាតើគួរដកការប្រាក់តាមអត្រាដែលច្បាប់បានកំណត់សម្រាប់អំឡុងពេលរហូតដល់ពេលកំណត់សង ដែរឬទេ ។

## ៣. នីតិវិធីចែកចំណែកដោយតុលាការ

(i) **ករណីនៃការចែកចំណែកដោយតុលាការ**

(១) ករណីដែល នៅក្នុងនីតិវិធីចែកចំណែកដោយអាជ្ញាសាលា ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានស្ថានភាពដូចខាងក្រោមទាក់ទងទៅនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែក ហើយអាជ្ញាសាលាបានធ្វើប្រាក់ដែលមានចំនួនស្មើនឹងចំណែករបស់ម្ចាស់បំណុលនោះ នៅនឹងសាលាដំបូងដែលខ្លួនស្ថិតនៅ ដោយបានរាយការណ៍អំពីហេតុការណ៍នោះផង តែមូលហេតុនៃការធ្វើប្រាក់នោះ បានរលត់ទៅ (មាត្រា ៤០០ កថាខណ្ឌទី ១ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ក វាក្យខណ្ឌទី ១) ។ នៅក្នុងករណីបែបនេះ ដោយសារថាចំនួនទឹកប្រាក់ដែលត្រូវចែកចំណែក ត្រូវបានកំណត់រួចហើយ ដូច្នេះ ត្រូវអនុវត្តតាមនីតិវិធីដូចគ្នា

នឹងនីតិវិធីដែលបានបញ្ញត្តិក្នុងមាត្រា ៤៩៥ កថាខណ្ឌទី ១ បើទោះបីជាការចែកចំណែកនេះ ធ្វើឡើងដោយសាលាដំបូងក៏ដោយ ។

(ក) បើសិទ្ធិលើបំណុលនោះ មានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ឬ កំណត់ពេលមិនពិតប្រាកដ

(ខ) បើសិទ្ធិលើបំណុលនោះ ជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន

(គ) បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ (មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ក)

(ឃ) បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈ នៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ។

(២) ករណីដែល នៅក្នុងនីតិវិធីចែកចំណែកដោយអាជ្ញាសាលា ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានម្ចាស់បំណុលច្រើន ហើយប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស មិនគ្រប់គ្រាន់សម្រាប់សងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់ ហើយម្ចាស់បំណុលទាំងអស់ ពុំអាចពិភាក្សាគ្នាឱ្យបានដាច់ស្រេច រួចអាជ្ញាសាលាក៏បានរាយការណ៍អំពីហេតុការណ៍នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៤០១ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ក វាក្យខណ្ឌទី ២) ។

(៣) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត កូនបំណុលទី ៣ បានធ្វើទុកប្រាក់ស្មើនឹងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ហើយបានជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត (មាត្រា ៤១១ កថាខណ្ឌទី ១ និង ទី ២) ឬ ការធ្វើប្រាក់ត្រូវបានធ្វើឡើង នៅតុលាការអនុវត្ត ដោយផ្អែកលើសាលក្រមនៃបណ្ដឹងទាមទារប្រមូលបំណុល (មាត្រា ៤១២ កថាខណ្ឌទី ៣ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ខ វាក្យខណ្ឌទី ១) ។

(៤) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សិទ្ធិលើបំណុល ត្រូវបានលក់ ដោយផ្អែកលើដីកាសម្រេចបង្គាប់ឱ្យលក់ ហើយប្រាក់ដែលបានមកពីការលក់នោះត្រូវបានប្រគល់ឱ្យតុលាការអនុវត្ត (មាត្រា ៤១៣ កថាខណ្ឌទី ១ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ខ វាក្យខណ្ឌទី ២) ។

(៥) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ត្រូវបានរឹបអូស ហើយអាជ្ញាសាលាបានលក់ចលនវត្ថុដែលបានទទួលការប្រគល់ដោយផ្អែកលើសិទ្ធិទាមទារនោះ រួចអាជ្ញាសាលាបានប្រគល់ប្រាក់ដែលមកពីការលក់នោះ ទៅឱ្យតុលាការអនុវត្ត (មាត្រា ៤១៤ កថាខណ្ឌទី ២ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ខ វាក្យខណ្ឌទី ៣) ។

(៦) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ហើយអ្នកទិញបានបង់ថ្លៃលក់ ទៅឱ្យតុលាការអនុវត្ត (មាត្រា ៤៤៧ កថាខណ្ឌទី ១ និង មាត្រា

៤៨៨ កថាខណ្ឌទី ១ ចំណុច គ វាក្យខណ្ឌទី ១) ។

(៧) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អ្នកទិញ គឺជាម្ចាស់បំណុលដែលត្រូវទទួលចំណែកពីថ្លៃលក់ដែរ ហើយអ្នកទិញនេះ បានបង់ថ្លៃលក់ដោយដកចំនួនទឹកប្រាក់នៃចំណែករបស់ខ្លួនចេញនៅកាលបរិច្ឆេទនៃការចែកចំណែក ហើយដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពររួចហើយ (មាត្រា ៤៨៧ កថាខណ្ឌទី ៣ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច គ វាក្យខណ្ឌទី ២) ។

(៨) ករណីដែល នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា អ្នកទិញបានបង់ថ្លៃលក់រួច (មាត្រា ៤៧៩ កថាខណ្ឌទី ១ និង មាត្រា ៤៨៨ កថាខណ្ឌទី ១ ចំណុច ឃ) ។

(ii) **ការរៀបចំការចែកចំណែក**

(១) ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក និង ការជូនដំណឹងអំពីការណ៍នោះ : នៅពេលដែលត្រូវអនុវត្តការចែកចំណែក តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយត្រូវផ្តល់ដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និង កូនបំណុលនៃការអនុវត្ត ដោយត្រូវកោះហៅអ្នកទាំងនោះផង (មាត្រា ៤៨៨ កថាខណ្ឌទី ១ និង មាត្រា ៤៩០ កថាខណ្ឌទី ២) ។ កាលបរិច្ឆេទនៃការចែកចំណែក សំដៅទៅលើកាលបរិច្ឆេទដែលត្រូវធ្វើការចែកចំណែកទៅឱ្យម្ចាស់បំណុល ដោយផ្អែកលើតារាងចែកចំណែក ឬ ដោយមិនចាំបាច់ធ្វើតារាងចែកចំណែក ។

(២) ម្ចាស់បំណុលដែលត្រូវទទួលបានចំណែក : វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលបានចំណែកចំពោះប្រភេទនីមួយៗនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ មានដូចតទៅ (មាត្រា ៤៩០ កថាខណ្ឌទី ២) :

ចំណុច ក (ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ) : ① ម្ចាស់បំណុលនៃការអនុវត្ត, ② ម្ចាស់បំណុលដែលបានធ្វើការទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ដែលបានមកពីការលក់ ក្នុងករណីដែលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់, ③ ម្ចាស់បំណុលដែលបានធ្វើការទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានរឹបអូសប្រាក់ ក្នុងករណីដែលចែកចំណែកនូវប្រាក់ដែលត្រូវបានរឹបអូស (មាត្រា ៣៩៨) ។

ចំណុច ខ (ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) : ① ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស (រួមទាំងម្ចាស់បំណុលនៃការអនុវត្តផង), ② ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន, និង ③ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក នៅមុនពេលដែលបានកំណត់ខាងក្រោមនេះ (មាត្រា ៤១៥) :

(a) ពេលដែលកូនបំណុលទី ៣ បានធ្វើការផ្ញើ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៤១១ ។

(b) ពេលដែលពាក្យបណ្តឹងទាមទារប្រមូលបំណុលត្រូវបានបញ្ជូនទៅកូនបំណុលទី ៣ ។

(c) ពេលដែលអាជ្ញាសាលា បានទទួលប្រាក់ដែលបានមកពីការលក់ តាមដីកាសម្រេចបង្គាប់ឱ្យលក់ ។

(d) ពេលដែលអាជ្ញាសាលា បានទទួលការប្រគល់ចលនវត្ថុ ក្នុងករណីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ។

ចំណុច គ (ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) : ① ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬ ការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក, ②ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក, និង ③ ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នមុនការចុះបញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ជាដំបូង (មាត្រា ៤៥៣) ។

ចំណុច ឃ (ករណីអនុវត្តដោយបង្ខំចំពោះនាវា) : ①ម្ចាស់បំណុលនៃការអនុវត្ត, ②ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក, និង ③ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ (មាត្រា ៤៨៦) ។

(៣) ការដាស់តឿនឱ្យផ្ដល់លិខិតគណនា : នៅពេលដែលកាលបរិច្ឆេទនៃការចែកចំណែក ត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗ ឱ្យផ្ដល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត ទៅតុលាការដែលត្រូវចែកចំណែក នៅក្នុងអំឡុងពេលមួយសប្ដាហ៍ (មាត្រា ៤៨៨ កថាខណ្ឌទី ២) ។

(៤) ការរៀបចំសេចក្ដីព្រាងនៃតារាងចែកចំណែក : ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយមានការប៉ាន់ប្រមាណដោយផ្អែកលើលិខិតគណនា ដែលម្ចាស់បំណុលនីមួយៗបានដាក់ ជាអាទិ៍ ថាទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ មិនគ្រប់គ្រាន់សម្រាប់សងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់ទេ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវរៀបចំសេចក្ដីព្រាងនៃតារាងចែកចំណែកដែលត្រូវធ្វើនៅកាលបរិច្ឆេទនៃការចែកចំណែក ។ នៅក្នុងសេចក្ដីព្រាងនៃតារាងចែកចំណែក ត្រូវសរសេរបញ្ចូលនូវ : ①ចំនួនទឹកប្រាក់ដែលបានមកពីការលក់វត្ថុដែលត្រូវបានរឹបអូស និង ចំនួនទឹកប្រាក់ដែលត្រូវបានរឹបអូស ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ, ② ចំនួនទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែក ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត, និង ③ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ឬ ការអនុវត្តដោយបង្ខំចំពោះនាវា ។ ម្យ៉ាងទៀត នៅក្នុងសេចក្ដីព្រាងនៃតារាងចែកចំណែកក៏ត្រូវសរសេរអំពីចំនួនប្រាក់ដើម ការប្រាក់ សិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងៗនៃសិទ្ធិលើបំណុល សោហ៊ុយ

សម្រាប់ការអនុវត្ត និង លំដាប់និងចំនួនទឹកប្រាក់ នៃការចែកចំណែក ចំពោះម្ចាស់បំណុលនីមួយៗ ផងដែរ (មាត្រា ៤៩០ កថាខណ្ឌទី ៤) ។ មួយវិញទៀត ដូចដែលបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងការចែកចំណែក សិទ្ធិលើបំណុលដែលភ្ជាប់នឹងពេលកំណត់ពិតប្រាកដ ហើយដែលពេលកំណត់ពិតប្រាកដនោះពុំទាន់មកដល់ ត្រូវចាត់ទុកថា ពេលកំណត់សងបានមកដល់ហើយ (មាត្រា ៤៩០ កថាខណ្ឌទី ៦) ។

(iii) **ការធ្វើតារាងចែកចំណែក**

ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ តែទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ គ្រប់គ្រាន់សម្រាប់សងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្តផង តុលាការមិនចាំបាច់ធ្វើតារាងចែកចំណែកទេ ព្រោះគេអាចយកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ មកសងបំណុលទាំងអស់របស់ម្ចាស់បំណុល ហើយបើមានប្រាក់នៅសល់ តុលាការត្រូវប្រគល់សំណល់នោះ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។ ក៏ប៉ុន្តែ នៅក្នុងករណីផ្សេងពីនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើតារាងចែកចំណែក នៅកាលបរិច្ឆេទនៃការចែកចំណែកនោះ (មាត្រា ៤៩០ កថាខណ្ឌទី ១) ។ តារាងចែកចំណែក ត្រូវធ្វើឡើង នៅក្រោយពេលដែលសេចក្តីព្រាងនៃតារាងនោះ ដែលបានរៀបចំឡើងដោយផ្អែកលើលិខិតគណនាដែលម្ចាស់បំណុលនីមួយៗបានដាក់ជាមុន ជាអាទិ៍ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយម្ចាស់បំណុលនីមួយៗ ក៏ដូចជាកូនបំណុលនៃការអនុវត្ត និង ក្រោយពីតុលាការបានសួរយោបល់ពីអ្នកទាំងនោះ នៅកាលបរិច្ឆេទនៃការចែកចំណែក ។ លំដាប់ និង ចំនួនទឹកប្រាក់នៃការចែកចំណែក ត្រូវសរសេរតាមការព្រមព្រៀង ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នៅកាលបរិច្ឆេទនៃការចែកចំណែក ឯក្នុងករណីផ្សេងទៀត ត្រូវកំណត់ទៅតាមបញ្ញត្តិនៃច្បាប់ (មាត្រា ៤៩០ កថាខណ្ឌទី ៥) ។

(iv) **ការតវ៉ានៅកាលបរិច្ឆេទនៃការចែកចំណែក**

(១) ការតវ៉ាចំពោះការសរសេរនៅក្នុងសេចក្តីព្រាងនៃតារាងចែកចំណែក ៖ ម្ចាស់បំណុលណាម្នាក់ និង កូនបំណុលនៃការអនុវត្ត ដែលមិនពេញចិត្តចំពោះការសរសេរនៅក្នុងសេចក្តីព្រាងនៃតារាងចែកចំណែក ដែលខ្លួនពិនិត្យផ្ទៀងផ្ទាត់ អាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។ ប្រសិនបើមានការថ្លែងសេចក្តីតវ៉ាដូច្នេះ តុលាការ ត្រូវសួរម្ចាស់បំណុលនីមួយៗ និង កូនបំណុលនៃការអនុវត្ត ហើយត្រូវធ្វើការពិនិត្យភស្តុតាងជាឯកសារ ដែលអាចពិនិត្យភ្លាមៗបាន នៅកាលបរិច្ឆេទនៃការចែកចំណែក (មាត្រា ៤៩០ កថាខណ្ឌទី ៣) ។ បន្ទាប់ពីនោះ តុលាការ ត្រូវកំណត់ថាតើគួរកែប្រែសេចក្តីព្រាងនៃតារាងចែកចំណែកនោះ ដែរឬទេ ។

(២) ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ៖ ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្ត ដែលមានឧបាស្រ័យ ចំពោះសិទ្ធិលើបំណុល ឬ ចំនួនប្រាក់ចំណែករបស់ម្ចាស់បំណុលម្នាក់ៗ ដែលត្រូវបានសរសេរលើតារាងចែកចំណែក អាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក (មាត្រា ៤៩១

កថាខណ្ឌទី ១) ។

តុលាការដែលត្រូវអនុវត្តការចែកចំណែក មិនធ្វើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកនេះ នៅកាលបរិច្ឆេទនៃការចែកចំណែកទេ ។ ការតវ៉ានេះ នឹងត្រូវបានសម្រេចសេចក្តីនៅក្នុងបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលមានពន្យល់នៅខាងក្រោម ។

(៣) ការតវ៉ាចំពោះវិការៈនៅក្នុងនីតិវិធី : បន្ថែមពីលើការតវ៉ាចំពោះការសរសេរនៅលើតារាងចែកចំណែក ម្ចាស់បំណុលនីមួយៗ និង កូនបំណុលនៃការអនុវត្ត អាចថ្លែងសេចក្តីតវ៉ាចំពោះវិការៈនៅក្នុងនីតិវិធីនៃការចែកចំណែក ដូចជាអំពីការកំណត់កាលបរិច្ឆេទនៃការចែកចំណែក និង ការកោះហៅភាគីតាមកាលបរិច្ឆេទនៃការចែកចំណែក, អំពីការដាស់តឿនឱ្យផ្តល់លិខិតគណនា នីតិវិធីនៃការរៀបចំតារាងចែកចំណែក ជាអាទិ៍ នៅកាលបរិច្ឆេទនៃការចែកចំណែក ។ ការតវ៉ាបែបនេះ មានចរិតលក្ខណៈជាការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤) ហើយតុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការសម្រេចសេចក្តីអំពីការតវ៉ានេះ ដោយចេញដីកាសម្រេច នៅកាលបរិច្ឆេទនៃការចែកចំណែក ។

(v) **ការអនុវត្តការចែកចំណែក**

(១) ការអនុវត្តការចែកចំណែក ដោយមិនធ្វើតាមតារាងចែកចំណែក : ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ តែទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវចែកចំណែកទៅឱ្យម្ចាស់បំណុលគ្រប់រូប ហើយត្រូវប្រគល់ទឹកប្រាក់ដែលនៅសេសសល់ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ដោយពុំចាំបាច់ធ្វើតារាងចែកចំណែកនៅកាលបរិច្ឆេទនៃការចែងចំណែកទេ (មាត្រា ៤៨៩ កថាខណ្ឌទី ២) ។ នៅក្នុងករណីបែបនេះ ដោយសារពុំមាននីតិវិធីដែលប្រហាក់ប្រហែលទៅនឹងការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកនោះ កូនបំណុលនៃការអនុវត្តដែលចង់ធ្វើវិវាទអំពីអត្ថិភាព ឬ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង ចង់រាំងការអនុវត្តការចែកចំណែក ពុំមានជម្រើសអ្វីផ្សេងឡើយ ក្រៅពីការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣), ការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៥០), ការដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាអាទិ៍ ហើយទទួលដីកាសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ ឬ ដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យផ្អាកការទទួលចំណែក ជាអាទិ៍ ។

(២) ការអនុវត្តការចែកចំណែក ដោយធ្វើទៅតាមតារាងចែកចំណែក : តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវអនុវត្តការចែកចំណែក ទៅតាមតារាងចែកចំណែក លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុចទី (១) ខាងលើ (មាត្រា ៤៨៩ កថាខណ្ឌទី ១) ។ ប្រសិនបើមានសេចក្តីថ្លែងតវ៉ាចំពោះការសរសេរនៅលើតារាងចែកចំណែក តុលាការត្រូវធ្វើការចែកចំណែក តែផ្នែកដែលពុំមានការតវ៉ាចំពោះការ

សរសេរលើតារាងចែកចំណែក ប៉ុណ្ណោះ (មាត្រា ៨៩១ កថាខណ្ឌទី ២) ។ ចំពោះផ្នែកដែលមានសេចក្តីថ្លែងតវ៉ា ប្រសិនបើម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងតវ៉ា មិនបានបញ្ជាក់ថាខ្លួនបានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ឬ បណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍ នៅក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចែកចំណែកទេ នោះការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថា បានដកវិញ (មាត្រា ៨៩២ កថាខណ្ឌទី ៣ និង មាត្រា ៨៩៣ កថាខណ្ឌទី ៤) ហើយតុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែក (មាត្រា ៨៩១ កថាខណ្ឌទី ២) ។

(៣) វិធីនៃការអនុវត្តការចែកចំណែក : ការចែកចំណែក ត្រូវធ្វើឡើងតាមវិធីនៃការប្រគល់នូវចំណែកដោយផ្ទាល់ ទៅឱ្យម្ចាស់បំណុលដែលមានវត្តមាននៅកាលបរិច្ឆេទនៃការចែកចំណែក ។ ជាលទ្ធផលនៃការអនុវត្តការចែកចំណែក បើម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត បានទទួលនូវចំណែកគ្រប់ចំនួននៃសិទ្ធិលើបំណុលហើយនោះ កូនបំណុលនៃការអនុវត្ត អាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តដែលម្ចាស់បំណុលនោះបានផ្តល់ឱ្យបាន (មាត្រា ៨៩១ កថាខណ្ឌទី ៣) ។ លើកលែងតែករណីដែលបានរៀបរាប់មកនេះ កាលដែលរឿងក្តីបានបញ្ចប់ហើយ ម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក អាចទាមទារឱ្យក្រឡាបញ្ជី ប្រគល់មកវិញនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តបាន ។ ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលនោះបានទទួលចំណែកនៃសិទ្ធិលើបំណុលតែមួយផ្នែក ក្រឡាបញ្ជីត្រូវប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយចារនូវចំនួននៃចំណែកដែលម្ចាស់បំណុលនោះបានទទួល លើឯកសារនោះ (មាត្រា ៨៩១ កថាខណ្ឌទី ៤) ។

(៤) ការផ្អាកទុកនូវចំនួនប្រាក់ចំណែក : ប្រសិនបើមានមូលហេតុនៃការរារាំងនូវការទទួលយកភ្លាមនូវប្រាក់ចំណែក ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក ឬ ប្រសិនបើម្ចាស់បំណុលមិនបានបង្ហាញខ្លួន ចំពោះមុខតុលាការ នៅកាលបរិច្ឆេទនៃការចែកចំណែកទេ នោះតុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកសិន នូវប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃចំណែកនោះ (មាត្រា ៨៩៤ កថាខណ្ឌទី ១ និង ទី ២) ។ ករណីដែលមានមូលហេតុនៃការរារាំងនូវការទទួលយកភ្លាមនូវប្រាក់ចំណែក ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក មានដូចតទៅ :

① សិទ្ធិលើបំណុលនោះ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ (មាត្រា ៨៩៤ កថាខណ្ឌទី ១ ចំណុច ក) : ក្នុងករណីនេះ ដោយសារថា ការចែកចំណែក មិនគួរធ្វើឡើងទេ បើល័ក្ខខ័ណ្ឌបង្អង់មិនទាន់ត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដ មិនទាន់បានមកដល់ ដូច្នេះហើយបានជាតុលាការ

ត្រូវផ្អាកចំនួនទឹកប្រាក់នៃចំណែកនោះទុកសិន ។

② សិទ្ធិលើបំណុលនោះ ជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ខ) : អត្ថិភាពនៃសិទ្ធិទាមទារដែលត្រូវបានការពារដោយការរឹបអូសជាបណ្ដោះអាសន្ន មិនទាន់ត្រូវបានបញ្ជាក់ទេ មុនពេលសាលក្រម ឬ សាលដីកានៃបណ្ដឹងអង្គសេចក្ដីដែលឱ្យម្ចាស់បំណុលឈ្នះក្ដី ចូលជាស្ថាពរនោះ ។ ហេតុនេះហើយបានជាតុលាការត្រូវផ្អាកទុកនូវចំនួនទឹកប្រាក់នៃចំណែកនោះសិន ។

③ ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈចំពោះសិទ្ធិលើបំណុលនោះ ដោយសារមានការប្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍ ត្រូវបានផ្ដល់ (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច គ និង មាត្រា ៣៧០ កថាខណ្ឌទី ២ ចំណុច ក) : ដោយសារគេមិនអាចកំណត់ថាតើគួរអនុវត្តការចែកចំណែក ឬ មិនគួរ បើបណ្ដឹងទាំងនេះ មិនទាន់បានបញ្ចប់ ដូច្នេះហើយបានជាចំនួនទឹកប្រាក់នៃចំណែកនោះ ត្រូវផ្អាកទុកសិនដោយតុលាការ ។

④ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ត្រូវបានផ្ដល់ (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ឃ) : នៅក្នុងករណីដែលមានវិវាទអំពីអត្ថិភាពនៃឯកសិទ្ធិ ជាអាទិ៍ ហើយមានការផ្ដល់នូវឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តឯកសិទ្ធិ ជាអាទិ៍នោះ ដោយសារមានការដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃឯកសិទ្ធិ ជាអាទិ៍ នោះបានន័យថា គេមិនអាចកំណត់ថាតើគួរអនុវត្តការចែកចំណែក ឬ មិនគួរទេ បើបណ្ដឹងទាំងនោះ មិនទាន់បានបញ្ចប់ ។ ហេតុនេះហើយបានជាចំនួនទឹកប្រាក់នៃចំណែកនោះ ត្រូវផ្អាកទុកសិន ដោយតុលាការ ។

⑤ ពាក្យបណ្ដឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក (មាត្រា ៤៩២ កថាខណ្ឌទី ១) ឬ ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក របស់កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (មាត្រា ៤៩៣ កថាខណ្ឌទី ២) ត្រូវបានដាក់ (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ង) : គេមិនអាចកំណត់ថាតើគួរអនុវត្តការចែកចំណែក ឬ មិនគួរទេ បើបណ្ដឹងទាំងនេះ មិនទាន់បានបញ្ចប់ ។ ហេតុនេះហើយបានជាតុលាការ ត្រូវផ្អាកទុកសិន នូវទឹកប្រាក់នៃចំណែកនោះ ។

(៥) ការអនុវត្តការចែកចំណែក ដោយការកំណត់សិទ្ធិជាស្ថាពរ : (ក) ក្នុងករណីដែលទឹកប្រាក់នៃចំណែកត្រូវបានផ្អាកទុក បើហេតុនៃការផ្អាកទុកនោះ បានរលត់ (ឧទាហរណ៍ ដូចជាករណីដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដបានមកដល់ ឬ ករណីដែលម្ចាស់បំណុលនៃការរឹបអូសជា

បណ្តោះអាសន្ន បានទទួលសាលក្រមស្ថាពរដែលសម្រេចលើអង្គសេចក្តី តាមការទាមទាររបស់ខ្លួន ឬ ករណីដែលហេតុនៃការផ្អាកការអនុវត្តដោយបង្ខំ បានរលត់ ជាអាទិ៍) តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែក ដោយប្រគល់នូវប្រាក់ដែលបានផ្អាកទុកនោះ ទៅឱ្យម្ចាស់បំណុល (មាត្រា ៤៩៥ កថាខណ្ឌទី ១) ។

(ខ) ផ្ទុយទៅវិញ ប្រសិនបើហេតុនៃការផ្អាកទុកនោះ បែរទៅជាមូលហេតុពិតប្រាកដ ជាស្ថាពរដែលនាំឱ្យម្ចាស់បំណុលនោះមិនអាចទទួលចំណែកនោះ ជាគោលការណ៍ តុលាការត្រូវចាប់ផ្តើមនីតិវិធីនៃការចែកចំណែកឡើងវិញ ដោយបែងចែកប្រាក់ដែលត្រូវបានផ្អាកទុកនោះ ទៅឱ្យម្ចាស់បំណុលដទៃទៀត ។ ក្នុងករណីដែលការផ្អាកទុក ត្រូវបានធ្វើឡើង ដោយយកមូលហេតុផ្សេងពីការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក (ករណីនៃការផ្អាកទុក ដោយមូលហេតុដែលបានកំណត់ក្នុងមាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ក ដល់ចំណុច ឃ) ប្រសិនបើមូលហេតុនោះ កើតមានយ៉ាងពិតប្រាកដចំពោះម្ចាស់បំណុលដែលប្រាក់ចំណែករបស់ខ្លួនត្រូវបានផ្អាកទុក នោះតុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ដើម្បីបែងចែកប្រាក់ចំណែកដែលត្រូវបានផ្អាកទុក បន្ថែមទៅឱ្យម្ចាស់បំណុលដទៃទៀត (មាត្រា ៤៩៥ កថាខណ្ឌទី ២ ចំណុច ក) ។ ក្នុងករណីដែលការផ្អាកទុក ត្រូវបានធ្វើឡើង ដោយយកមូលហេតុនៃបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលកូនបំណុលនៃការអនុវត្តបានដាក់ចំពោះម្ចាស់បំណុលដែលពុំមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ង និង មាត្រា ៤៩៣ កថាខណ្ឌទី ២) ប្រសិនបើម្ចាស់បំណុលដែលប្រាក់ចំណែករបស់ខ្លួនត្រូវបានផ្អាកទុក បានចាញ់ក្តី ហើយសាលក្រម ឬ សាលដីកានោះ បានចូលជាស្ថាពរ នោះតុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ដើម្បីបែងចែកប្រាក់ចំណែកដែលត្រូវបានផ្អាកទុក បន្ថែមទៅឱ្យម្ចាស់បំណុលដទៃទៀត រួមទាំងម្ចាស់បំណុលដែលមិនបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកផងដែរ (មាត្រា ៤៩៥ កថាខណ្ឌទី ២ ចំណុច ខ) ។ ឧទាហរណ៍ថា មានម្ចាស់បំណុលបីនាក់ដែលមានសិទ្ធិបានទទួលចំណែក គឺ A, B និង C ហើយចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ពួកគេ គឺ ៤ លានរៀល ចំពោះ A, ៦ លានរៀល ចំពោះ B, និង ៨ លានរៀល ចំពោះ C ។ ឧបមាថា ចំនួនទឹកប្រាក់សម្រាប់បំពេញការចែកចំណែក មានតែ ៩ លានរៀលប៉ុណ្ណោះ ។ ដូច្នេះ តាមតារាងចែកចំណែក A នឹងទទួលបាន ២ លានរៀល, B នឹងទទួលបាន ៣ លានរៀល ហើយ C នឹងទទួលបាន ៤ លានរៀល (ក្នុងឧទាហរណ៍នេះ មិនគិតអំពីសោហ៊ុយសម្រាប់ការអនុវត្ត) ។ ឧបមាទៀតថា កូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក (មាត្រា ៤៩៣ កថាខណ្ឌទី ២) ចំពោះ B ដោយអះអាងថា សិទ្ធិលើបំណុលរបស់ B ពុំមានអត្ថិភាពទេ ហើយកូនបំណុលនៃការអនុវត្ត បានឈ្នះក្តីនោះ ។ ក្នុងករណីបែបនេះ ប្រសិនបើសិទ្ធិលើបំណុលរបស់ B ត្រូវបានចាត់ទុកថាពុំមានអត្ថិភាពទេនោះ នត្ថិភាពនេះ នឹងមានឥទ្ធិពលទៅលើម្ចាស់បំណុលដទៃទៀត ។ មានន័យថា ប្រាក់ ៩ លានរៀល

សម្រាប់បំពេញការចែកចំណែកនោះ នឹងត្រូវបែងចែកទៅឱ្យតែ A និង C ហើយជាលទ្ធផល A នឹងទទួលបានប្រាក់ចំណែក ៣ លានរៀល ឯ C នឹងទទួលបានប្រាក់ចំណែក ៦ លានរៀល ។ ម្យ៉ាងទៀត ចំពោះករណីដែល B ជាម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយកូនបំណុលនៃការអនុវត្តបានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ចំពោះ B ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៩៣ កថាខណ្ឌទី ១ រួចបានឈ្នះក្តីនោះ ក៏ត្រូវអនុវត្តតាមវិធីដូចគ្នានេះដែរ ។

នៅក្នុងករណីដោយឡែក គឺករណីដែលការផ្អាកទុក ត្រូវបានធ្វើឡើង ដោយយកមូលហេតុនៃបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលម្ចាស់បំណុលណាម្នាក់បានដាក់ចំពោះម្ចាស់បំណុលដទៃទៀត (មាត្រា ៤៩៤ កថាខណ្ឌទី ១ ចំណុច ង និង មាត្រា ៤៩២ កថាខណ្ឌទី ១) នោះ ប្រសិនបើម្ចាស់បំណុលដែលជាចុងចម្លើយបានចាញ់ក្តី ប្រាក់ចំណែកដែលបានផ្អាកទុកនោះ នឹងត្រូវយកមកបែងចែកបន្ថែមទៅឱ្យតែម្ចាស់បំណុលដែលបានឈ្នះក្តីប៉ុណ្ណោះ (សូមមើល ៤. (iv) (២) ដែលនឹងមានពន្យល់ដូចខាងក្រោម) ។

## ៤. បណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

### (i) ការបញ្ជាក់អំពីការដាក់ពាក្យបណ្តឹង

(១) ប្រសិនបើម្ចាស់បំណុលណាម្នាក់ បានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលទាក់ទងទៅនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដទៃទៀត នៅកាលបរិច្ឆេទនៃការចែកចំណែក ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ានោះ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការតវ៉ានោះ ធ្វើជាចុងចម្លើយ (មាត្រា ៤៩២ កថាខណ្ឌទី ១) ។ បើម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងតវ៉ានោះ នៅក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចែកចំណែកទេ ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកនោះ ត្រូវចាត់ទុកថា បានដកវិញ (មាត្រា ៤៩២ កថាខណ្ឌទី ៣) ។

(២) ក៏ដូចគ្នាដែរ ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត បានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ប្រសិនបើកូនបំណុលនៃការអនុវត្តនោះ មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក នៅក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចែកចំណែកទេ ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកនោះ ត្រូវចាត់ទុកថាបានដកវិញ (មាត្រា ៤៩៣ កថាខណ្ឌទី ២ និង ទី ៤) ។

ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត បានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តវិញ កូនបំណុលនៃការអនុវត្តនោះ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដោយយកម្ចាស់

បំណុលនោះ ធ្វើជាចុងចម្លើយ (មាត្រា ៤៩៣ កថាខណ្ឌទី ១) ។ នៅក្នុងករណីនេះ កូនបំណុលនៃការអនុវត្ត ត្រូវបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ និង ត្រូវផ្តល់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្ត ដែលទាក់ទងនឹងបណ្តឹងរបស់ខ្លួននោះ ទៅតុលាការ នៅក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក (មាត្រា ៤៩៣ កថាខណ្ឌទី ៤) ។

(ii) **តុលាការដែលមានសមត្ថកិច្ច**

តុលាការដែលត្រូវអនុវត្តការចែកចំណែក មានសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក (មាត្រា ៤៩២ កថាខណ្ឌទី ២) ។ តុលាការដែលមានសមត្ថកិច្ចនៅទីនេះ មិនមែនសំដៅទៅលើតុលាការដែលមានតួនាទីជាស្ថាប័នចែកចំណែកទេ តែសំដៅទៅលើតុលាការដែលមានសិទ្ធិអំណាចលើតុលាការដែលត្រូវអនុវត្តការចែកចំណែក ។ ហេតុនេះហើយ ចៅក្រមដែលមានតួនាទីនៅក្នុងនីតិវិធីចែកចំណែក នឹងមិនមានតួនាទីនៅក្នុងបណ្តឹងតវ៉ាទេ ។

(iii) **ការវិនិច្ឆ័យ**

នៅក្នុងបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក កម្មវត្ថុនៃការជំនុំជម្រះ និង ការសម្រេចសេចក្តី គឺចំណុចថាតើគួរទទួលស្គាល់ ឬ មិនទទួលស្គាល់ នូវការតវ៉ារបស់ដើមបណ្តឹង ចំពោះសិទ្ធិលើបំណុល និងចំនួនទឹកប្រាក់នៃចំណែក របស់ចុងចម្លើយដែលបានសរសេរនៅលើតារាងចែកចំណែក ។ ដើមចោទអាចលើកការអះអាងអំពីចំណុចសារធាតុ ដូចជា ការមិនបានបង្កើត និង/ឬ ការរលត់នូវសិទ្ធិលើបំណុលរបស់ចុងចម្លើយ នត្ថិភាពនៃសិទ្ធិអាទិភាពដែលបានកំណត់នៅក្នុងតារាងចែកចំណែក ជាអាទិ៍ ក៏ដូចជាការអះអាងអំពីចំណុចនីតិវិធី ដូចជា មោឃភាពនៃការរឹបអូស និង ការទាមទារឱ្យចែកចំណែករបស់ចុងចម្លើយ, អត្ថិភាពនៃឯកសារអំពីការផ្អាក និង/ឬ ការលុបចោលការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលរបស់ចុងចម្លើយ ជាអាទិ៍ ។ ទោះជាយ៉ាងណាក៏ដោយ ដើមចោទមិនត្រូវបានចងដោយមូលហេតុនៃការតវ៉ាដែលខ្លួនបានថ្លែងនៅកាលបរិច្ឆេទនៃការចែកចំណែកនោះទេ ។ មានន័យថា ដើមចោទ អាចបន្ថែមមូលហេតុថ្មី ឬ អាចប្តូរមូលហេតុបាន ។

ប្រសិនបើដើមចោទ គឺជាម្ចាស់បំណុល ដើមចោទនោះអាចអះអាងអង្គហេតុតវ៉ាទាំងអស់ ដែលកូនបំណុលមាន (មោឃភាព ការសង ការលើកលែង ជាអាទិ៍) ហើយបើចាំបាច់ អាចអនុវត្តសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល (មាត្រា ៤២២ នៃក្រមរដ្ឋប្បវេណី) ដើម្បីលើកយកសិទ្ធិទូទាត់ សិទ្ធិលុបចោល និង សិទ្ធិរំលាយកិច្ចសន្យា មកអះអាងបាន ។

(iv) **សាលក្រម**

(១) ប្រសិនបើតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ តុលាការត្រូវលុបចោលចំនួនទឹកប្រាក់

នៃចំណែករបស់ចុងចម្លើយដែលបានសរសេរនៅលើតារាងចែកចំណែក កែប្រែតារាងចែកចំណែកនោះ និង កំណត់អំពីវិធីបំពេញចំនួនទឹកប្រាក់នៃចំណែកនោះ ដើម្បីបែងចែកបន្ថែមទៅឱ្យម្ចាស់បំណុលដទៃទៀត នៅក្នុងសាលក្រម ។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលត្រូវបែងចែកបន្ថែម មិនអាចកំណត់បាន ដោយសារមានបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមួយទៀត កំពុងត្រូវបានចាត់ការ ជាអាទិ៍ នោះ តុលាការ អាចលុបចោលចំនួនទឹកប្រាក់នៃចំណែករបស់ចុងចម្លើយដែលបានសរសេរនៅលើតារាងចែកចំណែក និង គ្រាន់តែបង្គាប់ឱ្យធ្វើតារាងចែកចំណែកថ្មី នៅក្នុងសាលក្រមបាន (មាត្រា ៩៩២ កថាខណ្ឌទី ៤ និង មាត្រា ៩៩៣ កថាខណ្ឌទី ៥) ។

(២) ប្រសិនបើម្ចាស់បំណុលណាម្នាក់ ដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលម្នាក់ទៀត នោះការបែងចែកសាជាថ្មីនូវចំនួនទឹកប្រាក់នៃចំណែក នឹងត្រូវធ្វើឡើងតែក្នុងចំណោមភាគីទាំងនោះតែប៉ុណ្ណោះ ពោលគឺមិនប៉ះពាល់ដល់ចំនួនទឹកប្រាក់នៃចំណែករបស់ម្ចាស់បំណុលដទៃទៀត ដែលមិនបានថ្លែងសេចក្តីតវ៉ាទេ ។ ឧទាហរណ៍ថា ម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក មានបីនាក់ គឺ A, B និង C ហើយចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលពួកគេរាយការណ៍ គឺ ៤ លានរៀល ចំពោះ A, ៦ លានរៀល ចំពោះ B និង ៨ លានរៀល ចំពោះ C ។ ឧបមាថា ចំនួនទឹកប្រាក់សម្រាប់បំពេញការចែកចំណែក មានតែ ៩ លានរៀលប៉ុណ្ណោះ ។ ដូច្នេះ តាមតារាងចែកចំណែក A នឹងទទួលបាន ២ លានរៀល, B នឹងទទួលបាន ៣ លានរៀល ហើយ C នឹងទទួលបាន ៤ លានរៀល ។ ឧបមាទៀតថា A បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដោយលើកការអះអាងអំពីនត្ថិភាពនៃសិទ្ធិលើបំណុលរបស់ B ហើយ A បានឈ្នះក្តីនោះ ។ នៅក្នុងករណីបែបនេះ តាមយុត្តិសាស្ត្ររបស់តុលាការកំពូលនៃប្រទេសជប៉ុន ចំនួនទឹកប្រាក់ ៣ លាន រៀល ដែលជាចំណែករបស់ B នឹងត្រូវយកមកចែកទៅឱ្យតែ A ប៉ុណ្ណោះ ។ ក៏ប៉ុន្តែ នៅក្នុងករណីខាងលើនេះ ចំនួនទឹកប្រាក់នៃសិទ្ធលើបំណុលរបស់ A មានទាំងអស់ ៤ លានរៀល ហើយ A បានទទួល ២ លានរៀលរួចទៅហើយ ។ ហេតុដូច្នេះ ចំនួនទឹកប្រាក់ដែលត្រូវបែងចែកបន្ថែមទៅឱ្យ A ត្រូវកម្រិតត្រឹមតែ ២ លានរៀលទៀតប៉ុណ្ណោះ ពីក្នុងចំនួនទឹកប្រាក់ ៣ លានរៀលដែលជាចំណែករបស់ B ហើយប្រាក់ដែលនៅសល់ ១ លានរៀលទៀត ត្រូវប្រគល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។ ផ្ទុយទៅវិញ នៅក្នុងករណីដែលកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលពុំមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយប្រសិនបើតុលាការយល់ឃើញថាការតវ៉ានេះ មានមូលហេតុត្រឹមត្រូវ តារាងចែកចំណែកនោះនឹងត្រូវបានកែប្រែ ហើយការចែកចំណែក នឹងត្រូវធ្វើឡើងម្តងទៀត ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ រាប់ទាំងម្ចាស់បំណុលដែលមិនបានថ្លែងសេចក្តីតវ៉ា ផងដែរ (មាត្រា ៩៩៥ កថាខណ្ឌទី ២ ចំណុច ខ) ។ ឧទាហរណ៍នៃករណីនេះ ត្រូវបានលើកមកពន្យល់រួចហើយ នៅក្នុង **៣.** (v) (៥) ខាងលើ ។ ក៏ដូចគ្នាផងដែរ ក្នុងករណី

ដែលកូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលណាម្នាក់ បានដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដោយរួមគ្នា ចំពោះម្ចាស់បំណុលដទៃទៀត ហើយប្រសិនបើដើមចោទទាំងនេះឈ្នះក្ដី នោះការចែកចំណែកម្ដងទៀត ត្រូវធ្វើឡើងដើម្បីជាផលប្រយោជន៍របស់ម្ចាស់បំណុលដទៃទៀតដែលមិនបានថ្លែងសេចក្ដីតវ៉ាផងដែរ ។

## ផ្នែកទី ២ បទប្បញ្ញត្តិពិសេសស្ដីពីការអនុវត្តសិទ្ធិប្រាតិភោគ

### កថាភាគទី ១ កំណត់សំគាល់ទូទៅ

### ១. អត្ថន័យនៃនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ

បុគ្គលដែលមានសិទ្ធិប្រាតិភោគ ដូចជា ហ៊ីប៉ូតែក ឬ សិទ្ធិលើការបញ្ចាំ ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ជាទូទៅ អាចធ្វើការប្ដូរជាប្រាក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលត្រូវបានធានា តាមរយៈស្ថាប័នអនុវត្ត ហើយទទួលការសងពីប្រាក់ដែលបានមកនោះ បានមុនម្ចាស់បំណុលដទៃទៀត ។ នីតិវិធីដែលត្រូវអនុវត្តដើម្បីសម្រេចគោលបំណងនេះ គឺនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ។ នីតិវិធីជាក់លាក់ ត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ដែលរួមមាន ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ (មាត្រា ៥០០ ដល់មាត្រា ៥០៤), ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ៥០៥ ដល់មាត្រា ៥០៨), ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ (មាត្រា ៥០៩ ដល់មាត្រា ៥២០) និង ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា (មាត្រា ៥២១ ដល់មាត្រា ៥២៣) ។ នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ គឺជាប្រភេទមួយនៃការអនុវត្តដោយបង្ខំ (មាត្រា ៣៣៤) និង ត្រូវអនុលោមទៅតាមបញ្ញត្តិនៃគន្ថីទី ៦ ជំពូកទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ទោះជាយ៉ាងណាក៏ដោយ បញ្ញត្តិពិសេសដែលត្រូវយកមកអនុវត្តជាទូទៅ សម្រាប់ការអនុវត្តសិទ្ធិប្រាតិភោគគ្រប់ប្រភេទ (មាត្រា ៤៩៦ ដល់មាត្រា ៤៩៩) មានដូចតទៅនេះ ។

### ២. បញ្ញត្តិពិសេសស្ដីពីលិខិតអនុវត្ត

ដើម្បីចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ក៏ត្រូវទាមទារឱ្យមានលិខិតអនុវត្តដែរ ។ ប៉ុន្តែ ខុសប្លែកពីការអនុវត្តដោយបង្ខំដទៃទៀត ការអនុវត្តសិទ្ធិប្រាតិភោគ តម្រូវឱ្យមានលិខិតអនុវត្ត ដែលជាឯកសារបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដែលត្រូវអនុវត្តនោះ ។ ឯកសារដែលត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្តរួមមាន (ក) សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ (មាត្រា ៤៩៦ ចំណុច ក), និង (ខ) លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (មាត្រា ៤៩៦ ចំណុច ខ) ។ ឧទាហរណ៍នៃឯកសារដែលបានកំណត់ក្នុងចំណុច (ក) មានដូចជា សាលក្រមឬសាលដីកាស្ថាពរដែលទទួល

ស្គាល់ការទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក ឬ សាលក្រមឬសាលដីកាស្ថាពរដែលច្រានចោលការទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃហ៊ីប៉ូតែក, សាលក្រមឬសាលដីកាស្ថាពរដែលបង្គាប់ឱ្យចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក, កំណត់ហេតុអំពីការសះជា ឬ កំណត់ហេតុអំពីការទទួលស្គាល់ការទាមទារ ដែលមានខ្លឹមសារដូចសាលក្រមឬសាលដីកាស្ថាពរទាំងនោះ ជាអាទិ៍ ។ ដោយឡែក ឧទាហរណ៍នៃឯកសារដែលបានកំណត់ក្នុងចំណុច (ខ) មានដូចជា លិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលធ្វើឡើងដោយសារការី ជាអាទិ៍ ។

## ៣. សមត្ថកិច្ចលើបណ្ដឹងពាក់ព័ន្ធនឹងការអនុវត្ត

នៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ក៏គេអាចដាក់ (ក) ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារដើម្បីធ្វើវិវាទលើអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ ទៅលើអត្ថិភាពនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា (មាត្រា ៣៦៣), និង (ខ) ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ដើម្បីធ្វើវិវាទអំពីការបំពេញល័ក្ខខ័ណ្ឌបង្អង់ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬ អំពីហេតុនៃការបន្តសិទ្ធិ (មាត្រា ៣៦៤) ។ មានបញ្ញត្តិពិសេសអំពីសមត្ថកិច្ចលើបណ្ដឹងទាំងនេះ ។ តុលាការដែលមានសមត្ថកិច្ចគឺសាលាដំបូងដែលបានធ្វើនីតិវិធីនៃបណ្ដឹង ក្នុងករណីពាក់ព័ន្ធនឹងលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង តុលាការដែលកំណត់ទៅតាមលំនៅឋាន ជាអាទិ៍ របស់ចុងចម្លើយ (ម្ចាស់បំណុលនៃការអនុវត្ត) នៅក្នុងករណីពាក់ព័ន្ធនឹងលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច (ខ) នៃមាត្រាដដែល ។

## ៤. បញ្ញត្តិពិសេសពាក់ព័ន្ធនឹងការផ្អាក និង ការលុបចោលការអនុវត្ត

មាត្រា ៣៧០ ស្ដីពីការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ មិនត្រូវយកមកអនុវត្តចំពោះការផ្អាក និង ការលុបចោលនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគទេ ។ ការផ្អាក និង ការលុបចោលនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវស្ថិតនៅក្រោមបញ្ញត្តិនៃមាត្រា ៤៩៨ ។ ប៉ុន្តែ បញ្ញត្តិពិសេសនេះ ត្រូវបានចែងឡើងដាច់ដោយឡែក ដោយយោងទៅតាមភាពខុសគ្នានៃលិខិតអនុវត្តតែប៉ុណ្ណោះ ។ ខ្លឹមសារនៃបញ្ញត្តិពិសេសនេះស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងករណីនៃការអនុវត្តដោយបង្ខំដទៃទៀតដែរ ។

## ៥. ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្ដូរជាប្រាក់

សិទ្ធិឃាត់ទុក គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគ ។ ក៏ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុក គ្រាន់តែអាចឃាត់ទុកនូវវត្ថុ រហូតដល់ពេលដែលខ្លួនបានទទួលការសងចំពោះសិទ្ធិលើបំណុលប៉ុណ្ណោះ ហើយម្ចាស់សិទ្ធិនោះ ពុំមានសិទ្ធិទាមទារអាទិភាពនៅក្នុងការសងទេ (មាត្រា ៧៧៤ នៃក្រមរដ្ឋប្បវេណី) ។ ម្ចាស់សិទ្ធិឃាត់ទុក អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវវត្ថុដែលជាកម្មវត្ថុនោះបាន (សូមមើលមាត្រា ៧៧៣ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែនេះមិនមែនជាការទាមទារសំណងដោយមានអាទិភាពទេ គឺវាគ្រាន់តែជានីតិវិធីនៃការប្ដូរជាប្រាក់ដែលមិនអាច

ចាត់ទុកថាជាការអនុវត្តសិទ្ធិប្រាតិភោគបានទេ ។

ស្រដៀងគ្នានេះដែរ មាត្រា ២១២ (វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ), មាត្រា ៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង), និង មាត្រា ១២៧១ (ការប្តូរជាប្រាក់ដោយការលក់) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏ចែងអំពីការលក់ដោយបង្ខំដែលមានគោលបំណងប្តូរជាប្រាក់ដែរ គឺមិនមែនដើម្បីសម្រេចសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្តទេ ។

ការលក់ដោយបង្ខំទាំងនេះ មិនមែនជានីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគឡើយ ។ ហេតុនេះហើយ ការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំបែបនេះ មិនទាមទារឱ្យមានលិខិតអនុវត្តទេ ។ ក៏ប៉ុន្តែ ដោយសារវាមានចរិតលក្ខណៈដូចការអនុវត្តសិទ្ធិប្រាតិភោគ ត្រង់ចំណុចថាវាជាការប្តូរជាប្រាក់ដោយបង្ខំ តាមរយៈតុលាការ ដូច្នេះ ទើបច្បាប់ចែងថា នីតិវិធីនៃការប្តូរជាប្រាក់ទាំងនេះ ត្រូវអនុវត្តទៅតាមបញ្ញត្តិស្តីពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ (មាត្រា ៤៩៥) ។

## កថាភាគទី ២ ការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះចលនវត្ថុ

### ១. កំណត់សំគាល់ទូទៅ

ចំពោះសិទ្ធិប្រាតិភោគដែលមានកម្មវត្ថុជាចលនវត្ថុ ក្រមរដ្ឋប្បវេណីចែងអំពីឯកសិទ្ធិទូទៅ ឯកសិទ្ធិលើចលនវត្ថុ និង សិទ្ធិលើការបញ្ចាំ ។ ជាគោលការណ៍ ការអនុវត្តសិទ្ធិទាំងអស់នេះ ត្រូវធ្វើតាមរយៈការលក់ចលនវត្ថុ (លើកលែងតែករណីពិសេសនៃសិទ្ធិលើការបញ្ចាំ, មាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី និង មាត្រា ៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ម្យ៉ាងទៀត វិធីនៃការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានចលនវត្ថុគឺវិធីមួយដែលហៅថា ការអនុវត្តដោយខ្លួនឯង ដែលមិនចាំបាច់មានការលក់ដោយបង្ខំទេ (សូមមើលមាត្រា ៨៩៨ នៃក្រមរដ្ឋប្បវេណី) ។

ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ លើកលែងតែចំពោះវិធានពិសេសមួយចំនួន (បញ្ញត្តិពិសេសចំពោះផ្នែកទី ១: ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់) ត្រូវយកបញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មកអនុវត្ត (ប៉ុន្តែ បញ្ញត្តិមួយចំនួន ក្នុងចំណោមបញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មិនត្រូវយកមកអនុវត្តទេ ។ សូមមើលមាត្រា ៥០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

### ២. ការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគ

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវចាប់ផ្តើមដោយការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ជាលាយលក្ខណ៍អក្សរ ដោយម្ចាស់សិទ្ធិប្រាតិភោគ ក្នុងនាមជាម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៣៨៤ កថាខណ្ឌទី ១) ។ ស្ថាប័នអនុវត្ត គឺអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលទ្រព្យ

សម្បត្តិពាក់ព័ន្ធនោះ ស្ថិតនៅ ។ ពាក្យសុំជាលាយលក្ខណ៍អក្សរ ត្រូវសរសេរបញ្ចូល នូវចំណុចដូចតទៅ : (ក) សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង, (ខ) សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា, (គ) សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និង ទីកន្លែងនៃចលនវត្ថុនោះ, និង (ឃ) ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ (មាត្រា ៥០២) ។

ជាគោលការណ៍ ការអនុវត្តសិទ្ធិប្រាតិភោគ ទាមទារឱ្យមានលិខិតអនុវត្ត (មាត្រា ៤៥៦) ហើយលិខិតអនុវត្តនេះ ត្រូវដាក់ជាមួយនឹងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ។ ម៉្យាងទៀត ឯកសារដែលត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត ជាទូទៅ រួមមាន សាលក្រមឬសាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រមឬសាលដីកាស្ថាពរនោះ (មាត្រា ៤៥៦ ចំណុច ក) និង លិខិតយថាភូតដែលធ្វើដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (មាត្រា ៤៥៦ ចំណុច ខ) ។ ប៉ុន្តែ លើកលែងតែចលនវត្ថុមានតម្លៃ ការជួញដូរចលនវត្ថុ ដូចជាការលក់ទិញ កម្រនឹងធ្វើឡើងដោយលិខិតយថាភូតដែលធ្វើដោយសារការីណាស់ ហើយការតម្រូវឱ្យមានសាលក្រមឬសាលដីកាស្ថាពរដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ក៏ជាការដាក់បន្ទុកធ្ងន់ធ្ងរហួសហេតុទៅលើម្ចាស់សិទ្ធិប្រាតិភោគដែរ ។ ហេតុនេះហើយបានជានៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត កាន់កាប់ដោយខ្លួនឯងនូវចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ (ដូចជាករណីនៃម្ចាស់សិទ្ធិលើការបញ្ចាំ ជាអាទិ៍) ហើយបានដាក់ចលនវត្ថុនោះ អាជ្ញាសាលាអាចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុនោះបាន បើទោះបីជាពុំមានការដាក់លិខិតអនុវត្តក៏ដោយ (មាត្រា ៥០០) ។ ម៉្យាងទៀត ទោះបីជាម្ចាស់បំណុលនៃការអនុវត្ត មិនបានកាន់កាប់ចលនវត្ថុនោះក៏ដោយ (ដូចជាករណីនៃម្ចាស់ឯកសិទ្ធិទូទៅ ម្ចាស់ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ (មាត្រា ៧៩៧ នៃក្រមរដ្ឋប្បវេណី) ជាអាទិ៍) ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តនោះ បានដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុ បានយល់ព្រមចំពោះការរឹបអូស នោះអាជ្ញាសាលាក៏អាចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគបានដែរ (មាត្រា ៥០០) ។

នៅពេលដែលម្ចាស់សិទ្ធិប្រាតិភោគបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ បានដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុ បានយល់ព្រមចំពោះការរឹបអូស នោះអាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុដែលម្ចាស់សិទ្ធិប្រាតិភោគបានដាក់ ឬ អ្នកកាន់កាប់បានយល់ព្រមចំពោះការរឹបអូស (មាត្រា ៣៨៥ កថាខណ្ឌទី ១) ។

## ៣. ការធ្វើឧបាស្រ័យ

ប្រសិនបើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវបានចាប់ផ្តើមដោយពុំមានការដាក់លិខិតអនុវត្ត

ទេ កូនបំណុលនៃការអនុវត្ត (កម្មសិទ្ធិករនៃចលនវត្ថុ) ឬ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា អាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្តនោះបាន ដោយយកនត្ថិភាព ឬ ការរលត់នៃសិទ្ធិប្រាតិភោគនោះ មកធ្វើជាមូលហេតុ (មាត្រា ៥០១) ។ ដោយសារថា ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដោយមិនបាច់ដាក់លិខិតអនុវត្តបាន ដើម្បីថ្លឹងថ្លែងនឹងការអនុញ្ញាតនេះ ទើបច្បាប់ចែងឱ្យមាននីតិវិធីសាមញ្ញនៃការដាក់ពាក្យសុំតវ៉ានេះឡើង បន្ថែមពីលើបណ្តឹងតវ៉ាចំពោះការទាមទារ ដើម្បីជាផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ឬ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។ ដើមដំបូង មូលហេតុដែលអាចលើកឡើងនៅក្នុងការតវ៉ាចំពោះការអនុវត្ត ត្រូវបានកម្រិតតែត្រឹមបញ្ហាដែលទាក់ទងទៅនឹងការខុសនីតិវិធីប៉ុណ្ណោះ ។ ក៏ប៉ុន្តែ នៅក្នុងករណីដូចខាងលើនេះ គេអាចលើកបញ្ហានៅក្នុងច្បាប់សារធាតុ ដូចជានត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាអាទិ៍ មកធ្វើជាមូលហេតុនៃការតវ៉ាបានដែរ ។

## ៤. នីតិវិធី

(១) នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវចាប់ផ្តើមដោយការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលា តាមវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ ។ ក៏ប៉ុន្តែនៅទីនេះ កម្មវត្ថុនៃការរឹបអូស គឺជាចលនវត្ថុជាក់លាក់ ដែលអាស្រ័យទៅតាមចរិតលក្ខណៈនៃសិទ្ធិប្រាតិភោគ ។ ហេតុនេះហើយ បញ្ញត្តិស្តីពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨០ និង មាត្រា ៣៨១) និងបញ្ញត្តិស្តីពីការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ (មាត្រា ៣៩១) មិនត្រូវយកមកអនុវត្ត ចំពោះការរឹបអូសខាងលើនេះឡើយ (មាត្រា ៥០៣) ។ ក៏ប៉ុន្តែ ចំពោះការរឹបអូសដែលជាការអនុវត្តនូវឯកសិទ្ធិទូទៅ ដោយសារថាកម្មវត្ថុនៃការអនុវត្ត គឺជាទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល ដូច្នេះ បញ្ញត្តិស្តីពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស និង ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស ក៏ដូចជាបញ្ញត្តិស្តីពីការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ ត្រូវយកមកអនុវត្ត ។

(២) ការលក់ចលនវត្ថុនៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវធ្វើឡើងតាមវិធីដូចគ្នានឹងករណីនៃការលក់ចលនវត្ថុដែលត្រូវបានរឹបអូស នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ (មាត្រា ៣៩៥) ។

(៣) ការរួមបញ្ចូលរឿងក្តី ការទាមទារឱ្យចែកចំណែក និង នីតិវិធីចែកចំណែក ក៏ត្រូវធ្វើឡើងតាមវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ (មាត្រា ៣៨៨, មាត្រា ៣៩៤, មាត្រា ៣៩៨ និង មាត្រា ៣៩៩ និង គន្ថីទី ៦ ជំពូកទី ២ ផ្នែកទី ៦) ។

## ៥. នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ចំពោះសិទ្ធិលើការបញ្ចាំចលនវត្ថុ ច្បាប់ចែងឱ្យមាននីតិវិធីសាមញ្ញសម្រាប់ការអនុវត្ត ដែលនេះគឺជាបញ្ញត្តិពិសេសនៃនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ (មាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី និង

មាត្រា ៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះ មកសងដោយផ្ទាល់តែម្តង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ។

## កថាភាគទី ៣ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

### ១. កំណត់សំគាល់ទូទៅ

លើកលែងតែមានបញ្ញត្តិចែងពិសេស ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ៥០៧ និង មាត្រា ៥០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និង ការអនុវត្តសិទ្ធិដោយផ្អែកលើឧបាទេសកម្មលើវត្ថុ ដោយម្ចាស់សិទ្ធិប្រាតិភោគ (មាត្រា ៥០៦ កថាខណ្ឌទី ១) ត្រូវអនុលោមទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល (គន្ថីទី ៦ ជំពូកទី ២ ផ្នែកទី ៣) ។

ទាក់ទងនឹងចំណុចខាងលើ ពាក្យថា "សិទ្ធិលើបំណុល" នៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវសំដៅដល់ "សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ឬ ឱ្យប្រគល់ចលនវត្ថុ" ដែលបានកំណត់នៅក្នុងមាត្រា ៤០២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដោយឡែក ពាក្យថា "សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត" ត្រូវសំដៅដល់ "សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល" ដែលបានកំណត់នៅក្នុងមាត្រា ៤១៦ ។ តាមច្បាប់ជប៉ុន សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនេះ រួមមានដូចជា សិទ្ធិអ្នកនិពន្ធ សិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិជួល សិទ្ធិជាសមាជិកនៃសហគ្រាស ជាអាទិ៍ ។ យោងតាមមាត្រា ៥០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវអនុលោមទៅតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស ។

ការអនុវត្តសិទ្ធិដោយផ្អែកលើឧបាទេសកម្មលើវត្ថុ មានន័យថា បុគ្គលដែលមានសិទ្ធិប្រាតិភោគ អនុវត្តសិទ្ធិប្រាតិភោគនោះ ចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលកូនបំណុលត្រូវទទួលដោយការលក់ ការជួល ជាអាទិ៍ ជំនួសឱ្យកម្មវត្ថុដើមនៃសិទ្ធិប្រាតិភោគ ដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី (ដូចជាមាត្រា ៧៨២ (ឯកសិទ្ធិ), មាត្រា ៨១៧ (សិទ្ធិលើការបញ្ចាំ), មាត្រា ៨៤៩ (ហ៊ីប៉ូតែក) ជាអាទិ៍) (សូមមើលមាត្រា ៥០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ តាមមាត្រា ៥០៦ បុគ្គលដែលមានសិទ្ធិប្រាតិភោគ អាចអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើឧបាទេសកម្មលើវត្ថុ ដោយរឹបអូសយកប្រាក់ ឬ វត្ថុផ្សេងទៀតដែលកូនបំណុលត្រូវទទួលដោយការលក់ ការជួល ជាអាទិ៍ ។

ម្យ៉ាងទៀត ម្ចាស់បំណុលដែលមានសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុល អាចធ្វើការប្រមូលដោយផ្ទាល់នូវសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន (មាត្រា ៨៤២

នៃក្រមរដ្ឋប្បវេណី) ។ ប៉ុន្តែ ទន្ទឹមនឹងនេះ គេក៏អាចអនុវត្តសិទ្ធិលើការបញ្ចាំនោះ តាមនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែរ ។

## ២. ការចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ

(១) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និង ការអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើឧបាទេសកម្មលើវត្ថុ (ចាប់ពីត្រឹមនេះទៅ ហៅថា ការអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុ) ត្រូវធ្វើឡើង ដោយផ្អែកលើការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ទៅតុលាការអនុវត្ត (មាត្រា ៤០២ កថាខណ្ឌទី ៣) (មាត្រា ៤០៣ កថាខណ្ឌទី ១, ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សូមមើលមាត្រា ៥០៧) ។ តុលាការអនុវត្តនៅទីនេះ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅឋាន ឬ ទីតាំងនៃទីស្នាក់ការឬទីកន្លែងអាជីវកម្មចម្បង ជាអាទិ៍ របស់កូនបំណុល ។ ប៉ុន្តែបើពុំមានទីកន្លែងទាំងនេះទេ តុលាការអនុវត្តនោះ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅឋាន ជាអាទិ៍របស់កូនបំណុលទី ៣ (មាត្រា ៤០២ កថាខណ្ឌទី ៣) ។

(២) នៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរនូវចំណុចដូចតទៅ : (ក) សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុលទី ៣ និង អ្នកតំណាង, (ខ) សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា, (គ) សញ្ញាណនៃសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ, និង (ឃ) ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ (មាត្រា ៥០៥ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ពាក្យសុំជាលាយលក្ខណ៍អក្សរនោះ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែបានកំណត់ក្នុងមាត្រា ៤៥៦ ផង (មាត្រា ៥០៥ កថាខណ្ឌទី ២) ។ នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល អាចចាប់ផ្ដើមបានតែពេលណាដែលមានការដាក់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តប៉ុណ្ណោះ ។

(៣) ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគ អនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុ ក៏ត្រូវអនុលោមតាមនីតិវិធីដូចករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុលដែរ (មាត្រា ៥០៦ កថាខណ្ឌទី ១) ។ នៅក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរអំពីទំនាក់ទំនងរវាងសិទ្ធិលើបំណុលដែលត្រូវបានធានា និងសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស បន្ថែមពីលើចំណុចនានាដែលតម្រូវឱ្យសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល (មាត្រា ៥០៦ កថាខណ្ឌទី ២) ។ យើងដឹងហើយថា ជាគោលការណ៍ពាក្យសុំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (មាត្រា ៥០៦ កថាខណ្ឌទី ១ និង មាត្រា ៥០៥ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ នៅក្នុងករណីនៃការអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុ ដោយម្ចាស់សិទ្ធិប្រាតិ

ភោគចំពោះចលនវត្ថុ ដូចគ្នានឹងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុដែរ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំ ដោយគ្រាន់តែភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃឯកសារដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ជំនួសឱ្យឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ក៏បាន (មាត្រា ៥០៦ កថាខណ្ឌទី ៣) ។

## ៣. នីតិវិធី

(១) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក៏ដូចជាការអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុ ដោយម្ចាស់សិទ្ធិប្រាតិភោគ ត្រូវចាប់ផ្តើម ដោយតុលាការអនុវត្តចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ជាអាទិ៍ ដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ (មាត្រា ៤០៣ កថាខណ្ឌទី ៤) ។ បញ្ញត្តិអំពីសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨២), ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨៣), និង ការហាមឃាត់ការរឹបអូសហួសប្រមាណ (មាត្រា ៤០៤ កថាខណ្ឌទី ២) នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មិនត្រូវយកមកអនុវត្តទេ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធលើទ្រព្យសម្បត្តិផ្សេងទៀត និង ការអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគ (មាត្រា ៥០៨) ។

(២) នីតិវិធីនៃការប្តូរជាប្រាក់នូវសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ជាអាទិ៍ ដែលត្រូវបានរឹបអូស ត្រូវអនុវត្តទៅតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ ។ ការប្តូរជាប្រាក់ ក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុ ដោយផ្អែកលើសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើងតាមវិធីប្តូរជាប្រាក់នូវសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ (ការប្រមូល (មាត្រា ៤១០) និងការបង្គាប់ឱ្យលក់ (មាត្រា ៤១៣)) ឬ តាមវិធីនៃការប្តូរជាប្រាក់នូវសិទ្ធិទាមទារឱ្យប្រគល់ (មាត្រា ៤១៤) ដោយអាស្រ័យទៅតាមប្រភេទនៃសិទ្ធិដែលជាកម្មវត្ថុនៃឧបាទេសកម្មលើវត្ថុនោះ ។

(៣) ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគច្រើន ចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត តែមួយដូចគ្នា តុលាការអនុវត្តត្រូវចេញដីកាសម្រេចរឹបអូសត្រួតគ្នា ។ កូនបំណុលទី ៣ ដែលបានទទួលការបញ្ជូនដីកាសម្រេចរឹបអូសត្រួតគ្នាបែបនេះ ត្រូវធ្វើទុកប្រាក់ស្មើនឹងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ (មាត្រា ៤១១ កថាខណ្ឌទី ២) ។ បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តដូចគ្នាដែរ ចំពោះករណីដែលដីកាសម្រេចរឹបអូសតាមពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវបានចេញ ត្រួតគ្នាជាមួយនឹងដីកាសម្រេចរឹបអូសតាមពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ។ ចំពោះការទាមទារឱ្យចែកចំណែក និង នីតិវិធីចែកចំណែក ត្រូវអនុវត្តទៅតាមនីតិវិធីដូចករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ (មាត្រា ៤០៩ និង មាត្រា ៤១៥, គន្ថីទី ៦ ជំពូកទី ២ ផ្នែកទី ៦) ។

(៤) ដូចបានពន្យល់ខាងលើ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវអនុលោមតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស (មាត្រា ៥០៧) ។ សិទ្ធិលើទ្រព្យសម្បត្តិ មានច្រើនប្រភេទ ហើយតុលាការអនុវត្ត ចាំបាច់ត្រូវបង្កាប់វិធីប្តូរជាប្រាក់ណា ដែលសមស្របទៅនឹងចរិតលក្ខណៈនៃសិទ្ធិនីមួយៗនោះ ។ ហេតុនេះហើយ ការអនុវត្តនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគបែបនេះ ត្រូវទុកឱ្យតុលាការជាអ្នកកំណត់ ដោយអាស្រ័យទៅតាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនោះ ។

## កថាភាគទី ៤ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

### ១. កំណត់សំគាល់ទូទៅ

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ជាគោលការណ៍ ត្រូវធ្វើឡើងតាមវិធីលក់ដោយបង្ខំ ដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ (មាត្រា ៤១៧ កថាខណ្ឌទី ២) ។ លើកលែងតែមានបញ្ញត្តិពិសេស នីតិវិធីលក់ដោយបង្ខំនេះ ត្រូវធ្វើឡើងដូចគ្នានឹងនីតិវិធីលក់ដោយបង្ខំ នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ (គន្លឹះទី ៦ ជំពូកទី ២ ផ្នែកទី ៤ និង ទី ៦) ។ សិទ្ធិប្រាតិភោគចំពោះអចលនវត្ថុនៅទីនេះ សំដៅដល់ ហ៊ីប៉ូតែក (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៨៤៣), សិទ្ធិលើការបញ្ចាំអចលនវត្ថុ (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៨៣៤), ឯកសិទ្ធិលើអចលនវត្ថុ (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៧៩៩), និង ឯកសិទ្ធិទូទៅ ដែលមានអានុភាពលើអចលនវត្ថុ (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៧៨៣) ។

### ២. ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

(១) ដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តដែលជាម្ចាស់សិទ្ធិប្រាតិភោគ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ឱ្យអនុវត្តសិទ្ធិប្រាតិភោគ ទៅតុលាការអនុវត្ត ។ តុលាការអនុវត្ត គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុនោះស្ថិតនៅ (មាត្រា ៤១៨ ចំណុច ក) ។ នៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ ត្រូវសរសេរបញ្ចូលនូវចំណុចដូចតទៅ : (ក) សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង, (ខ) សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា, (គ) សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ, និង (ឃ) ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ (មាត្រា ៥០៩ កថាខណ្ឌទី ១) ។

(២) បន្ថែមពីលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់ក្នុងមាត្រា ៤៩៦ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជាមួយនឹងពាក្យសុំ នូវឯកសារដូចតទៅ :

(ក) ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃ

សៀវភៅចុះបញ្ជី ( មាត្រា ៥០៩ កថាខណ្ឌទី ២ ចំណុច ក) ។

(ខ) ករណីដែលអនុវត្តឯកសិទ្ធិទូទៅ : (i) ចំពោះអចលនវត្ថុដែលបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត បានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត, (ii) ចំពោះដីធ្លីដែលមិនទាន់បានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីធ្លីនោះ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ( មាត្រា ៥០៩ កថាខណ្ឌទី ២ ចំណុច ខ) ។

## ៣. នីតិវិធីនៃការលក់ដោយបង្ខំ

### (i) កំណត់សំគាល់ទូទៅ

ដូចករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ត្រូវចាប់ផ្ដើម ដោយតុលាការអនុវត្ត ចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ និង ប្រកាសរឹបអូសអចលនវត្ថុតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលជាម្ចាស់សិទ្ធិប្រាតិភោគ ( មាត្រា ៤១៩ កថាខណ្ឌទី ១) ។ អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស (មាត្រា ៤២០) ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ( មាត្រា ៤២១ កថាខណ្ឌទី ២) ។

បន្ទាប់ពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ នឹងចូលទៅដល់ដំណាក់កាលនៃការប្ដូរជាប្រាក់ តាមវិធីលក់ដោយបង្ខំ និង ការសងទៅម្ចាស់បំណុល តាមនីតិវិធីចែកចំណែក ។ ដូចក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដូច្នោះដែរ នៅក្នុងនីតិវិធីនេះ ក៏អាចមានការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា ( មាត្រា ៥១១ និង មាត្រា ៥១២, សូមមើលមាត្រា ៤២៤ និង មាត្រា ៤២៥ ផងដែរ) ហើយការទាមទារឱ្យចែកចំណែកក៏អាចធ្វើទៅបានដែរ ( មាត្រា ៤២៦) ។ ឯនីតិវិធីផ្សេងៗទៀត ក៏ត្រូវអនុវត្តដូចគ្នាដែរ ដែលក្នុងនោះមានដូចជា ការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ( មាត្រា ៤៣៤ កថាខណ្ឌទី ២ និង ទី ៣), ការវាយតម្លៃ ( មាត្រា ៤៣០), ការរៀបចំឯកសារលំអិតអំពីវត្ថុ ( មាត្រា ៤៣៤ កថាខណ្ឌទី ១), ការកំណត់តម្លៃលក់អប្បបរមា ( មាត្រា ៤៣២), វិធីលក់ ( ចាប់ពីមាត្រា ៤៣៦), ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ មិនអនុញ្ញាតឱ្យលក់ ( ចាប់ពីមាត្រា ៤៤០), ការអនុវត្តការចែកចំណែកពីប្រាក់ដែលបានមកពីការលក់ ( ចាប់ពីមាត្រា ៤៨៧) ជាអាទិ៍ ។

ចាប់ពីត្រឹមនេះតទៅ នឹងមានការពន្យល់តែអំពីចំណុចពិសេសនានាដែលទាក់ទងទៅនឹងការលក់ដោយបង្ខំនូវអចលនវត្ថុ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ តែប៉ុណ្ណោះ ។

### (ii) ការអនុវត្តសិទ្ធិប្រាតិភោគ និង ការបន្តអត្ថិភាពឬការរលត់នៃសិទ្ធិដែលមានភ្ជាប់នឹងអចលនវត្ថុ

នៅក្នុងការលក់ដោយបង្ខំនូវអចលនវត្ថុ ប្រសិនបើមានបន្ទុក ដូចជា សិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ភ្ជាប់ជាមួយនឹងអចលនវត្ថុដែលជាកម្មវត្ថុ នោះមានសំណួរមួយចោទឡើងថាតើគួរលុបចេញនូវសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ទាំងនោះ ដោយយកថ្លៃលក់អចលនវត្ថុនោះ មកបង់ជាសំណង (គោលការណ៍លុបចេញ) ឬ គួរឱ្យសិទ្ធិទាំងនោះបន្តអត្ថិភាពដូចដើម (គោលការណ៍ទទួលបន្ត) ។ ចំណុចនេះ ត្រូវបានពន្យល់រួចមកហើយ នៅក្នុងជំពូកទី ៣ ផ្នែកទី ១ កថាភាគទី ៤ ចំណុចទី ២ ៣. ខាងលើ ។ ក្រមនីតិវិធីរដ្ឋប្បវេណី បានអនុម័តយកគោលការណ៍ទទួលបន្ត ធ្វើជាវិធានទូទៅ ។ ដូច្នេះ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ សិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ (មាត្រា ៤៣១ កថាខណ្ឌទី ១ និង ទី ៣) ។ ដោយឡែក ចំពោះសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលមិនអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបានទេ ត្រូវរលត់ ឬ បាត់បង់អានុភាព នៅក្រោយការលក់ (មាត្រា ៤៣១ កថាខណ្ឌទី ២ និង ទី ៣) ។ ទោះជាយ៉ាងណាក៏ដោយ យោងតាមលក្ខណៈរបស់វា ការរឹបអូស និង ការរឹបអូសជាបណ្តោះអាសន្ន ជានិច្ចកាលត្រូវបាត់បង់អានុភាពដោយការលក់ ដោយសារលក្ខណៈរបស់វា ។ ហេតុនេះហើយបានជានៅទីនេះ ភាពអាចតតាំងបាន ឬ មិនអាចតតាំងបាន នៃបន្ទុកដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍ ចំពោះការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត គឺជាល័ក្ខខ័ណ្ឌសម្រាប់ការបន្តអត្ថិភាព ឬ ការរលត់ ឬ ការបាត់បង់អានុភាពនៃបន្ទុកទាំងនោះ ។ នេះក៏ព្រោះតែនៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានគោលបំណងធានានូវតម្លៃដោះដូររបស់អចលនវត្ថុដែលជាកម្មវត្ថុ ដើម្បីសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត តាមរយៈការរឹបអូស ។

ផ្ទុយទៅវិញ ក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ ដោយសារថា នៅពេលបង្កើតសិទ្ធិប្រាតិភោគនោះ ម្ចាស់សិទ្ធិប្រាតិភោគ ដែលជាម្ចាស់បំណុលនៃការអនុវត្ត បានដឹងអំពីតម្លៃដោះដូរនៃអចលនវត្ថុដែលជាកម្មវត្ថុនាពេលនោះរួចទៅហើយ ដូច្នេះ ប្រសិនបើឱ្យបន្ទុកលើអចលនវត្ថុនោះ ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ដែលបានកើតឡើងនៅពេលក្រោយមក នៅតែបន្តអត្ថិភាពនៅក្រោយការលក់ នោះនឹងអាចនាំឱ្យមានការខូចខាតដល់សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ និយាយម្យ៉ាងទៀត វានឹងនាំឱ្យកើតការបារម្ភថា អចលនវត្ថុនោះ នឹងលក់បានថោកជាងតម្លៃរបស់វានៅពេលបង្កើតសិទ្ធិប្រាតិភោគ ហើយម្ចាស់សិទ្ធិប្រាតិភោគ នឹងមិនអាចប្រមូលបំណុលដែលត្រូវបានធានា តាមការរំពឹងទុកបាន ។ ហេតុនេះហើយ ក្នុងករណីបែបនេះ គេគួរនិយាយថា ល័ក្ខខ័ណ្ឌសម្រាប់ការបន្តអត្ថិភាព ឬ ការរលត់

ឬ ការបាត់បង់អានុភាពនៃបន្ទុកលើអចលនវត្ថុនោះ នៅក្រោយការលក់ ស្ថិតនៅលើថាតើបន្ទុកទាំងនោះ អាចតតាំងជាមួយនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត បានដែរឬទេ ។

ហេតុនេះហើយបានជា នៅក្នុងការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ សិទ្ធិប្រាតិភោគ ប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ ហើយដែល អាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ដោយ បង្ខំ (មាត្រា ៥១០ កថាខណ្ឌទី ១) ហើយសិទ្ធិផ្សេងទៀតដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ ក្រៅពី សិទ្ធិទាំងនេះ (សិទ្ធិដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តបាន) ត្រូវរលត់ ដោយសារការលក់ដោយបង្ខំ (មាត្រា ៥១០ កថាខណ្ឌទី ២) ។ ចំពោះការអនុវត្តការចាត់ចែងជា បណ្តោះអាសន្ន ក៏ត្រូវអនុលោមទៅតាមវិធានដូចគ្នានេះដែរ (មាត្រា ៥១០ កថាខណ្ឌទី ៣) ។ ទោះជា យ៉ាងណាក៏ដោយ នៅក្នុងផ្នែកនេះ ការរឹបអូស ឬ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន តែងតែបាត់បង់ អានុភាពដោយការលក់ជានិច្ច (មាត្រា ៥១០ កថាខណ្ឌទី ៣) ។ ម៉្យាងវិញទៀត ប្រសិនបើអ្នកដែល មានទំនាក់ទំនងនឹងផលប្រយោជន៍ បានធ្វើការព្រមព្រៀងគ្នាផ្សេងពីល័ក្ខខ័ណ្ឌនៃការលក់ ដូចខាងលើ ហើយ បានរាយការណ៍អំពីការណ៍នេះ ទៅតុលាការអនុវត្តថា នៅមុនពេលដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ នោះអចលនវត្ថុ ត្រូវលក់ទៅតាមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងគ្នានោះ (មាត្រា ៥១០ កថាខណ្ឌទី ៤) ។

### (iii) **ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា**

(១) នៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគ អាចមានករណីមួយចំនួនដែលពាក្យសុំឱ្យលក់ដោយបង្ខំ ដែល ជាការអនុវត្តសិទ្ធិប្រាតិភោគដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ត្រូវបានដាក់ ចំពោះអចលនវត្ថុដែល ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានចេញរួចទៅហើយ តាមពាក្យសុំឱ្យលក់ដោយបង្ខំ ដែលជាការ អនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ឬ ក៏អាចមានករណីដែល ចំពោះអចលនវត្ថុតែមួយដែលដីកាសម្រេច ចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានចេញរួចទៅហើយ តាមពាក្យសុំឱ្យលក់ដោយបង្ខំដែលការអនុវត្តសិទ្ធិ ប្រាតិភោគ ពាក្យសុំឱ្យលក់ដោយបង្ខំមួយទៀត ដែលជាការអនុវត្តសិទ្ធិប្រាតិភោគដែរ ត្រូវបានដាក់ ដោយ ម្ចាស់សិទ្ធិប្រាតិភោគម្នាក់ទៀត ។ នៅក្នុងករណីទាំងនេះ មានសំណួរចោទឡើងថាតើគួរចាត់ការលើពាក្យសុំ ឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ដែលត្រូវបានដាក់តាមក្រោយនោះ យ៉ាងដូចម្តេច ។ គួររំលឹកថា មាត្រា ៤២៥ ចែងអំពីករណីដែលពាក្យសុំឱ្យលក់ដោយបង្ខំដែលជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវ បានដាក់ ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវ បានចេញរួចទៅហើយ (ចំពោះករណីនេះ សូមមើលជំពូកទី ៣ ផ្នែកទី ១ កថាភាគទី ៤ ចំណុចទី ២ ៦. (i)) ។

(២) ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិ ប្រាតិភោគ :

(ក) ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា : ប្រសិនបើមានពាក្យសុំឱ្យលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគផ្សេងទៀត ត្រូវបានដាក់ដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដែលជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនោះ ត្រូវបានចេញរួចទៅហើយ ហើយបើទទួលស្គាល់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគនោះ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត (មាត្រា ៥១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ នៅក្នុងករណីនេះ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន (មាត្រា ៥១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្តើមមុន ត្រូវទទួលនោះ នឹងរងការប៉ះពាល់ ។ ហេតុនេះហើយបានជាបញ្ញត្តិស្តីពីការជូនដំណឹងនេះ ត្រូវបានចែងឡើង ដើម្បីផ្តល់ឱកាសឱ្យម្ចាស់បំណុលនោះ អាចចាត់វិធានការផ្សេងៗ ដូចជាធ្វើការអនុវត្តចំពោះទ្រព្យសម្បត្តិផ្សេងទៀត ជាអាទិ៍ ។

(ខ) ការលក់ដោយបង្ខំ នៅក្នុងការអនុវត្តដោយបង្ខំមុន ចំពោះអចលនវត្ថុ និង ការបន្តអត្ថិភាព និង ការរលត់នៃសិទ្ធិដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ : ទោះបីជាមានការចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នាក៏ដោយ ប្រសិនបើពុំមានកាលៈទេសៈពិសេសទេ នីតិវិធីបន្តបន្ទាប់នៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលបានចាប់ផ្តើមមុន នៅតែបន្តទៅមុខដដែល ។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ លក្ខខណ្ឌនៃការលក់ ដែលទាក់ទងទៅនឹងការបន្តអត្ថិភាព និង ការរលត់នៃបន្ទុកលើអចលនវត្ថុ ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុជាគោលការណ៍ ត្រូវបានកំណត់ដោយផ្អែកទៅលើកត្តាថាតើសិទ្ធិទាំងនោះ អាចតតាំងជាមួយនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបានដែរឬទេ ។ មានន័យថា សិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ណាដែលអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបាន បន្តមានអត្ថិភាព ហើយសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ណាដែលមិនអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវរលត់ (មាត្រា ៤៣១) ។ ក៏ប៉ុន្តែ ក្នុងករណីដែលចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ពោលគឺដីកាសម្រេចចាប់ផ្តើមក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុផង និង ដីកាសម្រេចចាប់ផ្តើមក្នុងការអនុវត្តសិទ្ធិប្រាតិភោគផង ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគដែលបានដាក់ក្រោយ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងការរឹបអូសដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តមុនបាន នោះលក្ខខណ្ឌនៃការលក់ ត្រូវកំណត់ដោយផ្អែកទៅលើកត្តាថាតើសិទ្ធិដែលជាបន្ទុកលើអចលនវត្ថុទាំងនោះ អាចតតាំងជាមួយនឹងសិទ្ធិប្រាតិភោគនោះដែរឬទេ ។ ហេតុនេះហើយ ទោះបីជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ អាចតតាំងជាមួយនឹងការរឹបអូស

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលបានចាប់ផ្ដើមមុនក៏ដោយ ប្រសិនបើសិទ្ធិទាំងនេះ មិនអាចតតាំងជាមួយនឹងសិទ្ធិប្រាតិភោគ ដែលជាមូលដ្ឋាននៃការអនុវត្តសិទ្ធិប្រាតិភោគ ដែលបានចាប់ផ្ដើមក្រោយទេ សិទ្ធិទាំងនេះនឹងត្រូវរលត់ នៅក្រោយការលក់ (មាត្រា ៥១៣ កថាខណ្ឌទី ១) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា : ជាគោលការណ៍ នៅក្រោយការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ នៅតែបន្តទៅមុខជាលំដាប់ ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។ ក៏ប៉ុន្តែ ដោយសារថា ម្ចាស់សិទ្ធិប្រាតិភោគ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគរួចទៅហើយ ហើយដីកាសម្រេចចាប់ផ្ដើមដោយផ្អែកលើពាក្យសុំនោះ ក៏ត្រូវបានចេញរួចទៀតនោះ នីតិវិធីដែលកំពុងដើរនោះ ត្រូវចាត់ទុកថាជានីតិវិធីដែលមានគោលបំណងសម្រេចនូវសិទ្ធិប្រាតិភោគ របស់ម្ចាស់បំណុលនៃការអនុវត្តក្រោយនេះ ដែរ ។ មានន័យថា ក្នុងករណីនៃការលក់អចលនវត្ថុ ក្នុងនីតិវិធីនៃការលក់ដោយបង្ខំនេះ ប្រសិនបើឱ្យសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ ដែលអាចតតាំងជាមួយនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុន បន្តមានអត្ថិភាពនៅក្រោយការលក់ ទោះបីជាសិទ្ធិនោះមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគដែលជាមូលដ្ឋាននៃការអនុវត្តសិទ្ធិប្រាតិភោគក្រោយបាន នោះនឹងនាំឱ្យកើតការបារម្ភថា ផលប្រយោជន៍របស់ម្ចាស់សិទ្ធិប្រាតិភោគ ដែលមានអាទិភាពលើសិទ្ធិទាំងនោះ តាមច្បាប់សារធាតុ នឹងទទួលរងការខូចខាត ។ ហេតុនេះហើយ សិទ្ធិទាំងនោះត្រូវតែរលត់ ។ ឧទាហរណ៍ថា នៅលើអចលនវត្ថុមួយ មានការបង្កើតហ៊ីប៉ូតែកលំដាប់ទី ១, ហ៊ីប៉ូតែកលំដាប់ទី ២, និង ហ៊ីប៉ូតែកលំដាប់ទី ៣ ហើយ នៅក្រោយពេលដែលម្ចាស់បំណុលទូទៅម្នាក់ បានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះ ហើយបានទទួលដីកាសម្រេចចាប់ផ្ដើមការលក់ ស្រាប់តែម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ហើយពេលនោះ តុលាការបានចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា ។ ក្នុងករណីនេះ ជាការពិត ដែលថា ហ៊ីប៉ូតែកលំដាប់ទី ១ នឹងត្រូវរលត់ នៅពេលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ នោះ បានទទួលចំណែកពីប្រាក់ថ្លៃលក់ ព្រោះថាម្ចាស់បំណុលហ៊ីប៉ូតែកនេះ បានអនុវត្តសិទ្ធិរបស់ខ្លួនហើយ ដើម្បីទទួលការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។ ក៏ប៉ុន្តែ ប្រសិនបើហ៊ីប៉ូតែកលំដាប់ទី ២ និង ហ៊ីប៉ូតែកលំដាប់ទី ៣ ដែលមិនអាចតតាំងនឹងហ៊ីប៉ូតែកលំដាប់ទី ១ បាននៅតែបន្តអត្ថិភាពនៅក្រោយការលក់នោះ អចលនវត្ថុនឹងត្រូវលក់ក្នុងតម្លៃដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលបានធានាដោយហ៊ីប៉ូតែកលំដាប់ទី ២ និង ហ៊ីប៉ូតែកលំដាប់ទី ៣ នោះ ហើយការណ៍នេះនឹងនាំឱ្យមានការខូចខាតដល់សិទ្ធិរបស់ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ ។ ហេតុនេះហើយបានជា ច្បាប់កំណត់ថា ហ៊ីប៉ូតែកទាំងនេះ ត្រូវរលត់នៅក្រោយការលក់ បើទោះបីជាហ៊ីប៉ូតែកទាំងនេះ អាចតតាំងជាមួយនឹងការរឹបអូសដោយម្ចាស់បំណុលទូទៅ ដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុក៏ដោយ ។ ក្នុងករណីបែបនេះ ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ និង ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣

នឹងទទួលបានចំណែកពីប្រាក់ថ្លៃលក់ ទៅតាមលំដាប់សិទ្ធិរបស់ខ្លួន ។ ក៏ប៉ុន្តែ ក្នុងករណីដែលពាក្យសុំឱ្យអនុវត្ត សិទ្ធិប្រាតិភោគដែលបានដាក់ក្រោយ ត្រូវបានដាក់នៅក្រោយការចាប់ផ្តើមកាលបរិច្ឆេទនៃការលក់ឡាយឡុង ដោយស្រោមសំបុត្រ ឬ ការលក់ឡាយឡុងដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដែលផ្អែកលើពាក្យសុំឱ្យអនុវត្ត ដោយបង្ខំចំពោះអចលនវត្ថុដែលបានដាក់មុន នោះល័ក្ខខ័ណ្ឌនៃការលក់ដែលបានកំណត់រួចហើយ ដោយផ្អែកលើ ការរឹបអូសដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំមុន មិនត្រូវបានផ្លាស់ប្តូរ ឡើយ ហើយត្រូវបន្តអត្ថិភាពដោយគ្មានការកែប្រែ (មាត្រា ៥១៣ កថាខណ្ឌទី ៣) ។ មូលហេតុនៃ ការកំណត់បែបនេះ ព្រោះថា អ្នកស្នើសុំទិញ បានស្នើសុំទិញ ដោយទទួលយកល័ក្ខខ័ណ្ឌនៃការលក់នេះ មកធ្វើជាបុរេល័ក្ខខ័ណ្ឌនៃសំណើទិញទៅហើយ ។ ហេតុនេះ ការផ្លាស់ប្តូរល័ក្ខខ័ណ្ឌនៃការលក់ និង ការចាប់ផ្តើម នីតិវិធីសាជាថ្មី មិនយុត្តិធម៌សម្រាប់អ្នកស្នើសុំទិញនោះទេ ។ ចំពោះចំណាត់ការលើពាក្យសុំឱ្យអនុវត្ត សិទ្ធិប្រាតិភោគ ដែលបានដាក់ក្រោយ នៅក្នុងករណីនេះ សូមមើលចំណុច (ឃ) ខាងក្រោម ។

(គ) ការដកពាក្យសុំឱ្យលក់ដោយបង្ខំមុន និង ការផ្អាកនិងការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំមុន :

(a) ប្រសិនបើពាក្យសុំឱ្យលក់ដោយបង្ខំមុន ត្រូវបានដក ឬ បើនីតិវិធីមុន ត្រូវបានលុបចោល នោះនីតិវិធី នៃការលក់ដោយបង្ខំក្រោយ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបន្ត (មាត្រា ៥១១ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ត្រូវបានដាក់នៅក្រោយពេលកំណត់ ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដែលបានកំណត់នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំមុន (សូម មើលមាត្រា ៤២២) តុលាការអនុវត្ត ត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ជាថ្មី (មាត្រា ៥១១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។ បើមិនធ្វើដូច្នេះទេ ទោះបីជានីតិវិធីនៃការលក់ដោយ បង្ខំដោយផ្អែកលើពាក្យសុំក្រោយ ត្រូវបានអនុវត្តក៏ដោយ ម្ចាស់បំណុលដទៃទៀត នឹងមិនអាចទាមទារឱ្យចែក ចំណែក តាមនីតិវិធីក្រោយនេះបានឡើយ ។ រីឯចំពោះបុគ្គលដែលត្រូវបានដាស់តឿន និង បានធ្វើសេចក្តី រាយការណ៍អំពីសិទ្ធិលើបំណុល ជាអាទិ៍ រួចហើយ តុលាការអនុវត្ត មិនចាំបាច់ធ្វើការដាស់តឿន (មាត្រា ៤២២ កថាខណ្ឌទី ២) ទៀតទេ (មាត្រា ៥១១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

(b) ប្រសិនបើនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានផ្អាក តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេច ចាប់ផ្តើមក្រោយ (មាត្រា ៥១១ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ នៅក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគ របស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្តើមក្រោយ អាចតតាំងជាមួយនឹងការរឹបអូស ដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន នោះល័ក្ខខ័ណ្ឌនៃការលក់ នឹងពុំមានការផ្លាស់ប្តូរទេ (មាត្រា ៥១៣ កថាខណ្ឌទី ១, សូមមើលចំណុច (ខ) ខាងលើ) ។ ហេតុនេះហើយ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេច បន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃ

ការអនុវត្តក្រោយ និង ត្រូវបន្តនីតិវិធីនៃការលក់ សម្រាប់ម្ចាស់បំណុលនៃការអនុវត្តនោះ (មាត្រា ៥១១ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២) ។ នៅពេលដែលចេញដីកាសម្រេចបន្តនីតិវិធីនោះ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៥១១ កថាខណ្ឌទី ៥) ។

(ឃ) ការផ្អាកនីតិវិធីក្រោយ បន្ទាប់ពីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា : ប្រសិនបើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានដាក់ នៅក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ការលក់ឡាយឡុងដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្ដើមទៅហើយ នោះតុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា ដោយគ្រាន់តែផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសប៉ុណ្ណោះ ហើយព្រមពេលជាមួយគ្នានេះ ត្រូវចេញដីកាសម្រេចផ្អាកនីតិវិធីនៃការលក់ដោយបង្ខំក្រោយ ជាបន្ទាន់ (មាត្រា ៥១៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ដោយសារថា នីតិវិធីមុនបានដើរដល់កាលបរិច្ឆេទនៃការលក់ទៅហើយនោះ ល័ក្ខខ័ណ្ឌនៃការលក់ នឹងពុំមានការផ្លាស់ប្ដូរទេ (មាត្រា ៥១៣ កថាខណ្ឌទី ៣) ហើយនីតិវិធីនោះ នឹងបន្តដោយពុំមានការកែប្រែ ដោយរង់ចាំមើលដំណាក់កាលតមកទៀត ដើម្បីកំណត់ថាតើគួរចាត់ការនីតិវិធីក្រោយ តាមរបៀបណា ។ ប្រសិនបើនីតិវិធីមុន បន្តដំណើរការទៅមុខ ហើយដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ រួចអ្នកទិញបានបង់ថ្លៃលក់នោះ តុលាការអនុវត្តត្រូវលុបចោលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ (មាត្រា ៥១៥ កថាខណ្ឌទី ៣) ។ ក្នុងករណីបែបនេះ សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ មិនរលត់ដោយការលក់ទេ គឺវាបន្តមានអត្ថិភាព ហើយនឹងត្រូវទទួលយកដោយអ្នកទិញ ។ ផ្ទុយទៅវិញ ប្រសិនបើនីតិវិធីមុន មិនបន្តឈានទៅដល់ដំណាក់កាលនៃការបង់ប្រាក់ថ្លៃលក់ដោយអ្នកទិញ ហើយត្រូវចាប់ផ្ដើមសាជាថ្មីចាប់ពីដំណាក់កាលនៃការកំណត់កាលបរិច្ឆេទនៃការលក់នោះ តុលាការអនុវត្ត ត្រូវលុបចោលដីកាសម្រេចដែលបង្គាប់ឱ្យផ្អាកនីតិវិធីក្រោយ កែប្រែល័ក្ខខ័ណ្ឌនៃការលក់ដែលទាក់ទងទៅនឹងបន្ទុក និង បន្តនីតិវិធីនោះ ។ នៅក្នុងករណីផ្ទុយពីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ មិនអាចតតាំងជាមួយនឹងការរឹបអូសដោយដីកាសម្រេចចាប់ផ្ដើមមុនទេ ល័ក្ខខ័ណ្ឌនៃការលក់នឹងមិនទទួលរងការប៉ះពាល់ឡើយ ។ ហេតុដូច្នេះ តុលាការអនុវត្ត មិនចាំបាច់ផ្អាកនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមក្រោយនោះទេ (មាត្រា ៥១៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

(៣) ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ :

(ក) ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា : បើមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគផ្សេងទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានសម្រេចរួចហើយ ហើយទទួលស្គាល់ពាក្យសុំនោះ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីទៀត (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) (មាត្រា ៥១២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក្នុងករណីនេះ តុលាការអនុវត្ត ត្រូវជូន

ដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេចចាប់ផ្តើមមុន (មាត្រា ៥១២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ចំពោះចំណាត់ការនៃនីតិវិធីនៅក្នុងករណីនេះ ជាគោលការណ៍ ត្រូវអនុលោមទៅតាមវិធីនៃការចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ ។

(ខ) ការលក់ដោយបង្ខំ នៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគមុន និង ការបន្តអត្ថិភាព ឬ ការរលត់នៃសិទ្ធិដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ : ក្នុងករណីនៃការចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុម្តងរួចមកហើយនោះ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តមុនបាន ល័ក្ខខ័ណ្ឌនៃការលក់ដែលទាក់ទងនឹងការបន្តអត្ថិភាព ឬ ការរលត់នៃបន្ទុក ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ត្រូវកំណត់ទៅតាមស្ថានភាពថាតើសិទ្ធិទាំងនោះ អាចតតាំងនឹងសិទ្ធិប្រាតិភោគនោះបានដែរឬទេ (មាត្រា ៥១៣ កថាខណ្ឌទី ១) ។ ផ្ទុយទៅវិញ ក្នុងករណីនៃការចេញដីកាសម្រេចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគត្រួតគ្នា ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគរួចហើយនោះ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុន ល័ក្ខខ័ណ្ឌនៃការលក់នោះ ត្រូវកំណត់ទៅតាមស្ថានភាពថាតើបន្ទុកនោះ អាចតតាំងនឹងសិទ្ធិប្រាតិភោគនៃការអនុវត្តក្រោយនោះ បានដែរឬទេ (មាត្រា ៥១៣ កថាខណ្ឌទី ២) ។ មានន័យថា ក្នុងករណីនៃការចេញដីកាសម្រេចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគត្រួតគ្នា ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគរួចហើយ នៅចុងបញ្ចប់ ល័ក្ខខ័ណ្ឌនៃការលក់ ត្រូវកំណត់ទៅតាមលំដាប់អាទិភាពនៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលដែលបានដាក់ពាក្យសុំ ហើយដោយផ្អែកទៅតាមសិទ្ធិប្រាតិភោគដែលមានអាទិភាព ។ ហេតុនេះហើយ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយ អាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំមុន (មានន័យថា សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលក្រោយ មានអាទិភាពជាងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលមុន) សិទ្ធិប្រាតិភោគប្រត្យក្ស ឬ សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ទាំងឡាយណាដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគក្រោយនោះបាន នឹងមិនរលត់ដោយសារការលក់ទេ ពោលគឺវានឹងបន្តអត្ថិភាពទៅមុខទៀត ។ ផ្ទុយទៅវិញ ចំពោះសិទ្ធិដែលជាបន្ទុកទាំងឡាយណា ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគក្រោយនោះបាន នឹងត្រូវរលត់ដោយការលក់ដោយបង្ខំ (មាត្រា ៥១៣ កថាខណ្ឌទី ២) ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ហើយការរឹបអូស និង ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ជានិច្ចកាល ត្រូវបាត់បង់

អានុភាពដោយសារការលក់ ដូចគ្នានឹងករណីនៃការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគដែរ ។

(គ) ការដកពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគមុន និង ការលុបចោលនិងការផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគមុន :

(a) បើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចមុន ត្រូវបានលុបចោល តុលាការអនុវត្ត ត្រូវបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ (មាត្រា ៥១២ កថាខណ្ឌទី ២) ។ ក្នុងករណីនេះ ប្រសិនបើពាក្យសុំឱ្យអនុវត្តក្រោយ ត្រូវបានដាក់នៅក្រោយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដែលបានកំណត់នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំមុន នោះតុលាការអនុវត្ត ត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី (មាត្រា ៥១២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។ ក្នុងករណីនេះ តុលាការអនុវត្ត មិនចាំបាច់ដាស់តឿនចំពោះជនដែលបានធ្វើសេចក្ដីរាយការណ៍ តាមការដាស់តឿននៅក្នុងនីតិវិធីមុនទេ (មាត្រា ៥១២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

(b) ប្រសិនបើនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានផ្អាក តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ (មាត្រា ៥១២ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ ក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ អាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុនបាន នោះដោយសារល័ក្ខខ័ណ្ឌនៃការលក់ មិនមានការផ្លាស់ប្ដូរអ្វីទេ ហេតុដូច្នេះ តុលាការអនុវត្ត អាចចេញដីកាសម្រេចបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តក្រោយបាន ហើយត្រូវជូនដំណឹងអំពីការណ៍នេះទៅឱ្យកូនបំណុលនៃការអនុវត្តផង (មាត្រា ៥១២ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២ និង កថាខណ្ឌទី ៥) ។

(ឃ) ការផ្អាកនីតិវិធីក្រោយ នៅក្រោយពេលចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា : ដូចក្នុងករណីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរួចហើយដែរ ក្នុងករណីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគរួចហើយ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ត្រូវបានដាក់ នៅក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគមុន បានចាប់ផ្ដើម តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា និង ត្រូវផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចនោះ ហើយព្រមជាមួយគ្នានេះ

ត្រូវចេញដីកាសម្រេចបង្គាប់ឱ្យផ្អាកនីតិវិធីក្រោយជាបន្ទាន់ (មាត្រា ៥១៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ ចំពោះចំណាត់ការបន្តទៅទៀតនៃនីតិវិធីនៃការអនុវត្តដោយបង្ខំក្រោយ ត្រូវអនុលោមទៅតាមករណីនៃការចេញដីកាសម្រេចត្រួតគ្នា នៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគដែរ (មាត្រា ៥១៥ កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ មិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុនបានទេ នោះតុលាការអនុវត្ត មិនចាំបាច់ចេញដីកាសម្រេចបង្គាប់ឱ្យផ្អាកនីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមក្រោយឡើយ ព្រោះវាពុំមានឥទ្ធិពលអ្វីចំពោះល័ក្ខខ័ណ្ឌនៃការលក់នោះទេ (មាត្រា ៥១៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

(៤) ការរៀបចំឯកសារលំអិតអំពីវត្ថុ ជាអាទិ៍ ក្នុងករណីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា : ដូចបានពន្យល់ខាងលើ ក្នុងករណីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ ក៏ដូចជាក្នុងករណីចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ នីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន នឹងបន្តដំណើរការទៅមុខ លើកលែងតែមានកាលៈទេសៈពិសេស ។ ក៏ប៉ុន្តែ ល័ក្ខខ័ណ្ឌនៃការលក់ដែលទាក់ទងទៅនឹងការបន្តអត្ថិភាព ឬ ការរលត់ នៅក្រោយការលក់ នៃបន្ទុកលើអចលនវត្ថុ ដូចជាសិទ្ធិប្រាតិភោគប្រត្យក្សសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ មិនតែងតែត្រូវបានកំណត់ដោយផ្អែកលើស្ថានភាព ថាតើសិទ្ធិនោះអាចតតាំងជាមួយនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុន ឬ អាចតតាំងជាមួយនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុននោះទេ ។ ក្នុងករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមក្រោយ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុន (ក្នុងករណីនៃការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ឬ អាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្ដើមមុន (ក្នុងករណីនៃការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) បាន បន្ទុកលើអចលនវត្ថុ ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ទាំងឡាយណាដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគក្រោយនោះបាន ត្រូវរលត់ដោយការលក់ដោយបង្ខំ (មាត្រា ៥១៣ កថាខណ្ឌទី ១ និង ទី ២) ។ ម្យ៉ាងទៀត សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តក្រោយ ដែលត្រូវបានអនុវត្តនោះ នឹងត្រូវរលត់ ហើយម្ចាស់បំណុលក្រោយនោះ នឹងទទួលបានចំណែកពីប្រាក់ថ្លៃលក់ ។ មានន័យថា ក្នុងករណីនេះ ប្រសិនបើមានដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នោះល័ក្ខខ័ណ្ឌនៃការលក់ដែលទាក់ទងនឹងការបន្តអត្ថិភាព ឬ ការរលត់នៃបន្ទុកលើអចលនវត្ថុ នឹងត្រូវ

បានកែប្រែ ។

អាស្រ័យហេតុនេះហើយ ក្នុងករណីបែបនេះ ទោះបីជាអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុនក៏ដោយ តុលាការអនុវត្ត ត្រូវកំណត់តម្លៃលក់អប្បបរមា (មាត្រា ៤៣២ កថាខណ្ឌទី ១) និង រៀបចំឯកសារលំអិតអំពីវត្ថុ (មាត្រា ៤៣៤ កថាខណ្ឌទី ១) ដោយគិតពិចារណាអំពីការរលត់នៅក្រោយការលក់ដោយបង្ខំ នៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ក៏ដូចជាសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល ជាអាទិ៍ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះបាន (មាត្រា ៥១៤ កថាខណ្ឌទី ១) ។ ប្រសិនបើបានកំណត់តម្លៃលក់អប្បបរមា ឬ បានរៀបចំឯកសារលំអិតអំពីវត្ថុរួចហើយ នៅក្នុងនីតិវិធីមុន នៅពេលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ នោះតុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ឬ ត្រូវរៀបចំឯកសារលំអិតអំពីវត្ថុនោះ សាជាថ្មី ។

ម្យ៉ាងទៀត ដើម្បីជៀសវាងការដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគបន្ថែមទៀត នៅក្នុងខណៈដែលនីតិវិធីនៃការលក់ដោយបង្ខំមុន បានដើរដល់ដំណាក់កាលសំខាន់ទៅហើយនោះ ទើបនៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តុលាការអនុវត្ត ត្រូវដាស់តឿនម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ឱ្យរាយការណ៍ថាតើខ្លួនមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគនោះ ដែរឬទេ (មាត្រា ៤២២ កថាខណ្ឌទី ២ ចំណុច ខ និង កថាខណ្ឌទី ៣) ។

## ៤. ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ

### (i) កំណត់សំគាល់ទូទៅ

តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី នៅពេលអចលនវត្ថុណាមួយត្រូវបានរឹបអូសដើម្បីអនុវត្តសិទ្ធិប្រាតិភោគ អានុភាពនៃសិទ្ធិប្រាតិភោគលើអចលនវត្ថុនោះ ត្រូវមានទៅលើផលដែលកើតចាប់ពីពេលរឹបអូសនោះផងដែរ (មាត្រា ៨៤៨ វាក្យខណ្ឌទី ២, មាត្រា ៨១៥ និង មាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណី) ។ ហេតុនេះហើយ បានជាក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគត្រូវបានជួល ក្រមនីតិវិធីរដ្ឋប្បវេណី (ចាប់ពីមាត្រា ៥១៦ ទៅ) ចែងនីតិវិធីបន្ទាប់បន្សំនៃការលក់ដោយបង្ខំ អំពីវិធីដែលម្ចាស់សិទ្ធិប្រាតិភោគអាចសម្រេចនូវអានុភាពនៃសិទ្ធិប្រាតិភោគនោះ ដែលមានទៅដល់ប្រាក់ថ្លៃឈ្នួល (ផលស៊ីវិល) ក្រោយការរឹបអូសអចលនវត្ថុនោះ និង អាចទទួលការសង ដោយមានអាទិភាព ពីថ្លៃលក់ ព្រមទាំងប្រាក់ថ្លៃឈ្នួល (ចាប់ពីត្រឹមនេះទៅ ហៅថា សិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល) ។ ក្នុងនីតិវិធីនេះ សិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ត្រូវបានរឹបអូស ហើយបុគ្គលដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល (កូនបំណុលទី ៣) ត្រូវផ្ញើប្រាក់ថ្លៃឈ្នួលនោះ ទុកនៅនឹងតុលាការ ។ ការរៀបចំបែបនេះ ស្ទើរតែដូចគ្នាទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ (សូមមើលជំពូកទី ៣ ផ្នែកទី ១ កថាភាគទី ៣) ។ ក៏ប៉ុន្តែ ម្ចាស់បំណុលនៃ

ការអនុវត្ត មិនអាចប្រមូលដោយផ្ទាល់ នូវសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលនោះបានទេ គឺគ្រាន់តែអាចទាមទារឱ្យបុគ្គលដែលមានករណីយកិច្ចបង់ប្រាក់ថ្លៃឈ្នួល ផ្ញើប្រាក់ថ្លៃឈ្នួលនោះ នៅតុលាការអនុវត្តប៉ុណ្ណោះ ។ម្យ៉ាងទៀត សិទ្ធិដាក់ពាក្យបណ្តឹងទាមទារប្រមូលបំណុល ក៏មិនត្រូវបានទទួលស្គាល់ទេ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល មានអានុភាពតែក្នុងរយៈពេលខ្លីពោលគឺត្រឹមតែពេលដែលអចលនវត្ថុ ត្រូវបានលក់ដោយបង្ខំប៉ុណ្ណោះ ។ ហេតុនេះហើយបានជាគេគិតថានីតិវិធីដែលមានដំណើរការតែក្នុងករណីដែលអ្នកជួលធ្វើការផ្ញើប្រាក់ទុកដោយស្ម័គ្រចិត្ត នៅតុលាការ ជានីតិវិធីដែលមានប្រយោជន៍ ។

(ii) **នីតិវិធី**

(១) ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ៖ ក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគត្រូវបានជួល ប្រសិនបើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញហើយការរឹបអូសអចលនវត្ថុនោះ មានអានុភាព នោះម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំឱ្យរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុនោះ ទៅតុលាការអនុវត្តបាន ។ ប្រសិនបើទទួលស្គាល់ពាក្យសុំនេះតុលាការអនុវត្ត ត្រូវចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល (មាត្រា ៥១៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ដីកាសម្រេចនេះ ត្រូវធ្វើឡើងដោយមិនសួរកូនបំណុលនៃការអនុវត្ត និង អ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលអចលនវត្ថុនោះ (មាត្រា ៥១៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា បើសួរកូនបំណុលនៃការអនុវត្ត ឬ អ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលមុននឹងចេញដីកាសម្រេចរឹបអូស នោះនឹងនាំឱ្យកូនបំណុលនៃការអនុវត្ត អាចដឹងអំពីការរឹបអូសជាមុន ហើយការណ៍នេះនឹងធ្វើឱ្យកូនបំណុលនោះ អាចដោះខ្លួនពីការអនុវត្ត ដោយធ្វើការចាត់ចែងផ្សេងៗ ដូចជាការប្រមូលប្រាក់ថ្លៃឈ្នួល ជាអាទិ៍ ។

នៅក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្ត ត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ក្នុងការប្រមូលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល ឬ ធ្វើការចាត់ចែងផ្សេងទៀត ហើយត្រូវហាមឃាត់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ក្នុងការសងទៅឱ្យកូនបំណុលនៃការអនុវត្ត ហើយត្រូវបង្គាប់ឱ្យជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលនោះ ផ្ញើនូវប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដែលត្រូវបានរឹបអូស នៅតុលាការអនុវត្ត (មាត្រា ៥១៦ កថាខណ្ឌទី ២) ។ ដីកាសម្រេចរឹបអូស ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល (មាត្រា ៥១៦ កថាខណ្ឌទី ៣) ។ អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅដល់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល (មាត្រា ៥១៦ កថាខណ្ឌទី ៤) ។

(២) ការផ្ញើប្រាក់ថ្លៃឈ្នួល ៖ ម្ចាស់បំណុលនៃការអនុវត្ត ដែលបានរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល

អចលនវត្ថុ អាចទាមទារឱ្យអ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ផ្ញើប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដែលត្រូវបានរឹបអូសនោះ ទៅតុលាការអនុវត្តបាន បើអំឡុងពេល ១ សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅដល់កូនបំណុលនៃការអនុវត្ត (មាត្រា ៥១៧ កថាខណ្ឌទី ១) ។ អានុភាពនៃការរឹបអូស ត្រូវមានទៅលើថ្លៃឈ្នួលដែលកូនបំណុលនៃការអនុវត្តត្រូវទទួល ក្រោយការរឹបអូស រហូតដល់ពេលដែលអ្នកទិញបង់ថ្លៃលក់អចលនវត្ថុនោះ (មាត្រា ៥១៧ កថាខណ្ឌទី ២) ។ បន្ទាប់ពីអ្នកទិញបានបង់ថ្លៃលក់ នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំ និង បានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុហើយ សិទ្ធិទទួលផល ត្រូវផ្ទេរទៅឱ្យអ្នកទិញនោះ (សូមមើលជំពូកទី ៣ ផ្នែកទី ១ កថាភាគទី ៤ ចំណុចទី ២ **៥.** (iv)) ។ ហេតុនេះហើយ អានុភាពនៃការរឹបអូស មិនមានទៅលើប្រាក់ថ្លៃឈ្នួលនៅពេលក្រោយពីនោះទេ ។ ម្យ៉ាងទៀត នៅក្នុងអំឡុងពេលចាប់ពីពេលដែលការរឹបអូស បានបង្កើតអានុភាពរហូតដល់ការបង់ថ្លៃលក់ដោយអ្នកទិញ ទោះជាទឹកប្រាក់នៃសិទ្ធិលើបំណុលដែលកំពុងត្រូវបានអនុវត្ត (ទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា) មានចំនួនប៉ុន្មានក៏ដោយ អានុភាពនៃការរឹបអូស ត្រូវមានទៅលើចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ។ មូលហេតុនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ភាពងាយស្រួលដល់នីតិវិធី ហើយ ម្យ៉ាងទៀត ដោយសារហេតុដែលថា នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំនូវអចលនវត្ថុ ម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក មានវិសាលភាពធំទូលាយផង ។

ប្រាក់ថ្លៃឈ្នួលដែលបុគ្គលដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល បានផ្ញើទុកនៅនឹងតុលាការអនុវត្ត ត្រូវចាត់ទុកថាជាផ្នែកមួយនៃថ្លៃលក់ ពោលគឺវាជាប្រភពធនធានមួយសម្រាប់ការចែកចំណែកដែរ (មាត្រា ៥១៧ កថាខណ្ឌទី ៣) ។

### (iii) ភាពជាន់គ្នាជាមួយនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ក្នុងករណីដែលសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ត្រូវបានរឹបអូសដោយផ្អែកលើដីកាសម្រេចរឹបអូសបន្ទាប់បន្សំ នៅក្នុងការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក៏អាចមានហេតុដែលថា ម្ចាស់បំណុលដទៃទៀតធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល (គន្ថីទី ៦ ជំពូកទី ២ ផ្នែកទី ៣) ពោល គឺសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលនោះដែរ ។ ក្នុងករណីបែបនេះ បញ្ហាដែលចោទឡើង គឺនៅត្រង់របៀបនៃការគ្រប់គ្រងលើទំនាក់ទំនងរវាងការរឹបអូសទាំងពីរ ។

ជាដំបូង ក្នុងករណីដែលដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវបានបញ្ជូនទៅដល់បុគ្គលដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល មុនពេលដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដែលជាដីកាសម្រេចបន្ទាប់បន្សំនៅក្នុងការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ បានបង្កើតអានុភាព នោះជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល នឹងមានអាទិភាព ហើយដីកាសម្រេចរឹបអូសដើម្បីម្ចាស់សិទ្ធិប្រាតិភោគ មិនត្រូវបង្កើតអានុភាពឡើយ

(មាត្រា ៥១៨ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តនៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចុះបញ្ជីនៅមុនពេលបញ្ជូនដីកាសម្រេចរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល នោះដីកាសម្រេចរឹបអូសនៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ នឹងមានអាទិភាពជាង ហើយដីកាសម្រេចរឹបអូសនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មិនត្រូវបង្កើតអានុភាពទេ ។

ផ្ទុយទៅវិញ ប្រសិនបើការរឹបអូសនៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានធ្វើឡើងមុន នោះការរឹបអូសនូវសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល តាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មិនអាចធ្វើបានឡើយ ហើយបើទោះបីជាតុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសរួចហើយក៏ដោយ ក៏ដីកាសម្រេចនោះ មិនត្រូវបង្កើតអានុភាពដែរ (មាត្រា ៥១៨ កថាខណ្ឌទី ២) ។

## ៥. វិសាលភាពនៃម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក

នៅក្នុងការលក់ដោយបង្ខំ ដែលជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលទូទៅ សិទ្ធិប្រាតិភោគទាំងឡាយណាដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន នឹងត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ។ ហេតុនេះហើយ ម្ចាស់សិទ្ធិប្រាតិភោគទាំងនេះ មិនមែនជាម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែកទេ ។ម៉្យាងទៀត សិទ្ធិប្រាតិភោគទាំងឡាយណាដែលមិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ពោលគឺសិទ្ធិប្រាតិភោគដែលបានបំពេញល័ក្ខខ័ណ្ឌតតាំង នៅក្រោយពេលដែលការរឹបអូសបានបង្កើតអានុភាព ត្រូវចាត់ទុកថាជាមោឃៈ នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហេតុនេះហើយ ម្ចាស់សិទ្ធិប្រាតិភោគទាំងនេះ មិនអាចទទួលបានចំណែក នៅក្នុងនីតិវិធីនេះបានទេ ។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីសិទ្ធិប្រាតិភោគដែលត្រូវបានអនុវត្តនោះ សិទ្ធិប្រាតិភោគដែលមានលំដាប់ក្រោយ ក៏ត្រូវរលត់ នៅក្រោយការលក់ (មាត្រា ៥១០ កថាខណ្ឌទី ១ និង ទី ២) ។ នៅក្នុងករណីនេះ ម្ចាស់បំណុលដែលសិទ្ធិប្រាតិភោគរបស់ខ្លួនត្រូវរលត់ អាចទទួលបានចំណែក ដោយមិនចាំបាច់ធ្វើការទាមទារឱ្យចែកចំណែកទេ (មាត្រា ៥១៩ វាក្យខណ្ឌទី ១) ។ ម៉្យាងទៀត នៅក្នុងករណីដែលមានម្ចាស់បំណុលដទៃទៀតដែលមានសិទ្ធិប្រាតិភោគ បានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរួចហើយ (សូមមើលមាត្រា ៥១១ និង មាត្រា ៥១២) សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំនេះ ព្រមទាំងសិទ្ធិប្រាតិភោគដែលមានលំដាប់ក្រោយ នឹងត្រូវរលត់ ដោយសារការលក់ដោយបង្ខំ (មាត្រា ៥១៣ កថាខណ្ឌទី ១ និង ទី ២) ហើយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគទាំងនេះ នឹងទទួលបានចំណែក ដោយមិនបាច់ធ្វើការទាមទារឱ្យចែកចំណែកទេ (មាត្រា ៥១៩ វាក្យខណ្ឌទី ១) ។

ក៏ប៉ុន្តែ នៅក្នុងករណីនីមួយៗដូចខាងលើ ប្រសិនបើសិទ្ធិប្រាតិភោគដែលត្រូវរលត់នោះ ត្រូវបានចុះបញ្ជី នៅក្រោយពេលដែលការរឹបអូសដោយដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បានបង្កើតអានុភាព ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគទាំងនោះ មិនអាចទទួលបានចំណែកទេ ( មាត្រា ៥១៩ វាក្យខណ្ឌទី ២) ។

## កថាភាគទី ៥ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា

### ១. កំណត់សំគាល់ទូទៅ

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ជាគោលការណ៍ ត្រូវធ្វើឡើងតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ (គន្លឹះទី ៦ ជំពូកទី ២ ផ្នែកទី ៥) ។ នាវា ( មាត្រា ៤៩៤ កថាខណ្ឌទី ១) គឺជាចលនវត្ថុ តាមក្រមរដ្ឋប្បវេណី ។ ក៏ប៉ុន្តែ តម្លៃរបស់នាវា មានកម្រិតប្រហាក់ប្រហែលទៅនឹងអចលនវត្ថុដែរ ហើយបទប្បញ្ញត្តិច្បាប់ចែងថា ការធ្វើលទ្ធកម្ម ការបាត់បង់ ការផ្លាស់ប្តូរ ជាអាទិ៍ នូវកម្មសិទ្ធិលើនាវា ត្រូវប្រកាសជាសាធារណៈ ដោយការចុះបញ្ជី ។ ហេតុនេះហើយបានជាគេគិតថា ការអនុវត្តចំពោះនាវា តាមវិធីប្រហាក់ប្រហែលគ្នានឹងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានភាពប្រសើរជាងធ្វើតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ។ ដោយហេតុនេះ ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើឡើង ដោយអនុលោមទៅតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ( មាត្រា ៤៩៥ កថាខណ្ឌទី ១) ។ ដោយមូលហេតុដូចគ្នានេះដែរ បញ្ញត្តិស្តីពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា លើកលែងតែមានបញ្ញត្តិពិសេស ( មាត្រា ៥២២) ។

### ២. ការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគ

នៅក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត ( មាត្រា ៤៩៦) ។ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ត្រូវធ្វើឡើងតាមការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ទៅតុលាការអនុវត្ត ( មាត្រា ៤៩៥ កថាខណ្ឌទី ២ និង ទី ៣) ។ ពាក្យសុំនោះ ត្រូវសរសេរបញ្ចូលនូវចំណុចដូចតទៅ : (ក) សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃនាវាដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង, (ខ) សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា, (គ) សញ្ញាណនៃនាវាដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ, (ឃ) ទីកន្លែងដែលនាវាស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវា និង ទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅ នាពេលបច្ចុប្បន្ន, និង (ង) ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិ

លើបំណុលដែលត្រូវបានធានា ( មាត្រា ៥២១ កថាខណ្ឌទី ១) ។

ពាក្យសុំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត សម្រាប់ការអនុវត្តសិទ្ធិប្រាតិភោគ (មាត្រា ៤៩៦) ព្រមទាំងឯកសារដូចតទៅនេះ ដោយអាស្រ័យទៅតាមប្រភេទនៃសិទ្ធិប្រាតិភោគ : (ក) ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនាវា (មាត្រា ៥២១ កថាខណ្ឌទី ២ ចំណុច ក), (ខ) ករណីដែលអនុវត្តឯកសិទ្ធិទូទៅ: ចំពោះនាវាដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនាវា និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ គឺឯកសារដែលបញ្ជាក់ថា នាវានោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះនាវាដែលមិនត្រូវបានចុះបញ្ជី គឺឯកសារដែលបញ្ជាក់ថា នាវាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត (មាត្រា ៥២១ កថាខណ្ឌទី ២ ចំណុច ខ) ។

## ៣. នីតិវិធី

ដូចក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ត្រូវធ្វើឡើងតាមពាក្យសុំរបស់ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ។ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំនូវនាវា និង ត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ (មាត្រា ៤៥៤ កថាខណ្ឌទី ២) ដែលជាឯកសារចាំបាច់សម្រាប់ឱ្យនាវាធ្វើចរាចរណ៍ដោយស្របច្បាប់ មកប្រគល់ជូនតុលាការអនុវត្ត ( មាត្រា ៤៩៧) ។ នៅពេលណាដែលលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ត្រូវបានដកហូតហើយ នាវានោះមិនអាចធ្វើចរាចរណ៍ស្របច្បាប់បានទេ ។

ម្យ៉ាងទៀត ក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ទោះបីជានាវានោះកំពុងស្ថិតនៅក្រោមការកាន់កាប់របស់តតិយជនក៏ដោយ ក៏គេអាចចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំដោយស្របច្បាប់បានដែរ ប្រសិនបើតតិយជននោះពុំមានសិទ្ធិជាមូលហេតុតតិយុត្តនៃការកាន់កាប់ ដែលអាចតតាំងជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគបាន ។ តុលាការអនុវត្ត អាចចេញដីកាសម្រេចបង្គាប់ឱ្យតតិយជនដែលកំពុងកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន (មាត្រា ៥២១ កថាខណ្ឌទី ៣) ។ ចំពោះដីកាសម្រេចអំពីពាក្យសុំនេះ អាចប្ដឹងជំទាស់បាន ( មាត្រា ៥២១ កថាខណ្ឌទី ៤) ។ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំឱ្យអាជ្ញាសាលា ធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ដោយយកដីកាសម្រេចបង្គាប់ឱ្យប្រគល់ ដែលបានចូលជាស្ថាពរមកធ្វើជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ) បាន ។ ចំពោះដីកាសម្រេចនេះទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ( មាត្រា ៥២១ កថាខណ្ឌទី ៥) ។

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ក៏ត្រូវធ្វើឡើងតាមវិធីនៃការលក់ដោយបង្ខំ ដូចករណីនៃការអនុវត្ត

ដោយបង្ខំចំពោះនាវាដែរ ( មាត្រា ៤៥៥ កថាខណ្ឌទី ១) ។

## ផ្នែកទី ៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់

### កថាភាគទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុរូបី

**១. កំណត់សំគាល់ទូទៅ**

ពីទស្សនទានរបស់កូនបំណុល សិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់វត្ថុរូបីក្រៅពីប្រាក់ គឺជាប្រភេទនៃ "បំណុលដែលត្រូវប្រគល់ឱ្យ" ដែលអាចសម្រេចបានដោយការអនុវត្តដោយបង្ខំដោយផ្ទាល់ និងដោយប្រើអំណាចរបស់ស្ថាប័នអនុវត្ត ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារប្រភេទនេះ មិនអាចធ្វើតាមវិធានបង្ខំដោយប្រយោល ( មាត្រា ៥២៨) បានទេ ។

(១) ការប្រគល់វត្ថុរូបី មានន័យថាជាការផ្ទេរការកាន់កាប់ដោយផ្ទាល់ ពោលគឺការគ្រប់គ្រងជាក់ស្តែងលើវត្ថុ ទៅឱ្យម្ចាស់បំណុល ឬ តតិយជន ។

(២) ចំពោះករណីយកិច្ចដែលមានគោលបំណងឱ្យផលិត ឬ កែច្នៃវត្ថុរូបី ហើយប្រគល់វត្ថុនោះដោយសារថាគោលបំណងនៃករណីយកិច្ចនេះ រួមបញ្ចូលផងដែរនូវសកម្មភាពផលិត ឬ កែច្នៃដោយកូនបំណុលដូច្នេះ លើកលែងតែករណីដែលសកម្មភាពទាំងនេះបានបញ្ចប់រួចហើយ គោលបំណងនេះ មិនអាចសម្រេចដោយការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់តែមួយមុខបានឡើយ ។ ចំពោះវត្ថុរូបីទាំងឡាយណាដែលចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌពិសេសដើម្បីគ្រប់គ្រង និង ផ្ទេរ ដូចជាករណីយកិច្ចផ្គត់ផ្គង់សេវាទឹក និង ហ្គាស ជាអាទិ៍ ម្ចាស់បំណុលមិនអាចទទួលបានការកាន់កាប់ ដោយគ្រាន់តែឱ្យស្ថាប័នអនុវត្ត ដកហូតចេញនូវការគ្រប់គ្រងរបស់កូនបំណុលនោះទេ ។ មានន័យថា ករណីយកិច្ចបែបនេះ មិនអាចសម្រេចដោយការអនុវត្តដោយបង្ខំឱ្យប្រគល់ឡើយ ។

(៣) ចំពោះគោលបំណងនៃការប្រគល់វិញ ពុំមានបញ្ហាអ្វីចោទឡើងទេ ទោះបីជាវាផ្អែកលើសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (ដូចជាសិទ្ធិទាមទារឱ្យប្រគល់វត្ថុដោយផ្អែកលើកម្មសិទ្ធិ) ឬ ផ្អែកលើសិទ្ធិទាមទារដែលមានលក្ខណៈជាសិទ្ធិលើបំណុល (ដូចជាការទាមទាររបស់ភតិបតី ឱ្យភតិកៈប្រគល់វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមកវិញ នៅពេលចប់កិច្ចសន្យា) ក៏ដោយ ។ ទោះបីជាក្នុងករណីដែលសិទ្ធិត្រូវបានបង្កើតឡើងនៅពេលប្រគល់វត្ថុក៏ដោយ ក៏គេអាចធ្វើការអនុវត្តឱ្យប្រគល់វត្ថុរូបីបានដែរ ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំ ទាមទារឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប្រគល់វត្ថុបញ្ចាំ ដោយផ្អែកលើការព្រមព្រៀងបង្កើតសិទ្ធិលើការបញ្ចាំ ការប្រគល់នោះ អាចត្រូវបានសម្រេច តាមរយៈការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុរូបីបាន ។

**២. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍**

(១) ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬ ទីទំនេរណាមួយ ទៅឱ្យម្ចាស់បំណុល ឬ តតិយជន ។ វិធីអនុវត្តនេះ អាចធ្វើទៅបាន ដោយមិនបាច់គិតអំពីអត្ថិភាព ឬ នត្ថិភាពនៃការចុះបញ្ជី ឬ សិទ្ធិផ្សេងៗ ដូចជាកម្មសិទ្ធិ ជាអាទិ៍ នៃអចលនវត្ថុដែលជាកម្មវត្ថុទេ ហើយថែមទាំងអាចធ្វើទៅបានចំពោះផ្នែកណាមួយនៃអចលនវត្ថុ ដូចជាចំពោះបន្ទប់មួយនៃផ្ទះ ជាអាទិ៍ ទៀតផង ។ "នាវា ឬ វត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ" សំដៅទៅលើចលនវត្ថុ ដូចជា រថយន្តសម្រាប់បោះជំរំ ផ្ទះចល័ត ជាអាទិ៍ ដែលមនុស្សរស់នៅក្នុងនោះ ។ ជាគោលការណ៍ ការអនុវត្តសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុទាំងនេះត្រូវធ្វើទៅតាមវិធីអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ (មាត្រា ៥២៥) ។ ក៏ប៉ុន្តែ ប្រសិនបើមានមនុស្សរស់នៅក្នុងនោះ នៅពេលអនុវត្ត ចាំបាច់ត្រូវបណ្តេញអ្នកនោះចេញ ។ ហេតុនេះហើយបានជាក្នុងករណីនេះ ត្រូវយកនីតិវិធីនៃការអនុវត្តដោយបណ្តេញចេញពីអចលនវត្ថុ មកអនុវត្ត ដោយអនុលោមទៅតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបណ្តេញចេញពីអាគារ ។ ការប្រគល់ មានន័យថាជាការផ្ទេរនូវការគ្រប់គ្រងដោយផ្ទាល់លើអចលនវត្ថុ ។ ចំណែកឯការបណ្តេញចេញ មានន័យថា ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត និងញាតិរបស់អ្នកនោះ រស់នៅក្នុងអចលនវត្ថុ ជាអាទិ៍ ឬ មានវត្ថុផ្សេងៗទៀតក្នុងនោះ ដូចជាគ្រឿងសង្ហារិម ជាអាទិ៍ អ្នកទាំងនោះត្រូវយកវត្ថុទាំងនោះ ហើយរើចេញពីអចលនវត្ថុនោះ ។

(២) វិធីអនុវត្ត : (ក) ដោយផ្អែកលើអាណត្តិ (ការប្រគល់សិទ្ធិ) របស់ម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើវត្ថុនោះ ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបានការកាន់កាប់នោះ (មាត្រា ៥២៤ កថាខណ្ឌទី ១) ។ ដើម្បីសម្រេចបានតាមគោលបំណងនេះ អាជ្ញាសាលាត្រូវបង្គាប់កូនបំណុលនៃការអនុវត្ត ជាអាទិ៍ ឱ្យចាកចេញ ហើយប្រសិនបើពួកគេមិនព្រមធ្វើតាមការបង្គាប់នេះទេ អាជ្ញាសាលាអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាលបាន ប្រសិនបើចាំបាច់ (មាត្រា ៣៣៨ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ដើម្បីធ្វើការអនុវត្តចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា កាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយឯករាជ្យដាច់ដោយឡែកពីកូនបំណុលនៃការអនុវត្ត (បុគ្គលដែលមិនមែនជាសមាជិកគ្រួសាររបស់កូនបំណុលនៃការអនុវត្ត ជាអាទិ៍) ដូចជាអ្នកជួល ជាដើម នោះចាំបាច់ត្រូវមានលិខិតអនុវត្តចំពោះបុគ្គលនោះ ។

(៣) ការអនុវត្តដោយបង្ខំនេះ អាចធ្វើបានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត (មាត្រា ៥២៤ កថាខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ទោះបីជាការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ត្រូវបានរំលាយក៏ដោយ ក៏មិនអាចសម្រេចគោលបំណងនៃការអនុវត្តបានដែរ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត មិនបានទទួលការកាន់កាប់ទេនោះ ។

(គ) វត្ថុចំណុះទាំងឡាយដែលនៅរួមជាមួយនឹងអចលនវត្ថុដែលជាកម្មវត្ថុ ត្រូវប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយពុំមានការផ្លាស់ប្តូរ (ឧទាហរណ៍ដូចជា វត្ថុតាំងភ្ជាប់ គ្រឿងសង្ហារិម ជាអាទិ៍) ។ ចំពោះចលនវត្ថុក្រៅពីវត្ថុចំណុះ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ឬ តតិយជន លើកលែងតែករណីដែលម្ចាស់បំណុលនៃការអនុវត្ត បានទាមទារឱ្យរឹបអូសដោយការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដាច់ដោយឡែកពីការអនុវត្តឱ្យបណ្តេញចេញពីអចលនវត្ថុ អាជ្ញាសាលាអាចដោះចលនវត្ថុទាំងនោះ ចេញពីអចលនវត្ថុ ហើយប្រគល់ចលនវត្ថុទាំងនោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ (មាត្រា ៥២៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ នៅក្នុងករណីនេះ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុនោះ ទៅឱ្យជនទាំងនោះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ តាមវិធីសមរម្យ ដោយឱ្យកូនបំណុលនៃការអនុវត្ត ចេញសោហ៊ុយក្នុងការថែរក្សាគ្រប់គ្រងនោះ (មាត្រា ៥២៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២ និង កថាខណ្ឌទី ៥) ហើយត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យកូនបំណុលនៃការអនុវត្ត (សូមមើលមាត្រា ៥២៤ កថាខណ្ឌទី ៨) ។ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុ ទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនៃការអនុវត្ត ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា អាចលក់ចលនវត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ហើយក្នុងករណីនេះ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់ នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និង ការថែរក្សាគ្រប់គ្រង ហើយត្រូវធ្វើទុកប្រាក់ដែលនៅសេសសល់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៥២៤ កថាខណ្ឌទី ៦ និង ទី ៧) ។ ដោយសារថា ចលនវត្ថុទាំងនេះ ពុំមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំទេនោះ តតិយជន មិនអាចធ្វើការអះអាងអំពីកម្មសិទ្ធិលើចលនវត្ថុទាំងនោះ មិនអាចដាក់ពាក្យប្តឹងតវ៉ារបស់តតិយជន និង មិនអាចទប់ស្កាត់វិធានការណ៍របស់អាជ្ញាសាលានេះ បានឡើយ ។ ម៉្យាងទៀត ដោយសារថា ស្ថានភាពជាក់ស្តែងរបស់អចលនវត្ថុ មិនអាចកែប្រែបានទេនោះ ប្រសិនបើមានសំណង់ណាមួយដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ស្ថិតនៅលើដីដែលត្រូវបណ្តេញចេញ អាជ្ញាសាលាមិនអាចបំផ្លាញសំណង់នោះ ដោយគ្មានការអនុញ្ញាតឡើយ ។ ដើម្បីទាមទារឱ្យដកសំណង់នេះចេញ ម្ចាស់បំណុលនៃការអនុវត្ត ពុំមានជម្រើសអ្វីផ្សេងក្រៅពីត្រូវទទួលលិខិតអនុវត្តមួយដោយឡែក ដើម្បីអនុវត្តដោយបង្ខំឱ្យដកសំណង់នោះចេញ និង ត្រូវងាកទៅរកវិធីនៃការអនុវត្តជំនួស ដែលនឹងមានពន្យល់នៅផ្នែកខាងក្រោម (មាត្រា ៥២៧) នោះឡើយ ។

(ឃ) ប្រសិនបើមានតតិយជនកំពុងកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុ អាជ្ញាសាលា មិនអាចរំលាយការកាន់កាប់ដោយតតិយជននោះ ហើយប្រគល់អចលនវត្ថុ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយផ្ទាល់បានទេ ។ ក៏ប៉ុន្តែ ប្រសិនបើកូនបំណុលនៃការអនុវត្ត មានសិទ្ធិទាមទារឱ្យប្រគល់ ចំពោះតតិយជននោះ

ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំឱ្យអនុវត្ត តាមវិធីដូចការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ទៅតុលាការអនុវត្ត ដើម្បីទទួលដីកាសម្រេចដែលបង្គាប់ឱ្យរឹបអូសសិទ្ធិទាមទារឱ្យប្រគល់នោះ និង ដែលអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារឱ្យប្រគល់នោះ ដែលបញ្ជាក់ថាម្ចាស់បំណុលនៃការអនុវត្ត អាចទាមទារឱ្យប្រគល់នោះ ចំពោះតតិយជននោះ ជំនួសកូនបំណុលនៃការអនុវត្តបាន (មាត្រា ៥២៦, មាត្រា ៤០២ កថាខណ្ឌទី ៣ និង ទី ៤, មាត្រា ៤០៣, មាត្រា ៤០៥, មាត្រា ៤០៦, និង មាត្រា ៤១០ កថាខណ្ឌទី ១ ទី ២ និង ទី ៤) ។ នៅក្នុងករណីនេះ តុលាការអនុវត្ត គឺសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលលំនៅឋាន ជាអាទិ៍ របស់កូនបំណុលនៃការអនុវត្តស្ថិតនៅ (មាត្រា ៥២៦ កថាខណ្ឌទី ២, មាត្រា ៤០២ កថាខណ្ឌទី ៣) ។ម្យ៉ាងទៀត ប្រសិនបើតតិយជន គ្រាន់តែជាអ្នកកាន់កាប់អចលនវត្ថុ ដែលជាកម្មវត្ថុ ដើម្បីផលប្រយោជន៍របស់កូនបំណុល (អ្នកទទួលបញ្ញើដោយឥតគិតថ្លៃ អ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) ទេនោះ ដោយផ្អែកលើលិខិតអនុវត្តដូចជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ជាអាទិ៍ ម្ចាស់បំណុល អាចទទួលរូបមន្តអនុវត្ត ហើយធ្វើការអនុវត្តដោយបង្ខំបាន (មាត្រា ៣៥១ កថាខណ្ឌទី ២, មាត្រា ៣៥៦ កថាខណ្ឌទី ២ និង ទី ៣) ។ ប៉ុន្តែ គួរបញ្ជាក់ថា នៅក្នុងករណីនេះ អ្នកកាន់កាប់អចលនវត្ថុ គឺកូនបំណុល នៃការអនុវត្ត មិនមែនតតិយជនទេ ។

## ៣. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុជាក់លាក់

(១) ដើម្បីចាត់ទុកថាជា "សិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុជាក់លាក់" កម្មវត្ថុ ដែលត្រូវប្រគល់នោះ ចាំបាច់ត្រូវតែជាចលនវត្ថុជាក់លាក់ ប៉ុន្តែ មិនសំខាន់ថាតើនោះជាចលនវត្ថុមួយទាំងមូល ឬ ជាផ្នែកណាមួយនៃចលនវត្ថុដែលរួមគ្នានោះទេ ។ ឧទាហរណ៍ ការប្រគល់ទំនិញនៅក្នុងហាងណាមួយ ។ ដោយសារនេះមិនមែនជាការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ដូច្នេះ ទោះបីជាចលនវត្ថុ ដែលជាកម្មវត្ថុនោះ គ្មានតម្លៃ ឬ មានតម្លៃប៉ុន្មានក៏ដោយ ហើយទោះបីជាចលនវត្ថុនោះជាទ្រព្យសម្បត្តិ ដែលហាមឃាត់មិនឱ្យរឹបអូស (មាត្រា ៣៨០) ក៏ដោយ ក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ឱ្យប្រគល់ចលនវត្ថុជាក់លាក់ដែរ ។ ករណីយកិច្ចប្រគល់ សំដៅលើការប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ក៏ដូចជាការប្រគល់ទៅឱ្យតតិយជន ឬ ការបង្ហាញដើម្បីធ្វើការត្រួតពិនិត្យ ។ ទោះបីជាកូនបំណុលនៃការ អនុវត្ត មានករណីយកិច្ចបន្ទាប់បន្សំផ្សេងទៀត ដូចជាករណីយកិច្ចក្នុងការវេចខ្ចប់ និង ផ្ញើក៏ដោយ ក៏គេនៅតែ អាចធ្វើការអនុវត្តដោយបង្ខំ នៅកន្លែងដែលចលនវត្ថុនោះស្ថិតនៅ បានដែរ ។

មានសំណួរមួយចោទឡើងថា តើគេអាចធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់កូនក្មេង តាមវិធីអនុវត្តដែលកំពុងពន្យល់នេះ (ការអនុវត្តដោយផ្ទាល់) ដោយបកស្រាយថា សិទ្ធិទាមទារឱ្យប្រគល់ កូននោះ គឺជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុជាក់លាក់ បានដែរឬទេ ។ មិនចាំបាច់ និយាយអ្វីច្រើនឡើយ កូនក្មេង មិនមែនជា "ចលនវត្ថុ (វត្ថុ)" ទេ ។ បើសង្កត់ធ្ងន់ទៅលើចំណុចនេះ គេអាច

និយាយបានថា វិធីអនុវត្តនៅក្នុងករណីនៃការទាមទារឱ្យប្រគល់កូនក្មេង (ឧទាហរណ៍ ករណីម្តាយដែលត្រូវបានជ្រើសតាំងជាបុគ្គលដែលមានអំណាចមេបានៅក្រោយការលែងលះ ធ្វើការទាមទារឱ្យប្រគល់កូនដែលកំពុងនៅជាមួយនឹងឪពុក ជាអាទិ៍) អាចធ្វើបានតែតាមរយៈវិធានបង្ខំដោយប្រយោល (មាត្រា ៥២៨) ប៉ុណ្ណោះ ។ មានមតិដោយឡែកមួយទៀតត្រូវបានលើកឡើង ដោយធ្វើការបែងចែកករណីទៅតាមកត្តាថាតើកូនក្មេងនោះ មានសមត្ថភាពបង្ហាញឆន្ទៈដែរឬទេ ។ មានន័យថា ការទាមទារឱ្យប្រគល់កូនក្មេងដែលពុំមានសមត្ថភាពបង្ហាញឆន្ទៈ អាចធ្វើតាមវិធីនៃការអនុវត្តដោយផ្ទាល់ ចំណែកឯការទាមទារឱ្យប្រគល់កូនក្មេងដែលមានសមត្ថភាពបង្ហាញឆន្ទៈ អាចធ្វើតាមវិធានបង្ខំដោយប្រយោល ។ម្យ៉ាងទៀត ក៏មានមតិមួយផ្សេងលើកឡើងថា ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាពនៅក្នុងការទាមទារឱ្យប្រគល់កូនក្មេង និង ដើម្បីការពារផលប្រយោជន៍របស់កុមារផងនោះ គេអាចនឹងធ្វើតាមវិធីអនុវត្តដោយផ្ទាល់ ដូចគ្នានឹងករណីនៃចលនវត្ថុដែរ ដែលតាមរយៈនោះ អាជ្ញាសាលាដកយកក្មេងនោះ ហើយប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ហើយក្នុងពេលជាមួយគ្នា ត្រូវពិចារណាឱ្យបានដិតដល់ អំពីបុគ្គលិកលក្ខណៈរបស់ក្មេងនោះផងដែរ ។ នៅប្រទេសជប៉ុន ភាគច្រើនជ្រើសយកមតិចុងក្រោយនេះ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ការជ្រើសរើសយកវិធីអនុវត្តណាមួយនោះ គឺអាស្រ័យទៅតាមការយល់ដឹងផ្នែកច្បាប់របស់ពលរដ្ឋនៃប្រទេសនីមួយៗ ។

(២) វិធីអនុវត្ត : (ក) ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត ជាអ្នកកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុ អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុនោះស្ថិតនៅ ត្រូវដកយកវត្ថុនោះពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់វត្ថុនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត (ឬ ទៅឱ្យតតិយជនដែលត្រូវទទួលវត្ថុនោះ) តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា ៥២៥ កថាខណ្ឌទី ១) ។ ប្រសិនបើកូនបំណុលនៃការអនុវត្ត មិនពេញចិត្តចំពោះការកំណត់សញ្ញាណនៃវត្ថុ ជាអាទិ៍ កូនបំណុលនោះ អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន (មាត្រា ៣៨៤) ។

(ខ) ក្នុងករណីដែលតតិយជនជាអ្នកកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុវិញ ដូចក្នុងករណីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុដែរ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលដីកាសម្រេចរបស់តុលាការអនុវត្តដែលបង្គាប់ឱ្យរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជន ហើយទាមទារឱ្យតតិយជននោះ ប្រគល់វត្ថុដែលជាកម្មវត្ថុមកឱ្យខ្លួន ដោយផ្អែកលើដីកាសម្រេចនោះ (មាត្រា ៥២៦ និង សូមមើល **២.** (២) (ឃ)) ។

## ៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យផ្តល់តាវកាលិកនូវចំនួនជាកំណត់នៃវត្ថុជំនួស

ដូចករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុដែរ នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកនូវចំនួនជាកំណត់នៃវត្ថុជំនួស ប្រសិនបើវត្ថុជំនួសដែលជាកម្មវត្ថុនៃការ

ផ្តល់តាវកាលិកនោះ ស្ថិតនៅក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត អាជ្ញាសាលា ត្រូវដកយកវត្ថុនោះ ហើយប្រគល់ទៅឱ្យម្ចាស់បំណុល ( មាត្រា ៥២៥ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ បើទោះបីជាម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិទាមទារឱ្យប្រគល់វត្ថុជំនួសដែលមានប្រភេទដូចគ្នា ចំពោះតតិយជនក៏ដោយ ក៏គេមិនអាចដាក់ពាក្យសុំឱ្យអនុវត្តតាមមាត្រា ៥២៦ បានឡើយ ។ នេះក៏ ព្រោះថា កម្មវត្ថុនៃការផ្តល់តាវកាលិកគ្រាន់តែជាវត្ថុជំនួស ។ ហេតុនេះហើយ គេមិនអាចនិយាយថា តតិយជន កាន់កាប់វត្ថុដែលកូនបំណុលនៃការអនុវត្តត្រូវប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត បានឡើយ ។

## កថាភាគទី ២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពអ្វីមួយ

### ចំណុចទី ១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ

#### ១. កំណត់សំគាល់ទូទៅ

បើពិចារណានូវសិទ្ធិទាមទារ ដោយផ្អែកលើទស្សនៈដែលទាញចេញពីខ្លឹមសារនៃករណីយកិច្ចដែលកូនបំណុល ត្រូវបំពេញ គេអាចបែងចែកករណីយកិច្ចនោះជាពីរប្រភេទ គឺ "ករណីយកិច្ចផ្តល់ឱ្យ" ដូចជាការបង់ប្រាក់ ការប្រគល់វត្ថុ ជាអាទិ៍ និង "ករណីយកិច្ចធ្វើ" ដែលមានកម្មវត្ថុជាការធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយ ។ "ករណីយកិច្ចផ្តល់ឱ្យ" ដែលស្មើនឹងសិទ្ធិទាមទារឱ្យបង់ប្រាក់ ឬ ឱ្យប្រគល់វត្ថុអ្វីមួយ បើមើលពីទស្សនទានរបស់ម្ចាស់សិទ្ធិ ត្រូវអនុវត្តតាមវិធីនៃការអនុវត្តដោយផ្ទាល់ ដែលតាមរយៈនោះ ខ្លឹមសារនៃករណីយកិច្ច ត្រូវបានសម្រេចដោយផ្ទាល់ ដោយស្ថាប័នអនុវត្ត ដូចបានរៀបរាប់ពីខាងដើម ។ ផ្ទុយទៅវិញ ចំពោះ "ករណីយកិច្ចធ្វើ" ដែលស្មើនឹងសិទ្ធិទាមទារឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពអ្វីមួយ បើមើលពីទស្សនទានរបស់ម្ចាស់សិទ្ធិវិញ ការសម្រេចនូវខ្លឹមសារនៃករណីយកិច្ចនោះ ដោយស្ថាប័នអនុវត្ត មានការលំបាកច្រើន ឬ មិនអាចធ្វើទៅកើតតែម្តង ។

ដោយហេតុនេះហើយ ចំពោះករណីយកិច្ចធ្វើ ក្រមនីតិវិធីរដ្ឋប្បវេណី បានធ្វើការបែងចែករវាងសកម្មភាពដែលអាចអនុវត្តជំនួសបាន និង សកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ដោយផ្អែកលើទស្សនទាននៃការអនុវត្តដោយបង្ខំ ។ ក្រមនេះចែងថា ករណីយកិច្ចធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន ត្រូវអនុវត្តតាមវិធីនៃការអនុវត្តជំនួស ។ ផ្ទុយទៅវិញ ចំពោះករណីយកិច្ចធ្វើសកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ដែលចាំបាច់ត្រូវបំពេញដោយកូនបំណុលខ្លួនឯង ក្រមនេះចែងថា ការអនុវត្ត ត្រូវធ្វើឡើងតាមវិធានបង្ខំដោយប្រយោល ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តករណីយកិច្ចធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន ក៏អាចធ្វើឡើងតាមវិធានបង្ខំដោយប្រយោល បានដែរ ។ ម្យ៉ាងទៀត ចំពោះករណីយកិច្ចរបស់កូនបំណុលក្នុងការបង្ហាញឆន្ទៈណាមួយ ដែលជាប្រភេទមួយនៃករណីយកិច្ចធ្វើដែរនោះ ក្រមនេះមានចែងអំពីវិធីអនុវត្តពិសេសដែលកំណត់ថា នៅពេលដែលការសម្រេចសេចក្តីបង្គាប់ឱ្យធ្វើការបង្ហាញឆន្ទៈ បានចូលជាស្ថាពរ ឬ

នៅពេលដែលលិខិតអនុវត្តផ្សេងទៀតដែលកំណត់ករណីយកិច្ចក្នុងការបង្ហាញឆន្ទៈ បានបង្កើតអានុភាព នោះត្រូវចាត់ទុកថាបានបង្ហាញឆន្ទៈហើយ ។

## ២. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន

(១) វិសាលភាព : សិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន សំដៅទៅលើសិទ្ធិទាមទារដែលសកម្មភាពដែលជាខ្លឹមសារនៃតាវកាលិក អាចបំពេញដោយអ្នកផ្សេងបាន ហើយដែលការធ្វើសកម្មភាពដោយអ្នកផ្សេងនោះ នឹងនាំឱ្យកើតអានុភាពផ្នែកសេដ្ឋកិច្ច និង អានុភាពផ្នែកច្បាប់ ដូចគ្នានឹងករណីនៃការធ្វើសកម្មភាពនោះ ដោយកូនបំណុលនៃការអនុវត្ត ដោយខ្លួនឯងដែរ ។

ថាតើសកម្មភាពណាមួយអាចអនុវត្តជំនួសបាន ឬ មិនបាននោះ គឺអាស្រ័យទៅលើកាលៈទេសៈជាក់លាក់ផ្សេងៗ ។ ប៉ុន្តែ ជាទូទៅ សកម្មភាពដែលមានគោលបំណងជាការផ្តល់ពលកម្មដោយប្រើកម្លាំង ដូចជាការសំអាតផ្លូវថ្នល់ ការកាប់ដើមឈើ ការសាងសង់ ឬ បំផ្លាញអាគារ ការដឹកជញ្ជូនទំនិញ ជាអាទិ៍ សុទ្ធសឹងជាសកម្មភាពដែលអាចអនុវត្តជំនួសបាន ។ ចំពោះការផលិតវត្ថុផ្សេងៗ ការផ្តល់ចរន្តអគ្គិសនី ជាអាទិ៍ ប្រសិនបើអ្នកដទៃ អាចធ្វើសកម្មភាពទាំងនេះបានដោយងាយស្រួលនោះ វាគឺជាសកម្មភាពដែលអាចអនុវត្តជំនួសបាន ។ ករណីយកិច្ចក្នុងការបង្ហាញខ្លួន និង ធ្វើការសុំទោសជាលក្ខណៈបុគ្គល គឺជាសកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ។ ក៏ប៉ុន្តែ ករណីយកិច្ចក្នុងការផ្សាយពាក្យសុំទោសដែលមានខ្លឹមសារអ្វីមួយ តាមសារព័ត៌មាន គឺជាសកម្មភាពដែលអាចអនុវត្តជំនួសបាន ។

(២) នីតិវិធីនៃការអនុវត្តជំនួស : (ក) ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបាន ជាគោលការណ៍ ត្រូវធ្វើតាមវិធីនៃការអនុវត្តជំនួស (មាត្រា ៥២៧) ។ ក៏ប៉ុន្តែ ទោះជាសកម្មភាពនោះអាចអនុវត្តជំនួសបានក៏ដោយ ក៏គេអាចធ្វើការអនុវត្ត តាមវិធានបង្ខំដោយប្រយោលបានដែរ (មាត្រា ៥២៨) ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការជ្រើសរើសវិធីណាមួយ ក្នុងចំណោមវិធីអនុវត្តទាំងនេះ នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (មាត្រា ៣៤៩ កថាខណ្ឌទី ២ ចំណុច គ និង ចំណុច ង) ។

(ខ) ដោយផ្អែកលើសាលក្រម ឬ សាលដីកាបង្គាប់ឱ្យធ្វើសកម្មភាពណាមួយដែលអាចអនុវត្តជំនួសបាន ឬ ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តផ្សេងទៀត ដែលមានអានុភាពអនុវត្ត និង ដែលទទួលស្គាល់ករណីយកិច្ចធ្វើសកម្មភាពណាមួយដែលអាចអនុវត្តជំនួសបាន ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំទៅតុលាការអនុវត្ត ឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត ឱ្យតតិយជនធ្វើសកម្មភាពជំនួសកូនបំណុលនៃការអនុវត្ត ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តនោះ (មាត្រា ៥២៧ កថាខណ្ឌទី ១) ។ ដោយយោងទៅតាមប្រភេទនៃលិខិតអនុវត្តដែលបានកំណត់ក្នុងមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) កថាខណ្ឌទី ៣ ចំណុច ក ឬ ចំណុច គ តុលាការអនុវត្តដែលមានសមត្ថកិច្ច គឺតុលាការដែលបានកំណត់ក្នុងចំណុច

នីមួយៗនោះ ។

(គ) នៅពេលបានទទួលពាក្យសុំ តុលាការអនុវត្ត ត្រូវធ្វើការពិនិត្យស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌទូទៅដើម្បីចាប់ផ្ដើមការអនុវត្តដោយបង្ខំ ក៏ដូចជាល័ក្ខខ័ណ្ឌដើម្បីដាក់ពាក្យសុំឱ្យអនុវត្តជំនួស ហើយត្រូវសម្រេចលើពាក្យសុំនោះ ដោយចេញដីកាសម្រេច ។ នៅពេលចេញដីកាសម្រេច តុលាការអនុវត្ត ត្រូវសួរកូនបំណុលនៃការអនុវត្ត (មាត្រា ៥២៧ កថាខណ្ឌទី ៣) ។ ភាគីអាចដាក់ពាក្យប្ដឹងជំទាស់ ចំពោះដីកាសម្រេចឱ្យអនុវត្តជំនួស ឬ ដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តជំនួសបាន (មាត្រា ៥២៧ កថាខណ្ឌទី ៥) ។

(ឃ) បើទទួលស្គាល់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តនោះ ឱ្យតតិយជនធ្វើសកម្មភាពជំនួសកូនបំណុលនៃការអនុវត្ត តាមខ្លឹមសារនៃពាក្យសុំនោះ (មាត្រា ៥២៧ កថាខណ្ឌទី ១) ។ ដីកាសម្រេចនេះ ហៅថា "ដីកាសម្រេចប្រគល់សិទ្ធិ" ។ នៅពេលចេញដីកាសម្រេចប្រគល់សិទ្ធិនេះ តុលាការអនុវត្ត អាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់សោហ៊ុយដែលត្រូវការចាំបាច់សម្រាប់ធ្វើសកម្មភាពដែលបានកំណត់ក្នុងដីកាសម្រេចនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ជាមុន តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន (មាត្រា ៥២៧ កថាខណ្ឌទី ៤) ។ នៅក្នុងដីកាសម្រេចប្រគល់សិទ្ធិ ចាំបាច់ត្រូវបញ្ជាក់អំពីសកម្មភាពជាក់លាក់ដែលត្រូវធ្វើ ប៉ុន្តែ មិនចាំបាច់បញ្ជាក់អំពីបុគ្គលដែលត្រូវធ្វើសកម្មភាពនោះទេ ។

(ង) ដោយផ្អែកលើដីកាសម្រេចប្រគល់សិទ្ធិ ម្ចាស់បំណុលនៃការអនុវត្ត អាចធ្វើសកម្មភាពដែលពាក់ព័ន្ធនោះ ដោយខ្លួនឯង ឬ ឱ្យតតិយជនណាម្នាក់ដែលខ្លួនជ្រើសរើស ធ្វើសកម្មភាពនោះ ។ កូនបំណុលនៃការអនុវត្ត ត្រូវបង្កលទ្ធភាពឱ្យអាចធ្វើសកម្មភាពដោយផ្អែកលើដីកាសម្រេចប្រគល់សិទ្ធិ និង សកម្មភាពផ្សេងៗទៀតដែលចាំបាច់ដើម្បីធ្វើសកម្មភាពនោះ (ឧទាហរណ៍ដូចជាការចូលទៅកាន់ដី) ។ ប្រសិនបើកូនបំណុលនៃការអនុវត្ត ជាអាទិ៍ ធ្វើការរារាំង ម្ចាស់បំណុលនៃការអនុវត្ត អាចស្នើសុំជំនួយពីអាជ្ញាសាលា ដោយផ្អែកលើដីកាសម្រេចនោះបាន (មាត្រា ៥២៧ កថាខណ្ឌទី ៦ និង មាត្រា ៣៣៨ កថាខណ្ឌទី ២) ។ម្យ៉ាងទៀត ប្រសិនបើនៅក្នុងដីកាសម្រេចប្រគល់សិទ្ធិ មានការបង្គាប់ឱ្យបង់សោហ៊ុយជាមុនដែរនោះ ការប្រមូលសោហ៊ុយនោះ អាចធ្វើទៅបាន តាមរយៈការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ដោយយកដីកាសម្រេចនោះធ្វើជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ) ។ ប្រសិនបើពុំមានការបង្គាប់ឱ្យបង់ប្រាក់ជាមុន ឬ ប្រសិនបើចំនួនទឹកប្រាក់ដែលបានកំណត់ដោយការបង្គាប់នោះ មិនគ្រប់គ្រាន់ទេ ម្ចាស់បំណុលនៃការអនុវត្ត អាចចេញសោហ៊ុយនោះ (ជំនួសកូនបំណុល) សិន រួចទើបសុំឱ្យមានការកំណត់លំអិតអំពីចំនួនទឹកប្រាក់នៃសោហ៊ុយសម្រាប់ការអនុវត្ត នៅពេលក្រោយ ហើយប្រមូលសោហ៊ុយនោះពីកូនបំណុលនៃការអនុវត្ត ដោយយកការចាត់ចែងអំពីការកំណត់ចំនួនប្រាក់ប្រដាប់ក្ដី (មាត្រា ៦៦)

ធ្វើជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ង) ។ ប្រសិនបើចំនួនទឹកប្រាក់ដែលបានបង់រួចហើយលើសពីសោហ៊ុយជាក់ស្តែង កូនបំណុលនៃការអនុវត្ត អាចទាមទារឱ្យធ្វើបដិទាននូវសេចក្តីចម្រើនដោយឥតហេតុ ពីម្ចាស់បំណុលនៃការអនុវត្តបាន ។

(៣) នីតិវិធីនៃវិធានបង្ខំដោយប្រយោល : ទោះជាក្នុងករណីដែលអាចធ្វើការអនុវត្តជំនួសបានក៏ដោយ ក៏គេនៅតែអាចធ្វើការអនុវត្តតាមវិធានបង្ខំដោយប្រយោល (មាត្រា ៥២៨) ដោយមិនចាំបាច់ធ្វើការអនុវត្តដោយផ្ទាល់ បានដែរ ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវជ្រើសរើសយកវិធីណាមួយ ក្នុងចំណោមវិធីទាំងនេះ នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (មាត្រា ៣៤៩ កថាខណ្ឌទី ២ ចំណុច គ និង ចំណុច ង) ។ នីតិវិធីនៃវិធានបង្ខំដោយប្រយោល ត្រូវអនុវត្តដូចគ្នាទៅនឹងករណីនៃសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលមិនអាចអនុវត្តជំនួសបានដែរ (សូមមើល ៣. (២) ខាងក្រោម) ។

### ៣. ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាព ដែលមិនអាចអនុវត្តជំនួសបាន

(១) វិសាលភាព : (ក) សកម្មភាពដែលមិនអាចអនុវត្តជំនួសបាន សំដៅទៅលើសកម្មភាពដែលគោលបំណងរបស់វា នឹងអាចសម្រេចបាន លុះត្រាតែត្រូវបានបំពេញដោយបុគ្គលជាក់លាក់ ដោយខ្លួនឯង ។ នេះគឺជាសកម្មភាពដែលមិនអាចធ្វើដោយអ្នកដទៃបាន តាមច្បាប់ ឬ តាមការជាក់ស្តែង ឬ បើធ្វើដោយអ្នកដទៃ មិនអាចនាំឱ្យមានអានុភាពផ្នែកច្បាប់ ឬ ផ្នែកសេដ្ឋកិច្ច ដូចគ្នានឹងករណីនៃការធ្វើដោយបុគ្គលជាក់លាក់ឡើយ ។ ឧទាហរណ៍ ករណីដែលសកម្មភាពដែលត្រូវធ្វើ ទាមទារចាំបាច់នូវចំណេះដឹងពិសេសខាងផ្នែកសិក្សា ឬ បច្ចេកទេសពិសេសរបស់បុគ្គលជាក់លាក់ណាម្នាក់ (ករណីយកិច្ចបង្ហាញខ្លួននៅលើឆាក ករណីយកិច្ចធ្វើការវាយតម្លៃ/កោសលវិច័យ ជាអាទិ៍), ករណីដែលសកម្មភាពដែលត្រូវធ្វើ នឹងពុំមានន័យខ្លឹមសារអ្វីឡើយ ប្រសិនបើមិនបានធ្វើដោយបុគ្គលជាក់លាក់ ដោយប្រើសមត្ថភាពគតិយុត្តរបស់បុគ្គលនោះ (ករណីយកិច្ចធ្វើរបាយការណ៍គណនេយ្យ), ករណីដែលការធ្វើសកម្មភាពដោយបុគ្គលជាក់លាក់ ជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការកើតឡើងនូវអានុភាពគតិយុត្ត (ករណីយកិច្ចចុះហត្ថលេខា), ករណីដែលខ្លឹមសារនៃសកម្មភាព ត្រូវទុកឱ្យបុគ្គលជាក់លាក់ជាអ្នកសម្រេច (ករណីយកិច្ចជ្រើសតាំងអ្នកតំណាង) ជាអាទិ៍ ។

(ខ) កាតព្វកិច្ចធ្វើសកម្មភាពដែលមិនអាចអនុវត្តជំនួសបានមួយចំនួន មិនសមស្របនឹងធ្វើការអនុវត្តដោយបង្ខំទេ ។ (a) ដំបូងបង្អស់ ក្នុងចំណោមកាតព្វកិច្ចទាំងនេះ មានកាតព្វកិច្ចដែលមានឧបសគ្គរាំងពីខាងក្រៅ ដែលមិនអាចដកចេញបានដោយឆន្ទៈ និង ការប្រឹងប្រែងរបស់កូនបំណុលនៃការអនុវត្ត ។ នៅក្នុងករណីនេះ ប្រសិនបើកូនបំណុលនៃការអនុវត្ត ត្រូវបានបង្ខំ និង ត្រូវបានធ្វើឱ្យមានឆន្ទៈក្នុងការបំពេញសកម្មភាព នោះការបំពេញជាក់ស្តែង នឹងមិនអាចសម្រេចបានឡើយ ។ ទាំងនេះ គឺជាសកម្មភាពដែលមិនអាចបំពេញបាន ដោយគ្មានការយល់ព្រម និង ការសហការពីសំណាក់តតិយជន ហើយដែលមានលទ្ធភាពតែបន្តិចបន្តួច ក្នុងការទទួលបានការយល់ព្រម និង ការសហការនោះ (ឧទាហរណ៍ កាតព្វកិច្ចទទួលបានការចេញលិខិត

បញ្ជាក់ភាគហ៊ុន ពីតតិយជនដែលជាក្រុមហ៊ុន ហើយប្រគល់លិខិតនោះ, កាតព្វកិច្ចធ្វើការវះកាត់បុគ្គលណាម្នាក់) ។

(b) ក្រៅពីនេះ ប្រសិនបើគេគិតថា ការបង្ខំឱ្យអនុវត្តករណីយកិច្ច ដោយផ្ទុយនឹងឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត មិនត្រូវបានអនុញ្ញាតដោយមូលហេតុវប្បធម៌ ជាអាទិ៍ ករណីយកិច្ចនោះ មិនអាចអនុវត្តដោយបង្ខំបានទេ ។ ឧទាហរណ៍ ករណីយកិច្ចរស់នៅជាមួយគ្នារបស់សហព័ទ្ធក្នុងចំណងអាពាហ៍ពិពាហ៍ ករណីយកិច្ចទទួលការបញ្ចូលឈាម ជាអាទិ៍ ។

(c) ម្យ៉ាងទៀត ប្រសិនបើការអនុវត្តករណីយកិច្ច នឹងមិនអាចសម្រេចតាមគោលបំណងបានទេ ប្រសិនបើការអនុវត្តនោះ មិនផ្អែកលើឆន្ទៈស្ម័គ្រចិត្តរបស់កូនបំណុលនៃការអនុវត្ត ករណីយកិច្ចនោះ មិនអាចអនុវត្តដោយបង្ខំ បានទេ ។ ឧទាហរណ៍ ករណីយកិច្ចគូរគំនូរ ករណីយកិច្ចសរសេរប្រលោមលោក ជាអាទិ៍ ។

(២) នីតិវិធីនៃវិធានបង្ខំដោយប្រយោល : (ក) ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យធ្វើសកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ត្រូវធ្វើឡើងតាមវិធានបង្ខំដោយប្រយោល ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តដោយប្រយោល ដោយផ្អែកលើលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យធ្វើសកម្មភាពណាមួយដែលមិនអាចអនុវត្តជំនួសបាន (មាត្រា ៥២៨ កថាខណ្ឌទី ១) ។ តុលាការអនុវត្តដែលមានសមត្ថកិច្ច គឺតុលាការដែលបានកំណត់ទៅតាមប្រភេទនៃលិខិតអនុវត្ត ដូចបានរៀបរាប់ក្នុងមាត្រា ៣៦៣ កថាខណ្ឌទី ៣ ចំណុច ក ឬ ចំណុច គ (មាត្រា ៥២៨ កថាខណ្ឌទី ២) ។

(ខ) នៅពេលចេញដីកាសម្រេចលើពាក្យសុំនេះ តុលាការអនុវត្ត ត្រូវសួរកូនបំណុលនៃការអនុវត្ត (មាត្រា ៥២៨ កថាខណ្ឌទី ៤) ។ ប្រសិនបើទទួលស្គាល់ពាក្យសុំ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមថ្ងៃ ឬ ខែនៃការយឺតយ៉ាវ ឬ បង់នូវចំនួនទឹកប្រាក់ជាកំណត់តែម្តង ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ប្រសិនបើកូនបំណុលនៃការអនុវត្ត មិនធ្វើសកម្មភាពជាក់លាក់ នៅក្នុងអំឡុងពេលដែលតុលាការកំណត់ (មាត្រា ៥២៨ កថាខណ្ឌទី ១) ។ ប្រាក់ដែលកូនបំណុលនៃការអនុវត្ត ត្រូវបានបង្គាប់ឱ្យបង់នៅក្នុងការអនុវត្តដោយប្រយោលនេះ ហៅថា "ប្រាក់បង្ខំ" ។ ឧទាហរណ៍ ក្នុងករណីដែលមានពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តដោយប្រយោល ដើម្បីអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យដាក់របាយការណ៍គណនេយ្យនៃអាជីវកម្មណាមួយ តុលាការអនុវត្ត ចេញដីកាសម្រេចដែលកំណត់អំឡុងពេល ៣ ខែ ហើយបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់ទឹកប្រាក់ចំនួន ១០ ម៉ឺនរៀល ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត បើយឺត ១០ ថ្ងៃ ឬ ត្រូវបង់ ១ លានរៀល ប្រសិនបើកូនបំណុលនៃការអនុវត្ត មិនដាក់របាយការណ៍ នៅក្នុងអំឡុងពេលនោះ ។ ចំពោះអំឡុងពេល និង ចំនួនប្រាក់បង្ខំ តុលាការអនុវត្តអាចកំណត់ទៅតាមការយល់ឃើញរបស់ខ្លួន អំពីប្រសិទ្ធិភាព

នៃវិធីអនុវត្តនោះ ដោយគិតពិចារណាលើកាលៈទេសៈជាក់ស្តែង ហើយមិនត្រូវបានចងជានិច្ចកាលដោយពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តទេ ។

(គ) បើមានការផ្លាស់ប្តូរស្ថានភាព នៅក្រោយពេលចេញដីកាសម្រេចអនុវត្តដោយប្រយោល ម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត អាចសុំឱ្យតុលាការអនុវត្ត កែប្រែដីកាសម្រេចបាន (មាត្រា ៥២៨ កថាខណ្ឌទី ៣) ។ ខ្លឹមសារទាំងនោះមានដូចជាការសុំឱ្យពន្យារអំឡុងពេលដែលត្រូវអនុវត្តសកម្មភាព ឬ បំព្រួញអំឡុងពេលនោះ ជាដើម ។ នៅពេលចេញដីកាសម្រេចលើពាក្យសុំឱ្យកែប្រែ តុលាការអនុវត្ត ត្រូវសួរភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ (មាត្រា ៥២៨ កថាខណ្ឌទី ៤) ។ ចំពោះដីកាសម្រេចលើពាក្យសុំឱ្យអនុវត្តដោយប្រយោល ឬ ដីកាសម្រេចលើពាក្យសុំឱ្យកែប្រែ អាចប្តឹងជំទាស់បាន (មាត្រា ៥២៨ កថាខណ្ឌទី ៦) ។

(ឃ) ប្រសិនបើកូនបំណុលនៃការអនុវត្ត ដែលបានទទួលដីកាសម្រេចបង្គាប់ឱ្យអនុវត្តដោយប្រយោល មិនធ្វើសកម្មភាពរបស់ខ្លួន នៅក្នុងអំឡុងពេលដែលបានកំណត់ទេ ម្ចាស់បំណុលនៃការអនុវត្ត អាចយកដីកាសម្រេចនោះ ធ្វើជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ) រួចទទួលរូបមន្តអនុវត្តពិសេសលើឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ (មាត្រា ៣៥៦ កថាខណ្ឌទី ១) ហើយធ្វើការអនុវត្តដោយបង្ខំដើម្បីប្រមូលប្រាក់បង្ខំបាន ។ ប្រសិនបើចំនួនទឹកប្រាក់នៃការខូចខាតដែលម្ចាស់បំណុលនៃការអនុវត្តទទួលរង ដោយសារការមិនធ្វើសកម្មភាពរបស់កូនបំណុលនៃការអនុវត្ត លើសពីចំនួនប្រាក់បង្ខំ ម្ចាស់បំណុលនៃការអនុវត្ត អាចទាមទារសំណងការខូចខាត ចំពោះចំនួនទឹកប្រាក់ដែលលើសនោះបាន (មាត្រា ៥២៨ កថាខណ្ឌទី ៥) ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ប្រសិនបើចំនួនប្រាក់បង្ខំ លើសពីចំនួនទឹកប្រាក់នៃការខូចខាតដែលម្ចាស់បំណុលនៃការអនុវត្តទទួលរង កូនបំណុលនៃការអនុវត្ត មិនអាចទាមទារឱ្យប្រគល់វិញ នូវចំនួនទឹកប្រាក់ដែលលើសនោះបានឡើយ ព្រោះថា ប្រាក់បង្ខំ ត្រូវបានបង្គាប់ឱ្យបង់ ក្នុងលក្ខណៈជាការដាក់ទណ្ឌកម្មដើម្បីឱ្យកូនបំណុលនៃការអនុវត្ត បំពេញសកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ហើយវាមិនមែនជាសំណងនៃការខូចខាតទេ ។

## ៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ

(១) វិសាលភាព : ពាក្យថា "ការបង្ហាញឆន្ទៈ" នៅក្នុងករណីនៃសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈនេះ ត្រូវតែជាការបង្ហាញឆន្ទៈដែលមានអានុភាពគតិយុត្តពិតប្រាកដ ។ ក៏ប៉ុន្តែ វាមិនត្រូវបានកម្រិតត្រឹមតែជាការបង្ហាញឆន្ទៈដែលជាធាតុផ្សំមួយនៃការបង្កើតសកម្មភាពគតិយុត្ត ឬ ការបង្កើតអានុភាព ដូចជាការយល់ព្រម ស្ទីការជាអាទិ៍ នោះទេ គឺវារួមបញ្ចូលផងដែរ នូវការជូនដំណឹងអំពីឆន្ទៈដែលជាសកម្មភាពគតិយុត្តមិនពេញលេញ (ឧទាហរណ៍ដូចជា ការជូនដំណឹងអំពីអនុប្បទានសិទ្ធិលើបំណុល, ពាក្យសុំឱ្យចុះបញ្ជី) ។ ភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈ អាចជា ម្ចាស់បំណុល តតិយជន ឬ ស្ថាប័នរដ្ឋ ។ ក៏ប៉ុន្តែ ចំពោះសកម្មភាពចេញរូបិយាណត្តិជាអាទិ៍ គេពុំមានជម្រើសអ្វីផ្សេង ក្រៅពីការអនុវត្តតាមវិធីនៃការអនុវត្តសកម្មភាពដែលមិនអាចអនុវត្តជំនួស

បាននោះទេ ព្រោះវាទាមទារឱ្យមានហត្ថលេខាផ្ទាល់ខ្លួនរបស់កូនបំណុលនៃការអនុវត្ត ។

(២) នីតិវិធីនៃការអនុវត្ត : (ក) បើសាលក្រម សាលដីកា ឬ ដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង្ហាញឆន្ទៈ បានចូលជាស្ថាពរហើយ ឬ បើលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់ ដែលមានខ្លឹមសារថា កូនបំណុលនៃការអនុវត្តត្រូវបង្ហាញឆន្ទៈ បានបង្កើតអានុភាពឡើង ត្រូវចាត់ទុកថាកូនបំណុលនៃការអនុវត្ត បានបង្ហាញឆន្ទៈ នៅពេលនៃការចូលជាស្ថាពរ ឬ ការបង្កើតអានុភាពនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ មិនចាំបាច់មានសកម្មភាពអនុវត្តជាក់ស្តែង ដោយចាត់ទុកថាបានបង្ហាញឆន្ទៈហើយ ។ ប្រសិនបើការបង្ហាញឆន្ទៈ គឺជាសកម្មភាពដែលទាមទារឱ្យមានទម្រង់ណាមួយ នោះអានុភាពនៃការបង្ហាញឆន្ទៈ នឹងកើតមានដូចករណីដែលបានធ្វើតាមទម្រង់នោះដែរ ហើយប្រសិនបើកូនបំណុលនៃការអនុវត្ត គឺជាអសមត្ថជន នោះអានុភាពនៃការបង្ហាញឆន្ទៈ នឹងកើតឡើងដូចករណីដែលសមត្ថភាពនោះត្រូវបានបំពេញដែរ ។ ម្ចាស់បំណុលនៃការអនុវត្ត អាចអះអាងអំពីអានុភាពនៃការបង្ហាញឆន្ទៈ ដោយបញ្ជាក់ថា សាលក្រម ឬ សាលដីកា បានចូលជាស្ថាពរហើយ ជាអាទិ៍ ។ ឧទាហរណ៍ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំតែម្នាក់ឯង ដើម្បីឱ្យធ្វើការកែប្រែសៀវភៅបញ្ជី ឬ អត្រានុកូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺជាការអនុវត្តក្នុងន័យទូលាយ ពោលគឺមិនមែនជាការអនុវត្តដោយបង្ខំក្នុងន័យដើមនោះទេ ។ ហេតុនេះហើយ ដើម្បីដាក់ពាក្យសុំឱ្យកែប្រែសៀវភៅបញ្ជី ឬ អត្រានុកូលដ្ឋាន មិនចាំបាច់មានការផ្តល់រូបមន្តអនុវត្តទេ ហើយម្យ៉ាងទៀត នៅក្នុងករណីនេះ ពុំមានមូលដ្ឋានអ្វីដើម្បីផ្អាក ឬ លុបចោលការអនុវត្តនោះទេ ។

(ខ) ប្រសិនបើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ការបង្ហាញឆន្ទៈ ត្រូវចាត់ទុកថាបានធ្វើឡើង នៅពេលដែលម្ចាស់បំណុល ដាក់លិខិតបញ្ជាក់ថា ល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដនោះបានមកដល់ ហើយទទួលការផ្តល់រូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ កថាខណ្ឌទី ១) គឺមិនមែននៅពេលដែលសាលក្រមឬសាលដីកាបានចូលជាស្ថាពរ ឬ នៅពេលដែលលិខិតអនុវត្តបានបង្កើតអានុភាពនោះទេ (មាត្រា ៥២៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ម្យ៉ាងទៀត ប្រសិនបើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ មានពេលកំណត់ពិតប្រាកដ ក៏ប៉ុន្តែ ពេលកំណត់នោះមិនទាន់មកដល់នៅពេលដែលលិខិតអនុវត្តបានបង្កើតអានុភាព នោះការបង្ហាញឆន្ទៈត្រូវចាត់ទុកថាបានធ្វើឡើងនៅពេលដែលពេលកំណត់នោះបានមកដល់ ។

(គ) ម្យ៉ាងទៀត ប្រសិនបើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះ បានបង្ហាញឆន្ទៈនៅពេលដែលម្ចាស់បំណុលនៃការអនុវត្ត បានទទួលការផ្តល់រូបមន្តអនុវត្ត ដោយបញ្ជាក់ថា ខ្លួនបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះរួចហើយ (មាត្រា ៥២៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៣ និង

កថាខណ្ឌទី ២) ។ ជាទូទៅ ការផ្តល់ ឬ ការស្នើផ្តល់តាវកាលិកតប ពុំមែនជាល័ក្ខខ័ណ្ឌទាមទារ ដើម្បីផ្តល់រូបមន្តអនុវត្តទេ តែវាគឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្តើមការអនុវត្តដោយបង្ខំ ដែលស្ថាប័នអនុវត្ត (គឺមិនមែនជាស្ថាប័នផ្តល់រូបមន្តអនុវត្ត) ត្រូវធ្វើការស្រាវជ្រាវ (មាត្រា ៣៦១) ។ ក៏ប៉ុន្តែ ក្នុងករណីដែលលិខិតអនុវត្តបង្គាប់ឱ្យបង្ហាញឆន្ទៈ ការអនុវត្តដោយផ្អែកលើលិខិតនេះ មានលក្ខណៈគ្រាន់តែជាសញ្ញាណក្នុងគំនិតតែប៉ុណ្ណោះ ព្រោះថាការបង្ហាញឆន្ទៈត្រូវបានចាត់ទុកថាបានធ្វើ ហើយសកម្មភាពអនុវត្តជាក់ស្តែងនោះមិនត្រូវបានធ្វើឡើងទេ ។ ហេតុនេះហើយ ដោយសារស្ថាប័នអនុវត្តមិនអាចធ្វើការស្រាវជ្រាវអំពីស្ថានភាពថាតើតាវកាលិកតប ត្រូវបានផ្តល់ ឬ ត្រូវបានស្នើផ្តល់ហើយឬនៅនោះ ទើបបានជាមានបញ្ញត្តិចែងអំពីល័ក្ខខ័ណ្ឌទាមទារដើម្បីផ្តល់រូបមន្តអនុវត្តថា ស្ថាប័នផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើការស្រាវជ្រាវអំពីស្ថានភាពនោះ ហើយម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការបញ្ជាក់ថា ខ្លួនបានផ្តល់ ឬ បានស្នើផ្តល់តាវកាលិកតបរួចហើយ ដើម្បីអាចចាត់ទុកថា ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងនៅពេលផ្តល់រូបមន្តអនុវត្ត ។

(ឃ) ក្នុងករណីដែលការបង្ហាញឆន្ទៈ ត្រូវបានចាត់ទុកថាបានធ្វើ នៅពេលផ្តល់រូបមន្តអនុវត្ត ដោយសារថាសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ជាអាទិ៍ ប្រសិនបើរូបមន្តអនុវត្តដែលបានផ្តល់រួចហើយ ត្រូវលុបចោល ឬ បាត់បង់អានុភាព ដោយសារកូនបំណុលនៃការអនុវត្តបានដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ (មាត្រា ៣៦២) ឬ បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦៤) នោះអានុភាពនៃការចាត់ទុកថាបានបង្ហាញឆន្ទៈ ក៏ត្រូវបាត់បង់ដែរ ។

## ចំណុចទី ២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ

### ១. ប្រភេទនៃសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ

(១) ពាក្យថា "សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ" នៅទីនេះ សំដៅទៅលើសិទ្ធិដែលម្ចាស់សិទ្ធិអាចទាមទារមិនឱ្យអ្នកមានករណីយកិច្ច ធ្វើសកម្មភាពណាមួយ ទោះបីជាសិទ្ធិនោះ ផ្អែកលើសិទ្ធិលើបំណុល ឬ សិទ្ធិប្រត្យក្សក៏ដោយ និង ទោះបីកើតឡើង ដោយកិច្ចសន្យា ឬ ដោយច្បាប់ក៏ដោយ ។ សិទ្ធិទាមទារឱ្យកូនបំណុលទទួល និង មិនរារាំងសកម្មភាពណាមួយរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ របស់តតិយជន ក៏ជាសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយដែរ ។

(២) ក្នុងចំណោមករណីយកិច្ចទាំងឡាយ ដែលអ្នកមានករណីយកិច្ចត្រូវទទួល ចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ គេអាចបែងចែកជា : ករណីយកិច្ចតែមួយលើក (ឧទាហរណ៍ ករណីយកិច្ចមិនបង្ហាញខ្លួននៅលើឆាកប្រគំតន្ត្រីមួយយប់, ករណីយកិច្ចមិនធ្វើអនុប្បទានវត្ថុជាក់លាក់ណាមួយ), ករណីយកិច្ចច្រើនដង (ឧទាហរណ៍ ករណីយកិច្ចមិនបោះពុម្ពទស្សនាវដ្តីនៅមុនថ្ងៃទី ២០ រៀងរាល់ខែ, ករណីយកិច្ចមិនបង្កសម្លេងរំខានលើសពីកម្រិតណាមួយ នៅក្រោយម៉ោង ៩ រៀងរាល់យប់), និង ករណីយកិច្ចបន្តបន្ទាប់ (ឧទាហរណ៍ ករណីយកិច្ចមិនសាងសង់អាគារនៅលើដីណាមួយ, ករណីកិច្ចមិនប្រកួតប្រជែង) ។ វិធីនៃការអនុវត្តដោយបង្ខំ

ខុសគ្នាពីមួយទៅមួយ អាស្រ័យទៅតាមប្រភេទនៃករណីយកិច្ចទាំងនេះ ។

## ២. វិធីអនុវត្ត

(១) ការទប់ស្កាត់ការបំពាន : ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ មិនមានភាពចាំបាច់ទេ ប្រសិនបើពុំមានការបំពានលើករណីយកិច្ចមិនធ្វើសកម្មភាព ព្រោះក្នុងករណីនេះ ល័ក្ខខ័ណ្ឌដើម្បីចាប់ផ្តើមការអនុវត្ត មិនត្រូវបានបំពេញទេ ។ ហេតុនេះហើយ ការអនុវត្តប្រភេទនេះ មិនអាចធ្វើឡើងក្នុងគោលបំណងទប់ស្កាត់ការបំពានទេ ។ ក្នុងករណីដែលសិទ្ធិទាមទារឱ្យទប់ស្កាត់ពិសេស ត្រូវបានទទួលស្គាល់ដោយច្បាប់សារធាតុ (មាត្រា ១៩៩ កថាខណ្ឌទី ២, មាត្រា ២៤០ នៃក្រមរដ្ឋប្បវេណី ជាអាទិ៍) ការអនុវត្តដោយបង្ខំ អាចធ្វើឡើងបាន ដោយទទួលលិខិតអនុវត្តអំពីសិទ្ធិទាមទារឱ្យទប់ស្កាត់នោះ ។ ក៏ប៉ុន្តែនេះគឺជាករណីដោយឡែក ផ្សេងពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ (នៅក្នុងករណីជាច្រើន នេះគឺជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ មិនមែនជាសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយនោះទេ) ។ ទោះជាយ៉ាងណាក៏ដោយ បើយល់ឃើញថាចាំបាច់ដើម្បីទប់ស្កាត់ការខូចខាតដែលអាចនឹងកើតឡើងដោយសារការបំពានដែលប្រុងនឹងកើតមានហើយនោះ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់សកម្មភាពបំពាននោះបាន (មាត្រា ៥៤៨ កថាខណ្ឌទី ២) ។

(២) ការបញ្ឈប់ការបំពានដែលកំពុងតែកើតមាន : ប្រសិនបើសកម្មភាពបំពានលើករណីយកិច្ចបន្តបន្ទាប់ ឬ ករណីយកិច្ចច្រើនដង ក្នុងការមិនធ្វើសកម្មភាពអ្វីមួយ កំពុងតែកើតមាននាពេលបច្ចុប្បន្ន នោះពាក្យសុំឱ្យអនុវត្តដោយប្រយោលដែលបានកំណត់ក្នុងមាត្រា ៥២៨ អាចដាក់បាន ដើម្បីធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ ។ ក្នុងករណីដែលមានការបំពានលើករណីយកិច្ចបន្តបន្ទាប់ក្នុងការមិនធ្វើសកម្មភាពអ្វីមួយ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចបង្គាប់ឱ្យបញ្ឈប់ការបំពាននោះនៅក្នុងអំឡុងពេលកំណត់មួយ ឬ ឱ្យបញ្ឈប់ជាបន្ទាន់ ហើយបង្គាប់ឱ្យបង់ប្រាក់បង្ខំមួយចំនួន ស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬ ឱ្យបង់ភ្លាមៗ ប្រសិនបើមិនបញ្ឈប់ការបំពាននោះ ។ ម៉្យាងទៀត ក្នុងករណីដែលមានការបំពានលើករណីយកិច្ចច្រើនដងក្នុងការមិនធ្វើសកម្មភាពអ្វីមួយ តុលាការអនុវត្ត ក៏អាចចេញដីកាសម្រេចបង្គាប់ឱ្យបញ្ឈប់ការបំពាននោះ នៅក្នុងអំឡុងពេលកំណត់មួយ ឬ ឱ្យបញ្ឈប់ជាបន្ទាន់ ហើយបង្គាប់ឱ្យបង់ប្រាក់បង្ខំមួយចំនួន សម្រាប់សកម្មភាពបំពានម្តងៗនោះដែរ ។ ផ្ទុយទៅវិញ ចំពោះករណីយកិច្ចតែមួយលើកវិញ មានតែការទប់ស្កាត់ជាមុន តាមវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន ដូចបានពន្យល់ក្នុង (១) ប៉ុណ្ណោះ ដែលអាចធ្វើទៅបាន ។

(៣) ការដកចេញនូវលទ្ធផលនៃការបំពាន : ក្នុងករណីដែលអំពើបំពានលើករណីយកិច្ចមិនធ្វើសកម្មភាពអ្វីមួយ ត្រូវបានធ្វើឡើង អំពើបំពានដែលបានធ្វើរួចហើយនោះ មិនអាចដកចេញបានទេ ។ ប៉ុន្តែ ប្រសិនបើ

លទ្ធផលនៃអំពើបំពាននោះ នៅមានសេសសល់ នោះម្ចាស់បំណុលនៃការអនុវត្ត អាចទាមទារឱ្យដកចេញនូវលទ្ធផលនៃអំពើបំពាននោះបាន តាមវិធីនៃការអនុវត្តជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត (មាត្រា ៥២៧ កថាខណ្ឌទី ៧) ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលនៃការអនុវត្ត បានសាងសង់សំណង់លើដីមួយ ដោយបំពានលើករណីយកិច្ចមិនសាងសង់សំណង់នៅលើដីនោះមួយ នោះម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំទៅតុលាការអនុវត្ត ឱ្យចេញដីកាសម្រេចប្រគល់សិទ្ធិសម្រាប់ការអនុវត្តជំនួសបាន ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនៃសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពសាងសង់ ដែលមានអានុភាពអនុវត្ត ។ ប្រសិនបើបានទទួលដីកាសម្រេចប្រគល់សិទ្ធិនោះ ម្ចាស់បំណុលនៃការអនុវត្ត អាចជួលតតិយជនឱ្យបំផ្លាញសំណង់នោះ ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តបាន ដោយផ្អែកលើដីកាសម្រេចនោះ ។ ម្យ៉ាងទៀត ដោយផ្អែកលើលិខិតអនុវត្តនៃសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាព និងដោយប្រើវិធីនៃការអនុវត្តជំនួស ម្ចាស់បំណុលនៃការអនុវត្ត អាចទាមទារឱ្យបង្កើតការសាងសង់ ដើម្បីបង្ការសកម្មភាពបំពាននោះ ឬ អាចទាមទារឱ្យមានមធ្យោបាយសមរម្យផ្សេងទៀតបាន (មាត្រា ៥២៧ កថាខណ្ឌទី ៧) ។ ប្រភេទនៃការសាងសង់ដែលត្រូវបង្កើតនោះ ត្រូវទុកឱ្យតុលាការអនុវត្តជាអ្នកសម្រេច តាមឆន្ទានុសិទ្ធិរបស់ខ្លួន ។ ក៏ប៉ុន្តែ ការសាងសង់នោះ ត្រូវមានចរិត (សកម្មភាពដែលអាចអនុវត្តជំនួសបាន) និង រចនាសម្ព័ន្ធដែលអាចអនុវត្តតាមវិធីអនុវត្តជំនួសបាន ។ ឧទាហរណ៍ ដើម្បីធានាការអនុវត្តករណីយកិច្ចមិនបង្កសម្លេងរំខានហួសពីកម្រិតណាមួយ វិធីដែលអាចធ្វើទៅបាន មានដូចជាការសាងសង់ជញ្ជាំងការពារសម្លេង ជាអាទិ៍ តាមវិធីនៃការអនុវត្តជំនួស ។ នៅក្នុងការអនុវត្តជាក់ស្តែង ការកំណត់ប្រភេទនៃមធ្យោបាយសមរម្យផ្សេងទៀតដែលអាចបង្ការបាន មានការលំបាកយ៉ាងច្រើន ។

ផ្ទុយពីករណីខាងលើ ប្រសិនបើសកម្មភាពបំពានមិនបន្សល់ទុកនូវលទ្ធផលជាសម្ភារៈណាមួយទេនោះ ម្ចាស់បំណុលនៃការអនុវត្ត ពុំមានជម្រើសអ្វីផ្សេងក្រៅពីការទាមទារសំណងនៃការខូចខាតឡើយ ។

# ជំពូកទី ៤ នីតិវិធីនៃការចាត់ចែងរក្សាការពារ

## ផ្នែកទី ១ គោលគំនិត

### ១. គោលបំណង និង ប្រភេទនៃការចាត់ចែងរក្សាការពារ

(១) ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និង ថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ (មាត្រា ៥៣០) ។ ជាការពិត ការចាប់ផ្ដើមការអនុវត្តដោយបង្ខំ តម្រូវឱ្យបំពេញល័ក្ខខ័ណ្ឌដូចជាអត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់សង ជាអាទិ៍ ។ ក៏ប៉ុន្តែ ទោះបីជាការអនុវត្តដោយបង្ខំ មិនអាចចាប់ផ្ដើមបានបើខ្វះល័ក្ខខ័ណ្ឌណាមួយក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុន មិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និង ស្ថានភាពជាក់ស្ដែងដែរ ក្នុងករណីដែលការសម្រេចសិទ្ធិទាមទារដោយការអនុវត្តដោយបង្ខំ ទំនងជាមិនអាចធ្វើទៅបាន ឬ ទំនងជាមានការលំបាកយ៉ាងខ្លាំង នៅពេលដែលគ្រប់ល័ក្ខខ័ណ្ឌទាំងអស់សម្រាប់ការអនុវត្ត ត្រូវបានបំពេញនាពេលអនាគត ប្រសិនបើកូនបំណុលត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដោយសេរីនោះ ។

(២) ការចាត់ចែងរក្សាការពារ រួមមាន ការរឹបអូសជាបណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្ន ។ ការចាត់ចែងជាបណ្ដោះអាសន្ន ចែកជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន (មាត្រា ៥៣១) ។ ការរឹបអូសជាបណ្ដោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឱ្យសងជាប្រាក់ ។ ចំណែកឯការចាត់ចែងជាបណ្ដោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទារឱ្យសងជាប្រាក់ ។ ទោះជាយ៉ាងណាក៏ដោយ បើនិយាយអំពីមុខងារ ការរឹបអូសជាបណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានលក្ខណៈរួមត្រង់ថា វិធានការទាំងពីរនេះ គឺជាការចាត់ចែងដែលមានគោលបំណងរក្សាការពារនូវស្ថានភាពបច្ចុប្បន្ន សម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត ។ ដោយឡែក ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន មានលក្ខណៈខុសប្លែកពីនេះ ដោយវាបង្កើតឱ្យមាននូវឋានៈជាបណ្ដោះអាសន្ន រហូតដល់ពេលកំណត់ទំនាក់ទំនងនៃសិទ្ធិជាស្ថាពរ ក្នុងគោលបំណងដកចេញ និង ទប់ស្កាត់នូវគ្រោះថ្នាក់ និង ការលំបាកនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយភាពយឺតយ៉ាវនៃការកំណត់ទំនាក់ទំនងនៃសិទ្ធិនោះជាស្ថាពរ ។

## ២. រចនាសម្ព័ន្ធនៃនីតិវិធីចាត់ចែងរក្សាការពារ

(១) ការបែងចែកដំណាក់កាលនៅក្នុងនីតិវិធី : ជាទូទៅ នីតិវិធីចាត់ចែងរក្សាការពារ មានចរិតលក្ខណៈជានីតិវិធីដែលបំពេញបន្ថែមទៅលើការអនុវត្តដោយបង្ខំ ដែលនៅក្នុងនោះ មានការបែងចែកជាពីរដំណាក់កាលដូចតទៅ : នីតិវិធីនៃការសម្រេចសេចក្តី ដែលវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ និង នីតិវិធីនៃការអនុវត្ត ដែលសម្រេចដោយបង្ខំនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញ ដោយយកដីកាសម្រេចនេះមកធ្វើជាលិខិតអនុវត្ត ។ ដំណាក់កាលទីមួយ អាចហៅថា ការសម្រេចរក្សាការពារ ឯដំណាក់កាលទីពីរ អាចហៅថា ការអនុវត្តរក្សាការពារ ។ ការបែងចែកនេះមានលក្ខណៈដូចគ្នានឹងការបែងចែករវាងនីតិវិធីបណ្តឹង និង នីតិវិធីនៃការអនុវត្តដោយបង្ខំដែរ ។ ក៏ប៉ុន្តែគោលបំណងនៃដីកាសម្រេចរក្សាការពារ អាចសម្រេចបានលុះណាតែមានការអនុវត្តដោយបង្ខំ ។ ហេតុនេះហើយ ទំនាក់ទំនងរវាងការសម្រេចរក្សាការពារ និង ការអនុវត្តរក្សាការពារ មានលក្ខណៈជិតស្និទ្ធជាងទំនាក់ទំនងរវាងនីតិវិធីបណ្តឹង និង នីតិវិធីនៃការអនុវត្តដោយបង្ខំ ។

(២) ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ : ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ តាមពាក្យសុំ (មាត្រា ៥៣២ កថាខណ្ឌទី ១) ។ ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃការសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច (មាត្រា ៥៣៥ កថាខណ្ឌទី ១) ។ បញ្ញត្តិនៃគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១), គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) និង គន្ថីទី ៤ (ការជំនុំជម្រះសាជាថ្មី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការសម្រេចរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស (មាត្រា ៥៣៥) ។ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា រួមមានមាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ និង កថាខណ្ឌទី ២ ដែលចែងអំពីភាពមិនចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច និង អំពីការសួរភាគីនៅក្នុងករណីនោះ, មាត្រា ២១៣ ដែលចែងអំពីការជូនដំណឹងអំពីដីកាសម្រេច, គន្ថីទី ២ ជំពូកទី ៨ ដែលចែងអំពីកាលបរិច្ឆេទ អំឡុងពេល និង ការបញ្ជូន, និង គន្ថីទី ៣ ជំពូកទី ៤ ដែលចែងអំពីបណ្តឹងជំទាស់ចំពោះដីកាសម្រេច (មាត្រា ៥៣៦ អំពីការផ្តល់នូវប្រាតិភោគ, មាត្រា ៥៣៧ អំពីសោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍, និង មាត្រា ៥៣៨ អំពីការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍ គឺជាបញ្ញត្តិពិសេស) ។ ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ហៅថា អ្នកដាក់ពាក្យសុំ ឬ ម្ចាស់បំណុល ហើយចំណែកឯភាគីម្ខាងទៀត ហៅថា កូនបំណុល ។

(៣) ការអនុវត្តរក្សាការពារ : ការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ (មាត្រា ៥៣២ កថាខណ្ឌទី ២) ។ តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៣២ កថាខណ្ឌទី ៣) ។ ការសម្រេចសេចក្តីដែល

ទាក់ទងនឹងនីតិវិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច (មាត្រា ៥៣៥ កថាខណ្ឌទី ១) ។ បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន (មាត្រា ៥៣៥ កថាខណ្ឌទី ២) ។ បញ្ញត្តិមួយចំនួនស្តីពីការអនុវត្តដោយបង្ខំ ដែលស្ថិតក្នុងគន្ថីទី ៦ ជំពូកទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស (មាត្រា ៥៦៤) ។ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា ត្រូវបានកម្រិត និង រៀបរាប់លំអិតនៅក្នុងមាត្រា ៥៦៤ (បញ្ញត្តិពិសេស គឺមាត្រា ៥៦៣ ដែលចែងអំពីតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងតវ៉ារបស់តតិយជន) ។

## ផ្នែកទី ២ ការរឹបអូសជាបណ្ដោះអាសន្ន

### កថាភាគទី ១ ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន

#### ១. ល័ក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ

(១) សិទ្ធិដែលត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្ដោះអាសន្ន ចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (សិទ្ធិទាមទារឱ្យសងជាប្រាក់) (មាត្រា ៥៣១ ចំណុច ក និង មាត្រា ៥៤៥ កថាខណ្ឌទី ១) ។ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ប្រសិនបើចង់សម្រេចដោយឱ្យសងជាប្រាក់ ក៏អាចសុំឱ្យចាត់ចែងរក្សាការពារ តាមរយៈការរឹបអូសជាបណ្ដោះអាសន្នដែរ ។

(២) សិទ្ធិទាមទារដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ (មាត្រា ៥៤៥ កថាខណ្ឌទី ២) បាន ។ ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ ។ ឧទាហរណ៍ ដូចជា សិទ្ធិទាមទារឱ្យសំណងនាពេលអនាគតរបស់អ្នកធានា និង សិទ្ធិរបស់អ្នកដាក់ពាក្យបណ្ដឹង ក្នុងការទាមទារឱ្យសងវិញនូវប្រាក់ប្រដាប់ក្ដីនាពេលអនាគត ចំពោះភាគីម្ខាងទៀត ។ ក៏ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលពុំមានការទទួលស្គាល់តម្លៃជាទ្រព្យសម្បត្តិបច្ចុប្បន្ន ដូចជាករណីដែលល័ក្ខខ័ណ្ឌរបស់វាកម្រនឹងបានសម្រេច ឬ ករណីដែលពេលកំណត់ស្ថិតនៅឆ្ងាយពេក ជាដើមនោះ មិនអាចត្រូវបានទទួលស្គាល់នូវល័ក្ខខ័ណ្ឌនៃសិទ្ធិដែលត្រូវបានរក្សាការពារទេ ។

(៣) ទោះបីជាបណ្ដឹងអង្គសេចក្ដីអំពីសិទ្ធិដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការកម្ពុជាបាន ដូចជាករណីនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬ សិទ្ធិទាមទារដែលស្ថិតក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការបរទេស ជាអាទិ៍ ក៏ដោយ ក៏អាចធ្វើការរឹបអូសជាបណ្ដោះអាសន្នបានដែរ ដោយយោងទៅលើភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ។ ចំពោះសិទ្ធិទាមទារដែលកើតចេញពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (ការទាមទារឱ្យផ្ដល់អាហារកាតព្វកិច្ច, ការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិ ជាអាទិ៍)

ក៏ត្រូវអនុវត្តដូចគ្នាដែរ ។

**២. ភាពចាំបាច់នៃការរក្សាការពារ**

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវផ្អែកមិនត្រឹមតែទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកទៅលើភាពចាំបាច់នៃការរក្សាការពារផងដែរ ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគត នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្ដោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែល ប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថា ការរក្សាការពារមានភាពចាំបាច់ ( មាត្រា ៥៤៥ កថាខណ្ឌទី ១) ។

(១) ការរក្សាការពារត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬ ជាគុណភាព ឬ នឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្ដូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍ ។ ការរក្សាការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្ដូរលំនៅឋានជាច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ ។ ការកំណត់នេះ មិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ ។ ក៏ប៉ុន្តែ ដោយសារថាគោលបំណងនៃការរឹបអូសជាបណ្ដោះអាសន្ន មិនមែនដើម្បីទទួលបានការសម្រេចសិទ្ធិដែលពេញលេញជាងពេលបច្ចុប្បន្នទេនោះ អសាធនភាពនាពេលបច្ចុប្បន្នរបស់កូនបំណុលតែឯកឯង មិនអាចធ្វើឱ្យការរក្សាការពារមានភាពចាំបាច់ទេ ។ ដោយឡែក ប្រសិនបើសាធនភាពរបស់កូនបំណុល មានភាពគ្រប់គ្រាន់ ហើយទំនងជានឹងអាចសម្រេចសិទ្ធិទាមទារបាន ដោយងាយស្រួលនោះ ភាពចាំបាច់នៃការរក្សាការពារ នឹងត្រូវបានបដិសេធ ។ ការបដិសេធរបស់កូនបំណុលចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬ ឥរិយាបថរបស់កូនបំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុនៃការបញ្ជាក់អំពីភាពចាំបាច់នៃការរក្សាការពារទេ ព្រោះសកម្មភាពទាំងនោះមិនមែនជាឧបសគ្គ ចំពោះការអនុវត្តដោយបង្ខំឡើយ ។ ត្រង់ចំណុចនេះ ចរិតលក្ខណៈរបស់ភាពចាំបាច់ក្នុងការរក្សាការពារ គឺខុសគ្នាពី "ភាពចាំបាច់ដែលតម្រូវឱ្យធ្វើការទាមទារជាមុន" ដែលជាល័ក្ខខ័ណ្ឌសម្រាប់ធ្វើបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត ( មាត្រា ៧៦) ។

(២) ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំ ទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារ ត្រូវចាត់ទុកថាមានភាពចាំបាច់ ។ ឧទាហរណ៍ ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និង ការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍ ។

(៣) ទោះបីជាក្នុងករណីដែលបានបំពេញតាមល័ក្ខខ័ណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារ អាចនឹងត្រូវបានបដិសេធដែរ ។ ឧទាហរណ៍ ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគ

ប្រត្យក្សគ្រប់គ្រាន់ហើយ ឬ ករណីដែលសិទ្ធិលើបំណុល បំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានល័ក្ខខ័ណ្ឌ ។

## កថាភាគទី ២ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### ១. តុលាការនៃការរឹបអូសជាបណ្ដោះអាសន្ន

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ស្ថិតនៅ គឺជាតុលាការមានសមត្ថកិច្ចលើរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៤០ កថាខណ្ឌទី ១) ។ សមត្ថកិច្ចនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ( មាត្រា ៥៣៣) ។

( ១) តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី : "អង្គសេចក្ដី" គឺជារឿងក្ដីនៃបណ្ដឹងដែលពាក្យបណ្ដឹងត្រូវបានដាក់ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ( ដូចបានពន្យល់ពីខាងដើម ( ជាករណីលើកលែងដូចបានពន្យល់នៅកថាភាគទី ១ **១.** ( ៣) ខាងលើ) អង្គសេចក្ដីក៏អាចជារឿងក្ដីមជ្ឈត្តកម្ម ឬ រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដែរ) ។ នៅមុនពេលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការមានសមត្ថកិច្ចគឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីនៃបណ្ដឹងដែលនឹងធ្វើនាពេលអនាគត ហើយបើមានតុលាការដែលមានសមត្ថកិច្ចបែបនេះច្រើន នោះអាចជ្រើសយកតុលាការណាមួយក្នុងចំណោមតុលាការទាំងនោះបាន ។ នៅពេលដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះលើកទី ១ ។ ក៏ប៉ុន្តែ ប្រសិនបើអង្គសេចក្ដីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ( មាត្រា ៥៤០ កថាខណ្ឌទី ២) ។ ក្នុងករណីដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្ដឹងសាទុក្ខ នោះត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញ ពោលគឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះលើកទី ១ ។

( ២) សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ស្ថិតនៅ : នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ នោះត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ ហើយបើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាចលនវត្ថុវិញ ត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ ( សូមមើល **២.** ខាងក្រោម) ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថា សិទ្ធិនោះ ស្ថិតនៅឯលំនៅឋាន ជាអាទិ៍ ( សូមមើលមាត្រា ៨) របស់កូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ( មាត្រា ៥៤០ កថាខណ្ឌទី ៣ និង ទី ៤) ។

## ២. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

(១) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ : ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ៥៣៤ ចំណុច ក) ។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីធានានូវភាពច្បាស់លាស់ ។ ពន្ធនៃការដាក់ពាក្យសុំ ត្រូវបានកំណត់ចំនួន ៥ ០០០ រៀល (មាត្រា ៥៣៧ កថាខណ្ឌទី ១) ។ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម (មាត្រា ៥៤១ កថាខណ្ឌទី ១) :

①អត្តសញ្ញាណនៃភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់

② ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ : ជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ត្រូវកំណត់ឱ្យបានជាក់លាក់ (សូមមើលមាត្រា ៥៤៦ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ មិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ (សូមមើលមាត្រា ៥៤៦ វាក្យខណ្ឌទី ២) តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ (សូមមើលមាត្រា ៥៦៥ កថាខណ្ឌទី ១) ។

③សិទ្ធិដែលត្រូវបានរក្សាការពារ : ត្រូវរៀបរាប់អំពីមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ ។

④ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ។

ចំពោះចំណុច ③ និង ចំណុច ④ ត្រូវសរសេរឱ្យបានច្បាស់លាស់ និង ត្រូវសរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ (មាត្រា ៥៤១ កថាខណ្ឌទី ២) ។

(២) ឯកសារនៃសេចក្ដីបញ្ជាក់ដំបូង : ចំពោះចំណុច ③ និង ចំណុច ④ ដោយសារថាអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង (មាត្រា ៥៤១ កថាខណ្ឌទី ៣) ដូច្នេះ អ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់ជាមួយនឹងពាក្យសុំជាលាយលក្ខណ៍អក្សរ នូវឯកសារដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូង ។ ម្យ៉ាងទៀត អ្នកតំណាងដោយអាណត្តិដែលមានសិទ្ធិតំណាងនៅក្នុងបណ្ដឹងអំពីសិទ្ធិដែលត្រូវរក្សាការពារ ក៏ត្រូវមានសិទ្ធិតំណាងនៅក្នុងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែរ (សូមមើលមាត្រា ៥៤ កថាខណ្ឌទី ២) ។

## ៣. វិធីនៃការវិនិច្ឆ័យ

(១) នីតិវិធីនៃដីកាសម្រេច : ដោយសារថា ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយដីកាសម្រេច (សូមមើល **៤.** (១) ខាងក្រោម) ដូច្នេះ នីតិវិធីនេះមិនធ្វើតាមនីតិវិធីនៃបណ្ដឹងទេ គឺត្រូវធ្វើតាមនីតិវិធីនៃការចេញដីកាសម្រេច ។ ហេតុនេះហើយ ការទាញហេតុផលដោយផ្ទាល់មាត់ មិនមានភាពចាំបាច់ជានិច្ចនោះទេ ពោលគឺតុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ តុលាការអាចសួរភាគីបាន (មាត្រា ១១៤ កថាខណ្ឌទី ២) ។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលទាមទារឱ្យ

ធ្វើឡើងជាសម្ងាត់ ជាទូទៅ ត្រូវបានចេញ ដោយគ្រាន់តែសួរម្ចាស់បំណុលប៉ុណ្ណោះ ។

(២) ការធ្វើសេចក្ដីបញ្ជាក់ដំបូង : ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តម្រូវឱ្យមានអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ (សូមមើលកថាភាគទី ១) ។ ហេតុនេះហើយ ចាំបាច់ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីចំណុចទាំងនេះ (មាត្រា ៥៤១ កថាខណ្ឌទី ៣) ។ ប្រសិនបើតម្រូវឱ្យបញ្ជាក់តែម្ដង នោះវាមិនមានអ្វីខុសគ្នាអំពីបណ្ដឹងអង្គសេចក្ដីនោះទេ ហើយវាក៏មិនស្របទៅនឹងភាពបណ្ដោះអាសន្ន និង ភាពឆាប់រហ័សនៃការរឹបអូសជាបណ្ដោះអាសន្នផងដែរ ។ ចំពោះការធ្វើសេចក្ដីបញ្ជាក់ដំបូង ត្រូវយកបញ្ញត្តិនៃមាត្រា ១៣១ មកអនុវត្ត ។ មានន័យថា សេចក្ដីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ។ ហេតុនេះហើយ ការប្រគល់កិច្ចការស្រាវជ្រាវ ការចេញដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ឬ ការសាកសួរសាក្សីដែលទាមទារឱ្យមានការកោះហៅ ជាអាទិ៍ មិនអាចធ្វើបានទេ ។

## ៤. ដីកាសម្រេច

(១) ការសម្រេចសេចក្ដីលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេច (មាត្រា ៥៣៥ កថាខណ្ឌទី ១) ។

(២) បើខ្វះល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការធ្វើបណ្ដឹង ដែលអនុវត្តដូចគ្នាចំពោះនីតិវិធីនៃដីកាសម្រេចរក្សាការពារ (ដូចជាសមត្ថភាពភាគី និង លក្ខណសម្បត្តិជាភាគី) នោះពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន នឹងត្រូវបានលើកចោល ។ បើខ្វះល័ក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន ក៏ពាក្យសុំនឹងត្រូវបានលើកចោលដែរ (ជាទ្រឹស្ដី វាគួរតែជាការច្រានចោល តែនៅទីនេះវាត្រូវបានចាត់ចែងជាការលើកចោល) ។ ចំពោះដីកាសម្រេចដែលលើកចោលពាក្យសុំនេះ អាចប្ដឹងជំទាស់បាន (មាត្រា ៥៤៤) ។ អំឡុងពេលធម្មតានៃការប្ដឹងជំទាស់ គឺ ១ សប្ដាហ៍ (មាត្រា ៣០៣) ប៉ុន្តែ អំឡុងពេលនៃការប្ដឹងជំទាស់នៅក្នុងករណីនេះ ត្រូវបានកំណត់ដល់ទៅ ២ សប្ដាហ៍ ដោយយោងទៅលើភាពស្មុគស្មាញរបស់វា ។

(៣) ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន : ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវចេញនៅពេលដែលល័ក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន ក៏ដូចជាល័ក្ខខ័ណ្ឌចាំបាច់ផ្សេងទៀតសម្រាប់ការធ្វើបណ្ដឹង ត្រូវបានបំពេញសព្វគ្រប់ ។ ជាគោលការណ៍ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្ន អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ (មាត្រា ៥៤៦) ។ តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទៅភាគី (មាត្រា ៥៤៣) ។

(ក) ប្រាតិភោគ : ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន (មាត្រា ៥៤២) ។ ការឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ត្រូវអាស្រ័យ

ទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ (នៅក្នុងការរឹបអូសជាបណ្តោះអាសន្ន ជាធម្មតា តែងតែមានការតម្រូវឱ្យដាក់ប្រាតិភោគ) ។ ប្រាតិភោគនេះ គឺដើម្បីធានានូវសំណងនៃការខូចខាតដែលអាចនឹងកើតមានដល់កូនបំណុល ក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ មានភាពខុសពីការពិត (ឧទាហរណ៍ ករណីដែលកម្មវត្ថុមិនអាចលក់បានដោយសារការរឹបអូសជាបណ្តោះអាសន្ន ហើយនៅពេលដែលអាចលក់វិញ ថ្លៃរបស់វាបានធ្លាក់ចុះ) ។ ម្យ៉ាងទៀត ជំនួសឱ្យការបង្គាប់ឱ្យដាក់ប្រាតិភោគជាមុន តុលាការក៏អាចបង្គាប់ឱ្យដាក់ប្រាតិភោគ ជាល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នដែរ ។ ចំពោះវិធីនៃការដាក់ប្រាតិភោគ គឺត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ (មាត្រា ៥៣៦, ចំពោះការប្តូរប្រាតិភោគ សូមមើលមាត្រា ៧១ កថាខណ្ឌទី ២) ។ ចំពោះសិទ្ធិរបស់អ្នកដែលទទួលការដាក់ប្រាតិភោគ និង ការលុបចោលនូវប្រាតិភោគ ត្រូវយកបញ្ញត្តិស្តីពីប្រាតិភោគលើបណ្តឹង មកអនុវត្ត (សូមមើលមាត្រា ៧២ និង មាត្រា ៧៣) ។ ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ម្ចាស់បំណុលដែលអះអាងថាដីកាសម្រេចនោះគួរចេញ ដោយមិនចាំបាច់ឱ្យដាក់ប្រាតិភោគ អាចប្តឹងជំទាស់បាន (ទាក់ទងទៅនឹងមាត្រា ៥៤៤ កថាខណ្ឌទី ១ ដីកាសម្រេចនេះ អាចចាត់ទុកថាជាការលើកចោលពាក្យសុំមួយផ្នែក) ។

(ខ) ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន : ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើទៅតុលាការ ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) (មាត្រា ៥៤៧ កថាខណ្ឌទី ១) ។ ការរឹបអូសជាបណ្តោះអាសន្ន មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហេតុដូច្នេះ ប្រសិនបើចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារដែលពាក់ព័ន្ធ ត្រូវបានផ្ញើ ម្ចាស់បំណុលនឹងមិនទទួលការខូចខាតទេ ។ ម្យ៉ាងទៀត វាអាចនឹងនាំឱ្យមានការបាត់បង់ផលប្រយោជន៍មួយចំនួនដល់កូនបំណុល ប្រសិនបើកូនបំណុល ត្រូវបានហាមឃាត់ក្នុងការចាត់ចែងទ្រព្យសម្បត្តិ ដោយសារការរឹបអូសជាបណ្តោះអាសន្ននោះ ។ ហេតុនេះហើយបានជាច្បាប់អនុញ្ញាតឱ្យមានការរំដោះខ្លួន ចេញពីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដោយផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ ។ ប្រាក់ដែលផ្ញើនេះ នឹងជំនួសឱ្យទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ហើយនៅពេលដែលម្ចាស់បំណុលបានទទួលលិខិតអនុវត្តហើយ ម្ចាស់បំណុលនោះអាចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ប្រាក់ដែលផ្ញើបាន ។

## កថាភាគទី ៣ ឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

### ១. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

(១) ចំពោះដីកាសម្រេចរក្សាការពារ មិនអាចប្តឹងជំទាស់ភ្លាមបានទេ ប៉ុន្តែ អាចដាក់ពាក្យសុំតវ៉ា ទៅ

តុលាការដែលបានចេញដីកាសម្រេចនោះបាន ( មាត្រា ៥៥០ ) ។ ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុន ក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែល ដែលចំណុចនេះ ស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្នុងនីតិវិធីនៃការដាស់តឿនដែរ ( មាត្រា ៣២៧ និង មាត្រា ៣២៨ ) ។ ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ លុបចោលដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះដែរ ។

( ២ ) ពាក្យសុំតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ( មាត្រា ៥៣៤ ចំណុច គ ) ។ ដោយពុំមានការកំណត់អំឡុងពេល ពាក្យសុំតវ៉ា អាចដាក់នៅពេលណាក៏បាន ឱ្យតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នៅមានសុពលភាព ។ ការដាក់ពាក្យសុំតវ៉ា មិនធ្វើឱ្យអានុភាពអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែក ដែលបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត ( មាត្រា ៥៥១ ) ។ សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណីដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារនោះ ប៉ុណ្ណោះ ហើយម្យ៉ាងទៀត ការដាក់ប្រាតិភោគ មានភាពចាំបាច់ជានិច្ច ( មាត្រា ៥៥១ កថាខណ្ឌទី ១ ) ។ "ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ" សំដៅទៅលើស្ថានភាពដែលផ្ទុយយ៉ាងច្បាស់លាស់ នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ( ឧទាហរណ៍ មានភាពមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត នៅក្នុងការទទួលស្គាល់ ឬ នៅក្នុងការបកស្រាយច្បាប់ ) ។ ដោយឡែក "ការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារ" សំដៅទៅលើករណីដែលសំណងជាប្រាក់ តាមក្រោយទំនងជានឹងមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ ( ឧទាហរណ៍ ករណីដែលកូនបំណុលនឹងក្ស័យធន ឬ មិនអាចរស់បាន ដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុល ជាអាទិ៍ ) ។

( ៣ ) នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ធ្វើការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ( មាត្រា ៥៥២ ) ។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ទៅឱ្យភាគី ( ជាពិសេសកូនបំណុល ) នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី ។ ប៉ុន្តែ យ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ

ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាឱ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន តែម្តងក៏ជាការគ្រប់គ្រាន់ដែរ ។ ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ា ជាគោលការណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៥៣ វាក្យខណ្ឌទី ១) ។ ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច តុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏ដោយ ក៏នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគី អំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្តល់ឱកាសឱ្យភាគី ក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យ ទៅតុលាការ ឱ្យបានគ្រប់គ្រាន់ ។ ក៏ប៉ុន្តែ ប្រសិនបើការវិនិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាម១ថាបញ្ចប់ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយ គឺដូចគ្នា ទៅនឹងនីតិវិធីបណ្តឹងដែរ (មាត្រា ៥៥៣ វាក្យខណ្ឌទី ២) ។

(៤) នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៥៤ កថាខណ្ឌទី ១) ។ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះ ។ រីឯតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានផ្នែកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ ។ ករណីនេះ រួមបញ្ចូលករណីដូចជាល័ក្ខខ័ណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬការបន្ថែមនូវប្រាតិភោគ នៅក្នុងអំឡុងពេលកំណត់ណាមួយ ជាអាទិ៍ ។ តុលាការត្រូវចេញដីកាសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចនោះ មានភាពមិនត្រឹមត្រូវ ហើយនៅក្នុងករណីនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន (មាត្រា ៥៥៤ កថាខណ្ឌទី ២) ។ ដីកាសម្រេចនេះ មិនមានអានុភាព បើមិនទាន់ចូលជាស្ថាពរទេ ក៏ប៉ុន្តែ បើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនេះ មានអានុភាពភ្លាម១បាន (មាត្រា ៥៥៦) ។ ដីកាសម្រេចទាំងនេះ ត្រូវបញ្ជូនទៅភាគី (មាត្រា ៥៥៤ កថាខណ្ឌទី ៣) ហើយ បណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចទាំងនេះ (មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក) ។

## ២. ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

(១) ក្រៅពីការលុបចោលដោយសារការតវ៉ា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានលុបចោលនៅក្នុងករណីពីរទៀត ដែលមាននីតិវិធីដោយឡែកពីគ្នា តាមពាក្យសុំរបស់កូនបំណុល : ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍ និង ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព ។

(២) ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍ : តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបង្គាប់ឱ្យម្ចាស់បំណុល ដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់

ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ( មាត្រា ៥៥៧ កថាខណ្ឌទី ១) ។ ការបង្គាប់នេះ ហៅថា ការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹង ។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឱ្យម្ចាស់បំណុលទៅទទួលលិខិតអនុវត្ត សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ។ ការកំណត់បែបនេះ នឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឱ្យយូរអង្វែង ។ ហេតុនេះហើយ ការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹង អាចចេញបានដោយពុំមានល័ក្ខខ័ណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល ។ អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី មិនត្រូវតិចជាង ២ សប្ដាហ៍ទេ ( មាត្រា ៥៥៧ កថាខណ្ឌទី ២) ។

ប្រសិនបើម្ចាស់បំណុល មិនដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹងទេ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមពាក្យសុំរបស់កូនបំណុល ( មាត្រា ៥៥៧ កថាខណ្ឌទី ៣) ។ ម៉្យាងទៀត ប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នោះត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ហើយការណ៍នេះ ក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលដែរ ( មាត្រា ៥៥៧ កថាខណ្ឌទី ៤) ។ ការចាប់ផ្ដើមនីតិវិធីមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្ដី ( មាត្រា ៥៥៧ កថាខណ្ឌទី ៥) និង ការចាប់ផ្ដើមនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រសិនបើអង្គសេចក្ដី គឺជារឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ក៏ត្រូវចាត់ទុកថាជាការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីដែរ ។ ដីកាសម្រេចលុបចោល ត្រូវបញ្ជូនទៅភាគី ( មាត្រា ៥៥៧ កថាខណ្ឌទី ៨) ហើយបណ្ដឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចនេះ ( មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក) ។

( ៣) ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព : បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមពាក្យសុំរបស់កូនបំណុលបាន ( មាត្រា ៥៥៨ កថាខណ្ឌទី ១) ។ ការផ្លាស់ប្ដូរស្ថានភាពនេះ ត្រូវបានបែងចែកជាពីរប្រភេទ ។ ប្រភេទទីមួយ គឺករណីដែលនៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានកើតឡើងនូវអង្គហេតុថ្មីដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ( ឧទាហរណ៍ ករណីដែលសិទ្ធិទាមទារទាំងអស់ដែលត្រូវបានរក្សាការពារ ត្រូវបានសងគ្រប់ចំនួន, ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី ១ សម្រេចឱ្យម្ចាស់បំណុលចាញ់ក្ដី នៅក្នុងបណ្ដឹងអង្គសេចក្ដី, ករណីដែលកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង, ករណីដែលម្ចាស់បំណុលមិនធ្វើការ

អនុវត្តដោយបង្ខំ បើទោះជាបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយ ជាអាទិ៍) ។ ប្រភេទទីពីរ គឺករណីដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬ អាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីជាអង្គហេតុនោះបានកើតឡើងនៅពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង អំពីការផ្លាស់ប្តូរស្ថានភាពនោះ ( មាត្រា ៥៥៨ កថាខណ្ឌទី ២) ។

បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្តីអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ( មាត្រា ៥៦០ កថាខណ្ឌទី ១) ។ មានន័យថា បញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាអាទិ៍ ( មាត្រា ៥៥១), ការទាញហេតុផលដោយផ្ទាល់មាត់ និង ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ( មាត្រា ៥៥២), ការបញ្ចប់ការវិនិច្ឆ័យ ( មាត្រា ៥៥៣), និង អានុភាពនៃដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ( មាត្រា ៥៥៦) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយសារការផ្លាស់ប្តូរស្ថានភាព ។ ដីកាសម្រេចលុបចោល អាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ហើយដីកាសម្រេចនេះ ត្រូវបញ្ជូនទៅភាគី ( មាត្រា ៥៥៨ កថាខណ្ឌទី ៣) និង អាចប្តឹងជំទាស់បាន ( មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក) ។

## ៣. បណ្តឹងជំទាស់

(១) ដូចបានពន្យល់រួចហើយ ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនអាចប្តឹងជំទាស់បានទេ ។ ក៏ប៉ុន្តែ ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចប្តឹងជំទាស់បាន ( មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក) ។ បញ្ញត្តិនេះ ធានាចំពោះការសម្រេចសេចក្តីអំពីការរឹបអូសជាបណ្តោះអាសន្នផងដែរ នូវឱកាសក្នុងការទទួលបានការវិនិច្ឆ័យ និង ការសម្រេចសេចក្តី នៅតុលាការជាន់ខ្ពស់ ។ ដីកាសម្រេចដែលទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើពាក្យសុំតវ៉ា និង ដីកាសម្រេចដែលលើកចោលពាក្យសុំទាមទារឱ្យលុបចោល ឬ ដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើពាក្យសុំទាមទារឱ្យលុបចោល សុទ្ធសឹងជាមុខសញ្ញានៃការប្តឹងជំទាស់ ។ អំឡុងពេលនៃការប្តឹងជំទាស់ គឺ ២ សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន ( មាត្រា ៥៦១ កថាខណ្ឌទី ១) ។ ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាលើកទីមួយ បណ្តឹងជំទាស់មិនអាចធ្វើបានទេ ចំពោះដីកាសម្រេចនេះ ព្រោះមានការបកស្រាយថា ដីកាសម្រេចនេះ បានបំពេញល័ក្ខខ័ណ្ឌនៃប្រព័ន្ធនៃការ

ជម្រះក្តីពីរថ្នាក់រួចហើយ ។ ផ្ទុយទៅវិញ ក្នុងករណីដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង លើកចោលពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ នៅក្នុងបណ្តឹងអង្គសេចក្តីដែលកំពុងត្រូវបានចាត់ការនៅសាលាឧទ្ធរណ៍ នោះបណ្តឹងជំទាស់អាចធ្វើទៅតុលាការកំពូលបាន ដើម្បីធានាឱ្យបាននូវប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់ ។

(២) ជាមូលដ្ឋាន បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្តី និង ដីកាសម្រេច នៅតុលាការនៃការជំនុំជម្រះអំពីការតវ៉ា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តី និង ដីកាសម្រេច នៅតុលាការនៃបណ្តឹងជំទាស់ (មាត្រា ៥៦១ កថាខណ្ឌទី ៣) ។ ដូច្នេះ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា រួមមានបញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៥១ កថាខណ្ឌទី ១), ការទាញហេតុផលដោយផ្ទាល់មាត់ និង ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន (មាត្រា ៥៥២), ការបញ្ចប់ការវិនិច្ឆ័យ (មាត្រា ៥៥៣), ដីកាសម្រេចលុបចោលដោយមានល័ក្ខខ័ណ្ឌឱ្យដាក់ប្រាតិភោគ (មាត្រា ៥៥៤ កថាខណ្ឌទី ២), ការបញ្ជូនដីកាសម្រេច (មាត្រា ៥៤៣) (ក្រៅពីនេះបញ្ញត្តិទូទៅស្តីពីបណ្តឹងជំទាស់ (ចាប់ពីមាត្រា ៣០១ តទៅ ដូចជាមាត្រា ៣១៧ ជាដើម) ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានបញ្ញត្តិពិសេស, មាត្រា ៥៣៩) ។

## កថាភាគទី ៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

### ១. ល័ក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

(១) ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត : ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានអានុភាពអនុវត្តភ្លាមៗ និង ជាគោលការណ៍ ត្រូវអនុវត្តបានភ្លាមៗ ដោយសារមានការកម្រិតអំឡុងពេលនៃការអនុវត្ត ។ មានន័យថា អត្ថិភាពនៃអានុភាពអនុវត្ត មិនចាំបាច់ត្រូវធ្វើនិយ័តកម្ម ដោយរូបមន្តអនុវត្តទេ ។ ហេតុនេះហើយ ជាគោលការណ៍ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ (មាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះជនក្រៅពីភាគី ឬ សម្រាប់ជនក្រៅពីភាគីដែលបានកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នោះដើម្បីបញ្ជាក់ភាគីនៃការអនុវត្ត (សូមមើលមាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច ក) ការអនុវត្តនេះ ទាមទារឱ្យមានការផ្តល់នូវរូបមន្តអនុវត្ត (រូបមន្តអនុវត្តពិសេស) (មាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

(២) អំឡុងពេលនៃការអនុវត្ត : ការរឹបអូសជាបណ្តោះអាសន្ន មិនអាចអនុវត្តបានទៀតឡើយ ប្រសិនបើមិនបានអនុវត្តក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ជូនទៅម្ចាស់បំណុល (មាត្រា ៥៦២ កថាខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើមិនអនុវត្តភ្លាមៗទេ នោះការរឹបអូសជាបណ្តោះអាសន្ន នឹងមិនមានភាពចាំបាច់ឡើយ ។ ក៏ប៉ុន្តែ

វាជាការគ្រប់គ្រាន់ហើយក្នុងការចាប់ផ្តើមសកម្មភាពនៃការអនុវត្ត នៅក្នុងអំឡុងពេល ២ សប្តាហ៍ ចំណែកឯសកម្មភាពបន្តបន្ទាប់មកទៀតនៃការអនុវត្ត មិនចាំបាច់ត្រូវតែធ្វើនៅក្នុងអំឡុងពេលនេះទេ ។ អំឡុងពេលនេះមិនកែប្រែជាថ្មីដោយដីកាសម្រេចទទួលស្គាល់ការរឹបអូសជាបណ្តោះអាសន្ន ដែលបានចេញដោយសារមានការដាក់ពាក្យសុំតវ៉ានោះទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានផ្អាកនៅមុនពេលផុតអំឡុងពេលនេះ ត្រូវចាត់ទុកថា អំឡុងពេលមានដំណើរការពីដំបូង ចាប់ពីពេលដែលការផ្អាកបានកន្លងផុត ។ ទោះបីជាអំឡុងពេលនោះកន្លងផុតក៏ដោយ ក៏មិនធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបាត់បង់អានុភាពក៏ដោយ ក៏គេអាចធ្វើឧបាស្រ័យចំពោះការអនុវត្តនៅក្រោយពេលផុតអំឡុងពេល ដោយការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត ( មាត្រា ៣៨៤) ឬ ដោយបណ្តឹងជំទាស់បានដែរ ។

(៣) ការបញ្ជូនលិខិតអនុវត្ត : ទោះបីនៅមុនពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចធ្វើបានដែរ (មាត្រា ៥៦២ កថាខណ្ឌទី ៣) ។ បញ្ញត្តិនេះ ត្រូវបានកំណត់ដោយផ្អែកទៅលើភាពឆាប់រហ័ស និង ភាពលាក់ការសម្ងាត់ ដែលជាគោលបំណងនៃការចាត់ចែងរក្សាការពារ ។

## ២. ប្រភេទផ្សេងៗនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

(១) ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាមូលដ្ឋាន ត្រូវធ្វើទៅតាមការអនុវត្តការរឹបអូស នៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យសងជាប្រាក់ដែរ ។ ក៏ប៉ុន្តែ ជាគោលការណ៍ ការអនុវត្តនេះមិនឈានចូលទៅដល់ដំណាក់កាលនៃការប្តូរជាប្រាក់ទេ ។ នៅគ្រប់ករណីទាំងអស់ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ទៅស្ថាប័នអនុវត្ត ( មាត្រា ៥៣២ កថាខណ្ឌទី ២) ហើយពាក្យសុំនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ( មាត្រា ៥៣៤ ចំណុច ច) ។

(២) ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះចលនវត្ថុ : ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ (មាត្រា ៥៦៥ កថាខណ្ឌទី ១) ។ នីតិវិធីនេះជាមូលដ្ឋាន ត្រូវធ្វើតាមវិធីដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ (មាត្រា ៥៦៥ កថាខណ្ឌទី ៤, មាត្រា ៣៨៤ កថាខណ្ឌទី ២, និង បញ្ញត្តិចាប់ពីមាត្រា ៣៨៥ ដល់មាត្រា ៣៩២) ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាប្រាក់ អាជ្ញាសាលាមិនដកហូតទុក (មាត្រា ៣៨៥ កថាខណ្ឌទី ១) ឬ ឱ្យកូនបំណុលរក្សាទុកប្រាក់នោះ ( មាត្រា ៣៨៥ កថាខណ្ឌទី ៤) ទេ តែអាជ្ញាសាលាត្រូវផ្ញើប្រាក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ ( មាត្រា ៥៦៥ កថាខណ្ឌទី ២) ។ វត្ថុផ្សេងទៀតក្រៅពីប្រាក់ត្រូវដកហូត និង រក្សាទុកដោយអាជ្ញាសាលា ។ ក៏ប៉ុន្តែ ប្រសិនបើមានការបារម្ភថា ចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ននោះ នឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុក

ចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមនីតិវិធីនៃការលក់នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន តាមពាក្យសុំរបស់ម្ចាស់បំណុល ឬ កូនបំណុល ( មាត្រា ៥៦៥ កថាខណ្ឌទី ៣ ) ។ នៅក្នុងករណីនេះ ប្រាក់ដែលទទួលបានពីការលក់ ត្រូវយកទៅផ្ញើនៅតុលាការដែលអាជ្ញាសាលានោះស្ថិតនៅ ។ មាត្រា ៣៨៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះរថយន្ត ឬទោចក្រយានយន្តដែលត្រូវបានចុះបញ្ជី ។ មានន័យថា អាជ្ញាសាលាដែលធ្វើការអនុវត្តរឹបអូសជាបណ្ដោះអាសន្នត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច សរសេរនូវហេតុការណ៍នៃការរឹបអូសជាបណ្ដោះអាសន្ន ចូលទៅក្នុងសៀវភៅបញ្ជី ហើយការរឹបអូសជាបណ្ដោះអាសន្ននោះ នឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរចូលក្នុងសៀវភៅបញ្ជីនោះ ។

( ៣ ) ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ( មាត្រា ៥៦៦ កថាខណ្ឌទី ១ និង ទី ៤ ) ។ តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៦៦ កថាខណ្ឌទី ២ និង ទី ៤ ) ។ នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ជាមូលដ្ឋាន មានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ ( មាត្រា ៥៦៦ កថាខណ្ឌទី ៥, មាត្រា ៤០៣ កថាខណ្ឌទី ២ ទី ៣ ទី ៦ ទី ៧ ទី ៨ ទី ១០ និង ទី ១១, មាត្រា ៤០៤ ដល់មាត្រា ៤០៨, មាត្រា ៤១១, និង មាត្រា ៤១៦ ) ។ នៅក្នុងករណីដែលការរឹបអូសជាបណ្ដោះអាសន្នត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប្រសិនបើកូនបំណុលទី ៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់ទាំងអស់ ឬ មួយផ្នែកនៃសិទ្ធិលើបំណុល នៅតុលាការ នោះនៅក្នុងចំនួនទឹកប្រាក់ទាំងអស់ដែលបានផ្ញើ ភាគដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ( សូមមើលផ្នែកទី ២ កថាភាគទី ២ ៤. ( ៣ ) ( ខ ) ) ត្រូវចាត់ទុកថា ជាប្រាក់ដែលកូនបំណុលបានផ្ញើជាប្រាក់រំដោះ ហើយភាគដែលលើស ត្រូវចាត់ទុកថាជាការសងចំពោះកូនបំណុលនៃការអនុវត្ត ( មាត្រា ៥៦៦ កថាខណ្ឌទី ៣ ) ។

( ៤ ) ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ : ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះ ( មាត្រា ៥៦៧ កថាខណ្ឌទី ១ ) ។ តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៦៧ កថាខណ្ឌទី ២ ) ។ ក្រឡាបញ្ជី ត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៦៧ កថាខណ្ឌទី ៣ ) ។ នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ជាមូលដ្ឋាន មានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយ

បង្ខំចំពោះអចលនវត្ថុដែរ (មាត្រា ៥៦៧ កថាខណ្ឌទី ៤, មាត្រា ៤២០ កថាខណ្ឌទី ២, មាត្រា ៤២១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១, មាត្រា ៤២៤ កថាខណ្ឌទី ១, មាត្រា ៤២៥, មាត្រា ៤២៧, មាត្រា ៤២៨) ។

(៥) ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា : ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូត លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះ ទៅតុលាការអនុវត្តរក្សាការពារ ហើយរបៀប ទាំងពីរនេះ អាចអនុវត្តរួមគ្នាបាន (មាត្រា ៥៦៨ កថាខណ្ឌទី ១) ។ ចំពោះការអនុវត្តរឹបអូសជា បណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលមានសមត្ថកិច្ចជាតុលាការ អនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន រីឯចំពោះការអនុវត្ត រឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ តុលាការដែល មានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះ ស្ថិតនៅ (មាត្រា ៥៦៨ កថាខណ្ឌទី ២) ។ ក្រឡាបញ្ជី ត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៦៨ កថាខណ្ឌទី ៣) ។ នីតិវិធីនៃការអនុវត្តរឹបអូសជា បណ្តោះអាសន្នចំពោះនាវា ជាមូលដ្ឋាន មានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំ ចំពោះនាវាដែរ (មាត្រា ៥៦៨ កថាខណ្ឌទី ៤, មាត្រា ៤៥៥, មាត្រា ៤៥៧ កថាខណ្ឌទី ៧, មាត្រា ៤៦០, មាត្រា ៤៦២, មាត្រា ៤៦៥, និង មាត្រា ៤៦៦) ។ ចំពោះនិយមន័យនៃនាវា សូមមើលមាត្រា ៤៥៤ កថាខណ្ឌទី ១ ។

## ៣. ការផ្អាក និង ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

(១) ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាក ក្នុងលក្ខណៈជាការផ្អាកការអនុវត្តដោយ សារមានពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោល នូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬ ពាក្យសុំលុបចោលនោះ (មាត្រា ៥៥១, មាត្រា ៥៦០, និង មាត្រា ៥៦១ កថាខណ្ឌទី ៣), ការផ្អាកការអនុវត្តដោយសារមានការតវ៉ាចំពោះការអនុវត្ត និង ដោយសារមានការដាក់ពាក្យបណ្តឹងជំទាស់ (មាត្រា ៣៤៣ កថាខណ្ឌទី ២, មាត្រា ៣៤៤ កថាខណ្ឌទី ៣), ការផ្អាកការអនុវត្តដោយសារមានបណ្តឹងតវ៉ារបស់តតិយជន (មាត្រា ៣៦៧ កថាខណ្ឌទី ១) ជាអាទិ៍ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ខុសប្លែកអំពីការអនុវត្តដោយបង្ខំ ការផ្អាកនៅក្រោយការអនុវត្ត មិនសូវមានអត្ថន័យទេ ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ ។

(២) ស្រដៀងគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំដែរ ការលុបចោលនូវការចាត់ចែងការអនុវត្ត រឹបអូសជាបណ្តោះអាសន្ន អាចធ្វើទៅបាន (មាត្រា ៣៦៧ កថាខណ្ឌទី ២, មាត្រា ៣៧០ កថាខណ្ឌទី ១) ។ បន្ថែមពីលើនេះ មានប្រព័ន្ធនៃការលុបចោលការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយការធ្វើ

ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៦៩ កថាខណ្ឌទី ១. ចំពោះប្រាក់រំដោះពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន សូមមើលផ្នែកទី ២ កថាភាគទី ២ ៤. (៣) (ខ)) ។ ទោះបីជាបណ្ដឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចលុបចោលក៏ដោយ តែដោយគិតពិចារណាទៅលើភាពច្បាស់លាស់នៃល័ក្ខខ័ណ្ឌនៃការសម្រេចសេចក្ដីនេះ ការលុបចោលការអនុវត្ត ត្រូវមានអានុភាពភ្លាមៗ ដោយមិនបាច់ចាំរហូតដល់ពេលចូលជាស្ថាពរ (មាត្រា ៥៦៩ កថាខណ្ឌទី ២) ។

## ៤. ការបំលែងពីការរឹបអូសជាបណ្ដោះអាសន្ន ទៅជាការអនុវត្តដោយបង្ខំ

នៅក្រោយពេលដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្ត ប្រសិនបើគ្រប់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញ ហើយម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្ត នោះការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញ ត្រឹមទំហំនៃការអនុវត្តនោះ ។ ហេតុនេះហើយ នីតិវិធីនេះ អាចឈានបន្តទៅដំណាក់កាលនៃការប្ដូរជាប្រាក់បាន ដោយមិនបាច់ធ្វើនីតិវិធីដដែលសម្រាប់ការអនុវត្តដោយបង្ខំទេ ។ ប៉ុន្ដែ យ៉ាងណាក៏ដោយ បើជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលតម្រូវឱ្យមានការចុះបញ្ជីអំពីការរឹបអូស ដាច់ដោយឡែកពីការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នោះត្រូវមានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ របស់តុលាការដែលមានសមត្ថកិច្ច ។ ក្នុងករណីដែលម្ចាស់បំណុលមានការធ្វេសប្រហែសមិនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ បើទោះបីជាគ្រប់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញហើយក៏ដោយនោះ កូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារការផ្លាស់ប្ដូរស្ថានភាពបាន ដោយសំអាងទៅលើការរលត់នៃភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៥៨) ។

# ផ្នែកទី ៣ ការចាត់ចែងជាបណ្ដោះអាសន្ន

## កថាភាគទី ១ ប្រភេទ ល័ក្ខខ័ណ្ឌ និង វិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន

### ១. ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន

ដូចបានពន្យល់ខាងលើ (សូមមើលផ្នែកទី ១ ១. (២)) ការចាត់ចែងជាបណ្ដោះអាសន្ន មានពីរប្រភេទ : ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន (មាត្រា ៥៣១) ។ ទោះបីជាមានគោលបំណង និង ចរិតលក្ខណៈ ខុសគ្នាក៏ដោយ (សូមមើលផ្នែកទី ១ ១. (២)) ក៏ការចាត់ចែងជាបណ្ដោះអាសន្នទាំងពីរនេះ ស្ថិតនៅក្នុងប្រភេទនៃការចាត់ចែងរក្សាការពារ ដែលសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ដូចគ្នា ។ ហេតុនេះហើយ ការចាត់ចែងជាបណ្ដោះអាសន្នទាំងពីរនេះ ត្រូវធ្វើតាមនីតិវិធីដូចគ្នា ។

### ២. ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(១) សិទ្ធិដែលត្រូវបានរក្សាការពារ ៖ គោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្ដោះអាសន្ននេះ ត្រូវមានខ្លឹមសារជាការផ្លាស់ប្ដូរ ឬ មិនផ្លាស់ប្ដូរនូវស្ថានភាពជាក់ស្ដែង ឬ ទំនាក់ទំនងសិទ្ធិដែលមានលើវត្ថុ ។ វត្ថុនេះ ហៅថា "វត្ថុដែលជាកម្មវត្ថុនៃវិវាទ" ។ សិទ្ធិដែលត្រូវបានរក្សាការពារ រួមមាន សិទ្ធិទាមទារឱ្យប្រគល់វត្ថុ, សិទ្ធិទាមទារឱ្យបណ្ដេញបុគ្គលចេញពីដី ឬ អាគារ, សិទ្ធិទាមទារឱ្យដកចេញនូវការសាងសង់, សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ, សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពដែលពាក់ពន្ធនឹងការប្រើប្រាស់វត្ថុ ជាអាទិ៍ ។ ឧទាហរណ៍គំរូនៃការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ រួមមាន ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យបណ្ដេញចេញពីអចលនវត្ថុនោះ, ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុ ជាអាទិ៍ ។ សិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដែលមានគោលបំណងជាការចាត់ចែង ដូចជាអនុប្បទាន និង ការប្រមូល ត្រូវចាត់ទុកដូចជាវត្ថុ ហើយដោយហេតុនេះ អាចក្លាយជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះបាន ។

(២) ភាពចាំបាច់នៃការរក្សាការពារ ៖ ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា ៥៤៨ កថាខណ្ឌទី ១) ។ ករណីនេះ រួមមាន ករណីដែលមានហានិភ័យនៃការខូចខាត ការតែបំបាត់ ការផ្ទេរ ឬ ការរារាំងសិទ្ធិ លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយកូនបំណុល ឬ អ្នកផ្សេង, ករណីដែលបុគ្គលណាម្នាក់កំពុងបន្តដំណើរការនៃការសាងសង់ ក្នុងខណៈដែលមានការទាមទារឱ្យដកចេញនូវការសាងសង់នោះ, ករណីដែលបុគ្គលម្នាក់នាំបុគ្គលម្នាក់ផ្សេងទៀតរួមទាំងឥវ៉ាន់របស់គេ មករស់នៅជាមួយ ក្នុងខណៈដែលមានការទាមទារឱ្យបណ្ដេញចេញពីផ្ទះនោះ, ករណីដែលបុគ្គលម្នាក់ចាប់ផ្ដើមការសាបព្រួស ក្នុងខណៈដែលមានការទាមទារឱ្យប្រគល់ដីកសិកម្មនោះ ជាអាទិ៍ ។

## ៣. លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

(១) សិទ្ធិដែលត្រូវបានរក្សាការពារ ៖ ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន រួមបញ្ចូលនូវការចាត់ចែងជាច្រើនប្រភេទ (ដូចនឹងរៀបរាប់ខាងក្រោម ការចាត់ចែងជាបណ្ដោះអាសន្នដែលសម្រេចសិទ្ធិតែម្ដង ក៏អាចធ្វើទៅបានដែរ) ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះ ក៏មានច្រើនដែរ ។ សិទ្ធិដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬ សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល ។ ឧទាហរណ៍ ទំនាក់ទំនងសិទ្ធិផ្ទាល់មុខ ដូចជា កម្មសិទ្ធិ

សិទ្ធិកាន់កាប់ សេរីភាព សិទ្ធិលើនាម និង សិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម, ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្ស ដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និង កម្មសិទ្ធិអវិភាគ, ទំនាក់ទំនងគតិយុត្តដែលបន្ត ដូចជា កិច្ចសន្យាក្រុមហ៊ុន ភតិសន្យា ការងារ និង ការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច), និង ទំនាក់ទំនងឋានៈបុគ្គល ដូចជា ទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។ ចំពោះសិទ្ធិទាមទារដែលមាន គោលបំណងឱ្យសងជាប្រាក់ ប្រសិនបើគោលបំណងនៃការរក្សាការពារ មិនមែនដើម្បីរក្សាការពារនូវការ អនុវត្តដោយបង្ខំ នាពេលអនាគតទេ តែគឺដើម្បីទប់ស្កាត់ និង ដកចេញនូវគ្រោះថ្នាក់ ឬ ការខូចខាតពិសេស ដែលកើតឡើង ពីការមិនអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារ នោះ គេអាចទាមទារឱ្យផ្ដល់តាវកាលិកទាំងស្រុង ឬ មួយផ្នែក តាមនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន បាន ។ ឧទាហរណ៍ ករណីដែលបុគ្គលណាម្នាក់ ពិបាកនឹងរស់នៅដោយគ្មានការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) ឬ ការបើកប្រាក់បៀវត្ស, ករណីដែលបុគ្គលណាម្នាក់ពិបាកនឹងទទួលបានការព្យាបាល ឬ មិនងាយនឹងជាពីជំងឺ ប្រសិនបើគ្មានការទទួលការសងប្រាក់ធានារ៉ាប់រង ជាអាទិ៍ ។

ត្រង់ចំណុចនេះ មានបញ្ហាមួយទាក់ទងទៅនឹងការចាត់ចែងជាបណ្ដោះអាសន្នដែលសម្រេចសិទ្ធិតែម្ដង ។ ការចាត់ចែងបែបនេះ សំដៅទៅលើការចាត់ចែងជាបណ្ដោះអាសន្នដែលសម្រេចតាមខ្លឹមសារនៃសិទ្ធិទាមទារ លើអង្គសេចក្ដីតែម្ដង ។ ចំណុចដែលថាការចាត់ចែងជាបណ្ដោះអាសន្នដែលសម្រេចសិទ្ធិតែម្ដង អាចមាន លទ្ធផលដូចជាការទទួលស្គាល់ការអនុវត្តជាបណ្ដោះអាសន្ននោះ អាចធ្វើឱ្យគេគិតថាការសម្រេចនោះលើសពី គោលបំណងនៃការចាត់ចែងបណ្ដោះអាសន្ន ។ ក៏ប៉ុន្តែ ជាទូទៅ ការចាត់ចែងបែបនេះ ត្រូវបានចាត់ទុកថា ស្របច្បាប់ ព្រោះថា ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន មានគោលបំណងដើម្បី កំណត់ឋានៈជាបណ្ដោះអាសន្ន ដោយផ្អែកលើការសន្មតថា សិទ្ធិទាមទារទាំងមូល ឬ មួយផ្នែក មានអត្ថិភាព ក្នុងគោលបំណងដកចេញនូវគ្រោះថ្នាក់ជាពិសេស និង ក្ដីបារម្ភដែលកើតមានចំពោះម្ចាស់បំណុល ពីការមិន សម្រេចសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិនោះ ហើយបង្គាប់ឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច នៃសិទ្ធិទាមទារនោះ ។ មានន័យថា គោលបំណងរបស់វា មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយ បង្ខំនាពេលអនាគតនោះទេ ។ ឧទាហរណ៍ ករណីដែលនិយោជិតដែលធ្វើការអះអាងអំពីមោឃភាពនៃការ បណ្ដេញចេញដោយនិយោជក សុំឱ្យធ្វើការចាត់ចែងជាបណ្ដោះអាសន្ន ដោយបង្គាប់ឱ្យនិយោជកនោះ ផ្ដល់ប្រាក់ ខែឱ្យខ្លួនចំនួនពាក់កណ្ដាល រហូតដល់ពេលដែលបណ្ដឹងអង្គសេចក្ដីត្រូវបានសម្រេច ព្រោះថានិយោជិតនោះ នឹងជួបការលំបាកយ៉ាងខ្លាំងក្នុងការរស់នៅ ប្រសិនបើមិនបានបើកប្រាក់ខែ ក្នុងខណៈដែលវិវាទនោះកំពុងត្រូវ បានដោះស្រាយទេនោះ ។

(២) ភាពចាំបាច់នៃការរក្សាការពារ : ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជា បណ្ដោះអាសន្ន ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ

គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (មាត្រា ៥៤៨ កថាខណ្ឌទី ២) ។ ឧទាហរណ៍ ករណីដែលការខូចខាតដែលមិនអាចជួសជុលបាន កំពុងកើតឡើងចំពោះម្ចាស់បំណុល ដោយសារការចុះផ្សាយជាសាធារណៈនូវអត្ថបទទស្សនាវដ្តីដែលមានលក្ខណៈជាការបរិហាកេរ្តិ៍, ករណីដែលមានការបារម្ភអំពីគ្រោះថ្នាក់ដល់សុខភាពរបស់ម្ចាស់បំណុល ដែលបង្កឡើងដោយសម្លេងនៃការសាងសង់ ជាអាទិ៍ ។

## ៤. វិធីនៃការចាត់ចែងជាបណ្តោះអាសន្ន

(១) ខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន មិនអាចបំពេញគោលបំណងរបស់វា ដោយវិធីតែមួយនៃការរឹបអូសយកទ្រព្យសម្បត្តិនោះឡើយ ។ ហេតុនេះហើយ វិធី និង កម្រិតនៃការចាត់ចែងជាបណ្តោះអាសន្ន អាចនឹងមិនអាស្រ័យទៅតាមដំណាក់កាលនៃការអនុវត្តទេ តែត្រូវកំណត់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នទៅវិញ ។ ជាពិសេស ការចាត់ចែងជាបណ្តោះអាសន្នមួយចំនួនដែលកំណត់ឋានៈជាបណ្តោះអាសន្ន គ្រាន់តែបង្កើតនូវឋានៈគតិយុត្តនៅក្នុងការសម្រេចសេចក្តីប៉ុណ្ណោះ គឺមិនបង្កើតបញ្ហានៃការអនុវត្តទេ (ដែលនេះហៅថា ការចាត់ចែងជាបណ្តោះអាសន្ន ដែលរំពឹងថាកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត) ។

(២) តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្តល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន (មាត្រា ៥៤៩) ។ តុលាការ មានឆន្ទានុសិទ្ធិនៅក្នុងការជ្រើសរើសវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន ។ ក៏ប៉ុន្តែ ការសម្រេចរបស់តុលាការ ត្រូវស្របទៅតាមវិធានដូចខាងក្រោមនេះ :

(ក) កម្រិត និង វិធីសាស្ត្រនៃការចាត់ចែងជាបណ្តោះអាសន្ន ត្រូវស្ថិតនៅក្នុងទំហំនៃពាក្យសុំរបស់ម្ចាស់បំណុល ។ ទោះបីជាម្ចាស់បំណុលមិនចាំបាច់ត្រូវកំណត់ឱ្យច្បាស់លាស់នៅក្នុងពាក្យសុំ អំពីខ្លឹមសារជាក់លាក់នៃការចាត់ចែងជាបណ្តោះអាសន្នក៏ដោយ ក៏យ៉ាងហោចណាស់ ម្ចាស់បំណុលត្រូវបញ្ជាក់អំពីគោលបំណងដែលខ្លួនត្រូវការឱ្យសម្រេច ដោយការចាត់ចែងជាបណ្តោះអាសន្នដែរ ។

(ខ) វិធីសាស្ត្រដែលជ្រើសរើសដោយតុលាការ ចាំបាច់ត្រូវតែជាអ្វីដែលអាចទាមទារចំពោះកូនបំណុល ឬ អាចអនុវត្តបានចំពោះកូនបំណុល ដោយការទាមទារនៅក្នុងបណ្តឹងអង្គសេចក្តី ។ ប្រសិនបើការទាមទារសំណងគឺជាវិធីតែមួយគត់ដែលអាចធ្វើបាននៅក្នុងការទាមទារផ្នែកអង្គសេចក្តី សិទ្ធិទាមទារនោះ គួរតែត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ហើយដោយហេតុនេះ គេមិនអាចដាក់ពាក្យសុំឱ្យចាត់ចែងជាបណ្តោះអាសន្នបានទេ ។ ម្យ៉ាងទៀត តុលាការ អាចបង្គាប់ឱ្យកម្រិតក្នុងការធ្វើសកម្មភាព ឬ បង្គាប់

ឱ្យផ្តល់តាវកាលិក ចំពោះតែកូនបំណុល ឬ តតិយជនផ្សេងទៀត ដែលត្រូវទទួលអានុភាពអនុវត្តនៃលិខិតអនុវត្តដែលទាក់ទងនឹងសិទ្ធិទាមទារផ្នែកអង្គសេចក្តីប៉ុណ្ណោះ ពោលគឺ មិនអាចធ្វើការចាត់ចែងណាដែលជះឥទ្ធិពលដោយផ្ទាល់ ទៅដល់សិទ្ធិ និង ឋានៈគតិយុត្ត របស់តតិយជនផ្សេងទៀតបានឡើយ ។ ក៏ប៉ុន្តែក្នុងករណីដែលតតិយជន ត្រូវបានតម្រូវឱ្យទទួលស្គាល់ឋានៈរបស់កូនបំណុលដែលត្រូវចងដោយការចាត់ចែងជាបណ្តោះអាសន្ន តតិយជននោះ អាចនឹងទទួលរងនូវឥទ្ធិពលពីការចាត់ចែងនោះ ។ ករណីបែបនេះ កើតមានច្រើន នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន (ឧទាហរណ៍ បើមានការចាត់ចែងចំពោះសហគ្រាសណាមួយ ដែលកំណត់អ្នកប្រតិបត្តិកិច្ចការជំនួសនាយក នោះតតិយជនក៏ត្រូវទទួលស្គាល់សិទ្ធិអំណាចរបស់អ្នកប្រតិបត្តិកិច្ចការជំនួសនេះ ជាអាទិ៍) ។

(គ) វិធីសាស្ត្រនៃការចាត់ចែងជាបណ្តោះអាសន្នដែលជ្រើសរើសដោយតុលាការ ត្រូវស្ថិតនៅក្នុងទំហំដែលចាំបាច់ដើម្បីសម្រេចនូវគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។ ជាពិសេស នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការចាត់ចែងមួយចំនួនដូចជាការផ្តល់ទៅឱ្យម្ចាស់បំណុល នូវការសម្រេចសិទ្ធិ ដូចគ្នានឹងការសម្រេចសិទ្ធិនៅក្នុងការអនុវត្តដោយបង្ខំដែរនោះគឺជាការធ្វើហួសពីគោលបំណងនៃការចាត់ចែងរក្សាការពារហើយ ។

(៣) វិធីសាស្ត្រជាក់លាក់នៃការចាត់ចែងជាបណ្តោះអាសន្ន រួមមាន ①ការចាត់ចែងឱ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាកំណត់, ② ការចាត់ចែងឱ្យកូនបំណុលផ្តល់តាវកាលិក, ③ ការចាត់ចែងឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន, និង ④ ការចាត់ចែងចាំបាច់ផ្សេងទៀត ។

① "ការចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់" គឺជាការបង្គាប់ឱ្យកូនបំណុលធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ។ ឧទាហរណ៍ ការបង្គាប់ឱ្យរុះរើសំណង់, ការហាមឃាត់មិនឱ្យសាងសង់, ការហាមឃាត់មិនឱ្យធ្វើចរាចរណ៍, ការហាមឃាត់មិនឱ្យបោះពុម្ពផ្សាយជាសាធារណៈ ជាអាទិ៍ ។

② "ការចាត់ចែងឱ្យកូនបំណុលផ្តល់តាវកាលិក" សំដៅទៅលើការបង្គាប់ឱ្យធ្វើសកម្មភាពដែលអាចអនុវត្តដោយផ្ទាល់បាន ដូចជាការប្រគល់វត្ថុ ការបណ្តេញចេញពីអចលនវត្ថុ និង ការសងប្រាក់ ជាដើម ។

③ "ការចាត់ចែងឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះ-អាសន្ន" មានន័យថាជាការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ពីកូនបំណុល ទៅឱ្យអ្នកថែរក្សាគ្រប់គ្រង ។ វិធីនេះ ត្រូវបានប្រើជាញឹកញាប់ ដើម្បីថែរក្សានូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ។ ជាទូទៅ អាជ្ញាសាលា ត្រូវបានចាត់ឱ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រង ។ ក៏ប៉ុន្តែ ម្ចាស់បំណុល ឬ តតិយជនក៏អាចធ្វើជាអ្នកថែរក្សាគ្រប់គ្រងបានដែរ ។ ក្នុងករណីដែលបានចាត់អាជ្ញាសាលា ឱ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រងតុលាការក៏អាចធ្វើការចាត់ចែងជាបណ្តោះអាសន្នដែលអនុញ្ញាតឱ្យកូនបំណុលអាចប្រើប្រាស់វត្ថុដែលជាកម្មវត្ថុ

នោះបានដែរ ។

④ "ការចាត់ចែងចាំបាច់ផ្សេងទៀត" មានដូចជា ការហាមឃាត់មិនឱ្យកូនបំណុលទី ៣ សង នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការប្រមូលបំណុល, ការបង្គាប់ឱ្យប្រកាសជាសាធារណៈអំពីការណ៍ដែលអាជ្ញាសាលាកំពុងថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយអាជ្ញាសាលា នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបង្គាប់ឱ្យអាជ្ញាសាលាធ្វើជាអ្នកថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាដើម ។

## កថាភាគទី ២ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

### ១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន

បញ្ញត្តិដែលទាក់ទងទៅនឹងតុលាការមានសមត្ថកិច្ច ការដាក់ពាក្យសុំ វិធីនៃការវិនិច្ឆ័យ និង ការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូចគ្នាទៅនឹងបញ្ញត្តិស្ដីពីការរឹបអូសជាបណ្ដោះអាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស (សូមមើលផ្នែកទី ២ កថាភាគទី ២) ។

### ២. តុលាការមានសមត្ថកិច្ច

ក្នុងការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្រៅពីតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ ក៏ជាតុលាការមានសមត្ថកិច្ចដែរ (មាត្រា ៥៤០ កថាខណ្ឌទី ១, ចំពោះទីកន្លែងនៃសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សូមមើលកថាខណ្ឌទី ៣ និង ទី ៤ នៃមាត្រាដដែល) ។ ផ្ទុយទៅវិញ មានតែតុលាការនៃបណ្ដឹងអង្គសេចក្ដីទេ ដែលមានសមត្ថកិច្ចផ្ដាច់មុខ លើការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ។

### ៣. វិធីនៃការវិនិច្ឆ័យ

តុលាការ មិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន (មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ ទោះបីជាមូលដ្ឋាន ការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវធ្វើជាសម្ងាត់ដូចករណីនៃការរឹបអូសជាបណ្ដោះអាសន្នក៏ដោយ នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ផលប្រយោជន៍របស់ម្ចាស់បំណុល នៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យជាសម្ងាត់ក៏ដោយ ហើយម៉្យាងទៀត បើនីតិវិធីនេះធ្វើឡើងដោយសម្ងាត់ នោះនឹងនាំឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល ។ ហេតុនេះហើយបានជាច្បាប់ផ្ដល់ឱកាសឱ្យដល់កូនបំណុល ក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះ (ចំណុចនេះប្រហាក់ប្រហែលទៅនឹង référé

(ដីកាកិច្ចការប្រញាប់) នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបារាំងដែរ) ។ ក៏ប៉ុន្តែ ប្រសិនបើមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍ នោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចចេញបាន ដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ (មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២) ។ ឧទាហរណ៍ ក្នុងករណីដែលទស្សនាវដ្តីដែលមានផ្ទុកនូវអត្ថបទបរិហារកេរ្តិ៍ នឹងត្រូវចេញផ្សាយជាសាធារណៈនៅថ្ងៃបន្ទាប់ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចេញផ្សាយជាសាធារណៈនោះ នឹងមិនអាចធ្វើទៅរួចឡើយ ប្រសិនបើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់សិន ។

### ៤. ដីកាសម្រេច

ខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ន ពុំមានការចាត់ចែងជាបណ្តោះអាសន្នណាមួយដែលកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវធ្វើដើម្បីលុបចោលការអនុវត្តការចាត់ចែង (ប្រាក់រំដោះ) នោះឡើយ ព្រោះថា គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្ន មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំឱ្យសងជាប្រាក់ទេ ។

## កថាភាគទី ៣ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

### ១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្តោះអាសន្ន

របៀបធ្វើឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមបញ្ញត្តិដូចគ្នានឹងរបៀបធ្វើឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលរួមមាន ពាក្យសុំតវ៉ា ពាក្យសុំទាមទារឱ្យលុបចោល និង បណ្តឹងជំទាស់ដែរ លើកលែងតែមានបញ្ញត្តិពិសេស (សូមមើលផ្នែកទី ២ កថាភាគទី ៣) ។

### ២. អានុភាពនៃការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

នៅក្នុងករណីដែលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលបានចេញម្តងហើយ ត្រូវលុបចោលវិញ ដោយសារពាក្យសុំតវ៉ា ពាក្យសុំទាមទារឱ្យលុបចោល ឬ បណ្តឹងជំទាស់ ប្រសិនបើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ កំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន នោះតុលាការអាចបង្គាប់ឱ្យម្ចាស់បំណុល បង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រង នៅក្នុងដីកាសម្រេចលុបចោលនោះបាន តាមពាក្យសុំរបស់កូនបំណុល (មាត្រា ៥៥៩, មាត្រា ៥៦០ កថាខណ្ឌទី ១, មាត្រា ៥៦១ កថាខណ្ឌទី ៣) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ប្រសិនបើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលផ្លាស់ប្តូរនូវស្ថានភាពដើម ត្រូវបានអនុវត្តហើយ ស្ថានភាពដើមនោះ មិនអាចធ្វើបដិទានបានវិញឡើយ ដោយគ្រាន់តែលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះ

ទេ ។ ហេតុនេះហើយ តុលាការត្រូវតែ អាចបង្គាប់ឱ្យធ្វើបដិទាននូវស្ថានភាពដើម នៅក្នុងដីកាសម្រេចលុបចោល ។ បណ្តឹងជំទាស់ អាចធ្វើឡើងដោយឯករាជ្យបាន ចំពោះដីកាសម្រេចទាំងនេះ (មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ខ និង ចំណុច គ) ។

### ៣. ការលុបចោលការចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស

(១) ស្របទៅនឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែរ ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន រួមមាន ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍ ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារការផ្លាស់ប្តូរស្ថានភាព និង មានបន្ថែមការលុបចោលមួយប្រភេទទៀត គឺការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស ។ មានន័យថា តុលាការ អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តាមពាក្យសុំរបស់កូនបំណុលបាន ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត (មាត្រា ៥៥៩ កថាខណ្ឌទី ១) ។ តុលាការដែលមានសមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ តុលាការនៃបណ្តឹងអង្គសេចក្តី ។

(២) ករណីដែលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចនឹងត្រូវបានលុបចោលដោយសារស្ថានភាពពិសេស ត្រូវបានបែងចែកជាពីរ ។ ករណីទីមួយ គឺករណីដែលគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នអាចសម្រេចបាន ដោយការសងជាប្រាក់ទៅឱ្យម្ចាស់បំណុល ។ ទោះបីជាទូទៅ ការសងជាប្រាក់សុទ្ធសាធមិនអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នបាន ព្រោះថាសិទ្ធិដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្ននោះ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ក៏ដោយ ក៏ប៉ុន្តែ ក្នុងករណីដែលការចាត់ចែងជាបណ្តោះអាសន្ននោះ មានមូលដ្ឋានជាសិទ្ធិទាមទារឱ្យសងជាប្រាក់ ឬ ករណីដែលមានសិទ្ធិទាមទារឱ្យសងជាប្រាក់ស្ថិតនៅពីក្រោយការចាត់ចែងជាបណ្តោះអាសន្ននោះ ហើយប្រសិនបើការសងជាប្រាក់ នឹងធ្វើឱ្យសម្រេចយ៉ាងជាក់ស្តែងនូវសិទ្ធិដែលត្រូវបានរក្សាការពារ នោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចធ្វើបាន ដោយតម្រូវឱ្យដាក់ប្រាតិភោគ ។ ឧទាហរណ៍ដូចជាករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិរបស់អ្នកដែលបានទទួលផលប្រយោជន៍ ដើម្បីរក្សាការពារនូវសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ដែលបានប្រព្រឹត្តឡើងដោយកូនបំណុល (បញ្ញត្តិចាប់ពីមាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី) ជាដើម ។ ករណីទីពីរ គឺករណីដែល បើគិតពីសមធម៌រវាងភាគីទាំងពីរ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន បង្កឱ្យមានការខូចខាតដែលធ្ងន់ធ្ងរជាងការខូចខាតដែលកើតឡើងជាធម្មតាចំពោះកូនបំណុល ។ ដោយគិតពិចារណាអំពីផលប្រយោជន៍របស់ម្ចាស់បំណុល និង កូនបំណុល ប្រសិនបើការខូចខាតចំពោះកូនបំណុលដែល

បណ្ដាលមកពីការចាត់ចែងជាបណ្ដោះអាសន្ន មានទំហំធំធេងខ្លាំងជាងការខូចខាតចំពោះម្ចាស់បំណុលដែលបណ្ដាលមកពីការមិនអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះ ផ្ទុយនឹងគោលការណ៍សមធម៌ហើយ ។ ឧទាហរណ៍ ករណីដែលការចាត់ចែងជាបណ្ដោះអាសន្ន ដោយការដែលអាជ្ញាសាលាទៅថែរក្សាគ្រប់គ្រងចលនវត្ថុដែលកូនបំណុលកំពុងលក់ដូរ ធ្វើឱ្យកូនបំណុលនោះមិនអាចធ្វើអាជីវកម្ម ឬមានការពិបាកយ៉ាងខ្លាំងក្នុងការបន្តអាជីវកម្មតទៅមុខទៀត ជាអាទិ៍ ។ ចំពោះស្ថានភាពពិសេសទាំងនេះ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង (មាត្រា ៥៥៩ កថាខណ្ឌទី ២) ។

(៣) បញ្ញត្តិទាក់ទងទៅនឹងការសម្រេចសេចក្ដីអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីពាក្យសុំឱ្យលុបចោលដោយសារស្ថានភាពពិសេសនេះ (មាត្រា ៥៦០ កថាខណ្ឌទី ១) ។ មានន័យថា បញ្ញត្តិស្ដីពីការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ជាអាទិ៍ (មាត្រា ៥៥១), ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងពីរអាចចូលរួមបាន (មាត្រា ៥៥២), ការបញ្ចប់ការវិនិច្ឆ័យ (មាត្រា ៥៥៣), អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៥៦) ត្រូវយកមកអនុវត្តដូចគ្នា ចំពោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេសនេះ ។ ជាងនេះទៅទៀត ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន (មាត្រា ៥៥៥) ក៏អាចចេញបានដែរ នៅក្នុងករណីនេះ ។ ដីកាសម្រេចលុបចោលនេះ ត្រូវចេញដោយដាក់ល័ក្ខខ័ណ្ឌតម្រូវឱ្យកូនបំណុលដាក់ប្រាតិភោគ (មាត្រា ៥៥៩ កថាខណ្ឌទី ១) ។ ដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោល ត្រូវបញ្ជូនទៅឱ្យភាគី (មាត្រា ៥៥៩ កថាខណ្ឌទី ៣) ហើយចំពោះដីកាសម្រេចនេះ អាចប្ដឹងជំទាស់បាន (មាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក) ។

## កថាភាគទី ៤ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

### ១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុលោមតាមបញ្ញត្តិដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស (សូមមើលផ្នែកទី ២ កថាភាគទី ៤) ។ ទោះជាយ៉ាងណាក៏ដោយ ដូចបានពន្យល់ពីខាងដើម ការចាត់ចែងជាបណ្ដោះអាសន្នមួយចំនួន ដែលគោលបំណងរបស់វាអាចសម្រេចបានដោយគ្រាន់តែបង្កើតឋានៈគតិយុត្តដោយដីកាសម្រេច ហើយរង់ចាំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ដោយស្ម័គ្រចិត្ត នោះមិនត្រូវការឱ្យមានការអនុវត្តទេ ។ ដោយឡែក ការចាត់ចែងជាបណ្ដោះអាសន្នមួយចំនួនទៀត ដូចជា ការចាត់ចែងជាបណ្ដោះអាសន្នដែលគ្រាន់តែបង្គាប់កូនបំណុលមិនឱ្យធ្វើសកម្មភាពអ្វីមួយ ជាដើម ក៏មិនត្រូវការឱ្យមានការអនុវត្តដែរ លើកលែងតែករណីដែលកូនបំណុលបំពានករណីយកិច្ចដែលបានបង្គាប់នោះ ។

### ២. វិធីនៃការអនុវត្ត

(១) ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្តោះ-អាសន្ន ឬ វិធីអនុវត្តដោយបង្ខំដែរ (មាត្រា ៥៧០) ។ ដោយសារថាវិធីចាត់ចែងជាបណ្តោះអាសន្ន មានច្រើន (សូមមើលមាត្រា ៥៤៩) ដូច្នេះទើបពុំមានបញ្ញត្តិចែងឱ្យបានជាក់លាក់អំពីវិធីនៃការអនុវត្តទេ ។ វិធីនៃការអនុវត្តនីមួយៗ ត្រូវអនុលោមទៅតាមវិធីដែលមានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចចាត់ចែង ជាបណ្តោះអាសន្ន ។

(២) ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យសងជាប្រាក់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (គន្ថីទី ៦ ជំពូកទី ២ ចាប់ពីមាត្រា ៣៧៩ តទៅ) ។ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យប្រគល់ ឬ បណ្តេញចេញពីអចលនវត្ថុ និង ចលនវត្ថុ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និង ចលនវត្ថុ (មាត្រា ៥២៤ ដល់មាត្រា ៥២៦) ។ ចំណែកឯការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យកូនបំណុលធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តជំនួស (មាត្រា ៥២៧) និង វិធានបង្ខំដោយប្រយោល (មាត្រា ៥២៨) ។

(៣) ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ។

(៤) បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់នោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ ប្រកាសជាសាធារណៈ តាមរបៀបសមរម្យផ្សេងទៀត (មាត្រា ៥៧១ កថាខណ្ឌទី ១) ។ មានន័យថា បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្នុងនៃអាគារដែលជាកម្មវត្ថុ ប្រកាសនោះ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំងនៃអាគារនោះ ឬ នៅកន្លែងណាផ្សេងដែលងាយនឹងមើលឃើញ ។ បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្រៅនៃអាគារ ឬ ប្រកាសជាសាធារណៈលើដីវិញ ក្តារប្រកាសដែលរៀបរាប់អំពីខ្លឹមសារនៃការប្រកាសជាសាធារណៈនោះ ត្រូវដំភ្ជាប់នឹងសសរឈើដោយប្រើដែកគោល ឬ ត្រូវដាក់ភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារដោយដំដែកគោល ឬ វិធីផ្សេងៗទៀតភ្ជាប់នឹងជញ្ជាំង ខាងក្រៅនៃអាគារ ។

### ៣. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

(១) ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ៖ បើការចាត់ចែងជាបណ្តោះអាសន្នមានខ្លឹមសារជាការហាមឃាត់ការចាត់ចែងរបស់កូនបំណុល លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ នោះស្រដៀងគ្នាទៅ

នឹងករណីនៃការរឹបអូសជាបណ្តោះអាសន្នដែរ ការចាត់ចែងរបស់កូនបំណុលដែលធ្វើផ្ទុយនឹងការហាមឃាត់នេះ មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ។ មានន័យថា តតិយជន ដែលបានទទួលសិទ្ធិពីការចាត់ចែងនេះ មិនអាចយកលទ្ធកម្មនេះ ទៅតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ ហើយលទ្ធកម្មនេះ នឹងត្រូវបានចាត់ទុកថាពុំមានអត្ថិភាព នៅក្នុងការអនុវត្តដោយបង្ខំនៅពេលបន្ទាប់ ។

(២) ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ : ក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្តោះអាសន្នណាដែលមានការប្រកាសជាសាធារណៈដូចបានរៀបរាប់ខាងលើ (សូមមើល **២.** (៤)) បើមានការផ្ទេរការកាន់កាប់ ដោយផ្ទុយនឹងការហាមឃាត់នេះ ការផ្ទេរនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ។ ហេតុនេះហើយ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី (មាត្រា ៥៧១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ នៅក្នុងបណ្តឹងទាមទារឱ្យប្រគល់វត្ថុ ប្រសិនបើបណ្តឹងនោះធ្វើឡើងដោយយកអ្នកកាន់កាប់នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ ធ្វើជាចុងចម្លើយ អានុភាពនៃសាលក្រម នឹងមានទៅលើបុគ្គលដែលទទួលបន្តនូវការកាន់កាប់ នៅក្រោយពេលដែលបណ្តឹងត្រូវបានចាត់ការ បើទោះបីជាមានការផ្ទេរការកាន់កាប់ក៏ដោយ (មាត្រា ១៩៨ ចំណុច គ និង មាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច គ) ។ ក៏ប៉ុន្តែ អានុភាពនៃសាលក្រម មិនត្រូវមានទៅលើអ្នកកាន់កាប់ដែលមិនបានទទួលបន្តនូវសិទ្ធិកាន់កាប់ពីអ្នកកាន់កាប់ នៅពេលដែលបណ្តឹងកំពុងត្រូវបានចាត់ការទេ (ឧទាហរណ៍ដូចជាអ្នកកាន់កាប់ខុសច្បាប់) ។ ម្យ៉ាងទៀត នៅក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ នោះក៏អាចនឹងកើតមាននូវករណីនៃលទ្ធកម្មដោយសុចរិតបានដែរ ។ ហេតុនេះហើយ ច្បាប់អនុញ្ញាតឱ្យបុគ្គលដែលមានបំណងចង់ដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់វត្ថុ ឬ បុគ្គលដែលបានដាក់ពាក្យបណ្តឹងនោះហើយ អាចកំណត់ទំនាក់ទំនងនៃការកាន់កាប់បច្ចុប្បន្ន។

ទោះបីជាយ៉ាងណាក៏ដោយ ការពង្រីកអានុភាពនៃសាលក្រមតាមវិធីនេះ ត្រូវបានកម្រិតត្រឹមតែករណីដែលអ្នកកាន់កាប់ មានទុច្ចរិតអំពីអត្ថិភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលពាក់ព័ន្ធ ពោលគឺករណីដែលអ្នកកាន់កាប់វត្ថុនោះ ដឹងថាមានការចាត់ចែងជាបណ្តោះអាសន្នប៉ុណ្ណោះ (មាត្រា ៥៧១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ទោះជាក្នុងករណីនៃលទ្ធកម្មនៃការកាន់កាប់មិនមែនជាការទទួលបន្តក៏ដោយ ក៏អ្នកកាន់កាប់ដោយទុច្ចរិត មិនត្រូវទទួលបានការការពារដែរ ។ គួរបញ្ជាក់ថា ជនដែលកាន់កាប់ ដែលចាប់ផ្តើមការកាន់កាប់ ក្រោយពេលដែលការចាត់ចែងជាបណ្តោះអាសន្នត្រូវបានប្រកាសជាសាធារណៈ ត្រូវសន្មតថាជាអ្នកកាន់កាប់ដោយទុច្ចរិត (មាត្រា ៥៧១ កថាខណ្ឌទី ៣. ហេតុនេះហើយ ដើម្បីតទល់នឹងការសន្មតនេះ អ្នកកាន់កាប់ត្រូវបញ្ជាក់អំពីភាពសុចរិតនៃការកាន់កាប់របស់ខ្លួន) ។ ក្នុងករណីដែលអ្នកកាន់កាប់ កាន់កាប់វត្ថុដែលពាក់ព័ន្ធ ដោយមានសិទ្ធិដែលនាំឱ្យមានមូលហេតុតតិយុត្តនៃ

ការកាន់កាប់ ដែលអាចតតាំងជាមួយនឹងម្ចាស់បំណុលបាន (ដូចជា ករណីដែលជននេះមានសិទ្ធិជួលដែលអាចតតាំងជាមួយនឹងម្ចាស់បំណុលបាន) ឬ ក្នុងករណីដែលអ្នកកាន់កាប់ មិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ហើយមិនមែនជាអ្នកទទួលបន្តនូវការកាន់កាប់ពីកូនបំណុល (ដូចជាករណីដែលជននោះកាន់កាប់វត្ថុដែលពាក់ព័ន្ធដោយមិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ព្រោះសេចក្ដីប្រកាសជាសាធារណៈបានរបកបាត់ ជាដើម) អ្នកកាន់កាប់នេះ អាចអះអាង អំពីស្ថានភាពនេះ ដោយដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត (មាត្រា ៣៦២) បាន (សូមមើលមាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

(៣) ការចាត់ចែងជាបណ្ដោះអាសន្នដោយឡែកណា ដែលរារាំងអានុភាពនៃការចាត់ចែងជាបណ្ដោះ-អាសន្ន ឬ ដែលផ្អាកការចាត់ចែងជាបណ្ដោះអាសន្ន មិនត្រូវបានអនុញ្ញាតទេ ។ ដើម្បីដកចេញនូវការចាត់ចែងជាបណ្ដោះអាសន្ន កូនបំណុលត្រូវដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ចំណែកឯតតិយជន ត្រូវដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន ឬ ដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត ជាអាទិ៍ ។ ទោះជាយ៉ាងណាក៏ដោយ ករណីដែលមានការចាត់ចែងជាបណ្ដោះអាសន្នច្រើនលើកម្ដងលើវត្ថុតែមួយ មិនត្រូវបានហាមឃាត់ទេ ប្រសិនបើខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នទាំងនោះ មិនមានខ្លឹមសារផ្ទុយគ្នា (ឧទាហរណ៍ ករណីដែលការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង និង ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានអនុវត្តចំពោះអចលនវត្ថុតែមួយ) ។

# ជំពូកទី ៥ អន្តរប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ

## ១. និយមន័យនៃអន្តរប្បញ្ញត្តិ

នៅពេលអនុម័តច្បាប់ថ្មី ឬ នៅពេលធ្វើវិសោធនកម្ម ឬ លុបចោលនូវច្បាប់ចាស់ ជួនកាលមានភាពចាំបាច់ដែលត្រូវបន្ថែមនូវការសម្របសម្រួលចាំបាច់រវាងសណ្តាប់ធ្នាប់នៃច្បាប់ចាស់ និង សណ្តាប់ធ្នាប់នៃច្បាប់ថ្មី ដើម្បីធានាឱ្យបាននូវភាពរលូនក្នុងការប្តូរពីសណ្តាប់ធ្នាប់នៃច្បាប់ចាស់ ទៅសណ្តាប់ធ្នាប់នៃច្បាប់ថ្មីនោះ ដូចជាការទុកឱ្យច្បាប់ចាស់បន្តអានុភាពអនុវត្តជាបណ្តោះអាសន្នសិន ឬ ការចាត់វិធានការឱ្យមានការលើកលែងជាបណ្តោះអាសន្ន ពីការអនុវត្តបញ្ញត្តិនៃច្បាប់ថ្មី ជាដើម ។ វិធានការនៃការសម្របសម្រួលរវាងសណ្តាប់ធ្នាប់នៃច្បាប់ចាស់ និង សណ្តាប់ធ្នាប់នៃច្បាប់ថ្មីនេះ ហៅថា "វិធានការអន្តរកាល" ហើយបញ្ញត្តិដែលកំណត់នូវវិធានការទាំងនេះ ហៅថា "អន្តរប្បញ្ញត្តិ" ។

នៅក្នុងច្បាប់នីតិវិធី ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ នីតិវិធីដែលជាកម្មវត្ថុនៃច្បាប់នេះ គឺជាទម្រង់នៃសកម្មភាពបណ្តឹងជាបន្តបន្ទាប់ ដែលធ្វើឡើងដោយតុលាការ ឬ ដោយភាគី ហើយវាមានការពាក់ព័ន្ធនឹងដំណើរការនៃពេលវេលាកំណត់មួយ រាប់ចាប់តាំងពីពេលចាប់ផ្តើម រហូតដល់ពេលបញ្ចប់ ។ ហេតុនេះហើយចាំបាច់ត្រូវមានការកំណត់ថាតើគួរយកច្បាប់ចាស់ ឬ ក៏ច្បាប់ថ្មី មកអនុវត្តចំពោះរឿងក្តីដែលកំពុងត្រូវបានចាត់ការរួចហើយ នៅពេលដែលច្បាប់វិសោធនកម្មថ្មីត្រូវបានអនុវត្តនោះ ។ ទស្សនទានជាមូលដ្ឋានដែលទាក់ទងទៅនឹងបញ្ហានេះ ចែកចេញជាពីរប្រភេទ គឺ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" និង "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" ។

ជាទូទៅ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" គឺជាទស្សនទានដែលយល់ថា នីតិវិធីថ្មី ត្រូវយកទៅអនុវត្តផងដែរ ចំពោះរឿងក្តីដែលត្រូវបានដាក់ នៅមុនពេលដែលច្បាប់វិសោធនកម្មបានចូលជាធរមាន ឬ ត្រូវបានអនុវត្ត (ឬ ចំពោះបញ្ហាដែលបានកើតឡើងនៅមុនពេលច្បាប់វិសោធនកម្មបានចូលជាធរមាន ឬ ត្រូវបានអនុវត្ត) ។ ដោយឡែក "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" គឺជាទស្សនទានដែលយល់ថា ច្បាប់ថ្មី ត្រូវយកទៅអនុវត្តតែចំពោះរឿងក្តីដែលត្រូវបានដាក់នៅក្រោយពេលដែលច្បាប់វិសោធនកម្មបានចូលជាធរមាន ឬ ត្រូវបានអនុវត្តប៉ុណ្ណោះ រីឯចំពោះរឿងក្តីដែលត្រូវបានដាក់នៅមុនពេលដែលច្បាប់វិសោធនកម្មបានចូលជាធរមាន ឬ ត្រូវបានអនុវត្ត (ឬ ចំពោះបញ្ហាដែលបានកើតឡើងនៅមុនពេលច្បាប់វិសោធនកម្មបានចូលជាធរមាន ឬ ត្រូវបានអនុវត្ត) ត្រូវយកច្បាប់ចាស់មកអនុវត្ត ។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជាមូលដ្ឋាន បានជ្រើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី ដែលមានពន្យល់ដូចខាងលើនេះ មកធ្វើជាគោលការណ៍នៃវិធានការអន្តរកាល ។ ហេតុនេះហើយជាគោលការណ៍ បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ត្រូវយកទៅអនុវត្តផងដែរ ចំពោះរឿងក្តីដែលកំពុងត្រូវបានចាត់ការរួចហើយ (មាត្រា ៥៧២) ។ ក៏ប៉ុន្តែ ចំពោះការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សា

ការពារ មានវិធានការអន្តរកាលពិសេសដែលមានចែងនៅក្នុងមាត្រា ៥៨៥ និង មាត្រា ៥៨៦ ។ ហេតុនេះហើយ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើង ដោយអនុលោមទៅតាមវិធានការអន្តរកាលដែលមានចែងក្នុងមាត្រាទាំងពីរនេះ ។

## ២. វិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ

មាត្រា ៥៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងអំពីវិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ បានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ មកធ្វើជាវិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ ។ ហេតុផលនៃការជ្រើសរើសនេះ មានដូចតទៅ :

ទោះបីជាច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី អនុវត្តចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ នៅក្នុងនីតិវិធីចាស់ក៏ដោយ នីតិវិធីនៃការអនុវត្តដោយបង្ខំនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានភាពខុសគ្នាយ៉ាងខ្លាំងពីនីតិវិធីចាស់ មានភាពជាការបន្តពីនីតិវិធីចាស់ តែបន្តិចបន្តួចប៉ុណ្ណោះ ។ ការជ្រើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី នៅក្នុងកាលៈទេសៈនេះ អាចនឹងធ្វើឱ្យឧបាស្រ័យដែលមិនអាចធ្វើបានពីមុន ក្លាយជាអាចធ្វើបាន ព្រមទាំងនឹងផ្លាស់ប្តូរនូវវិធីនៃការលក់ នៅពាក់កណ្តាលទីនៃនីតិវិធីនៃការលក់ទៀត ដែលការណ៍នេះ នឹងបង្កឱ្យមានបញ្ហាលំបាក និង ស្មុគស្មាញជាច្រើន ដូចជាបញ្ហាថាតើត្រូវភ្ជាប់ពីនីតិវិធីចាស់ ទៅនីតិវិធីថ្មីយ៉ាងដូម្តេច ចំពោះផ្នែកដែលត្រូវបានផ្លាស់ប្តូរ ជាអាទិ៍ ។ ហេតុនេះហើយ ដោយប្រកាន់យកគោលគំនិតនៃស្ថិរភាព និង ភាពងាយស្រួលនៃនីតិវិធី ទើបបានជាមាត្រា ៥៨៥ កថាខណ្ឌទី ១ បានជ្រើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ដោយចែងថា ចំពោះរឿងក្តីនៃការអនុវត្តដោយបង្ខំ ដែលបានដាក់ពាក្យសុំនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ពោលគឺមិនយកបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីទៅអនុវត្តទេ ។

ក៏ប៉ុន្តែ ចំពោះបញ្ញត្តិស្តីពីការដាក់គុកបង្ខំដល់រូបកាយ ដែលមានចែងនៅក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី វាមិនសមរម្យក្នុងការរក្សាទុកនូវបញ្ញត្តិនេះ ក្នុងខណៈដែលក្រមនីតិវិធីរដ្ឋប្បវេណីបានរៀបចំប្រព័ន្ធថ្មីនៃការអនុវត្តដោយបង្ខំនោះទេ ។ ហេតុនេះហើយ គ្មានបញ្ញត្តិណាមួយនៅក្នុងជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត នៅក្រោយពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្តឡើយ (មាត្រា ៥៨៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ជាងនេះទៅទៀត ដើម្បីធានាឱ្យបាននូវការអនុវត្តតាមការកំណត់ខាងលើនេះ សេចក្តីសម្រេចទាំងឡាយណាដែលបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ដែលបានចេញនៅមុនពេលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត (មាត្រា ៥៨៥ កថាខណ្ឌទី ២) ហើយប្រសិនបើកូនបំណុលទទួលការដាក់គុកបង្ខំដល់រូបកាយ នៅពេលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដែលបានបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ឬ ប្រធានតុលាការ ត្រូវបង្គាប់ឱ្យដោះលែងកូន

បំណុលនោះភ្លាម ( មាត្រា ៩៨៥ កថាខណ្ឌទី ៣) ។

### ៣. វិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ

មាត្រា ៩៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងអំពីវិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ បានជ្រើសយកជាវិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ នូវគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី សម្រាប់នីតិវិធីនៅមុនពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ (កថាខណ្ឌទី ១) និង គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ចំពោះនីតិវិធីនៅក្រោយការសម្រេចសេចក្តីលើរឿងក្តីចាត់ចែងរក្សាការពារ (កថាខណ្ឌទី ២) ។ ហេតុផលនៃការជ្រើសរើសនេះ មានដូចតទៅ :

ការចាត់ចែងរក្សាការពារតាមនីតិវិធីចាស់ មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេ តែត្រូវបានបង្កើតតាមការអនុវត្តជាក់ស្តែង ចេញពីកថាខណ្ឌស្តីពី "វិធានការបណ្តោះអាសន្ន" នៃសារាចរលេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ របស់ក្រសួងយុត្តិធម៌ ។ ក៏ប៉ុន្តែ ខ្លឹមសារ និង នីតិវិធីនៃវិធានការបណ្តោះអាសន្នដែលមានចែងនៅក្នុងកថាខណ្ឌនោះ មិនមានភាពច្បាស់លាស់ទេ ។ ដោយសារថា នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៧ បានចែងនូវបទប្បញ្ញត្តិលំអិតស្តីពីការចាត់ចែងរក្សាការពារ ដូច្នេះហើយ ដោយឈរលើគោលគំនិតនៃភាពច្បាស់លាស់នៃនីតិវិធី និង ខ្លឹមសារនៃការចាត់ចែងរក្សាការពារ វាជាការសមរម្យដែលត្រូវយកបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ទៅអនុវត្ត ឱ្យបានទូលំទូលាយតាមដែលអាចធ្វើបាន ។ ក៏ប៉ុន្តែ នីតិវិធីចាត់ចែងរក្សាការពារ គឺជានីតិវិធីដ៏ស្មុគស្មាញ ដែលរួមបញ្ចូលទាំងនីតិវិធីនៃការសម្រេចសេចក្តីផង និង នីតិវិធីនៃការអនុវត្តផង ។ ហេតុនេះហើយ ប្រសិនបើបណ្តោយឱ្យយកបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ទៅអនុវត្តចំពោះរឿងក្តីនៃការចាត់ចែងរក្សាការពារទាំងអស់ ដែលបានដាក់ពាក្យនៅមុនពេលដែលក្រមរដ្ឋប្បវេណីត្រូវបានអនុវត្ត នោះនឹងកើតមានបញ្ហានានាដូចជាការប្រែប្រួលនៃវិធីឧបាស្រ័យ និង អស្ថិរភាពនៃនីតិវិធីនៃការអនុវត្ត ជាដើម ។

អាស្រ័យហេតុនេះហើយ ដោយគិតពិចារណាយ៉ាងហ្មត់ចត់អំពីចំណុចនេះ ទើបបានជាមាត្រា ៩៨៦ បានបែងចែកនីតិវិធីចាត់ចែងរក្សាការពារ ជាពីរ គឺនីតិវិធីចាត់ចែងរក្សាការពារនៅមុនពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ និង នីតិវិធីចាត់ចែងរក្សាការពារនៅក្រោយពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ ព្រោះថា ឧបាស្រ័យ និង ការអនុវត្តចាត់ចែងរក្សាការពារ នឹងលេចចេញជាបញ្ហា នៅក្រោយពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ ប៉ុន្តែ នីតិវិធីនៅមុនពេលចេញសេចក្តីសម្រេចនោះ មានលក្ខណៈសាមញ្ញតែប៉ុណ្ណោះ ។ ករណីដែលត្រូវយកក្រមនីតិវិធីរដ្ឋប្បវេណីទៅអនុវត្ត នៅមុនពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ គឺជាការអនុម័តយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី ។ ហេតុនេះហើយ នីតិវិធីបន្តបន្ទាប់ ត្រូវបន្តអនុវត្តបញ្ចប់ ដោយក្រមនីតិវិធីរដ្ឋប្បវេណី ( មាត្រា ៩៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក្នុងករណីនេះ នីតិវិធីដែលបានធ្វើនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ពុំត្រូវបាត់បង់អានុភាពឡើយ (មាត្រា ៩៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ផ្ទុយទៅវិញ ក្នុងករណីដែលក្រមនេះ

ត្រូវបានអនុវត្ត នៅក្រោយពេលចេញសេចក្ដីសម្រេចលើរឿងក្ដីចាត់ចែងរក្សាការពារ នោះគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ត្រូវបានជ្រើសយក ពោលគឺនីតិវិធីបន្ទាប់ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ( មាត្រា ៥៨៦ កថាខណ្ឌទី ២) ។

## ៤. អវសានប្បញ្ញត្តិ

(១) ក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចែងបញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ ត្រូវផ្សព្វផ្សាយរយៈពេល ១ ឆ្នាំ ក្រោយពីចូលជាធរមាន ទើបអនុវត្ត (មាត្រា ៥៨៧) ។ ដោយសារថា ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦ ដូច្នេះ ក្រមនេះបានចាប់ផ្ដើមអនុវត្តនៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៧ នៅភ្នំពេញ និង នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៧ នៅទូទាំងប្រទេស ( សូមមើលមាត្រា ៩៣ កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា) ។

(២) ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍ : ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ( មាត្រា ៥៨៨ កថាខណ្ឌទី ១) :

① ច្បាប់ស្ដីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

②ច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

ជាងនេះទៅទៀត ក្នុងករណីដែលច្បាប់ណាផ្សេង មានបញ្ញត្តិផ្ទុយ ឬ ប្រឆាំងនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី នោះបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី នឹងត្រូវអនុវត្តដោយវាមានអាទិភាពលើច្បាប់ផ្សេង ។ មានន័យថា បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ( មាត្រា ៥៨៨ កថាខណ្ឌទី ២) ។